សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

# ច្បាប់ និងកម្មវិធីព្រៃឈើជាតិ

# FORESTRY LAW AND NATIONAL FOREST PROGRAM

ថាច សុភ័ក្រ

ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

# ច្បាប់ និងកម្មវិធីព្រៃឈើជាតិ

# FORESTRY LAW AND NATIONAL FOREST PROGRAM

ថាច សុភ័ក្រ

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១

## រក្សាសិទ្ធគ្រប់យ៉ាង

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន) នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

## ទំនាក់ទំនងព័ត៌មាន:

អ្នកនិពន្ធ៖ ថាវ សុភ័ក្រ

ទូរស័ព្ទ៖ (+៨៥៥) ១២ ៧៨២ ៧៥៩

អ៊ីមែល៖ sopheakthav@yahoo.com

©. Thav Sopheak. All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:

Author: Mr. Thav Sopheak

Mobile phone: +855 12 782 759

Email: sopheakthav@yahoo.com

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលបានផ្តល់អនុញ្ញាត និងលើកទឹកចិត្តនៅក្នុងការរៀបចំសរសេរសៀវភៅមួយក្បាលនេះដើម្បីចែករំលែកចំណេះដឹងខ្លះៗដល់អ្នកអានជាពិសេសប្អូនៗនិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តួចផ្តើមនៅក្នុងការលើកទឹកចិត្ត និងធ្វើឱ្យបញ្ញវន្តខ្មែរជាច្រើនអ្នកមានឱកាសបញ្ចេញស្នាដៃនៅក្នុងការបោះពុម្ពសៀវភៅជាខេមរភាសារសម្រាប់និស្សិតបញ្ញវន្ត ក៏ដូចជាភាគីពាក់ព័ន្ធនានាអាចយកទៅធ្វើការសិក្សាស្រាវជ្រាវប្រកបដោយភាពងាយស្រួល។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូ **ខខ សុជាតិ** ក៏ដូចជាក្រុមការងារនៅក្នុងផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយសម្របសម្រួលក្នុងការដំណើរការការសរសេរសៀវភៅមួយនេះបញ្ចប់ដោយជោគជ័យ។

ជាពិសេសជាងនេះទៅទៀត ខ្ញុំបាទសូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលបានផ្តល់មតិយោបល់សម្រាប់ធ្វើឱ្យប្រើឡើងក្នុងការសរសេរសៀវភៅមួយនេះ។ ខ្ញុំសូមគោរពជូនពរ និងប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ជូនចំពោះឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី និងលោកគ្រូ អ្នកគ្រូ ដែលបានចំណាយពេលវេលាក្នុងការជួយជ្រុំជ្រែងសរសេរសៀវភៅមួយនេះ។

ខ្ញុំបាទ សូមគោរពជូនពរ ជូនចំពោះ ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី និងលោកគ្រូ អ្នកគ្រូ ព្រមទាំងក្រុមគ្រួសារទទួល បាននូវសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ព្រមទាំងបុត្រាបុត្រី និងចៅប្រុសចៅស្រី ជួបប្រទះតែនឹងភាពចម្រុងចម្រើន សុខដុមរមនា សុភមង្គល វិបុលសុខ និងប្រកបដោយ ពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

កម្ពុជាគឺជាប្រទេសមួយដែលសម្បូរទៅដោយធនធានធម្មជាតិ ជាពិសេសធនធានព្រៃឈើ។ រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់ក្នុងការថែរក្សា ការពារ ក៏ដូចជាស្តារឡើងវិញនូវតំបន់ព្រៃឈើដែលសឹករិចរឹល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ស្តីពីព្រៃឈើ និងបទដ្ឋានគតិយុត្តិផ្សេងៗដើម្បីគ្រប់គ្រងធនធានព្រៃឈើនៅកម្ពុជា។

ដើម្បីចូលរួមចំណែកក្នុងការថែរក្សាការពារ និងអភិរក្សធនធានព្រៃឈើនៅកម្ពុជា ខ្ញុំបាទបាននិពន្ធសៀវភៅមួយក្រោមចំណងជើង **ច្បាប់ និងកម្មវិធីព្រៃឈើជាតិ** ។ ខ្ញុំបាទសង្ឃឹមថា ព័ត៌មាន និងការណែនាំដែលមាននៅក្នុងសៀវភៅនេះ អាចជាជំនួយដល់អ្នកអានដែលចាប់អារម្មណ៍ទៅលើការយល់ដឹងអំពីច្បាប់ព្រៃឈើ ដើម្បីជាការរួមចំណែកក្នុងការអភិរក្ស និងថែរក្សាការពារធនធានព្រៃឈើនៅក្នុងប្រទេសកម្ពុជា។

ខ្ញុំបាទនឹងរង់ចាំទទួលនូវការរិះគន់កែលម្អក្នុងន័យស្ថាបនា ដើម្បីធ្វើឱ្យសៀវភៅមួយនេះកាន់តែប្រសើរឡើងថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ប្រជាពលរដ្ឋទាំងអស់ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លា ប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលមាននៅក្នុងសៀវភៅនេះ។

សូម សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ប្រជាពលរដ្ឋ ព្រមទាំងមិត្តអ្នកអានទាំងអស់ ជួបតែនឹងសេចក្តីសុខ និងសុភមង្គលគ្រប់ពេលវេលា។

ថ្ងៃ.................ខែ..............ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញថ្ងៃទី......... ខែ............គ.ស ២០២១

**អ្នកនិពន្ធ**

**ថាវ សុភ័ក្រ**

# អ្នកនិពន្ធ



| | | |
|---|---|---|
| **នាម និងគោត្តនាម** | ៖ | ថាវ សុភ័ក្រ |
| **អាស័យដ្ឋាន** | ៖ | សង្កាត់ដង្កោ ខណ្ឌដង្កោ ភ្នំពេញ |
| **ស្ថាប័នការងារ** | ៖ | គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| **ឯកទេស ឬមុខជំនាញ** | ៖ | វិទ្យាសាស្ត្រព្រៃឈើ |
| **ប្រវត្តិការសិក្សា** | ៖ | កំពុងបន្តថ្នាក់បណ្ឌិតផ្នែក អេកូឡូស៊ីព្រៃឈើ |
| **ប្រវត្តិការងារ** | ៖ | គ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (២០១៦-បច្ចុប្បន្ន) |

# មាតិកា

បុព្វកថា និងសេចក្ដីបញ្ជាក់នៃមូលនិធិ

**ទំព័រ**


សេចក្ដីថ្លែងអំណរគុណ ........................................ I
អារម្ភកថា ........................................ II

**ជំពូក១ ច្បាប់ព្រៃឈើ**

មេរៀនទី១ សេចក្ដីផ្ដើមអំពីស្ថានភាពព្រៃឈើនៅកម្ពុជា ........................ ១
១.១ វិស័យព្រៃឈើនៅកម្ពុជា ........................ ១
១.២ ប្រជាជន និងព្រៃឈើកម្ពុជា ........................ ៧
១.៣ ការបាត់បង់ព្រៃឈើនៅកម្ពុជា ........................ ៨
១.៤ ការរៀបចំស្ថាប័ន និងអភិបាលកិច្ចព្រៃឈើ ........................ ១២
១.៥ សារៈសំខាន់នៃព្រៃឈើ ........................ ១៣
១.៥.១ ព្រៃឈើធម្មជាតិ ........................ ១៤
១.៥.២ ព្រៃឈើធម្មជាតិ និងជីវចម្រុះ ........................ ១៤
១.៥.៣ ព្រៃឈើធម្មជាតិ និងបរិយាកាស ........................ ១៥
១.៥.៤ ព្រៃឈើធម្មជាតិ និងធនធានក្នុងដី ........................ ១៥
១.៥.៥ ព្រៃឈើធម្មជាតិ និងមនុស្ស ........................ ១៥
១.៥.៦ ផលប៉ះពាល់នៃការបាត់បង់ព្រៃឈើធម្មជាតិ ........................ ១៦
១.៥.៧ ព្រៃឈើ និងសុខភាព ........................ ១៦
១.៥.៨ ព្រៃឈើ និងទឹក ........................ ១៦
១.៥.៩ ព្រៃឈើ និងអាកាសធាតុ ........................ ១៧
១.៥.១០ ព្រៃឈើបង្ការសំណឹកដី និងកាត់បន្ថយទឹកជំនន់ ........................ ១៧
១.៥.១១ ព្រៃឈើ និងជីវៈចម្រុះ ........................ ១៧
១.៥.១២ ព្រៃឈើ អាហារ អុសដុត និងឱសថ ........................ ១៨
១.៥.១៣ ព្រៃឈើ និងយេនឌ័រ ........................ ១៨
១.៥.១៤ ព្រៃឈើ និងការចិញ្ចឹមជីវិត ........................ ១៩
១.៥.១៥ ព្រៃឈើ និងកសិកម្ម ........................ ១៩
១.៥.១៦ ព្រៃឈើ និងអេកូទេសចរណ៍ ........................ ២០
១.៥.១៧ ព្រៃឈើ និងអនុផលព្រៃឈើ ........................ ២០
១.៦ ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព ........................ ២១
១.៦.១ សំនួរមួយចំនួនដែលពាក់ព័ន្ធនឹងការធ្វើផែនការគ្រប់គ្រងព្រៃឈើ ...... ២២

១.៦.២ ការអភិរក្សព្រៃឈើ.......................................................... ២៣
១.៦.៣ ការដាំដើមឈើឡើងវិញ .................................................. ២៤
១.៧ ប្រវត្តិនៃការតាក់តែងច្បាប់ និងបទដ្ឋានគតិយុទ្ធព្រៃឈើផ្សេងៗនៅកម្ពុជា ២៦
១.៨ សហគមន៍ព្រៃឈើនៅកម្ពុជា ........................................................ ៣២
១.៨.១ និយមន័យនៃសហគមន៍ព្រៃឈើ ........................................ ៣២
១.៨.២ ទម្រង់ជាក់ច្បាស់នៃការអនុវត្តន៍លើសហគមន៍ព្រៃឈើនៅកម្ពុជា៣៣
១.៩ គោលការណ៍ណែនាំរបស់សហគមន៍ព្រៃឈើ .................................... ៣៦
១.១០តួនាទីរបស់សហគមន៍ព្រៃឈើដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើព្រៃឈើ៣៧
១.១១ ការស្តារឡើងវិញនូវសេវាកម្មអេកូឡូស៊ី និងព្រៃឈើ .......................... ៤២

**ជំពូក ២ ច្បាប់ព្រៃឈើ**

មេរៀនទី ២ បទបញ្ញត្តិទូទៅនៃច្បាប់ព្រៃឈើ ...................................................... ៤៨
២.១ បទបញ្ញត្តិទូទៅ ...................................................................... ៤៨
២.២ ជំពូក២ រដ្ឋបាលព្រៃឈើ ............................................................ ៤៩
២.៣ ជំពូកទី៣ និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ .................................. ៥១
២.៤ ជំពូកទី ៤ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ................................................ ៥៣
២.៥ ជំពូកទី ៥ ការគ្រប់គ្រងព្រៃសម្បទាន............................................. ៥៥
២.៦ ជំពូកទី ៦ ការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន និងព្រៃការពារ. ៥៨
មេរៀនទី៣ លិខិត និងសិទ្ធអំណាចផ្សេងៗនៃច្បាប់ព្រៃឈើ................................. ៦០
៣.១ ជំពូក៧ អំពីលិខិតអនុញ្ញាតិ និងសិទ្ធិអំណាច ................................... ៦០
៣.២ ជំពូកទី ៨ ការហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងការការពារព្រៃឈើ .......................................................................................... ៦៣
៣.៣ ជំពូកទី ៩ សិទ្ធិប្រើប្រាស់ជាប្រពៃណី ការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃឯកជន .......................................................................................... ៦៧
៣.៤ ជំពូកទី ១០ ការអភិរក្សសត្វព្រៃ ..................................................... ៧០
៣.៥ ជំពូកទី ១១ ថ្លៃសួយសារនិងបុព្វលាភ លើផល អនុផលព្រៃឈើ .......... ៧២
មេរៀនទី៤ ការគ្រប់គ្រងព្រៃឈើក្នុងច្បាប់ព្រៃឈើ ............................................ ៧៥
៤.១ ជំពូកទី ១២ ការដាំដើមឈើឡើងវិញ និងមូលនិធិអភិវឌ្ឍន៍ឈើជាតិ......៧៥
៤.២ ជំពូកទី ១៣ វិធានការគ្រប់គ្រងសកម្មភាពឈើ................................. ៧៧
៤.៣ ជំពូកទី ១៤ នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ.............................. ៨១

៤.៤ ជំពូកទី១៥ បទល្មើសឈើ និងទោសប្បញ្ញត្តិ ................................... ៨៥
៤.៥ ជំពូកទី ១៦ ការអនុវត្តសាលក្រមតុលាការ........................................ ៩៣
៤.៦ ជំពូកទី ១៧ អន្តរប្បញ្ញត្តិ............................................................... ៩៤
៤.៧ ជំពូកទី ១៨ អវសានប្បញ្ញត្តិ ........................................................... ៩៥

**ជំពូក៣ កម្មវិធីព្រៃឈើថ្នាក់ជាតិ**

មេរៀនទី៥ ទស្សនវិស័យ បេសកកម្ម និងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ.......... ៩៦
៥.១ ទស្សនវិស័យ និងបេសកកម្ម........................................................ ៩៦
៥.២ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង ព្រៃឈើឱ្យមាននិរន្តរភាព..... ៩៨
៥.២.១ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ១ គឺបង្កើនជីវភាពរស់នៅ ការងារ និងសេដ្ឋកិច្ច............................................................... ៩៨
៥.២ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង ព្រៃឈើឱ្យមាននិរន្តរភាព៩៩
៥.២.២ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ២ គឺបញ្ហាប្រែប្រួលអាកាសធាតុ .......................................................................................... ១០០
៥.២.៣ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៣ គឺការរៀបចំផែនការប្រើប្រាស់ដីធ្លី............................................................................. ១០០
៥.២.៤ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៤ គឺអភិបាលកិច្ចល្អវិស័យព្រៃឈើ .................................................................................... ១០១
៥.២.៥ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៥ គឺការគ្រប់គ្រងទំនាស់ .......................................................................................... ១០១
៥.២.៦ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៦ គឺការអភិវឌ្ឍសមត្ថភាព .......................................................................................... ១០២
៥.២.៧ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី៧ គឺការការពារបរិស្ថាន និងការអភិរក្សធនធានព្រៃឈើ ........................................................ ១០៣
៥.២.៨ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី៤ គឺជម្រើសរបបគ្រប់គ្រងព្រៃឈើ .................................................................................... ១០៣
៥.២.៩ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៩ គឺការផ្តល់ហិរញ្ញប្បទានប្រកបដោយ និរន្តរភាពសម្រាប់ វិស័យព្រៃឈើ.............................. ១០៥
មេរៀនទី៦ ក្របខណ្ឌនៃកម្មវិធីព្រៃឈើជាតិ ...................................................... ១០៧
៦.១ ទំរង់នៃឯកសារកម្មវិធីព្រៃឈើជាតិ................................................. ១០៧
៦.២ តួនាទីរបស់អ្នកពាក់ព័ន្ធ ................................................................ ១០៨
៦.៣ ក្របខណ្ឌប្រតិបត្តិការ..................................................................... ១០៩

៦.៤. កម្មវិធីអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ.................... ១០៩
៦.៥. កម្មវិធីពង្រឹងច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច............................ ១១០
៦.៦. កម្មវិធីសហគមន៍ព្រៃឈើ......................................................... ១១១
៦.៧.កម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ ................................ ១១១
៦.៨កម្មវិធីហិរញ្ញប្បទានដោយចីរភាពសម្រាប់វិស័យព្រៃឈើ ................... ១១១
មេរៀនទី៧ ការអនុវត្ត ការតាមដាននិងរាយការណ៍ ........................................ ១០៣
៧.១ ការផ្តល់ហិរញ្ញប្បទាន និងចំណាយ .............................................. ១០៣
៧.២ ប្រព័ន្ធតាមដាន និងរាយការណ៍នៃកម្មវិធីព្រៃឈើជាតិ...................... ១០៣
៧.២ ប្រព័ន្ធតាមដាន និងរាយការណ៍នៃកម្មវិធីព្រៃឈើជាតិ...................... ១០៤
មេរៀនទី៨ ការធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ........................................ ១១៦
៨.១ កម្មវិធីទី ១ ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជីកា ............ ១១៧
៨.១.១ ចំណុចអាទិភាពសំខាន់ៗ.............................................. ១០៧
៨.១.២ រយៈពេលកម្មវិធី......................................................... ១០៧
៨.១.៣ ការឆ្លើយតបទៅនឹងទស្សនវិស័យនៃកម្មវិធីព្រៃឈើជាតិ........ ១០៧
៨.១.៤ ការឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីពឈើជាតិ .......... ១០៨
៨.១.៥ . សាវតារកម្មវិធី............................................................ ១០៩
៨.១.៦ ការវិភាគបញ្ហា............................................................... ១២១
៨.១.៧ គោលបំណងនៃកម្មវិធី..................................................... ១២២
៨.១.៨ សូចនាករ...................................................................... ១២៣
៨.១.៩ ការផ្ទៀងផ្ទាត់................................................................. ១២៤
៨.១.១០ ហានិភ័យនៃកម្មវិធី....................................................... ១២៤
៨.១.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី ............................................... ១២៥
៨.១.១២ អនុកម្មវិធី ១ កំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ .................................................................................... ១២៧
៨.១.១៣ អនុកម្មវិធី ២ ការចាត់ថ្នាក់ព្រៃឈើជាតិតាមមុខងារ .......... ១៣២
៨.២ កម្មវិធីទី ២ ការអភិរក្ស និង ការអភិវឌ្ឍធនធនព្រៃឈើ និងជីវចម្រុះ.... ១៣៥
៨.៣ កម្មវិធី ៣ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច.......... ១៧០
៨.៤ កម្មវិធីទី៤ សហគមន៍ឈើ ........................................................ ១៩៨
៨.៥ កម្មវិធីទី ៥ អភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ............................ ២២៦
៨.៦ កម្មវិធីទី ៦ ហិរញ្ញប្បទនដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ.......... ២៥១

**ជំពូក៤ ប្រវត្តិនៃការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តព្រៃឈើផ្សេងៗ**

# ជំពូក១ ច្បាប់ព្រៃឈើ

## មេរៀនទី១ សេចក្តីផ្តើមអំពីស្ថានភាពព្រៃឈើនៅកម្ពុជា

### ១.១ វិស័យព្រៃឈើនៅកម្ពុជា

កម្ពុជា ស្ថិតនៅតំបន់អាស៊ីភាគអាគ្នេយ៍ ដែលមានអាកាសធាតុត្រូពិច កម្ពុជាត្រូវបានចាត់ជាប្រទេសសម្បូរដោយធនធានធម្មជាតិ ជាពិសេសព្រៃឈើ និងជីវចម្រុះ។ កម្ពុជាមានផ្ទៃដីព្រៃឈើ សរុបប្រមាណជាង ៩ លាន ហិកតា ក្នុងឆ្នាំ ២០២០ ដែលបានប៉ាន់ប្រមាណដោយអង្គការស្បៀងអាហារ និងកសិកម្ម (FAOSTAT, 2020; RGC, 2021)។ ផ្ទៃដីព្រៃឈើនៅកម្ពុជាគ្រប់គ្រងដោយ ៣ ស្ថាប័ន: រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។ រដ្ឋបាលព្រៃឈើ គឺជាអាជ្ញាធរស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានភារកិច្ចគ្រប់គ្រងព្រៃអចិន្ត្រៃយ៍រដ្ឋ ដែលរួមបញ្ចូលព្រៃដាំ និងព្រៃធម្មជាតិ និងបែងចែកជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន។ ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមាន ព្រៃផ្តល់ផល ព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ការអភិរក្ស។ ព្រៃឯកជន នឹងត្រូវថែរក្សាដោយ ឯកជន ដែលមានសិទ្ធិគ្រប់គ្រង អភិវឌ្ឍ ប្រមូលផល ប្រើប្រាស់ លក់ដូរ និងចែកចាយផលិតផលព្រៃឈើដោយអនុលោមតាមច្បាប់ព្រៃឈើ ២០០២ (RGC, 2002a)។ ធនធានព្រៃ ឈើក្នុងតំបន់ព្រៃការពារ ស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រង និង អាជ្ញាធរមានសមត្ថកិច្ច នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ក្រោមច្បាប់តំបន់ការពារធម្មជាតិ ២០០៨ (RGC, 2008b)។ តំបន់ព្រៃលិចទឹក និងព្រៃកោងកាង ស្ថិតនៅក្រៅតំបន់ព្រៃការពារដែលគ្រប់គ្រងដោយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (RGC, 2006)។

បច្ចុប្បន្នព្រៃឈើនៅកម្ពុជាត្រូវបានចែកជា ១១ ថ្នាក់ គោលបំណង នៃការប្រើប្រាស់/វាយតម្លៃគំរបដី។ ចំណាត់ថ្នាក់នោះរួមមាន ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃរល្បោះ ព្រៃឫស្សី ព្រៃកោងកាង ព្រៃស្មាច់ ព្រៃលិចទឹក ព្រៃលិចទឹកដុះឡើងវិញ ព្រៃស្រល់ ព្រៃស្រល់ដាំ និងព្រៃដាំ។

លើសពីនេះ វិសមភាពយេនឌ័របច្ចុប្បន្នក្នុងការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនិងដំណើរការគ្រប់គ្រងព្រៃឈើនៅមានកម្រិតទាប និងតំណាងស្ត្រីក្នុងស្ថាប័នព្រៃឈើនៅមានកម្រិត។ ពួកគេមានឱកាសទទួលព័ត៌មាន ការអប់រំ និងបណ្តុះបណ្តាល តិចជាងបុរស ជាពិសេសលើការដេកហូត ប្រើប្រាស់ និងផ្សព្វផ្សាយស្តីពីការអភិរក្ស និងការពារធនធានធម្មជាតិ និងបរិស្ថាន (WOCAN, 2019)។

ព្រៃឈើនៅកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកសិកម្ម និងនេសាទ ដោយរក្សាបានផលិតភាព និងនិរន្តភាពនៃវិស័យទាំងពីរនេះ។ សេវាកម្មដែលផ្តល់ដោយអេកូឡូស៊ីព្រៃឈើរួមមានបទបញ្ញត្តិនៃ វដ្តទឹកក្នុងតំបន់ កាត់បន្ថយគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងកាត់បន្ថយការហូរច្រោះដី។

ដូច្នេះ ហើយព្រៃឈើគឺជាកត្តាគន្លឹះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការប្រើប្រាស់ដោយចីរភាព អាចផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រទេសជាតិ និងប្រជាជនយើង។

ឱកាសកំពុងកើនឡើងតម្លៃផលិតផលកែច្នៃឈើមានតម្លៃ និងទីផ្សារកាបូនអន្តរជាតិ។ កំណែទម្រង់ហិរញ្ញប្បទានថ្មីតាមរយៈ "ការបង់សេវាកម្មបរិស្ថាន" សម្រាប់អភិរក្សធនធានធម្មជាតិ។

ខណៈដែលតំបន់ព្រៃឈើ ស្ថិតក្រោមការការពារដោយបទបញ្ញត្តិច្បាប់កម្ពុជា ដើម្បីជម្រុញពង្រឹងការអនុវត្តច្បាប់ និងការពារធនធានព្រៃឈើ ដើម្បីកាត់បន្ថយការបាត់បង់ និងថយចុះនៃធនធានព្រៃឈើ។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត ចក្ខុវិស័យព្រៃឈើរយៈពេលវែង តាមរយៈការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ពីវិស័យព្រៃឈើ មកដល់សូន្យភាគរយ ត្រឹមឆ្នាំ ២០៤០ (RGC, 2021)។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ គោលនយោបាយមួយចំនួនត្រូវបានបង្កើតឡើងក្រោយន្តការរ៉េដបូក (REDD+ mechanism)។ ក្រៅពីនេះ ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្រុមជនជាតិដើម និងវិស័យឯកជន ក្នុងការអនុវត្តគោលនយោបាយរ៉េដបូក គឺជាមូលដ្ឋានគ្រឹះដើម្បីលើកកម្ពស់សកម្មភាពដោយនិរន្តភាពក្នុងវិស័យ AFOLU។ ព្រៃឈើនៅកម្ពុជា ប្រសិនបើមិនត្រូវបានប្រញាប់ការពារពីការរេចរឹលទាំងនោះសម្រាប់ធ្វើការស្តារឡើងវិញ " ការបាត់បង់ព្រៃផ្តល់ផល ក៏ដូចជា ជីវចម្រុះផងដែរ នឹងនាំដល់ការបាត់បង់ចំណូល ឬជម្រើសសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍ ដែលពឹងអាស្រ័យលើធនធានព្រៃឈើ" (UNDP, 2011)។ ស្ថានភាពនេះនឹងកាន់តែអាក្រក់ទៅ ៗ នៅពេលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនាទសវត្សខាងមុខ។

ព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតមួយនៅលើពិភពលោក ដែលមានប្រជាពលរដ្ឋវ័យក្មេង អាយុក្រោម២០ឆ្នាំ ចំនួន ៤៨% ដែលឈានដល់វ័យធ្វើការ និងកំពុងត្រូវការនូវទីផ្សារការងារ។ ការកើនឡើងនូវសម្ពាធ និងតម្រូវការដី និងធនធានធម្មជាតិដោយសារតែកំណើនប្រជាជន (ប្រហែល១.៥៣%) កំណើននៃភាពគ្មានការងារ ការផ្លាស់ប្តូរទីលំនៅក្នុងប្រទេសនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ចផ្សេងៗ គួបផ្សំជាមួយកង្វះខាតខាងផ្នែកច្បាប់ និងការអភិវឌ្ឍនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ផងនោះ បណ្តាលឱ្យព្រៃឈើរបស់យើងប្រឈមនឹងការធ្វើអាជីវកម្មដោយគ្មាននិរន្តរភាព ព្រមទាំងបង្កឱ្យមានទំនាស់ ពាក់ព័ន្ធទៅនឹងសិទ្ធិកាន់កាប់ និងប្រើប្រាស់ព្រៃឈើ។

ទោះជាយ៉ាងណា ព្រះរាជាណាចក្រកម្ពុជា បានទទួលជោគជ័យគួរឱ្យកត់សម្គាល់ក្នុងការថែរក្សាធនធានព្រៃឈើ ដែលគ្របដណ្តប់ជាង ៥៩% ស្មើនឹងជាង ១០,៨លានហិកតានៃផ្ទៃប្រទេស។ ធនធានព្រៃឈើទាំងនេះ មានលក្ខណៈជីវសាស្ត្រពិសេស និងជាតំបន់មរតកវប្បធម៌ជាតិ ដែលមានសក្តានុពល និងផ្តល់ទិន្នផលខ្ពស់។ ជាងនេះទៅទៀតព្រៃឈើរបស់កម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងវិស័យកសិកម្ម និងជលផលដោយជួយរក្សានិរន្តរភាព និងផលិតភាពនៃវិស័យទាំងពីរនេះ។ សេវាកម្មព្រៃឈើ រួមមានទាំងការរក្សានិយ័តភាពប្រភពទឹកចរន្តទឹក ការទប់ស្កាត់ភាពរាំងស្ងួត និងទឹកជំនន់ ការ

កាត់បន្ថយការហូរច្រោះដី ការ គោករាក់នៃទន្លេ-ស្ទឹង-អូរបឹងបួរ។ល។ ដូច្នេះព្រៃឈើមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍជាតិដោយចីរភាព។ ការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព អាចផ្តល់ផលប្រយោជន៍ យ៉ាងច្រើនដល់ប្រទេសជាតិ និងប្រជាជន។ ឱកាសជាច្រើនកំពុងតែកើតមានឡើងនៅលើទីផ្សារអន្តរជាតិ ដូចជាការកែច្នៃផលិតផលព្រៃឈើ និងផលិតផលព្រៃឈើកែច្នៃដែលមានតម្លៃខ្ពស់ និងសក្តានុពលនៃការអភិវឌ្ឍទីផ្សារ កាបូនព្រៃឈើជាដើម។ ប្រភពហិរញ្ញវត្ថុថ្មីៗ កំពុងត្រូវបានគេបង្កើតឡើងតាមរយៈយន្តការ ការបង់ថ្លៃសេវាកម្មបរិស្ថាន សម្រាប់ការអភិរក្សធនធានព្រៃឈើ និងជីវចម្រុះ។

ភាគច្រើននៃប្រជាពលរដ្ឋជនបទជាកសិករ ហើយប្រមាណជា ៧៥% គាត់ក៏ដូចជាគ្រួសារដែលគ្មានដីស្រែ គឺពឹងផ្អែកទៅលើការប្រមូលផលពីធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត ពិសេសនៅពេលជួបគ្រោះធម្មជាតិ។ ព្រៃឈើក៏បានផ្តល់អំណោយផល ដល់ប្រជាកសិករផងដែរនូវឱកាសក្នុងការដាំដុះដំណាំចម្រុះ ការកប្រាក់ចំណូលបន្ថែម និងការបង្កើតការងារដោយសហគ្រាសផលិតកម្ម អនុផលព្រៃឈើ។

ការថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងជម្រើសនៃការអភិវឌ្ឍសេដ្ឋកិច្ច ការទាញយកផលប្រយោជន៍កាន់តែច្រើនឡើងពីព្រៃឈើ និងកិច្ចការពារបរិស្ថាន គឺជាបញ្ហាលំបាកមួយ ដោយយើងមិនអាចទុកចោលនូវបញ្ហាណាមួយបានឡើយ។ ការចាត់ចែងគ្រប់គ្រងដ៏ប៉ិនប្រសប់ នៃធនធានព្រៃឈើប្រកបដោយសមធម៌ គឺជាមូលដ្ឋានសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចទំនើប ហើយក៏អាចរក្សា និងពង្រីកនូវមុខងារ ប្រព័ន្ធអេកូឡូស៊ី ភាពសម្បូរបែបនៃជីវចម្រុះ និងភាពខុសគ្នានៃអេកូឡូស៊ី ទៀតផង។

ទន្ទឹមនឹងការផ្តល់ជាប្រភពចំណូល សម្រាប់ជីវភាពរស់នៅដល់ប្រជាជនរស់នៅតាមជនបទនោះ ព្រៃឈើក៏ជាប្រភពមួយនៃទំនាស់ នឹងការធ្វើអាជីវកម្មផងដែរ។ នៅអំឡុងទសវត្ស ១៩៨០ គ្រប់ភាគីទំនាស់បានប្រើប្រាស់ព្រៃឈើធ្វើជាតំបន់លាក់ខ្លួន និងប្រើប្រាស់ ធនធានព្រៃឈើសម្រាប់ផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។ ក្រោយពេលប្រទេសជាតិ រំដោះចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត ធនធានព្រៃឈើក៏ត្រូវបានប្រើប្រាស់សម្រាប់ការស្តារប្រទេសជាតិឡើងវិញ ដែលខ្ទេចខ្ទាំដោយសារសង្គ្រាមស៊ីវិល។ នៅទសវត្សរ៍ទី ៩០ ការជំរុញវិនិយោគទុនពីវិស័យឯកជនបានធ្វើឱ្យមានការកើនឡើងនូវការផ្តល់សម្បទានព្រៃឈើធំៗ ហើយបង្កើតជាឱកាសដែលក្រុមហ៊ុន មួយចំនួនអាចធ្វើអាជីវកម្មខុសច្បាប់ និងគ្មាននិរន្តភាព។ រយៈពេលជាងបួនទសវត្សកន្លងផុតទៅ គម្របព្រៃឈើកម្ពុជាត្រូវបានបាត់បង់ ជិត ៣ លានហិកតា គឺ ប្រមាណជាង ១៤% នៃផ្ទៃដីសរុបរបស់ប្រទេស។

ប្រទេសកម្ពុជាមានការអភិវឌ្ឍផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ទស្សនវិស័យវែងឆ្ងាយសម្រាប់អភិវឌ្ឍន៍ដោយចីរភាពត្រូវបានគូសបញ្ជាក់ នៅក្នុងយុទ្ធសាស្ត្រចតុកោណទាំងពីរដំណាក់កាល និងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

តាមរយៈអភិបាលកិច្ចល្អ គឺជាគោលការណ៍គន្លឹះតែមួយគត់នៅក្នុងគោលនយោបាយរបស់ប្រទេស។ កម្មវិធីព្រៃឈើជាតិដំបូងរបស់យើង (២០១០-២០២៩) នេះនឹងកែលម្អលក្ខខណ្ឌសម្រាប់ស្ថានភាពព្រៃឈើ សេដ្ឋកិច្ច សង្គម និង តួនាទីរបស់ប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ ហើយកម្មវិធីនេះផ្តល់នូវទិសដៅជាយុទ្ធសាស្ត្រដែលកំណត់ថា អភិបាលកិច្ចល្អ និង ការចូលរួម គឺជាគោលការណ៍គ្រឹះនៃការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព និងការបង្កើនវិភាគទានរបស់ព្រៃឈើទៅក្នុងការអភិវឌ្ឍប្រទេស។

ការប្រឈមក្នុងការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព មានពាក់ព័ន្ធជាមួយឱកាសក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ បញ្ហាទាំងនេះមានរៀបរាប់ជូនខាងក្រោម ដែលដំបូងគឺមានអធិប្បាយអំពីបញ្ហានៅថ្នាក់តំបន់ បន្ទាប់មកពិពណ៌នាកាន់តែច្បាស់អំពីបញ្ហាប្រឈមដែលទាក់ទងនឹងវិស័យព្រៃឈើ។

- **ការនៅតែមានតម្រូវការនៃវិស័យព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ការបង្កើនជីវភាពរស់នៅ និងសេដ្ឋកិច្ចជាតិ**

អ្វីដែលជាបញ្ហាប្រឈមនោះគឺតម្រូវការការប្រើប្រាស់ និងបង្កើនវិភាគទានរបស់វិស័យព្រៃឈើក្នុងការកាត់បន្ថយ ភាពក្រីក្រតាមរយៈការបង្កើនជីវភាពនិងសេដ្ឋកិច្ចគ្រួសារ។ ភាគច្រើននៃប្រជាជននៅជនបទពឹងផ្អែកលើការចូលព្រៃរកផល អនុផលព្រៃឈើ ជាពិសេសសម្រាប់អាហារ ថាមពលអុសកូនឈើតូចៗ និង សសរ ប្រមូលជ័រ ឃ្វាលគោក្របី ប្រមូលរុក្ខជាតិ ថ្នាំបុរាណ និងមានជំនឿអារក្សអ្នកតាជាដើម។ ប្រជាជនមូលដ្ឋានត្រូវតែមានសិទ្ធិជាសារវន្តក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដោយស្របច្បាប់ និងប្រកបដោយនិរន្តរភាព។

តួនាទីរបស់ព្រៃឈើក្នុងការចូលរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពុំទាន់មានការយល់ច្បាស់ និងឱ្យតម្លៃ នៅឡើយ។ ម្យ៉ាងទៀត វិភាគទានផ្នែកសេដ្ឋកិច្ចរបស់ព្រៃឈើនៅក្នុងផលិតផលសរុបក្នុងស្រុក (GDP) បានបន្តធ្លាក់ចុះជា បន្តបន្ទាប់។ អ្វីដែលជាបញ្ហាប្រឈមនោះ គឺការប្រមូលចំណូលអំពីសកម្មភាពផ្សេងៗ ដែលទាក់ទងទៅនឹងផលិតកម្មផល អនុផលព្រៃឈើ ដោយរួមបញ្ចូលទាំងតម្លៃនៃការអភិរក្សជីវចម្រុះ និងសេវាកម្មបរិស្ថាន ឬប្រព័ន្ធអេកូឡូស៊ីផងដែរ។

- **ការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលលើជីវភាពរស់នៅ របស់អ្នកដែលពឹងផ្អែកលើព្រៃឈើ**

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមជាសកលរបស់ពិភពលោក ហើយបញ្ហានេះនឹងជះឥទ្ធិពលដល់កម្រិត កម្ពស់ផ្ទៃទឹកសមុទ្រ ទិន្នផលកសិកម្ម ផលនេសាទ និងនិរន្តរភាពនៃការអភិវឌ្ឍ។

ភាពមិនច្បាស់លាស់នៃផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុទៅលើព្រៃឈើ ជីវចម្រុះ កសិកម្ម វាលស្មៅ និងតំបន់ដីផ្សេងៗទៀត គឺជាបញ្ហាប្រឈមដ៏ចម្បងៗ។ យុទ្ធសាស្ត្រ

កាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុ ត្រូវតែរៀបចំជាចាំបាច់ដើម្បីការពារព្រៃឈើ និងជីវចម្រុះធម្មជាតិ តាមលក្ខណៈអេកូឡូស៊ីរបស់វា ដែលអាចធានាបាននូវ សក្តានុពលផលិតកម្ម និងសេវាកម្មបរិស្ថាន និងអាចជួយកាត់បន្ថយផលប៉ះពាល់ដល់ការធ្វើកសិកម្មនៅតាមតំបន់ជុំវិញ និង តំបន់ដែលមានអត្រាប្រជាជនរស់នៅខ្ពស់។

- **ការរៀបចំផែនការប្រើប្រាស់ដីធ្លី**

ការរៀបចំផែនការរបស់វិស័យនីមួយៗតែងកងង បណ្តាលឱ្យមានការទាមទារជាន់គ្នាការជំទាស់តវ៉ាច្រើននៅលើដីព្រៃឈើ ដែលករណីទាំងនេះតម្រូវឱ្យមានការរៀបចំផែនការគ្រប់គ្រងថ្នាក់ម៉ាក្រូរយៈពេលវែង និងត្រូវមានការចូលរួមសហការពីវិស័យសេដ្ឋកិច្ច ផ្សេងៗ ដែលអាចជះឥទ្ធិពលលើ ឬទទួលរងឥទ្ធិពលពីសកម្មភាពព្រៃឈើដូចជា វិស័យកសិកម្ម ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការផ្តល់សម្បទានរ៉ែ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ល។ ដើម្បីសម្រេចឱ្យបានការរួមចំណែកពីព្រៃឈើជាអតិបរមាដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនោះ គឺទាមទារឱ្យមានកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងក្រសួង និងស្ថាប័នពាក់ព័ន្ធនានា។

- **សកម្មភាពល្មើសច្បាប់ និងភាពមានកម្រិតនៃកិច្ចសហការ**

បញ្ហាប្រឈមទាក់ទងនឹងចំណុចនេះមានច្រើន ហើយគ្រោះថ្នាក់បាត់បង់ទ្រព្យសម្បត្តិសាធារណៈ គឺជាចំណុចគួរឱ្យព្រួយ បារម្ភជាងគេ។ តំបន់ព្រៃឈើដែលមានទំហំធំមួយចំនួនគ្មានការគ្រប់គ្រងច្បាស់លាស់ បណ្តាលឱ្យមានទំនាស់ ការកាប់ឈើខុសច្បាប់ និងការរំលោភបំពានចាប់យកដី។ ភាគច្រើននៃដីព្រៃឈើនៅមិនទាន់ត្រូវបានកំណត់ព្រំប្រទល់ច្បាស់លាស់ គួបផ្សំនឹងការអនុវត្តច្បាប់ នៅមានកម្រិត ហើយតម្រូវការដីធ្លីកើនឡើងខ្ពស់ រឹតតែជំរុញឱ្យមានការរំលោភទន្ទ្រានចាប់យកដីព្រៃឈើ ការធ្វើចម្ការពនេចរធនធាននិរន្តរភាព និងការប្រើប្រាស់ដីព្រៃ ឈើដោយគ្មានការសិក្សាស្រាវជ្រាវ និងវាយតម្លៃឱ្យបានត្រឹមត្រូវ។

- **ទំនាស់ក្នុងវិស័យព្រៃឈើ**

ជារឿយៗ ទំនាស់ព្រៃឈើកើតចេញមកពីអតុល្យភាពនៃសិទ្ធិអំណាច ការចង់បានផលប្រយោជន៍ខុសៗគ្នាពី ដីព្រៃឈើ និង ផលព្រៃឈើ បញ្ហាអភិបាលកិច្ច ការគ្រប់គ្រងបែកខ្ញែក និងបញ្ហាសិទ្ធិមនុស្សជាដើម។ ភាគច្រើនទំនាស់ (ភាគីទាំងសងខាងតែងរងនូវផលប៉ះពាល់ )និងកើតនៅតំបន់ជនបទ ហើយភាគច្រើនប្រជាជនជនបទ និងប្រជាជនដែលពឹងផ្អែក លើព្រៃឈើតែងក្លាយជាជនរងគ្រោះ ដោយសារតែសិទ្ធិអំណាចនិងកម្លាំងសេដ្ឋកិច្ចរបស់គេនៅមានកម្រិត។ បើសិនជាទំនាស់ព្រៃឈើមិនត្រូវបានគ្រប់គ្រងទេនោះ វាអាចក្លាយទៅជាជំងឺរ៉ាំរ៉ៃ និងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការគ្រប់គ្រង

ព្រៃឈើដោយនិរន្តរភាព។ ទំនាស់ ព្រៃឈើបានក្លាយទៅជាបញ្ហាប្រឈមយ៉ាងធំ ចំពោះការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តភាពនាពេលបច្ចុប្បន្ន។

- **សមត្ថភាព និងចំណេះដឹងនៅមានកម្រិត**

សមត្ថភាពបុគ្គល និងស្ថាប័ននៅមានកម្រិត គួបផ្សំសាធារណជនមានការយល់ដឹងតិចតួចផងនោះ គឺជាចំណោទបញ្ហាសំខាន់ មួយក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ។ ពិសេស ការខ្វះខាតចំណេះដឹងក្នុងការអនុវត្ត និងការផ្ទេរចំណេះដឹងពីអ្នកបញ្ចប់ការសិក្សា វិទ្យាសាស្រ្តបច្ចេកវិទ្យាថ្មីៗក៏ជាឧបសគ្គមួយដល់ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពផងដែរ។

- **ការរេចរឹលព្រៃឈើ**

ការរេចរឹលព្រៃឈើបានកាត់បន្ថយគុណភាពរបស់ព្រៃឈើ និងសមត្ថភាពដំណុះឡើងវិញដោយធម្មជាតិ ដែល ប្រការនេះធ្វើឱ្យ ប៉ះពាល់ដល់សមត្ថភាពផ្តល់សេវាកម្មសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ព្រៃឈើយ៉ាងខ្លាំង។ ការរេចរឹលជម្រក និងជីវចម្រុះ បណ្តាល ឱ្យកាត់បន្ថយភាពសម្បូរបែបនៃធនធានព្រៃឈើ និងតំលៃប្រើប្រាស់នាពេលអនាគត។ បញ្ហាប្រឈម គឺការថែរក្សាអេកូឡូស៊ីព្រៃឈើ ដែលល្អ និងអភិរក្សប្រភេទដែលងាយរងគ្រោះ។

- **និរន្តរភាពនៃគំរូគ្រប់គ្រង**

នាពេលបច្ចុប្បន្ននេះ តំបន់ព្រៃឈើផ្តល់ផលជាព្រៃសម្បទានមួយចំនួនធំមិនមានគំរូជម្រើសនៃការគ្រប់គ្រងច្បាស់លាស់មួយនៅ ឡើយទេ។ គំរូគ្រប់គ្រងព្រៃឈើដែលមានស្រាប់នឹងត្រូវបានកែលម្អតាមអ្វីដែលអាចធ្វើទៅបាន។ នេះគឺជាការងារប្រឈមមួយសម្រាប់ យើងដែលត្រូវរៀបចំគំរូគ្រប់គ្រងឱ្យស្របតាមវិជ្ជាជីវៈ និងធ្វើការសាកល្បងវាយតម្លៃ ហើយដកស្រង់បទពិសោធន៍ដើម្បីកែលម្អគំរូគ្រប់ គ្រងទាំងនេះ។

- **ប្រភពហិរញ្ញប្បទាន**

បច្ចុប្បន្នចំណូលបានពីព្រៃឈើនៅមានកម្រិត ហើយមិនត្រូវបានវិនិយោគទៅក្នុងវិស័យនេះវិញដោយផ្ទាល់ទេដែលប្រការនេះ ធ្វើឱ្យរាំងស្ទះដល់ការធ្វើទំនើបកម្ម និងការបង្កើតនូវការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព។ ទន្ទឹមនឹងនេះ ព្រៃឈើរបស់កម្ពុជាមាន សក្តានុពលយ៉ាងធំក្នុងការចូលរួមវិភាគទានដល់សេដ្ឋកិច្ចជាតិ និងសង្គម។ បញ្ហាប្រឈម គឺការធ្វើឱ្យមនុស្សគ្រប់រូបទទួលយកនិងចាត់ទុក ការងារវិស័យព្រៃឈើថាជាការធ្វើជំនួញមួយ ដែលអាចផ្តល់ប្រាក់ចំណូល ហើយត្រូវការការវិនិយោគទៅវិញជាបន្តបន្ទាប់ និងត្រូវការ គម្រោងថវិកាសម្រាប់ទ្រទ្រង់ប្រតិបត្តិការទាំងអស់នេះ។

## ១.២ ប្រជាជន និងព្រៃឈើកម្ពុជា

ព្រៃឈើមានសារៈប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាដែលរស់នៅពឹងអាស្រ័យលើព្រៃឈើសម្រាប់ជីវភាពរស់នៅរបស់ពួកគាត់។ អនុលោមតាមរបាយការណ៍របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា និងការអភិរក្សសត្វព្រៃនៅកម្ពុជា គ្រួសារកសិកររស់នៅជនបទកម្ពុជាប្រមាណ ៤១% ទទួលចំណូលប្រចាំថ្ងៃពី ២០% ដល់ ៥០% ពីធនធានព្រៃឈើ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ខណៈគ្រួសារ ១៥% ទៀតពឹងអាស្រ័យធនធានព្រៃឈើច្រើនជាងពាក់កណ្ដាលសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ (McKenney et al., 2004)។ ទោះបីព្រៃឈើមានតួនាទីសំខាន់សម្រាប់សុខុមាលភាពប្រជាជនកម្ពុជាក៏ដោយក៏ប្រទេសនេះនៅមានកង្វះខាតការរៀបចំគោលនយោបាយ អភិបាលកិច្ច និងធនធាន (មនុស្ស ថវិកា និងមធ្យោបាយ) រារាំងដល់ការគ្រប់គ្រងព្រៃឈើបានល្អ (RGC, 2021)។ សរុបសេចក្ដីប្រជាជនកម្ពុជាទទួលបានផលសំខាន់ៗ ចំនួន ០៣ ពីធនធានព្រៃឈើ៖ កសិកម្ម ចំណូលប្រចាំថ្ងៃ ការចិញ្ចឹមជីវិត និងវប្បធម៌។ សម្រាប់ជាតុចូលនៃកសិកម្ម ព្រៃឈើផ្ដល់ចំណុចចាប់ផ្ដើម សម្រាប់កសិកម្មបង្វិលជុំ និងការការពារ។ ដើមឈើផ្ដល់ម្លប់ របាំងខ្យល់ និងបន្លែវណ្ណវង្ក (ជួរ ស្រទាប់)។ ព្រៃឈើក៏ជួយកែលំអរ ឱនភាពដីដោយប្រើប្រាស់តម្លៃថោក។ ជាតុផ្សំនៃធនធានព្រៃឈើផ្ដល់ជាអាហារ ចំណីសត្វ និងជាតុសរសៃផលិតកន្ត្រក សម្រាប់ដាក់ផលិតផលកសិកម្ម ដងនង្គ័ល និងឧបករណ៍កសិកម្មផ្សេងៗទៀត។ ដើមឈើមានសារសំខាន់ជួយកាត់បន្ថយមូលធនចំណាយឱ្យទាប ដូចជាការជួយកែលំអឱនភាពដី

កសិកម្ម បង្កើនផលិតផលដំណាំ និងកម្លាំងពលកម្ម ឧ. សួនបន្លែគ្រួសារ)។ ទោះយ៉ាងណាសម្ភារៈប្រើប្រាស់មួយចំនួនអាចរកបានពីព្រៃឈើជំនួសពីការទិញ ដូចជា វាលស្មៅចំណីសត្វ ជីធម្មជាតិ ផ្លាស្ទិចសម្រាប់វិចខ្ចប់។ ម្យាងវិញទៀត ព្រៃឈើផ្ដល់ចំណូលប្រចាំថ្ងៃសម្រាប់ប្រជាជនកម្ពុជា (Nhem et al.,2018)។ ផលិតផលព្រៃឈើជួយធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារ ផ្ដល់ប្រភពចំណូលតាមរដូវ និងគ្រាលំបាក។ ផលិតផលព្រៃឈើក៏អាចជួយដល់ជីវភាពរស់នៅដល់គ្រួសារដែលងាយរងគ្រោះ។ ផលិតផលព្រៃឈើមានសារសំខាន់ជាច្រើនដូចជា ងាយស្រួលរកប្រភពធនធាន មិនត្រូវជំនាញចំណាយដើមទុនតិច។ ជាទូទៅគ្រួសារក្រីក្រដែលពឹងអាស្រ័យលើការប្រមូលធនធានព្រៃឈើលក់ ដូរទីផ្សារក្នុងតំបន់ (ភូមិ/ឃុំ) ទទួលបានចំណូលតិចតួច សម្រាប់ការងាររកប្រាក់ចំណូលបំពេញបន្ថែម ព្រៃឈើមានសក្ដានុពលយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ជាពិសេសសម្រាប់ស្ត្រី (សហគ្រិនភាពក៏ដូចជាបុគ្គលិកក្រុមហ៊ុន)។ ផលិតផលព្រៃឈើមួយចំនួនផ្ដល់ជាមូលដ្ឋានការងារពេញលេញ និងទទួលប្រាក់ចំណូលខ្ពស់ អាស្រ័យជំនាញបច្ចេកទេស កម្រិតមូលធនចូលរួម និងតម្រូវការប្រើប្រាស់មានការផ្លាស់ប្ដូរចំណូលពីព្រៃឈើ។

## ១.៣ ការបាត់បង់ព្រៃឈើនៅកម្ពុជា

យោងទៅតាមទិន្នន័យទទួលបានពីរដ្ឋបាលព្រៃឈើ កម្ពុជាធ្លាប់មានគម្របព្រៃរហូតដល់ ៧៣%នៃផ្ទៃដីទូទាំងប្រទេសកាលពីឆ្នាំ១៩៧០ (រដ្ឋបាលព្រៃឈើ ២០១៨)។ ភាគរយនៃគម្របព្រៃឈើត្រូវបានកាត់បន្ថយរហូតដល់៦៤%ក្នុងឆ្នាំ២០០៤ ដែលភាគរយនេះខុសប្លែកគ្នាពីមួយទៅមួយអាស្រ័យលើនិយមន័យព្រៃឈើដែលផ្តល់ដោយស្ថាប័នផ្សេងៗដូចជា FAO, REDD+, UNDP និងMRC ។

ដោយយោងទៅតាមស្ថិតិពីអង្គការហ្វៅបានបង្ហាញអោយឃើញអំពីបម្រែបម្រួលផ្ទៃដីព្រៃឈើនៅកម្ពុជាចាប់ពីឆ្នាំ១៩៩០ដល់ឆ្នាំ២០២០។ វាត្រូវបានគេបកស្រាយថាផ្ទៃដីប្រមាណជា ១១លានហិចតានៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៩០ត្រូវបានថយចុះរហូតមកដល់ឆ្នាំ២០២០។

ក្រាហ្វិកទី១ ៖ បង្ហាញអំពីការប្រែប្រួលផ្ទៃដីព្រៃឈើចន្លោះឆ្នាំ១៩៩០ដល់២០២០

ប្រភព (*http://www.fao.org/faostat/en/#data*)




មូលហេតុនៃការថយចុះទំហំដីព្រៃឈើនៅកម្ពុជាក្នុងចន្លោះឆ្នាំ១៩៩០ដល់២០២០ត្រូវបានរៀបរាប់លម្អិតដូចខាងក្រោម៖

- **កំណើនប្រជាជន**

ចំនួនប្រជាជននៅកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ ប្រមាណប្រហែលពី ៣ លាននាក់ទៅ ១៦ លាននាក់ដូចសព្វថ្ងៃនេះ។ ក្នុងចំណោមប្រជាជន ១៦ លាននាក់នេះ ២ទៅ៣ លាននាក់រស់នៅ

ក្នុងទីក្រុង ខណៈដែលនៅសល់គឺរស់នៅតាមតំបន់ជនបទដោយពឹងផ្អែកជាចម្បងលើធនធានធម្មជាតិ ជាពិសេសព្រៃឈើ និងអនុផលព្រៃឈើសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំប្រមាណ២.៥%ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំក្នុងរយៈពេល ២ ទៅ ៣ ទសវត្សចុងក្រោយនេះ។ អត្រាកំណើនប្រជាជនខ្ពស់អាចបណ្តាលឱ្យមានការកាប់បំផ្លាញព្រៃឈើកាន់តែច្រើន ដោយសារតែតម្រូវការដីសម្រាប់សាងសង់លំនៅស្ថាន និងធ្វើកសិកម្ម។ គម្លាតកាន់តែខ្លាំងរវាងអ្នកមាននិងអ្នកក្រក៏ជាកត្តាជំរុញមួយក្នុងការកាប់បំផ្លាញព្រៃឈើផងដែរ។ អ្នកមានទទួលបានដីកាន់តែច្រើននៅក្នុងតំបន់អំណោយផលកសិកម្ម រីឯអ្នកក្របង្ខំចិត្តឈូសឆាយដីព្រៃសម្រាប់សាងសង់លំនៅស្ថាន និងធ្វើកសិកម្ម។

- **តម្រូវការដីកសិកម្ម**

ក្នុងនាមជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម និងកំណើនប្រជាជនជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាប្រឈមមុខនឹងការបំផ្លាញព្រៃឈើកាន់តែខ្លាំងផងដែរ។ យុទ្ធសាស្រ្តដ៏ល្អមួយសម្រាប់ដោះស្រាយបញ្ហាតម្រូវការដីកសិកម្មគឺធ្វើឱ្យប្រសើរឡើងនូវទិន្នផលកសិកម្មនិងបង្កើនចំនួនដងនៃការដាំដុះជារៀងរាល់ឆ្នាំពោលគឺអនុវត្តកសិកម្មទំនើប។ ព្រៃឈើផ្តល់ផលប្រយោជន៍ជាច្រើនដល់វិស័យកសិកម្ម ដែលជាទូទៅព្រៃឈើចូលរួមចំណែកបង្កើននូវជីវជាតិដី ជារបាំងការពារទឹកជំនន់ រក្សាលំនឹងទឹកភ្លៀង និងចូលរួមចំណែកការពារទីជម្រាល។

- **ការអភិវឌ្ឍន៍ផ្លូវ**

ផ្លូវថ្នល់ជាបច្ចេកវិទ្យាជួយសម្រួលដល់ការការទៅដល់ទៅតាំងឆ្ងាយដែលពីមុនមិនធ្លាប់ត្រូវបានគេធ្វើដំណើរទៅ ឬពិបាកក្នុងការធ្វើដំណើរទៅ។ ទោះយ៉ាងណាផ្លូវថ្មីៗក៏ជះឥទ្ធិពលដល់ព្រៃឈើផងដែរប្រសិនបើគ្មានយុទ្ធសាស្រ្តការពារព្រៃឈើសមស្រប។

- **តំម្រូវការឈើៈ តម្រូវការក្នុងស្រុក និងក្នុងតំបន់**

ក្រៅពីតំរូវការក្នុងស្រុក ទីផ្សារឈើក្នុងតំបន់ក៏កំពុងមានការកើនឡើងផងដែរ។ ព្រៃឈើនៅប្រទេសកម្ពុជាប្រឈមនឹងស្ថានភាពលំបាកក្នុងការការពារនិងអភិរក្សដោយសារ កង្វះខាតធនធានមនុស្សនិងហិរញ្ញវត្ថុ ។ព្រៃឈើកម្ពុជាត្រូវបាននាំចេញទៅប្រទេសម៉ាឡេស៊ី ថៃ និងវៀតណាមកាន់តែច្រើនឡើង ៗ ក្នុងអំឡុងទស្សវត្ស ១៩៩០ និងដើមទសវត្សឆ្នាំ ២០០០ ដែលធ្វើឱ្យរដ្ឋាភិបាលសម្រេចចិត្តផ្អាកការនាំចេញឈើគ្រញូងនិងដើមឈើនៅដើមឆ្នាំ ២០០២។ ដោយយោងតាមកម្មវិធីព្រៃឈើថ្នាក់ជាតិ តម្រូវការឈើនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានសិក្សាដោយរដ្ឋបាលព្រៃឈើកម្ពុជា។

គោលបំណងនៃការសិក្សាគឺដើម្បីទទួលបានចំណេះដឹងអំពីសមត្ថភាពផ្គត់ផ្គង់ព្រៃឈើនិងការកើនឡើងនូវតំរូវការដោយផ្អែកលើគោលនយោបាយអភិរក្សព្រៃឈើ។

- **ធនធានមនុស្ស**

កង្វះបុគ្គលិកសម្រាប់ការគ្រប់គ្រងព្រៃឈើបាននាំឱ្យការលំបាកក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ បុគ្គលិកដែលគ្មានជំនាញព្រៃឈើច្បាស់លាស់បានបង្កការលំបាកច្រើនក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេស។ ធនធានមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺជាតម្រូវការចាំបាច់ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមានក្នុងវិស័យព្រៃឈើ។ ដោយសារតែការគ្រប់គ្រងព្រៃឈើបានផ្លាស់ប្តូរពីគោលបំណងដែលចង់បានត្រឹមតែឈើ និងការគិតគូរដល់បរិស្ថានក្នុងពេលតែមួយ ដូចនេះការលើកកម្ពស់ធនធានមនុស្សគឺមានសារៈសំខាន់ណាស់។ ការសិក្សាគោលនយោបាយជាច្រើនស្តីពីការគ្រប់គ្រងនិងអភិរក្សព្រៃឈើនៅក្នុងប្រទេសចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៩០ និងដើមទសវត្សឆ្នាំ ២០០០ ត្រូវបានដឹកនាំដោយទីប្រឹក្សាបច្ចេកទេសប៉ុន្តែពួកគេភាគច្រើនបានចាកចេញពីប្រទេសបាត់ទៅហើយ។ លើសពីនេះទៅទៀតឯកសារដែលនៅសេសសល់ភាគច្រើនអាចប្រើបានតែភាសាបរទេសតែប៉ុណ្ណោះ ។ យ៉ាងណាក៏ដោយធនធានមនុស្សនៅក្នុងជួររដ្ឋាភិបាលបាននឹងកំពុងអភិវឌ្ឍន៍ជាបណ្តើរ ៗ នូវគោលនយោបាយសម្រាប់ការគ្រប់គ្រងនិងអភិរក្សព្រៃឈើចាប់តាំងពីចុងឆ្នាំ ២០០០ ។ ជំនាញនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពគឺមានសារៈសំខាន់មិនត្រឹមតែរាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងមានសារៈសំខាន់ចំពោះវិស័យឯកជន។

- **ការគាំទ្រផ្នែកហិរញ្ញវត្ថុ**

ការគ្រប់គ្រងព្រៃឈើគឺជាបញ្ហាប្រឈមចម្បងសម្រាប់ អភិវឌ្ឍន៍វិស័យព្រៃឈើនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ កង្វះថវិកាគឺក៏ជាបញ្ហាសំខាន់ដែលកើតមានជាបន្តបន្ទាប់។ ឧទាហរណ៍គម្រោងអភិរក្សគ្រាប់ពូជឈើ កម្មវិធីអភិរក្សសត្វខ្លា និងការអភិវឌ្ឍន៍ចំការដាំដើមឈើក៏ត្រូវបានបញ្ឈប់ដោយសារកង្វះថវិកា សម្រាប់បន្តអនុវត្តកម្មវិធីទាំងនោះ។ ចាប់តាំងពីកំណែទម្រង់រដ្ឋបាលព្រៃឈើមកទាំងរដ្ឋបាលព្រៃឈើ និងរាជដ្ឋាភិបាល បានគ្រោងបោះបង្គោលព្រំប្រទល់ព្រៃដែលជាបញ្ហាអាទិភាពប៉ុន្តែកង្វះជំនួយហិរញ្ញវត្ថុបានពន្យារពេលការងារនេះ។ទោះជាយ៉ាងណាក៏ដោយ យើងនៅតែមានថវិកាជាតិនិងជំនួយហិរញ្ញវត្ថុមួយចំនួនដែលបានមកពីស្ថាប័នផ្សេងៗដូចជា DANIDA, DFID, NZAid, FAO និងជំនួយផ្សេងទៀត។ រដ្ឋបាលព្រៃឈើ បានចាប់ផ្តើមគ្រោងបោះបង្គោលនៅតំបន់ដែលជាអទិភាពនៅក្នុងប្រទេស។

- **ផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍសេដ្ឋកិច្ច**

ផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍសេដ្ឋកិច្ចដូចជាការអភិវឌ្ឍទីក្រុង និង ការបង្កើតតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចពិសេស និងតំបន់សម្បទានសេដ្ឋកិច្ចព្រៃឈើបានចូលរួមចំណែកកាត់បន្ថយគម្របព្រៃឈើនៅកម្ពុជា។ ឧទាហរណ៍ដីសម្បទានសេដ្ឋកិច្ច គឺជាការជួលដីក្នុងរយៈពេលវែងដែលអនុញ្ញាតឱ្យអ្នកទទួលផលមានសិទ្ធិក្នុងការឈូសឆាយដីព្រៃដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម។ រហូតមកដល់បច្ចុប្បន្នដីសម្បទានសេដ្ឋកិច្ច ត្រូវបានផ្តល់សិទ្ធិសម្រាប់សកម្មភាពផ្សេងៗរួមមានចំការដំណាំខ្នាតធំ ការចិញ្ចឹមសត្វនិងសាងសង់រោងចក្រដើម្បីដំណើរការកែច្នៃផលិតផលកសិកម្ម។ ម្យ៉ាងវិញទៀត ក៏នៅមានដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានផ្តល់សម្រាប់គោលបំណងរុករករ៉ែ កំពង់ផែ និងនេសាទផងដែរដែលចូលរួមចំណែកក្នុងការបាត់បង់ព្រៃឈើ។ ដីសម្បទានសេដ្ឋកិច្ចនៅតែបន្តជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពរស់នៅរបស់សហគមន៍ជនបទដែលពឹងផ្អែកលើធនធានព្រៃឈើសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ជារួម បញ្ហាដែលកើតចេញពីដីសម្បទានសេដ្ឋកិច្ចលើវិស័យព្រៃឈើមានជាអាទិ៍៖ ការទន្ទ្រានដី ប៉ះពាល់ជីវភាពប្រជាជនដែលពឹងអាស្រ័យលើធនធានព្រៃឈើ ប៉ះពាល់ដល់វប្បធម៌ និងទំនៀមទំលាប់ និងបញ្ហាបរិស្ថានផ្សេងៗ។

## ១.៤ ការរៀបចំស្ថាប័ន និងអភិបាលកិច្ចព្រៃឈើ

ដូចដែលបានបញ្ជាក់ខាងលើ ព្រៃឈើនៅកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន។ គេកត់សំគាល់ថាអភិបាលកិច្ចព្រៃឈើនៅកម្ពុជាត្រូវបានឆ្លងកាត់របបដឹកនាំ និងប្រព័ន្ធគ្រប់គ្រងជាច្រើន។ កំណត់ត្រាមួយបានបង្ហាញថាវិស័យព្រៃឈើនៅកម្ពុជាបានចាប់ផ្តើមប្រព័ន្ធគ្រប់គ្រងរបស់ខ្លួននៅក្នុងឆ្នាំ ១៨៩៨ ក្រោយ៣៦ឆ្នាំ(១៨៦៣-១៨៩៨) នៃការចាប់ផ្តើមនៃអាណានិគមបារាំងដែលបានគ្រប់គ្រងនៅឥណ្ឌូចិននិងកម្ពុជា (FA, ២០០៨)។ ក្នុងអំឡុងមុនពេលនៃការគ្រប់គ្រងរបស់អាណានិគមបារាំងមកលើកម្ពុជា ព្រៃឈើត្រូវបានប្រើប្រាស់យ៉ាងអានាធិបតេយ្យ និងគ្មានការគ្រប់គ្រងច្បាស់លាស់។ ក្រោមអាណានិគមបារាំង មានវិធានកាគ្រប់គ្រងព្រៃឈើយ៉ាងតឹងរឹងនៅប្រទេសកម្ពុជាតែធ្វើឱ្យមានផលប៉ះពាល់ដល់ការប្រើប្រាស់ព្រៃឈើជាលក្ខណៈប្រពៃណី។ ក្រោយមកប្រព័ន្ធនេះត្រូវបានផ្លាស់ប្តូរដែលអនុញ្ញាតឱ្យការប្រើប្រាស់បែបប្រពៃណីសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ទោះបីជាអាណានិគមន៍បារាំងនៅកម្ពុជាត្រូវបានបញ្ចប់ក្នុងឆ្នាំ ១៩៥៤ ក៏ដោយក៏ប្រព័ន្ធគ្រប់គ្រងព្រៃឈើរបស់បារាំងនៅតែត្រូវបានអនុវត្តជាបន្តបន្ទាប់រហូតដល់ឆ្នាំ ១៩៧០ ដោយពេលនោះប្រទេសកម្ពុជាបានចូលទៅក្នុងភាពវឹកវរនិងសង្គ្រាមស៊ីវិល (របបប៉ុលពត)។ ប្រព័ន្ធគ្រប់គ្រងព្រៃឈើក្រោមអាណានិគមបារាំងអាចត្រូវបានគេចាត់ទុកថាជាអភិបាលកិច្ចមជ្ឈឹម ពីព្រោះការសម្រេចចិត្តទាំងអស់ស្ថិតនៅថ្នាក់កណ្តាល (ថ្នាក់ជាតិដែលមានមូលដ្ឋាននៅភ្នំពេញ) បានធ្វើការសំរេចចិត្តទាំងអស់ទាក់ទងនឹងការដេកហូត និងការស្តារព្រៃឈើឡើងវិញ។ ក្នុងអំឡុងឆ្នាំ

១៩៧០ ដល់ ១៩៨០ ព្រៃឈើ និងធនធានធម្មជាតិនៅទូទាំងប្រទេសពុំមានការគ្រប់គ្រងច្បាស់លាស់ឡើយ លើកលែងតែក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ដែលធនធានធម្មជាតិទាំងអស់ត្រូវបានគ្រប់គ្រងដោយរបបប៉ុលពត ដែលក្នុងសម័យនោះគ្រប់វិស័យសាធារណៈស្ថិតនៅក្រោមការសម្រេចចិត្តដាច់ខាតរបស់មេដឹកនាំជាន់ខ្ពស់នៃរបបនោះ។ ប្រព័ន្ធគ្រប់គ្រងព្រៃឈើក្នុងរបបខ្មែរក្រហម មានប្រព័ន្ធគ្រប់គ្រងពីលើចុះក្រោម ខណៈពេលដែលក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានិងក្រោយមកហៅថារដ្ឋកម្ពុជា (១៩៧៩-១៩៩៣) ប្រព័ន្ធគ្រប់គ្រងព្រៃឈើគឺស្ថិតនៅលើការសម្រេចចិត្តថ្នាក់កណ្តាល(ថ្នាក់ជាតិ) ដែលអនុវត្តការប្រមូលផលឈើប្រចាំឆ្នាំ។ ដោយមានអនុសាសន៍បច្ចេកទេសពីនាយកដ្ឋានព្រៃឈើ និងសត្វព្រៃ និង ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឈើនិងអនុផលព្រៃឈើ (ជាទូទៅមានតែឈើប៉ុណ្ណោះ) ត្រូវបានដកហូតយោងទៅតាមផែនការរបស់រដ្ឋាភិបាលកណ្តាល។ គួរបញ្ជាក់ផងដែរថា ប្រព័ន្ធគ្រប់គ្រងព្រៃឈើនេះគឺជាការគ្រប់គ្រងគ្រងរបស់រដ្ឋាភិបាលកណ្តាលដែលស្ថិតក្រោមផែនការប្រាំឆ្នាំម្តង។យ៉ាងណាមិញ អភិបាលកិច្ចគ្រប់គ្រងព្រៃឈើ ត្រូវបានផ្លាស់ប្តូរនៅក្នុងឆ្នាំ ១៩៩០ ។ ប្រព័ន្ធគ្រប់គ្រងព្រៃឈើថ្មីត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដែលប្រព័ន្ធត្រូវបានហៅថា " ប្រព័ន្ធគ្រប់គ្រងសម្បទានព្រៃឈើ" ចាប់ផ្តើមពីឆ្នាំ ១៩៩៣។ ជាមួយនឹងសេចក្តីសំរេចរបស់រដ្ឋាភិបាល តំបន់សម្បទានព្រៃឈើត្រូវបានធ្វើឡើង ដោយគ្មានការពិគ្រោះយោបល់ពីសហគមន៍មូលដ្ឋាន។ ក្រោយមកដោយសារលទ្ធិប្រជាធិបតេយ្យកាន់តែត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០១ ម្ចាស់សម្បទានព្រៃឈើទាំងអស់ត្រូវបានណែនាំឱ្យបង្កើតផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើសម្រាប់ការគ្រប់គ្រងដីសម្បទានព្រៃឈើហើយនៅពេលនោះសហគមន៍មូលដ្ឋានបានចូលរួមក្នុងដំណើរការគ្រប់គ្រងព្រៃឈើ។ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ ត្រូវបានស្នើសុំឱ្យដាក់បញ្ចូលនូវការដោះស្រាយបញ្ហាតាមលំដាប់ថ្នាក់ផ្សេងៗគ្នា និងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ។ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ ត្រូវបានតម្រូវឱ្យដាក់បង្ហាញជាសាធារណៈក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ជាពិសេសសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិល។ ។ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ និងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានស្នើឡើងក្នុងគោលបំណងអំពីតម្លាភាពក្នុងការប្រមូលផលព្រៃឈើ និងការបែងចែកផលប្រយោជន៍។ ក្រៅពីការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ សហគមន៍មូលដ្ឋានត្រូវបានផ្តល់សិទ្ធិក្នុងការបង្កើតសហគមន៍ព្រៃឈើរបស់ពួកគេដែលមានទីតាំងនៅជិតឃុំឬភូមិដែលពួកគេរស់នៅ។ ក្នុងឆ្នាំ ២០០៣ អនុក្រឹត្យស្តីអំពីសហគមន៍ព្រៃឈើត្រូវបានផ្តល់សច្ចាប័ននិងចូលជាធរមានសម្រាប់ការអនុវត្តនៅទូទាំងប្រទេស។ នេះសបញ្ជាក់ឱ្យឃើញថាអភិបាលកិច្ចក្នុងការគ្រប់គ្រងព្រៃឈើបែបវិមជ្ឈការ ត្រូវបានដាក់បញ្ចូលខ្លះៗទៅក្នុងក្នុងការគ្រប់គ្រងព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១.៥ សារៈសំខាន់នៃព្រៃឈើ

ព្រៃឈើផ្តល់ឲ្យយើងនូវធនធានដ៏សំខាន់ៗ ដូចជាអាហារ, អុសសម្រាប់ដុតកម្តៅ, សម្ភារៈសំណង់, ស្មៅចំណីសត្វ, ឱសថ, និងច្រើនទៀត។ ដើមឈើ និងព្រៃឈើក៏មានតួនាទីសំខាន់ផងដែរក្នុងការរក្សាស្ថិរភាពនៃបរិស្ថានល្អ។ វាធ្វើឲ្យខ្យល់និងទឹកមានសភាពស្អាត, បង្ការសំណឹកដី និងទឹកជំនន់, បង្កើនជីជាតិដី, ផ្តល់ជម្រកសម្រាប់សត្វបក្សា សត្វបក្សី និងរុក្ខជាតិ, ផ្តល់ម្លប់, និងធ្វើឲ្យសហគមន៍យើងស្រស់បំព្រង។

ដើម្បីឲ្យព្រៃឈើបន្តផ្តល់នូវធនធាន និងរក្សាស្ថិរភាពបរិស្ថានល្អ មនុស្សត្រូវតែថែទាំព្រៃឈើឲ្យបានល្អ, ចាត់ចែងយ៉ាងយុត្តិធម៌, និងប្រើប្រាស់ដោយប្រយ័ត្នប្រយែង។ ប៉ុន្តែដោយហេតុថាឧស្សាហកម្មក៏មើលឃើញពីផលប្រយោជន៍នៃធនធានព្រៃឈើដូចសហគមន៍ដែរ និងដោយហេតុថាជួនកាលមនុស្សចង់យកដីក្នុងព្រៃមកប្រើប្រាស់ក្នុងបំណងផ្សេងៗ ទើបព្រៃឈើនៅទូទាំងពិភពលោកកំពុងត្រូវបានកាប់រំលំលឿនជាងពេលវេលាដែលវាអាចដុះមកវិញ។ ជួនកាលក្រុមហ៊ុនឈើ ឬឧស្សាហកម្មដទៃទៀតដែលរកស៊ីកាប់ព្រៃឈើ ដូចជាការជីករ៉ែជាដើម បានផ្តល់ប្រភពចំណូលដល់ប្រជាជនដែលកំពុងត្រូវការវាយ៉ាងខ្លាំង។

ទោះជាយ៉ាងនេះក្តី គេអាចស្វែងរកតុល្យភាពរវាងតម្រូវការប្រើប្រាស់ដីនិងធនធាន និងតម្រូវការនៃការការពារធនធានទាំងនេះសម្រាប់អនាគតបាន។ នៅពេលមានការប្រើប្រាស់ធនធានច្រើនពេក វាបង្កគ្រោះថ្នាក់យ៉ាងធំ និងយូរអង្វែង។ សហគមន៍ជាច្រើនដែលបានរស់នៅអាស្រ័យព្រៃឈើជាច្រើនជំនាន់មកហើយ ដឹងថាពួកគេនឹងរងគ្រោះយ៉ាងធ្ងន់ធ្ងរប្រសិនបើព្រៃឈើត្រូវបានប្រើប្រាស់ ឬកាប់ឆ្ការច្រើនពេក។

### ១.៥.១ ព្រៃឈើធម្មជាតិ

ព្រៃឈើធម្មជាតិត្រូវបានអ្នកជំនាញផ្នែកព្រៃឈើសម្គាល់ថា ជាព្រៃដែលដុះដោយឯកឯងតាំងពីយូរយារមកហើយ។ ព្រៃឈើធម្មជាតិថែរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី មិនត្រូវបានបំផ្លាញរេចរឹល និងមានជីវចម្រុះដែលរស់នៅតាមធម្មជាតិរបស់វា។ ព្រៃប្រភេទនេះច្រើនស្ថិតនៅតាមតំបន់ត្រូពិច ដែលជាតំបន់ក្តៅហើយសើម មានទំហំធំ ព្រៃក្រាស់ និងខ្ពស់ៗ ។ ជាទូទៅព្រៃធម្មជាតិខុសពី ព្រៃសហគមន៍ ដែលព្រៃសហគមន៍ជាព្រៃដែលធ្វើការដាំដុះដើម្បីរក្សាទុកបម្រើផល ប្រយោជន៍សហគមន៍។ ព្រៃធម្មជាតិដែលឆ្លងកាត់ការកាប់រុករានបំផ្លិចបំផ្លាញដោយប្រការណាមួយ រហូតបាត់បង់ប្រព័ន្ធអេកូឡូស៊ីដែលទ្រទ្រង់ព្រៃឈើ និងបាត់បង់ជីវចម្រុះព្រៃនេះនឹងលែងជាព្រៃធម្មជាតិទៀតហើយ។ ប៉ុន្តែបើត្រឡប់ជាធ្វើការដាំដុះ ការពារទុករាប់រយឆ្នាំលុះព្រៃនោះកើតឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីមានជីវចម្រុះ ទើប

ព្រៃនោះអាចចាត់ថាជាព្រៃធម្មជាតិជាថ្មីម្តងទៀត។ នៅលើពិភពលោកនេះ គ្រប់ជីវសាស្ត្រទាំងអស់ត្រូវការព្រៃឈើជាចាំបាច់ណាស់។ ដូច្នេះគ្មានអ្វីដែលគ្មានទំនាក់ទំនងនឹងព្រៃ ឈើនោះទេ។

### ១.៥.២ ព្រៃឈើធម្មជាតិ និងជីវចម្រុះ

ជីវចម្រុះរស់នៅពឹងផ្អែកទាំងស្រុងទៅលើព្រៃឈើ។ ក្នុងនោះមានដូចជាពពួកថនិកសត្វ ទាំងតូចធំ ពពួកសត្វល្មូន ពពួកសត្វស្លាបជាដើម។ សត្វគ្រប់ប្រភេទវាអាចរស់នៅលាក់ខ្លួន បង្កើតពូជពង្សតាមអំបូររបស់វានៅទីនោះ ។ សត្វស្លាបទាំងឡាយរស់នៅពឹងផ្អែកលើព្រៃឈើ អាស្រ័យចំណីជាអនុផលព្រៃឈើ ឬជាសាច់សត្វដទៃទៀត ។ ឯពពួកសត្វចតុបាតខ្លះវាស៊ីស្លឹករុក្ខជាតិ ខ្លះប្រហារសត្វប្រភេទផ្សេងស៊ីជាអាហារ។ យើងក៏អាចនិយាយបានទៀតថា ពួកវាមានចំណីដ៏សម្បូរបែប និងស៊ីគ្នាមានលក្ខណៈវិលជាប្រព័ន្ធពីតូចទៅធំជាដើម ។ ក្រៅពីផ្តល់ជាជម្រកដ៏ប្រសើរសម្រាប់សត្វគ្រប់ប្រភេទ វាក៏នៅមានផ្តល់នូវឧស្ម័នអុកស៊ីសែនសម្រាប់សត្វទាំងនោះដកដង្ហើមផងដែរ ។

### ១.៥.៣ ព្រៃឈើធម្មជាតិ និងបរិយាកាស

ព្រៃឈើមានចំណែកធំធេងណាស់ក្នុងការជួយឱ្យបរិយាកាសមានសភាពល្អប្រសើរ ។ ព្រៃឈើបង្កឱ្យមានភ្លៀងធ្លាក់ទៀងទាត់ ស្រូបយកឧស្ម័នកាបូនិចដែលជាជាតិពុលក្នុងស្រទាប់ខ្យល់ ហើយបញ្ចេញមកវិញនូវឧស្ម័ន អុកស៊ីសែន( នាពេលថ្ងៃ ) ដែលមនុស្សសត្វត្រូវការដកដង្ហើមដើម្បីរស់ ។ ព្រៃឈើបានស្រូបយកពន្លឺព្រះអាទិត្យ( កម្តៅ )ធ្វើឱ្យកម្តៅមានលំនឹង និងមិនក្តៅខ្លាំង។ ពោលព្រៃឈើជួយរក្សាបរិយាកាសឱ្យត្រជាក់ជានិច្ច ព្រមទាំងជួយកាត់បន្ថយការរំខានដោយសូរសម្លេង ខ្យល់កខ្វក់ ឬពុល និងកាត់បន្ថយបាននូវគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះជាដើម។

### ១.៥.៤ ព្រៃឈើធម្មជាតិ និងធនធានក្នុងដី

ព្រៃឈើមានចំណែកធំណាស់ក្នុងការជួយទប់ស្កាត់ការហូរច្រោះដី និងរក្សានិន្នរ ភាពទឹកក្រោមដីជាដើម ។ ឫសឈើដែលចាក់ចូលយ៉ាងជ្រៅទៅក្នុងដី បានទប់ដីមិនឱ្យបាក់ស្រុតទៀតផង ។ ម្យ៉ាងទៀតទឹកមួយផ្នែក បានស្រូបយកដើម្បីចិញ្ចឹមដើមស្លឹករបស់វា ។ ស្លឹក និងផ្លែផ្សេងៗរបស់វាដែលជ្រុះមកលើដីនឹងពុកផុយរលួយធ្វើឱ្យដីមានជីជាតិ ។ រីឯធនធានរ៉ែក្នុងដីមួយចំនួនកកើតឡើងដោយសារចំណែករលួយនៃរុក្ខជាតិ ដែលកប់ក្នុងដីរាប់ពាន់ម៉ឺនឆ្នាំកន្លងមក ។

### ១.៥.៥ ព្រៃឈើធម្មជាតិ និងមនុស្ស

មនុស្ស និងព្រៃឈើមានទំនាក់ទំនងគ្នាជាប្រព័ន្ធមិនអាចខ្វះបាន ឬអាចថាជាផ្នែក មួយនៃជីវិតមនុស្ស ។ មនុស្សអាចទាញយកផលប្រយោជន៍ពីព្រៃធម្មជាតិ ប៉ុន្តែមិនមែនមានន័យថាទាញយកផលប្រយោជន៍រហូតបាត់បង់ ទាំងព្រៃបាត់បង់ទាំងប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះនោះទេ។ ព្រៃឈើធម្មជាតិ

អាចជាតំបន់ទេសចរណ៍ធ្វើឱ្យអារម្មណ៍ជ្រះថ្លាអាចជា ប្រភពឱសថព្យាបាលជម្ងឺ អាចជាប្រភពអាហារមួយចំនួនតាមរយៈផលល្លានុផលជាផ្លែ ឬគ្រាប់ធញ្ញជាតិសាច់ជាដើម ។ ប៉ុន្តែមនុស្សត្រូវ ចេះទាញយកសក្តានុពលនោះឱ្យមាននិរន្តរភាព ដូចជាត្រូវកាប់ដើមឈើដែលគ្រប់អាយុ និងត្រូវដាំឡើងវិញ ទើបព្រៃឈើធម្មជាតិនោះស្ថិតស្ថេរបាន ។ នៅមានផលប្រយោជន៍ជាប្រយោលច្រើនផ្សេងទៀត ដូចជាទទួលបានខ្យល់អាកាសល្អ កម្តៅសមស្របជាដើម ។ ភាពស្រស់បំព្រងនៃរុក្ខជាតិទាំងឡាយ គឺជាភាពស្រស់បំព្រងនៃជីវិតរបស់មនុស្ស ។ មនុស្សចូលរួមការពារព្រៃឈើធម្មជាតិ គឺមានន័យថាមនុស្សចូលរួមការពារបរិស្ថាន ហើយមានន័យថាចូលរួមការពារជីវិតសត្វ និងមនុស្សខ្លួនឯងផងដែរ។

### ១.៥.៦ ផលប៉ះពាល់នៃការបាត់បង់ព្រៃឈើធម្មជាតិ

មានផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលជាច្រើនមកលើមនុស្ស សត្វ និងបរិស្ថាន។ បាត់បង់ព្រៃឈើគឺបាត់បង់ប្រភពឱសថ និងចំណីអាហារ បាត់បង់ជីវចម្រុះ ដោយសារគ្មានជម្រក គ្មានចំណី និងមានការបរបាញ់បាត់បង់តំបន់ទេសចរណ៍ដែលជាឧស្សាហកម្មគ្មានផ្សែងអាចទាញយកផលប្រយោជន៍មិនចេះរីងស្ងួតដីបាត់បង់ជីជាតិធ្វើឱ្យមានផលប៉ះពាល់ដល់ការដាំដុះ រដូវមិនទៀង ធ្វើឱ្យផ្នែកកសិកម្មជួបផលលំបាក ងាយកើតឡើងគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួតជាដើម ការហូរច្រោះ នាំជាតិពុលទៅក្នុងទឹកប៉ះពាល់ដល់ការប្រើប្រាស់ទឹក ប៉ះពាល់ដល់ជីវិតធនធានក្នុងទឹក ដូចជាមច្ឆាជាតិ ឡើងកម្តៅផែនដី ព្រោះបាត់បង់អ្នកស្រូបកម្តៅ និងមានវត្តមានឧស្ម័នពុលបំផ្លាញស្រទាប់អូហ្សូនដែលទប់កម្តៅ មានឧស្ម័នពុលច្រើនបំផ្លាញសុខភាពមនុស្សសត្វ កើតឡើងវិបត្តិសេដ្ឋកិច្ចទាំងក្នុងគ្រួសារ និងជាតិ ពោលគឺកើនឡើងនូវភាពក្រីក្រ ។

### ១.៥.៧ ព្រៃឈើ និងសុខភាព

ព្រៃឈើជួយគាំទ្រសុខភាពមនុស្សនៅគ្រប់ទីកន្លែង។ សូម្បីតែមនុស្សដែលរស់នៅឆ្ងាយពីព្រៃឈើ ឬក្នុងតំបន់ដែលមានការបំផ្លាញព្រៃឈើយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏ពួកគេពឹងផ្អែកលើវត្ថុផ្សេងៗដែលព្រៃឈើផ្តល់ឲ្យដែរ។ នៅពេលព្រៃឈើត្រូវបានកាត់បន្ថយឬបំផ្លាញ សុខភាពសហគមន៍ក៏ទទួលការគំរាមកំហែងព្រោះដំណើរការនិងមុខងារទាំងឡាយរបស់ដើមឈើក្នុងការជួយគាំទ្រសុខភាពមនុស្សមិនត្រូវបានធ្វើចប់សព្វគ្រប់ទេ។

### ១.៥.៨ ព្រៃឈើ និងទឹក

មនុស្សមួយចំនួនជឿថា ដើមឈើទាក់ទាញទឹកភ្លៀង និងទប់ទឹកនៅក្បែរដី។ អ្នកខ្លះទៀតជឿថាដើមឈើប្រើប្រាស់ទឹកច្រើនជាងការបញ្ចេញមកវិញ ដូច្នេះវារាំងដល់ការដាំដំណាំ។ ជំនឿទាំងពីរនេះអាចត្រឹមត្រូវដូចគ្នា អាស្រ័យលើប្រភេទដើមឈើ, កន្លែងដែលដាំវា, និងលក្ខខណ្ឌដទៃទៀត។

ដីដែលសម្បូរព្រៃឈើ និងឫសឈើជ្រៅៗ ដើរតួជាអ្នកច្រោះទឹក។ នៅពេលដែលថ្នាំសម្លាប់សត្វល្អិត, លោហៈធ្ងន់, និងសារជាតុគីមីពុលដទៃទៀត, ធ្វើឲ្យទឹកលើដី និងក្រោមដីក្លាយជាកខ្វក់ ព្រៃឈើជួយច្រោះសារជាតុទាំងនេះចេញពីទឹក។ ទឹកដែលបានច្រោះរួច ហូរចូលក្នុងអណ្តូងរបស់យើង, ខ្សែទឹក, បឹង, ហើយធ្វើឲ្យទីជម្រាល និងប្រជាជនដែលរស់ក្នុងទីជម្រាល មានសុខភាពល្អ។ បើគ្មានព្រៃឈើសម្រាប់ការពារប្រភពទឹកទេ នោះនឹងមានទឹកតិចតួចសម្រាប់ផឹកនិងងូត។ ដោយមូលហេតុទាំងអស់នេះ ជាការប្រសើរបំផុតគឺត្រូវទុកដើមឈើឲ្យដុះចោល ជាជាងការកាប់រំលំវា ជាពិសេសបើទឹករបស់អ្នកមានច្រើននិងស្អាត។

ប៉ុន្តែដើមឈើប្រភេទខ្លះ ជាពិសេសដើមឈើដែលលូតលាស់ឆាប់រហ័ស និងមិនមែនជាដើមឈើក្នុងតំបន់វាទេ នោះវាអាចស្រូបយកទឹកច្រើន។ សម្រាប់កសិករ និងអ្នកដទៃទៀតដែលចង់ការពារប្រភពទឹក ជាការសំខាន់គួរសង្កេតមើលប្រភេទផ្សេងៗគ្នានៃដើមឈើដែលស្រូបទឹក និងគួរសម្រេចចិត្តដោយប្រុងប្រយ័ត្នថាដើមឈើប្រភេទណាដែលគួរដាំ។

## ១.៥.៩ ព្រៃឈើ និងអាកាសធាតុ

ព្រៃឈើមានឥទ្ធិពលយ៉ាងសំខាន់លើអាកាសធាតុ និងបរិយាកាស(អាកាសធាតុនៅទីកន្លែងមួយក្នុងរយៈពេលយូរអង្វែង)។ ព្រៃឈើជួយសម្រួលអាកាសធាតុ ដោយធ្វើឲ្យខ្យល់ក្តៅចុះត្រជាក់ និងមានសំណើមខ្លះ, និងធ្វើឲ្យខ្យល់ត្រជាក់មានកម្តៅ និងស្ងួតខ្លះ។ ដើមឈើការពារផ្ទះសម្បែងនិងដំណាំពីខ្យល់ខ្លាំងនិងថ្ងៃក្តៅ និងផ្តល់ជម្រកការពារពីភ្លៀងធំ។

ក្នុងទ្រង់ទ្រាយធំ ព្រៃឈើប្រឆាំងនឹងការឡើងកម្តៅផែនដី តាមរយៈស្រូបយកសារជាតុពុល។ ធ្វើដូចនេះជួយរក្សាបរិយាកាសនៃផែនដីទាំងមូលឲ្យមានសភាពសមរម្យ។ នៅពេលយើងបាត់បង់ព្រៃឈើក្នុងទ្រង់ទ្រាយធំ ការគំរាមកំហែងនៃគ្រោះមហន្តរាយធម្មជាតិនឹងកើនឡើង ដូចជាព្យុះហ៊ីរ៉ីយែន, ភាពរាំងស្ងួត, និងរលកក្តៅ។

## ១.៥.១០ ព្រៃឈើបង្ការសំណឹកដី និងកាត់បន្ថយទឹកជំនន់

ដើមឈើបង្ការសំណឹកដី និងកាត់បន្ថយជំនន់ តាមរយៈការបន្ថែមស្លឹកឈើទៅលើដី, ផ្តល់ម្លប់ដល់រុក្ខជាតិដែលដុះក្រោមដើមឈើ, និងទប់ដីដោយឫសរបស់វា។ ព្រៃឈើបន្ថយល្បឿនទឹកភ្លៀងហូរ និងបំបែកខ្សែទឹកពាសពេញដីដូច្នេះវានឹងជ្រាបទៅក្នុងដីជាជាងហូរហៀរលើដី។ នៅពេលព្រៃឈើត្រូវបានកាប់បំផ្លាញ ដីត្រូវបានហូរដាច់ទៅក្នុងទន្លេ និងខ្សែទឹក។ នៅពេលមានព្យុះមកដល់ ដីមិនអាចស្រូបយក និងរក្សាទុកទឹកភ្លៀងទៀតទេ។ ផ្ទុយទៅវិញ ទឹកភ្លៀងនឹងហូរកាន់តែលឿនឆ្លងកាត់ផ្ទៃដី រួចបង្កជាជំនន់។ ការថែរក្សាដើមឈើនិងព្រៃឈើ គឺជាការសំខាន់ក្នុងការការពារលំហូរធម្មជាតិនៃទឹកឆ្លងកាត់ទីជម្រាល។ (សម្រាប់ព័ត៌មានអំពីសកម្មភាពសូមមើល តើទឹកភ្លៀងធ្វើអ្វីខ្លះមកលើដីវាល។

### ១.៥.១១ ព្រៃឈើ និងជីវៈចម្រុះ

នៅក្នុងព្រៃ យើងអាចមើលឃើញពីសំណាញ់នៃជីវិត បានយ៉ាងងាយ ព្រោះព្រៃឈើមានរុក្ខជាតិ និងសត្វជាច្រើនប្រភេទខុសប្លែកពីគ្នា។ ភាពចម្រុះនៃជីវិតបែបនេះ ការពារសុខភាពមនុស្សតាមវិធីច្រើនយ៉ាង។ សត្វឃ្មុំនិងសត្វល្អិតដទៃទៀតដែលរស់នៅលើដើមឈើ ពោយលម្អងលើដំណាំ ដូច្នេះដំណាំនឹងចេញផ្កានិងផ្លែ។ សត្វឱម៉ាល់និងស្រមោច ស៊ីសត្វល្អិតទាំងឡាយដែលស៊ីដំណាំ។ សត្វប្រចៀវនិងសត្វស្លាប ស៊ីសត្វមូសដែលចម្លងជំងឺគ្រុនចាញ់, ជំងឺគ្រុនលឿង, និងជំងឺដទៃទៀត។ សត្វព្រៃដទៃទៀត គ្រប់គ្រងកណ្តុរ, ចៃ, សត្វ, និងរុយ ដោយការចាប់ស៊ី និងដេញវាចេញឲ្យឆ្ងាយ និងបង្ការវាមិនឲ្យចម្លងជំងឺ។

នៅពេលសាងសង់ផ្ទះសម្បែងនៅក្នុងឬនៅក្បែរព្រៃឈើដែលមានការកាប់បំផ្លាញ ចំនួននិងភាពចម្រុះនៃសត្វ មានការថយចុះ ព្រោះប្រភពជម្រកនិងអាហាររបស់ពួកវា លែងសូវសម្បូរនិងលែងសូវមានភាពចម្រុះ។ ម្យ៉ាងទៀតសត្វដែលនៅសល់ក្នុងព្រៃ ត្រូវបានបង្ខំឲ្យរស់នៅក្បែរប្រជាជន។ ធ្វើដូចនេះនាំឲ្យមានឱកាសខ្ពស់នៃការចម្លងជំងឺសត្វទៅកាន់មនុស្ស។ តាមរយៈការថែរក្សាព្រៃឲ្យបានគ្រប់គ្រាន់ដើម្បីជួយទ្រទ្រង់ភាពចម្រុះនៃរុក្ខជាតិនិងសត្វ គឺយើងការពារសុខភាពមនុស្សដែរ។

### ១.៥.១២ ព្រៃឈើ អាហារ អុសដុត និងឱសថ

ព្រៃឈើមានផ្លែឈើ, គ្រាប់ផ្លែឈើ, គ្រាប់ពូជ, ឫសឈើ, សត្វល្អិត, និងសត្វព្រៃដ៏ច្រើនសម្បូរបែប សម្រាប់ជាតម្រូវការរបស់មនុស្ស។ នៅពេលព្រៃឈើនៅសល់តិច វាច្រើនតែបណ្តាលឲ្យមានភាពអត់ឃ្លាន, កង្វះអាហារូបត្ថម្ភ, និងជំងឺ។ ប្រជាជនដែលពឹងផ្អែកលើធនធានទាំងនេះ ត្រូវរកវិធីផ្សេងៗដើម្បីរស់។ នៅពេលអាហារនិងឱសថពីព្រៃឈើបានបាត់បង់ ចំណេះវិជ្ជាក្នុងការរៀបចំ និងប្រើប្រាស់វាក៏បាត់បង់ដែរ។ បែបនេះមានន័យថា ការបាត់បង់ព្រៃឈើ នាំឲ្យបាត់បង់ចំណេះវិជ្ជា និងទំនៀមទម្លាប់សំខាន់ៗផងដែរ។

នៅកន្លែងដែលខ្វះខាតធនធាន មនុស្សជួនកាលមានអារម្មណ៍ថាត្រូវបានបង្ខំឲ្យជ្រើសរើសរវាងការទុកដើមឈើ និងការកាប់ដើមឈើដើម្បីដាំដំណាំ។ ប៉ុន្តែការទុកដើមឈើខ្លះៗគឺជាការសំខាន់ ទោះបីកសិករត្រូវកាប់ឆ្ការព្រៃយកដីដាំដំណាំក៏ដោយ។ ក្នុងតំបន់ដែលកសិករត្រូវការដីក្នុងព្រៃ ជាការសំខាន់គឺត្រូវរក្សាតុល្យភាពរវាងព្រៃឈើ និងកសិកម្ម។

### ១.៥.១៣ ព្រៃឈើ និងយេនឌ័រ

ភាគច្រើនគឺស្ត្រីនិងកុមារដែលជាអ្នកធ្វើការងារដ៏លំបាកក្នុងការស្វែងរកនិងលីសែងអុសយកមកដុត។ បន្ទុកការងារនេះក្នុងរយៈពេលច្រើនឆ្នាំ នឹងបណ្តាលឲ្យមានបញ្ហាសុខភាព។ នៅពេលមានការបំផ្លាញព្រៃឈើ មនុស្សត្រូវធ្វើដំណើរទៅទីឆ្ងាយៗដើម្បីស្វែងរកអុស។ បែបនេះធ្វើឲ្យពួកគេមានពេលវេលាតិចតួចសម្រាប់ធ្វើការងារសំខាន់ៗដទៃទៀតនៅឯផ្ទះ និងទៅសាលារៀន។ ស្ត្រីនិងកុមារក៏អាចប្រឈមនឹងអំពើហឹង្សាផ្លូវកាយនិងផ្លូវភេទផងដែរ នៅពេលពួកគេធ្វើដំណើរទៅស្វែងរកអុស។ ដោយមូលហេតុនេះហើយ ទើបនៅតំបន់ខ្លះស្ត្រីនិងក្មេងស្រីធ្វើដំណើរជាក្រុមទៅស្វែងរកឧសក្នុងពេលថ្ងៃ។ តាមរយៈការដាំនិងថែរក្សាដើមឈើអុសល្អៗនៅក្បែរផ្ទះ អ្នកទទួលបន្ទុករកអុស អាចមានសុវត្ថិភាពនិងសុខភាពល្អ។

## ១.៥.១៤ ព្រៃឈើ និងការចិញ្ចឹមជីវិត

ព្រៃឈើគឺជាប្រភពដ៏សំខាន់មួយសម្រាប់ការចិញ្ចឹមជីវិត។ រដ្ឋាភិបាលនិងអង្គការអន្តរជាតិមួយចំនួននិយាយថា ការកាប់បំផ្លាញព្រៃឈើដ៏ធ្ងន់ធ្ងរបំផុតគឺបង្កឡើងដោយប្រជាជនក្រីក្រដែលកាប់ព្រៃឈើយកដីធ្វើកសិកម្មឬចិញ្ចឹមជីវិតតាមវិធីផ្សេងៗទៀត។ ប៉ុន្តែនៅពេលប្រជាជនមិនមានអាហារ ប្រាក់ចំណូល និងតម្រូវការចាំបាច់ដទៃទៀតគ្រប់គ្រាន់ទេ តម្រូវការដើម្បីការរស់រានបានក្លាយជាបញ្ហាសំខាន់ជាងតម្រូវការនៃការថែរក្សាព្រៃឈើទៅទៀត។ ជួនកាលប្រជាជនគ្មានជម្រើសអ្វីក្រៅពីកាប់ដើមឈើឡើយ, អាចជាការកាប់ឆ្ការយកដីធ្វើកសិកម្ម ឬដើម្បីប្រមូលយកអុសនិងឈើ។ យើងកម្រឃើញមានការបន្ទោសលើការកាប់បំផ្លាញព្រៃឈើពីសំណាក់ឧស្សាហកម្មធំៗដែលយកឈើយ៉ាងច្រើន ឬកាប់ព្រៃឈើដើម្បីការជីករ៉ែ រុករកប្រេង ឬចម្ការកូនឈើទ្រង់ទ្រាយធំ។

នៅពេលប្រជាជនអាចបំពេញតម្រូវការប្រចាំថ្ងៃរបស់ខ្លួនបាន ពួកគេអាចគិតអំពីអនាគតបានកាន់តែល្អប្រសើរ រួមទាំងការថែទាំបរិស្ថានផងដែរ។ ប្រជាជនដែលរស់នៅក្នុងតំបន់ព្រៃឈើនិងដែលយកចិត្តទុកដាក់នឹងព្រៃឈើ ដឹងថាមានវិធីច្រើនយ៉ាងក្នុងការចិញ្ចឹមជីវិតដោយសារព្រៃឈើដោយមិនបណ្តាលឲ្យមានការបំផ្លាញច្រើនពេកទេ។ ក្នុងករណីជាច្រើន ការបំផ្លាញព្រៃឈើគឺបណ្តាលមកពីតម្រូវការរបស់ឧស្សាហកម្ម និងសម្ពាធនៃភាពក្រីក្រ។

## ១.៥.១៥ ព្រៃឈើ និងកសិកម្ម

នៅកន្លែងជាច្រើន កសិករកាប់ព្រៃយកដីមួយក្បាលដើម្បីដាំដំណាំ ដោយមិនប៉ះពាល់ព្រៃឈើដែលនៅវិញទេ។ ពួកគេធ្វើកសិកម្មនៅលើដីនេះរហូតទាល់តែរុក្ខជាតិតូច(ដូចជាស្មៅ)ចាប់ផ្តើមដុះរំខានដំណាំ។ បន្ទាប់មកពួកគេក៏ទៅកាប់ឆ្ការយកដីមួយក្បាលទៀត ហើយដើមឈើក៏ដុះនិងបង្កើនដីជាតិដីឡើងវិញនៅលើក្បាលដីចាស់។ វិធីនេះជួនកាលហៅថា "ការកាប់រួចដុត"។ "ការកាប់រួចដុត" ត្រូវ

បានអនុវត្តរាប់ពាន់ឆ្នាំមកហើយ។ ប៉ុន្តែនៅពេលចំនួនប្រជាជនកើនឡើង ហើយតាំងទីលំនៅនៅកន្លែងថ្មី, ចំនួនព្រៃឈើសម្រាប់ការធ្វើកសិកម្មបែបនេះក៏ត្រូវបានកាត់បន្ថយ។ ហើយដីដែលធ្វើកសិកម្មរួច ក៏មិនមានគ្រប់គ្រាន់ឲ្យដើមឈើដុះឡើងវិញដែរ។ "ការកាប់រួចដុត" បានក្លាយជាគ្មានស្ថិរភាព សម្រាប់ទាំងកសិករនិងព្រៃឈើ។ សហគមន៍ដែលធ្វើកសិកម្មនៅក្នុងតំបន់ព្រៃឈើ អាចទទួលបានលទ្ធផលល្អប្រសើរនិងថែរក្សាទីតាំងនៅលើដីរបស់ខ្លួនបានយូរអង្វែង ប្រសិនបើពួកគេប្រើប្រាស់មធ្យោបាយកសិកម្មដែលមានស្ថិរភាព។

## ១.៥.១៦ ព្រៃឈើ និងអេកូទេសចរណ៍

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិការ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ខែវិច្ឆិកា ឆ្នាំ ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។ សកម្មភាពនេះនឹងមិនប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា ៤**

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពប៉ះពាល់ធ្ងន់ធ្ងរទៅលប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចម្បងៗពាក់ពន្ធ័ទៅនឹងប្រពន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលអោយមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចម្បងៗពាក់ព័ន្ធទៅនឹងប្រពន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលអោយមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់សម្រាប់ការចូលរួមផ្តល់មតិជាសារជារណៈបាន ។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធមជ្ឈដ្ឋាននេះព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុវត្តន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

### មាត្រា ៥

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់ ។

## ២.២ ជំពូក២ រដ្ឋបាលព្រៃឈើ

### មាត្រា ៦

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាល ដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ ។

រដ្ឋបាលព្រៃឈើមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយ ដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខ័ណ្ឌ ផ្នែក និង សង្កាត់ រដ្ឋបាលព្រៃឈើ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

រដ្ឋបាលព្រៃឈើត្រូវបានបំពេញភារកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍តម្លាភាពដោយធានានូវសិទ្ធិរបស់សាធារណជនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង ការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ ។

**មាត្រា ៧**

រដ្ឋបាលព្រៃឈើត្រូវបំពេញនូវភារកិច្ចដូចតទៅ :

១-ធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រកបដោយនិរន្តរភាពដោយដាក់បទបញ្ជាលើរាល់សកម្មភាពព្រៃឈើ ។

២-សិក្សាប្រមូលទិន្នន័យលើព្រៃឈើរដ្ឋទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវកម្រិតផ្តល់ផលប្រកបដោយនិរន្តរភាព ។

៣-វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បីបង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ។

៤-រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅថ្នាក់នីមួយៗ នៃរដ្ឋបាលព្រៃឈើ ។

៥-បង្កើតការដាំដុះព្រៃឈើឡើងវិញលើដីព្រៃរេចរឹល និងដីព្រៃទំនេរ ។

៦-បង្កើតការអភិវឌ្ឍន៍កិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប ។

៧-អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារនិងថែរក្សាធនធានព្រៃឈើនិងសត្វ។

៨-ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លេចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

៩-បង្កើតការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាព្រៃឈើ ក៏ដូចជាចាត់វិធានការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងថែរក្សាព្រៃឈើជាតិ ។

១០-បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារនិងអភិវឌ្ឍធនធានព្រៃឈើ ។

១១-ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្មភាពទាក់ទងនឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ ។

មន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម :

១-ត្រួតពិនិត្យការធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំការដាំឈើរបស់រដ្ឋ ។

២-ត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ និងផលប្រមាញ់តាមមធ្យោបាយដឹកជញ្ជូននានា ។

៣-ត្រួតពិនិត្យកន្លែងសន្និផល អនុផលព្រៃឈើ ទីតាំងលក់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ។

៤-ត្រួតពិនិត្យមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផលអនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬប្រភពថាមពលអំពីឈើ ។

៥-ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀតដែលតម្រូវឱ្យត្រួតពិនិត្យតាមច្បាប់នេះ។

៦-បង្កើនការអភិវឌ្ឍន៍កិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប។

៧- អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារនិងថែរក្សាធនធានព្រៃឈើ និងសត្វព្រៃ។

៨- ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

៩-បង្កើនការអប់រំប្រជាពលរដ្ឋតាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាព្រៃឈើ ក៏ដូចជាចាត់វិធានការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

១០-បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារនិងអភិវឌ្ឍន៍ធនធានព្រៃឈើ ។

១១-ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្មភាពទាក់ទងនិងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ ។

## ២.៣ ជំពូកទី៣ និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ

### មាត្រា ៨

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភា ត្រូវអនុវត្តន៍ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវគោលនយោបាយវិស័យព្រៃឈើជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈ កម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធនឹងវិស័យព្រៃឈើ ។ ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រាជរដ្ឋាភិបាលត្រូវកំណត់នូវគោលនយោបាយវិស័យព្រៃឈើជាតិ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

គោលនយោបាយវិស័យព្រៃឈើជាតិ អាចសើរើដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ក្នុងលក្ខខណ្ឌផ្លាស់ប្តូរនៃស្ថានភាពវិស័យព្រៃឈើតាមគោលការណ៍ដែលនាំមកនូវដំណោះស្រាយដើម្បីរក្សានិរន្តរភាពនៃ ការគ្រប់គ្រងព្រៃឈើ ។

### មាត្រា ៩

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន ដែលអនុលោមតាមមាត្រា ៤នៃច្បាប់នេះ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវសម្រេចដោយរាជរដ្ឋាភិបាលសំរាប់រយះពេលវែង ដើម្បីកំណត់អាទិភាពនិងសកម្មភាពគ្រប់គ្រងព្រៃឈើ ។ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ ៥ឆ្នាំ ម្តងដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌនិងកាលៈទេសៈផ្លាស់ប្តូរ ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវលើកឡើងនូវសមាសភាគដូចតទៅ :

១-ពិនិត្យកត្តារូបសាស្ត្រ បរិស្ថាន និងសង្គមទាក់ទងនឹងធនធានព្រៃឈើនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើ ។

២-ប៉ាន់ស្មានបរិមាណផល អនុផលព្រៃឈើគ្រប់លំដាប់ថ្នាក់ ។

៣-កំណត់ផ្ទៃដីតំបន់ព្រៃឈើ តំបន់ត្រូវដាំឈើឡើងវិញ និងព្រៃសហគមន៍។

៤-ពិនិត្យកម្មវិធី និងប្រតិទិនសកម្មភាពលំអិតលើការងាររៀបចំព្រៃឈើ និងរុក្ខវប្បកម្ម ។

៥-អភិវឌ្ឍកម្មវិធីនៃការធ្វើអន្តរាគមន៍ ដល់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើរដ្ឋ និងឯកជន។

៦-អភិវឌ្ឍកម្មវិធីសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ទីផ្សារផល អនុផលព្រៃឈើ ។

៧-អភិវឌ្ឍកម្មវិធីស្រាវជ្រាវ ស្តីពីការអភិវឌ្ឍន៍បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រព្រៃឈើ ។

៨-បង្កើន និងពង្រីកចំណេះដឹងពីព្រៃឈើដោយអញ្ជើញការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់ និងការពារព្រៃឈើ ។

៩-អភិវឌ្ឍន៍ធនធានមនុស្ស និងមធ្យោបាយសម្ភារៈចំបាច់ ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី ។

១០-ពង្រឹងស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើនៅគ្រប់ថ្នាក់ កែលំអ និងពង្រឹងការអនុវត្តន៍ច្បាប់ ។

១១-ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេស ក្នុងតំបន់ និងក្រៅតំបន់ ក្នុងកិច្ចការពារ និងអភិវឌ្ឍន៍ធនធានព្រៃឈើ ។

១២-ឧបត្ថម្ភគាំទ្ររាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តន៍គោលនយោបាយវិស័យព្រៃឈើជាតិ ។

ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំនយោបាយវិស័យព្រៃឈើជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តន៍ នូវគោលបំណងនៃផែនការគ្រប់វិស័យព្រៃឈើជាតិ ជូនរាជរដ្ឋាភិបាល ។ របាយការណ៍នេះ ត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ ។

## ២.៤ ជំពូកទី ៤ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

### មាត្រា ១០

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន :

- ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។
- ព្រៃឯកជន ។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ :

១-ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់ ។ ព្រៃផ្តល់ផលមានជាអាទិ៍ :

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចំការព្រៃឈើ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរេចរឹល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង ។

២-ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ ។ ព្រៃការពារមានជាអាទិ៍ :

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជំរាល
- ព្រៃលំហែកម្សាន្ត
- សួនរុក្ខជាតិ
- ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីដែលមានផលប៉ះពាល់ទាមដោយសហគមន៍មូលដ្ឋាន ។

៣-ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃ បន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍន៍សម្រាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល ។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

## មាត្រា ១១

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគ្រប់គ្រងក្នុងគោលបំណងបង្កើនជាអតិបរមាណនូវប្រយោជន៍ សង្គម សេដ្ឋកិច្ច បរិស្ថាន និងមរតកវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋកម្ពុជា ស្របនឹងគោលការណ៍គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចាត់ថ្នាក់ចុះបញ្ជាកា និងកំណត់ព្រំប្រទល់ព្រៃឈើទាំងអស់នៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ក្នុងការអនុវត្តន៍នូវសកម្មភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរពាក់ព័ន្ធ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដើម្បីជួយដល់ដំណើរការចុះបញ្ជាការកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច និងការរៀបចំផែនទីប្រើប្រាស់ថ្នាក់ជាតិ ។

គ្រប់ព្រៃឈើដែលបានចាត់ថ្នាក់នៅក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានរៀបចំ និងគ្រប់គ្រង ស្របតាមគោលបំណងនៃផែនការគ្រប់វិស័យព្រៃឈើជាតិ ។

នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជាការសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១២

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើណាមួយពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ ការសម្រេចបែបនេះត្រូវស្ថិតនៅក្នុងផលប្រយោជន៍សាធារណៈ និងមានសង្គតិភាពចាមួយគោលនយោបាយវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់គោលបំណងមិនមែនព្រៃឈើត្រូវពិចារណាលើអាទិភាព ដូចខាងក្រោម :

១- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។

២-ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្សេងទៀតដែលត្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួសផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលបានរំសាយក្នុងគោលបំណងការពារ និងដាំព្រៃឡើងវិញ ដើម្បីរក្សាគម្របជាអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលសម្រេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុងដែនព្រៃអចិន្ត្រៃយ៍ ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ ។

រាល់ការសម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខណ្ឌទី១ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខណ្ឌទី៣ នៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ២.៥ ជំពូកទី ៥ ការគ្រប់គ្រងព្រៃសម្បទាន

### មាត្រា ១៣

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចផ្តល់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរ ស្របតាមផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិទៅជាព្រៃសម្បទាន ដោយដាក់ឱ្យដេញថ្លៃជាសាធារណៈ តាមដំណើររបស់រដ្ឋម-ន្ត្រីក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ក្រោយពីបានពិគ្រោះយោបល់ជាមួយបណ្តាលក្រសួងពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានរួចហើយ ។

សំណុំឯកសារ និងនីតិវិធីនៃការដេញថ្លៃជាសាធារណៈចំពោះការផ្តល់ព្រៃសម្បទានត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

### មាត្រា ១៤

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអំណាចចុះកិច្ចព្រមព្រៀងព្រៃសម្បទានជាមួយវិនិយោគិន ឬនីតិបុគ្គលណាមួយដោយការផ្តល់សម្បទាននេះ ត្រូវមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រង វិស័យព្រៃឈើជាតិ និងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

ការដេញថ្លៃជាសាធារណៈ ត្រូវតែអនុវត្តន៍ជាមូលដ្ឋាននៅមុនពេលរាជរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងព្រៃសម្បទានដោយអនុលោមតាមបទប្បញ្ញតិនៃច្បាប់នេះ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

គណៈកម្មការដេញថ្លៃព្រៃសម្បទានត្រូវផ្តល់នូវកាលានុវត្តិភាព និង ការពិចារណាជូនអ្នកដេញថ្លៃគ្រប់រូប ដោយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈឱ្យបានទាន់ពេលវេលា ជាពិសេសដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងតំបន់ដាក់ជាព្រៃសម្បទាន ។

បេក្ខភាពក្រុមហ៊ុនដេញថ្លៃ ត្រូវភ្ជាប់រាល់ឯកសារដេញថ្លៃជាមួយនឹងលិខិតថ្លែងការណ៍របស់ក្រុមហ៊ុន ដែលចែងលំអិតអំពីការប្រព្រឹត្តល្អលើកិច្ចព្រមព្រៀងព្រៃសម្បទានដែលបានអនុវត្តន៍កន្លងមក ទោះក្នុងប្រទេសក្តី ឬក្រៅប្រទេសក្តីដោយមានភស្តុតាងធានាអះអាងផង ។

### មាត្រា១៥

ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនដីព្រៃសម្បទានរបស់ខ្លួនដោយធានាថា ប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ :

១-សិទ្ធិប្រើប្រាស់ជាប្រពៃណីដែលអនុវត្តន៍នៅលើទឹកដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិភាគតិច ដែលបានចុះបញ្ជីការដោយរដ្ឋស្របតាមច្បាប់ភូមិបាល ។

២-សិទ្ធិចេញ-ចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណី អនុវត្តន៍ដោយសហគមន៍ដែលមានទីតាំងឬក្បែរព្រៃសម្បទាន ។

## មាត្រា ១៦

ខ្លឹមសារកិច្ចព្រមព្រៀងព្រៃសម្បទានក្នុងកម្រិតអប្បរមាត្រូវមាន :

១-កាលបរិច្ឆេទនៃការផ្ដល់ព្រៃសម្បទាន និងរយះពេលនៃការផ្ដល់ ។

២-ទីតាំងព្រៃសម្បទានដែលកំណត់បង្ហាញនូវអត្តសញ្ញាណដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច តំបន់ព្រៃសហគមន៍ តំបន់គ្រប់គ្រងពិសេស និងផ្ទៃដីព្រៃដែលអាចប្រមូលផលបាន ។

៣-សេចក្ដីថ្លែងការណ៍ជាលាយលក្សណ៍អក្សរថា ព្រៃសម្បទានិកត្រូវគោរព និងមិនជ្រៀតចូលធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងតំបន់គ្រប់គ្រងពិសេសតំបន់កម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច និងព្រៃសហគមន៍ឡើយ ។

៤-ប្រភេទ និងបរិមាណផល អនុផលព្រៃឈើអនុញ្ញាតឱ្យប្រមូល និងវិធីសាស្ត្រគណនាបរិមាណដែលអាចដកហូតបាន ។

៥-ការបរិយាយពីកាតព្វកិច្ចរបស់ព្រៃសម្បទានិកក្នុងការកសាង និងការអនុវត្តន៍ គម្រោងផែនការណ៍គ្រប់គ្រងព្រៃឈើកម្រិតព្រៃសម្បទាន ព្រៃគុប និងប្លុកប្រមូលផល ។

៦-លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋបាលព្រៃឈើពាក់ព័ន្ធទៅនឹងព្រៃសម្បទាន ។

## មាត្រា ១៧

កិច្ចព្រមព្រៀងព្រៃសម្បទាន មិនត្រូវកំណត់ឱ្យលើសរយះពេលសាមសិប (៣០)ឆ្នាំឡើយ ។

កិច្ចព្រមព្រៀងព្រៃសម្បទានអាចបញ្ឈប់ នៅពេលណាដែលរាជរដ្ឋាភិបាលបានរកឃើញថាព្រៃសម្បទានិកបានរំលោភធ្ងន់ធ្ងរលើបណ្ដាលក្ខខណ្ឌដែលតម្រូវឱ្យបញ្ឈប់ ដូចមានចែងក្នុងអនុក្រឹត្យការគ្រប់គ្រងសម្បទាន ។

ព្រៃសម្បទានិកមានសិទ្ធិស្នើសុំការពន្យល់ពីមូលហេតុនៃការសម្រេចលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទាន មុនកាលកំណត់ដោយរដ្ឋាភិបាល ។ វិធានដោះស្រាយវិវាទ ត្រូវស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន និងច្បាប់ជាធរមាន ។

ដោយផ្អែកតាមការវាយតម្លៃលើការអនុវត្តន៍របស់ព្រៃសម្បទានិកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជរដ្ឋាភិបាលអាចអនុគ្រោះបន្តកិច្ចព្រមព្រៀងបាន ហើយរយះពេលបន្តនេះ មិនត្រូវលើសពីរយះពេលកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទានដំបូងឡើយ ។

### មាត្រា ១៨

ការរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់កម្រិត ត្រូវទទួលខុសត្រូវដោយព្រៃសម្បទានិក តាមគោលការណ៍ណែនាំដែលមានចែងក្នុងក្បួនធ្វើផែនការគ្រប់គ្រងព្រៃសម្បទានក្រមបច្ចេកទេសអនុវត្តន៍ ប្រមូលផល ព្រៃឈើនៅកម្ពុជា និងប្រការទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន ។

ព្រៃសម្បាទានិកត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានតាមកម្រិតដូចខាងក្រោម :

១-ផែនការគ្រប់គ្រងរយៈពេលវែងសម្រាប់ព្រៃសម្បទានទាំងមូល ។

២-ផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំសម្រាប់កម្រិតព្រៃគុបនីមួយៗ ។

៣-ផែនការគ្រប់គ្រងប្លុកប្រមូលផលសម្រាប់ការប្រមូលផលប្រចាំឆ្នាំនីមួយៗ ។

ផែនការគ្រប់គ្រងព្រៃសម្បទាន និងការសើរើត្រូវកំណត់តាមវិធានខាងក្រោម :

១-ផែនការគ្រប់គ្រងព្រៃសម្បទានត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ ផែនការនេះត្រូវត្រួតពិនិត្យសើរើរៀងរាល់ឆ្នាំ (៥) ឆ្នាំម្តង ។

២-ផែនការប្រមូលផលកម្រិតព្រៃគុបប្រចាំឆ្នាំ និងផែនការគ្រប់គ្រងប្លុកប្រមូលផលត្រូវសម្រេច ដោយប្រធានរដ្ឋបាលព្រៃឈើ ។

### មាត្រា ១៩

ព្រៃសម្បទានិកទាំងអស់ត្រូវតែដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងព្រៃសម្បទាននូវការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងប៉ះពាល់សង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋាននានាស្តី ពីការគ្រប់គ្រងព្រៃសម្បទានត្រូវរៀបចំដោយព្រៃសម្បទានត្រូវរៀបចំដោយព្រៃសម្បទានទាក និងត្រូវ បានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុននិងសម្រេចយល់ព្រមដោយមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធានាការចូលរួមផ្តល់មតិជាសាធារណៈលើ ផែនការគ្រប់គ្រង ព្រៃសម្បទាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម មុន ពេលការសម្រេចចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

## ២.៦ ជំពូកទី ៦ ការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន និងព្រៃការពារ

### មាត្រា ២០

ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវបានគ្រប់គ្រងដើម្បីបំរើជាអទិភាពនូវសេចក្តីត្រូវការផល អនុផលព្រៃឈើប្រចាំឆ្នាំក្នុងស្រុក ។ ផល អនុផលព្រៃឈើទាំងនេះអាចធ្វើការនាំចេញបាន នៅពេល

ណាដែលការផ្គត់ផ្គង់លើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមដំណើររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ២១

ប្រធានផ្នែករដ្ឋបាលព្រៃឈើមានភារកិច្ចរៀបចំ និងដាក់ស្នើផែនការគ្រប់គ្រងព្រៃផ្តល់ផល ក្រៅពីព្រៃសម្បទានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីពិនិត្យសម្រេច ។ ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីសម្បទានប្រព្រឹត្តទៅតាមលំនាំផែនការគ្រប់គ្រងព្រៃសម្បទាន ដូចមានចែងក្នុងមាត្រា ១៨ កឋាខ័ណ្ឌទី២ នៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ណាមួយអាចដាក់ពាក្យដេញថ្លៃដើម្បីទទួលបាននូវសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅសម្បទាន ក្រោមនីតិវិធីនៃការដេញថ្លៃជាសាធារណៈ។

នីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ២២

ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាតំបន់មជ្ឈដ្ឋានពិសេស ឬមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ទេសចរណ៍ ឬជាតំបន់អភិរក្សជីវៈចម្រុះ ទឹក និងដី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីដាក់ជាព្រៃការពារ ។

រាល់ការបង្កើត ឬការរំសាយព្រៃការពារត្រូវមានរបាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ។

## មាត្រា ២៣

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការអនុវត្តន៍ច្បាប់ព្រៃឈើ និងគ្រប់សកម្មភាពប្រត្តិបត្តិក្នុងការរៀបចំគ្រប់គ្រងការពារគ្រប់ដែនព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់ ។

# មេរៀនទី៣ លិខិត និងសិទ្ធអំណាចផ្សេងៗនៃច្បាប់ព្រៃឈើ

## ៣.១ ជំពូក៧ អំពីលិខិតអនុញ្ញាត និងសិទ្ធិអំណាច

### មាត្រា ២៤

ផល អនុផលព្រៃឈើទាំងអស់ដែលស្ថិតនៅក្នុង និងមានប្រភពចេញពីបម្រុងទុកអចិន្ត្រៃយ៍ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែសិទ្ធិលើផល អនុផលព្រៃឈើដែលត្រូវបានប្រគល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ ដែលមានបំណងប្រមូលផល អនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលផលព្រៃឈើចេញដោយរដ្ឋបាលព្រៃឈើ ។

ការប្រមូលផល អនុផលព្រៃឈើដោយសមាជិកសហគមន៍មូលដ្ឋានដែលមានបរិមាណស្មើ ឬក្រោមបរិមាណបំរើសេចក្តីត្រូវការសម្រាប់ការរស់នៅជាប្រពៃណី ដូចមានចែងក្នុងជំពូកទី ៩ នៃច្បាប់នេះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតឡើយ ។

### មាត្រា ២៥

រាល់សកម្មភាពលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងផល អនុផលព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមានលិខិតអនុញ្ញាតសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម :

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ

២-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

៣-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៤-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៥-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ។

៦-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ។

៧-លិខិតអនុញ្ញាតចូលព្រៃ ដើម្បីការងាររៀបចំព្រៃគុប

៨-លិខិតអនុញ្ញាតបង្កើតរោងសន្និផលលក់ចែកចាយផល អនុផលព្រៃឈើ ។

៩-លិខិតអនុញ្ញាតបង្កើតគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ។

១០-លិខិតកំណត់កូតាអនុញ្ញាតឱ្យនាំចេញផល អនុផលព្រៃឈើ ។

១១-លិខិតអនុញ្ញាតនាំចេញ នាំចូលផល អនុផលព្រៃឈើ ។

១២-លិខិតអនុញ្ញាតផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតដូចមានចែងខាងលើ ត្រូវបានផ្តល់សិទ្ធិស្នើសុំចំពោះ៖

១-ព្រៃសម្បទានិកដែលបានទទួលការឯកភាពលើផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ដូចតម្រូវដោយកិច្ចព្រមព្រៀងព្រៃសម្បទាន ។

២-នីតិបុគ្គល ដែលបានទទួលការឯកភាពលើការប្រមូលផលក្រៅពីព្រៃសម្បទាន ។

៣-សហគមន៍ដែលបានទទួលសិទ្ធិធ្វើការប្រមូលផលក្នុងព្រៃសហគមន៍លើសពីកម្រិតប្រើប្រាស់ជាប្រពៃណីក្រោមវិធានសហគមន៍ព្រៃឈើ ។

៤-បុគ្គល ឬអតិជន ដែលដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីតំបន់ព្រៃប្រមូលផលឆ្ពោះទៅទិសដៅកំណត់ ។

៥-រូបវន្តបុគ្គល នីតិបុគ្គល សហគមន៍ ឬអតិថិជនទូទៅដែលអាចទទួលសិទ្ធិស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះ ត្រូវសំគាល់ដោយ :

១-ឈ្មោះអ្នកកាន់លិខិតអនុញ្ញាត ។

២-រយះពេលសុពលភាពនៃលិខិតអនុញ្ញាត ។

៣-ទីតាំង និងព្រំប្រទល់ជាក់លាក់នៃតំបន់ប្រមូលផល អនុញ្ញាតព្រៃឈើ

៤-បរិមាណផល អនុផលព្រៃឈើដែលបានអនុញ្ញាតគិតជាឯកតាកំណត់ដោយរដ្ឋបាលព្រៃឈើ ។

៥-ប្រភព និងទិសដៅនៃការដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៦-ចំណុចផ្សេងទៀត អាស្រ័យតាមប្រភេទលិខិតអនុញ្ញាតដែលកំណត់ដោយរដ្ឋបាលព្រៃឈើ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះអាចពន្យារពេលបន្តប្រើប្រាស់បាន ដោយផ្អែកលើរបាយការណ៍វាយតម្លៃពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

គំរូឯកសារជាលាយលក្ខអក្សរសម្រាប់លិខិតអនុញ្ញាតនីមួយៗ ត្រូវកំណត់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ២៦

ការទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាតមានដូចតទៅ :

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចសម្រេចលើ :

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២-កូតាអនុញ្ញាតឱ្យនាំចេញ និងនាំចូលផល អនុផលព្រៃឈើ យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

៣-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ។

៤-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើប្រភេទធំ និងមធ្យម ។

ប្រធានរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២-កូតាអនុញ្ញាតឱ្យនាំចេញ និងនាំចូលផល អនុផលព្រៃឈើ យោងតាមសេចក្តីសម្រេចរបស់រដ្ឋរាជរដ្ឋាភិបាល ។

៣-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ។

៤-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើប្រភេទធំ និងមធ្យម ។

ប្រធានរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន។

២-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន។

៣-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ សម្រាប់នាំចេញ នាំចូល។

៤-លិខិតអនុញ្ញាតចូលព្រៃដើម្បីដំណើរការរៀបចំព្រៃគុបមុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ។

៥-លិខិតអនុញ្ញាត ឬចុះទិដ្ឋាការលើអាជ្ញាប័ណ្ណនាំចូលផល អនុផលព្រៃឈើ។

នាយកខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន។

២-លិខិតអនុញ្ញាតឱ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើប្រភេទតូច។

៣-លិខិតអនុញ្ញាតឱ្យបង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណ:ឧស្សាហកម្ម ឬសិប្បកម្ម។

៤-លិខិតអនុញ្ញាតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសហគមន៍។

នាយផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើលើបរិមាណលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណី សម្រាប់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍។

២-រាល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើដែលមានប្រភពចេញពីតំបន់ដែនសមត្ថកិច្ចរបស់ផ្នែករដ្ឋបាលព្រៃឈើនោះ។

### មាត្រា ២៧

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចចេញលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើដល់រូបវន្តបុគ្គល នីតិបុគ្គល សម្រាប់ដំណើរការសកម្មភាពនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :

១-ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រ។

២-ការអប់រំ និងការបណ្តុះបណ្តាលវិស័យកសិកម្ម។

៣-ការប្រើប្រាស់ធនធានទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ឬគោលបំណងកសិកម្ម ដោយមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម។

៤-ការបង្កើតសួនរុក្ខតាមសាស្ត្រ ឬស្ថានីយ៍ពិសោធន៍។

៥-ការបង្កើតថ្នាលកូនឈើត្រូវផ្ទេរ។

៦-ការបង្កើតតំបន់សម្រាប់សម្រាលលំហែ ទស្សនាកម្សាន្ត ឬការថតភាពយន្តឯកសារ។

លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើនេះមិនត្រូវយកទៅប្រើដើម្បីប្រមូលផល អនុផលព្រៃឈើ តំបន់ដែលបានកំណត់សម្រាប់សកម្មភាពខាងលើឡើយ លើកលែងតែការដកហូតសម្រាប់គោលបំណងស្រាវជ្រាវរុក្ខវប្បកម្ម ដើម្បីបង្កើនគុណភាពព្រៃឈើ។

## ៣.២ ជំពូកទី ៨ ការហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងការការពារព្រៃឈើ

### មាត្រា ២៨

រាល់ការផ្តល់ ឬបែងចែកព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រាប់ការប្រមូល អនុផលព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះអាចប្រព្រឹត្តទៅបានតែក្នុងករណីព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះជាប្រភេទព្រៃផ្តល់ផល និងមានសក្តានុពលផ្តល់ផលដែលការគ្រប់គ្រង និងត្រួតពិនិត្យត្រូវតែអនុវត្តក្រុមបច្ចេកទេស អនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា។

គ្មានបុគ្គលណាមានសិទ្ធិផ្តល់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃការពារគ្រប់ប្រភេទនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឡើយ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលកែប្រែដែនព្រៃការពារទៅជាដែនព្រៃផ្តល់ផលនៅពេលដែលរដ្ឋបាលព្រៃឈើបានផ្តល់ទិន្នន័យសិក្សាថ្មីចំពោះព្រៃការពារណាមួយដែលអាចមាន សក្តានុពលគ្រប់គ្រាន់សម្រាប់ដកហូត បើពុំទោះទេការប្រមូលផល អនុផលព្រៃឈើត្រូវហាមឃាត់។

## មាត្រា ២៩

លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមូលហេតុជាអាទិ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផល ឈើចំណីផ្លូវដែលត្រូវសាងសង់ដោយមានការអនុញ្ញាត ឬលក្ខខណ្ឌឧបទ្ទវហេតុផ្សេងទៀតដែលស្នើឡើងដោយរដ្ឋបាលព្រៃឈើ ការប្រមូលផល អនុផលព្រៃឈើដូចខាងក្រោមព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ :

១-ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រលំ។

២-ប្រភេទឈើដែលមានដោយកម្រ។

៣-ប្រភេទឈើដែលមានប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី។

៤-ដើមឈើផ្តល់ជ័រមានតម្លៃ។

ផល អនុផលព្រៃឈើដែលហាមឃាត់ដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា ៣០

ហាមឃាត់ការកែច្នៃផល អនុផលព្រៃឈើ ឬការបង្កើតនិងដំណើរការមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ រោងចក្រកែច្នៃ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងគ្រប់ប្រភេទនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

គ្រប់មូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងគ្រប់ប្រភេទ ត្រូវមានទីតាំងស្ថិតនៅចម្ងាយប្រាំ (៥)គីឡូម៉ែតយ៉ាងតិច ពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការលើកលែងការហាមឃាត់ដែលចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រានេះ ក្នុងករណីដែលរដ្ឋបាលព្រៃឈើសិក្សាឃើញថា ផលប្រយោជន៍នៃការលើកលែងនេះមិនមានផលប៉ះពាល់សង្គម បរិស្ថាន ឬមានផលប៉ះពាល់កម្រិតទាប។

## មាត្រា ៣១

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការសម្រេចពីរាជរដ្ឋាភិបាលតាមដំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រាល់គំរោងស្ថាបនាផ្លូវសាធាណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន និងការវាយតម្លៃ ហេតុប៉ះពាល់ដល់បរិស្ថាន និងផលប៉ះពាល់ដល់សង្គម ស្របតាមមាត្រា ៤ នៃច្បាប់នេះ។

ការដាក់តាំងលំនៅដ្ឋានថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

## មាត្រា ៣២

ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាពដែលធ្វើឱ្យខូចខាតបណ្តាលមកពីការធ្វើអាជីវកម្មហួសហេតុការកាប់រានដីព្រៃដោយរំលោភ ការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចំការពនេរចរ ជម្ងឺ សត្វល្អិតចង្រៃ និងការនាំចូលប្រភេទរុក្ខជាតិ និងសត្វរាតត្បាត។

សកម្មភាពដែលនាំឱ្យខូចខាតដល់ព្រៃឈើដែលត្រូវបានហាមឃាត់មានដូចជា:

១-រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសំគាល់សម្រាប់កំណត់ដែនព្រៃឈើ។

២-គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរលំដើមឈើ ឬគាស់រលើងគល់ឈើដោយគ្មានការចាំបាច់ខាងបច្ចេកទេស។

៣-ប្រើសិទ្ធិប្រមូលផល អនុផលព្រៃឈើខុសពីសិទ្ធិ ដែលត្រូវបាលទទួលស្គាល់ ឬអនុញ្ញាត។

៤-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងកន្លែងដែលមានកូនឈើដុះថ្មីក្រោយពេលអាជីវកម្ម ឬភ្លើងព្រៃ ឬក្នុងតំបន់ព្រៃកំពុងតែដាំ ឬទើប នឹងដាំ។

៥-បង្កើតមូលដ្ឋានកែច្នៃរល្លីរមៀត ឬអនុផលព្រៃឈើផ្សេងៗទៀតដែលនាំមកនូវការបំពុល ឬបំផ្លាញមជ្ឈដ្ឋានព្រៃឈើ។

## មាត្រា ៣៣

រាល់សកម្មភាពកាប់រានដីព្រៃក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៣១ មាត្រា ៣៥ និងមាត្រា ៣៧ នៃច្បាប់នេះ។

## មាត្រា ៣៤

ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃត្រូវឆ្លងកាត់ការសិក្សាស្រាវជ្រាវវាយតម្លៃពីរដ្ឋបាលព្រៃឈើ និងត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ត្រូវមានទិដ្ឋាការគ្រាប់ពូជ ដែលបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ។

## មាត្រា ៣៥

បន្ថែមលើច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងការយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលត្រូវអនុវត្តន៍ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសិក្សាវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួល ការអនុញ្ញាតពីរាជរដ្ឋាភិបាលដោយត្រូវអនុវត្តន៍តាមមាត្រា ៤ នៃច្បាប់នេះ។

ការអនុញ្ញាតនេះត្រូវកម្រិតផងដែរនូវវិធានការការពារ និងស្តារឡើងវិញនៅទីកន្លែងគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលអ្នកទទួលសិទ្ធិត្រូវទទួលបន្ទុកដើម្បី :

១-ចៀសវាងបង្ក ឬធ្វើអោយធ្ងន់ធ្ងរដល់ការហូរច្រោះបាក់ដី ឬធ្វើឱ្យខូចខាតដល់ការលូតលាស់របស់រុក្ខជាតិ ឬធ្វើឱ្យខូចខាតដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក

២-រៀបចំស្តារទីតាំងនោះឱ្យមានសភាពដូចដើមវិញ ក្រោយពេលបញ្ចប់កិច្ចការគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតក្នុងរយៈពេល ដែលលិខិតអនុញ្ញាតបានកំណត់។

## មាត្រា ៣៦

ហាមបង្កភ្លើងឆេះព្រៃក្នុងដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះចំពោះរដ្ឋបាលព្រៃឈើ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ឬអនាម័យព្រៃ។

គោលការណ៍ណែនាំក្នុងការកំណត់តំបន់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការការពារឆេះព្រៃ និងការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃ សម្រាប់ជាវិធានការអនុវត្តន៍គ្រប់តំបន់ព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីកិច្ចទទួលខុសត្រូវ ថែរក្សាការពារព្រៃឈើ បង្ការ និងប្រយុទ្ធនឹងភ្លើងព្រៃ។

## មាត្រា ៣៧

សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តន៍លើដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីការរួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាន ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

ដីព្រៃឈើដែលរៀបចំបម្រុងសម្រាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា ៣៨

ការអាររច្រៀក និងការចាំងឈើមូលនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់។ ការប្រើប្រាស់រណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតប្រើប្រាស់ចេញដោយរដ្ឋបាលព្រៃឈើ។

## មាត្រា ៣៩

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់ដើមឈើ រានដីព្រៃឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងបម្រុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះឡើយ។

## ៣.៣ ជំពូកទី ៩ សិទ្ធិប្រើប្រាស់ជាប្រពៃណី ការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃឯកជន

### មាត្រា ៤០

ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅ ដូចមានចែងក្នុងមាត្រានេះ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានមិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួចមាន:

១-ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់។

២-ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋាន ក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម។

៣-ការច្រូតយកស្មៅ ឬលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ។

៤-ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ។

៥-សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះមិនគំរាមកំហែងដល់និរន្តរភាពនៃព្រៃឈើ។ អតិថិជន ឬភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋានក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់ទិសដៅបានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញទៅមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី។ សិទ្ធិប្រើប្រាស់នៃប្រពៃណីត្រូវ:

១-ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ។

២-ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយប្បញ្ញត្តិនៃច្បាប់នេះ។

### មាត្រា ៤១

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬជិតតំបន់ព្រៃឈើ ក្រោមរូបភាពជាព្រៃសគមន៍។

### មាត្រា ៤២

ខ័ណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចសិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ នឹងមានទំហំសមស្របផ្អែក តាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍។

នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥)ឆ្នាំ តែអាចពន្យារបានដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលព្រៃឈើ។

## មាត្រា ៤៣

ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តរភាពដោយសហគមន៍មូលដ្ឋាន ស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ វិធានសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។ រដ្ឋបាលព្រៃឈើត្រូវផ្តល់ជំនួយបច្ចេកទេសតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍។

ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រមដោយថ្នាក់ខ័ណ្ឌរដ្ឋបាលព្រៃឈើ។ ផែនការនេះនឹងត្រូវផ្ញើជូនទៅថ្នាក់កណ្តាលរដ្ឋបាលព្រៃឈើ និងត្រួតពិនិត្យឡើងវិញជារៀងរាល់ប្រាំ (៥)ឆ្នាំម្តង ឬមុនពេលកំណត់ក្នុងករណីចាំបាច់។

ទោះបីព្រៃសហគមន៍ត្រូវបានដាំដុះ ឬដុះដោយធម្មជាតិក៏ដោយ ក៏ការគ្រប់គ្រងអនុវត្តន៍តាមផែនការគ្រប់គ្រងព្រៃសហគមន៍ និងក្រោមការឧបត្ថម្ភបច្ចេកទេស និងត្រួតពិនិត្យបច្ចេកទេសដោយរដ្ឋបាលព្រៃឈើ។

វិធានសម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ។

គោលការណ៍នាំអំពីសហគមន៍ព្រៃឈើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា ៤៤

សហគមន៍មូលដ្ឋានដែលដំណើរការក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មានសិទ្ធិប្រមូលផលអនុផលព្រៃឈើនៅក្នុងដែនព្រៃឈើស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ដែលបានកំណត់ព្រំប្រទល់ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍។

សហគមន៍មូលដ្ឋានមិនអាចយកព្រៃសហគមន៍ទៅប្រើប្រាស់ក្រោមរូបភាពជាព្រៃសម្បទាន ឬលក់ ដូរ ផ្ទេរសិទ្ធិលើព្រៃឈើនោះឱ្យភាគីទីបីបានឡើយ។

### មាត្រា ៤៥

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរព្រៃនោះទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬការអភិរក្ស។ ដើមឈើជំនឿសាសនាអាចត្រូវបានសំដៅសម្គាល់ជាពិសេសមិនអនុញ្ញាតឱ្យកាប់រលំ និងត្រូវកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍។

### មាត្រា ៤៦

បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន ។

វិធានស្តីពីព្រៃឈើឯកជន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជំរុញលើក ទឹកចិត្ត ដល់បុគ្គល ក្នុងការដាំដុះ និងថែរក្សាចំការ ព្រៃឈើ ។

### មាត្រា ៤៧

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្តល់ជូនបុគ្គល និងសហគមន៍ដែលអនុវត្តការគ្រប់គ្រងព្រៃឈើ ឬដាំ ដើមឈើដែលសម្រេចបាននូវបរិមាណ នឹងគុណភាពខ្ពស់ នូវប្រព័ន្ធលើកទឹកចិត្តទៅតាមវិធានមានជាអាទិ៍ :

១-ប្រគល់លិខិតសរសើរ ប័ណ្ណសរសើរ និងប្រគល់គ្រឿងឥស្សរិយយស ។

២-ផ្តល់ជំនួយអភិវឌ្ឍន៍ដោយផ្ទាល់ក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

៣-រយៈពេលកិច្ចព្រមព្រៀងសំរាប់ព្រៃសហគមន៍ ។

៤-ផ្សព្វផ្សាយពីសកម្មភាពមានស្នាដៃ។

## ៣.៤ ជំពូកទី ១០ ការអភិរក្សសត្វព្រៃ

### មាត្រា ៤៨

ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺជាសម្បត្តិរបស់រដ្ឋ និងជាសមាសភាគនៃធនធានព្រៃ ឈើដែលរួមមាន : ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ

និងសត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំង ពង កូនរបស់វា ។ ពពួកសត្វព្រៃទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងសិក្សាស្រាវជ្រាវ និងការអភិរក្សដោយរដ្ឋបាល ព្រៃឈើ ដោយមិនរាប់បញ្ចូលត្រី និងសត្វបង្កកំណើតក្នុងទឹក ។

សំណាកសត្វព្រៃ គឺជាសត្វព្រៃដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹង ឬផលិត ផលកែច្នៃ ត្រូវស្ថិតក្រោមសិទ្ធិគ្រប់គ្រង់របស់រដ្ឋបាលព្រៃឈើ ។

គ្រប់ប្រភេទសត្វព្រៃទាំងអស់ ត្រូវបានបែងចែកជាបីក្រុម គឺ៖

១-ក្រុមប្រភេទជិតផុតពូជ

២-ក្រុមប្រភេទមានដោយកម្រ

៣-ក្រុមប្រភេទមានដោយបង្គួរ ។

លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់ថ្នាក់ក្រុមនីមួយៗ និងបញ្ជីឈ្មោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងប្រភេទ មានដោយកម្រដែលអាចប្រែប្រួលទៅតាមតំបន់ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលព្រៃឈើ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន ។

## មាត្រា ៤៩

ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយីបំផ្លិចបំផ្លាញសត្វព្រៃគ្រប់ប្រភេទដោយ :

១-ការប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់គ្រប់ប្រភេទ ។

២-ការប្រមាញ់ក្នុងរដូវកាលហាមឃាត់ ។

៣-ការប្រមាញ់ក្នុងតំបន់ការពារ និងទីសាធារណៈពិសេស ។

ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិត អនុញ្ញាតចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រសម្រាប់គោលបំណងដូចខាងក្រោម :

១-ការសិក្សាអប់រំ ឬការស្រាវជ្រាវវិទ្យាសាស្ត្រ ។

២-ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ ។

៣-ការផ្លាស់ប្តូរប្រភេទសត្វ អនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ ។

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រ ត្រូវហាមឃាត់ :

១-ការឃោឃី ឬបំផ្លិចបំផ្លាញដល់ប្រភេទសត្វខាងលើ និងជម្រករបស់ប្រភេទសត្វទាំងនេះ ។

២-ការបរបាញ់ ទាក់ចាប់ ដាក់អង្កប់ បំពុល ។

៣-ការយកធ្វើជាកម្មសិទ្ធិ សន្និធិ ឬថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

៤-ការដឹកជញ្ជូន

៥-ការធ្វើពាណិជ្ជកម្ម ។

៦- ការនាំចេញ នាំចូល

វិធានការនៃការធ្វើសកម្មភាពចំពោសត្វព្រៃគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្មប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ។

## មាត្រា ៥០

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវហាមឃាត់លើកលែង

តែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ ។

១-ការធ្វើសន្និធី ការថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

២-ការដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មលើសពីបរិមាណចាំបាច់សម្រាប់ការប្រើប្រាស់ជាប្រពៃណី ។

ការនាំចេញ នាំចូល ប្រភេទសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៥១

រដ្ឋបាលព្រៃឈើត្រូវ ប្រមូលប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃដូចខាងក្រោម

១-ប្រាក់ចំណូលអភិរក្សសត្វព្រៃត្រូវបង់ចូលមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

២-ប្រាក់សួយសារសត្វព្រៃត្រូវបង់ចូលថវិកាជាតិ ។

ប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៣.៥ ជំពូកទី ១១ ថ្លៃសួយសារនិងបុព្វលាភ លើផល អនុផលព្រៃឈើ

### មាត្រា ៥២

លើកលែងតែករណីដូចមានចែងក្នុងមាត្រា ៥៣នៃច្បាប់នេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល អនុផល ព្រៃឈើសម្រាប់គោលដៅពាណិជ្ជកម្មលើព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ ។ រាជរដ្ឋាភិបាលត្រូវកំណត់ថ្លៃសួយសារ និងបុព្វលាភ ផ្អែកតាមសំណើរួមរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមិនតម្រូវឱ្យបង់ថ្លៃសួយសារ នឹងបុព្វលាភ សម្រាប់ការប្រមូលផល អនុផលព្រៃឈើលើសឯកជនឡើយ ។ គំរូកិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវបញ្ចូលនូវតារាងនៃថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើ ។

### មាត្រា ៥៣

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ នឹងនេសាទអាចបន្ថយ ឬមិនយកថ្លៃសួយសារ និងបុព្វលាភលើផល អនុផល ព្រៃឈើ ដែលប្រមូលពីព្រៃឈើរដ្ឋសម្រាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បីបង្កើនការលើកទឹកចិត្តសេដ្ឋកិច្ច ចំពោះការ ប្រើប្រាស់អស់លទ្ធភាពលើផលិតផល ។

រដ្ឋមិនយកថ្លៃសួយសារ និងបុព្វលាភពីសហគមន៍មូលដ្ឋានលើផល អនុផលព្រៃឈើដែលប្រមូលដោយសហគមន៍ មូលដ្ឋានសម្រាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីសហគមន៍ក្រោមកិច្ចព្រមព្រៀងសហគមន៍ឡើយ ។

### មាត្រា ៥៤

រាល់ផល អនុផលព្រៃឈើត្រូវវាយតម្លៃដោយមន្ត្រីរដ្ឋបាលព្រៃឈើលើបរិមាណ នឹងគុណភាពនៅគំនរក្នុងព្រៃគុបប្រចាំឆ្នាំ មុនពេលដឹកចេញពីព្រៃ។

គុណភាព និងបរិមាណ នៃផល អនុផលព្រៃឈើដែលបានវាយតម្លៃរួច ត្រូវចូលក្នុងកំណត់ហេតុបង្កាសៀវភៅ ក ដោយមានការឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ ។

### មាត្រា ៥៥

រាល់ផល អនុផលព្រៃឈើដែលបានចុះក្នុងកំណត់ហេតុបញ្ជាសៀវភៅ ក ត្រូវបង់ប្រាក់ថ្លៃសួយសារ និងបុព្វលាភ ។

វិធាននៃការបង់ និងទទួលប្រាក់ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរវាងក សួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ៥៦

អ្នកកាន់កាប់លិខិតអនុញ្ញាត ប្រមូលផល អនុផលព្រៃឈើមិនអាចផ្ទេរ ឬលក់សិទ្ធិលើផល អនុផលព្រៃឈើទៅឱ្យ បុគ្គលណាមួយផ្សេងទៀតបានឡើយ លុះត្រាតែខ្លួនបានបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើនោះរួច ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចសម្រេចឱ្យមានការពន្យារពេលការបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើចំពោះអ្នកកាន់ កាប់លិខិតអនុញ្ញាតដែលបានទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើ ថាបានអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរ ភាព ។ ការពន្យារនោះ ត្រូវផ្អែកតាមវិធាន និងគោលការណ៍ណែនាំស្របតាមមាត្រា ៥៥ ក្របខ័ណ្ឌទី ២ នៃច្បាប់នេះ ។

## មាត្រា ៥៧

ប្រសិនបើអ្នកកាន់កាប់លិខិតអនុញ្ញាតមិនបានបង់ថ្លៃសួយសារ និងបុព្វលាភតាមកម្មវិធី ពេលវេលាកំណត់ទេនោះ រដ្ឋបាលព្រៃឈើមានសិទ្ធិដកហូតយកផល អនុផលព្រៃឈើទាំងនោះដោយគ្មានលក្ខខណ្ឌ និងឃាត់ទុកផល អនុផលព្រៃ ឈើ ទាំងនោះរក្សាជាកម្មសិទ្ធិរបស់រដ្ឋដដែល រហូតដល់មានដំណោះស្រាយវិវាទនេះតាមផ្លូវច្បាប់ ។

## មាត្រា ៥៨

មុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ អ្នកស្នើសុំលិខិតអនុញ្ញាតនោះត្រូវបង់ប្រាក់ដំកល់ដើម្បី ធានាការបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ ។ បរិមាណប្រាក់ដំកល់ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬក្នុងលិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។ ការប្រមូលផល អនុផលព្រៃឈើលើព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍មិនតម្រូវឱ្យមានការបង់

ប្រាក់ដំកល់នោះឡើយ ។

# មេរៀនទី៤ ការគ្រប់គ្រងព្រៃឈើក្នុងច្បាប់ព្រៃឈើ

## ៤.១ជំពូកទី ១២ ការដាំដើមឈើឡើងវិញ និងមូលនិធិអភិវឌ្ឍន៍ឈើជាតិ

### មាត្រា៥៩

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់មានករណីយកិច្ចចូលរួមដាំដើមឈើ និងដាំដើមឈើឡើងវិញ ។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការដាំដើមឈើ និងដាំដើមឈើឡើងវិញ ត្រូវបានលើកទឹកចិត្តដោយរាជរដ្ឋាភិបាល តាមរយៈចលនារបស់សហគមន៍ និងអង្គការសង្គមផ្សេងៗទៀត ។

រដ្ឋបាលព្រៃឈើ ត្រូវមានវិធានការសមស្របក្នុងការអភិវឌ្ឍន៍ព្រៃឈើតាមរយៈការផ្សព្វផ្សាយ ការអប់រំ ការបំផុស ដល់បុគ្គលសហគមន៍ នឹងមហាជនឱ្យដាំដើមឈើ និងការពារព្រៃឈើ ដោយផ្តល់នូវជំនួយការបច្ចេកទេសចាំបាច់ ។

### មាត្រា ៦០

ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃព្រៃឈើ ទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិ ហៅថា រុក្ខទិវា ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី ៩ ខែ កក្កដា ជារៀងរាល់ឆ្នាំក្រោមព្រះរាជាធិបតីភាពដ៏ ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង ។

ប្រជាពលរដ្ឋទាំងពីរភេទដែលជាគូស្រករថ្មី ត្រូវបានលើកទឹកចិត្តដាំដើមឈើពីរដើមក្រោមកិច្ចសម្របសម្រួល និង ផ្តល់កូនឈើដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។ រាជរដ្ឋាភិ បាលត្រូវកំណត់សួនសម្រាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិដាំដើមឈើដើម្បីទុកជាអនុស្សាវរីយ៍ ។

ការដាំដើមឈើនៅលើដីពរបស់រដ្ឋ អាចធ្វើឡើងដោយរដ្ឋបាលព្រៃឈើផ្ទាល់ សហគមន៍ព្រៃឈើ ឬដោយ មានការចូលរួមពីប្រជាពលរដ្ឋតាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ ។

ការដាំដើមឈើនៅលើដីកម្មសិទ្ធិឯកជនអាចធ្វើឡើងបាន ដោយសិទ្ធិវន្តស្របតាមវិធានឯកជន ដូចមានចង ក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសំរាប់ការដាំឈើ ត្រូវកំណត់ដោយអនុក្រឹត្យ។ វិធាន និងបទបញ្ញាទំងនេះ ត្រូវគិតពីសក្តានុពល ហេតុប៉ះពាល់បរិស្ថាន នឹងផលប៉ះពាល់សង្គមនៃប្រភេទឈើដែលត្រូវជ្រើសរើសសំរាប់ការដាំនោះ ។

### មាត្រា ៦២

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា **មូលនិធិអភិវឌ្ឍន៍ឈើជាតិ** គ្រប់គ្រត់ចាត់ចែង និងទទួល ខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសហប្រធាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៦៣

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមានប្រភពចំណូលមកពី

១-វិភាគមានផ្សេងៗរបស់រាជរដ្ឋាភិបាល ។

២-បុព្វលាភលើផល អនុផលព្រៃឈើ ។

៣-ប្រាក់ចំណូលអភិរក្សសត្វព្រៃ ។

៤-ជំនួយរបស់អង្គការអន្តរជាតិនានា

៥-អំណោយពីសប្បុរជន និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

៦-កំរៃសេវាផ្សេងៗ ពីវិស័យព្រៃឈើ ។

រាល់ចំណូលខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

## មាត្រា ៦៤

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមិនអាចត្រូវយកទៅប្រើប្រាស់សំរាប់ការរៀបចំនិងការប្រព្រឹត្តទៅនៃរដ្ឋបាលព្រៃឈើបានឡើយ ។

មូលនិធិនេះសំរាប់ប្រើប្រាស់ចំពោះតែសកម្មភាពនេះ

១-ការដាំដើមឈើឡើងវិញ ។

២-កិច្ចការរុក្ខវប្បកម្ម និងការស្តារព្រៃឈើឡើងវិញ ។

៣-កិច្ចការពារ និងអភិរក្សព្រៃឈើ និងជីវៈចម្រុះ ។

៤-ការស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រនៃព្រៃឈើ និងសត្វព្រៃ ។

៥-ការផ្សព្វផ្សាយអំពីវិស័យព្រៃឈើ និងសត្វព្រៃ ។

៦-ការអភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃ

៧-ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ។

៨-ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព្រៃឈើ និងសត្វព្រៃ ។

## ៤.២ ជំពូកទី ១៣ វិធានការគ្រប់គ្រងសកម្មភាពឈើ

### មាត្រា ៦៥

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបង្កើតញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាដើម្បី

១-វាយលើឈើស្របច្បាប់មុនពេលឱ្យដឹកជញ្ជូនចេញពីគំនរក្នុងព្រៃ។
២-វាយលើឈើដែលជាវត្ថុតាងនៃបទល្មើសព្រៃឈើ ។

ស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាមានរាងមូលហើយមានអក្សរកាត់ **រ.ក** និងលេខនៅពីក្រោមតួអក្សរនោះសម្រាប់សំគាល់ញញួរត្រានីមួយៗ ។

មុននឹងដាក់ឱ្យប្រើប្រាស់ញញួរត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើកំណត់ហេតុផ្តិតស្នាមញញួរ ត្រានេះ ហើយយកទៅដំកល់ទុកជាគំរូនៅក្រសួងមហាផ្ទៃ និងតុលាការខេត្ត ក្រុង ។

### មាត្រា ៦៦

ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាត្រូវតែបោះឱ្យបានជិតច្បាស់ដាច់ខាតដោយមន្ត្រីរដ្ឋបាលព្រៃឈើលើរាល់ឈើហ៊ុបដូចតទៅ :

១-ឈើហ៊ុបស្របច្បាប់ដែលត្រូវដឹកជញ្ជូនចេញពីគំនរក្នុងព្រៃរហូតដល់ទីដៅកំណត់ ត្រូវមានស្នាមញញួរ រដ្ឋបាលព្រៃឈើកម្ពុជាចំនួនពីបួន (៤)ឡើងទៅកន្លែងនីមួយៗ ខាងគល់ និងខាងចុងឈើហ៊ុប ។
២-ឈើហ៊ុបល្មើសច្បាប់ដែលរដ្ឋបាលព្រៃឈើបានឃាត់ចាប់ត្រូវមានស្នាមញញួរ (៣) គឺនៅខាងគល់ កណ្តាល និងខាងចុងឈើហ៊ុបដោយធ្វើឱ្យមានស្នាមបី (៣) រួមគ្នាបង្កើតជារាងត្រីកោណនៅកន្លែងនីមួយៗនោះ ។

ចំពោះដើមឈើដែលត្រូវអនុញ្ញាតអោយកាប់ក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាចំនួនមួយ (១) ជាសំគាល់ ។

ការកាន់កាប់ និងការប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាអាចប្រព្រឹត្តទៅបានគិតចំពោះមន្ត្រីរដ្ឋបាលព្រៃ ឈើដែលបានធ្វើសច្ចាប្រណិធាន។ វិធាននៃការគ្រប់គ្រង និងប្រើប្រាស់ញញួរត្រានោះត្រូវកំណត់ដោយប្រកាសរបស់ក្រ សួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៦៧

រាល់ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបអាចមានញញួរត្រាឯកជនសម្រាប់វាយលើផលព្រៃឈើរបស់ខ្លួនជា ស្នាមញញួរត្រាឯកជននេះ ត្រូវ មានរាង ទំហំ និងអក្សរសំពាល់ខុសពីស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ។ មុននឹងយកទៅប្រើប្រាស់ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវបញ្ជាក់កំណត់សញ្ញាសំគាល់ និងត្រូវផ្តិតស្នាមញញួរត្រា នោះ ទៅសុំការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ និងតម្កល់ទុកជាមុននៅការិយាល័យរដ្ឋបាលព្រៃឈើសាមី ។

## មាត្រា ៦៨

ទោះជាមានលិខិតអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើ ការប្រមូល ឬការដឹក ជញ្ជូនផលអនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវហាមឃាត់ចាប់ពីម៉ោងប្រាំបី( ៨ )យប់ដល់ម៉ោង ( ៥ )ភ្លឺ។

## មាត្រា ៦៩

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលចរាចរក្នុងទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើ គ្រប់ប្រភេទក្រោយពេលបានកាប់រំលំ ត្រូវដឹកជញ្ជូនចេញពីព្រៃឱ្យអស់មកធ្វើសន្និធិនៅតំនរ អចិន្ត្រៃយ៍ ក្នុងអំឡុងពេល មិនឱ្យលើសពីមួយ ( ១ )ខែឡើយ នឹងត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលជាសន្និធិ ទោះជានៅទីណាក៏ដោយ ក៏ត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិចេញឱ្យដោយរដ្ឋបាលព្រៃឈើ ។

ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬសន្និធិខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាពដឹកជញ្ជូន ឬ សន្និធិត្រូវចាត់ទុកជាល្មើសច្បាប់ ។

## មាត្រា ៧០

មុនពេលបើកការដ្ឋានប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវយកគ្រឿងចក្រ យានយន្ត និងវណារយន្តគ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើទៅសុំការអនុញ្ញាតចុះបញ្ជី នឹងបិទស្លាកជាសំគាល់នៅរដ្ឋបាលព្រៃឈើ ។

គ្រឿងចក្រ យានយន្ត និងវណារយន្តគ្រប់ប្រភេទដែលបំរើឱ្យការប្រមូលផល អនុផលព្រៃឈើដោយពុំបានចុះបញ្ជី នឹងបិទស្លាកជាសំគាល់របស់រដ្ឋបាលព្រៃឈើ ហើយធ្វើចរាចរក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ ។

រាល់គ្រឿងចក្រយានយន្ត និងវណារយន្តគ្រប់ប្រភេទដែលព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបស្របច្បាប់មានបំណង ធ្វើការនាំចូលដើម្បីបម្រើឱ្យការប្រមូល និងដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវឆ្លងកាត់ការវាយតម្លៃភាពសមស្របពីក្រ សួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការប្រើប្រាស់វណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋ បាលព្រៃឈើ ។

## មាត្រា ៧១

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវកំណត់ដោយប្រកាសនូវចំនួនមូលដ្ឋានឧស្សាហកម្មលើរោងចក អារឈើ សិប្បកម្មកែ ច្នៃផល អនុផលព្រៃឈើ ដើម្បីធានាបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមជាផល អនុផលព្រៃឈើប្រកប ដោយនិរន្តរភាព ។

វត្ថុធាតុដើមសម្រាប់មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើត្រូវមានប្រភពពីព្រៃសម្បទាន ព្រៃគុប ឈើរឹបអូស ឬពីប្រភពស្របច្បាប់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ នេះ ។

## មាត្រា ៧២

ការនាំចេញផល អនុផលព្រៃឈើគ្រប់ប្រភេទទៅបរទេស ត្រូវសម្រេចតាមការកម្រិតកំណត់ប្រចាំឆ្នាំដោយរាជរដ្ឋា ភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

យថាប្រភេទផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូល ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ នាំចូលផល អនុផលព្រៃឈើ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

## មាត្រា៧៣

អាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើ ត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន ។ ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនេះត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។

រាល់ផល អនុផលព្រៃឈើនាំចេញដែល ចាំបាច់ត្រូវមានការត្រួតពិនិត្យជាមុនដោយមន្ទី រដ្ឋបាលព្រៃឈើ និងបិទសំណាខិតមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង និងទីលានបញ្ចេញទំនិញពីតយគំរូសំណា អនុផលព្រៃឈើនាំចេញនេះ ត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវបង់ពន្ធនាំចេញ នាំចូល និងពន្ធផ្សេងៗទៀតចូលថវិកាជាតិ ។

## មាត្រា ៧៤

ឈើរសាត់តាមខ្សែទឹក គៀង ឬលិចដែលគ្មានដាក់សញ្ញា និងឈើគ្មានម្ចាស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋដោយដាក់លក់ឱ្យដេញថ្លៃជាសាធារណៈ ។

ក្នុងករណីមានបុគ្គលណាមួយទាមទារថា ឈើដូចមានចែងក្នុងក្របខ័ណ្ឌទី១ របស់ខ្លួននោះ ត្រូវឱ្យបុគ្គលនោះ បង្ហាញភស្តុតាងជាក់ស្តែង លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ លិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាត សន្និធិ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ចាប់ពីថ្ងៃប្រកាសជូនដំណឹងដោយរដ្ឋបាលព្រៃឈើ ។

ថ្លៃលក់ឈើ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ មាត្រា ៧៤ នៃច្បាប់នេះ ត្រូវបង់ចូលថវិកាជាតិ ។ ក្នុងករណីមានការបាត់បង់ឈើរសាត់តាមខ្សែទឹក គៀង ឬលិច ក៏ដូចជាការបាត់បង់ផល អនុផលព្រៃឈើផ្សេង ទៀត ដែលរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានធ្វើ មុខច្បាប់ ។ ឱ្យថែរក្សា បុគ្គល ឬអាជ្ញាធររដែលទទួលថែរក្សាត្រូវទទួលខុសត្រូវចំពោះ

## មាត្រា៧៥

បុគ្គលដែលប្រមូលដឹកជញ្ជូន កែច្នៃ សន្និធិ លក់ដូរ ឬនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវទទួលខុសត្រូវ ក្នុង ការបង្ហាញឯកសារដើមស្របច្បាប់នៃផល អនុផលព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ ។

## ៤.៣ ជំពូកទី ១៤ នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

### មាត្រា ៧៦

បទល្មើសព្រៃឈើ ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។ រដ្ឋបាលព្រៃឈើមាន សមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។

ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងវង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

### មាត្រា ៧៧

នៅពេលបំពេញបេសកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកម្ម ។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខជាមន្ត្រីនគរបាលយុត្តិធម៌បានលុះតែសាម៉ីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា៧៨

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាល ព្រៃឈើមានសមត្ថកិច្ច ។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែងអាជ្ញាធរទាំងនោះ

១-ត្រូវជូនព័ត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត ។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។

៣-មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ។

## មាត្រា ៧៩

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិ ដូចតទៅ

១-អាចអោយបុគ្គលណាមួយឆ្លើយតបសំណួរ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ

២-ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រកំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ច ជាប់ពាក់ព័ន្ធ ។

៣-ដកហូតជាបណ្តោះអាសន្ននូវ អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិន ជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនោះ ប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូល ឆែកឆេរនៅក្នុងទីធ្លា អាគារ ឬក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់ សង្ស័យ និងមានសាក្សីពីរ (២)នាក់ ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

## មាត្រា៨០

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនិតិសម្បទាជានរគបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន :

១-រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលល្មើស និងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ ។

៣-គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្ត បទល្មើសព្រៃឈើ និងសត្វព្រៃ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស ព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។

## មាត្រា ៨១

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

## មាត្រា ៨២

វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោម :

១-ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ។
២-សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើស ត្រូវ បានដោះស្រាយរួចជាស្ថាពរ ពាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជំរះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូន ដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសម គំនិត ។

ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុកហើយ ងាយខូចខាត ផ្នែករដ្ឋបាលព្រៃ ឈើមានសិទ្ធិបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ ។

## មាត្រា ៨៣

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ ។

## មាត្រា៨៤

ទៅរាល់ពេលសវនាការ មន្រ្តីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំ រឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ ។

## មាត្រា ៨៥

អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើមាន :

១-បទល្មើសព្រៃឈើថ្នាក់ទី១ មានអាជ្ញាយុកាលដប់ប្រាំ( ១៥ ) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

២-បទល្មើសព្រៃឈើថ្នាក់ទី២ មានអាជ្ញាយុកាលប្រាំ ( ៥ )ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

៣-បទល្មើសព្រៃឈើថ្នាក់ទី៣ មានអាជ្ញាយុកាលមួយ ( ១ ) ឆ្នាំគិតពីពេលប្រព្រឹត្តបទល្មើស ។

ការអនុវត្តន៍អាជ្ញានៃបណ្តឹងបទល្មើសព្រៃឈើ ត្រូវ ស្របតាមនីតិវិធីព្រហ្មទណ្ឌ។

## មាត្រា ៨៦

បុគ្គលដែលប្រព្រឹត្តបទល្មើស ព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬឯកជនដែលប្រើប្រាស់មធ្យោបាយរបស់អង្គភាពដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ បុគ្គល ឬប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គល ឬក្រុម ក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គ ភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## មាត្រា ៨៧

រូបវន្តបុគ្គលបរទេស ឬនីតិបុគ្គលបរទេសដែលមានបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនេះ។

## មាត្រា ៨៨

មន្រ្តីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូល ឬ មួយផ្នែក មួយរយៈ ដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានីកប្រព្រឹត្តល្មើសនឹងបទប្បញ្ញតិនៃច្បាប់នេះ ឬ ល្មើស នឹងកិច្ចព្រមព្រៀងព្រៃសម្បទានរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបន្ទាប់ ។

### មាត្រា ៨៩

បុគ្គលណាដែល មិនពេញចិត្ត ចំពោះការសម្រេចណាមួយធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្រប តាមច្បាប់នេះមាន សិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ។ ក្រោយពី បានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយមានប្រធានរដ្ឋបាលព្រៃឈើក្នុងករណីមិនអាចទទួលយកបាន ជននោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តន៍ច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

## ៤.៤ ជំពូកទី១៥ បទល្មើសឈើ និងទោសប្បញ្ញត្តិ

### មាត្រា ៩០

ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន : ទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការ ពិន័យអន្តរការណ៍ ការជួសជុលការខូចខាត ការព្រមាន ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការជួសជុលការខូចខាត និងការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬជួសជុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំ រឿងបទល្មើសទៅតុលាការ ។

ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលមានកំណត់ក្នុងច្បាប់នេះ ។

### មាត្រា ៩១

រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើដូចមានចែងក្នុងមាត្រា៩៦នៃច្បាប់នេះការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើអាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស នឹងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

បែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់នេសាទ ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :

១-ការខូចខាតដល់បរិស្ថាន ។
២-ចំនួននៃការប្រព្រឹត្តល្មើស ។
៣-បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។
៤-ការប្រព្រឹត្តល្មើសដោយចេតនា ។

## មាត្រា ៩២

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាងត្រូវបង់ចូលក្នុងថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាប បទល្មើសព្រៃឈើជាក់លាក់ណាមួយ ។

## មាត្រា ៩៣

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំទៅដល់ដប់ (១០)ឆ្នាំនិងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។

២-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំទៅប្រាំ (៥)ឆ្នាំ និង/ឬត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីដប់លាន១០.០០០.០០០)រៀល ទៅមួយរយលាន( ១០០.០០០.០០០) រៀល ។ វត្ថុតាងទាំងត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ។

៣-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ(១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់អាចត្រូវ រឹបអូសមកជាសម្បត្តិរដ្ឋ ។

៤-ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

តម្លៃទីផ្សារ ជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តន៍ឯកភាពទូទាំងប្រទេស ។

### មាត្រា ៩៤

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញស្តារ ជួស ជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

### មាត្រា ៩៥

រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាននិងតម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :

១-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំការឈើ ឬថ្នលកូនឈើរបស់រដ្ឋ ដោយបំផ្លាញឈើ ឬកូនឈើនៅទីនោះ ។

២-ធ្វើឱ្យរបួស ឬធ្វើឱ្យខូចខាតដល់ដើមឈើ ឬរុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬដែលបានដាំ ។

៣-លួច ឬធ្វើឱ្យខូចខាតដល់របង បង្គោល ឬស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬក្នុងដែនបម្រុងទុកអចិន្ត្រៃយ៍ ។

### មាត្រា ៩៦

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពី ពីរ (២)ទៅបី(៣)ដងនៃតម្លៃវត្ថុតាងពិតប្រាកនៃទីផ្សារ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។

២-ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៣-ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៤-ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៥-ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។

៦-មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។ ៧-ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។

៨-នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ

៩-កាប់រំលំ អារ ចៀក និងចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬប្រើរណារយន្តជាមធ្យោបាយ ប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា ។

១០-ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។

១១-ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់។

១២-ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ឬប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៣-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយ បានមកពីការកាប់ ឬរុករក ដឹកជញ្ជូន កែច្នៃ។

១៤-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

១៥ -នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ។

១៦-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។

១៧-យកធ្វើកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ។

១៨-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។

១៩-ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយបង្គួរដោយគ្មានលិខិតអនុញ្ញាត ។

២០-បរបាញ់ក្នុងទីសាធារណៈ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ មិនរាងចាលក្នុងរយៈពេលមួយ (១)ខែ ត្រូវ ទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួន ពីពីរ (២)ទៅបួន (៤) ដង នៃតម្លៃវត្ថុតាងពិតប្រាកដ ទីផ្សារ ។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ វត្ថុតាងផ្សេង ទៀតក្រៅពីផល អនុផលព្រៃឈើ អាចប្រគល់ឱ្យសាមីជនវិញតែក្នុងករណី ប្រព្រឹត្តល្មើសនឹងមាត្រា ៩៦នៃច្បាប់នេះ ។

## មាត្រា ៩៧

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១ ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥) ឆ្នាំ ទៅដប់ (១) ឆ្នាំ និងត្រូវ រឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងកំទេចចោលវត្ថុតាង ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហ៊ុប

២-ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ឬពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ

៣-ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬសត្វព្រៃ ។

៤-បំផ្លាញ កំបាំង លក់ ឬលួចវត្ថុតាងព្រៃឈើ ។

៥-កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ ។

៦-កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ព្រៃឈើ ។

៧-បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា ។

៨-គៀរ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬតាសំ រំលើងប្រមូលគល់ឈើ។

៩-បង្កើតមូលដ្ឋានកែច្នៃរល្លីរមៀត ឬមូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំផ្លាញ ព្រៃឈើ និងមជ្ឈដ្ឋានព្រៃឈើ ។

១០ -បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី១ មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

## មាត្រា ៩៨

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវ ផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០, ០០០.០០០)រៀល ឬផ្តន្ទាទោស ណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១-មិនគោរពតាមបទបញ្ញាបច្ចេកទេសដែលបានកំណត់ក្នុងក្រុមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

២-មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣-យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ ។

៤-ប្រើប្រាស់គ្រឿងចក្រយានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសំគាល់ ។

៥ –គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦-ប្រើប្រាស់ព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬ ដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ ។

៧-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និងមធ្យមដោយគ្មានប្រកាស ។

៨-បង្កើតឡ គ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩-បរបាញ់ក្នុងរដូវកាលហាមឃាត់ ឬក្នុងតំបន់ការពារ ។

១០-បរបាញ់សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ។

១១-របាញ់សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវសាស្ត្រសត្វ ។

១២-យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលប្រភេទសត្វរស់ និងសំណាកក្នុងក្រុមជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវ ផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០.០០០.០០០.)រៀល ទៅមួយរយលាន

( ១០០ .០០០.០០០) រៀល វត្ថុតាង ទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២-ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬក្រៅភូមិសាស្ត្រដែលកំណត់ ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣-ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤-កាប់ដើមឈើក្នុងចំការ ដាំឈើរបស់រដ្ឋ ។

៥-ប្រមូលផល អនុផលព្រៃឈើ ចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាត ឱ្យកាប់ រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោរយកជ័រតាមប្រពៃណី និងប្រភេទឈើផ្តល់ជ័រមានតម្លៃ ។

៦-នាំចូល គ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ និង គ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧-នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ២ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១នៃច្បាប់

## មាត្រា ៩៩

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ៣ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ខែទៅមួយ (១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀលទៅដប់លាន (១០.០០០.០០០)រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបាន ប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១-ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការ អនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

២-នាំចូលគ្រឿងចក្រយានយន្ត និងរណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើ ដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣-នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទរបស់រដ្ឋបាលព្រៃឈើលើ ។

៤-យាយី ធ្វើឱ្យរបួស ប្រមូលពង កូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយក ឬបំផ្លាញជម្រករបស់វា ។

៥ -បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយគ្មានលិខិតអនុញ្ញាត ឬផ្ទុយពីការកំណត់ ។

៦-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬជាប្រភពថាមពល ខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី៣មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើ ថ្នាក់ទី ២ នៃ ច្បាប់នេះ ។

## មាត្រា ១០០

សកម្មភាពទាំងឡាយណាដលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលជួយដល់អាជីវកម្មព ឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ រាំង ស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោស ជាប់ពន្ធនាគារពីមួយ (១)ឆ្នាំទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០.០០០.០០០)រៀលទៅមួយរយលាន(១០០.០០០.០០០)រៀល ។

មាត្រា ១០១

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើសនិងត្រូវ ផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០,០០០)រៀល

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ ក្នុងសកម្មភាព ណាមួយ នៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

៣-អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។

៤-ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តីជាម្ចាស់ភាគហ៊ុនក្តីឬធ្វើជានិយោជិក ឬអ្នកជានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១) ឆ្នាំ ក្រោយពីការ ឈប់កាន់តំណែងដោយប្រការ ណាក៏ដោយ ។

៥-មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ដែលបានកើតក្នុងរង្វង់ សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍ អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ។

## ៤.៥ ជំពូកទី ១៦ ការអនុវត្តសាលក្រមតុលាការ

មាត្រា ១០២

ការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ ភារកិច្ចរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចលើកលែងតែទោសជាបំពន្ធនាគារ ។

មាត្រា ១០៣

រាល់សម្រេង់សាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

មាត្រា១០៤

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ ។

## ៤.៦ ជំពូកទី ១៧ អន្តរប្បញ្ញត្តិ

### មាត្រា ១០៥

ព្រៃសម្បទានទាំងឡាយ ទោះជាមានស្រាប់នៅមុនពេលច្បាប់នេះចូលជាធរមានក្តី ឬបានផ្តល់ឱ្យក្រោយៗមក ទៀត តាមការដាក់ឱ្យដេញថ្លៃជាសាធារណៈ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ក្តីព្រៃសម្បទានឹកត្រូវចុះកិច្ចព្រម ព្រៀងព្រៃសម្បទាន តាមគំរូថ្មីតែមួយជា មូលដ្ឋាន ។

### មាត្រា ១០៦

នៅទីណាដែលរដ្ឋបាលព្រៃឈើមានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីព្រៃណាមួយបានមកពីការកាប់រាន ដីព្រៃឈើ រដ្ឋដោយខុសច្បាប់មុនច្បាប់នេះចូលជាធរមាន រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតជូនដំណឹងក្នុងនាមរាជរដ្ឋាភិបាលជា ម្ចាស់កម្មសិទ្ធិលើដីព្រៃឈើរដ្ឋដោយធ្វើការបណ្តេញ និងទាមទារកម្មសិទ្ធិដីព្រៃឈើរដ្ឋមកវិញដោយឥតលក្ខខណ្ឌ ។

### មាត្រា ១០៧

នៅពេលច្បាប់នេះចូលជាធរមាន រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានបង្កើត ឡើង នឹងកំពុងដំណើរការក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឱ្យ ស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពរហូតដល់ផុតសុពលភាពនៃប្រកាស ។

ចំពោះរោងចក្រកែច្នៃផល អនុផលព្រៃឈើត្រូវបំពេញបែបបទសុំបន្តផលិតកម្ម អាជីវកម្មស្របតាមនីតិវិធីដូចមាន ចែងក្នុងច្បាប់នេះក្នុងរយៈពេលប្រាំមួយ (៦)ខែ គិតពីច្បាប់នេះចូលជាធរមាន ។

## ៤.៧ ជំពូកទី ១៨ អវសានប្បញ្ញត្តិ

### មាត្រា ១០៨

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

### មាត្រា ១០៩

ច្បាប់នេះត្រូវ ប្រកាសជាការប្រញាប់ ។

# ជំពូក៣ កម្មវិធីព្រៃឈើថ្នាក់ជាតិ

## មេរៀនទី៥ ទស្សនវិស័យ បេសកកម្ម និងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

### ៥.១ ទស្សនវិស័យ និងបេសកកម្ម

ទស្សនវិស័យនិងបេសកកម្មរបស់កម្មវិធីព្រៃឈើជាតិត្រូវបានកំណត់ចេញពីការពិភាក្សាជាមួយបណ្ដាអ្នកពាក់ព័ន្ធ នៅក្នុង សិក្ខាសាលាជាច្រើនលើក។ តាមរយៈការពិភាក្សាជាច្រើនលើក និងការពិគ្រោះយោបល់ជាសាធារណៈ ៦ លើកបានកំណត់ចេញជា ពាក្យស្លោកមួយថា " និរន្តរភាពព្រៃឈើសម្រាប់ប្រជាជនរបស់យើង ។

ទស្សនវិស័យ បានពិពណ៌នាអំពីសេចក្ដីប្រាថ្នា និងទិសដៅសម្រាប់អនាគតជាគោលដៅរយៈពេលវែង។ បេសកកម្ម គឺបានសំយោគចញពីទស្សនវិស័យ និងជាប្រយោគមួយខ្លីដែលបង្ហាញថា តើត្រូវធ្វើបែបណា ដើម្បីឈានទៅសម្រេចទស្សនវិស័យបាន។

- **ទស្សនវិស័យនៃកម្មវិធីព្រៃឈើជាតិ**

ទស្សនវិស័យនៃរាជរដ្ឋាភិបាលកម្ពុជា គឺ ការគ្រប់គ្រងធនធានព្រៃឈើដែលជានានិរន្តរភាព អេកូឡូស៊ី សេដ្ឋកិច្ច-សង្គម វប្បធម៌ និងបរិស្ថាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពសាធារណៈ។

- **បេសកកម្មនៃកម្មវិធីព្រៃឈើជាតិ**

បេសកម្មរួមរបស់យើង គឺជម្រុញឱ្យមាន ការគ្រប់គ្រង និងការអភិវឌ្ឍព្រៃឈើប្រកបដោយ និរន្តរភាព ដើម្បីរួមចំណែកដល់ការកាត់បន្ថយ ភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ ការ អភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថាន រួមទាំងការ អភិរក្សជីវចម្រុះ និងមរតកវប្បធម៌របស់យើង។

របនាសម្ព័ន្ធអភិបាលកិច្ចរួមបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ហើយការកំណត់ច្បាស់លាស់ជាងនេះ គឺមានចែងក្នុងឋានានុក្រម ច្បាប់និងបទប្បញ្ញត្តិផ្សេងៗ។ ផែនការនៃវិស័យនីមួយៗ គឺផ្អែកទៅតាមគោលបំណង និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួបផ្សំស្មារតី ក្នុងអនុសញ្ញានិងពិធីសារអន្តរជាតិ ក៏ដូចជាកិច្ចព្រមព្រៀងនានាដែលបានបង្កើតឡើងក្នុងតំបន់។

អភិបាលកិច្ចល្អ គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណទាំងពីរដំណាក់កាល សម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណនេះបានកំណត់សសរទ្រូងពាសំខាន់ៗ សម្រាប់វិស័យព្រៃឈើ ហើយការកំណត់នេះ មានចែងផងដែរ នៅ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍ

ន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។ ការការពារ និងការបង្កើនធនធានធម្មជាតិត្រូវបានកំណត់ថាជាកូនសោគន្លឹះក្នុងការអភិវឌ្ឍជនបទ ហើយប្រការនេះក៏មានការទទួលស្គាល់នៅក្នុងគោលដៅអភិវឌ្ឍន៍សហវត្សកម្ពុជាដែរ។ អ្វីដែល ពាក់ព័ន្ធនឹងវិស័យព្រៃឈើ ត្រូវបានកំណត់នៅក្នុងគោលដៅទី៧៖ ស្ថេរភាពបរិស្ថាន ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព និងការ ថែរក្សាគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃដីសរុបរបស់ប្រទេសនៅឆ្នាំ ២០១៥។

- **គោលបំណងរួមរបស់កម្មវិធីព្រៃឈើជាតិ**

"ធនធានព្រៃឈើផ្តល់វិភាគទានជាអតិបរមាដល់កំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតាមតំបន់ជនបទ តាមរយៈការអភិរក្សនិងការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាព ដោយមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធទាំងអស់ "

- **គោលបំណងជាយុទ្ធសាស្ត្រ**

- **គោលបំណងទី១** បង្កើនជាអតិបរមានូវការទទួលផលប្រយោជន៍ពីព្រៃឈើឱ្យមាននិរន្តរភាព ដើម្បីចូលរួម បង្កើនជីវភាព កាត់បន្ថយ ភាពក្រីក្រ និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។
- **គោលបំណងទី២** បន្សាំជាមួយការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយឥទ្ធិពលអាក្រក់នៃការប្រែប្រួអាកាសធាតុទៅលើជីវភាពរស់នៅដែលពឹងអាស្រ័យលើព្រៃឈើ។
- **គោលបំណងទី៣** ជំរុញឱ្យមានការរៀបចំផែនការរួមនៃការប្រើប្រាស់ដី ដែលអនុញ្ញាតឱ្យមានការធ្វើ ផែនការគ្រប់ជ្រុងជ្រោយ ដោយឆ្លងផុតពីវិស័យ ពីដែនយុត្តាធិការ និងពីព្រំប្រទល់រដ្ឋបាលមូលដ្ឋាន ដើម្បីពង្រឹងការអនុវត្តកម្មវិធីព្រៃឈើជាតិប្រកបដោយនិរន្តរភាព។
- **គោលបំណងទី៤** ពង្រឹងអភិបាលកិច្ចក្នុងវិស័យព្រៃឈើ និងពង្រឹងការអនុវត្តច្បាប់នៅគ្រប់កម្រិត។
- **គោលបំណងទី៥** ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទំនាស់ពាក់ព័ទ្ធនិងវិស័យព្រៃឈើទាំងក្នុងនិងក្រៅប្រព័ន្ធ តុលាការ។
- **គោលបំណងទី៦** លើកកម្ពស់ការយល់ដឹង បង្កើនសមត្ថភាពមនុស្ស ស្ថាប័ន និងគុណភាពអប់រំបណ្តុះបណ្តាល ដើម្បីឱ្យការអនុវត្ត កម្មវិធីព្រៃឈើជាតិប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។
- **គោលបំណងទី៧** ធានាឱ្យបាននូវការអភិរក្សធនធានព្រៃឈើ និងកិច្ចការពារបរិស្ថាន។

- **គោលបំណងទី៨** អនុវត្តគំរូថ្មីៗនៃការគ្រប់គ្រងព្រៃឈើដោយចីរភាពដែលសមស្របទៅតាមស្ថានភាព លក្ខខណ្ឌ មុខងារ សក្ដានុពល ជាក់ស្ដែងរបស់ព្រៃឈើ និងស្របទៅតាមបរិបទនៃការប្រែប្រួល។
- **គោលបំណងទី៩** អភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញប្បទានព្រៃឈើប្រកបដោយនិរន្តរភាព រួមទាំងការធ្វើពាណិជ្ជកម្មឥណទានកាបូនព្រៃឈើ និងបង្កើតប្រព័ន្ធគណនេយ្យកាបូនព្រៃឈើជាតិផងដែរ។

## ៥.២ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង ព្រៃឈើឱ្យមាននិរន្តរភាព

### ៥.២.១ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ១ គឺបង្កើនជីវភាពរស់នៅ ការងារ និងសេដ្ឋកិច្ច

សិទ្ធិប្រើប្រាស់ធនធានព្រៃឈើ និងដីព្រៃឈើរបស់ជនជាតិភាគតិច និងសហគមន៍មូលដ្ឋានត្រូវបានធានាតាមរយៈ ការបង្កើនចំណេះដឹង និងការអនុវត្តច្បាប់។ ការបង្កើតការងារគឺជាគោលបំណងរួមរបស់ជាតិ ហើយនឹងត្រូវបានបង្កើន តាមរយៈការអនុវត្តសកម្មភាពគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដូចជាការថែទាំព្រៃឈើ ការដាំដុះដើមឈើ ការស្ដារ ព្រៃឈើឡើងវិញ ការធ្វើរុក្ខវប្បកម្ម ការផលិតអនុផលព្រៃឈើ នឹងការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសជនបទធុនតូច និង មធ្យម ដែលអាចបន្ថែមតម្លៃដល់ផលិតផលព្រៃឈើស្របតាមលក្ខណៈប្រកួតប្រជែងទីផ្សារ និងប្រសិទ្ធភាពតម្លៃផលិតកម្ម។ យើងមានសក្ដានុពលធំណាស់ក្នុងការបង្កើនតម្លៃបន្ថែមដល់ផលអនុផលព្រៃឈើដែលយកមកប្រើប្រាស់ ឬលក់ ដោយមិន ទាន់បានកែច្នៃឱ្យអស់លទ្ធភាព និងសមត្ថភាពនៅឡើយ។

ការបង្កើនប្រសិទ្ធភាពនៃការដកហូត ការបញ្ចូលបច្ចេកវិជ្ជាកែច្នៃ (បង្កើនចង្វាក់តម្លៃ/ផលិតកម្ម) នឹងអាចបង្កើត ជាបន្តបន្ទាប់ គួបផ្សំជាមួយនឹងការឈានចូលទីផ្សារដែលផ្ដល់តម្លៃខ្ពស់នឹងអាចបង្កើនប្រាក់ចំណូលសម្រាប់សហគ្រាស ការងារ និងសិប្បកម្មផលិតផលព្រៃឈើនៅក្នុងស្រុក។ យន្តការធ្វើវិញ្ញាបនបត្របញ្ជាក់គុណភាពផល-អនុផលព្រៃឈើអាចជួយ ផ្ដល់ជាមធ្យោបាយសម្រាប់អនុវត្តការងារ។ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានលើកទឹកចិត្តក្នុងការ បណ្ដុះបណ្ដាលអភិវឌ្ឍន៍សមត្ថភាព និងបច្ចេកវិជ្ជាសម្រាប់ជួយដល់ឱកាសទាំងនេះ។

យើងនឹងផ្ដល់អាទិភាពដល់ការអភិវឌ្ឍគំរូគ្រប់គ្រងព្រៃឈើបែបសហគមន៍ព្រៃឈើបែបឯកជន និងបែបរដ្ឋ ដែល អាចទ្រទ្រង់ថវិកាខ្លួនឯងបាន។ សកម្មភាពព្រៃឈើដែលមានការគ្រប់គ្រងត្រឹមត្រូវនឹងផ្ដល់ប្រាក់ចំណូលឱ្យរដ្ឋតាមរយៈ ការ បង់ថ្លៃសួយសារផល-អនុផលព្រៃឈើ ពន្ធដារលើការធ្វើអាជីវកម្ម ពាណិជ្ជកម្មពីក្រុមហ៊ុនឯកជន សហគ្រាស សហគមន៍ ការលក់ឥណទានកាបូន ការបង់ថ្លៃសេវាកម្មបរិស្ថានព្រៃឈើ និងសម្បទានអភិរក្សផ្សេងៗទៀត។

ក៏ដូចជាសេដ្ឋកិច្ចផ្អែកលើកសិកម្មដែរ វិស័យព្រៃឈើ និងឧស្សាហកម្មកែច្នៃព្រៃឈើ ក៏មានសារៈសំខាន់ចំពោះការ លូតលាស់ ការកាត់បន្ថយភាពក្រីក្រ និងការធានាសន្តិសុខស្បៀងផងដែរ។ ការប្រើប្រាស់កសិកម្មជាមូលដ្ឋាន សម្រាប់ កំណើនសេដ្ឋកិច្ចទាមទារឱ្យមានការធ្វើបដិវត្តន៍ផលិតភាពនៅតាមកសិដ្ឋានធុនតូច ខណៈដែលការដាំចម្ការព្រៃឈើអាច ចូលរួមវិភាគទានដល់ការលើកកំពស់កសិដ្ឋានតូចៗឱ្យចេញផុតពីភាពក្រីក្រ តាមរយៈការបញ្ចូលគ្នានៃការធ្វើកសិកម្មផលិតផល ការលក់ឥណទានកាបូន ការបង់ថ្លៃសេវាកម្មបរិស្ថានព្រៃឈើ និងសម្បទានអភិរក្សផ្សេងៗទៀត។

ក៏ដូចជាសេដ្ឋកិច្ចផ្អែកលើកសិកម្មដែរ វិស័យព្រៃឈើ និងឧស្សាហកម្មកែច្នៃព្រៃឈើ ក៏មានសារៈសំខាន់ចំពោះការ លូតលាស់ ការកាត់បន្ថយភាពក្រីក្រ និងការធានាសន្តិសុខស្បៀងផងដែរ។ ការប្រើប្រាស់កសិកម្មជាមូលដ្ឋាន សម្រាប់ កំណើនសេដ្ឋកិច្ចទាមទារឱ្យមានការធ្វើបដិវត្តន៍ផលិតភាពនៅតាមកសិដ្ឋានធុនតូច ខណៈដែលការ ដាំចម្ការព្រៃឈើអាច ចូលរួមវិភាគទានដល់ការលើកកំពស់កសិដ្ឋានតូចៗឱ្យចេញផុតពីភាពក្រីក្រ តាមរយៈការបញ្ចូលគ្នានៃការធ្វើកសិកម្មផលិតផល ព្រៃឈើ និងកសិរុក្ខកម្ម។ ការធ្វើកសិរុក្ខកម្មនឹងជួយបង្កើនទិន្នផលកសិកម្មជាមួយគ្នានឹងការទទួលបានបន្ថែមនូវផលិតផលព្រៃឈើ និង សេវាកម្មព្រៃឈើផង

ដែរ។

## ៥.២.២ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ២ គឺបញ្ហាប្រែប្រួលអាកាសធាតុ

ការកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនឹងត្រូវកំណត់តាមរយៈយន្តការហិរញ្ញវត្ថុនៃការកាត់ បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ (EDD) យន្តការអភិវឌ្ឍស្អាត (CDM) នៃពិធីសារ - eang នឹងយន្តការច្នៃប្រឌិតផ្សេងៗទៀត។ ទីផ្សារឥណទានកាបូនព្រៃឈើអន្តរជាតិ មានទាំងទីផ្សារក្រោមលក្ខខណ្ឌផ្លូវការ និងទីផ្សារស្ម័គ្រចិត្ត ដែលចាំបាច់ត្រូវធ្វើការអភិវឌ្ឍ និងអនុវត្តឱ្យបាន ដើម្បីជាការលើកទឹកចិត្តបន្ថែមដល់ការគ្រប់គ្រង ការការពារព្រៃឈើ និងការស្តារការ ដាំដុះព្រៃឈើឡើងវិញ ជាពិសេសសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សហគមន៍មូលដ្ឋាន ។

ការសិក្សាអំពីការបន្សុំ និងយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធនឹងសកម្មភាពព្រៃឈើក្នុងការចូលរួមចំណែកក្នុងការជំនះលើការ គំរាមកំហែងដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដើម្បីធានាសន្តិសុខស្បៀង បង្កើនជីវភាពរស់នៅ និងកែលំអការគ្រប់គ្រង បរិស្ថាន។ ដូច្នេះការងារនេះ នឹងអាចជាផ្នែកមួយនៃការបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិរក្សនាពេលអនាគត។

### ៥.២.៣ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៣ គឺការរៀបចំផែនការប្រើប្រាស់ដីធ្លី

ចរិតលក្ខណៈពហុវិស័យរបស់កម្មវិធីព្រៃឈើជាតិ គឺសង្កត់ធ្ងន់លើការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធផែនការជាតិដែល ធ្វើឱ្យមានសុខដុមនីយកម្ម និងភាពស៊ីសង្វាក់គ្នារវាងវិស័យព្រៃឈើ និងវិស័យផ្សេងៗក្នុងក្របខណ្ឌរួមរបស់ជាតិ។ ការកែលម្អផែនការ ប្រើប្រាស់ដី និងការធ្វើកិច្ចសហការរវាងបណ្ដាក្រសួង ស្ថាប័នផ្សេងៗ គឺជាមូលដ្ឋានធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ដី និងការរៀបចំ ផែនការធនធានសម្រាប់ជាប្រយោជន៍ដល់វិស័យទាំងអស់ និងសង្គមជាតិ។ ការងារនេះ តម្រូវឱ្យមានការសម្របសម្រួលពីក្រុមការងារ បច្ចេកទេសចម្រុះ (I'W) ដែលមានតំណាងមកពីបណ្ដាក្រសួងស្ថាប័ននរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ផងដែរ។ ការកំណត់ព្រំប្រទល់ព្រៃឈើនឹងអាចជួយដោះស្រាយបញ្ហាការងារត្រួតស៊ីគ្នា ឬការប្ដឹងតវ៉ានានា។

### ៥.២.៤ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៤ គឺអភិបាលកិច្ចល្អវិស័យព្រៃឈើ

ដើម្បីសម្រេចបានអភិបាលកិច្ចល្អវិស័យព្រៃឈើ គឺតម្រូវឱ្យមានការបែងចែកអំណាចតាមវិធីមួយដែលមានតម្លាភាព និងប្រជា ធិបតេយ្យដែលអាចបំរើគ្រប់ផ្នែកនៃសង្គមបានល្អបំផុត។ អភិបាលកិច្ចព្រៃឈើផ្សារភ្ជាប់ជាមួយគោលនយោបាយ នីតិកម្ម ការពង្រឹងច្បាប់ និងការអនុវត្តរបស់ស្ថាប័នទូទៅ។ ការកែលម្អអភិបាលកិច្ចគឺផ្ដោតទៅលើ ៖

- ការបង្កើតភាពជឿជាក់ក្នុងវិស័យព្រៃឈើ តាមរយៈការបង្កើតប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនៃការត្រួតពិនិត្យ និង តុល្យភាព (Check und Balance) ដើម្បីធានាថាអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ ត្រូវបានអនុវត្ត ដាច់ដោយឡែកត្រឹមត្រូវ និងឯករាជ្យ។
- ដំណើរការនៃការចូលរួម និងការពិគ្រោះយោបល់ គឺដើម្បីបង្កើតឱ្យមានភាពជឿជាក់កាន់តែរឹងមាំ ហើយជំរុញឱ្យ មានការចូលរួមពីបណ្ដាអ្នកពាក់ព័ន្ធតាមរយៈដំណើរការរៀបចំកម្មវិធីព្រៃឈើជាតិ និងការរៀបចំយុទ្ធសាស្ត្រ ទំនាក់ទំនងក្នុង ការផ្ដល់និងទទួលព័ត៌មានស្ដីពីវិស័យព្រៃឈើ និងការគ្រប់គ្រងធនធានព្រៃឈើ និងជីវចម្រុះប្រកបដោយតម្លាភាព។
- ការពង្រឹងនីតិកម្មព្រៃឈើនិងការអនុវត្តច្បាប់ នៅគ្រប់កម្រិតចំពោះរាល់ជនល្មើសនឹងរាល់សកម្មភាពល្មើសច្បាប់ ទាំងអស់ តាមរយៈការស្រាវជ្រាវ បង្ការ ទប់ស្កាត់ និងចាត់វិធានការបង្ក្រាបជាបន្ទាន់។
- កិច្ចសហការ និងការពិភាក្សា ត្រូវធ្វើជាមួយបណ្ដាភាគីអ្នកពាក់ព័ន្ធមកពីគ្រប់ជាន់ថ្នាក់នៃសង្គម ដើម្បីត្រួសត្រាយផ្លូវ ឈានទៅរកការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យព្រៃឈើឱ្យមាននិរន្តរភាព។

- ការបែងចែកផលប្រកបដោយសមធម៌ នឹងអាចចូលរួមចំណែកក្នុងការធានាលើកកំពស់ជីវភាពរស់នៅ របស់ប្រជាជន ដែលពឹងអាស្រ័យលើព្រៃឈើ គឺអាចធ្វើតាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រង ដើម្បីផលប្រយោជន៍ដល់អ្នកក្រីក្រ ដែលបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពជួយគ្រប់គ្រង ការពារ ដាំដុះ ថែទាំព្រៃឈើ។

### ៥.២.៥ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៥ គឺការគ្រប់គ្រងទំនាស់

ការគ្រប់គ្រងទំនាស់ដោយស្ថាប័ន គឺជាវិធីសាស្ត្រមួយអាចធ្វើបានល្អបំផុត ដើម្បីជួយបំពេញនូវភាពចាំបាច់ និងតម្រូវការនៃកិច្ច សហការនៅបរិបទតឹងតែងក្នុងស្ថានភាពដែលពោរពេញដោយភាពក្រីក្រ និងក្នុងស្ថានភាពដែលប្រជាជនកំពុងតែប្រវេប្រវាស្វែងរក មធ្យោបាយដើម្បីរស់ និងក្នុងស្ថានភាពដែលធនធានធម្មជាតិនិងសម្ពាធខ្លាំង ព្រមជាមួយការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅមានកម្រិត។

រដ្ឋបាលព្រៃឈើ នឹងត្រូវបង្ការទប់ស្កាត់កុំឱ្យមានទំនាស់ពាក់ព័ន្ធនឹងវិស័យព្រៃឈើកើនឡើងរហូតដល់គ្រួតត្រាមិនបាន ហើយ អាចបង្កទៅជាការបំផ្លិចបំផ្លាញ ដោយត្រូវមាននីតិវិធី និងបច្ចេកទេសកាត់បន្ថយស្ថានភាពតឹងតែង។ រដ្ឋបាលព្រៃឈើ នឹងអាចអនុវត្ត បានតាមរយៈបច្ចេកទេសគ្រប់គ្រងទំនាស់ដូចខាងក្រោម ៖

- វិភាគ និងទប់ស្កាត់ទំនាស់ ដោយធ្វើការស្វែងយល់ និងកាត់បន្ថយបរិយាកាសដែលជំរុញឱ្យកើតទំនាស់។
- ទប់ស្កាត់ការរីកសាយទំនាស់ តាមរយៈការប្រើវិធីសាស្ត្រគ្រប់គ្រងទំនាស់ដ៏ប៉ិនប្រសព្វ ហើយទុកឱកាសសម្រាប់កិច្ចសហការនៅថ្ងៃអនាគត។

ប្រព័ន្ធគ្រប់គ្រងទំនាស់ជាផ្លូវការ គឺតម្រូវឱ្យមានសមត្ថភាព និងទេពកោសល្យក្នុងការបង្កើតទំនុកចិត្ត ចំណេះដឹង អំពីចរិត និង ទំហំនៃទំនាស់ ហើយនឹងការប្រើវិធីដោះស្រាយជាមួយគ្នានឹងអាចរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព។ រដ្ឋបាល ព្រៃឈើនឹងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងទំនាស់ចាប់ពីដំណាក់កាលដំបូង ដែលជាចំណុចអាចដោះស្រាយសម្រេចបានផលវិជ្ជមានសម្រាប់ការឈានទៅមុខ និងការអភិវឌ្ឍទៅរកការគ្រប់គ្រងដោយមាននិរន្តរភាព។

### ៥.២.៦ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៦ គឺការអភិវឌ្ឍសមត្ថភាព

បញ្ហាអន្តរវិស័យ និងសមត្ថភាពជាហានិយភ័យធំបំផុតដល់ភាពជោគជ័យនៃការអនុវត្តកម្មវិធីព្រៃឈើជាតិ ប្រកបដោយចីរភាព។

ការគ្រប់គ្រងធនធានព្រៃឈើទាមទារឱ្យមានស្ថាប័នមួយដែលមានការជឿជាក់ និងមានសមត្ថភាពបច្ចេកទេសជាច្រើនមុខវិជ្ជា និងមាននៅគ្រប់លំដាប់ថ្នាក់នៃអង្គភាពដើម្បីឆ្លើយតប និងបន្សាំទៅតាមស្ថានភាព និងការប្រែប្រួលនៃសាកលភាវូបនីយកម្ម។ ដើម្បី សម្រេចឱ្យបានជោគជ័យ យើងត្រូវកសាងសមត្ថភាពមន្ត្រីទៅតាមចំណង់ចំណូលចិត្តពិតប្រាកដ និងការសន្យារបស់ពួកគេ។ ការអភិវឌ្ឍសមត្ថភាពគឺជាការផ្លាស់ប្តូរតម្លៃ និងឥរិយាបទរបស់មនុស្ស ដើម្បីឱ្យពួកគេប្រើប្រាស់សមត្ថភាពជំនាញពិតប្រាកដក្នុងការគ្រប់គ្រង ព្រៃឈើដោយចីរភាព។

ការអនុវត្តចំណេះដឹងដែលទទួលបាន និងដើម្បីឱ្យមន្ត្រីសាធារណៈអនុវត្តចំណេះដឹងឱ្យបានល្អបំផុតនោះ គឺជាបញ្ហាប្រឈម មួយផ្សេងទៀត។ ទន្ទឹមនឹងយើងត្រូវការការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការងារ យើងក៏ត្រូវបង្កើនគុណភាពអប់រំបច្ចេកទេសនៅ ទាំង ៣ កម្រិតផងដែរ ទើបមានប្រសិទ្ធភាពបំផុតក្នុងការធានានិរន្តរភាព។ដោយធ្វើការគាំទ្រដល់វិស័យអប់រំនិងការបណ្តុះបណ្តាលណា ដែលចាំបាច់នៅពេលកំពុងបម្រើការងារ យើងសង្ឃឹមថាពួកគេអាចអភិវឌ្ឍន៍សមត្ថភាពដោយខ្លួនឯង។ ការវិនិយោគទៅលើការបង្កើន សមត្ថភាពដល់យុវវ័យរបស់យើងឱ្យក្លាយទៅជាអ្នកធ្វើសេចក្តីសម្រេចចិត្តដ៏ត្រឹមត្រូវបាននោះ គឺជាការវិនិយោគមួយដើម្បីអនាគត ធនធានធម្មជាតិរបស់យើង ហើយក៏ដើម្បីជីវិតនៃកូនចៅជំនាន់ក្រោយរបស់យើងដែរ។ ការកសាងសមត្ថភាពនឹងត្រូវផ្តោតទៅ ៖

- *ការអភិវឌ្ឍស្ថាប័នអប់រំបណ្តុះបណ្តាល* ដើម្បីផ្តល់នូវធនធានមនុស្សដែលល្អសក្តិសមបំផុតសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីឱ្យពួកគេមានលទ្ធភាពក្នុងការផ្តល់សេវាកម្មប្រកបដោយគុណភាព។ តម្រូវការបណ្តុះបណ្តាលមិន ត្រឹមតែការបណ្តុះទេពកោសល្យបច្ចេកទេសប៉ុណ្ណោះទេ តែថែមទាំងបច្ចេកទេសគ្រប់គ្រងខ្លួនឯង និងការផ្តល់សេវាកម្ម សាធារណៈតាមរយៈមេរៀនបទពិសោធន៍ និងការអនុវត្តជាក់ស្តែងផងដែរ។
- *ប្រសិទ្ធភាពនៃស្ថាប័ននិងធនធានមនុស្ស* គឺជាការយកចិត្តទុកដាក់ទៅលើអាទិភាពរបស់ស្ថាប័ន លើការងារយុទ្ធសាស្រ្តនិងលទ្ធផលស្រាវជ្រាវដែលត្រូវអនុវត្តដោយបុគ្គលិកដែលសកម្មក្នុងការងារ និងមានសមត្ថភាពបច្ចេកទេស និងសមត្ថភាពចាត់ចែងក្នុងកិច្ចសហការជាមួយបណ្តាភាគីអ្នកពាក់ព័ន្ធ។
- *ការកសាងសមត្ថភាពនិងផ្តោតលើគុណធម៌ឥរិយាបទ និងការអនុវត្តចំណេះដឹង* តាមរយៈការចូលរួមអនុវត្ត និងរៀនសូត្រក្នុងបរិយាកាសជាក់ស្តែងនៃជីវិតពិត ការដើរតួការផ្ទេរចំណេះដឹង ការទទួលបាននូវការបណ្តុះបណ្តាលក្នុង ពេលធ្វើការងារជាមួយអង្គភាព ឬក្រុមផ្សេងៗទៀត ដើម្បីទទួលបានចំណេះដឹងជំនាញ និងមានសមត្ថភាពសម្រាប់បំពេញ ភារកិច្ចដែលដាក់ឱ្យ។

### ៥.២.៧ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី៧ គឺការការពារបរិស្ថាន និងការអភិរក្សធនធានព្រៃឈើ

ការវាយតម្លៃសេដ្ឋកិច្ចសរុបនៃផលិតផល និងសេវាកម្មរបស់ព្រៃឈើនឹងត្រូវធ្វើការសិក្សាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ប្រើប្រាស់ដីធ្លី។ ការវាយតម្លៃនេះ រួមមានមុខងារអេកូឡូស៊ីពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹក ការការពារហេដ្ឋារចនាសម្ព័ន្ធជីវចម្រុះ និង សក្តានុពលប្រាក់ចំណូលពីការលក់ឥណទានកាបូន។ ការអភិរក្សព្រៃឈើដែលនៅល្អនឹងអាចស្រូបបាននូវប្រាក់ចំណូលតាមរយៈការ បង់ប្រាក់សម្រាប់សេវាកម្មបរិស្ថាន។

ព្រៃការពារនឹងធ្វើការពិនិត្យឡើងវិញដើម្បីធានាដល់ការអភិរក្សប្រភេទពូជមានតម្លៃខ្ពស់ប្រភេទរងការគំរាមកំហែង ប្រព័ន្ធអេកូឡូស៊ី ផុយស្រួយ និងតំបន់មរតកវប្បធម៌។

### ៥.២.៨ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី៨ គឺជម្រើសរបបគ្រប់គ្រងព្រៃឈើ

វិធីសាស្ត្រចម្រុះនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនឹងត្រូវរៀបចំដោយផ្អែកលើរបបគ្រប់គ្រងដែលមានស្រាប់នៅពេល បច្ចុប្បន្ន និងបញ្ចូលនូវគំរូគ្រប់គ្រងថ្មីៗផ្សេងៗទៀត។ របបគ្រប់គ្រងព្រៃឈើបច្ចុប្បន្ន រួមមាន៖

- *សហគមន៍ព្រៃឈើបានអភិវឌ្ឍបន្តិចម្តងៗតាំងពីពាក់កណ្តាលឆ្នាំ១៩៩០តាមរយៈគំរោងសាកល្បងតូចៗ* ដែលបានបង្ហាញឱ្យឃើញពីសក្តានុពលក្នុងការការពារព្រៃឈើ និងទ្រទ្រង់ដល់ជីវភាពប្រជាជនជនបទ។ ថ្មីៗនេះសហគមន៍ព្រៃឈើបានពង្រីកពីតំបន់ព្រៃរេចរឹលរហូតដល់ព្រៃឈើមានតម្លៃ។
- *ព្រៃគុបដេញថ្លៃប្រចាំឆ្នាំ* ត្រូវបានបង្កើតឡើងមុននេះក្នុងប្រវត្តិសាស្ត្រព្រៃឈើ ហើយត្រូវបានយកមកប្រើប្រាស់ឡើង វិញក្នុងឆ្នាំ ២០០៤ ដើម្បីឆ្លើយតបទៅនឹងការបញ្ឈប់អាជីវកម្មព្រៃសម្បទានសម្រាប់នាំចេញ ហើយថ្មីៗនេះ ក្រុមអនុវត្តបច្ចេកទេសព្រៃឈើក៏ត្រូវបានអភិវឌ្ឍ។
- *ការស្តារ ការដាំដុះដើមឈើនិងព្រៃឈើឡើងវិញ* ជាពិសេសផ្តោតទៅលើការស្តារៈការបង្កើនគុណភាព និងការបង្កើត ឡើងវិញឱ្យដូចព្រៃធម្មជាតិ។ យើងមានបទពិសោធន៍ខ្លះពីគំរោងដាំប្រភេទកំណើតនៅទីវាលចំហ និងក្នុងគម្របពុំ រេចរឹល គួបផ្សំនឹងការដាំសាកល្បងប្រភពកំណើត ឃើញថាអាចផ្តល់លទ្ធផលល្អសម្រាប់ការងារនាអនាគត។
- *ចម្ការព្រៃឈើដាំ* ជាការដាំដុះដោយរដ្ឋ ឯកជន ឬ សហគមន៍។ ការដាំប្រភេទឈើចម្រុះសម្រាប់គោលបំណងច្រើនយ៉ាង សម្រាប់កែលំអជីវភាពរស់នៅ និងសេវាកម្មបរិស្ថាន ដូចជា ការពារ

ដំណាំកសិកម្ម និងផលនេសាទជាដើម។ បច្ចុប្បន្នវដ្ត បានដើរតួជាអ្នកអភិវឌ្ឍចម្ការព្រៃឈើដាំ ប៉ុន្តែការដាំភាគច្រើនគឺជាប្រភេទឈើនាំចូល និងដាំតែមួយប្រភេទ។

*គំរូគ្រប់គ្រងព្រៃឈើថ្មី រួមមាន ៖*

- *ការធ្វើសម្បទានអភិរក្សព្រៃឈើ* ជាវិធីសាស្ត្រថ្មីមួយក្នុងការផ្តល់ហិរញ្ញប្បទានព្រៃឈើឱ្យមាននិរន្តរភាព ប្រើសម្រាប់ធ្វើ ការគ្រប់គ្រង និងការពារតំបន់ព្រៃ ដ៏ធំទាំងនេះ ពិសេសសក្តិសមនឹងសម្បទានព្រៃឈើបច្ចុប្បន្ន។ ការអភិរក្សនេះអាចធ្វើឱ្យ ប្រទេសសម្បូរព្រៃឈើទទួលនូវផលចំណេញបានច្រើនពីការថែរក្សាធនធានធម្មជាតិជាជាងការផ្លាស់ប្តូរការប្រើប្រាស់ដីតាមវិធី ផ្សេងៗ។ នេះជាដំណោះស្រាយថ្មីមួយចំពោះ ភាពមិនចុះសម្រុងគ្នារវាងគោលបំណងនៃតម្រូវការសេដ្ឋកិច្ច និងការអភិរក្ស។
- *ឯកជនភាវូបនីយកម្មព្រៃឈើទំហំតូចៗ* នឹងត្រូវយកមកពិចារណាផងដែរ។ បច្ចុប្បន្នរាជរដ្ឋាភិបាលជាអ្នកគ្រប់គ្រងព្រៃឈើ ទាំងអស់ ការគ្រប់គ្រងព្រៃឈើឯកជនពុំទាន់មាននៅឡើយទេ។ ប៉ុន្តែនៅតាមប្រទេសមួយចំនួនលើពិភពលោក - ព្រៃឈើ ឯកជនដើរតួនាទីសំខាន់ណាស់ក្នុងការផ្គត់ផ្គង់ឈើទាន់ពេលវេលា និងមានតម្លៃសមរម្យទៀតផង។ ការផ្ទេរអំណាចបន្តិច ម្តងៗទៅឱ្យវិស័យឯកជនចំពោះដីព្រៃដែលនៅសល់នឹងជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាព
  ហើយទន្ទឹមនេះ ស្ថាប័ន រាជ
  រដ្ឋាភិបាលនឹងមានពេលវេលាច្រើនផ្តោតទៅលើការងាររៀបចំគោលនយោបាយ បទប្បញ្ញត្តិ ច្បាប់ និងបច្ចេកទេស។ គឺគ្រប់គ្រងនេះអាចសមស្របសម្រាប់តំបន់ព្រៃឈើដែលមានទំហំតូចៗនៅដាច់ឆ្ងាយពីគ្នាដែលពិបាកក្នុងការគ្រប់គ្រង។ប៉ុន្តែយើងត្រូវការបង្កើតបទប្បញ្ញត្តិ
  សម្រាប់ការគ្រប់គ្រងគំរូនេះឱ្យបានសមស្របជាចាំបាច់។ ប្រាក់ចំណូលដែលបានមកពី ការធ្វើឯកជនភាវូបនីយកម្មនេះ នឹងត្រូវយកមកប្រើប្រាស់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍព្រៃឈើឱ្យមាននិរន្តរភាព។
- *ការប្រើប្រាស់ធនធានសម្រាប់ម៉ៅការ* ជាសកម្មភាពមួយអាចនឹងត្រូវសាកល្បងនៅតំបន់មួយចំនួន។ នេះជាមធ្យោបាយមួយដែលការចំណាយមានប្រសិទ្ធភាពចំពោះតំបន់ដែលសមត្ថភាពនៅមានកម្រិត។
- *ព្រៃឈើលំហែកំសាន្តក្នុងក្រុង* កំពុងត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំផែនការទីក្រុងរយៈពេលវែងកាន់តែច្រើនឡើង ដើម្បីធានាការលូតលាស់របស់ទីក្រុងឱ្យនៅតែរក្សាបានពណ៌បៃតង ទីធ្លាទូលាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព ទាំងកាយ និងចិត្ត ដោយផ្តល់នូវបរិស្ថានល្អប្រកបដោយផាសុកភាព សម្រាប់ការហាត់ប្រាណ និងការលំហែកាយ។ ជាធម្មតា

មនុស្សកាន់តែចាស់កាន់តែត្រូវការពេលវេលាលំហែកាយច្រើនឡើង ដូច្នេះតម្លៃនៃការលំហែកាយជាមួយព្រៃឈើក៏កាន់តែ កើនឡើងដែរ។ ក៏ប៉ុន្តែបទពិសោធន៍បង្ហាញថា ការយកចិត្តទុកដាក់ចំពោះការរៀបចំព្រៃឈើសម្រាប់លំហែកាយក្នុងទី ប្រជុំជននៅតាមទីក្រុងដែលរីកលូតលាស់លឿន ជារឿយៗ តែងតែមានភាពយឺតយ៉ាវ។ ការរៀបចំផែនការបង្កើតព្រៃឈើ ក្នុងក្រុងគឺជាភារកិច្ចរបស់សាលារាជធានី ខេត្ត ក្រុង ដែលត្រូវគិតពិចារណាដាក់ទៅក្នុងកម្មវិធីព្រៃឈើជាតិ ដើម្បីទទួល បានការគាំទ្រថវិកា និងបច្ចេកទេសពីរដ្ឋបាលព្រៃឈើ។

## ៥.២.៩ ទិសដៅជាយុទ្ធសាស្ត្រសម្រាប់គោលបំណងទី ៩ គឺការផ្តល់ហិរញ្ញប្បទានប្រកបដោយ និរន្តរភាពសម្រាប់ វិស័យព្រៃឈើ

កម្មវិធីព្រៃឈើជាតិ មានបំណងកំណត់វិធីសាស្ត្រធ្វើឱ្យសម្រេចបានស្វ័យហិរញ្ញប្បទានសម្រាប់វិស័យព្រៃឈើ ដោយមានការ គាំទ្រពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ជាមួយនឹងចំណូលថវិកាដែលអាចប្រមូលបានពីការធ្វើអាជីវកម្ម ពាណិជ្ជកម្មផល-អនុផលព្រៃឈើ ដោយចីរភាព ការធ្វើវិញ្ញាបនបត្រសេវាកម្មបរិស្ថានព្រៃឈើ និងការលក់ឥណទានកាបូនព្រៃឈើពីទីផ្សារកាបូនដែលមានលក្ខខណ្ឌ តម្រូវផ្លូវការ និងទីផ្សារកាបូនស្ម័គ្រចិត្ត។

ការកែលម្អប្រព័ន្ធសារពើពន្ធនឹងអាចធានាថា៖ ចំណូលពីវិស័យព្រៃឈើអាចប្រមូលបានទាំងអស់ អាចទទួលបានចំណូលពី ការបង់ថ្លៃសេវាកម្មបរិស្ថានព្រៃឈើតាមរយៈយន្តការកែច្នៃថ្មី និងទទួលបានការលើកទឹកចិត្ត សម្រាប់វិនិយោគទុន និងការផ្តល់ហិរញ្ញវត្ថុ សម្រាប់វិស័យព្រៃឈើ។

# មេរៀនទី៦ ក្របខណ្ឌនៃកម្មវិធីព្រៃឈើជាតិ

ក្របខណ្ឌនៃកម្មវិធីព្រៃឈើជាតិមាន ៣ ផ្នែក ដែលផ្នែកទី១ និយាយពីឯកសារកម្មវិធីព្រៃឈើជាតិ ផ្នែកទី២ និយាយ អំពីតួនាទីរបស់អ្នកពាក់ព័ន្ធសំខាន់ៗ និងផ្នែកទី៣ ការបង្ហាញអំពីកម្មវិធីអនុវត្ត។

## ៦.១ ទំរង់នៃឯកសារកម្មវិធីព្រៃឈើជាតិ

ឯកសារក្របខណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ ពិពណ៌នាសង្ខេបអំពីបរិបទនិងស្ថានភាពគ្រប់គ្រងព្រៃឈើឱ្យមាន និរន្តរភាពនៅកម្ពុជា។ ឯកសារនេះផ្តល់នូវទស្សនវិស័យ និងសេចក្តីថ្លែងការណ៍ស្តីពីកម្មវិធីព្រៃឈើជាតិ។ ការពិពណ៌នាអំពី អាទិភាពនយោបាយនិងទិសដៅជាយុទ្ធសាស្ត្រនិងជំហានឈានទៅរកការសម្រេចបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយ និរន្តរភាព ការគូសបញ្ជាក់អំពីជម្រើសគ្រប់គ្រងនាពេលអនាគត ការអនុវត្តកម្មវិធី ការប៉ាន់ស្មានអំពីហិរញ្ញប្បទាន។ ឯកសារ យុទ្ធសាស្ត្រនេះដាក់ចេញនូវគោលនយោបាយរួមសម្រាប់អនុវត្តកម្មវិធីព្រៃឈើជាតិ។

ឯកសារព័ត៌មានស្តីពីកម្មវិធីព្រៃឈើជាតិ ផ្តល់នូវព័ត៌មានពិត បង្ហាញអំពីការវិភាគ ជាពិសេសផ្តល់នូវយុត្តិកម្មលើគ្រោង ការណ៍យុទ្ធសាស្ត្រ និងកម្មវិធីអនុវត្ត។ ឯកសារផ្តល់នូវព័ត៌មានអំពីវិស័យព្រៃឈើកម្ពុជានៅក្នុងអភិបាលកិច្ចបច្ចុប្បន្ន និង ក្របខ័ណ្ឌច្បាប់សម្រាប់ព្រៃឈើ និងដីធ្លី ព្រមទាំងសង្ខេបអនុសាសន៍ពីការត្រួតពិនិត្យវិស័យព្រៃឈើមុនៗ និងការពិពណ៌នា អំពីដំណើរការនៃការរៀបចំកម្មវិធីព្រៃឈើជាតិ។ ឯកសារព័ត៌មានស្តីពីកម្មវិធីព្រៃឈើជាតិពិតជាបានបង្ហាញអំពីព័ត៌មាន សំខាន់ៗ និងគាំទ្រដល់ការវិភាគពីក្រោយគោលនយោបាយទាំងមូល។

ឯកសារគម្រោងប្រតិបត្តិការមាន ៦.កម្មវិធី។ កម្មវិធីនីមួយៗមានប្រធានបទធំមួយជាអាទិភាពសម្រាប់រយៈពេល ពីឆ្នាំ ២០១០-២០២៩។ កម្មវិធីនីមួយៗមានផ្នែកទូទៅដែលពណ៌នាគ្របដណ្តប់លើកម្មវិធីទាំងមូល និងមានផ្នែកជាក់លាក់ ដោយឡែកដែលមានពី២ ទៅ ៩. អនុកម្មវិធី។ គ្រោងការណ៍ប្រតិបត្តិត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលក្នុងការ រៀបចំកម្មវិធីការងារ។ រីឯកម្មវិធីការងារផ្សេងទៀត ដែលចាត់ទុកថាជាផ្នែកសំខាន់នៃកម្មវិធីព្រៃឈើជាតិដែរនោះ នឹង ត្រូវរៀបចំនៅក្នុងឆ្នាំ ២០១០ ដូចជា

១. ប្រព័ន្ធគ្រប់គ្រងទំនាស់ ដើម្បីឈានទៅរកការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើឱ្យមាននិរន្តរភាពតាមរយៈអភិបាលកិច្ច ព្រៃឈើ ការបង្ការ ទប់ស្កាត់ និងដោះស្រាយជម្លោះឱ្យបានទាន់ពេលវេលា និងលទ្ធផលល្អប្រសើរ។

២. ប្រព័ន្ធតាមដាន និងរាយការណ៍ ដើម្បីធានាឱ្យមានតម្លាភាព ការទទួលខុសត្រូវ រៀនសូត្រ និងកែលំអទាន់ ពេលវេលា តាមរយៈការអនុវត្តកម្មវិធីព្រៃឈើជាតិ និងការទទួលជោគជ័យនៃដំណើរការកម្មវិធីព្រៃឈើជាតិ ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ។

៣. ផែនការសកម្មភាពរយៈពេលខ្លី រួមមានផែនការរំកិល៥ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំ បាននឹងកំពុងតែរៀបចំសម្រាប់ អនុកម្មវិធីនីមួយៗ។ ផែនការទាំងនេះជាចំណុចចាប់ផ្តើម សម្រាប់ការកំណត់អំពីលទ្ធផលរំពឹងទុក និងមធ្យោបាយអនុវត្ត។ ផែនការទាំងនេះត្រូវបានរៀបចំជាតារាងម៉ាទ្រីក ដែលមានពិពណ៌នាអំពីគោលបំណង សកម្មភាព សូចនាករ លទ្ធផល ថវិកា និងពេលវេលាកំណត់ការចាប់ផ្តើមសកម្មភាព និងការសម្រេចលទ្ធផល។

## ៦.២ តួនាទីរបស់អ្នកពាក់ព័ន្ធ

អ្នកពាក់ព័ន្ធមកពីច្រើនផ្នែក មានការចាប់អារម្មណ៍ខុសៗគ្នាទៅលើព្រៃឈើ ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ ដូចនេះបណ្តាអ្នកពាក់ព័ន្ធសំខាន់ៗទាំងនេះ ត្រូវបានលើកទឹកចិត្ត និងអញ្ជើញឱ្យចូលរួមយ៉ាងសកម្មក្នុង ដំណើរការអនុវត្តកម្មវិធីព្រៃឈើជាតិ។

- *ស្ថាប័ននិងអង្គភាពរដ្ឋាភិបាល* ទទួលខុសត្រូវរៀបចំគោលនយោបាយ ច្បាប់ ផែនការសកម្មភាពដែលទាក់ទងនឹងការ បង្កើត និងរក្សាលក្ខខណ្ឌសមស្របសម្រាប់ការអនុវត្តកម្មវិធីព្រៃឈើជាតិ ដូចជាការពង្រឹងការអនុវត្តច្បាប់ការ ដោះស្រាយ ទំនាស់ ការផ្តល់សេវាកម្ម និងការធានាឱ្យមានមន្ត្រីធនធានមនុស្សប្រកបដោយសមត្ថភាព និងជំនួយបច្ចេកទេសចាំបាច់សម្រាប់ការអភិវឌ្ឍ។
- *សង្គមស៊ីវិល* ចូលរួមជួយបង្កើតជាវេទិកាសាធារណៈ សម្រាប់ការប្រមូលផ្តុំសកម្មភាពរួមគ្នាស្តីពីផលប្រយោជន៍គោលបំណង . និងតម្លៃ ដែលបានផ្លាស់ប្តូរព័ត៌មានគ្នា ហើយធានាថាមានការគាំទ្រជំនួយក្នុងការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ។ អង្គការមិនមែនរដ្ឋាភិបាល អាចជួយក្នុងការអនុវត្ត ការគាំទ្រ តាមដាន និង វាយតម្លៃ ផងដែរ។
- *វិស័យឯកជន* ចូលរួមចំណែកក្នុងការផ្តល់ហិរញ្ញប្បទាន និងការវិនិយោគ ការបង្កើតការងារ ការបង្កើតប្រាក់ចំណូល ការ គ្រប់គ្រង និងការរៀបចំផែនការសម្រាប់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍវិស័យព្រៃឈើប្រកបដោយនិរន្តរភាព។

- *គ្រឹះស្ថានអប់រំ / បណ្តុះបណ្តាល* ចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ការសម្របសម្រួល ការផ្តល់ ចំណេះដឹងវិទ្យាសាស្ត្របច្ចេកវិទ្យា បំពេញនូវការខ្វះខាតបច្ចេកទេស រួមទាំងការតាមដាន និងវាយតម្លៃ។
- *ដៃគូអភិវឌ្ឍន៍* ចូលរួមចំណែកក្នុងការពិភាក្សាកំណត់គោលនយោបាយ និងគាំទ្រហិរញ្ញវត្ថុ ព្រមទាំងជំនួយបច្ចេកទេស តាមតម្រូវការចាំបាច់។

## ៦.៣ ក្របខណ្ឌប្រតិបត្តិការ

ក្របខណ្ឌនេះបានឆ្លុះបញ្ចាំងអំពីការវិភាគ និងឯកសារព័ត៌មានស្តីពីកម្មវិធីព្រៃឈើជាតិ។ ក្រុមការងាររៀបចំកម្មវិធីព្រៃឈើជាតិ និងព័ត៌មានផ្សេងៗ ដែលបានមកពីការពិគ្រោះយោបល់ជាសាធារណៈ ហើយមានកម្មវិធីការងារ ធំៗចំនួន៦ ដែលបានកំណត់អំពី យុទ្ធសាស្ត្រ និងរបៀបអនុវត្តច្បាស់លាស់។ កម្មវិធីការងារនីមួយៗនឹងមានបន្ថែមដោយផែនការរយៈពេលខ្លី៥ឆ្នាំរំកិល រួមជាមួយ ផែនការសកម្មភាពប្រចាំឆ្នាំ ដែលផ្សារភ្ជាប់ជាមួយផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើ (ឆ្នាំ២០០៧-២០១០)។ កម្មវិធីការងារទាំង ៦ រួមមាន ៖

១. កម្មវិធីកំណត់ព្រំប្រទល់ព្រៃឈើ ការចាត់ថ្នាក់ និងចុះបញ្ជីកា

ដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់កម្មវិធីព្រៃឈើជាតិ កម្មវិធីនេះនឹងអនុវត្តការកំណត់ព្រំប្រទល់ព្រៃឈើ និងការធ្វើ ចំណាត់ថ្នាក់ព្រៃឈើជាប្រព័ន្ធស្របតាមមុខងារ និងសក្តានុពលជាក់ស្តែងរបស់ព្រៃឈើ និងប្រកបដោយតម្លាភាព មានសុខដុមនីយកម្ម ជាមួយក្របខណ្ឌច្បាប់ផ្សេងៗ ដើម្បីរួមចំណែកទប់ស្កាត់ទំនាស់ដីធ្លី ដែលពាក់ព័ន្ធជាមួយបញ្ហាកម្មសិទ្ធិ និងសិទ្ធិអ្នកប្រើប្រាស់តាមរយៈដំណើរការមួយដែលលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងអស់ឱ្យចូលរួមក្នុងការកំណត់ព្រំប្រទល់ព្រៃឈើ។ កម្មវិធីនេះមានអនុកម្មវិធីចំនួន២ ៖

- អនុកម្មវិធី ១.១ -ការកំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- អនុកម្មវិធី ១.២ -ការចាត់ថ្នាក់ព្រៃឈើជាតិ តាមមុខងារ។

## ៦.៤. កម្មវិធីអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ

ស្របជាមួយនឹងគោលបំណងរបស់កម្មវិធីព្រៃឈើជាតិ ការអភិរក្ស និងការអភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ ផ្តោតទៅលើការ អនុវត្តដែលមាននាពេលបច្ចុប្បន្ន និងបូកបញ្ចូលជាមួយគំរូនៃការគ្រប់គ្រងព្រៃឈើដែលកំពុងលេចធ្លោ និងការបន្ថែមតម្លៃទៅលើផលិត ផលព្រៃឈើ ដើម្បីបង្កើនការរួមវិភាគទានរបស់ព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ការបង្កើនជីវភាពរស់នៅ និងការអភិវឌ្ឍសេដ្ឋកិច្ចទន្ទឹមនឹងការការពារសេវាកម្មបរិស្ថានតាមរយៈការអនុវត្តអនុកម្មវិធីដូចខាងក្រោម ៖

- អនុកម្មវិធី ២, ១ - ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ
- អនុកម្មវិធី ២.២ - ការអភិវឌ្ឍ និងអនុវត្តបច្ចេកទេសគ្រប់គ្រងព្រៃផ្តល់ផល
- អនុកម្មវិធី ២.៣ - ពង្រឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- អនុកម្មវិធី ២.៤ - ការអភិរក្សធនធានជីវចម្រុះ និងសត្វព្រៃ
- អនុកម្មវិធី ២. ៥ - ការអភិរក្ស និងអភិវឌ្ឍន៍ធនធានសេនទិច និងប្រភពពូជ
- អនុកម្មវិធី ២, ៦ - ការដាំដុះដើមឈើ និងការអភិវឌ្ឍចម្ការព្រៃឈើដាំ
- អនុកម្មវិធី ២.៧ - ការអភិវឌ្ឍផលិតផលព្រៃឈើ និងពង្រីកទីផ្សារ
- អនុកម្មវិធី ២.៨ -ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងការកែច្នៃផល-អនុផលព្រៃឈើ
- អនុកម្មវិធី ២. ៩ - ការអភិវឌ្ឍប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើ។

## ៦.៥. កម្មវិធីពង្រឹងច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច

អភិបាលកិច្ចព្រៃឈើ និងការពង្រឹងការអនុវត្តច្បាប់ គឺមានសារៈសំខាន់ជាសារវន្តដល់និរន្តរភាពនៃកម្មវិធីព្រៃឈើជាតិ។ កម្មវិធី នេះជំរុញឱ្យមានការចូលរួមពីបណ្តាអ្នកពាក់ព័ន្ធទាំងអស់ក្នុងការជួយគ្រប់គ្រង និងការពារព្រៃឈើឱ្យមាននិរន្តរភាព និងការអនុវត្តច្បាប់ តាមរយៈអនុកម្មវិធីដូចខាងក្រោម ៖

- អនុកម្មវិធី ៣.១ - ការកែទម្រង់ច្បាប់ និង រដ្ឋបាល
- អនុកម្មវិធី ៣.២ - ការពង្រឹងការអនុវត្តច្បាប់ និង ការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ
- អនុកម្មវិធី ៣៣ - ការឆ្លើយតបរហ័សចំពោះព័ត៌មានឧក្រិដ្ឋកម្មព្រៃឈើ
- អនុកម្មវិធី ៣៤ - ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទំនាស់ (នឹងរៀបចំ និងអនុវត្តចាប់ពីឆ្នាំ២០១០)

អនុកម្មវិធីនេះ នឹងអភិវឌ្ឍសមត្ថភាពគ្រប់គ្រងទំនាស់របស់សមត្ថកិច្ចបំរើការក្នុងវិស័យព្រៃឈើ ដើម្បីទប់ស្កាត់ បង្ការ និងដោះស្រាយ បញ្ហាទំនាស់ដែលពាក់ព័ន្ធជាមួយវិស័យព្រៃឈើ ជាពិសេសទំនាស់ដែលកើតចេញពីការបំផ្លាញធនធានព្រៃឈើ។

- អនុកម្មវិធី ៣,៥ -ប្រព័ន្ធត្រួតពិនិត្យ តាមដាន និង វាយតម្លៃ (នឹងរៀបចំនៅឆ្នាំ២០១០)

ប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ នឹងផ្តល់នូវព័ត៌មានពិស្តារអំពីដំណើរការអនុវត្តកម្មវិធីដោយធ្វើការតាមដាន ត្រួតពិនិត្យទៅលើការអនុវត្ត លទ្ធផល នឹងផ្តល់អនុសាសន៍កែលម្អ ដើម្បីឱ្យដំណើរការនៃការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព និងមានចីរភាព។

## ៦.៦ កម្មវិធីសហគមន៍ព្រៃឈើ

កម្មវិធីសហគមន៍ព្រៃឈើនឹងចូលរួមវិភាគទានដោយផ្ទាល់ទៅនឹងគោលបំណងកម្មវិធីព្រៃឈើជាតិ។ កម្មវិធីនេះលើកទឹកចិត្ត ឱ្យសហគមន៍មូលដ្ឋានចូលរួមគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ព្រៃឈើឱ្យមាននិរន្តរភាព តាមរយៈការទទួលផលប្រយោជន៍ប្រកបដោយ សមធម៌ និងធ្វើឱ្យជីវភាពរស់នៅប្រសើរឡើង ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតាមតំបន់ជនបទនៃព្រះរាជាណាចក្រ កម្ពុជា។ កម្មវិធីនេះមាន ៣ អនុកម្មវិធីដូចខាងក្រោម ៖

- អនុកម្មវិធី ៤.១ ការកំណត់តំបន់សក្តានុពល និង ការបង្កើតសហគមន៍ព្រៃឈើ
- អនុកម្មវិធី ៤.២ ការអភិវឌ្ឍសហគមន៍ និង ការបង្កើនជីវភាព
- អនុកម្មវិធី ៤៣ ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ។

## ៦.៧.កម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ

កម្មវិធីនេះនឹងអភិវឌ្ឍន៍នូវសមត្ថភាពចាំបាច់សម្រាប់ការអនុវត្ត និងសម្រេចឱ្យបានគោលបំណងរួមរបស់កម្មវិធីព្រៃឈើជាតិ។កម្មវិធីនេះរួមមាន ៣ អនុកម្មវិធីដូចខាងក្រោម ៖

- អនុកម្មវិធី ៥.១ ការអភិវឌ្ឍស្ថាប័ន និង ធនធានមនុស្ស
- អនុកម្មវិធី ៥.២ ការអប់រំ និង ផ្សព្វផ្សាយសាធារណៈ
- អនុកម្មវិធី ៥.៣ ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ។

## ៦.៨.កម្មវិធីហិរញ្ញប្បទានដោយចីរភាពសម្រាប់វិស័យព្រៃឈើ

ការផ្តល់ហិរញ្ញប្បទានដោយចីរភាពសម្រាប់វិស័យព្រៃឈើ នឹងផ្តល់នូវក្របខណ្ឌសេដ្ឋកិច្ចស្ថេរភាព និងតម្លាភាព ដើម្បីសម្រេច បាននូវគោលបំណងរួមរបស់កម្មវិធីព្រៃឈើជាតិ។ បញ្ហានេះសម្រេចទៅបានតាមអនុកម្មវិធីទាំង ៥ ដូចខាងក្រោម៖

- អនុកម្មវិធី ៦.១ - ហិរញ្ញប្បទានផ្តល់ដោយរដ្ឋ
- អនុកម្មវិធី ៦.២-ចំណូលពីវិស័យព្រៃឈើ
- អនុកម្មវិធី ៦.៣ - ចំណូលពីវិស័យឯកជន និង សហគមន៍ព្រៃឈើ
- អនុកម្មវិធី ៦.៤ - ការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- អនុកម្មវិធី ៦.៥ - ប្រភពហិរញ្ញប្បទានថ្មីៗនៃសេវាកម្មបរិស្ថានព្រៃឈើ និងឥណទានកាបូន។

# មេរៀនទី៧ ការអនុវត្ត ការតាមដាននិងរាយការណ៍

ការអភិវឌ្ឍវិស័យព្រៃឈើ និង តួនាទីព្រៃឈើតម្រូវឱ្យមានកិច្ចប្រឹងប្រែងសហការល្អនៅក្នុងចំណោមបណ្តាភាគីអ្នកពាក់ព័ន្ធ ទាំងអស់។ រដ្ឋបាលព្រៃឈើ និងស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗទៀត ត្រូវធ្វើការប្រតិបត្តិអភិបាលកិច្ចព្រៃឈើឱ្យបានល្អ ហើយធានារក្សាបរិស្ថានល្អក្នុងការអភិវឌ្ឍ ដោយសហការជាមួយបណ្តាអ្នកពាក់ព័ន្ធ។ នៅពេលណាដែលមានតម្រូវការអំពី ធនធានសមត្ថភាព តែមិនអាចរកបាននៅក្នុងស្ថាប័នមូលដ្ឋាននោះ ភាគីពាក់ព័ន្ធត្រូវសកម្មផ្តល់ជំនួយប្រឹក្សាជាចាំបាច់ ។

## ៧.១ ការផ្តល់ហិរញ្ញប្បទាន និងចំណាយ

ការវិភាគអំពីហិរញ្ញប្បទានបង្ហាញថា វិស័យព្រៃឈើមានសក្តានុពលខ្ពស់ក្នុងការធ្វើស្វ័យហិរញ្ញប្បទាន ហើយអាច កែលម្អជីវភាពរស់នៅឱ្យប្រសើរឡើង ផ្តល់នូវការងារដោយផ្ទាល់និងដោយប្រយោល ព្រមទាំងបង្កើតប្រាក់ចំណូល។ ការ បង្កើនបរិមាណឈើអាជីវកម្មស្របច្បាប់ អាចធ្វើឱ្យទីផ្សារឈើក្នុងស្រុកមានស្ថេរភាព។ ការគ្រប់គ្រងព្រៃឈើប្រកបដោយ សមធម៌នឹងធានាឱ្យមានលំហូរប្រាក់ចំណូលពីសកម្មភាពព្រៃឈើសម្រាប់បង់ជូនរដ្ឋ និងសង្គម តាមរយៈថ្លៃសួយសារ និងពន្ធដារ ផ្សេងៗទៀត។

ប៉ុន្តែដើម្បីសម្រេចលទ្ធផលខាងលើ លុះត្រាតែមានការវិនិយោគជាមុនសិន គួបផ្សំនឹងការអភិវឌ្ឍសមត្ថភាពឱ្យមាន គ្រប់គ្រាន់ក្នុងរយៈពេលដំបូងពី ៥ ទៅ ១០ឆ្នាំ។ ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុនឹងត្រូវការជាចាំបាច់ក្នុងដំណាក់កាលនេះ ដើម្បីបញ្ចៀសបាននូវការរាំងស្ទះដោយថាហេតុ។

បើយោងតាមការសិក្សាវិភាគ បានប៉ាន់ស្មានការចំណាយសម្រាប់រយៈពេល៥ឆ្នាំដំបូង រួមមានចំណាយលើការ ប្រតិបត្តិការចំណាយមូលធន និងជំនួយបច្ចេកទេស គឺត្រូវការថវិកាប្រមាណ ៤៥១ លានដុល្លាអាមេរិក។ ភាគច្រើនន ថវិកានេះនឹងត្រូវវិនិយោគទៅលើកម្មវិធីអភិវឌ្ឍន៍សមត្ថភាព កម្មវិធីកំណត់ព្រំប្រទល់ព្រៃឈើ និងសហគមន៍ព្រៃឈើ។

## ៧.២ ប្រព័ន្ធតាមដាន និងរាយការណ៍នៃកម្មវិធីព្រៃឈើជាតិ

កម្មវិធីព្រៃឈើជាតិអាចអនុវត្តដោយរលូនទៅបាន លុះត្រាតែមានប្រព័ន្ធតាមដាន និងរាយការណ៍ប្រកបដោយ ប្រសិទ្ធភាព និងជឿទុកចិត្តបាន។ យើងដឹងច្បាស់ណាស់ថា ដើម្បីធ្វើឱ្យសហគមន៍អន្តរជាតិមានទំនុកចិត្ត និងបណ្តាអ្នក វិនិយោគទុនកើនឡើង គឺទាមទារឱ្យមានតម្លាភាព ការផ្តល់ព័ត៌មានបានត្រឹមត្រូវ និងទាន់ពេលវេលា។ មានន័យថា ទីផ្សារ អន្តរជាតិត្រូវការឱ្យមានវិញ្ញាបនបត្រ

ផលនិងអនុផលព្រៃឈើផ្សេងៗ បន្ថែមទៅលើវិញ្ញាបនបត្រប្រភពផលិតផល។ គោលបំណង នៃការតាមដានគឺដើម្បីកំណត់សូចនាករវាស់វែងពីវឌ្ឍនភាព និងស្ថានភាពនៃផលិតកម្មព្រៃឈើ ជីវចម្រុះ ការស្តុកឥណទានកាបូន ការប្រើប្រាស់ដីធ្លី ការធ្វើអាជីវកម្មឈើ និងអនុផលព្រៃឈើ ការធ្វើសម្បទាន ការធ្វើពាណិជ្ជកម្ម ការអនុវត្តច្បាប់ ការដោះស្រាយទំនាស់ ផលប៉ះពាល់សង្គមនិងបរិស្ថាន និងការបែងចែកផលប្រយោជន៍។

គោលបំណង ចំនៃប្រព័ន្ធតាមដាន និងរាយការណ៍នៃកម្មវិធីព្រៃឈើជាតិ គឺដើម្បីស្វែងយល់ពីស្ថានភាព និងមានព័ត៌មាន ជាមូលដ្ឋានមួយសម្រាប់ការអនុវត្ត និងការត្រួតពិនិត្យកែលំអកម្មវិធី។ យើងត្រូវការប្រព័ន្ធមួយដែលមានលក្ខណៈជឿនលឿន និងមាន | តម្លាភាព ដើម្បីធានាដល់សមភាពនៃការបញ្ចេញព័ត៌មាន និងរបាយការណ៍ឱ្យមានតម្លាភាព ដំណាលគ្នាទៅឱ្យបណ្តាអ្នកពាក់ព័ន្ធ។ ព័ត៌មានទទួលបាននឹងបទពិសោធន៍ទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងការងារគ្រប់គ្រងប្រចាំថ្ងៃនាពេលអនាគត។ ប្រព័ន្ធនេះត្រូវមាន រយៈពេលវែង និងជាលក្ខណៈអន្តរវិស័យ។

ហានិភ័យរួមនៃការអនុវត្តកម្មវិធីព្រៃឈើជាតិ គឺទាក់ទងសំខាន់បំផុតទៅលើការប្រើប្រាស់ចំណេះដឹងដែលទទួលបាន នឹងកង្វះ ខាតនៃការយកចិត្តទុកដាក់ដល់ទំហំ និងចំនួននៃទំនាស់។ ចំណូលពីវិស័យព្រៃឈើត្រូវយកមកវិនិយោគក្នុងការបង្កើនប្រសិទ្ធភាពការ អភិវឌ្ឍវិស័យព្រៃឈើឈានទៅរកនិរន្តភាព។ ហានិភ័យ និងផលវិបាកផ្សេងៗទៀត គឺមានបញ្ជាក់នៅក្នុងកម្មវិធីអនុវត្តន៍នីមួយៗ។

## ៧.៣ សូចនាករសម្រាប់តាមដានរយៈពេលវែងលើការអនុវត្តកម្មវិធីព្រៃឈើជាតិ (ត្រឹមឆ្នាំ ២០២៩)

- គម្របព្រៃឈើនឹងត្រូវបង្កើនឱ្យបាន ៦០% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា។
- ការគ្រប់គ្រងព្រៃឈើដែលមានលក្ខណៈរុក្ខវប្បកម្មនឹងត្រូវបានអនុវត្តលើផ្ទៃដីចំនួន ២.៤ លានហិកតានៃព្រៃឈើផ្តល់ផល។
- នៅតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនីមួយៗ សហគ្រាស ឬសិប្បកម្មធុនតូច និងមធ្យមប្រើប្រាស់ផលិតផលព្រៃឈើដោយ ផ្ទាល់ ឬដោយប្រយោលយ៉ាងតិច ២០ ត្រូវបានចុះបញ្ជី។ យ៉ាងតិច ៥០% នៃបរិមាណឈើកែច្នៃ នឹងត្រូវបានផ្តល់វិញ្ញាបនបត្រសម្រាប់នាំចេញក្នុង ១ ឆ្នាំៗ។
- ប្រាក់ចំណូលសរុបប្រចាំឆ្នាំ គឺ ១២៥ លានដុល្លាអាមេរិក នឹងត្រូវប្រមូលបានពីវិស័យព្រៃឈើ។
- ចំណូលជាមធ្យមប្រចាំឆ្នាំ គឺ ២៥ លានដុល្លាអាមេរិក នឹងបានមកពីការលក់ឥណទានកាបូន (មិនគិតបញ្ចូលការចំណាយ លើការបង្កើតគំរោង និងថែទាំ )។
- ការកំណត់ព្រំប្រទល់ព្រៃឈើសរុបឱ្យបាន ១២០.០០០ គម (ដោយការភាគច្រើននឹងត្រូវបញ្ចប់នៅក្នុងអំឡុង ១០ ឆ្នាំ ចុងក្រោយ)។

- ការសម្រេចចិត្តជាយុទ្ធសាស្ត្រនៃវិស័យព្រៃឈើត្រូវមានការចូលរួមពីក្រសួង ស្ថាប័ន និងសង្គមស៊ីវិលពាក់ព័ន្ធតាមរយៈកិច្ចប្រជុំពិភាក្សាជាសាធារណៈយ៉ាងតិចពីរដងក្នុងមួយឆ្នាំ។
- ប្រព័ន្ធតាមដាន និងរាយការណ៍អំពីព្រៃឈើត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំខែ ហើយត្រូវមានព័ត៌មាន សម្រាប់សាធារណជន គ្រប់ពេលវេលាតាមការចាំបាច់។
- ទំនាស់ដីព្រៃឈើជាទ្រង់ទ្រាយធំៗដែលអាចមានមហន្តរាយដល់ធនធានព្រៃឈើ ត្រូវបានយកចិត្តទុកដាក់ដោះស្រាយពីថ្នាក់ជាតិ យ៉ាងតិចបានចំនួនពីរករណីក្នុងមួយឆ្នាំតាមរយៈយន្តការដោះស្រាយទំនាស់ដីធ្លី។
- មន្ត្រីរាជការបម្រើការក្នុងវិស័យព្រៃឈើមានសមត្ថភាពអាចផ្តួចផ្តើមគំនិតនិងអនុវត្តសកម្មភាពជាមួយដៃគូជិតខាងក៏ដូចជាការបំពេញភារកិច្ចការងារប្រចាំថ្ងៃរបស់ពួកគេដែរ។
- តំបន់ព្រៃត្រូវការពារ នឹងគ្របដណ្តប់លើផ្ទៃក្រឡាចំនួន ៣ លានហិកតា។
- ចម្ការព្រៃឈើដាំដែលដាំដុះដោយប្រភេទឈើមានតម្លៃមានទំហំ ៥០០.០០០ ហិកតា នឹងត្រូវបានបង្កើតឡើង កូនឈើចំនួន ១០ លានដើមក្នុងមួយឆ្នាំ ត្រូវបានបណ្តុះចែកជូនប្រជាពលរដ្ឋដាំដុះនៅទូទាំងប្រទេស។
- ព្រៃឈើ២លានហិកតា ត្រូវបានកំណត់ជាសហគមន៍ព្រៃឈើ (ប្រហែល ១.០០០ កន្លែង)និងបានអនុម័ត និងចុះកិច្ចព្រមព្រៀងជាផ្លូវការ។
- វិស័យព្រៃឈើអាចធ្វើស្វ័យហិរញ្ញប្បទានទាំងស្រុង។

# មេរៀនទី៨ ការធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ

កម្មវិធីព្រៃឈើជាតិសំដែងឱ្យឃើញនូវការប្តេជ្ញាចិត្តខ្ពស់ និងទស្សនវិស័យវែងឆ្ងាយក្នុងរយៈពេល២០ឆ្នាំ ហើយ កម្មវិធីនេះគឺជាដំណើរការកំពុងប្រព្រឹត្តទៅមួយដែលបន្សាំទៅនឹងលក្ខខណ្ឌប្រែប្រួលដែលតម្រូវលើកទឹកចិត្តឱ្យមានការធ្វើ សមាហរណកម្មផ្នែកថ្មីៗ និង មុខងារភារកិច្ចបន្ថែម។ មធ្យោបាយនេះសមស្របសម្រាប់ ការកែតម្រូវទាំងយុទ្ធសាស្ត្រ និង ការប្រតិបត្តិ និងការអភិវឌ្ឍកម្មវិធីបន្ថែមផ្សេងៗទៀត។

នៅពេលដែលប្រព័ន្ធតាមដាន និងរាយការណ៍ គំរោងយន្តការគ្រប់គ្រងទំនាស់បានរៀបចំរួចរាល់ នឹងមានការផ្តល់ ហិរញ្ញប្បទាននៅឆ្នាំ ២០១០ ពេលនោះនឹងមានការធ្វើបច្ចុប្បន្នភាពមួយចំនួនតាមការចាំបាច់ដូចជាៈ

១.ចម្រុះស្តីពីកំណែទម្រង់ព្រៃឈើនឹងបង្កើតក្រុមការងារមួយ ដោយមានការគាំទ្រជំនួយបច្ចេកទេស ពីខាងក្រៅ១.ការចាប់ផ្តើមពិនិត្យឡើងវិញនៃការអនុវត្តដំណាក់កាលដំបូងនឹងត្រូវធ្វើនៅដើមឆ្នាំ ២០១១។

២.ឯកសារក្របខណ្ឌយុទ្ធសាស្ត្រ និងឯកសារព័ត៌មានស្តីពីកម្មវិធីព្រៃឈើជាតិ ដែលបានបង្ហាញជូននូវយុទ្ធសាស្ត និងព័ត៌មានដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ ឆ្នាំម្តងប៉ុណ្ណោះ (ចាប់ផ្តើមលើកទី១ នាឆ្នាំ ២០១៤)។

៣.ក្របខណ្ឌប្រតិបត្តិ

- កម្មវិធីការងារសម្រាប់អនុវត្ត រួមមានការអាទិភាព មានហេតុផល និងការងារសម្រាប់អនុវត្តរយៈពេល ៥ឆ្នាំ។
- អនុកម្មវិធីការងារសម្រាប់អនុវត្ត នឹងត្រូវធ្វើបច្ចុប្បន្នភាពក្នុងរយៈពេល៥ឆ្នាំម្តង គឺចាប់ផ្តើមដំបូងនាឆ្នាំ២០១៤។ ការធ្វើបច្ចុប្បន្នភាពមុនការកំណត់អាចធ្វើទៅបានតាមការចាំបាច់។
- ការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព ៥ ឆ្នាំ នឹងចាប់ផ្តើមក្នុងឆ្នាំ ២០១៤។ ការធ្វើបច្ចុប្បន្នភាពមុនការកំណត់អាចធ្វើទៅបានតាមការចាំបាច់ ។
- ផែនការសកម្មភាពប្រចាំឆ្នាំ គឺ ជាផែនការមានរៀបរាប់ពិស្តារលម្អិតអំពីការងារប្រចាំឆ្នាំ។

ក្រុមការងារបច្ចេកទេសសម្រាប់ការធ្វើបច្ចុប្បន្នភាពទាំងនេះ។ រាល់ការធ្វើបច្ចុប្បន្នភាព នៅក្នុងរយៈពេលសុពលភាពនៃកម្មវិធីព្រៃឈើជាតិ ត្រូវកំណត់ដោយក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើ និងត្រូវសុំការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

កម្មវិធីការងារនៃកម្មវិធីព្រៃឈើជាតិ ចែកចេញជា៦កម្មវិធីដូចខាងក្រោម៖

កម្មវិធីទី១ ការកំណត់ព្រំប្រទល់ ព្រៃឈើ ការចាត់ថ្នាក់ និងចុះបញ្ជីកា(៣៤)

កម្មវិធីទី២ ការអភិរក្ស និងការ អភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ(៤៩)

កម្មវិធីទី៣ ពង្រឹងការអនុវត្តច្បាប់ ស្តីពីព្រៃឈើ និងអភិបាលកិច្ច(៧៧)

កម្មវិធីទី៤ សហគមន៍ព្រៃឈើ(900)

កម្មវិធីទី៥ ការអភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវ(១២២)

កម្មវិធីទី៦ ហិរញ្ញប្បទានដោយនិរន្តរភាព សម្រាប់វិស័យព្រៃឈើ(១៤៣)

## ៨.១ កម្មវិធីទី ១ ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជីកា

### ៨.១.១ ចំណុចអាទិភាពសំខាន់ៗ

- ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- ការរៀបចំផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង ការចុះបញ្ជីកា
- ការធ្វើចំណាត់ថ្នាក់ព្រៃឈើ ដោយផ្អែកទៅលើមុខងារ
- ការដោះស្រាយទំនាស់
- ការធ្វើបច្ចុប្បន្នភាពផែនទីគម្របព្រៃឈើ

### ៨.១.២ រយៈពេលកម្មវិធី

- មានរយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២៩

### ៨.១.៣ ការឆ្លើយតបទៅនឹងទស្សនវិស័យនៃកម្មវិធីព្រៃឈើជាតិ

កម្មវិធីកំណត់ព្រំប្រទល់ ចាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ នឹងឆ្លើយតបចំពោះចក្ខុវិស័យនៃកម្មវិធី ព្រៃឈើជាតិ ដោយផ្តល់នូវទិន្នន័យជាគន្លឹះ និងជាមូលដ្ឋានច្បាប់ចាំបាច់សម្រាប់ការគ្រប់គ្រងអភិវឌ្ឍ និងអភិរក្សសម្បត្តិ ព្រៃឈើអចិន្ត្រៃយ៍ដើម្បីបម្រើផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថាន។

ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ច្បាស់លាស់នឹងកំណត់បាននូវភាពជាម្ចាស់ និងសិទ្ធិប្រើប្រាស់ ស្រប ច្បាប់លើធនធានព្រៃឈើរបស់គ្រប់ភាគីពាក់ព័ន្ធ ហើយក៏ត្រូវបានទទួលស្គាល់ថាជាការចាំបាច់សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួម ទាំងការអភិរក្សជីវចម្រុះ និងមរតកវប្បធម៌ផងដែរ។

ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍នឹងជួយសម្រួលដល់សិទ្ធិប្រើប្រាស់ធនធាន ព្រៃឈើរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ដំណើរការនេះនឹងត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ ជាមួយគ្រប់ភាគីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ក្រុមជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ការទទួលស្គាល់ សិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើផល-អនុផលព្រៃឈើ គឺជាគោលការណ៍គ្រឹះនៃ ចក្ខុវិស័យរបស់កម្មវិធីព្រៃឈើជាតិ ដើម្បីជំរុញឱ្យការប្រើប្រាស់ព្រៃឈើប្រកបដោយសមធម៌ និងមានចីរភាព។

## ៨.១.៤ ការឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ រាជរដ្ឋាភិបាលបានកំណត់នូវនិយមន័យព្រៃឈើដូចតទៅ: ព្រៃឈើ គឺជាឯកត្តានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសិប្បនិម្មិត ក្រោមទម្រង់ជាដីសើមដីលិចទឹក ឬ ដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិដុះ ដោយធម្មជាតិ ឬ ដាំ មានកម្ពស់ចាប់ពី ៥ ម៉ែត្រឡើងលើ ផ្ទៃដីលើសពី ០៥ ហិកតា និង មានកម្រិតគ្របដណ្តប់របស់កន្សោមស្លឹកលើស ពី ១០ ភាគរយ។ ចម្ការឈើដាំ ដូចជាកៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើដទៃទៀត ដែលមាន លក្ខណៈដូចរៀបរាប់ខាងលើក៏ត្រូវបានចាត់ចូលជាព្រៃដែរ។

កម្មវិធីកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ អាចនឹងឱ្យស្ថាប័នអាជ្ញាធរព្រៃឈើដោះស្រាយនូវ ទំនាស់លើការប្រើប្រាស់ដីព្រៃឈើ និងធ្វើការតំណែតំតំបន់ព្រៃឈើដោយផ្អែកលើសក្តានុពលដោយឡែកៗនៃដី និងមុខងារព្រៃឈើ។ កម្មវិធីនេះនឹងរួមវិភាគទានយ៉ាងសំខាន់ក្នុងការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ ដើម្បីបង្កើននូវប្រសិទ្ធភាពនៃការអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

ដំណើរការកំណត់ព្រំប្រទល់ ចាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ គឺជាដំណើរការដែលលើកទឹកចិត្តឱ្យអ្នកពាក់ព័ន្ធ ទាំងអស់ចូលរួម ដើម្បីធានានូវកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន ក៏ដូចជារួមចំណែកក្នុងការរៀបចំធ្វើផែនការគ្រប់គ្រង ធនធានព្រៃឈើ។ ការងារនេះនឹង

ជួយដល់ការវាយតម្លៃកម្មវិធី និងធានាថាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានគ្រប់គ្រងប្រកបដោយលក្ខណៈតម្លាភាព។

## ៨.១.៥ . សារចរិតកម្មវិធី

គម្របព្រៃឈើកម្ពុជាបានថយចុះមកនៅប្រមាណជា ៥៩% នៃផ្ទៃក្រឡាប្រទេស( ១០,៧ លានហិកតា ) ក្នុងឆ្នាំ ២០០៦។ ការថយចុះនេះ បណ្ដាលមកពីការរុករានទន្ទ្រានកាន់កាប់ដីព្រៃឈើ ការបំលែងដីព្រៃឈើទៅជាដីកសិកម្ម និងការប្រើប្រាស់ផ្សេងៗទៀត ក្រៅពីវិស័យព្រៃឈើ។

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវពិចារណាលើការប្រើប្រាស់ធនធានព្រៃឈើនិងដីព្រៃឈើ ដើម្បីផលប្រយោជន៍ • សង្គម សេដ្ឋកិច្ច បរិស្ថាន និងលទ្ធភាពចូលរួមនៃអ្នកពាក់ព័ន្ធ។ ការកើនឡើងនូវតម្រូវការប្រើប្រាស់ផលិតផលព្រៃឈើនឹងដីព្រៃឈើ រួមផ្សំនឹងភាពក្រីក្ររបស់ប្រជាជនផងនោះ បានជំរុញឱ្យប្រជាជនការរុករាន ជាបន្តបន្ទាប់ទៅលើធនធាននិងដីព្រៃឈើ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការបំលែងដីព្រៃឈើជាដីកសិកម្ម ដីលំនៅឋានសម្រាប់រស់នៅ ឬលក់បន្តការប្រមូល និង ការលក់ផល-អនុផលព្រៃឈើផ្សេងៗទៀត ដែលជាហេតុបណ្ដាលឱ្យធនធានព្រៃឈើថយចុះផងដែរ។

ការថយចុះធនធាន និងដីព្រៃឈើ និងការខូចខាតប្រព័ន្ធអេកូឡូស៊ីព្រៃឈើ បានជះឥទ្ធិពលជាច្រើនទៅលើ សង្គម និងសេដ្ឋកិច្ច របស់សហគមន៍មូលដ្ឋានដូចជា ការធ្វើកសិកម្ម ការនេសាទ ការចិញ្ចឹមសត្វ។ល។ ប្រជាជនដែលបានចូលទៅតំបន់ព្រៃឈើនៅឆ្ងាយពី មូលដ្ឋានរបស់ខ្លួនដើម្បីរុករកផល-អនុផលព្រៃឈើ ជារឿយៗតែងតែបង្កឱ្យមានជម្លោះជាមួយសហគមន៍ផ្សេងទៀត ឬ. មន្ត្រីពង្រឹង ការអនុវត្តច្បាប់។ នៅក្នុងស្ថានភាពបែបនេះ ប្រជាជនមូលដ្ឋានជាច្រើនក៏បានងាកមកស្តារ និងការពារព្រៃចរឹលដែលនៅជិតលំនៅ ឋានខ្លួន ដើម្បីបំពេញនូវតម្រូវការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ពុំទាន់បានកំណត់ព្រំប្រទល់ ចាត់ថ្នាក់ និងចុះបញ្ជីកាឱ្យបានច្បាស់លាស់នៅឡើយ ជាមូលហេតុចម្បងមួយអាចធ្វើឱ្យរំខានដល់ការបកស្រាយនូវកម្មសិទ្ធិ និងសិទ្ធិអ្នកប្រើប្រាស់ ដីធ្លីដែលជាធាតុមួយសំខាន់ក្នុងការធ្វើផែនការគ្រប់គ្រង និងទប់ស្កាត់ជម្លោះ។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅសំខាន់៤នៅក្នុងយុទ្ធសាស្ត្រចតុកោណដំហានទី២ដែលនៅក្នុងនោះ គោលដៅ ទី៤-គឺធានានូវចីរភាពបរិស្ថានតាមរយៈការគ្រប់គ្រងធនធានធម្មជាតិព្រៃឈើប្រកបដោយនិរន្តរភាព។ កិច្ចខិតខំប្រឹងប្រែង ដើម្បី កំណត់ព្រំប្រទល់ដែនព្រៃឈើនេះ ត្រូវបានចាត់ទុកជាផ្នែកដ៏សំខាន់មួយនៃវិធានការជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីការពារ កាត់បន្ថយ និងលុបបំបាត់ការកាប់រានទន្ទ្រានដីព្រៃឈើដោយខុសច្បាប់។ ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអ

ចិន្ត្រៃយ៍ស្របទៅនឹង សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយវិស័យព្រៃឈើជាតិ។ គោលបំណងសំខាន់នៃសេចក្តីថ្លែងការណ៍នេះ រួម បញ្ចូលការអនុវត្តការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ការអភិរក្សព្រៃឈើសំខាន់ៗទៅតាមមុខងារ និងសក្តានុពល ហើយ នឹងការដាំដើមឈើ និងព្រៃឈើឡើងវិញដោយមានការចូលរួមពីប្រជាជនមូលដ្ឋានដែលសកម្មភាពទាំងនេះសំដៅជួយបង្កើនសន្តិសុខ ស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ច្បាស់លាស់ ក៏ជាជំហានដំបូងសំខាន់មួយនៃកិច្ច ខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចគោលដៅទី៧ នៃគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាដែលចែងថា ត្រូវ រក្សាគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃក្រឡាប្រទេសរហូតដល់ឆ្នាំ ២០១៥។ ទិន្នន័យនេះ នឹងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រង ធនធាន និងដីព្រៃឈើប្រកបដោយចីរភាព និងកិច្ចការពារបរិស្ថាន។

ការកំណត់ព្រំប្រទល់ និងការធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវផ្អែកទៅលើក្របខណ្ឌគតិយុត្ត ជាពិសេសច្បាប់សំខាន់ ពីរគឺ ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ និងច្បាប់ភូមិបាលឆ្នាំ ២០០១ ព្រមទាំងលិខិតបទដ្ឋានដែលពាក់ព័ន្ធ។ល។ ច្បាប់ស្តីពីព្រៃឈើ បានចែងថា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគ្រប់គ្រងប្រកបដោយនិរន្តរភាព ដើម្បីបង្កើនជាអតិបរមានូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និងតម្លៃមរតកវប្បធម៌ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់ថ្នាក់ ចុះបញ្ជីកា និងកំណត់ព្រំប្រទល់ព្រៃឈើទាំងអស់នៅក្នុងដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍។ ក្នុងការអនុវត្តសកម្មភាពនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរពាក់ព័ន្ធ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីសម្របសម្រួលដល់ដំណើរការចុះបញ្ជីកាកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច រៀបចំផែនទីប្រើប្រាស់ដីថ្នាក់ជាតិ និងធានាថា ការចុះបញ្ជីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍បានចូលទៅក្នុងបញ្ជីដីរដ្ឋ។

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានចាត់ថ្នាក់ជាប្រភេទនៃ ព្រៃផ្តល់ផល"" ព្រៃការពារ" ឬ "ព្រៃសម្រាប់ផ្ទេរ" និងត្រូវបានចុះ បញ្ជីជា សម្បត្តិព្រៃឈើជាតិ"។ អនុក្រឹត្យលេខ ៥៣ អនក្រ.បកចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ បានប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាកំណត់ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅទូទាំងប្រទេស ដោយកំណត់យកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាផែនទីគោល ហើយត្រូវមានការ ចូលរួមពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។ អនុក្រឹត្យនេះក៏បានបញ្ជាក់ផងដែរថា ក្នុងករណីមានបាតុភាព ឬមានពាក្យតវ៉ាដែលមិនអាច ដោះស្រាយបាន គណៈកម្មាធិការថ្នាក់ជាតិដើម្បី

ដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍នឹងត្រូវបង្កើតឡើងដោយ រាជរដ្ឋាភិបាលកម្ពុជា។

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍មួយចំនួនត្រូវបានកំណត់ព្រំប្រទល់រួច ដូចជាតំបន់ព្រៃសម្បទាន តំបន់ការពារព្រៃការពារតំបន់ អភិរក្ស តំបន់ព្រៃសហគមន៍ និងតំបន់ផ្សេងៗមួយចំនួនទៀត ប៉ុន្តែព្រំប្រទល់នៃតំបន់ទាំងនេះក៏មានការប្រែប្រួលដែលចាំបាច់ត្រូវធ្វើ ការពិនិត្យឡើងវិញផងដែរ។

## ៨.១.៦ ការវិភាគបញ្ហា

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំពុះពារ ដើម្បីបង្កើនការអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើដែលកំពុងតថយចុះ។ តំបន់ ដ៏ធំនៃសារព័ន្ធព្រៃស្រោងនិងព្រៃពាក់កណ្តាលស្រោងស្ថិតក្រោមការគំរាមកំហែងយ៉ាងខ្លាំងពីការកាប់បំផ្លាញព្រៃឈើសម្រាប់ការធ្វើ កសិ-ឧស្សាហកម្ម ការអភិវឌ្ឍ និងការពង្រីកដីកសិកម្ម។ ការរំលោភបំពានសិទ្ធិ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើជារឿយៗ តែងកើតមានវិវាទ ហើយឬសគល់នៃវិវាទទាំងនេះភាគច្រើនបណ្តាលមកពីភាពមិនច្បាស់លាស់នៃព្រំប្រទល់ព្រៃឈើ និងចំណាត់ថ្នាក់ ព្រៃឈើ។ ភាពមិនច្បាស់ក្នុងកម្មសិទ្ធិដីព្រៃឈើ និងសិទ្ធិអ្នកប្រើប្រាស់មិនបានលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធនានាក្នុងការចូលរួមការពារ អភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយចីភាព។ ស្ថានភាពបែបនេះ អាចនឹងបន្តមានជារៀងរហូត លុះត្រាតែសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវបានកំណត់ព្រំប្រទល់ និងធ្វើចំណាត់ថ្នាក់រួច។

ការគ្មានសុវត្ថិភាពលើកម្មសិទ្ធិដីធ្លី មានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការ គ្រប់គ្រងធនធានព្រៃឈើ ហើយក៏បានរារាំងដល់កិច្ចព្រមព្រៀងរយៈពេលវែងរវាងរាជរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដូចជាកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ព្រមទាំងធ្វើឱ្យថយចុះនូវសកម្មភាពបង្កើនជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋាន។

ដើម្បីគ្រប់គ្រងធនធានព្រៃឈើឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវធ្វើការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទៅតាមមុខងារ និង សក្តានុពលពិតប្រាកដរបស់ព្រៃឈើដូចជា ព្រៃផ្តល់ផលព្រៃការពារ ឬព្រៃសម្រាប់ផ្ទេរ។ នេះជាជំហានដំបូងឆ្ពោះទៅរកការកំណត់ គោលបំណងគ្រប់គ្រងជាក់លាក់នៃចំណាត់ថ្នាក់ព្រៃឈើនីមួយៗ។ ការធ្វើចំណាត់ថ្នាក់នេះ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធ្វើឱ្យមាន តុល្យភាពរវាងតំបន់ដីព្រៃឈើសម្រាប់ការប្រើប្រាស់ផ្សេងៗ ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងទីជម្រាល ព្រៃការពារអភិរក្សប្រភពទឹកសាប តំបន់ព្រៃលំហែកំសាន្ត តំបន់គ្រប់គ្រងពិសេស។ល។ ដូចជាតំបន់អភិរក្សសត្វព្រៃ និងប្រភពផ្តល់ ពូជជាដើម។

នៅពេលដែលមានការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងមានផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ នោះជម្លោះនៃអ្នក ប្រើប្រាស់ដីនៅក្នុងឬក្បែរតំបន់ព្រៃឈើត្រូវបានពិភាក្សា និងដោះស្រាយ។ ការកាន់កាប់ដីព្រៃឈើដោយខុសច្បាប់នឹងត្រូវដកហូតមក វិញ ហើយដីដែលបានកាន់កាប់ស្របច្បាប់ត្រូវបានទទួលស្គាល់ ដែលចាំបាច់ត្រូវប្រើប្រាស់នូវនីតិវិធីសមស្រប និងមានតម្លាភាព។ ការកំណត់ព្រំប្រទល់ដោយប្រើប្រាស់វិធីសាស្ត្រសមស្រប អាចធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមាន ព្រមទាំងធ្វើឱ្យកាន់តែងាយស្រួលដោះស្រាយ ទំនាស់ផងដែរ។ បច្ចុប្បន្នរដ្ឋបាលព្រៃឈើបាន និងកំពុងធ្វើបច្ចុប្បន្នភាពនូវលក្ខណៈវិនិច្ឆ័យ នីតិវិធី និងមធ្យោបាយបច្ចេកទេស ដើម្បីធ្វើ អត្តសញ្ញាណ និងកំណត់ព្រំប្រទល់ដីព្រៃឈើឱ្យបានសុក្រឹត។

អនុក្រឹត្យលេខ ៥៣ អនក្រ.បក បានតម្រូវឱ្យមានការសិក្សាផ្តោតលើមុខងារបរិស្ថាន និងអេកូឡូស៊ីព្រៃឈើ សក្តានុពល និង បច្ចុប្បន្នភាពនៃការប្រើប្រាស់ដីព្រៃឈើ ដោយមានការពិគ្រោះយោបល់មុនពេលសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានធ្វើចំណាត់ថ្នាក់។

បន្ទាប់ពីតំបន់ព្រៃឈើមួយនៃសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជីកាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវចុះតំបន់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទាំងអស់នេះទៅក្នុងបញ្ជីដីរដ្ឋជាចាំបាច់។

### ៨.១.៧ គោលបំណងនៃកម្មវិធី

គោលបំណងរួមនៃកម្មវិធីកំណត់ព្រំប្រទល់ចាត់ថ្នាក់និងចុះបញ្ជីតាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ គឺរួមចំណែកក្នុងការរៀបចំគ្រប់គ្រង ធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដោយបង្កើតនូវសុវត្ថិភាពកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់របស់ភាគីពាក់ព័ន្ធ ជាពិសេសសហគមន៍ មូលដ្ឋាន ព្រមទាំងធ្វើឱ្យប្រសើរឡើងដល់ការដោះស្រាយទំនាស់ដែលកើតមានឡើង។

គោលបំណងជាក់លាក់ គឺបង្កើតនូវប្រព័ន្ធមួយប្រកបដោយតម្លាភាពដើម្បីកំណត់ព្រំប្រទល់ និងចំណាត់ថ្នាក់ព្រៃឈើដោយ យកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាគោលសម្រាប់ផ្ទៀងផ្ទាត់នឹងភាពជាក់ស្តែង និងធ្វើសុខដុមកម្មជាមួយនឹងច្បាប់ពាក់ព័ន្ធ សំដៅ រួមចំណែកដល់ការទប់ស្កាត់ជម្លោះដីធ្លីទាក់ទងទៅនឹងកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់ព្រៃឈើរបស់សហគមន៍មូលដ្ឋាន។

*សកម្មភាពចម្បងៗនគោលបំណងនេះ រួមមាន ៖*

- កំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទាំងអស់លើផែនទីនិងនៅលើទីតាំងជាក់ស្តែងដើម្បីធានាថាកម្មសិទ្ធិដែលទាក់ទងទៅ នឹងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍មានភាពច្បាស់លាស់ចំពោះគ្រប់អ្នកពាក់ព័ន្ធ ហើយទំនាស់ពាក់ព័ន្ធនឹងការកាន់កាប់ដីព្រៃឈើត្រូវបាន ដោះស្រាយ

- ធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ គឺផ្អែកលើមុខងារ និងសក្តានុពលពិតប្រាកដរបស់ព្រៃឈើ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុង ការធ្វើផែនការអភិវឌ្ឍន៍ និងប្រើប្រាស់ព្រៃឈើ
- ចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ទៅក្នុងការចុះបញ្ជីដីរដ្ឋ ។

## ៨.១.៨ សូចនាករ

- វិធីសាស្ត្រ និងគោលការណ៍ណែនាំដើម្បីឱ្យមានការចូលរួមជាសាធារណៈ និងការដោះស្រាយទំនាស់ក្នុងការកំណត់ព្រំប្រទល់ព្រៃឈើ ត្រូវបានបង្កើតឡើង និងត្រូវបានប្រើប្រាស់នៅក្នុងដំណើរការកំណត់ព្រំប្រទល់ព្រៃឈើ
- ដំណើរការកំណត់ព្រំប្រទល់ព្រៃឈើត្រូវបានធ្វើសុខដុមកម្មជាមួយនឹងដំណើរការធ្វើអត្តសញ្ញាណកម្មផែនទីដីរដ្ឋ និងការចុះបញ្ជីកា ដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច
- ប្រជាជននៅមូលដ្ឋានមានការយល់ដឹងត្រឹមត្រូវពីគោលបំណងនៃការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រព័ន្ធនៃការធ្វើចំណាត់ថ្នាក់ព្រៃឈើត្រូវបានរៀបចំឡើងដោយមានតម្លាភាព និងប្រសិទ្ធភាព
- គ្រប់ភាគីពាក់ព័ន្ធសហគមន៍ និងអាជ្ញាធរមូលដ្ឋានបានចូលរួមយ៉ាងសកម្មក្នុងការកំណត់ព្រំប្រទល់ដែនព្រៃឈើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានកំណត់ព្រំប្រទល់យ៉ាងច្បាស់នៅលើផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ជាផ្លូវការ និងនៅទីតាំង ជាក់ស្តែង
- ប្រជាជននៅមូលដ្ឋានបានដឹងពីទីតាំងព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងមុខងារព្រៃឈើ
- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជីកានៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទនិងចុះក្នុងបញ្ជីដីរដ្ឋនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- កម្មសិទ្ធិដីធ្លីនៅមូលដ្ឋាន និងសិទ្ធិអ្នកប្រើប្រាស់ត្រូវបានធានាសុវត្ថិភាព បន្ទាប់ពីបញ្ចប់ការកំណត់ព្រំប្រទល់ដែនព្រៃឈើ សម្បត្តិព្រៃឈើ អចិន្ត្រៃយ៍ ត្រូវបានធ្វើចំណាត់ថ្នាក់ផ្អែកទៅលើមុខងារ និងសក្តានុពលពិតប្រាកដរបស់ព្រៃឈើដើម្បីគាំទ្រដល់ សកម្មភាពគ្រប់គ្រង និងអភិវឌ្ឍវិស័យព្រៃឈើ
- ប្រព័ន្ធទិន្នន័យស្តីពីព្រៃឈើដែលបានចុះបញ្ជីកាត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំផែនការក្នុងវិស័យព្រៃឈើ។

### ៨.១.៩ ការផ្ទៀងផ្ទាត់

- ផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាលទ្ធផលទទួលបានពីការកំណត់ព្រំប្រទល់ដែនព្រៃឈើ
- ទិន្នន័យព្រំប្រទល់ដែនព្រៃ និងចំណាត់ថ្នាក់ព្រៃឈើទៅតាមមុខងារ និងសក្តានុពល
- គោលការណ៍ណែនាំសម្រាប់ការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងការដោះស្រាយទំនាស់
- យន្តការដោះស្រាយជម្លោះនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ
- សហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើឱ្យមាន សុខដុមកម្មដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើ
- របាយការណ៍ស្តីពីដំណោះស្រាយទំនាស់ដីព្រៃឈើ
- កិច្ចប្រជុំ និងកំណត់ហេតុឯកសារស្តីពីសហប្រតិបត្តិការអន្តរស្ថាប័ន
- ការបញ្ចូលផែនទីព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ទៅក្នុងឯកសារចុះបញ្ជីដីរដ្ឋ
- បង្គោលកំណត់ព្រំប្រទល់ដែនព្រៃឈើត្រូវបានបោះនៅលើទីតាំងជាក់ស្តែង ការអង្កេតដើម្បីផ្ទៀងផ្ទាត់ចំណេះដឹងរបស់ប្រជាជននៅមូលដ្ឋានស្តីពីព្រំប្រទល់ព្រៃឈើ
- ផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំណាត់ថ្នាក់ព្រៃឈើមាននៅមូលដ្ឋាន និងនៅថ្នាក់ជាតិត្រូវបានទទួលស្គាល់ជាផ្លូវការ
- ស្ថិតិព្រៃឈើ និងផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ត្រូវបានធ្វើបច្ចុប្បន្នភាព
- ផែនការសកម្មភាពរបស់កម្មវិធីត្រូវបានបង្កើតឡើង
- ដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី។

### ៨.១.១០ ហានិភ័យនៃកម្មវិធី

- ខ្វះកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នអនុវត្ត និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធដើម្បីចូលរួមអនុវត្តការកំណត់ព្រំ ប្រទល់ដែនព្រៃឈើឱ្យមានប្រសិទ្ធភាព
- ការចំណាយក្នុងការកំណត់ព្រំប្រទល់ដែនព្រៃឈើមានទំហំធំ រីឯថវិកាដែលផ្តល់មានកម្រិតកំណត់។

### ៨.១.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី

#### ក. សុខដុមកម្មរវាងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងការធ្វើផែនទីដីរដ្ឋ

ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ស្ថិតនៅក្នុងដំណើរការចាប់ផ្តើមនៅឡើយ។ ដូចនេះ ចាំបាច់ត្រូវធ្វើការដកស្រង់ នូវបទពិសោធន៍ល្អៗ ដែលធានាបានថា សកម្មភាព និងយន្តការទាំង

នោះ អាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព និង មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងប្រជាជនមូលដ្ឋាន។ ក្នុងដំណើរការនេះ រដ្ឋបាលព្រៃឈើនឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បី ធ្វើបច្ចុប្បន្នភាពនូវវិធីសាស្ត្រកំណត់ព្រំប្រទល់ដែនព្រៃ ដើម្បីបង្កើតផែនទីប្រើប្រាស់ដី សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឈានទៅដល់ការ ចុះបញ្ជីដីរដ្ឋ ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការកំណត់ព្រំប្រទល់ និងការចុះបញ្ជីកាត្រូវ បានកំណត់លម្អិតនៅក្នុងអនុកម្មវិធីទី ១។

## ខ. កំណត់តំបន់អាទិភាពសម្រាប់កំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

រដ្ឋបាលព្រៃឈើបាននឹងកំពុងពង្រីកដំណើរការកំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ សំដៅគាំទ្រ និង បង្កើនល្បឿននៃកិច្ចខិតខំប្រឹងប្រែងអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងកិច្ចការពារបរិស្ថានព្រៃឈើក្នុងប្រទេស កម្ពុជា។ អាទិភាពក្នុងការកំណត់តំបន់នេះ នឹងផ្អែកទៅលើដំណើរការបើកចំហជាមួយភាគីពាក់ព័ន្ធ ជាពិសេសផ្តោតទៅលើ ៖

- ព្រៃឈើដែលមានតម្លៃសម្រាប់ការការពារពិសេស (ជីវចម្រុះភ្នំ ទីជម្រាល ប្រភពទឹកសាប កោះ ប្រភពផ្តល់ពូជ ជម្រកសត្វព្រៃ ព្រៃអារក្ស តំបន់សិក្សាស្រាវជ្រាវព្រៃឈើ)។ល។
- តំបន់ព្រៃឈើដែលទទួលរងនូវការកាប់ទន្ទ្រានយកដីព្រៃឈើធ្វើជាកម្មសិទ្ធិខុសច្បាប់
- តំបន់ព្រៃឈើដែលមានផែនការស្តាបនា ឬត្រូវពង្រីកផ្លូវបន្ថែមទៀត
- តំបន់ព្រៃឈើស្ថិតតាមបណ្តោយផ្លូវ ដែលបច្ចុប្បន្នបាននិងកំពុងធ្វើការកែលំអ ឬមាននៅក្នុងផែនការអភិវឌ្ឍន៍
- ឡូត៍គំរូសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ ទឹកដី និង អាកាសធាតុ
- សហគមន៍ព្រៃឈើ ព្រៃឈើដៃគូ និងសហគមន៍ព្រៃការពារ។

## គ. ការចូលរួមរបស់ភាគីអ្នកពាក់ព័ន្ធ និងការដោះស្រាយទំនាស់ក្នុងវិស័យព្រៃឈើ

ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានទទួលស្គាល់ថា មិនមែនជាមធ្យោបាយតែមួយសម្រាប់ការពារព្រៃឈើ នោះទេ ប្រសិនបើគ្មានការចូលរួមដោយពិតប្រាកដពីភាគីអ្នកពាក់ព័ន្ធនៅមូលដ្ឋាន។ ក្នុងដំណើរការកំណត់ព្រំប្រទល់ យន្តការ ដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋានត្រូវបានបង្កើត និងអនុវត្តដោយមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធ។

សហគមន៍មូលដ្ឋាននឹងត្រូវបានផ្តល់ឱកាសសមស្រម និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការធ្វើផែនទី ការកំណត់ ព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមការជាក់ស្តែង ការថែរក្សាបង្គោលព្រំប្រទល់ព្រៃឈើ និងការដោះស្រាយទំនាស់ តាម រយៈអាជ្ញាធរមូលដ្ឋានដែលជាស្ពានភ្ជាប់ទំនាក់ទំនងរវាងសហគមន៍មូលដ្ឋាន និងរាជរដ្ឋាភិបាល។ អាជ្ញាធររដ្ឋបាលព្រៃឈើមូលដ្ឋាន ត្រូវទទួល

យកនូវគំនិតសមស្របដែលស្នើឡើងដោយសហគមន៍មូលដ្ឋាន ហើយសហការជាមួយមន្ត្រីរាជរដ្ឋាភិបាលដែលមាន បទពិសោធន៍ និងមានសមត្ថភាព ដើម្បីជួយសម្របសម្រួលដល់ដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងការដោះស្រាយ

ទំនាស់។

### ឃ. ការដោះស្រាយទំនាស់តាមរយៈគណៈកម្មាធិការជាតិ

រដ្ឋបាលព្រៃឈើមានតួនាទីធ្វើឱ្យមានសុខដុមកម្មរវាងការកំណត់ព្រំប្រទល់ព្រៃឈើជាមួយនឹងការធ្វើផែនទីដីរដ្ឋ។ ករណី ទំនាស់ក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍មិនអាចដោះស្រាយបាននោះ ទំនាស់នឹងត្រូវលើកយកមកដោះស្រាយដោយ គណៈកម្មា ធិការជាតិដើម្បីដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ហើយជាចុងក្រោយសម្រេចដោយ រាជរដ្ឋាភិបាល។ រដ្ឋបាលព្រៃឈើនឹងសហការយ៉ាងសកម្មជាមួយស្ថាប័នតុលាការ ពង្រឹងការអនុវត្តច្បាប់យ៉ាងពេញលេញ ដើម្បីលុបបំបាត់ការចាប់យកដីព្រៃឈើធ្វើជាកម្មសិទ្ធិដោយខុសច្បាប់។

ដំណើរការនេះមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យនាពេលអនាគតរបស់កម្មវិធីព្រៃឈើជាតិដែលទាមទារឱ្យ មានការប្តេជ្ញាចិត្តរួមគ្នាគោរព និងអនុវត្តច្បាប់ ព្រមទាំងគោរពសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន។ អាជ្ញាធរពាក់ព័ន្ធត្រូវធ្វើ ការសិក្សាពីឫសគល់នៃទំនាស់ដីព្រៃឈើដែលបាននឹងកំពុងតែកើតមាននាពេលបច្ចុប្បន្ន និងរកដំណោះស្រាយសមស្រប។ ជាការ ចាំបាច់ គ្រប់ទំនាស់ទាំងនោះត្រូវបានដោះស្រាយមុនពេលការកំណត់ព្រំប្រទល់ដែនព្រៃឈើធ្វើឡើង។ ទំនាស់នឹងត្រូវដោះស្រាយ តាមរយៈការទទួលស្គាល់ពីភាពត្រឹមត្រូវនៃដីរបស់សហគមន៍មូលដ្ឋាន។ នៅពេលបច្ចុប្បន្ននេះ មានលិខិតបញ្ជាក់កម្មសិទ្ធិនៅលើ ដីព្រៃឈើជាច្រើនពុំត្រឹមត្រូវតាមផ្លូវច្បាប់។ ក្នុងស្ថានភាពនេះ អាជ្ញាធរមេដ្ឋានត្រូវទទួលខុសត្រូវ និងបញ្ឈប់ការចេញលិខិត បញ្ជាក់លើដីព្រៃឈើគ្រប់ប្រភេទរហូតដល់ការកំណត់ព្រំប្រទល់ដែនព្រៃឈើត្រូវបានបញ្ចប់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានមន្ទីរជំនាញ និងការិយាល័យភូមិបាលស្រុក ក៏ដូចជា ក្រសួង មហាផ្ទៃ និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ខេត្ត ស្រុក ក្រុង និងជាពិសេស មេឃុំ ចៅសង្កាត់ និងមេភូមិត្រូវបញ្ឈប់ការបញ្ជាក់ លើការលក់ទិញ ឬផ្ទេរកម្មសិទ្ធិដីធ្លី ដែលអាចមានការពាក់ព័ន្ធជាមួយដីព្រៃឈើ ឬដីព្រៃលិចទឹកដែលជាសម្បត្តិសាធារណៈរបស់ រដ្ឋ។ ជាពិសេស នៅទីណាដែលមិនទាន់មានការកំណត់ព្រំដែនព្រៃឈើជាសម្បត្តិសាធារណៈរបស់រដ្ឋនៅឡើយនោះ គឺមិនត្រូវ មានការបញ្ជាក់ទទួលស្គាល់ការទិញ-លក់ និងកម្មសិទ្ធិដីធ្លីទេ។

### ង. ការធ្វើចំណាត់ថ្នាក់ព្រៃឈើ

ដើម្បីរៀបចំផែនការ និងអនុវត្តការគ្រប់គ្រងព្រៃឈើរយៈពេលវែងប្រកបដោយចីរភាព អនុក្រឹត្យលេខ ៥៣ អនក្រ .បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីសម្រាប់ការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍បាន ចែងថា រដ្ឋបាលព្រៃឈើមានភារកិច្ចក្នុងដំណើរការចាត់ថ្នាក់ និងចុះបញ្ជីកាព្រៃបម្រុងទុកអចិន្ត្រៃយ៍។ រដ្ឋបាលព្រៃឈើត្រូវទទួល ខុសត្រូវរៀបចំឱ្យបានច្បាស់លាស់ និងមានតម្លាភាពនូវវិធីសាស្ត្រ ដើម្បីប្រើក្នុងការធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ហើយ សម្របសម្រួលជាមួយភាគីអ្នកពាក់ព័ន្ធ ដើម្បីធានាថាការកំណត់តំបន់ព្រៃនេះយោងទៅលើនិរន្តរភាពនៃអេកូឡូស៊ី និងមុខងារ សំខាន់ៗរបស់ព្រៃឈើ។ ចំពោះដំណើរការទាំងមូលពិស្តារនឹងមានកំណត់លម្អិតនៅក្នុងអនុកម្មវិធីទី ២។

## ៨.១.១២ អនុកម្មវិធី ១ កំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

### ក. សេចក្តីអធិប្បាយ

ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ នឹងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ ដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបាននូវការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ គឺជាបំណងប្រាថ្នាឈាន ឆ្ពោះទៅរកការគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងធ្វើឱ្យមានប្រសិទ្ធភាពក្នុងការរៀបចំផែនការ ប្រើប្រាស់ដី ការបែងចែកដីធ្លី ការដាំដើមឈើ និងព្រៃឈើ ព្រមទាំងការការពារ និងការអភិវឌ្ឍព្រៃឈើក្នុងប្រទេសកម្ពុជា។

តាមរយៈច្បាប់ស្តីពីព្រៃឈើ និងអនុក្រឹត្យលេខ ៥៣ អនក្របក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីសម្រាប់ ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ រាជរដ្ឋាភិបាលកម្ពុជាបានជម្រុញការងារកំណត់ព្រំប្រទល់ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ចាប់ពីឆ្នាំ២០០៦ មកហើយរហូតមកដល់ពេលនេះ (ឆ្នាំ ២០០៩) រដ្ឋបាលព្រៃឈើបាននឹងកំពុងធ្វើ ការកំណត់ព្រំប្រទល់ព្រៃឈើនៅក្នុងខេត្តមួយចំនួន ដើម្បីទទួលបានបទពិសោធន៍ធ្វើបច្ចុប្បន្នភាពនូវវិធីសាស្ត្រនិងគោលការណ៍ ណែនាំអនុវត្តមួយសម្រាប់បន្តអនុវត្តនៅទូទាំងប្រទេស ដោយគោលការណ៍ណែនាំនេះ មានកំណត់នូវលក្ខណៈបច្ចេកទេស លក្ខណៈ វិនិច្ឆ័យព្រមទាំងនីតិវិធីនៃការធ្វើអត្តសញ្ញាណកំណត់ព្រំប្រទល់ដីព្រៃឈើអោយបានសមស្រប និងអាចអនុវត្តបានប្រកបដោយ ប្រសិទ្ធភាព។

ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយយកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាគោល និងតាម ស្ថានភាពជាក់ស្តែង។

ខ. មធ្យោបាយសម្រាប់អនុវត្ត

- **សុខដុមនីយកម្មនៃនីតិវិធីកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងគោលការណ៍ណែនាំសម្រាប់ការធ្វើផែនទីដីរដ្ឋ**

នីតិវិធីកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍នឹងត្រូវធ្វើការពិនិត្យកែលម្អ ដើម្បីធានាថា ការកំណត់ព្រំប្រទល់ ដែនព្រៃឈើនេះ មានប្រសិទ្ធភាព និងគាំទ្រដល់កម្មវិធីធ្វើផែនទីដីរដ្ឋ។ ចំណុចចាប់ផ្តើមនៃកម្មវិធីនេះ នឹងពិនិត្យលើវិធីសាស្ត ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ៥៣ អនក្រុបក និងបទពិសោធន៍ដែលទទួលបានពីដំណើរការកំណត់ព្រំប្រទល់ដែន ព្រៃឈើក្នុងឆ្នាំ២០០៦-២០០៩ បញ្ហាសំខាន់ៗដែលកើតមានកន្លងមកនឹងបន្តដោះស្រាយតាមរយៈការបង្កើនកិច្ច សហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងមានការចូលរួមជាអតិបរមារបស់ប្រជាជនមូលដ្ឋាន ដើម្បីឱ្យដំណើរ ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទទួលបានជោគជ័យ ហើយក៏ស្របនឹងកម្មវិធីចុះបញ្ជីដីថ្នាក់ជាតិដែរ។

- **ការសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ**

អនុកម្មវិធីនេះ នឹងធ្វើការជាពិសេសឆ្ពោះទៅបង្កើនកិច្ចសហការរវាងរដ្ឋបាលព្រៃឈើជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីបង្កើនល្បឿនដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងភ្ជាប់ទំនាក់ទំនងជាមួយផែនការប្រើប្រាស់ដីឃុំសង្កាត់ និងដំណើរការសម្បទានដីសង្គមកិច្ច។

- **ការចូលរួមកំណត់ព្រំប្រទល់ដែនព្រៃឈើនៅថ្នាក់មូលដ្ឋាន**

បច្ចុប្បន្នរដ្ឋបាលព្រៃឈើបាននិងកំពុងធ្វើការបោះបង្គោលព្រំប្រទល់ដែនព្រៃឈើដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងភាគីអ្នកពាក់ព័ន្ធ។ ក្នុងដំណើរការកំណត់ព្រំប្រទល់នេះ រដ្ឋបាលព្រៃឈើបានធ្វើការផ្សព្វផ្សាយ និងពិគ្រោះ យោបល់ជាមួយសហគមន៍មូលដ្ឋាន និងភាគីអ្នកពាក់ព័ន្ធផ្សេងទៀតឱ្យបានយល់ដឹងពីគោលបំណងនៃការកំណត់ព្រំប្រទល់ ដែនព្រៃឈើ ព្រមទាំងសិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការទទួលខុសត្រូវថែរក្សាបង្គោលព្រំប្រទល់ដែនព្រៃឈើ ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានជាការចាំបាច់ ពិសេសជាមួយអ្នក ភូមិចាស់ទុំ ពីព្រោះពួកគាត់ជាប្រភពនៃការផ្តល់ភស្តុតាងផ្នែកប្រវត្តិសាស្ត្រ និងវប្បធម៌នៅក្នុងសហគមន៍។

ក្នុងដំណើរការកំណត់ព្រំប្រទល់នេះ ត្រូវយកផែនទីគម្របព្រៃឈើឆ្នាំ២០០២ជាគោល ដោយត្រូវអនុវត្តតាមស្ថានភាពជាក់ស្តែង។ តំបន់ដែលកាន់កាប់ស្របច្បាប់ដោយប្រជាពលរដ្ឋត្រូវទទួលស្គាល់ ដោយត្រូវកាត់ចេញពីផែនទី គម្របព្រៃឈើឆ្នាំ២០០២ នូវផ្ទៃដីបង្កបង្កើនផល ផ្ទៃដីសង់លំនៅដ្ឋាន ហើយតំបន់ដែលដាំដុះបានជាចម្ការឈើដាំដែលស្រប តាមនិយមន័យព្រៃឈើដែលបានកំណត់

ក្នុងឯកសារនេះ ត្រូវបញ្ចូលទៅក្នុងផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។ រាល់ សកម្មភាពម្ដេងដីព្រៃ ការលាកំបាំងដីព្រៃ ឬ ការរារាំងសមត្ថកិច្ចមិនឱ្យកំណត់ព្រំប្រទល់ដីព្រៃ ក្នុងគោលបំណងហ៊ុព័ទ្ធ កាន់កាប់ដីព គឺជាសកម្មភាពល្មើសនឹងច្បាប់ស្ដីពីព្រៃឈើ ដែលជនល្មើសត្រូវផ្ដន្ទាទោសតាមមាត្រា ៩៧។

- **ការកំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍**

ការកំណត់ព្រំប្រទល់ដែនព្រៃឈើផ្អែកទៅលើគោលការណ៍ណែនាំដែលនឹងកែលម្អបង្កើតឡើងក្នុងដំណាក់កាល ដំបូងនៃការអនុវត្តអនុកម្មវិធីនេះ។ ជំហានសំខាន់ៗក្នុងដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើមាន ៖

១ .រៀបចំកែលម្អគោលការណ៍កំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយផ្អែកលើផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាផែនដីពេល

២.ធ្វើល្បាតឡើងវិញនូវទីតាំងចំណុចដែលត្រូវបោះបង្គោលព្រំនៅលើទីតាំងជាក់ស្ដែង ដែលបានឯកភាពគ្នា ៣. ធ្វើការអង្កេតនិងដោះស្រាយដោយអនុវត្តតាមគោលការណ៍ណែនាំថ្នាក់ជាតិ ចំពោះតំបន់ដែលមានការគ្រប់គ្រង មិនច្បាស់លាស់

៤.ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវចេញសេចក្ដីប្រកាសស្ដីពីការកំណត់ព្រំប្រទល់ដែនព្រៃបម្រុងទុក អចិន្ត្រៃយ៍ និងធ្វើការផ្សព្វផ្សាយជាសាធារណៈរហូតដល់កម្រិតថ្នាក់សហគមន៍មូលដ្ឋាន

៥.ការបិទផ្សាយជាសាធារណៈមានរយៈពេល៤៥ថ្ងៃដើម្បីទទួលពាក្យតវ៉ា ៖ ប្រសិនបើមិនមានពាក្យតវ៉ាទេនោះ

៦.សេចក្ដីព្រាងព្រំប្រទល់ដែលបានស្នើសុំ ត្រូវធ្វើការសម្រេចជាស្ថាព ៦. ប្រសិនបើមានពាក្យតវ៉ាមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅអនុគណៈកម្មាធិការថ្នាក់ខេត្តក្រុងដោះស្រាយ បន្ត ឬប្រសិនបើមានការចាំបាច់អាចធ្វើការដោះស្រាយនៅគណៈកម្មាធិការថ្នាក់ជាតិដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬ ស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល

៧.រដ្ឋបាលព្រៃឈើរៀបចំសម្របសម្រួល និងបោះបង្គោលព្រំអចិន្ត្រៃយ៍ដោយបង្គោលរបតុង លើព្រំប្រទល់ដែនព្រៃឈើ ដែលបានដោះស្រាយរួច

៨.ធ្វើប្រកាសចុះបញ្ជីកា ព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចុះបញ្ជី ផែនទី ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ជាតំបន់ដីសាធារណៈរបស់រដ្ឋនៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

- **ការដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍**

រាជរដ្ឋាភិបាលនឹងបង្កើតគណៈកម្មាធិការថ្នាក់ជាតិដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ហើយគណៈកម្មាធិការនេះអាចបង្កើតអនុគណៈកម្មាធិការថ្នាក់ខេត្តតាមការចាំបាច់។ ដូច្នេះទំនាស់ដីព្រៃឈើដែលមិនអាច ដោះស្រាយបាននៅថ្នាក់ខេត្ត នឹងត្រូវបានលើកយកមកដោះស្រាយនៅគណៈកម្មាធិការថ្នាក់ជាតិ រួចហើយដាក់ជូនរាជរដ្ឋ ភិបាលសម្រេច។ ប៉ុន្តែក្នុងករណីជាច្រើនបញ្ហាទំនាស់កើតឡើងដោយសារជនមួយចំនួនមានប័ណ្ណកាន់កាប់ដីលើតំបន់ដី ព្រៃឈើដែលសម្បត្តិសាធារណៈរបស់រដ្ឋ ដែលជាកត្តាធ្វើឱ្យរាំងស្ទះដល់ដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើនឹងត្រូវដោះស្រាយតាមប្រព័ន្ធតុលាការ ។

- **ការចុះបញ្ជីកា**

បន្ទាប់ពីដែនព្រៃឈើនៅតំបន់ណាមួយត្រូវបានកំណត់ព្រំប្រទល់រួច រដ្ឋបាលព្រៃឈើត្រូវបញ្ជូនគម្រោងសំណើចាត់ ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយភ្ជាប់នូវសំណុំឯកសារ ផែនទី និងរបាយការណ៍ស្តីពីដំណើរការរៀបចំចាត់ថ្នាក់ព្រៃបម្រុង ទុកអចិន្ត្រៃយ៍នោះតាមនីតិវិធី ដើម្បីស្នើសុំប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រភេទចំណាត់ថ្នាក់ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗត្រូវមានអត្តលេខចុះបញ្ជីកាដែលផ្តល់ និងតម្កល់ទុកនូវរដ្ឋបាលព្រៃឈើ សម្រាប់សម្គាល់ ជាអត្តសញ្ញាណនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះ។

បន្ទាប់ពីបានប្រកាសចុះបញ្ជីកាព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋបាល ព្រៃឈើត្រូវចម្លងសំណុំឯកសារព្រៃបម្រុងទុកអចិន្ត្រៃយ៍ចំនួនមួយច្បាប់ជូនក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ដើម្បីចុះបញ្ជីតាជាដីរដ្ឋជាចាំបាច់។

- **លទ្ធផលរំពឹងទុក**
- វិធីសាស្ត្រ នីតិវិធី និងការដោះស្រាយទំនាស់ក្នុងដំណើរការកំណត់ព្រំប្រទល់ដីព្រៃឈើ ត្រូវបានបង្កើតឡើង ដើម្បីកំណត់ពំ ប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៏ត្រូវបានអនុវត្តដោយមានតម្លាភាពគ្រប់ភាគីអ្នកពាក់ព័ន្ធទាំងអស់ត្រូវបានចូលរួម ហើយជម្លោះ ស្តីពីការកាន់កាប់ដីព្រៃឈើដោយរំលើសច្បាប់ត្រូវបានដោះស្រាយយ៉ាងមានប្រសិទ្ធភាពតាមរយៈការអនុវត្តច្បាប់ពេញលេញ និង មានកិច្ចសហការរវាងស្ថាប័នបានល្អ។ ដំណើរការនៃការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគាំទ្រដល់ការធ្វើផែនទីដីរដ្ឋ
- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានកំណត់ព្រំប្រទល់ច្បាស់លាស់នៅលើផែនទី និងបានបោះបង្គោលនៅទីតាំងជាក់ស្តែង ដើម្បី អាចធ្វើការចាក់ថ្នាក់សម្បត្តិ ព្រៃឈើអចិន្ត្រៃយ៍ដោយផ្អែកទៅលើមុខងារនិងសក្តានុពលពិតប្រាកដរបស់ព្រៃឈើ។ ព្រំប្រទល់ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជីកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងចុះបញ្ជីដីរដ្ឋនៅក្រសួង

រៀបចំដែន ដីនគរូបនីយកម្មនិងសំណង់។ ដីព្រៃឈើដែលជាសម្បត្តិសាធារណៈរបស់រដ្ឋត្រូវបានការពារដោយមានព្រំប្រទល់ច្បាស់លាស់ និងមានមូលដ្ឋានផ្លូវច្បាប់យ៉ាងរឹងមាំ ដើម្បីអាចអនុវត្តការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើដោយនិរន្តរភាព

- សហគមន៍មូលដ្ឋានយល់ដឹងពីគោលបំណងនៃការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ពួកគាត់ក្នុងដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើ
- សកម្មភាពបទល្មើសព្រៃឈើ និងការរំលោភកាន់កាប់ដីព្រៃឈើត្រូវបានកាត់បន្ថយតាមរយៈការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ច្បាស់លាស់
- សហគមន៍យល់ដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការការពារនិងប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព ហើយទំនាស់លើដីព្រៃឈើត្រូវបានកាត់បន្ថយ និងដោះស្រាយយ៉ាងមានប្រសិទ្ធភាព ដោយសារសមត្ថភាពក្នុងការដោះស្រាយទំនាស់ត្រូវបានបង្កើនឡើង។

## ៨.១.១៣ អនុកម្មវិធី ២ ការចាត់ថ្នាក់ព្រៃឈើជាតិតាមមុខងារ

### ៨.១.១៣.១ សេចក្ដីអធិប្បាយ

ការធ្វើចំណាត់ថ្នាក់ព្រៃឈើច្បាស់លាស់ដោយផ្អែកទៅលើកត្តាប្រព័ន្ធមជ្ឈដ្ឋានសក្តានុពល និងមុខងាររបស់ព្រៃឈើជាការ ចាំបាច់សម្រាប់ការខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានតុល្យភាពរវាងការប្រើប្រាស់ផលិតផលព្រៃឈើប្រកបដោយនិរន្តរភាពជាមួយ នឹងការផ្តល់សេវាកម្មការពារបរិស្ថាន។ បច្ចុប្បន្នកម្ពុជាបានធ្វើការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍តាមមុខងារព្រៃដូចតទៅៈ

ក.ព្រៃផ្តល់ផល ត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះ មុខងារការពារ ត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍ៈ

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចម្ការព្រៃឈើ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរេចរិល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង
- ស្ថានីយ៍ផ្សព្វផ្សាយ និង ស្តារព្រៃឈើ។

ខ.ព្រៃការពារត្រូវបានរក្សាទុកជាចម្បងដើម្បីផ្តល់សេវាកម្មបរិស្ថាន និងការពារប្រព័ន្ធមជ្ឈដ្ឋាននិងធនធានធម្មជាតិ។ ព្រៃការពារមានជាអាទិ៍៖

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស (ព្រៃទប់ស្កាត់ការប្រែប្រួលអាកាសធាតុ)
- ព្រៃឈើសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃឈើរក្សានីយតកម្មប្រភពទឹក
- ព្រៃឈើការពារទីជម្រាល
- ព្រៃអភិរក្សសត្វព្រៃ
- ព្រៃអភិរក្សសម្រាប់កីឡាប្រមាញ់
- ព្រៃអភិរក្សធនធានសេនេទិច និងពូជ
- ព្រៃអភិរក្សជីវចម្រុះ
- ព្រៃឈើសម្រាប់ប្រឆាំងភាពរហោស្ថាន
- ព្រៃលំហែកំសាន្ត
- សួនភូតគាម
- ឧទ្យានសួនសត្វ
- ព្រៃស្តារលទ្ធភាពជីវសាស្ត្រសត្វព
- ព្រៃច្រករបៀងសត្វព្រៃ
- ព្រៃជំនឿសាសនា។

គ. ផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដែលដុះរុក្ខជាតិព្រៃបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅ ក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូត ដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍសម្រាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល ជាពិសេសសម្បទានដី សង្គមកិច្ច។

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានរៀបចំកន្លងមកមាន ព្រៃសម្បទាន តំបន់ការពារព្រៃការពារ តំបន់ប្រភពគ្រាប់ពូជ សហគមន៍ព្រៃឈើ ព្រៃការពារទីជម្រាល និងតំបន់ការពារផ្សេងទៀត។ តំបន់ទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ ប៉ុន្តែ ព្រំប្រទល់នៃតំបន់ទាំងនេះមានការប្រែប្រួល ដែលចាំបាច់ត្រូវការធ្វើពិនិត្យឡើងវិញ។ ទោះជាយ៉ាងនេះក្តី ផ្ទៃដីព្រៃឈើដ៏ធំពុំទាន់ បានធ្វើចំណាត់ថ្នាក់ និងពុំទាន់មាននីតិវិធីលម្អិតធ្វើចំណាត់ថ្នាក់នៅឡើយ។

គោលបំណងនៃការធ្វើចំណាត់ថ្នាក់ដោយផ្អែកទៅលើមុខងារនិងសក្តានុពលពិតប្រាកដរបស់ព្រៃឈើគឺ ដើម្បីធានាថា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ អាច

ធ្វើការកំណត់តំបន់ដ៏មានប្រសិទ្ធភាពដើម្បីកាត់ បន្ថយឥទ្ធិពលអវិជ្ជមានដល់ការផ្លាស់ប្តូរការប្រើប្រាស់ដី នឹងជួយការពារយ៉ាងសំខាន់ដល់សេវាកម្មបរិស្ថានរបស់ព្រៃឈើ។

### ៨.១.១៣.២ មធ្យោបាយសម្រាប់អនុវត្ត

រដ្ឋបាលព្រៃឈើមានភារកិច្ចក្នុងដំណើរការចាត់ថ្នាក់ និងចុះបញ្ជីកាព្រៃបម្រុងទុកអចិន្ត្រៃយ៍ដូចខាងក្រោម ៖

- ចុះអង្កេតវាស់វែងចំណុចនិយាមតា និងសិក្សាស្ថានភាពព្រៃជាក់ស្តែង ដែលនឹងត្រូវចាត់ថ្នាក់ផ្អែកតាមផែនទីដែនព្រៃបម្រុងទុក អចិន្ត្រៃយ៍ ដោយប្រមូលទិន្នន័យអំពីប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ធនធានព្រៃឈើ និងព័ត៌មានអំពីតម្រូវការសង្គម សេដ្ឋកិច្ច និង សក្តានុពលផ្សេងទៀតរបស់ព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមតំបន់ ឬភូមិសាស្ត្រព្រៃឈើនីមួយៗ
- ធ្វើការវិភាគលើទិន្នន័យ និងព័ត៌មាន ដែលប្រមូលបានក្នុងតំបន់ ឬ ភូមិសាស្ត្រព្រៃឈើនីមួយៗ ដើម្បីធ្វើអត្តសញ្ញាណព្រៃបម្រុងទុកអចិន្ត្រៃយ៍ទៅតាមចំណាត់ថ្នាក់នីមួយៗ
- ដៅចំណុចនិយាមកាសម្គាល់ព្រំសីមាគោលរបស់ចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ នៅលើផែនទីដែនព្រៃបម្រុងទុក អចិន្ត្រៃយ៍ និងនៅលើទីតាំងជាក់ស្តែងដោយកំណត់យកព្រំធម្មជាតិ ជាអាទិភាពដូចជា ផ្លូវ អូរ ស្ទឹង ព្រែក ជួរខ្នងភ្នំ
- ធ្វើការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន ឬសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្របសម្រួលដល់ដំណើរការចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅតាមមូលដ្ឋានខេត្តនីមួយៗ
- រៀបចំឯកសារសម្រាប់គម្រោងចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ ដោយកំណត់នូវទីតាំងភូមិសាស្ត្រ ទីតាំងរដ្ឋបាល ព្រំប្រទល់ និងនិយាមកាច្បាស់លាស់ ព្រមទាំងបង្ហាញពីសារៈសំខាន់និងគោលបំណងសំខាន់ក្នុងការចាត់ថ្នាក់ព្រៃបម្រុងទុក អចិន្ត្រៃយ៍នីមួយៗ និងទិសដៅអនាគតក្នុងការអភិវឌ្ឍប្រើប្រាស់ និងគ្រប់គ្រងចំណាត់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ
- រៀបចំគម្រោងសំណើចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយភ្ជាប់សំណុំឯកសារផែនទី និងរបាយការណ៍ស្តីពីដំណើរការចាត់ ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដើម្បីសុំប្រកាសចាត់ថ្នាក់ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

### ៨.១.១៣.៣ លទ្ធផលរំពឹងទុក

- តំបន់ព្រៃឈើត្រូវបានធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មុខងារប្រព័ន្ធចំណាត់ថ្នាក់ព្រៃឈើ អាចជួយដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដោយរួមទាំងការផ្តល់តម្លៃសម្រាប់ សេវាកម្មបរិស្ថាន ការពារតម្លៃវប្បធម៌ និងចំណូលពីទេសចរណ៍ធម្មជាតិ។ល។
- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានចាត់ថ្នាក់ទៅតាមមុខងារ និងសក្តានុពលពិតប្រាកដរបស់ព្រៃឈើ ហើយធនធានព្រៃឈើត្រូវ បានអភិវឌ្ឍ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព
- ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងការធ្វើផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ។

## ៨.១.១៤ តម្រូវការហិរញ្ញវត្ថុ

តារាងទី១ ៖ តារាង ថវិកាសម្រាប់ កម្មវិធីកំណត់ព្រំប្រទល់ព្រៃឈើ ការចាត់ថ្នាក់ និងចុះបញ្ជីកាសម្រាប់ឆ្នាំ ២០១០-២០២០

| អនុកម្មវិធី | ថវិកាប៉ាន់ស្មានក្នុងឆ្នាំ ២០១០-២០១៤ (ដុល្លាអាមេរិក) | ថវិកាប៉ាន់ស្មានក្នុងឆ្នាំ ២០១០-២០១៤ (ដុល្លាអាមេរិក) |
|---|---|---|
| ១-១ កំណត់ព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើ អចិន្ត្រៃយ៍ | ២.៣៤០.០០០ | ៥.៧៧៤.០០០ |
| ២-២ ការចាត់ថ្នាក់ព្រៃឈើជាតិតាមមុខងារ | ៤៤៣.០០០ | ៤៤៣.០០០ |
| ចំណាយសរុប | ២.៧៨៣.០០០ | ៦.២១៧.០០០ |
| ថវិកាបរិច្ចាគមកពីដៃគូអភិវឌ្ឍន៍ | ១.០០០.០០០ | |

សន្មត់ថា ចំណូលពីព្រៃឈើនឹងត្រូវធ្វើការវិនិយោគឡើងវិញទៅក្នុងផ្នែកនិងការងារខាងលើនេះ ដែលជាលទ្ធផលនឹងធ្វើឱ្យ ការអនុវត្តការងារនេះកាន់តែមានលក្ខណៈស្វ័យហិរញ្ញប្បទានសមស្រប និងមានសង្គតិភាពជាមួយនឹងកម្មវិធីហិរញ្ញប្បទាន ដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ។ ចំណែកឯថវិកាបរិច្ចាគពីដៃគូអភិវឌ្ឍន៍នឹងកាន់តែមានការថយចុះបន្តិចម្តងៗ នៅ ជំហានទី២ ដែលមានរយៈពេល៥ឆ្នាំទៀត។

## ៨.២ កម្មវិធីទី ២ ការអភិរក្ស និង ការអភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ

### ៨.២.១ ចំណុចអាទិភាពសំខាន់ៗ

- ការអភិវឌ្ឍព្រៃឈើដោយនិរន្តរភាព
- ប្រព័ន្ធគ្រប់គ្រងព្រៃឈើ
- ចម្ការព្រៃឈើ ដាំ
- ការអភិរក្សធនធានសត្វព្រៃ និងជីវចម្រុះ
- ទេសចរណ៍ធម្មជាតិ (Eco-tourism)
- ការគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិជ្ជាកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើ និងពង្រីកទីផ្សារ
- ការកែច្នៃឈើ និងអនុផលព្រៃឈើ។

### ៨.២.២ រយៈពេលកម្មវិធី

មានរយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២៩

### ៨.២.៣ ការឆ្លើយតបទៅនឹងទស្សនវិស័យនៃកម្មវិធីព្រៃឈើជាតិ

កម្មវិធីអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើនឹងចូលរួមចំណែកធ្វើឱ្យប្រសើរឡើងដល់ការការពារបរិស្ថាន ការកាត់បន្ថយ ភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

### ៨.២.៤ ការឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

កម្មវិធីនេះមានគោលបំណងគាំទ្រដល់កិច្ចអភិវឌ្ឍជាតិ តាមរយៈការទាញយកផលប្រយោជន៍ជាអតិបរមាពីធនធានព្រៃឈើ និងសេវាកម្មបរិស្ថានរបស់ព្រៃឈើប្រកបដោយនិរន្តរភាព។

### ៨.៦.៥ សារតាកម្មវិធី

ព្រៃឈើគឺជាផ្នែកមួយនៃការទ្រទ្រង់ដល់ជីវិតរស់នៅ និងវប្បធម៌របស់ប្រជាជនកម្ពុជាយើងតាំងពីដើមរៀងរហូតមក។ ប្រជាពលរដ្ឋ ជនបទភាគច្រើនប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកទៅលើផលិតផលព្រៃឈើ។ រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកថាការអភិរក្ស និងការគ្រប់គ្រង ធនធានព្រៃឈើបានគង់វង្សចីរភាព គឺជាការរក្សានិងបង្កើនបាននូវទ្រព្យសម្បត្តិរបស់ជាតិដ៏មានតម្លៃ ហើយការគ្រប់គ្រងព្រៃឈើបានល្អនឹងនាំមកនូវការកាត់បន្ថយភាពក្រីក្រ និងជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដោយចីរភាព។ នៅពេលបច្ចុប្បន្ននេះ ការគ្រប់គ្រង ព្រៃឈើជួបប្រទះនូវការលំបាកដោយសារតែមានក្រុមជនឆ្លៀតឱកាស

មួយចំនួនធ្វើការរំលោភកាន់កាប់ដីព្រៃឈើរបស់រដ្ឋ ក្នុង ខណៈ ដែលតំបន់ព្រៃឈើនៅទូទាំងប្រទេស មានតែព្រំប្រទល់នៅលើផែនទី តែមិនទាន់បានបោះបង្គោលកំណត់ព្រំនៅលើទីតាំងភូមិសាស្ត្រ ជាក់ស្តែងនៅឡើយ។ ដោយមើលឃើញនូវផលវិបាកនៃការបាត់បង់ព្រៃឈើដូចនេះ រាជរដ្ឋាភិបាលបាន សម្រេចនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការមួយចំនួនដើម្បីថែរក្សាការពារសម្បត្តិធម្មជាតិ ព្រៃឈើដ៏មានតម្លៃនេះឱ្យបានរីកចម្រើន និង គង់វង្ស ក្នុងនោះ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តតាមរយៈ គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាថានឹងរក្សាគម្របព្រៃឈើឱ្យបាន ៦០%នៃផ្ទៃក្រឡាប្រទេស នៅឆ្នាំ២០១៥។ ទន្ទឹមនោះដែររាជរដ្ឋាភិបាលក៏បានរៀបចំនូវកម្មវិធីព្រៃឈើជាតិនេះឡើង ដើម្បីអនុវត្ត ដំណើរការការគ្រប់គ្រង ព្រៃឈើនៅកម្ពុជាឱ្យមាននិរន្តរភាព ក្នុងនោះកម្មវិធីអភិរក្ស និងអភិវឌ្ឍធនធាន ព្រៃឈើជាតិរួមចំណែកក្នុងការៈ

- កែលំអដល់ផែនការប្រើប្រាស់ដី និងធនធានព្រៃឈើជាតិ
- គាំទ្រដល់ការអនុវត្តប្រព័ន្ធគ្រប់គ្រងព្រៃឈើជាតិ
- អភិរក្សធនធានសេនេទិច និងជីវចម្រុះ
- បង្កើនប្រសិទ្ធភាព និងផលប្រយោជន៍ពីសេវាកម្មព្រៃឈើ
- ការគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិជ្ជាកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើ និងប្រសិទ្ធភាពទីផ្សារ។

### ៨.២.៦ ការវិភាគបញ្ហា

ទោះបីជាប្រទេសកម្ពុជាបច្ចុប្បន្នកំពុងមានការអភិវឌ្ឍលឿនក្តី ក៏កម្ពុជានៅមានអត្រាគម្របព្រៃឈើ ក្នុងកម្រិតមួយខ្ពស់ បើប្រៀប ធៀបទៅនឹងប្រទេសក្បែរខាងនៅក្នុងតំបន់។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្នព្រៃឈើនៅកម្ពុជា កំពុងទទួលរងនូវការបាត់បង់ជាបន្តបន្ទាប់ គួរឱ្យព្រួយបារម្ភ ដោយសារការផ្ទេរការប្រើប្រាស់ដីខុសពីមុខងារដើម ពិសេសការបំប្លែងដីព្រៃឈើឱ្យទៅជាដីសម្បទានសេដ្ឋកិច្ច និង ការឈូសឆាយហ៊ុព័ទ្ធទន្ទ្រានដីព្រៃឈើធ្វើជាកម្មសិទ្ធិដោយខុសច្បាប់។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ចាំបាច់ត្រូវពង្រឹងការងារអនុវត្តន៍ជាក់ស្តែងនាពេល បច្ចុប្បន្ន ហើយត្រូវតែប្រកាន់យកនូវ ភាពសមស្របដើម្បីថែរក្សាព្រៃឈើដែលនៅសេសសល់ និងស្តារដាំដុះបន្ថែមជាចាំបាច់។ ក្នុងបរិបទនៃការគ្រប់គ្រងព្រៃឈើ ត្រូវមានប្រព័ន្ធ និងយន្តការច្បាស់លាស់ ដើម្បីអនុវត្តសកម្មភាពនានា ដែលរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ក្នុងនោះរួមមានការ រៀបចំផែនការគ្រប់គ្រងព្រៃឈើឡើងវិញបន្ទាប់ពីព្រៃសម្បទានត្រូវបានបញ្ចប់សុពលភាព និង ការទប់ស្កាត់ឧក្រិដ្ឋកម្មព្រៃឈើដោយ ប្រសិទ្ធភាពព្រមទាំងផ្តល់នូវជម្រើសសមស្របសម្រាប់ធ្វើឱ្យ ប្រសើរឡើងដល់ប្រព័ន្ធគ្រប់គ្រងព្រៃឈើ សម្រាប់ការប្រឈមក្នុងពេល អនាគត ។

ប្រទេសកម្ពុជាមានតំបន់ការពារជាច្រើនដែលមានទំនាក់ទំនងគ្នា។ ប៉ុន្តែតំបន់ការពារមួយចំនួនពុំបានដាក់បញ្ចូលក្នុងតំបន់ព្រៃឈើ ដែលមានជីវចម្រុះខ្ពស់ទេ បែរជាផ្តោតតែទៅលើតំបន់ព្រៃផ្តល់ផលដែលមានគុណភាពខ្ពស់ ឬក៏តំបន់ព្រៃមានសក្តានុពលជីវចម្រុះ ទាបទៅវិញ។ មិនតែប៉ុណ្ណោះ តំបន់ការពារមួយចំនួនត្រូវបានអនុញ្ញាតឱ្យធ្វើការប្រែក្លាយទាំងស្រុងធ្វើឱ្យខូចទ្រង់ទ្រាយ និងរចនាសម្ព័ន្ធព្រៃឈើតែម្តង ដែលជាប្រការមិនសមស្របឡើយ ដូចជាការអនុញ្ញាតឱ្យមានដីសម្បទានសេដ្ឋកិច្ចដែលជាការបង្វែរការប្រើប្រាស់ដី ព្រៃឈើពីតំបន់ការពារទៅជាដីកសិកម្មអចិន្ត្រៃយ៍។ ស្ថានភាពបែបនេះតម្រូវឱ្យមានការពិនិត្យឡើងវិញនូវតំបន់ការពារ និងធ្វើការកែ ប្រែតំបន់នេះ ដោយផ្អែកទៅលើមុខងារបរិស្ថានការពារ និងស្ថានភាពជីវចម្រុះជាក់ស្តែងដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ការពារ ជាចាំបាច់។ ការត្រួតពិនិត្យលើពហុវិស័យនៃព្រៃឈើធម្មជាតិដែលនៅសេសសល់របស់ប្រទេសកម្ពុជានឹងទាមទារឱ្យប្រព័ន្ធនីមួយៗមាន របៀបរៀបរយ ដើម្បីរកឱ្យឃើញច្បាស់នូវអាទិភាពនានា សម្រាប់ការអភិរក្ស ហើយសំខាន់ជាងនេះទៅទៀត ប្រព័ន្ធតំបន់ការពារនៅ មានការខ្វះខាតជាច្រើននូវការការពារ ទាំងក្នុងកម្រិតប្រទេស តំបន់ និងអន្តរជាតិ។ ដើម្បីរួមចំណែកបន្ថែមទៅលើការអភិរក្សជីវចម្រុះ ព្រៃការពារមួយចំនួនត្រូវបានរដ្ឋបាលព្រៃឈើរៀបចំបង្កើតឡើងនៅក្រៅតំបន់ការពារសម្រាប់អភិរក្សជីវចម្រុះ នៅតាមតំបន់អេកូឡូស៊ី សំខាន់ៗដែលចាំបាច់ត្រូវអភិរក្សថែរក្សា ជីវចម្រុះ សេនេទិចព្រៃឈើ និងសត្វព្រៃ ដោយបង្កើតជាតំបន់គ្រាប់ពូជដែលយកទៅប្រើប្រាស់ ជាលក្ខណៈប្រពៃណី កន្លែងដែលមានប្រភេទកម្រ នឹងប្រភេទក្នុងតំបន់។ តំបន់ទាំងនេះត្រូវបានរកឃើញនូវប្រភេទសត្វព្រៃ និងរុក្ខជាតិ ជាច្រើនប្រភេទ ហើយក្នុងនោះមានប្រភេទសត្វ និងរុក្ខជាតិកំពុងរងគ្រោះ និងប្រភេទជិតផុតពូជ ដែលស្ថិតក្នុងបញ្ជីក្រហមរបស់សហព័ន្ធ អន្តរជាតិ សម្រាប់ការអភិរក្សធម្មជាតិ (IUCN)។

ថ្វីបើធនធានព្រៃឈើកំពុងដើរតួនាទីយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចសង្គមក៏ដោយ ក៏កម្ពុជាមិនទាន់ទាញយកផលប្រយោជន៍ពី ធនធាននេះ ឱ្យអស់លទ្ធភាពនៅឡើយ ដោយសារតែមានភាពខុសគ្នាខ្លាំងរវាងតម្លៃនៃការធ្វើពាណិជ្ជកម្មផល-អនុផលព្រៃឈើ ដែលត្រូវ លក់នោះនៅមានកម្រិត។ បច្ចេកវិទ្យាកែច្នៃឈើ ដើម្បីផ្តល់តម្លៃបន្ថែម និងទីផ្សារ ផលិតផលមានការអភិវឌ្ឍយឺតយ៉ាវយ៉ាងខ្លាំងបើ ប្រៀបធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់។

ដើម្បីធានា នូវនិរន្តរភាពព្រៃឈើនាពេលអនាគត ការតាក់តែងកម្មវិធីអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើនិងជីវចម្រុះនេះ គឺ ជាកត្តាសំខាន់ និងចាំបាច់ត្រូវរៀបចំចងក្រងឡើងដោយស្វែងរកដំណោះស្រាយឱ្យបានសមស្រប។ កម្មវិធីនេះនឹងផ្តោតលើការគ្រប់គ្រង ធនធានព្រៃឈើ និងជីវចម្រុះដែលផ្តល់ឱ្យនូវជំហានអភិវឌ្ឍដែលជឿជាក់បាន ដើម្បីកែលម្អអភិបាលកិច្ចក្នុងការគ្រប់គ្រងធនធានព្រៃឈើ។

### ៨.២.៧ គោលបំណងនៃកម្មវិធី

គោលបំណងរួម គឺធានាដល់ការអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើនិងជីវចម្រុះនៅកម្ពុជាប្រកបដោយនិរន្តរភាព។ ជាក់លាក់ត្រូវបានបង្កើតសម្រាប់ការងារអាទិភាព ៣ ដូចខាងក្រោម៖

*ការងារអាទិភាពទី ១ ៖ រៀបចំផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ*

- អភិវឌ្ឍ និង អនុវត្តផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ និង សារពើភ័ណ្ឌព្រៃឈើ
- ដោយផ្អែកលើសក្តានុពលនៃការអនុវត្តប្រព័ន្ធកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ នោះកម្មវិធីនេះ គ្រោងបង្កើតឱ្យមានប្រព័ន្ធគណនេយ្យកាបូនជាតិ។

*ការងារអាទិភាពទី ២ ៖ ពង្រឹងប្រព័ន្ធគ្រប់គ្រង និង អភិរក្សនៅកម្រិតឯកតាគ្រប់គ្រងព្រៃឈើ*

- អភិវឌ្ឍ និង អនុវត្តប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- អភិវឌ្ឍ និង អនុវត្តប្រព័ន្ធគ្រប់គ្រងព្រៃការពារ រួមទាំងការអភិរក្សសត្វព្រៃ ជីវចម្រុះ និងការអភិវឌ្ឍទេសចរណ៍ធម្មជាតិ
- អភិរក្សព្រៃឈើក្នុងតំបន់ និងក្រៅតំបន់នូវធនធានសេនេទិច និងការបង្កើតជាចម្ការគ្រាប់ពូជឈើសម្រាប់កម្មវិធីចម្ការព្រៃឈើដាំ
- អភិវឌ្ឍចម្ការព្រៃឈើដាំក្នុងគោលបំណងប្រើប្រាស់ច្រើនយ៉ាង។

*ការងារអាទិភាពទី ៣ ៖ គាំទ្រដល់ការអភិវឌ្ឍបច្ចេកវិជ្ជកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើ និងទីផ្សារ*

- អភិវឌ្ឍបច្ចេកវិទ្យាកែច្នៃឈើ និង សកម្មភាពនានាដែលបង្កើនតម្លៃបន្ថែម
- កែច្នៃផលិតផលព្រៃឈើ និង ការផ្សព្វផ្សាយរកទីផ្សារ។

### ៨.២.៨. សូចនាករ

*ការងារអាទិភាពទី ១ ៖ រៀបចំផែនការសកម្មភាពអភិវឌ្ឍពឈើ*

- ផែនការគ្រប់គ្រងសកម្មភាពអភិវឌ្ឍព្រៃឈើ នឹងត្រូវបានអភិវឌ្ឍដោយឈរលើមូលដ្ឋាននៃការពិគ្រោះយោបល់
- ការអនុវត្តផែនការសកម្មភាពអភិវឌ្ឍព្រៃឈើត្រូវស្របគ្នាជាមួយនឹងគោលបំណងរបស់កម្មវិធីព្រៃឈើជាតិ
- សូចនាករដែលពាក់ព័ន្ធវិស័យបរិស្ថាន សេដ្ឋកិច្ច នយោបាយ និងសង្គម ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនឹង ត្រូវបានអភិវឌ្ឍ

- វិធីសាស្ត្រសម្រាប់ធ្វើសារពើភ័ណ្ឌធនធានព្រៃឈើត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីប្រមូលទិន្នន័យ និងរាយការណ៍ រយៈពេល ៥ ឆ្នាំម្តង
- ទិន្នន័យពីសារពើភ័ណ្ឌធនធនព្រៃឈើ ត្រូវបានចងក្រង និង ធ្វើបច្ចុប្បន្នភាព
- ការគ្រប់គ្រងព្រៃឈើយកឥណទានកាបូន
- ផ្ទៃក្រឡាព្រៃការពារនឹងត្រូវបង្កើនពី ១.៥ លានហិកតា ទៅ ៣ លានហិកតា
- ចម្ការព្រៃឈើដាំដែលដាំដោយប្រភេទឈើមានតម្លៃខ្ពស់នឹងត្រូវបង្កើនឱ្យដល់ ៥០០០០០ ហិកតា
- យ៉ាងតិច ៥០% នៃឈើកែច្នៃសម្រាប់នាំចេញនឹងត្រូវមានវិញ្ញាបនបត្របញ្ជាក់។
- *ការងារអាទិភាពទី ២ ៖ ពង្រឹងប្រព័ន្ធគ្រប់គ្រង និង អភិរក្សនៅកម្រិតឯកតាគ្រប់គ្រងព្រៃឈើ* ការគ្រប់គ្រង តាមបច្ចេកទេសរុក្ខវប្បកម្មនឹងត្រូវអនុវត្តលើផ្ទៃដីព្រៃឈើ ចំនួន ២,៤ លានហិកតា
- ពង្រឹង និងកែលម្អវិធីសាស្ត្រគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពសម្រាប់ព្រៃផ្តល់ផល។ ព្រៃផ្តល់ផលត្រូវគ្រប់គ្រងស្របតាមកត្តាអេកូឡូស៊ី សង្គម និងសេដ្ឋកិច្ច
- ការបញ្ចូលប្រព័ន្ធគ្រប់គ្រងសម្រាប់ព្រៃការពារ រួមទាំងទេសចរណ៍ធម្មជាតិ គឺត្រូវបានអភិវឌ្ឍជាគំរូនិងបញ្ចូលទៅក្នុងការ គ្រប់គ្រងប្រកបដោយតម្លាភាព
- តំបន់អភិរក្សជីវចម្រុះ និងតំបន់ផលិតកម្មគ្រាប់ពូជ ត្រូវបានអភិវឌ្ឍសម្រាប់គ្រប់ប្រភេទរុក្ខជាតិ និងសត្វព្រៃអាទិភាពទាំងអស់
- ប្រព័ន្ធគ្រប់គ្រងចម្ការព្រៃឈើដាំសម្រាប់ប្រើប្រាស់ក្នុងគោលបំណងច្រើនយ៉ាងត្រូវពង្រីក និងធ្វើជាគំរូ

*ការងារអាទិភាពទី ៣ ៖ គាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើនិងប្រសិទ្ធភាពទីផ្សារ*

- ជំរុញ និង លើកទឹកចិត្តឱ្យមានការកែច្នៃ ផ្តល់តម្លៃបន្ថែមដល់ផលិតផលព្រៃឈើ និងពង្រីកទីផ្សារ
- គាំទ្រ និងជំរុញដល់ការបង្កើនការផលិតនិងកែច្នៃផលិតផលព្រៃឈើឱ្យមានភាពសម្បូរបែបផ្សព្វផ្សាយលក់នៅលើទីផ្សារក្នុង និងក្រៅប្រទេស
- កែលម្អបច្ចេកទេសកែច្នៃឈើ និងអនុផលព្រៃឈើ និងអភិវឌ្ឍបច្ចេកវិទ្យាឈើ
- ប្រព័ន្ធតាមដានត្រួតពិនិត្យវិញ្ញាបនបត្រព្រៃឈើ។

### ៨.២.៩ ការផ្សៀងផ្ទាត់

*ការងារអាទិភាពទី ១ ៖ រៀបចំផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ*

- ផែនការសកម្មភាពអភិវឌ្ឍព្រៃឈើត្រូវបានចងក្រងរួច,ដែលជាលទ្ធផលនៃការធ្វើសមាហរណកម្មផែនការសកម្មភាពគ្រប់គ្រងព្រៃឈើរបស់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន
- មានរបាយការណ៍ស្តីពីការធ្វើសិក្ខាសាលាពិគ្រោះយោបល់ និងការស្តាប់មតិជាសាធារណៈ
- ទិន្នន័យសារពើភណ្ឌព្រៃឈើជាតិ ត្រូវបានអភិវឌ្ឍ និងថែរក្សា និងបច្ចុប្បន្នភាព
- មានរបាយការណ៍ស្តីពីការអនុវត្តផែនការសកម្មភាពអភិវឌ្ឍព្រៃឈើប្រែចាំឆ្នាំ។

*ការងារអាទិភាពទី ២ ៖ ពង្រឹងប្រព័ន្ធគ្រប់គ្រង និងអភិរក្សនៅកម្រិតឯកតាគ្រប់គ្រងព្រៃឈើ*

- ផែនការគ្រប់គ្រងព្រៃផ្តល់ផល និងព្រៃអភិរក្ស
- មានគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងព្រៃឈើសម្រាប់តំបន់ព្រៃផ្តល់ផល
- មានទិន្នន័យព្រៃឈើសម្រាប់ព្រៃលំផលនិងព្រៃអភិរក្ស
- គោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងព្រៃការពារត្រូវបានរៀបចំរួច និង ដាក់ឱ្យអនុវត្ត មានទិន្នន័យ និង របាយការណ៍ស្តីពីភាពជឿនលឿននៃការអភិរក្សជីវចម្រុះ និងប្រភពពូជ
- មានទិន្នន័យ និងរបាយការណ៍ស្តីពីភាពជឿនលឿននៃការអភិវឌ្ឍចម្ការព្រៃឈើដាំក្នុងគោលបំណងប្រើប្រាស់ច្រើនយ៉ាង។

*ការងារអាទិភាពទី ៣ ៖ គាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើ និងទីផ្សារ* ឯកសារស្តីពីអំពីឧស្សាហកម្មកែច្នៃឈើ

- ឯកសារគតិយុត្តនានា ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ បង្កើនគុណភាពផលិតផលព្រៃឈើ និងទីផ្សារ
- មានរបាយការណ៍ ឯកសារ និង ស្ថិតិ អំពីផលិតផលថ្មី និងការកែលំអបច្ចេកទេសកែច្នៃ
- ផលិតផលកែច្នៃមានភាពសម្បូរបែបកើនឡើង និងផ្សព្វផ្សាយនៅលើទីផ្សារជាតិ និងអន្តរជាតិ
- របាយការណ៍រីកចំរើនពីបច្ចេកទេសកែច្នៃអនុផលព្រៃឈើរបស់សហគមន៍ព្រៃឈើ
- របាយការណ៍ស្តីពីការអភិវឌ្ឍវិញ្ញាបនបត្រព្រៃឈើ។

## ៨.២.១០ ហានិភ័យនៃកម្មវិធី

- កង្វះខាត ដំណើរការដែលសមស្រប និង តម្លាភាព ដើម្បីកំណត់ព្រៃផ្តល់ផល ព្រៃអភិរក្ស និងចម្ការព្រៃឈើដាំ
- ឥទ្ធិពលអាចកំនៃការរីករាលដាលដីសម្បទានសេដ្ឋកិច្ចទៅលើដីព្រៃឈើ ស្ថិតនៅពីក្រោយការខិតខំ ប្រឹងប្រែងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

- កង្វះកិច្ចសហការល្អពីភាគីពាក់ព័ន្ធដែលមានទំនាស់ផលប្រយោជន៍ជាមួយវិស័យព្រៃឈើ
- កង្វះធនធានរបស់ផ្នែកផ្សេងៗដើម្បីបង្កើតឱ្យមានបរិយាកាសសមស្របសម្រាប់ជំរុញការផលិត ការកែច្នៃបង្កើនតម្លៃបន្ថែមទៅលើផលិតផលព្រៃឈើ និងការពង្រីកទីផ្សារ
- ខ្វះការទទួល និងចែកចាយព័ត៌មាន ការទំនាក់ទំនង និងការពិភាក្សារវាងភាគីអ្នកពាក់ព័ន្ធនានា។

## ៨.២.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី

ប្រសិទ្ធភាពនៃការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព អាស្រ័យទៅលើការចាប់ផ្តើមសកម្មភាពគ្រប់គ្រងទាំងឡាយទៅតាមលក្ខខណ្ឌ និងស្ថានភាពសេដ្ឋកិច្ចសង្គម។ ដំណើរការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលធ្វើផែនការសកម្មភាពគ្រប់គ្រង ព្រៃឈើមានសារៈសំខាន់ណាស់ក្នុងការស្វែងរកនូវមតិយោបល់ដើម្បីធានាដល់ការគ្រប់គ្រងព្រៃឈើជាតិឱ្យមាននិរន្តរភាព។

គំរូថ្មីៗជាច្រើននៃការគ្រប់គ្រងព្រៃឈើនាពេលបច្ចុប្បន្ន បានចាប់ផ្តើមសាកល្បងធ្វើនៅក្នុងប្រទេសកម្ពុជា។ គោលការណ៍ និងគំរូទាំងនេះរួមមានជាអាទិ៍ គំរូព្រៃសម្បទាន ព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម បទពិសោធន៍នៃការដាំព្រៃឈើជាចម្ការ តំបន់ព្រៃការពារ តំបន់ការពារ និងតំបន់អភិរក្សសត្វព្រៃនិងទេសចរណ៍ធម្មជាតិ សហគមន៍ព្រៃឈើ ការគ្រប់គ្រងព្រៃឈើយកឥណទានកាបូន។ល។ កំពុងស្ថិតក្នុងដំណើរការសាកល្បងអនុវត្តដកស្រង់នូវបទពិសោធន៍ដើម្បីពង្រីកបន្ត។

កម្មវិធីអភិរក្ស និង អភិវឌ្ឍធនធានព្រៃឈើជាតិមានយុទ្ធសាស្ត្រអនុវត្តដូចតទៅ ៖

- អភិវឌ្ឍលក្ខណៈវិនិច្ឆ័យ និង សូចនាករសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព
- បង្កើតយន្តការសម្រាប់តាមដានការអនុវត្តផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ
- បង្កើតប្រព័ន្ធគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពនៅតាមកម្រិតឯកតាគ្រប់គ្រងព្រៃឈើ
- អភិវឌ្ឍយុទ្ធសាស្ត្រ និង ចាត់វិធានការដើម្បីគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងបង្កើនគុណភាពផលិតផលព្រៃឈើ និងប្រសិទ្ធភាព ទីផ្សារ
- បង្កើនសមត្ថភាពដើម្បីពង្រឹងបច្ចេកទេសគ្រប់គ្រងតាមបែបរុក្ខវប្បកម្មឱ្យមាននិរន្តរភាព
- បង្កើនចម្ការព្រៃដាំប្រភេទឈើដែលមានតម្លៃ ដើម្បីធានាការអភិវឌ្ឍដោយនិរន្តរភាពនៃសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ី។

## ៨.២.១២ អនុកម្មវិធីទី ១ ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ

### ៨.២.១២.១ សេចក្តីអធិប្បាយ

ដំណើរការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាសកម្មភាពគន្លឹះដែលត្រូវអនុវត្តដោយរដ្ឋបាលព្រៃឈើនិងដៃគូអភិវឌ្ឍន៍ នានា ផ្អែកទៅតាមកម្មវិធីព្រៃឈើជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យព្រៃឈើ។

### ៨.២.១២.២ មធ្យោបាយសម្រាប់អនុវត្ត

#### ៨.២.១២.២.១ ការអភិវឌ្ឍ និងថែរក្សាទិន្នន័យសារពើភណ្ឌព្រៃឈើ

សារពើភណ្ឌព្រៃឈើនឹងត្រូវបានអនុវត្តនៅលើទីតាំងជាក់ស្តែងដើម្បីប្រមូល នឹងធ្វើបច្ចុប្បន្នភាពទិន្នន័យព្រមទាំង វិភាគរកបរិមាណកាបូនស្តុកក្នុងព្រៃឈើ។ កម្មវិធីនេះ នឹងរៀបចំនូវវិធីសាស្ត្រធ្វើសារពើភណ្ឌព្រៃឈើ ដើម្បីប្រមូលទិន្នន័យ ពីទីតាំង ជាក់ស្តែងដែលអាចជឿជាក់បានសម្រាប់វិភាគ និងប្រើប្រាស់ក្នុងការរៀបចំផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ។ កិច្ចដំណើរការនេះ ត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំគម្រោងសារពើភណ្ឌព្រៃឈើ សម្រាប់អនុវត្តនៅគ្រប់ចំណាត់ថ្នាក់ព្រៃឈើ
- អភិវឌ្ឍគោលការណ៍ណែនាំស្តីពីការធ្វើសារពើភណ្ឌព្រៃឈើថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាពដើម្បីវាយតម្លៃគុណភាព និងបរិមាណធនធានព្រៃឈើ (រួមមានការធ្វើសារពើភណ្ឌរុក្ខជាតិឱសថ ដំណុះគ្រាប់ឈើ ដំណុះ កូនឈើតូចៗ ដំណុះកូនឈើ ឈើ សន្និធិជីវម៉ាស អនុផលព្រៃឈើ កាបូនស្តុក សេវាកម្មបរិស្ថាន ប្រភេទជិត ផុតពូជ)។ល។
- កំណត់នូវសមត្ថភាព និងបទពិសោធន៍ជំនាញក្នុងការធ្វើសារពើភណ្ឌធនធានព្រៃឈើ (គ្រប់ប្រភេទ នឹងលំដាប់ ថ្នាក់ទំហំរុក្ខជាតិ)
- បញ្ចូល និងវិភាគទិន្នន័យសារពើភណ្ឌព្រៃឈើជាតិ និងចងក្រងរក្សាទុក និងប្រើប្រាស់មូលដ្ឋានទិន្នន័យ

សារពើភណ្ឌធនធានព្រៃឈើថ្នាក់ជាតិ គឺជាមធ្យោបាយចម្បងរបស់រដ្ឋបាលព្រៃឈើ ដើម្បីតាមដានគោលដៅអភិវឌ្ឍ សហស្សវត្សកម្ពុជាក្នុងការថែរក្សាគំរបព្រៃឈើឱ្យបាន ៦០% នៃផ្ទៃក្រឡាប្រទេស ព្រមទាំងផ្តល់ទិន្នន័យកាបូនស្តុក។

#### ៨.២.១២.២.២ ក្រុមការងារសម្រាប់ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ

ការបង្កើតផែនការសកម្មភាពគ្រប់គ្រងព្រៃឈើគឺស្ថិតនៅក្នុងផ្នែកមួយនៃកំណែទម្រង់របស់រាជរដ្ឋាភិបាលដែលបាន នឹងកំពុងអនុវត្ត ដើម្បីធានាថា ការគ្រប់គ្រង និងការធ្វើផែនការព្រៃឈើជាតិ គឺមានតម្លាភាព។ ការងារនេះតម្រូវឱ្យបង្កើត ក្រុមការងារសម្របសម្រួលសម្រាប់ការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ។

ក្រុមរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើនៅរដ្ឋបាលព្រៃឈើនឹងកំណត់ថវិកាសម្រាប់ការរៀបចំផែនការសកម្មភាព គ្រប់គ្រងព្រៃឈើ។ ក្រុមការងារផែនការសកម្មភាពគ្រប់គ្រងព្រៃឈើតម្រូវឲ្យមានការចូលរួមពីភាគីអ្នកពាក់ព័ន្ធ ដើម្បីជួយ គាំទ្រផែនការនេះឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា។ ក្រុមការងារផែនការសកម្មភាពគ្រប់គ្រងព្រៃឈើត្រូវអនុវត្តសកម្មភាពដូចតទៅ ៖

- ប្រមូល ពិនិត្យឡើងវិញ និងធ្វើសំយោគនូវរាល់ព័ត៌មានដែលទាក់ទង ដើម្បីគាំទ្រដល់ការរៀបចំផែនការ
- សកម្មភាពអភិវឌ្ឍព្រៃឈើ (រួមទាំងសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានៈ និងសិទ្ធិ របស់សហគមន៍ជនជាតិភាគតិច)
- រៀបចំឯកសារពាក់ព័ន្ធសម្រាប់ការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ តាមដានពីភាពរីកចំរើននៃដំណើរការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ ដូចជា ការរៀបចំទម្រង់
- មាតិកា និង សេចក្តីព្រាងនៃផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ រៀបចំសិក្ខាសាលា ពិគ្រោះយោបល់ និងផ្សព្វផ្សាយផែនការនេះជាមួយភាគីអ្នកពាក់ព័ន្ធតាមការចាំបាច់។

ការទទួលមតិកែលម្អពីសំណាក់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើគឺមានសារៈប្រយោជន៍ចំពោះវិស័យពាក់ព័ន្ធផ្សេងៗទៀត។

ទម្រង់នៃផែនការនេះគួរមានបមាណីមួយច្បាស់លាស់ ដោយមានការបញ្ជាក់ច្បាស់ពីចក្ខុវិស័យ គោលដៅ និង លទ្ធផលរំពឹងទុកដែលមានសារៈសំខាន់ចំពោះការគាំទ្រដល់កម្មវិធីព្រៃឈើជាតិក្នុងរយៈកាល ២០ឆ្នាំ។ ការរៀបចំផែនការ សកម្មភាពគ្រប់គ្រងព្រៃឈើ គួរពិនិត្យទៅលើច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់នានា នឹងទៅអនាគត អាចធ្វើការពិនិត្យ កែសម្រួលតាមការចាំបាច់។

ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ គឺជាផែនការបច្ចេកទេសមួយ មានសារៈសំខាន់ក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិដែលគាំទ្រដល់ផែនការអភិវឌ្ឍន៍ជាតិ។

### ៨.២.១២.២.៣ ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ

ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាសមាហរណកម្មផែនការសកម្មភាពគ្រប់គ្រងព្រៃឈើរបស់អង្គភាពរដ្ឋបាល ព្រៃឈើមូលដ្ឋាន ដែលអនុលោមទៅតាមកម្មវិធីព្រៃឈើជាតិ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពី ព្រៃឈើ។ ក្រុមរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើនៃរដ្ឋបាលព្រៃឈើ មានគំនិតផ្តួចផ្តើមអនុវត្តបច្ចេកទេសក្នុងការ គ្រប់គ្រងព្រៃឈើជាតិ។ ការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ ត្រូវអនុវត្តសកម្មភាពដូចតទៅៈ

- តាមដានពីភាពរីកចំរើនក្នុងដំណើរការរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើនៅអង្គភាពរដ្ឋបាលព្រៃឈើ មូលដ្ឋាន
- ប្រមូលផែនការសកម្មភាពគ្រប់គ្រងព្រៃឈើរបស់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីពិនិត្យឡើងវិញ និង ធ្វើសំយោគនូវរាល់ព័ត៌មានដែលទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើ
- បូកសរុបរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើទូទាំងប្រទេស។

ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើត្រូវរៀបចំសកម្មភាពលម្អិតដែលស្របតាមចក្ខុវិស័យអភិវឌ្ឍព្រៃឈើនៃផែនការ ៥ ឆ្នាំនៃអនុកម្មវិធី និងកម្មវិធីព្រៃឈើជាតិ ដោយមានបញ្ជាក់ពីគោលបំណងសកម្មភាព លទ្ធផលរំពឹងទុក សូចនាករ មធ្យោបាយផ្ទៀងផ្ទាត់ និងមានកាលកំណត់ច្បាស់លាស់។ លើសពីនេះទៀតផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ ជាឯកសារមានភាពទន់ភ្លន់អាចធ្វើការកែសម្រួល ឬធ្វើវិសោធនកម្មបានស្របតាមការវិវត្ត និងស្ថានភាពរីកចម្រើនរបស់ ប្រទេសជាតិ។ ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ គឺជាផែនការបច្ចេកទេសលម្អិតសកម្មភាពការងារដើម្បីសម្រេចគោលដៅអភិវឌ្ឍដែលបានចែងក្នុងកម្មវិធីព្រៃឈើជាតិ។

### ៨.២.១២.៣ លទ្ធផលរំពឹងទុក

ព័ត៌មានស្តីពីធនធាននិងស្ថានភាពព្រៃឈើត្រូវបានអភិវឌ្ឍ និងចងក្រង និងផ្សព្វផ្សាយ។ ទិន្នន័យសារពើភណ្ឌព្រៃឈើ មានប្រយោជន៍ចំពោះការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងព្រៃឈើ និងជាមូលដ្ឋានបច្ចេកទេសសម្រាប់រៀបចំផែនការសកម្មភាព អភិវឌ្ឍព្រៃឈើ។

រៀបចំផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ តាមមាត់នៃកម្មវិធីព្រៃឈើជាតិ ដែលជាមូលដ្ឋានគ្រឹះមួយច្បាស់លាស់ សម្រាប់ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងធានាឱ្យមានតុល្យភាពរវាងតម្រូវការសេដ្ឋកិច្ច សង្គម ទំនៀមទំលាប់ប្រពៃណី និរន្តរភាពផលិតផលពាណិជ្ជកម្មព្រៃឈើ ការអភិរក្សធនធានព្រៃឈើ និងផ្តល់សេវាកម្មនានា។

## ៨.២.១៣ អនុកម្មវិធីទី២ ការអភិវឌ្ឍ និងអនុវត្តបច្ចេកទេសគ្រប់គ្រងពផ្តល់ផល

### ៨.២.១៣.១ សេចក្តីអធិប្បាយ

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍កម្ពុជាត្រូវបានចាត់ថ្នាក់ជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន។ ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមាន៣ប្រភេទ គឺ ព្រៃផ្តល់ផល ដែលត្រូវរក្សាទុកសម្រាប់ផលិតកម្មផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃការពារ ត្រូវបានរក្សាទុកជាចម្បងដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាននិងធនធានធម្មជាតិ។ក្រៅពីនោះ គឺជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ។ ប្រព័ន្ធចម្បងៗដែលបានអនុវត្តលើការគ្រប់គ្រងព្រៃផ្តល់ផលគឺ ព្រៃសហគមន៍

ក្រោមកិច្ច ព្រមព្រៀង ព្រៃសម្បទាន ព្រៃគុបប្រចាំឆ្នាំ ព្រៃឈើត្រូវស្តារឡើងវិញ និងព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចម្ការព្រៃឈើ ដាំ។ ការគ្រប់គ្រងតាមបច្ចេកទេសរុក្ខវប្បកម្មគឺជាការងារលំបាក ហើយទើបតែបានធ្វើការស្រាវជ្រាវសាកល្បងដោយពុំទាន់បាន យកមកអនុវត្តនៅឡើយ ប៉ុន្តែការអនុវត្តបច្ចេកទេសបែបនេះមានសក្តានុពលខ្ពស់ដល់ការបង្កើនគុណភាពព្រៃឈើធម្មជាតិ។ សកម្មភាព ព្រៃសម្បទានត្រូវបានផ្អាកចាប់តាំងពីឆ្នាំ ២០០១ រហូតមកដល់បច្ចុប្បន្ន ដោយការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាតម្រូវឱ្យក្រុមហ៊ុន រៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពស្របតាមនិយាមអន្តរជាតិ។ ដោយព្រៃសម្បទានត្រូវបានផ្អាកសកម្មភាព រាជរដ្ឋាភិបាលបានសម្រេចឱ្យរៀបចំព្រៃគុបដេញថ្លៃ ដើម្បីផ្គត់ផ្គង់តម្រូវការឈើប្រើប្រាស់ក្នុងស្រុក។ តាមមាគ៌ានទស្សនៈ និងបេសកកម្ម របស់កម្មវិធីព្រៃឈើជាតិ ជាការចាំបាច់ត្រូវអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផលតាមជម្រើសផ្សេងៗទៀតដែលផ្តល់សារៈសំខាន់លើការងារបង្កើនការងារប្រជាពលរដ្ឋជនបទ ជានាសុវត្ថិភាព សេវាកម្មបរិស្ថាន និងទីជម្រាល និងការស្តុកការបាន។

### ៨.២.១៣.២ មធ្យោបាយសម្រាប់អនុវត្ត

#### ៨.២.១៣.២.១ ការអភិវឌ្ឍការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅតំបន់ទេសភាព (Landscape)

ការពិនិត្យឡើងវិញថ្នាក់ជាតិអំពីប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផលនឹងត្រូវបានផ្តួចផ្តើម និងជំនួសនូវប្រព័ន្ធថ្មីជាបន្តបន្ទាប់ ដោយមានតម្លាភាព និងទទួលខុសត្រូវជាសាធារណៈ ព្រមទាំងត្រូវបានអភិវឌ្ឍន៍ក្នុងតំបន់ទេសភាព។ ការពិនិត្យឡើងវិញ និងការកែលំអត្រូវធានាឱ្យបាននូវៈ

- ផែនការព្រៃឈើ ត្រូវបានរៀបចំនៅក្នុងតំបន់ទេសភាពដលជាមូលដ្ឋានធានាការទទួលខុសត្រូវដោយសាធារណៈ តាមរយៈយន្តការតំណាងឱ្យថ្នាក់ខេត្ត ស្រុក ឃុំ ព្រមទាំងស្ថាប័នពាក់ព័ន្ធ។ ការងារនេះនឹងត្រូវធ្វើសកម្មភាព ដោយផ្សារភ្ជាប់រវាង " ក " ការធ្វើផែនការក្នុងតំបន់ទេសភាពជាមួយនឹង ការសម្រេចតាមដានត្រួតពិនិត្យនិងការអនុវត្ត
- វចនាសម្ព័ន្ធរបស់រដ្ឋបាលព្រៃឈើ នឹងត្រូវធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងការងារធ្វើផែនការ និងការអនុវត្ត ជាមួយនឹង ការងារធ្វើសេចក្តីសម្រេច តាមដាន ត្រួតពិនិត្យ ) (regulatory fucntion) ដូចមានចែងនៅក្នុង ចំណុច ក " និង " ខ " ខាងលើ
- យន្តការទទួលខុសត្រូវជាសាធារណៈនឹងត្រូវបានរៀបចំ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

#### ៨.២.១៣.២.២ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ព្រៃសម្បទានក្រោយបញ្ចប់កិច្ចព្រមព្រៀង

ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព្រៃផ្តល់ផលប្រកបដោយនិរន្តរភាព គឺជាអាទិភាពដើម្បីត្រួតពិនិត្យ និងបញ្ជាក់ ឱ្យច្បាស់នូវអនាគតនៃព្រៃសម្បទានដែលនៅសេសសល់ទាំងអស់។ រដ្ឋបាលព្រៃឈើនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយ ភាគីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យប្រកបដោយតម្លាភាព និងបញ្ជាក់ឱ្យច្បាស់នូវអនាគតនៃព្រៃសម្បទាន។ ដំណើរការនេះរដ្ឋបាលព្រៃឈើនឹងធ្វើឱ្យបានទូលំទូលាយនូវជម្រើសប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាម មាគ៌ានៃទស្សនៈ និងបេសកកម្មរបស់កម្មវិធីព្រៃឈើជាតិ។ ឧទាហរណ៍ ព្រៃឈើពាណិជ្ជកម្ម សហគមន៍ព្រៃឈើការកាត់ បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់នឹងការរេចរឹលព្រៃឈើ (REDD) ព្រៃការពារ និង តំបន់អភិរក្ស។ ការត្រួតពិនិត្យទាំងនេះនឹងអភិវឌ្ឍនូវយុទ្ធសាស្ត្រ និងប្រព័ន្ធគ្រប់គ្រងព្រៃឈើដោយជានាថា៖

- ព្រៃផ្តល់ផល និងព្រៃការពារក្នុងព្រៃសម្បទាន គឺត្រូវបានកំណត់ទៅតាមតំបន់ទេសភាពដើម្បីកាត់បន្ថយឥទ្ធិពលផលប៉ះពាល់អវិជ្ជមានពីសកម្មភាពមិនមាននិរន្តរភាពលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- ព្រៃឈើដែលមានមុខងារខ្ពស់ផ្នែកជីវចម្រុះក្នុងតំបន់ព្រៃសម្បទាន ត្រូវរៀបចំកំណត់ជា តំបន់អភិរក្ស
- ព្រៃសម្បទានមួយចំនួនដែលអាចចាប់ដំណើរការឡើងវិញ នឹងត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវតាមមុខងារព្រៃឈើ ដូចជា អេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម ព្រមទាំងមានការបញ្ជាក់វិញ្ញាបនបត
- ព្រៃសម្បទានដែលត្រូវបានលុប និងមិនមានសកម្មភាព ត្រូវការពាររហូតដល់មានដំណើរការត្រួតពិនិត្យឡើងវិញ។

### ៨.២.១៣.២.៣ ការអភិវឌ្ឍសមត្ថភាពបច្ចេកទេសរុក្ខវប្បកម្ម និងជម្រើសគំរូនៃការងារគ្រប់គ្រងពឈើ បកបដោយនិរន្តរភាព

ជំហានដំបូងគឺត្រូវអភិវឌ្ឍការយល់ដឹង និង សមត្ថភាពការងារបច្ចេកទេសរុក្ខវប្បកម្មចំពោះមន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានភារកិច្ចអនុវត្តការងារគ្រប់គ្រងព្រៃឈើនៅលើទីតាំងជាក់ស្តែង។

ភាពទូលំទូលាយនៃជម្រើសក្នុងប្រព័ន្ធការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព នឹង ត្រូវបានអភិវឌ្ឍដោយ បញ្ចូលនូវការបែងចែកផលប្រយោជន៍ជាមួយសហគមន៍មូលដ្ឋានកិច្ចការពារ និងផ្តល់សេវាកម្មបរិស្ថាន ការពារទីជម្រាល និងការស្រូបយកកាបូនពីបរិយាកាស។ ជម្រើសប្រព័ន្ធនេះ នឹងត្រូវធ្វើការអនុវត្តសាកល្បង ហើយធ្វើការតាមដាននូវលទ្ធផល នេះដើម្បីភ្ជាប់ទៅនឹងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការផ្តល់វិញ្ញាបនបត្រគ្រប់គ្រងព្រៃឈើនៅកម្ពុជា។ ការអនុវត្តល្អនៃជម្រើស ប្រព័ន្ធនេះ នឹងត្រូវបានទទួលយក និងពង្រីកការអនុវត្តដោយបញ្ចូលទៅក្នុងផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ។

### ៨.២.១៣.២.៤ ការគ្រប់គ្រងព្រៃគុបដេញថ្លៃប្រចាំឆ្នាំ

ដើម្បីអនុវត្តការគ្រប់គ្រងព្រៃគុបដេញថ្លៃឱ្យមានប្រសិទ្ធភាព តម្លាភាព និងការពិនិត្យតាមដាន ចាំបាច់ត្រូវត្រួតពិនិត្យអភិវឌ្ឍ និងអនុវត្តឱ្យជានាបាននូវកត្តាគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព គឺប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម។ក្នុងការកំណត់ទីតាំងព្រៃគុបដេញថ្លៃ ត្រូវរៀបចំយន្តការដំណើរការពិគ្រោះយោបល់ និងមានតម្លាភាព។

### ៨.២.១៣.២.៥ ការកំណត់ និងគ្រប់គ្រងតំបន់ព្រៃឈើត្រូវស្តារឡើងវិញ

វិធីសាស្ត្រសម្រាប់កំណត់តំបន់ដែលត្រូវស្តារព្រៃឈើឡើងវិញ ចាំបាច់ពិនិត្យអង្កេតលើផ្ទៃដីព្រៃរេចរឹល ព្រៃក្រោយពេលប្រមូលផលព្រៃឈើ និងព្រៃឈើដែលមានប្រភេទឈើមានតម្លៃពាណិជ្ជកម្មតិចតួច។ តំបន់ព្រៃរេចរឹលនោះត្រូវបាន កំណត់ និងរៀបចំស្តារឡើងវិញតាមរយៈការរៀបចំ និងអនុវត្តសកម្មភាពដាំដុះព្រៃឈើឡើងវិញ និងការអនុវត្តរុក្ខវប្បកម្ម។ ការ អនុវត្តប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការរៀបចំផែនការសកម្មភាពការងារដាំបង្កើនធនធនព្រៃឈើ ការអនុវត្តរុក្ខវប្បកម្ម និងការថែទាំឈើដាំដើម្បីជានាឱ្យមានលក្ខណៈអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម ព្រមទាំងបង្កើនការស្រូបយកកាបូនពីបរិយាកាស។

### ៨.២.១៣.៣ លទ្ធផលរំពឹងទុក

- មានបរិយាកាសសមស្របមួយក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបានបង្កើតឡើងនៅក្នុងព្រៃផ្តល់ផល តាមរយៈ នៃការត្រួតពិនិត្យឡើងវិញពីអនាគតរបស់ព្រៃសម្បទានដែលនៅសេសសល់ និងតម្លាភាពនៃប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយ និរន្តរភាពសម្រាប់តំបន់ទេសភាព ត្រូវបានអនុវត្តក្នុងតំបន់អតីតព្រៃសម្បទាន
- ជម្រើសនៃប្រព័ន្ធការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដ៏ទូលំទូលាយសម្រាប់ព្រៃផ្តល់ផល ត្រូវបានឆ្លើយតបទៅនឹង កត្តា - សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ជម្រើសនៃប្រព័ន្ធនេះនឹងត្រូវបានទទួលយកទៅសាកល្បង និងពង្រីក ព្រមទាំងធ្វើឱ្យ មានប្រសិទ្ធភាពសម្រាប់គ្រប់គ្រងព្រៃផ្តល់ផល អនុលោមតាមផែនការគ្រប់គ្រងថ្នាក់ជាតិ និងមូលដ្ឋាន ដែលនឹងត្រូវអភិវឌ្ឍ
- ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលមានធនធានឈើប្រភេទពាណិជ្ជកម្មតិចតួច និងមានការរេចរឹលត្រូវបាន
  ផ្តល់ថវិកាសម្រាប់ដាំដុះព្រៃឈើស្តារឡើងវិញប្រចាំឆ្នាំប្រមាណពី ២.០០០ - ៤.០០០ ហិកតា។

### ៨.២.១៤ អនុកម្មវិធីទី ៣ ពង្រឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

#### ៨.២.១៤.១ សេចក្តីអធិប្បាយ

ការអនុវត្តការងារដោយមិនមានការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច ការអនុវត្តក្របខ័ណ្ឌច្បាប់ តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ គឺមិនអាចជំនះបាននូវឧបសគ្គដែលរាំងស្ទះការងារ។ ប្រសិទ្ធភាពនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃមានសារៈសំខាន់ ក្នុងប្រព័ន្ធគ្រប់គ្រង ។ កំឡុងឆ្នាំ ២០០៧-២០០៨ រដ្ឋបាលព្រៃឈើបានអភិវឌ្ឍទម្រង់បែបបទសម្រាប់បំពេញទិន្នន័យតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពអនុលោមទៅតាមក្របខណ្ឌដែលបានអនុម័តដោយអាស៊ាន និង អង្គការ ITTO នាឆ្នាំ២០០៥។ ទម្រង់នេះគឺជាឯកសារបច្ចេកទេសមួយដ៏មានប្រសិទ្ធភាពសម្រាប់វាយតម្លៃ ត្រួតពិនិត្យ និងរៀបចំ ផែនការសកម្មភាពអភិវឌ្ឍ និងប្រើប្រាស់ធនធានព្រៃឈើ។ អនុកម្មវិធីនេះសំដៅទៅការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោ យនិរន្តរភាព។

#### ៨.២.១៤.២ មធ្យោបាយសម្រាប់ការអនុវត្ត

- កំណត់នូវលក្ខណៈវិនិច្ឆ័យនិងសូចនាករសម្រាប់តាមដានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅកម្ពុជា បង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីបង្កើតសូចនាករដើម្បីប៉ាន់ប្រមាណកត្តាបរិស្ថានសង្គម នយោបាយ និងសេដ្ឋកិច្ច ក្នុងការ គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងកម្រិតថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិក្នុងប្រទេសកម្ពុជា។
- រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ជំរុញឱ្យមានការបង្កើតការតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ តាមរយៈការបង្កើតនិងថែរក្សាមូលដ្ឋានទិន្នន័យ ដើម្បីធ្វើការវិភាគទិន្នន័យព្រៃឈើជាតិមានដូចជា ទិន្នន័យអំពី សេដ្ឋកិច្ច សង្គម បរិស្ថាន និងសារពើភណ្ឌ។ សកម្មភាព ទាំងនោះរួមមាន
  - បំពេញទិន្នន័យកម្រិតជាតិ និងឯកតាគ្រប់គ្រងក្នុងទម្រង់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាព
  - ពិនិត្យ វាយតម្លៃ និងរបាយការណ៍ ស្តីពីការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពប្រចាំឆ្នាំ
  - បង្កើតមូលដ្ឋានទិន្នន័យការគ្រប់គ្រងព្រៃឈើដើម្បីវាយតម្លៃការធ្វើរបាយការណ៍និងការរៀបចំផែនការសកម្មភាពអភិវឌ្ឍព្រៃឈើឱ្យមានប្រសិទ្ធភាពនៅកម្រិតជាតិ និងឯកតាគ្រប់គ្រង

- សហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដែលអាចជួយរដ្ឋបាលព្រៃឈើក្នុងការតាមដាន និងវាយតម្លៃពី កត្តាសង្គម នយោបាយ និងសេដ្ឋកិច្ចនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព នៅកម្រិតជាតិ និងឯកតាគ្រប់គ្រង ដើម្បីអនុវត្តការងារប្រកប ដោយចីរភាព។

ទម្រង់បែបបទតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ជាផ្នែកមួយ ដ៏សំខាន់សម្រាប់អភិវឌ្ឍផែនការសកម្មភាពព្រៃឈើ។ លើសពីនេះ ទិន្នន័យតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពី ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពអាចដាក់បញ្ចូលការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៨.២.១៤.៣ លទ្ធផលរំពឹងទុក

- មានទិន្នន័យតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីកត្តាបរិស្ថាន សង្គម នយោបាយ និងសេដ្ឋកិច្ច សំដៅធ្វើឱ្យ មានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងបានបន្ស៊ីទៅនឹងផែនការអភិវឌ្ឍជាតិក្នុងការប្រើប្រាស់ធនធានព្រៃឈើ
- និរន្តរភាពនៃការប្រើប្រាស់ធនធានព្រៃឈើត្រូវបានធ្វើឱ្យប្រសើរឡើង និងរួមចំណែកទៅក្នុងគោលដៅជាតិកាត់បន្ថយភាពក្រីក្រ ការការពារបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ៨.២.១៥ អនុកម្មវិធីទី ៤ ការអភិរក្សធនធានជីវចម្រុះ និងសត្វព្រៃ

### ៨.២.១៥.១ សេចក្តីអធិប្បាយ

ឈើ តំបន់ដីសើម និងវាលស្មៅនៅក្នុងប្រទេសកម្ពុជាជាទីជម្រកដ៏មានសារៈសំខាន់សម្រាប់ធនធានសត្វព្រៃ និងជីវចម្រុះ រួមមាន សត្វស្លាប ថនិកសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ សប្បិសត្វ សត្វឥតឆ្អឹងកង និងរុក្ខជាតិគ្រប់ប្រភេទ។ ក្រសួង កសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានធ្វើចំណាត់ថ្នាក់សត្វព្រៃជាបីប្រភេទគឺ ក្រុមប្រភេទជិតផុតពូជ ក្រុមប្រភេទមានដោយកម្រ និងក្រុមប្រភេទមានដោយបង្គួរ។ ក្រុមប្រភេទជិតផុតពូជរួមមាន ថនិកសត្វ ចំនួន ១០ប្រភេទ សត្វស្លាបចំនួន ៦ ប្រភេទ រីឯក្រុម ប្រភេទមានដោយកម្រមាន ថនិកសត្វចំនួន ២៧ ប្រភេទ សត្វស្លាប ចំនួន ៤៥ ប្រភេទ និងឧរង្គសត្វចំនួន ៥ ប្រភេទ និងប្រភេទរុក្ខជាតិ កំពុងរងគ្រោះថ្នាក់ជាច្រើនប្រភេទទៀត។ ប្រភេទសត្វព្រៃនៅកម្ពុជាចំនួន ២៣ប្រភេទត្រូវបានចុះក្នុងបញ្ជីក្រហម IUCN/ ( IUCN Red List ) ជាប្រភេទកំពុងរងគ្រោះថ្នាក់ជាសាកល។ ធនធានសត្វព្រៃនិងជីវចម្រុះមានសារៈសំខាន់ណាស់សម្រាប់ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន ព្រមទាំងទ្រទ្រង់ដល់ការរស់នៅរបស់សហគមន៍មូលដ្ឋាន។ ធនធានសត្វព្រៃ និងជីវ ចម្រុះក៏ផ្តល់នូវធនធានហ្សែនមានតម្លៃសម្រាប់អភិវឌ្ឍវិស័យកសិកម្ម ឱសថ ការស្រាវជ្រាវវិទ្យាសាស្ត្រ អប់រំផ្សព្វផ្សាយ ទេសចរណ៍ ធម្មជាតិ និងជួយថែរក្សាតុល្យភាពប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រួម

ទាំងសម្បត្តិវប្បធម៌ធម្មជាតិ។ បច្ចុប្បន្ននេះ សត្វព្រៃ និងជីវចម្រុះ កំពុងទទួលរងការគំរាមកំហែងដោយសារការបាត់បង់ទីជម្រក ការបរបាញ់ហួសកម្រិត ការបំពុល ការកកើតជម្ងឺរាតត្បាត និងកត្តាផ្សេងទៀត។

យុទ្ធសាស្ត្រចតុកោណជំហានទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញទិសដៅ និងគោលនយោបាយច្បាស់លាស់ សម្រាប់អភិរក្សធនធានព្រៃឈើ សត្វព្រៃ និងជីវចម្រុះ សំដៅឈានឆ្ពោះទៅការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយ ចីរភាព។ ការដាក់ចេញទិសដៅ និងគោលនយោបាយទាំងនេះ សំដៅបំពេញនូវកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាដែលជា សមាជិកអនុសញ្ញាជីវចម្រុះ (CHI) អនុសញ្ញាសាយតេស (TTES) ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធដទៃទៀត ជាពិសេស ពង្រឹងការអភិរក្សធនធានព្រៃឈើ សត្វព្រៃ និងជីវចម្រុះ ស្របតាមច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធផ្សេងទៀត។ ក្នុងករណីចាំបាច់ត្រូវមានកិច្ចសហការសម្របសម្រួលនៅក្នុងដែនយុត្តាធិការរបស់រដ្ឋបាលជលផល ក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

ការអភិរក្សទីជម្រក ប្រភេទរុក្ខជាតិ និងសត្វព្រៃដែលទទួលរងការគំរាមកំហែង អាចទទួលជោគជ័យបានតាមរយៈការ បង្កើតតំបន់ព្រៃការពារ តំបន់អភិរក្សផ្សេងៗទៀត និងយន្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ វិធានការទប់ស្កាត់ និងបង្ក្រាប បទល្មើសការជួញដូរប្រភេទសត្វព្រៃ និងរុក្ខជាតិ ត្រូវធ្វើឡើងតាមរយៈពង្រឹងការអនុវត្តច្បាប់នៅក្នុងឬក្បែរតំបន់ព្រៃការពារ និង ទីកន្លែងផ្សេងទៀតទូទាំងប្រទេស។ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការសង្គ្រោះសត្វព្រៃ ដែលចាប់រឹបអូសបានពីបទល្មើសជួញដូរសត្វព្រៃ ហើយជាទីកន្លែងដែលផ្តល់នូវការថែរក្សា ព្យាបាល វិបុលកម្ម អប់រំផ្សព្វផ្សាយ សាធារណៈ ស្រាវជ្រាវវិទ្យាសាស្ត្រ និងស្តារលទ្ធភាពលក្ខណៈជីវសាស្ត្រសត្វព្រៃទាំងនោះឡើងវិញ។

សកម្មភាពគ្រប់គ្រងតំបន់ព្រៃការពារប្រកបដោយប្រសិទ្ធភាព មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សត្វព្រៃនិងជីវចម្រុះ ប៉ុណ្ណោះទេ ថែមទាំងបានផ្តល់ឱកាស ផ្តល់ការងារ សេវាកម្មព្រៃឈើ ប្រាក់ចំណូលតាមរយៈការលក់ផល-អនុផលព្រៃឈើ ដែលជាសកម្មភាពរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ ការគ្រប់គ្រងតំបន់ដោយប្រសិទ្ធភាព ជាសកម្មភាពមួយដែលបានមកពីការ ខិតខំប្រឹងប្រែងរួមគ្នាជាមួយភាគីពាក់ព័ន្ធ និងយន្តការគ្រប់គ្រងមួយច្បាស់លាស់។

### ៨.២.១៥.២ មធ្យោបាយសម្រាប់ការអនុវត្ត

#### ៨.២.១៥.២.១ កំណត់សកម្មភាពជាអាទិភាពរបស់ជាតិសម្រាប់ការអភិរក្ស

រដ្ឋបាលព្រៃឈើនឹងធ្វើការសម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ អាជ្ញាធរ និងសហគមន៍មូលដ្ឋាន ព្រម ទាំងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីពិនិត្យនិងវាយតម្លៃដំណើរការគ្រប់គ្រងធនធានព្រៃឈើ ទីជម្រក និងសត្វព្រៃ ក្នុងប្រទេស ឡើងវិញតាមលក្ខណៈវិទ្យាសាស្ត្រ។ លទ្ធផលនៃការវាយតម្លៃនឹងកំណត់បាននូវសកម្មភាពជាអាទិភាពរបស់ជាតិសម្រាប់ ការងារអភិរក្សនៅក្នុងនិងក្រៅតំបន់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ហើយត្រូវធានាថាតំបន់ដែលមានសក្តានុពលជីវចម្រុះខ្ពស់ ត្រូវចាត់ទុកជាតំបន់អាទិភាពសម្រាប់បង្កើតជាតំបន់ព្រៃការពារ និងអភិរក្សដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។

រដ្ឋបាលព្រៃឈើជាអង្គភាពនាំមុខក្នុងការរៀបចំផែនការសកម្មភាពជាតិសម្រាប់អភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើ សត្វព្រៃ និងជីវចម្រុះ ដោយមានការចូលរួមពីស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធផ្សេងទៀត។

រដ្ឋបាលព្រៃឈើនឹងកំណត់អាទិភាពសំខាន់ៗសម្រាប់បញ្ចូលការការពារជីវចម្រុះទៅក្នុងការគ្រប់គ្រងតំបន់ដ៏ទ ទៀតនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រួមមានព្រៃគុប ព្រៃសហគមន៍ និងការប្រើប្រាស់ដីព្រៃឈើផ្សេងទៀត ដើម្បីធានា ដល់ការការពារទីជម្រកសំខាន់ៗ និងរក្សាតំបន់ច្រករបៀងសម្រាប់ការអភិរក្ស។

រដ្ឋបាលព្រៃឈើធានាថា កម្មវិធីផ្តួចផ្តើមថ្មីៗដូចជាការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ (REDHD) នឹងធានាដល់ការការពារ អភិរក្សសត្វព្រៃ និងជីវចម្រុះ។

រដ្ឋបាលព្រៃឈើនឹងផ្តល់មតិយោបល់ផ្លូវច្បាប់ និងបច្ចេកទេសដល់ក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីធានាថា ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារសត្វព្រៃនិងជីវចម្រុះក្នុងគម្រោងអភិវឌ្ឍន៍នានា ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍកសិ-ឧស្សាហកម្មជាដើម នៅក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍។

### ៨.២.១៥.២.២ ការគ្រប់គ្រងពការពារ និង តំបន់អភិរក្សឱ្យមានប្រសិទ្ធភាព

រដ្ឋបាលព្រៃឈើនឹងរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារ និងតំបន់អភិរក្ស និងកំណត់ការទទួលខុសត្រូវ ដោយ ផ្អែកលើគោលការណ៍ច្បាប់ បច្ចេកទេស និងវិទ្យាសាស្ត្រ ដោយរួមបញ្ចូលទាំងយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែប្រួលអាកាស ធាតុនៃប្រព័ន្ធមជ្ឈដ្ឋាននៃព្រៃឈើ។ រដ្ឋបាលព្រៃឈើនឹងកំណត់តំបន់មានសក្តានុពល និងបង្កើតតំបន់អភិរក្សបន្ថែមទៀត ព្រមទាំងកំណត់អនុតំបន់នៅក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សនីមួយៗដោយផ្អែកតាមលក្ខណៈជីវសាស្ត្រ មជ្ឈដ្ឋាន ព្រៃឈើ និង

សត្វព្រៃ។ ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត គួររួមបញ្ចូលនូវសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និង ទេសចរណ៍ធម្មជាតិក្នុងលក្ខខណ្ឌសមស្រប។ សកម្មភាពការពារ អភិរក្ស និងការរៀបចំផែនការសកម្មភាពឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានយន្តការនិរន្តរភាពហិរញ្ញវត្ថុ។

សកម្មភាពជាអាទិភាពសម្រាប់គ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត រួមមាន ការបោះបង្គោលព្រំតំបន់ ព្រៃការពារ ការពង្រឹងការអនុវត្តច្បាប់ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍសហគមន៍ ដែលកត្តាទាំងអស់នេះត្រូវមានការ ចូលរួមពីសហគមន៍មូលដ្ឋានផងដែរ។ ការគ្រប់គ្រងសត្វព្រៃរួមមាន ការគ្រប់គ្រងប្រភេទសត្វ និងទីជម្រករបស់វា។ ការ ចូលរួមនឹងការលើកស្ទួយជីវភាពប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន នឹងរួមចំណែកកាត់បន្ថយការពឹងផ្អែកទៅលើធនធាន ធម្មជាតិ។ ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត មានតួនាទីសំខាន់ និង លើកទឹកចិត្តក្នុងសកម្មភាពការពារ និងអភិរក្សធនធានព្រៃឈើនិងសត្វព្រៃ និងអាចបង្កើនសមត្ថភាពសហគមន៍ក្នុងការ ចូលរួមអប់រំផ្សព្វផ្សាយបន្ត ក្នុងទិសដៅជំរុញការងារការពារ និងអភិរក្សធនធានធម្មជាតិឱ្យកាន់តែមានប្រសិទ្ធភាព។ ការ គ្រប់គ្រងតំបន់ព្រៃការពារ តំបន់អភិរក្ស និងតំបន់អាទិភាពសំខាន់ៗផ្សេងទៀត គួរគិតគួរលើការរៀបចំបង្កើតកម្មវិធីដោះស្រាយ ជម្លោះរវាងមនុស្សនិងសត្វព្រៃ។ រាល់ផែនការទាំងអស់ ត្រូវធ្វើការផ្សព្វផ្សាយដល់អាជ្ញាធរ សហគមន៍មូលដ្ឋាន ព្រមទាំង ភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាឱ្យមានការចូលរួម និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៨.២.១៥.២.៣ ការរៀបចំ និងការគ្រប់គ្រងតំបន់លំហែកំសាន្ត និងអេកូ-ទេសចរណ៍

ការរៀបចំតំបន់លំហែកំសាន្ត និងអេកូ-ទេសចរណ៍ត្រូវគិតគូរការអភិវឌ្ឍពីតម្លៃធម្មជាតិដែលអាចទាក់ទាញទេសចរណ៍ និងគិតគូរពីការគ្រប់គ្រងធនធានធម្មជាតិ សកម្មភាពប្រតិបត្តិ និងរកទីផ្សារ ព្រមទាំងសកម្មភាពមគ្គុទ្ទេសក៏ សេវាកម្មអេកូ ទេសចរណ៍ ព្រមទាំងវប្បធម៌ប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងការគ្រប់គ្រងទេសចរណ៍ ដោយរៀបចំលិខិតបទដ្ឋាន ដើម្បីធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង យន្តការបែងចែកផលប្រយោជន៍ប្រកបដោយតម្លាភាព និងសមធម៌។

អេកូ-ទេសចរណ៍ និងកីឡាប្រមាញ់សម្រាប់កំសាន្ត ត្រូវរៀបចំជាលក្ខណៈសាកល្បងដោយធានានូវនិរន្តរភាព ធនធានសត្វពដោយផ្អែកតាមលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រ។ កីឡាប្រមាញ់សម្រាប់កំសាន្ត ត្រូវមានលិខិតបទដ្ឋាន ច្បាស់លាស់ ដោយត្រូវសិក្សាពីជំរឿនសត្វព្រៃ ការកំណត់រដូវបរបាញ់ ការកំណត់កូតាដកហូត ការកំណត់ប្រភេទសត្វព្រៃ ដែលអាចអនុញ្ញាតឱ្យប្រមាញ់ ការកំណត់តម្លៃស្ទួយសារ ថ្លៃអភិរក្សសត្វព្រៃ តម្លៃសំណាក វិធីសាស្ត្រ និងឧបករណ៍ សម្រាប់ប្រមាញ់តាមបមាណីជាតិ (ស្តង់ដារបទដ្ឋាន) ឬអន្តរជាតិ។

### ៨.២.១៥.២.៤ ការទប់ស្កាត់ការជួញដូរសត្វព្រៃខុសច្បាប់ និងការគ្រប់គ្រងសត្វព្រៃដែលរឹបអូសបាន

- ពង្រឹងការអនុវត្តច្បាប់សំដៅលុបបំបាត់ការជួញដូរសត្វព្រៃគ្រប់ប្រភេទនៅទូទាំងប្រទេស និង បន្តរៀបចំយុទ្ធសាស្ត្រថ្មីៗសម្រាប់ទប់ស្កាត់ការជួញដូរសត្វព្រៃ។ មន្ត្រីចុះពង្រឹងការអនុវត្តច្បាប់ នឹងធ្វើការក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង តំបន់ប្រើប្រាស់ដីផ្សេងទៀត ព្រមទាំងការទប់ស្កាត់ការជួញដូរសត្វព្រៃឆ្លងដែន។
- គាំទ្រកម្មវិធីសដោះសារលទ្ធភាព ការបង្កាត់ពូជ និងដោះលែងសតវៃពទៅក្នុងដែនព្រៃធម្មជាតិ។ កម្មវិធីនេះផ្តោតទៅលើការសាងហេដ្ឋានរចនាសម្ព័ន្ធរូបវ័ន្ត(ការសាងសងអគារនិងទ្រុងសត្វ)សមស្របសម្រាប់រឹបអូសសត្វព្រៃ មានរបួស សត្វព្រៃនៅតូចគ្មានមេ-បា ព្រមទាំងការបង្កាត់ពូប្រភេទរងគ្រោះថ្នាក់ជិតផុតពូជ និងកម្មវិធីស្តារលទ្ធភាពលក្ខណៈជីវសាស្ត្រសត្វព្រៃ។

### ៨.២.១៥.២.៥ ការស្រាវជ្រាវ និងការគ្រប់គ្រងទិន្នន័យ

ការស្រាវជ្រាវនិងសកម្មភាពអប់រំផ្សព្វផ្សាយផ្តោតទៅលើកម្មវត្ថុដែលជួយបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង។ កម្មវិធីទាំងនេះរួមមានការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានភូមិសាស្ត្រការស្រាវជ្រាវជីវសាស្ត្រសត្វព្រៃការស្រាវជ្រាវធនធានធម្មជាតិ និងជីវចម្រុះ ការសិក្សាអំពីសហគមន៍ការគ្រប់គ្រងតំបន់លំហែកំសាន្ត អេកូ-ទេសចរណ៍ ការអភិរក្សប្រភេទសត្វជាអាទិភាព ការធ្វើពាណិជ្ជកម្មសត្វព្រៃ ការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អភិរក្សជីវចម្រុះសំខាន់ៗ និងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ទៅលើប្រភេទសត្វព្រៃ ទីជម្រក ជីវភាព និងការគំរាមកំហែងផ្សេងៗ ទៀត។ រដ្ឋបាលព្រៃឈើគ្រប់គ្រងទិន្នន័យព្រៃឈើ និងសត្វព្រៃ ហើយលទ្ធផលនៃការស្រាវជ្រាវត្រូវបោះពុម្ពផ្សាយព្រមទាំង ផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធ។ ប្រព័ន្ធទិន្នន័យនៅតាមតំបន់ព្រៃការពារ និងតំបន់អភិរក្សនានាត្រូវមានបមាណឹឯតភាព រួមមួយ ដើម្បីជំរុញការគ្រប់គ្រង ប្រមូល និងចែករំលែកទិន្នន័យព្រៃឈើ និងសត្វព្រៃប្រកបដោយប្រសិទ្ធភាព។

### ៨.២.១៥.២.៦ ការអប់រំផ្សព្វផ្សាយ

ការអប់រំផ្សព្វផ្សាយដល់សាធារណជនស្តីពីលិខិតបទដ្ឋានផ្លូវច្បាប់ទាក់ទងទៅនឹងវិស័យព្រៃឈើ និងសត្វព្រៃ និង បទពិសោធន៍អភិរក្ស គឺជាសកម្មភាពចាំបាច់សំដៅបង្កើនការយល់ដឹង និងជម្រុញឱ្យមានការចូលរួមក្នុងសកម្មភាពការពារ និងអភិរក្ស ព្រមទាំងការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យពីកន្លែងមួយទៅកន្លែងមួយ។

### ៨.២.១៥.៣ លទ្ធផលរំពឹងទុក

- មានយន្តការផ្តល់ហិរញ្ញវត្ថុយូរអង្វែងដល់ការគ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត

- ការអភិរក្សប្រភេទសត្វព្រៃ និងជីវចម្រុះសំខាន់ៗបានល្អប្រសើរឡើង
- កំណត់បាននូវការទទួលខុសត្រូវច្បាស់លាស់សម្រាប់ការគ្រប់គ្រងព្រៃការពារ ការទប់ស្កាត់បទល្មើស បរបាញ់ និងជួញដូរ សត្វព្រៃនៅទូទាំងប្រទេស
- មានគោលការណ៍ណែនាំច្បាស់លាស់ស្តីពីការរៀបចំទេសចរណ៍ធម្មជាតិ
- កាត់បន្ថយការជួញដូរសត្វព្រៃដោយខុសច្បាប់ទូទាំងប្រទេសកម្ពុជា។
- មានចំណេះដឹងគ្រប់គ្រាន់សម្រាប់គ្រប់គ្រងប្រភេទសត្វព្រៃសំខាន់ៗ និងទីជម្រករបស់វា និងតាមដានអំពីផលប៉ះពាល់ ដោយសារការប្រែប្រួលអាកាសធាតុ។
- មានការយល់ដឹងជាអតិបរមាអំពីការងារអភិរក្ស និងឥរិយាបទវិជ្ជមានចំពោះការអភិរក្ស ព្រមទាំងការផ្លាស់ប្តូរឥរិយាបទដែលផ្តល់ផលប្រយោជន៍ចំពោះការអភិរក្ស។
- មានប្រព័ន្ធគ្រប់គ្រងទិន្នន័យច្បាស់លាស់ឯកភាពរួមទូទាំងប្រទេស។

## ៨.២.១៦ អនុកម្មវិធីទី ៥ ការអភិរក្ស និង អភិវឌ្ឍធនធានសេនេទិច និង ប្រភពពូជ

### ៨.២.១៦.១ សេចក្តីអធិប្បាយ

មានប្រភេទឈើក្នុងស្រុកជាច្រើននៅកម្ពុជា ដែលត្រូវបានចុះក្នុងបញ្ជីជាប្រភេទឈើងាយរងគ្រោះឬរងគ្រោះ ដោយ យោងលើការវិនិច្ឆ័យនៃបញ្ជីក្រហមរបស់សហគមន៍អន្តរជាតិសម្រាប់ការអភិរក្សធនធានធម្មជាតិ (Inrernational Lhnion for Conservation and Nature) ហើយមានប្រភេទឈើមួយចំនួនទៀតត្រូវបានទទួលការគម្រាមគំហែងនឹងអាចឈានដល់ការបាត់បង់។ ការចុះថយនៃធនធានសេនេទិក និងគុណភាពគ្រាប់ពូជបានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សកម្មភាពអភិវឌ្ឍការដាំឈើ បំរើឱ្យវិស័យពាណិជ្ជកម្ម (ប្រភេទឈើសំណង់ ឈើឧស្សាហកម្ម) ជីវភាពរស់នៅ (ប្រភេទឈើសម្រាប់កសិ-ទុក្ខកម្ម ច្បារដំណាំ ក្បែរផ្ទះ ឈើចាមពល។ល។ បរិស្ថាន (ប្រភេទឈើសម្រាប់ការពារទីជម្រាល ការគ្រប់គ្រងការហូរច្រោះ យន្តការអភិវឌ្ឍស្អាត )។

ដើម្បីឆ្លើយតបនូវសកម្មភាពទាំងនេះ រាជរដ្ឋាភិបាលបានផ្តល់សច្ចានុម័តលើអនុសញ្ញាស្តីពី ជីវចម្រុះ (Canvention on Biodiversity): នៅឆ្នាំ១៩៩៥ ក្នុងគោលបំណងដើម្បីបំពេញនូវយុទ្ធសាស្ត្រជីវចម្រុះថ្នាក់ជាតិ និងផែនការសកម្មភាពដែល បានស្វែងរកការអភិវឌ្ឍ និងការអនុវត្តនៃកម្មវិធីសម្រាប់ធ្វើឱ្យប្រសើរឡើងដល់ប្រភេទរុក្ខជាតិ ដែលបានរងគ្រោះ ក្នុងនោះរួមមាន ផែនការអភិរក្សក្នុងតំបន់ និងផែនការអភិរក្សក្រៅតំបន់។ ការអភិរក្សធនធានសេនេទិកព្រៃឈើនឹងចូលរួមវិភាគទានដល់ប្រទេស

កម្ពុជានូវកាតព្វកិច្ចឆ្ពោះទៅរកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិសម្រាប់ ការប្រែប្រួលអាកាសធាតុ ( United Nations Famework Convention for Climate Change- UNFCCCនិងពិធីសាក្យូតូ ( Kyoto Protocol )

កម្ពុជាធ្លាប់បានរៀបចំយុទ្ធសាស្ត្រអភិរក្សហ្សែនព្រៃឈើ ក្នុងនោះបានផ្តល់នូវគម្រោងការសម្រាប់ការគ្រប់គ្រងប្រភេទរុក្ខជាតិ ដែលបានកំណត់អត្តសញ្ញាណនៅក្នុងបណ្តាញការងារនៃតំបន់អភិរក្សហ្សែនព្រៃឈើដែលបានជ្រើសរើស។

កម្មវត្ថុនៃអនុកម្មវិធីនេះគឺដើម្បីអភិរក្សធនធានសេនទិកព្រៃឈើ តាមរយៈការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

### ៨.២.១៦.២ មធ្យោបាយសម្រាប់អនុវត្ត

- បង្កើតបណ្តាញការងារគ្រាប់ពូជជាតិ និងផ្នែកឯកជនសម្រាប់ការអភិរក្សហ្សែនព្រៃឈើឱ្យមាននិរន្តរភាព
- បង្កើតផែនការដាំឈើបន្សំ រវាងប្រភេទឈើ នឹងប្រភពកំណើត ទៅនឹងការប្រែប្រួលអាកាសធាតុ
- សិក្សាពីប្រភេទ និងគុណភាពឈើដាំ ព្រមទាំងធ្វើការសាកល្បងពូជឈើ
- កំណត់ និងបង្កើតតំបន់អភិរក្សហ្សែនព្រៃឈើក្រៅតំបន់នឹងក្នុងតំបន់ ហើយដាក់បញ្ចូលការតាមដាន និងការគ្រប់គ្រងទៅក្នុងផែនការគ្រប់គ្រងព្រៃឈើថ្នាក់មូលដ្ឋាន
- រៀបចំប្រភពគ្រាប់ពូជ និងសំភារៈហ្សែនចាំបាច់ដែលមាន ដើម្បីសម្របទៅតាមការប្រែប្រួលអាកាសធាតុ បង្កើតឡូត៍បង្ហាញអំពីការបង្កើនគុណភាពដើមឈើ តាមរយៈការប្រើប្រាស់គ្រាប់ពូជឈើ ចេញពីតំបន់ អភិរក្ស
- ផ្តួចផ្តើមឱ្យមានការបង្កើនគុណភាពឈើដាំ តាមរយៈការប្រើប្រាស់ពូជឈើបង្កាត់
- បង្កើនការផ្សព្វផ្សាយ ស្តីពីសារៈសំខាន់នៃការប្រើប្រាស់គ្រាប់ពូជដែលមានគុណភាព
- អភិវឌ្ឍទីផ្សារគ្រាប់ពូជ ដើម្បីធ្វើឱ្យប្រសើរឡើង និងលើកកម្ពស់ពីការរកចំណូលនៅមូលដ្ឋានដែលបានមកពីប្រភពគ្រាប់ពូជឈើ
- ផ្តល់ការបណ្តុះបណ្តាល និងបង្កើនការយល់ដឹងដល់មន្ត្រីរដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធនានាស្តីពីធនធាន សេនេទឹកព្រៃឈើ និងការផ្គូផ្គងទីតាំងដាំដុះ ជាមួយការប្រែប្រួលអាកាសធាតុ
- ជំរុញចលនាអភិរក្ស និងថែរក្សាគ្រាប់ពូជឈើ

- ស្វែងរកដៃគូសម្រាប់គាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងធនធានសេនេទិក
- លើកទឹកចិត្តសហគមន៍មូលដ្ឋានឱ្យបានទូលំទូលាយ ក្នុងការកំណត់ប្រភេទគ្រាប់ពូជសំខាន់ៗ អភិវឌ្ឍបច្ចេកទេសបេះប្រមូលគ្រាប់ពូជ និងមធ្យោបាយថែរក្សាទុកដាក់គ្រាប់ពូជឱ្យបានសមស្រប
- ង្កើតមន្ទីរពិសោធន៍គ្រាប់ពូជឈើ។

### ៨.២.១៦.៣ លទ្ធផលរំពឹងទុក

- ការធ្វើពាណិជ្ជកម្មនៃប្រភេទឈើដាំតាមរយៈគោលការណ៍ ការអភិរក្សសម្រាប់ប្រើប្រាស់ និងបង្កើនការដាំដុះ និងស្តារ ព្រៃឈើឡើងវិញ
- ប្រភេទរុក្ខជាតិកម្រ ឬ ប្រភេទឈើមានតម្លៃ ត្រូវបានអភិរក្សប្រកបដោយប្រសិទ្ធភាពនៅក្នុងបណ្តាការងារព្រៃអភិរក្ស
- ប្រភពគ្រាប់ពូជឈើមានគុណភាពត្រូវបានបង្កើតឡើងសម្រាប់ការស្តារព្រៃឈើឡើងវិញ និងសកម្មភាពដាំឈើ
- យន្តការនៃការបែងចែកផលប្រយោជន៍ ដែលទទួលបានពីការគ្រប់គ្រងនិងការក់ព្រាប់ពូជឈើដែលមាននៅក្នុងសហគមន៍ មូលដ្ឋាន
- កំណត់បានប្រភេទឈើសម្រាប់ការបន្សាំទៅនឹងធាតុអាកាស
- ធ្វើឱ្យកើតមានឡើងនូវគ្រាប់ពូជឈើដែលមានគុណភាព ហើយបានបន្សាំទៅនឹងធាតុអាកាស
- មានចំណេះដឹងអំពីទំនាក់ទំនងរវាងប្រភេទ ប្រភពកំណើត និងអាកាសធាតុ
- ការយល់ដឹងនៃតួនាទីសេដ្ឋកិច្ច និងអេកូឡូស៊ីប្រភេទឈើក្នុងស្រុកត្រូវបានលើកកម្ពស់
- ភាពកាន់តែប្រសើរឡើងនៃចម្ការឈើដាំ
- ពូជឈើអាទិភាពត្រូវធ្វើការពិសោធ ការរក្សាសន្និធិគ្រាប់ពូជ ភាពធន់ និងអត្រាដំណុះ។ល។

### ៨.២.១៧ អនុកម្មវិធីទី ៦ ការដាំដុះដើមឈើ និង ការអភិវឌ្ឍចម្ការព្រៃឈើដាំ

### ៨.២.១៧.១ សេចក្តីអធិប្បាយ

កម្មវិធីអភិវឌ្ឍថ្នាក់ជាតិនៅកម្ពុជាបានទទួលស្គាល់យ៉ាងច្បាស់ពីសារៈសំខាន់នៃធនធានព្រៃឈើចំពោះការចិញ្ចឹមជីវិតនៅតាម ជនបទ និងប្រជាជនមូលដ្ឋានដែលអាចចូលទៅប្រមូលផលលើធនធានទាំងនោះ។ រដ្ឋបាលព្រៃឈើបានប្រឹងប្រែងបង្កើតនូវ បរិយាកាសសមស្របមួយ ដោយបានផ្តោតសំខាន់លើការអភិវឌ្ឍចម្ការឈើដាំប្រើប្រាស់បានច្រើនយ៉ាង ដែលមានសក្តានុពលក្នុង ការផ្គត់ផ្គង់ផលិតផល

ឈើសម្រាប់ការប្រើប្រាស់ក្នុងស្រុក បង្កើនប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន និងធ្វើឱ្យប្រសើរឡើង នូវបរិស្ថាន តាមរយៈការការពារទីជំរាល និងគ្រប់គ្រងការហូរច្រោះ។ វាមានសារៈសំខាន់ណាស់ ដូចជា ចម្កាតឈើទាំងនេះត្រូវបាន អភិវឌ្ឍដោយយកចិត្តទុកដាក់ និងបានគិតគូរលើប្រភេទមួយចំនួនសម្រាប់ការប្រើប្រាស់ច្រើនយ៉ាងក្នុងរយៈពេលវែងនិងខ្លី ដូចជា ការ ដាំប្រភេទឈើទាល គឺ ស្តៅ កៅស៊ូ ប្រភេទប្រេងខ្យល់អាកាស្យា និងអង្កាដី។ល។ ម្យ៉ាងទៀតការអភិវឌ្ឍចម្ការ ឈើដាំនេះត្រូវដើរទន្ទឹមនឹងតម្រូវការទីផ្សារទាំងបច្ចុប្បន្ននិងអនាគត។ ក្នុងករណីនេះ វាក៏មានសារៈសំខាន់ផងដែរ គឺយកចិត្តទុកដាក់ទៅលើពូជឈើដែលធ្លាប់ស្គាល់ និងធ្លាប់បានប្រើប្រាស់ដោយសហគមន៍មូលដ្ឋាន។ ការស្គាល់ ឬយល់ច្បាស់នៃការអភិវឌ្ឍ ចម្ការឈើដាំប្រើប្រាស់យ៉ាងច្រើនយ៉ាងនេះ នឹងអាចកាត់បន្ថយឥរិយាបថអវិជ្ជមានរបស់សហគមន៍មូលដ្ឋាន ហើយសហគមន៍ មូលដ្ឋានចូលរួមយ៉ាងខ្ជាប់ខ្ជួនក្នុងការអនុវត្តជាទ្រង់ទ្រាយធំ។ សកម្មភាពនេះអាចជំរុញឱ្យវិស័យឯកជនមានការចាប់អារម្មណ៍ចំពោះ ការដាំឈើដោយសហគមន៍នៅលើដីទំនេររបស់ពួកគាត់ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ អនុកម្មវិធីនេះត្រូវតែបញ្ចូលសកម្មភាព ផ្សព្វផ្សាយ បណ្តុះបណ្តាល និងការអប់រំឱ្យបានទូលំទូលាយសម្រាប់សហគមន៍មូលដ្ឋាន ដែលក្នុងនោះ រួមមានចំណេះដឹងបច្ចេកទេស នៃវិធីសាស្ត្រដាំឈើ ការថែទាំកូនឈើក្នុងថ្នាល និងការគ្រប់គ្រងចម្ការឈើដាំឱ្យមាននិរន្តរភាព។

### ៨.២.១៧.២ មធ្យោបាយសម្រាប់អនុវត្ត

រដ្ឋបាលព្រៃឈើនឹងបង្កើតចម្ការឈើដាំប្រើប្រាស់បានច្រើនយ៉ាងនៅគ្រប់តំបន់សមស្របទាំងអស់ ក្នុងភាពដៃគូជាមួយ សហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិនិងដៃគូផ្សេងទៀតដែលមានចំណាប់អារម្មណ៍ក្នុងវិស័យព្រៃឈើ។ រដ្ឋបាលព្រៃឈើនឹង ៖

- បន្តកិច្ចខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិស្ថាន និងគោលនយោបាយថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍចម្ការឈើដាំប្រើប្រាស់ បានច្រើនយ៉ាង តាមរយៈសកម្មភាពដែលបាននិងកំពុងតែធ្វើការកំណែទម្រង់ មានដូចជា ការបោះបង្គោលព្រំដីព្រៃឈើ និង ការធានាសិទ្ធិរបស់ប្រជាជនមូលដ្ឋាន និងភាគីពាក់ព័ន្ធក្នុងការដាំ ប្រមូលផល រកទីផ្សារផលិតផលព្រៃឈើ និងសេវាកម្ម
- កំណត់អត្តសញ្ញាណប្រភេទឈើសមស្របសម្រាប់ចម្ការឈើ ប្រើប្រាស់បានច្រើនយ៉ាង
- រៀបចំថ្នាលបណ្តុះតាមបែបទំនើបវិទ្យាសាស្ត្រ ដើម្បីធានាបានការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាពចំពោះប្រភេទកូនឈើដែលមានគុណភាពល្អសម្រាប់សកម្មភាពចម្ការឈើដាំ ប្រើប្រាស់បានច្រើនយ៉ាង
- កំណត់ទីតាំងចម្ការលើដាំប្រើប្រាស់បានច្រើនយ៉ាង ហើយចម្ការឈើនេះត្រូវបានគាំទ្រដោយផែនការគ្រប់គ្រងថ្នាក់ជាតិ និងគាំទ្រក្នុងរង្វង់ផែនការគ្រប់គ្រងព្រៃឈើថ្នាក់មូលដ្ឋាន

- បង្កើតចម្ការឈើបង្ហាញប្រើប្រាស់ច្រើនយ៉ាង នៅតាមខណ្ឌរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន
- អភិវឌ្ឍសេវាកម្មផ្សព្វផ្សាយ និងដឹកនាំយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដើម្បីគាំទ្រសកម្មភាពដាំរ ទាំងបច្ចេកទេស និង ផ្លូវច្បាប់
- អភិវឌ្ឍន៍នូវកិច្ចសហការលើការបង្កើតចម្ការឈើ រវាងសហគមន៍ ផ្នែកឯកជន និងរដ្ឋបាលព្រៃឈើតាមរយៈ ការអភិវឌ្ឍនៃគំរូ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រង និងបែងចែកផលប្រយោជន៍។ គំរូកិច្ចព្រមព្រៀងនេះត្រូវបានធ្វើយុត្តិកម្មនៅក្នុងអនុក្រឹត្យស្តីពី វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- សាកល្បងពីប្រសិទ្ធភាពនៃការ ដុះលូតលាស់របស់ដើមឈើនៅក្នុងចម្ការស្រែរបស់កសិករ ដែលជាវិធីសាស្ត្រឱ្យមានភាពចម្រុះ នឹងបង្កើននូវប្រាក់ចំណូលរបស់ប្រជាកសិករ
- អនុវត្តការដាំឈើជាចម្ការលើផ្ទៃដីចំនួន ៥០, ០០០ហិកតាក្នុងមួយឆ្នាំដើម្បីបង្កើនធនធានព្រៃឈើ ។

### ៨.២.១៧.៣ លទ្ធផលរំពឹងទុក

- មានបរិយាកាសមួយសមស្របសម្រាប់វិនិយោគិន និងប្រជាជនមូលដ្ឋានចូលរួមការដាំឈើដែលអាចប្រើប្រាស់បានច្រើនយ៉ាង
- ការបង្កើតចម្ការឈើដាំប្រើប្រាស់បានច្រើនយ៉ាងនឹងផ្តល់ប្រាក់ចំណូល និងការចិញ្ចឹមជីវិតកាន់តែ ប្រសើរឡើង
- កាត់បន្ថយការហូរច្រោះ និងការពារទីជំរាលនៅក្នុងតំបន់ប្រមូលផ្តុំចម្ការឈើដាំប្រើប្រាស់ច្រើនយ៉ាង
- ការផ្គត់ផ្គង់ឈើសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញទៅទីផ្សារបរទេស តាមរយៈប្រភពផលិតផលឈើដាំ
- ជួយបង្កើនគម្របព្រៃឈើយ៉ាងតិច ៦០% ស្របតាមគោលដៅសហសវត្ស។

## ៨.២.១៨ អនុកម្មវិធី ៧ ការអភិវឌ្ឍផលិតផលព្រៃឈើ និង ពង្រីកទីផ្សារ

### ៨.២.១៨.១ សេចក្តីអធិប្បាយ

សេចក្តីថ្លែងការណ៍អំពីគោលនយោបាយព្រៃឈើជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០២ សំដៅលើកស្ទួយកិច្ច អភិវឌ្ឍន៍ផលិតផលព្រៃឈើរបស់ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន ដើម្បី

បំពេញនូវតម្រូវការរបស់ទីផ្សារក្នុងស្រុក និងនាំចេញ។ ការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និងការពង្រឹងទីផ្សារ គឺជាផ្នែកសំខាន់មួយពាក់ព័ន្ធនឹងការរស់នៅរបស់ប្រជាជន មូលដ្ឋានភាគច្រើន។ ការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និងការពង្រឹងទីផ្សារនាពេលបច្ចុប្បន្ននេះនៅមានកម្រិតទាបនៅ ឡើយ ហើយត្រូវការឱ្យមានការវិនិយោគបន្ថែមនៅមូលដ្ឋាន លើការកែច្នៃ ដើម្បីបង្កើនតម្លៃបន្ថែម និងការធ្វើពាណិជ្ជកម្មផលិតផល ព្រៃឈើព្រមទាំងបង្កើតការងារនៅមូលដ្ឋាន និងផ្តល់នូវភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។ ការងារនេះ ផ្សារភ្ជាប់ ទៅនឹងខ្សែចង្វាក់គ្រប់គ្រងផលិតកម្មកែច្នៃ ដែលអាចឱ្យយើងគ្រប់គ្រងបាននូវប្រភពឈើស្របច្បាប់ផ្សេងៗទៀតផងដែរ។

គោលបំណងនៃអនុកម្មវិធីនេះ គឺបង្កើតឱ្យមានយន្តការ និងបរិយាកាសល្អសម្រាប់ការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុង ស្រុកការធ្វើពាណិជ្ជកម្ម ការពង្រឹង និងការស្វែងរកទីផ្សារសម្រាប់ផលិតផល និងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផលិតផល ព្រៃឈើក្នុងស្រុក។

### ៨.២.១៨.២ មធ្យោបាយអនុវត្ត

#### ៨.២.១៨.២.១ បង្កើតក្រុមការងារមួយសម្រាប់ជំរុញដំណើរការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និង ការពង្រឹងទីផ្សារ

ដើម្បីឱ្យការងារនេះអនុវត្តប្រកបដោយប្រសិទ្ធភាព រដ្ឋបាលព្រៃឈើនឹងបង្កើតក្រុមការងារមួយសម្របសម្រួល សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីចូលរួមក្នុងការងារអភិវឌ្ឍ ផលិតផលព្រៃឈើកែច្នៃក្នុងស្រុក។ ក្រុមការងារនេះដឹកនាំដោយនាយកដ្ឋានអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- រៀបចំបង្កើតផែនការយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់ការងារគ្រប់គ្រង, អភិវឌ្ឍន៍ផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និងពង្រឹងទីផ្សារ។
- ធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានច្បាប់ និងបច្ចេកទេស ស្របទៅតាមសភាពការរីកចម្រើនរបស់ប្រទេស និងនិន្នាការវិវត្តន៍ របស់ទីផ្សារ ព្រមទាំងសិទ្ធិចូលរួមរបស់ប្រជាជនមូលដ្ឋានផ្នែកឯកជនក្នុងការអភិវឌ្ឍអាជីវកម្មកែច្នៃ និងធ្វើពាណិជ្ជកម្ម ផលិតផលព្រៃឈើ។
- សម្របសម្រួល សហការជាមួយដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីជួយសហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍផលិតកម្មកែច្នៃផល-អនុផលព្រៃឈើនិងជួយរកទីផ្សារ។

- រៀបចំវគ្គបណ្តុះបណ្តាលដល់ផលិតករកែច្នៃផល-នុផលព្រៃឈើ ពិសេសសហគមន៍មូលដ្ឋាន នូវចំណេះដឹង និងបច្ចេកទេស កែច្នៃព្រមទាំងតម្រូវការផលិតផលនៅលើទីផ្សារ។
- បង្កើតប្រព័ន្ធគ្រប់គ្រងផលិតផលដែលធានាបាននូវគុណភាពផលិតផលព្រៃឈើកែច្នៃ ស្រប តាមស្តង់ដារជាតិ និង អន្តរជាតិ ។

### ៨.២.១៨.២.២ ពង្រឹងការងារស្រាវជ្រាវ និងអភិវឌ្ឍផលិតផលព្រៃឈើ

រដ្ឋបាលព្រៃឈើនឹងពង្រឹងការងារស្រាវជ្រាវ និងអភិវឌ្ឍផលិតផលព្រៃឈើ ដោយសហការ ជាមួយដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន សហគមន៍មូលដ្ឋាន និងសង្គមស៊ីវិល។ ដើម្បីសម្រេចបាននូវការងាត នះ ចាំបាច់ត្រូវ ៖

- ពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធលើការងារស្រាវជ្រាវ និងអភិវឌ្ឍផលិតផលព្រៃ ឈើ
- ស្រាវជ្រាវរកបច្ចេកវិទ្យាថ្មី ទំនើប និងអភិវឌ្ឍផលិតផលមានគុណភាព និងតម្លៃ ដែលអាច ប្រកួតប្រជែងលើទីផ្សារហើយចងក្រងជាឯកសារដើម្បីផ្សព្វផ្សាយដល់ផលិតករកែច្នៃដល់ព្រៃ ឈើ
- ស្រាវជ្រាវរកផលិតផលព្រៃឈើកែច្នៃដែលមានចរិតលក្ខណៈប្រពៃណីវប្បធម៌របស់សហគមន៍ ដើម្បីធ្វើការកែសម្រួលបច្ចេកកែច្នៃផលិតផលផ្តល់នូវតម្លៃបន្ថែម។

### ៨.២.១៨.២.៣ ការពង្រឹងទីផ្សារ

- ពង្រឹងគុណភាពផលិតផលព្រៃឈើកែច្នៃសមស្របតាមតម្រូវការទីផ្សារ និងមានតម្លៃអាច ប្រកួតប្រជែងបាន
- ពង្រឹងទីផ្សារដែលមានស្រាប់ និងសិក្សាស្វែងរកទីផ្សារថ្មីៗ បន្ថែមទៀត ដើម្បីនាំយកមុខទំនិញ ផលិតផលព្រៃឈើដែលទើបអភិវឌ្ឍថ្មីៗ និងមុខទំនិញដែលមានស្រាប់ទៅកាន់ទីផ្សារ
- សិក្សាស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ដៃគូប្រកួតប្រជែង ដើម្បីងាយស្រួល ដល់ការជម្រុញពាណិជ្ជកម្មផលិតផលព្រៃឈើ
- រៀបចំនិងផ្តល់វិញ្ញាបនបត្របញ្ជាក់ពីផលិតផលព្រៃឈើ
- ស្រាវជ្រាវ ចងក្រងនិងផ្សព្វផ្សាយព័ត៌ទីផ្សារដល់សហគមន៍មូលដ្ឋាន ផ្នែកឯកជន និងផលិតករ ពាក់ពន្ធ
- រក្សានិរន្តរភាពផលិតផលសម្រាប់បំពេញសេចក្តីត្រូវរបស់ទីផ្សារ

### ៨.២.១៨.៣ លទ្ធផលរំពឹងទុក

- ក្រុមការងារសម្រាប់ជំរុញដំណើរការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និងការពង្រឹងទីផ្សា ត្រូវបានបង្កើតឡើងដើម្បី សម្របសម្រួល សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង សហគមន៍មូលដ្ឋាន
- ផែនការយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់ការងារគ្រប់គ្រង អភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក និងពង្រឹង ទីផ្សារត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- លិខិតបទដ្ឋានច្បាប់ និងបច្ចេកទេស ត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់
- បង្កើតបាននូវយន្តការ និងបរិយាកាសល្អសម្រាប់ការអភិវឌ្ឍផលិតផលព្រៃឈើកែច្នៃក្នុងស្រុក ការធ្វើពាណិជ្ជកម្ម, ការពង្រឹង និងស្វែងរកទីផ្សារ និងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផលិតផលព្រៃឈើក្នុងស្រុក
- ទីផ្សារដែលមានស្រាប់ និងទីផ្សារថ្មី ត្រូវបានពង្រឹង និងពង្រីកបន្ថែម និងអាចរក្សាបាននូវនិរន្តរភាពផលិតផល
- ព័ត៌មានទីផ្សារ និងបច្ចេកវិទ្យាថ្មី ទំនើបត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់សហគមន៍មូលដ្ឋាន ផ្នែកឯកជន ផលិតករ និងអ្នកពាក់ព័ន្ធ
- ប្រព័ន្ធទិន្នន័យស្តីពីផលិតផលព្រៃឈើ ត្រូវបានរៀបចំឡើង
- ប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់លើផលិតផលព្រៃឈើត្រូវបានរៀបចំ និងអនុវត្ត។

### ៨.២.១៩ អនុកម្មវិធី ៨ ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និង ការកែច្នៃផល - អនុផលព្រៃឈើ

#### ៨.២.១៩.១ សេចក្តីអធិប្បាយ

ក្នុងគោលបំណងលើកទឹកចិត្តឧស្សាហកម្មកែច្នៃផលិតផលព្រៃឈើក្នុងស្រុកឱ្យមានគុណភាពខ្ពស់ សំដៅបង្កើនតម្លៃបន្ថែម សម្រាប់ការប្រកួតប្រជែងនៅលើទីផ្សាររាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១៣១ ស្តីពី ប្រភេទផល-អនុផល ព្រៃឈើអនុញ្ញាត ឱ្យនាំចេញ នាំចូល ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦ បានហាមឃាត់ការនាំចេញឈើបបមូល ឈើអារសុទ្ធសាធ និងឈើជ្រុងដែលមានកម្រាស់លើសពី ២៥ ស.ម ទោះបីបានឈូសហើយក៏ដោយ។ ទន្ទឹមនឹងនោះដែរ រាជរដ្ឋាភិបាលកម្ពុជាគាំទ ឱ្យមានការនាំចូលនូវផល-អនុផលព្រៃឈើកែច្នៃ ឬមិនទាន់កែច្នៃដើម្បីបំពេញបន្ថែមនូវវត្ថុធាតុដើមសម្រាប់ការកែច្នៃប្រើប្រាស់ក្នុង ស្រុក និងនាំចេញទៅវិញ។

ទោះជាយ៉ាងនេះក្តី ផលិតផលព្រៃឈើនាំចេញពីប្រទេសកម្ពុជា ភាគច្រើនជាផលិតផលមានការកែច្នៃតិចតួចមិនបានផ្តល់ តម្លៃបន្ថែមច្រើននៅឡើយ។ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រទេសកម្ពុជានៅមានធនធានព្រៃឈើច្រើន ដែលជាសក្តានុពល ជួយដល់សេដ្ឋកិច្ចជាតិ។ ដូចនេះ ដើម្បីប្រើប្រាស់ធនធានព្រៃឈើប្រកបដោយប្រសិទ្ធភាពស្របតាមគោលនយោបាយកាត់បន្ថយ ភាពក្រីក្ររបស់

រាជរដ្ឋាភិបាល ចាំបាច់ត្រូវយកចិត្តទុកដាក់ ជំរុញកិច្ចអភិវឌ្ឍឧស្សាហកម្ម កែច្នៃផលិតផលព្រៃឈើឱ្យអស់លទ្ធភាព និងមានគុណភាពខ្ពស់ តាមតម្រូវការរបស់ទីផ្សារ រួមចំណែកបង្កើនចំណូលលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន។

គោលបំណងនៃអនុកម្មវិធីនេះ គឺដើម្បីជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឈើ និងការកែច្នៃផល អនុផលព្រៃឈើ ពីប្រភពធនធាន ព្រៃឈើក្នុង និងក្រៅស្រុក សំដៅបង្កើនគុណភាពផលិតផលឆ្លើយតបតាមលក្ខខណ្ឌនៃតម្រូវការរបស់ទីផ្សារ។

### ៨.២.១៩.២ មធ្យោបាយអនុវត្ត

#### ៨.២.១៩.២.១ ការវិភាគសក្តានុពលនៃការផ្គត់ផ្គង់និងតម្រូវការវត្ថុធាតុដើមផល-អនុផលព្រៃឈើស្របច្បាប់ ក្នុងក្របខ័ណ្ឌ គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

មុននឹងជំរុញការវិនិយោគខ្នាតធំលើការកែច្នៃឈើ រាជរដ្ឋាភិបាលនឹងធ្វើការវិភាគយ៉ាងយកចិត្តទុកដាក់ទៅ លើសក្តានុពលនៃការផ្គត់ផ្គង់ឈើដោយនិរន្តរភាពសម្រាប់ទីផ្សារ នាំចេញនិងក្នុងស្រុក ដើម្បីធានាថាសមត្ថភាពផលិតនៃ ឧស្សាហកម្មកែ ច្នៃឈើដែលបានអនុញ្ញាតមានតុល្យភាពជាមួយការផ្គត់ផ្គង់។ សកម្មភាពចាំបាច់ដើម្បីអនុវត្តអនុកម្មវិធីនេះមានដូចខាងក្រោម ៖

- សិក្សាវាយតម្លៃអំពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើក្នុងស្រុក
- សិក្សាវាយតម្លៃអំពីសក្តានុពល និងប្រភពផ្គត់ផ្គង់វត្ថុធាតុដើមផល-អនុផលព្រៃឈើ
- វិភាគ ចងក្រងទិន្នន័យ ព័ត៌មានដែលប្រមូលបាន។

#### ៨.២.១៩.២.២ ការគ្រប់គ្រងឧស្សាហកម្មកែច្នៃឈើ និងបច្ចេកវិទ្យាឈើ

ដើម្បីធានាបាននូវនិរន្តរភាពនៃការ នាំចេញឈើកែច្នៃពីកម្ពុជា រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ឧស្សាហកម្មកែច្នៃ ឈើទាំងអស់ឱ្យប្រើប្រាស់ឈើដែលបានធ្វើអាជីវកម្មស្របច្បាប់ពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវ អនុវត្តនូវបណ្តាសកម្មភាព ដូចខាងក្រោម ៖

- សិក្សាកំណត់មូលដ្ឋានកែច្នៃ ដែលប្រើប្រាស់ផល-អនុផលព្រៃឈើជាវត្ថុធាតុដើមព្រមទាំងអត្រាកែច្នៃ
- ជំរុញការរៀបចំខ្សែចង្វាក់ផលិតកម្មរីកច្នៃផល-អនុផលព្រៃឈើឱ្យបានសមស្របដើម្បីធានាដល់ប្រតិបត្តិការរបស់ឧស្សាហកម្មកែច្នៃឈើឱ្យមានតុល្យភាពទៅនឹងលទ្ធភាពនៃការផ្គត់ផ្គង់វត្ថុធាតុដើម នឹងសំដៅបង្កើនគុណភាពផលិតផលឆ្លើយតបតាមលក្ខខណ្ឌនៃតម្រូវការទីផ្សារ។

#### ៨.២.១៩.២.៣ ពង្រឹងការងារស្រាវជ្រាវ និង អភិវឌ្ឍបច្ចេកវិទ្យាកែច្នៃឈើ

រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើតប្រព័ន្ធសមស្របដើម្បីពង្រឹងការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសកែច្នៃឈើ ឱ្យមានប្រសិទ្ធភាព និងសាកល្បងបច្ចេកវិទ្យាថ្មីៗ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជានាការកែច្នៃឈើសមស្របទៅនឹងស្តង់ដារជាតិ-អន្តរជាតិ។ បច្ចេកវិទ្យាទាំងនេះផ្តល់នូវចំណេះដឹងក្នុងការអភិវឌ្ឍ ការកែច្នៃផល-អនុផលព្រៃឈើដល់ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន។

### ៨.២.១៩.៣ លទ្ធផលរំពឹងទុក

- ការអភិវឌ្ឍកែច្នៃផលិតផលព្រៃឈើពីប្រភពស្របច្បាប់របស់ផ្នែកឯកជនត្រូវបានទទួលការលើកទឹកចិត្ត
- ទិន្នន័យព័ត៌មាន និងលទ្ធផលនៃការវិភាគពីសក្តានុពលនៃការផ្គត់ផ្គង់ និងតម្រូវការវត្ថុធាតុដើមស្របច្បាប់ត្រូវបានចងក្រង និង ផ្សព្វផ្សាយ
- មូលដ្ឋានកែច្នៃដែលប្រើប្រាស់ផល-អនុផលព្រៃឈើជាវត្ថុធាតុដើមព្រមទាំងអត្រាកែច្នៃ ត្រូវបានកំណត់បរិមាណ និងអត្រាច្បាស់លាស់
- ខ្សែចង្វាក់ផលិតកម្មកែច្នៃផល-អនុផលព្រៃឈើ ត្រូវបានកែសម្រួលសមស្រប ហើយគុណភាពផលិតផល ត្រូវបានបង្កើនឆ្លើយតបតាមលក្ខខណ្ឌនៃតម្រូវការទីផ្សារ
- បច្ចេកវិទ្យាកែច្នៃផល-អនុផលព្រៃឈើទាន់សម័យ ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យអនុវត្ត
- ឧស្សាហកម្មកែច្នៃផល-អនុផលព្រៃឈើត្រូវបានពង្រីកក្នុងកម្រិតដែលអាចទាញយកផលប្រយោជន៍ពី បច្ចេកវិទ្យាថ្មី និងឱកាស ទីផ្សារសម្រាប់ការធ្វើពាណិជ្ជកម្ម
- ការងារស្រាវជ្រាវ អភិវឌ្ឍន៍ផលិតផលព្រៃឈើ និងការកែច្នៃប្រកបដោយប្រសិទ្ធភាពខ្ពស់ត្រូវបានពង្រឹង។

### ៨.២.២០ អនុកម្មវិធីទី ៩ ការអភិវឌ្ឍប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើ

### ៨.២.២០.១ សេចក្តីអធិប្បាយ

បច្ចុប្បន្ននេះ វិញ្ញាបនបត្រព្រៃឈើមានសកម្មភាពខ្លាំងក្លានៅបណ្តាប្រទេសអភិវឌ្ឍជាច្រើនលើពិភពលោក ប៉ុន្តែនៅតាម បណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់ត្រូពិកដែលជាប្រទេសផលិតឈើ ការអនុវត្តវិញ្ញាបនបត្រព្រៃឈើមានចំនួនតិចតួចប៉ុណ្ណោះ។ ចាប់ពីឆ្នាំ ២០០២ មកទល់នឹងពេលនេះ ផ្ទៃដីព្រៃឈើដែលបានទទួលវិញ្ញាបនបត្រមានការកើនឡើងគួរឱ្យកត់សម្គាល់។

ការផ្តល់វិញ្ញាបនបត្រព្រៃឈើក្នុងតំបន់ត្រូពិកៈ ភាគច្រើនផ្តល់ទៅឱ្យព្រៃសម្បទាន, ឬ ព្រៃឯកជន ឬ ផ្នែកឯកជន ដែល គ្រប់គ្រងផ្ទៃដីព្រៃឈើខ្នាតធំ។ ដោយឡែក ផ្នែកឯកជនដែលគ្រប់គ្រងផ្ទៃដីព្រៃឈើខ្នាតតូចទទួលបានវិញ្ញាបនបត្រតិចតួចបំផុតចំណែកឯសហគមន៍ព្រៃឈើ ទទួលបានវិញ្ញាបនបត្រត្រឹមតែ ១៤% ប៉ុណ្ណោះ។

បច្ចុប្បន្ននៅលើពិភពលោក មានប្រទេសចំនួន ៣២ បានបង្កើតវិញ្ញាបនបត្រព្រៃឈើជាតិប្រើប្រាស់រៀងៗខ្លួន រីឯនៅក្នុង កម្រិតសាកលមានបណ្តាញវិញ្ញាបនបត្រព្រៃឈើពីរកំពុងប្រកួតប្រជែងគ្នាដែលកម្មវិធីវិញ្ញាបនបត្រព្រៃឈើនោះ មានរបៀបប្រតិបត្តិខុសៗគ្នាដែលមួយមានឈ្មោះថា Forest Srewardship Council (FSC) និងមួយទៀតគឺ Pen Europe Forest Certification (PFFC).

ដោយឡែកនៅក្នុងតំបន់អាស៊ាន ប្រទេសមួយចំនួនកំពុងតែខិតខំអភិវឌ្ឍកម្មវិធីវិញ្ញាបនបត្រព្រៃឈើរបស់ខ្លួនដែរ ដូចជា នៅប្រទេសម៉ាឡេស៊ី គេបង្កើត Malaysian Timber Council ។ រីឯនៅប្រទេសឥណ្ឌូនេស៊ី ក៏មានកម្មវិធីវិញ្ញាបនបត្ររបស់ខ្លួន ដែរដែលហៅកាត់ថា LEY ។ ក្នុងក្របខណ្ឌអាស៊ាន បណ្តាសមាជិកទាំង ១០ កំពុងពិភាក្សាគ្នាអំពី Pen - ASEAN Certification ។ លើសពីនោះទៀត អង្គការ ITTO ក៏កំពុងតែជំរុញឱ្យអនុវត្ត ITTO C&I ដែលស្រដៀងគ្នាទៅនឹងការអនុវត្តដើម្បីទទួលយក វិញ្ញាបនបត្រព្រៃឈើដែរ។

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនដែលសំដែងនូវការចាប់អារម្មណ៍ក្នុងការរៀបចំឱ្យមាន ប្រព័ន្ធ វិញ្ញាបនបត្រ ព្រៃឈើហើយរដ្ឋបាលព្រៃឈើបច្ចុប្បន្នកំពុងផ្តួចផ្តើមគំនិតរៀបចំឱ្យមានប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើជាតិដើម្បីធានាដល់ការគ្រប់គ្រង ធនធានព្រៃឈើប្រកបដោយនិរន្តរភាព នឹងទាញយកផលចំណេញពីការនាំចេញផលិតផលព្រៃឈើទៅកាន់ទីផ្សារអន្តរជាតិផងដែរ។

គោលបំណងនៃអនុកម្មវិធីនេះគឺដើម្បីបង្កើតវិញ្ញាបនបត្រព្រៃឈើជាតិមួយសំដៅធានាការធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើកម្ពុជា ស្របតាមលក្ខខណ្ឌតម្រូវការទីផ្សារជាតិ អន្តរជាតិ ពង្រីកទីផ្សារ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលផល-អនុផលព្រៃឈើ នឹងការកែច្នៃប្រកបដោយនិរន្តរភាព។

*អ្វីទៅជា វិញ្ញាបនបត្រ ហើយអ្វីទៅជា វិញ្ញាបនបត្រព្រៃឈើ?*

- វិញ្ញាបនបត្រ គឺជាដំណើរការផ្តល់សក្ខីភាពដល់ភាគីម្ខាងទៀតថា អង្គភាពឬបុគ្គលដែលបានបំពេញតាមស្តង់ដារ គុណភាព និងបរិមាណ ឬ កម្រិតអប្បបរមានការអនុវត្តជាក់លាក់ដែលបានកំណត់

- វិញ្ញាបនបត្រព្រៃឈើ គឺជាដំណើរការវាយតម្លៃអំពីការគ្រប់គ្រងព្រៃឈើ ជាមួយនឹងដំណើការខ្សែចង្វាក់ផលិតកម្មធៀប នឹងស្តង់ដារដែលបានកំណត់។

### ៨.២.២០.២ មធ្យោបាយអនុវត្ត

បង្កើតក្រុមការងាររៀបចំវិញ្ញាបនបត្រព្រៃឈើជាតិមួយនៅរដ្ឋបាលព្រៃឈើ។ ក្រុមការងារនេះចាំបាច់ត្រូវអនុវត្តនូវបណ្តា សកម្មភាព ដូចខាងក្រោម ៖

- សិក្សា និងរៀបចំប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើជាតិ ដែលសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេសកម្ពុជា និងមានលក្ខណៈសមស្រប ទៅនឹងប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើអន្តរជាតិ
- បង្កើនការនាំចេញនូវឈើកែច្នៃ និងឈើដែលមានបញ្ជាក់វិញ្ញាបនប័ត្រ
- កំណត់ស្តង់ដារជាតិ លក្ខណៈវិនិច្ឆ័យ និងសូចនាករ សម្រាប់ការផ្តល់វិញ្ញាបនបត្រលើការគ្រប់គ្រងព្រៃឈើ
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេស ចំណេះដឹងអំពីលក្ខណៈវិនិច្ឆ័យ និងសូចនាករ តាមស្តង់ដារជាតិ ដើម្បីឈានទៅទទួលបានការបញ្ជាក់វិញ្ញាបនបត្រព្រៃឈើថ្នាក់ជាតិដល់អ្នកពាក់ព័ន្ធ
- ធ្វើសកម្មភាពលើកទឹកចិត្តដល់សហគមន៍ព្រៃឈើ ឧស្សាហកម្ម និងសហគ្រាសគ្រប់គ្រងព្រៃឈើឱ្យប្រតិបត្តិតាមលក្ខណៈវិនិច្ឆ័យ និងសូចនាករ ដើម្បីឈានទៅទទួលបានការបញ្ជាក់វិញ្ញាបនបត្រព្រៃឈើថ្នាក់ជាតិ និងចូលរួមចំណែកធ្វើឱ្យប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើនៅកម្ពុជាមានការរីកចម្រើនជាលំដាប់
- ធ្វើការសាកល្បងអនុវត្តប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើជាតិ ។

### ៨.២.២០.៣ លទ្ធផលរំពឹងទុក

- ក្រុមការងាររៀបចំវិញ្ញាបនបត្រព្រៃឈើជាតិ ត្រូវបានបង្កើតឡើង
- លក្ខណៈវិនិច្ឆ័យ និងសូចនាករមានលក្ខណៈជាស្តង់ដារជាតិសម្រាប់អនុវត្តការផ្តល់វិញ្ញាបនបត្រព្រៃឈើជាតិត្រូវបានបង្កើតឡើង
- លក្ខណៈវិនិច្ឆ័យ និងសូចនាករមានលក្ខណៈជាស្តង់ដារជាតិ ដើម្បីទទួលបានវិញ្ញាបនបត្រព្រៃឈើជាតិ ត្រូវបានធ្វើការសាក ល្បងនៅតំបន់ព្រៃឈើមួយកន្លែង
- ឯកសារអំពីលក្ខណៈវិនិច្ឆ័យ សូចនាករ និងគោលការណ៍ណែនាំបច្ចេកទេសដែលមានស្តង់ដារជាតិ ដើម្បីឈានទៅទទួលបាន ការបញ្ជាក់វិញ្ញាបនបត្រព្រៃឈើថ្នាក់ជាតិ ត្រូវបានរៀបចំរួចហើយធ្វើការផ្សព្វផ្សាយ និង បណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ

- វិញ្ញាបនបត្រព្រៃឈើនឹងត្រូវបានផ្តល់ដល់សហគមន៍ព្រៃឈើ ឧស្សាហកម្ម និងសហគ្រាសគ្រប់គ្រងព្រៃឈើ ដែលបានធ្វើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមលក្ខណៈវិនិច្ឆ័យ សូចនាករ និងគោលការណ៍ណែនាំបច្ចេកទេសដែលមាន ស្តង់ដារជាតិ
- ការសាកល្បងអនុវត្ត លក្ខណៈវិនិច្ឆ័យ និងសូចនាករមានលក្ខណៈជាស្តង់ដារជាតិ ដើម្បីទទួលបានការបញ្ជាក់វិញ្ញាបនបត វ្រៃឈើជាតិ ត្រូវបានទទួលការផ្តល់ថវិកាគ្រប់គ្រាន់ដើម្បីអនុវត្ត។

## ៨.២.២១ តម្រូវការហិរញ្ញវត្ថុ

តារាងទី២ ៖ ថវិកាសម្រាប់ កម្មវិធីអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើនិងជីវចម្រុះ សម្រាប់ឆ្នាំ ២០១០-២០២០

| អនុកម្មវិធី | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ ២០១០-២០១៤(ដុល្លាអាមេរិក) | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ ២០១៥-២០២០ (ដុល្លាអាមេរិក) |
|---|---|---|
| ២-១ ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ | ១.៥០០.០០០ | ៥០០.០០០ |
| ២-២ ការអភិវឌ្ឍ និង អនុវត្តបច្ចេកទេសគ្រប់គ្រងព្រៃផ្តល់ផល | ២.០០០.០០០ | ២.២៥០.០០០ |
| ២-៣ ពង្រឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព | ២.០០០.០០០ | ២.២៥០.០០០ |
| ២-៤ ការអភិរក្សធនធានជីវចម្រុះ និង សត្វព្រៃ | ២.០០០.០០០ | ២.០០០.០០០ |
| ២-៥ ការអភិរក្ស និង អភិវឌ្ឍធនធានសេនេទិច និង ប្រភពពូជ | ២.០០០.០០០ | ១០០.០០០ |
| ២-៦ ការដាំដុះដើមឈើ និង ការអភិវឌ្ឍចម្ការព្រៃឈើដាំ | ២.០០០.០០០ | ៣.០០០.០០០ |
| ២-៧ ការអភិវឌ្ឍផលិតផលព្រៃឈើ និង ពង្រីកទីផ្សារ | ២០០.០០០ | ៥៥.០០០ |

| | | |
|---|---|---|
| ២-៨ ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងកែច្នៃផលអនុផលព្រៃឈើ | ១០០.០០០ | ៣០០.០០០ |
| ២-៩ ការអនុវត្តប្រព័ន្ធវិញ្ញបនបត្រព្រៃឈើ | ២០០.០០០ | ៤០០.០០០ |
| ចំណាយសរុប | ១២.០០០.០០០ | ១២.២៥០.០០០ |
| ថវិកាបរិច្ចាគមកពីដៃគូអភិវឌ្ឍន៍ | ៩.២០០.០០០ | |

សន្មតថា ចំណូលពីព្រៃឈើនឹងត្រូវធ្វើការវិនិយោគឡើងវិញទៅក្នុងផ្នែកនិងការងារខាងលើនេះ ដែលជាលទ្ធផលនឹងធ្វើឱ្យការអនុវត្ត ការងារនេះកាន់តែមានលក្ខណៈស្វ័យហិរញ្ញប្បទានសមស្រប និងមានសង្គតិភាពជាមួយនឹងកម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាព សម្រាប់វិស័យព្រៃឈើ។ ចំណែកឯថវិកាបរិច្ចាគពីដៃគូអភិវឌ្ឍន៍នឹងកាន់តែមានការថយចុះបន្តិចម្តងៗ នៅជំហានទី២ ដែលមាន រយៈពេល៥ឆ្នាំទៀត។

## ៨.៣ កម្មវិធី ៣ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច

### ៣.១ ចំណុចអាទិភាពសំខាន់ៗ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- បង្ការ និង ទប់ស្កាត់បទល្មើសព្រៃឈើ
- បង្កើនការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ និង លិខិតបទដ្ឋានគតិយុត្តដល់អ្នកពាក់ព័ន្ធ
- អភិបាលកិច្ចព្រៃឈើ

### ៣.២ រយៈពេលកម្មវិធី

មានរយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២៩

### ៣.៣ ការឆ្លើយតបរបស់កម្មវិធីទៅនឹងទស្សនវិស័យកម្មវិធីព្រៃឈើជាតិ

ធនធានព្រៃឈើគឺជាសម្បត្តិធម្មជាតិមួយរបស់ជាតិដ៏មានតម្លៃបំផុត ដែលប្រជាជនរស់នៅក្នុង និងក្បែរតំបន់ព្រៃភាគច្រើនពឹងអាស្រ័យលើផល-អនុផលព្រៃឈើសម្រាប់ជីវភាពប្រចាំថ្ងៃ។ ព្រៃឈើគឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវតែគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។ សកម្មភាព កាប់ឈើខុសច្បាប់ ការកាប់ពនដីព្រៃ និងបទល្មើសព្រៃឈើផ្សេងៗទៀត បានធ្វើ ឱ្យព្រៃឈើរេចរឹល និងជះឥទ្ធិពលដល់ កាលានុវត្តភាពក្នុងការអភិវឌ្ឍជាតិប្រកបដោយនិរន្តរភាព។ សកម្មភាពបំផ្លាញព្រៃឈើធ្វើ ឱ្យបាត់បង់ជីវចម្រុះ មានបម ប

ម្រួលបរិស្ថាន បាត់បង់ចំណូល និងកាលានុវត្តភាពជាតិ ព្រមទាំងធ្វើឱ្យមានការកើនឡើងកំដៅលើភពផែនដីផងដែរ។កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ចនឹងចូលរួមចំណែកជួយកម្មវិធីព្រៃឈើជាតិក្នុងការគ្រប់គ្រងព្រៃឈើ ប្រកបដោយចីរភាពនៅកម្ពុជា។

## ៣.៤ ការឆ្លើយតបរបស់កម្មវិធីទៅនឹងគោលបំណងកម្មវិធីព្រៃឈើជាតិ

កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច នឹងចូលរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើឱ្យកាន់តែ ប្រសើរឡើងដើម្បីផលប្រយោជន៍ប្រជាជន ដោយធ្វើការទប់ស្កាត់ និងលុបបំបាត់បទល្មើសព្រៃឈើគ្រប់ប្រភេទឱ្យបានជា អតិបរមា។ កម្មវិធីនេះ នឹងជួយធ្វើឱ្យប្រសើរឡើងផងដែរនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងសហគមន៍មូលដ្ឋាន ព្រមទាំងជនជាតិដើមភាគតិចដែលពឹងផ្អែកលើព្រៃឈើ។ ជារឿយៗ ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ត្រូវរងផលប៉ះពាល់ដោយសារសកម្មភាពបទល្មើសព្រៃឈើពីអ្នកខាងក្រៅ ឬដោយសារសហគមន៍ខ្លួនឯងជាអ្នកប្រព្រឹត្ត។ ការទប់ស្កាត់ និងលុបបំបាត់ សកម្មភាពបទល្មើសព្រៃឈើ ការស៊ើបអង្កេត និងចំណាត់ការតាមផ្លូវតុលាការចំពោះអ្នកប្រព្រឹត្តបទល្មើសព្រៃឈើ នឹងជួយដល់រាជ រដ្ឋាភិបាលក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព និងផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។ តាមរយៈ ការទប់ស្កាត់ និងលុបបំបាត់សកម្មភាពកាប់ឈើ និងការកាប់រានដីព្រៃខុសច្បាប់របស់កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចនឹងទប់ស្កាត់មិនឱ្យផលិតផលព្រៃឈើដែលមានប្រភពមិនស្របច្បាប់ក្នុងទីផ្សារ ហើយរក្សាបាននូវលំនឹងរវាងតម្រូវការ និង ការផ្គត់ផ្គង់ផលិតផលព្រៃឈើពីប្រភពស្របច្បាប់ និងមានការប្រកួតប្រជែងដោយស្មើភាព។ កម្មវិធីនេះនឹងបង្កើនការយល់ដឹងដល់ សាធារណជន មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ អំពីវិធានច្បាប់ និងអភិបាលកិច្ចព្រៃឈើ ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។

## ៣.៥ សារៈសំខាន់កម្មវិធី

ផ្អែកតាមធនុសាសន៍របស់ក្រុមត្រួតពិនិត្យវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យ (Independent Forest Sector Review-IFSR) បានលើកឡើងថា ការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំ និងសកម្មភាពកាប់រានដីព្រៃឈើ បានធ្វើឱ្យរេចរឹលធនធានព្រៃឈើដ៏មានតម្លៃ របស់កម្ពុជា ហើយជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ មូលហេតុនៃការបាត់បង់និងរេចរឹលព្រៃឈើគឺបណ្តាល មកពីសង្គ្រាមស៊ីវិល និងភាពក្រីក្រដែលធ្វើឱ្យការចូលរួមរបស់ប្រជាជនក្នុងការទប់ស្កាត់សកម្មភាពបទល្មើសព្រៃឈើនៅមានកម្រិត។ ចាប់តាំងពីមានសង្គ្រាមស៊ីវិលរហូតដល់សង្គមជាតិមាន

សន្តិភាព ការអនុវត្តច្បាប់មិនទាន់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុង ការទប់ស្កាត់និងបង្រ្កាបបទល្មើសព្រៃឈើគ្រប់ប្រភេទនៅឡើយទេ។ កំណើនប្រជាជននិងតម្រូវការដីកសិកម្មក៏ជាមូលហេតុនៃការ បាត់បង់ព្រៃឈើផងដែរ។ ចំនួនមន្រ្តីបច្ចេកទេស សម្ភារៈ និងមធ្យោបាយមានកំណត់នាំឱ្យសមត្ថភាពពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាល ព្រៃឈើនៅមានកម្រិត។ កិច្ចសហការរវាងរដ្ឋបាលព្រៃឈើ និងអង្គភាពពាក់ព័ន្ធក៏មិនទាន់មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើនៅ តំបន់ដាច់ស្រយាលនៅឡើយ( IESR2004)។

ជាមួយគ្នានេះ : IFSR និង ITTO ក៏បានលើកឡើងនូវអនុសាសន៍បន្ថែមទៀតថា កម្ពុជាមានបទពិសោធន៍ចំពោះសកម្មភាព ទប់ស្កាត់ការកាប់ឈើដោយខុសច្បាប់ ជាពិសេសក្នុងអំឡុងពេលដំណើរការអនុវត្តព្រៃសម្បទាន។ ឆ្លើយតបនឹងបញ្ហាជាច្រើនដែល បណ្តាលមកពីសកម្មភាពកាប់ឈើខុសច្បាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្អាកការធ្វើអាជីវកម្មឈើព្រៃសម្បទាននៅ ខែ មករា ឆ្នាំ ២០០២។ បន្ទាប់មករាជរដ្ឋាភិបាលបានរៀបចំតំបន់គំរូសាកល្បងប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព រៀបចំ នីតិវិធីអនុវត្តការធ្វើអាជីវកម្មព្រៃគុបដេញថ្លៃ និងប្រព័ន្ធផ្សេងៗទៀតសម្រាប់ធ្វើការសាកល្បងនាពេលអនាគត។ ក្នុងដំណាក់កាលសំខាន់នេះ រាជរដ្ឋាភិបាលក៏បានពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ដើម្បីទប់ស្កាត់បញ្ហាពីពេលមុនមិនឱ្យកើតឡើងម្តងទៀត (IFSR 2004, ITTO 2004 ).

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្រ្តចតុកាណអាណត្តិទី ២ (យុទ្ធសាស្រ្តចតុកោណជំហានទី ១) របស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០០២ បានបញ្ចូលគោលបំណង ជាក់លាក់គឺ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ពិសេសការប្រយុទ្ធប្រឆាំងការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់" (RGC , 2002a) ផែនការអភិវឌ្ឍយុទ្ធសាស្រ្តជាតិ មិនបានបង្ហាញនូវការដោះស្រាយបទល្មើសព្រៃឈើ ឬការកាប់រានដីព្រៃឈើទេ ប៉ុន្តែបានដាក់ចេញ នូវអភិបាលកិច្ចល្អ រួមមានការបំបាត់អំពើពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ និងកំណែទម្រង់កងកំលាំងប្រដាប់អាវុធ (RGC 2006 d) ពង្រឹងវិធានការច្បាប់ នឹងកំណែទម្រង់អភិបាលកិច្ចជាអាទិភាពចម្បងផងដែរក្នុងយុទ្ធសាស្រ្តចតុកោណអាណត្តិទី៣ ( យុទ្ធសាស្រ្តចតុកោណជំហានទី ២) របស់រាជរដ្ឋាភិបាល RGC 2008b) ។

បេសកកម្មវិនិច្ឆ័យរបស់ IFSR និង ITTO នៅឆ្នាំ ២០០៤ បានធ្វើការវិភាគបញ្ហា និងកាលានុវត្តភាពវិស័យព្រៃឈើកម្ពុជា។ ការសិក្សារបស់អង្គការ ITTO នេះបានផ្តល់អនុសាសន៍ទាក់ទងនឹងការធ្វើអាជីវកម្មឈើ និងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចរួមមាន៖

- ពង្រឹងវិធានការបរិស្ថានដើម្បីកាត់បន្ថយការខូចខាតបណ្តាលមកពីការធ្វើអាជីវកម្មឈើ

- សិទ្ធិរបស់ប្រជាជនមូលដ្ឋានត្រូវបានគោរពដោយអ្នកធ្វើអាជីវកម្មឈើ
- ទទួលបានព័ត៌មានបន្ថែមទៀតអំពីផលប៉ះពាល់ជីវចម្រុះបណ្តាលមកពីការធ្វើអាជីវកម្មឈើ និងការកាពារព្រៃឈើមានតម្លៃដើម្បីធ្វើការអភិរក្ស
- លិខិតបទដ្ឋានដែលមានភាពស្មុគស្មាញនឹងមិនអាចលុបបំបាត់អំពើពុករលួយបានទាំងស្រុងទេ
- គ្រប់កម្មវិធី/គម្រោងព្រៃឈើទាំងអស់នៅកម្ពុជានឹងក្លាយជាបទពិសោធន៍ ហើយបទពិសោធន៍ដែលទទួលបាននេះមានសារៈសំខាន់ណាស់ត្រូវតែធ្វើការតាមដានឱ្យបានជិតដល់ (ITTO 2004)។

ក្រុមពិនិត្យវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យនៅឆ្នាំ ២០០៤ បានធ្វើការសន្និដ្ឋានថា មានបញ្ហាគន្លឹះ និងការលើកទឹកចិត្ត សម្រាប់ការធ្វើអាជីវកម្មឈើនៅក្នុងប្រទេសកម្ពុជា ដែលបញ្ហាគន្លឹះ និងការលើកទឹកចិត្តទាំងនេះ រួមមាន រោងចក្រអារឈើមានសមត្ថភាព ផលិតខ្ពស់ពេក (តម្រូវការផលិតឈើលើសពីការផ្គត់ផ្គង់) ការបង្ក្រាប និងការពិន័យមិនទាន់ធ្វើឱ្យជនល្មើសរាងចាលនៅឡើយ ហើយចំណូលមិនទាន់សមស្របចំពោះអ្នកដែលរស់នៅក្នុង ឬក្បែរតំបន់ព្រៃឈើ (IFSR 2004, p .71)។ ទាក់ទងនឹងការទប់ស្កាត់បទល្មើស ព្រៃឈើវិញ ក្រុមពិនិត្យវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យបានផ្តល់អនុសាសន៍ថា គួរលុបបំបាត់ការលើកទឹកចិត្តឱ្យមានសកម្មភាពបទល្មើសព្រៃឈើ ហើយត្រូវធ្វើយ៉ាងណាឱ្យយន្តការនឹងការពង្រឹងការអនុវត្តច្បាប់មានការត្រួតពិនិត្យនិងមានតុល្យភាពគ្នា។ អនុសាសន៍ចំពោះបទល្មើសព្រៃឈើមានដូចខាងក្រោម ៖

មិនឃើញមានផ្លូវថ្មីនៅក្នុងព្រៃដែលមិនទាន់រងការធ្វើអាជីវកម្ម មានការប៉ះពាល់សិទ្ធិស្របច្បាប់ និងការតវ៉ាថ្មីៗនៅតំបន់ព្រៃសម្បទាន និង តំបន់ក្រៅព្រៃសម្បទាន ប្រព័ន្ធតាមដានឈើស្របច្បាប់ត្រូវបានបង្កើតឡើងនៅពេលដែលមានការផ្អាកការធ្វើអាជីវកម្មឈើ យន្តការអភិបាលកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ត្រូវបានបង្កើតដើម្បីឱ្យប្រជាជនមូលដ្ឋានចូលរួមក្នុងសកម្មភាពធ្វើការសម្រេចចិត្ត និង ការគ្រប់គ្រងព្រៃឈើ ការចុះបញ្ជីផលប្រយោជន៍ព្រៃឈើឯកជន (private Forest Interest Register) ត្រូវបានបង្កើតដើម្បីធ្វើឱ្យមានតម្លាភាព ផលប្រយោជន៍ឯកជន ផ្នែក តាមដាន និងស៊ើបអង្កេតបទល្មើសព្រៃឈើត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការងារតាមដានការប្រែប្រួលជីវចម្រុះ។

ដើម្បីប្រយុទ្ធប្រឆាំងការកាប់រាន នឹងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិ និងអនុគណៈ កម្មាធិការខេត្តដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិនៅ ឆ្នាំ ២០០៤ ដើម្បីទប់ស្កាត់ និងប

ង្រ្កាបការកាប់រាន និងហ៊ុមព័ទ្ធវាតយកដីព្រៃធ្វើកម្មសិទ្ធិ ។ ជាមួយគ្នានេះដែរ រាជរដ្ឋ ភិបាលក៏បានបង្កើត អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តាំងពីឆ្នាំ ២០០៦ (RGC 2006 b , RGC 2008a)។

## ៣.៦ ការវិភាគបញ្ហា

សកម្មភាពបទល្មើសព្រៃឈើបានធ្វើឱ្យបាត់បង់និងរេចរឹលព្រៃឈើ ដែលជាឧបសគ្គក្នុងការ អភិវឌ្ឍប្រកបដោយនិរន្តរភាពនៅ កម្ពុជា ពីព្រោះវាបានធ្វើឱ្យបាត់ប្រាក់ចំណូលសម្រាប់សេដ្ឋកិច្ចជាតិ និងសង្គម។

នៅកម្រិតមូលដ្ឋាន ប្រជាជនបានធ្វើឱ្យព្រៃឈើរេចរឹលដោយសារភាពខ្វះខាតក្នុងជីវភាពរស់នៅ ប្រចាំថ្ងៃ។ ប្រជាជនដែលចូល រួមក្នុងសកម្មភាពបទល្មើសព្រៃឈើដោយសារតែពួកគាត់ចង់បានផល ប្រយោជន៍ក្នុងរយៈពេលខ្លី។ ការធ្វើអាជីវកម្មឈើហួសប្រមាណ នាំឱ្យរេចរឹលបរិស្ថាន និងមានផលប៉ះ ពាល់អវិជ្ជមានដល់ការរស់នៅរបស់សហគមន៍មូលដ្ឋាន ប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរការ កាត់ បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រអភិវឌ្ឍមូលដ្ឋានរបស់រាជរដ្ឋាភិបាល។

នៅកម្រិតជាតិ សកម្មភាពកាប់ឈើខុសច្បាប់ធ្វើឱ្យមានការលំបាកចំពោះយន្តការកទីផ្សារៈ ព្រោះតម្លៃផលិតផលឈើធ្លាក់ចុះ ដោយសារមានការគេចពន្ធ និងការប្រកួតប្រជែងមិនសមស្រប ចំពោះក្រុមហ៊ុនមួយចំនួនដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ IFSR 2004) ។

មានការលំបាកក្នុងការកំណត់ឱ្យបានត្រឹមត្រូវចំពោះមូលហេតុចម្បងនៃការកាប់ឈើខុសច្បាប់ និងបទល្មើសព្រៃឈើផ្សេងៗទៀត ជួនកាលវាទាក់ទងទៅនឹងបញ្ហាគ្រឹះក្នុងគោលនយោបាយព្រៃឈើ ជាតិ ច្បាប់ និងលិខិតបទដ្ឋានព្រៃឈើ អាណត្តិស្ថាប័ន និង សមត្ថ ភាពទប់ស្កាត់និងបង្ក្រាបបទល្មើស ព្រៃឈើ (WB 2006)។ ភាពប្រឈមទាំងនេះ ត្រូវមានកម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ នឹង អភិបាលកិច្ច

*អភិបាលកិច្ចព្រៃឈើអាស្រ័យលើ ៖*

- បង្កើតគោលនយោបាយព្រៃឈើ និង អនុវត្តផែនការផ្អែកលើតម្លាភាព និង ប្រព័ន្ធគណនេយ្យភាព
- ពង្រឹងការអនុវត្តច្បាប់
- ឆ្លើយតបចំពោះការគំរាមកំហែង និង ផលប៉ះពាល់។

សកម្មភាពបទល្មើសព្រៃឈើជានិច្ចកាល កើតឡើងដោយសារភាពទន់ខ្សោយនៃអភិបាលកិច្ច ព្រៃឈើ និងការពង្រឹងការអនុវត្ត ច្បាប់នៅមានកម្រិត។ តាមការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញការ

ជាតិនៃគម្រោង ITTO នៅក្នុងឆ្នាំ ២០០៧ បានបញ្ជាក់ថា មូលហេតុ ចម្បងដែលនាំឱ្យកើតមានបទល្មើសព្រៃឈើគ្រប់ប្រភេទគឺមានកត្តាក្នុងនិងក្រៅវិស័យព្រៃឈើដូចខាងក្រោម ៖

- ការតាមដាន និងធ្វើសេចក្ដីរាយការណ៍បទល្មើសព្រៃឈើមិនបានជិតដល់
- ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅមានកម្រិត មធ្យោបាយ និង សម្ភារៈមិនគ្រប់គ្រាន់ក្នុងការទប់ស្កាត់ និង បង្ក្រាបបទល្មើស
- មន្ត្រីមានសមត្ថភាពរបស់រដ្ឋបាលព្រៃឈើមានមិនគ្រប់គ្រាន់
- កិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងអន្តរជាតិនៅមានកម្រិត
- ការអនុវត្តនីតិវិធីរបស់តុលាការមិនទាន់មានប្រសិទ្ធភាព
- ការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រងព្រៃឈើនៅមានកម្រិតដែលនាំឱ្យខ្វះភាពជឿជាក់រវាងអ្នកប្រើប្រាស់ព្រៃឈើ និង អាជ្ញាធរមានសមត្ថកិច្ច។

បញ្ហាខាងលើនេះត្រូវការដោះស្រាយតាមផែនការយុទ្ធសាស្ត្រ និងព្រមពេលជាមួយគ្នា ដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពសម្រាប់វិស័យព្រៃឈើ។

ដើម្បីដោះស្រាយអភិបាលកិច្ចព្រៃឈើ និងបទល្មើសព្រៃឈើដែលកើតមានពីកត្តាខាងក្រៅឱ្យបានសមស្រប គឺត្រូវការកិច្ចសហការ ល្អពីស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួង-អង្គភាពពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ក្នុងការអនុវត្តជាក់ស្ដែង ប្រជាជន សមត្ថកិច្ចរដ្ឋបាលព្រៃឈើ អ្នកតាមដាន និងអាជ្ញាធរ ត្រូវចែករំលែកគោលដៅរួម សម្រាប់ការគ្រប់គ្រងព្រៃឈើ និងការបែងចែកផលប្រយោជន៍ពីព្រៃឈើ។ ជាមួយគ្នានេះ ស្ថាប័នរាជរដ្ឋាភិបាល ដូចជារដ្ឋបាលព្រៃឈើ និងកងកំលាំងប្រដាប់អាវុធត្រូវជឿជាក់ និងគោរពតួនាទី និងភារកិច្ចរបស់ខ្លួន ពង្រឹងទំនាក់ទំនងជាមួយប្រជាជន និងអាជ្ញាធរមូលដ្ឋាន។ គួរបង្កើតវេទិកាផ្សព្វផ្សាយដើម្បីបង្កើនភាពជឿជាក់ក្នុង ចំណោមសាធារណជនចំពោះអាជ្ញាធរមានសមត្ថកិច្ច និងធ្វើឱ្យមានការទុកចិត្តលើប្រព័ន្ធដឹកនាំដែលជាកត្តានាំឱ្យទទួលបាននូវភាពជោគជ័យ ក្នុងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ។ ការបាត់បង់ព្រៃឈើជានិច្ចកាលកើតឡើងមានទ្រង់ទ្រាយ និងមានមូលហេតុផ្សេងៗគ្នា ហើយកម្មវិធី ព្រៃឈើជាតិមានបំណងដោះស្រាយបញ្ហាប្រឈមនៃការបាត់បង់ព្រៃឈើដោយការឆ្លើយតបដ៏ជាក់លាក់ទៅនឹងបញ្ហាជាក់ស្ដែង។

## ៣.៧ គោលបំណងនៃកម្មវិធី

គោលបំណងទូទៅនៃកម្មវិធីពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ និងអភិបាលកិច្ច នឹងចូលរួមចំណែកក្នុងការគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍ព្រៃឈើប្រកបដោយតម្លាភាព ត្រឹមត្រូវ និងមានប្រសិទ្ធភាព។ គោលបំណងជាក់លាក់នៃកម្មវិធីគឺ ៖

- ដើម្បីពង្រឹងការអនុវត្តច្បាប់ដោយធ្វើការត្រួតពិនិត្យទប់ស្កាត់ បង្ក្រាប និងលុបបំបាត់សកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទ រៀបចំលិខិតបទដ្ឋានផ្សេងៗដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- អនុវត្តអភិបាលកិច្ចព្រៃឈើល្អតាមរយៈធ្វើឱ្យប្រសើរនូវសមត្ថភាពគ្រប់គ្រង និងដោះស្រាយទំនាស់
- ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព
- បង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- អភិវឌ្ឍវិធានការតាមដាន ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទឱ្យមានប្រសិទ្ធភាពខ្ពស់
- បង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីឱ្យមានការគោរពច្បាប់ជាទូទៅ។

## ៣.៨ សូចនាករ

- សហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើបានចូលរួមយ៉ាងសកម្មក្នុងការត្រួតពិនិត្យ និងរាយការណ៍ពីសកម្មភាពបទល្មើសព្រៃឈើ ដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន
- តម្លាភាព និងគណនេយ្យភាពក្នុងវិស័យព្រៃឈើត្រូវបានធ្វើឱ្យប្រសើរតាមរយៈអភិបាលកិច្ចព្រៃឈើល្អ
- មានការយល់ដឹងជាសាធារណៈអំពីការគោរពសិទ្ធិ និងកម្មសិទ្ធិរបស់ប្រជាជន
- មានការយល់ដឹងជាសាធារណៈអំពីគោលនយោបាយព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្ត
- ទំនាស់ផលប្រយោជន៍ព្រៃឈើត្រូវបានគ្រប់គ្រង និងដោះស្រាយដោយសមភាពផ្អែកតាមទិដ្ឋភាពច្បាប់ និង លិខិត ស្របទៅតាមកាលទេសៈជាក់ស្តែង
- ករណីបទល្មើសព្រៃឈើគ្រប់ប្រភេទត្រូវបានធ្វើសេចក្តីរាយការណ៍ និងចាត់វិធានការតាមនីតិវិធី ហើយបានបញ្ចូលទិន្នន័យក្នុង ប្រព័ន្ធតាមដានព័ត៌មានបទល្មើសព្រៃឈើ (Case Tracking System/CIS)
- សណ្ដុំរឿងបទល្មើសព្រៃឈើត្រូវបានរៀបចំ និងបញ្ជូនទៅអយ្យការអមសាលាដំបូងតាមនីតិវិធី
- សំណុំរឿងបទល្មើសព្រៃឈើ ត្រូវបានជំនុំជម្រះដោយសាលាជម្រះក្តីគ្រប់ថ្នាក់ប្រកបដោយយុត្តិធម៌
- សកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទត្រូវបានថយចុះតាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចល្អ

- មន្ត្រីរដ្ឋបាលព្រៃឈើត្រូវបានបង្កើនសមត្ថភាពក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច
- ព័ត៌មានដលពាក់ព័ន្ធនឹងវិស័យព្រៃឈើត្រូវបានគ្រប់គ្រង។

## ៣.៩ ការផ្ទៀងផ្ទាត់

- ឯកសារច្បាប់
- លិខិតបទដ្ឋានគតិយុត្ត
- ផែនទី (ផែនទីគម្របព្រៃឈើកម្ពុជា ឆ្នាំ ២០០២ និង ២០០៦)
- របាយការណ៍ស៊ើបអង្កេតដំបូង និងករណីសំណុំរឿងបទល្មើសព្រៃឈើក្នុង CIS
- សាលក្រម និងសាលដីការបស់សាលាជម្រះក្តីគ្រប់ថ្នាក់ដែលពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ
- កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ
- វគ្គបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រងទំនាស់
- ផ្នែកគ្រប់គ្រង និងដោះស្រាយទំនាស់ដែលបានបង្កើតឡើង
- របាយការណ៍សកម្មភាព និងលទ្ធផលការងារ
- តាមដាន និងត្រួតពិនិត្យកម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច។

## ៣.១០ ហានិភ័យនៃកម្មវិធី

នៅពេលដំណើរការអនុវត្តកម្មវិធី អាចជួបប្រទះនូវហានិភ័យដូចតទៅ ៖

- ដំណើរការជំនុំជម្រះក្តីលើសំណុំរឿងបទល្មើសព្រៃឈើដោយប្រព័ន្ធតុលាការ
- គោលនយោបាយដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងការសម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- កិច្ចសហការ ឬការចូលរួមពីអាជ្ញាធរមូលដ្ឋាន និង អង្គភាពពាក់ព័ន្ធ កិច្ចសហការ ឬការចូលរួមពីសហគមន៍មូលដ្ឋាន
- ថវិកាពីរាជរដ្ឋាភិបាលដើម្បីគាំទ្រដំណើរការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចបន្ត
- កិច្ចសហការ និងការផ្តល់ព័ត៌មានបទល្មើសព្រៃឈើជាមួយប្រទេសជិតខាង និងអន្តរជាតិក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើស ព្រៃឈើឆ្លងដែន
- ការគាំទ្រពីរាជរដ្ឋាភិបាលក្នុងការចាត់វិធានការចំពោះករណីបទល្មើសព្រៃឈើទ្រង់ទ្រាយធំ។

## ៣.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី

កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ត្រូវការកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរាជរដ្ឋាភិបាល និងប្រទេស ជាច្រើនដើម្បីចាត់វិធានការឱ្យមានប្រសិទ្ធភាពចំពោះបទល្មើសព្រៃឈើគ្រប់ប្រភេទ។ ដូចមាននៅក្នុងកម្មវិធីផ្សេងៗទៀតដែលបានលើក ឡើងអំពីកំណែទម្រង់អភិបាលកិច្ចដែរ ការកែទម្រង់អភិបាលកិច្ច គឺជាដំណើរការមួយដ៏វែងឆ្ងាយដែលត្រូវការចូលរួមពីស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ កម្មវិធីនេះនឹងផ្តោតសំខាន់លើយុទ្ធសាស្ត្រចម្បងៗមួយចំនួន ដើម្បីធ្វើយ៉ាងណាឱ្យការពង្រឹងការអនុវត្តច្បាប់ស្តីពី ព្រៃឈើ និងអភិបាលកិច្ច មានប្រសិទ្ធភាពខ្ពស់រយៈពេល ២០ ឆ្នាំ នាពេលអនាគត។

### ៣.១១.១ បង្កើនកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល

កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ នឹងអភិបាលកិច្ច នឹងធ្វើឱ្យប្រាកដថា សកម្មភាពបទល្មើសព្រៃឈើ គ្រប់ប្រភេទ ត្រូវបានចាត់វិធានការតាមនីតិវិធីច្បាប់។ ដំណាក់កាលដំបូង គឺត្រូវធ្វើកាកំណត់ប្រភេទបទល្មើសព្រៃឈើនិងរៀបចំយុទ្ធសាស្ត អនុវត្តក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើង។ចំណុចសំខាន់ៗដែលបានលើកឡើងដោយក្រុមពិនិត្យវាយតម្លៃវិស័យព្រៃឈើ ឯករាជ្យ (IFSR) គឺ:

- ការបង្រ្កាប និងការពិន័យលើបទល្មើសព្រៃឈើពុំទាន់ធ្វើឱ្យជនល្មើសរាងចាលនៅឡើយ
- ជីវភាពរស់នៅ និងកាលានុវត្តភាពរកប្រាក់ចំណូលសម្រាប់ប្រជាជនដែលអាស្រ័យលើព្រៃឈើ និងអ្នករស់នៅក្បែរតំបន់ព្រៃនៅមានកម្រិត
- ប្រព័ន្ធត្រួតពិនិត្យវាយតម្លៃមុនការធ្វើអាជីវកម្មឈើសម្រាប់ឧស្សាហកម្មដើម្បីធ្វើឱ្យតម្រូវការឈើមានតុល្យភាពជាមួយការផ្គត់ផ្គង់ឈើដោយនិរន្តរភាពនៅមានកម្រិត

យុទ្ធសាស្ត្រដែលត្រូវបង្កើតឡើង នឹងធ្វើយ៉ាងណាឱ្យការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច មានលក្ខណៈ សមស្របជាមួយកម្មវិធីជាតិសំខាន់ៗដ៏ទៃទៀតដូចជាកម្មវិធីចុះបញ្ជីកាដីធ្លីកម្មវិធីគ្រប់គ្រងព្រៃឈើ ដោយមានការចូលរួម កម្មវិធីបង្កើនជីវភាពរស់នៅដើម្បីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីប្រប្រាស់ថាមពលស្អាត។

### ៣.១១.២ បង្កើនសមត្ថភាពដោះស្រាយទំនាស់ក្នុងវិស័យព្រៃឈើ

រដ្ឋបាលព្រៃឈើនឹងធ្វើការគ្រប់គ្រងទំនាស់ដែលទាក់ទងនឹងព្រៃឈើទាំងទំនាស់តូចតាច (ទំនាស់បុគ្គល និងសហគមន៍)និង ទំនាស់ធំៗ (ទំនាស់រវាងសហគមន៍ជាមួយអ្នកក្រៅសហគមន៍ សហគមន៍ជាមួយស្ថាប័ន និងសហគមន៍ជាមួយក្រុមហ៊ុន)។

ដើម្បីធ្វើឱ្យមានតម្លាភាពក្នុងការដោះស្រាយទំនាស់ព្រៃឈើ រដ្ឋបាលព្រៃឈើនឹងផ្តល់សិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តមួយចំនួនដល់រដ្ឋបាលព្រៃឈើមូលដ្ឋានស្របតាមច្បាប់ស្តីពីព្រៃឈើ។រដ្ឋបាលព្រៃឈើមានផ្នែកទំនាក់ទំនងសាធារណៈសម្រាប់ទាក់ទងជាមួយនឹងមហាជនក្នុងការផ្តល់នូវព័ត៌មានស្តីពីការគ្រប់គ្រងព្រៃឈើជូនដល់អ្នកពាក់ព័ន្ធទៅតាមការចាំបាច់។

### ៣.១១.៣ កិច្ចសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត

ដើម្បីពង្រឹងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព រដ្ឋបាលព្រៃឈើនឹងធ្វើការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុង ការអនុវត្តច្បាប់និងគោលនយោបាយឱ្យបានសមស្របពាក់ព័ន្ធនឹងវិស័យព្រៃឈើ ព្រមទាំងបង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ និងមន្ត្រីតុលាការ។

### ៣.១១.៤ អភិបាលកិច្ចល្អក្នុងការរកទីផ្សារនាំចេញផលិតផលព្រៃឈើ

ដើម្បីធ្វើឱ្យកាន់តែប្រសើរដល់ការគ្រប់គ្រងដំណើរការផ្គត់ផ្គង់ឈើ រាជរដ្ឋាភិបាលអាចនឹងបង្កើតកិច្ចព្រមព្រៀងដៃគូស្ម័គ្រចិត្ត (Voluntary Partnership Agreement-VPA) ដើម្បីស្វែងរកទីផ្សារផលិតផលព្រៃឈើសំខាន់ៗ ដូចជា ទីផ្សារសហគមន៍អឺរ៉ុបប្រសិនបើ ចាំបាច់។ ដើម្បីសម្រេចការងារនេះ រាជរដ្ឋាភិបាលនឹងអភិវឌ្ឍប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់ (Legality Insurance System- LAS)។ ដំណើរការអនុវត្តប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់ នេះរួមមាន ៖

- កំណត់និយមន័យឱ្យបានច្បាស់លាស់នូវផលិតផលព្រៃឈើស្របច្បាប់ក្នុងប្រទេសកម្ពុជា
- បង្កើត និងអភិវឌ្ឍប្រព័ន្ធជឿទុកចិត្តមួយ ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តការគ្រប់គ្រងព្រៃឈើនៅថ្នាក់ប្រព័ន្ធផ្ទៀងផ្ទាត់
- ផ្តល់អាជ្ញាប័ណ្ណដល់ការនាំចេញដើម្បីបញ្ជាក់ភាពស្របច្បាប់របស់ផលិតផលព្រៃឈើ។

### ៣.១១.៥ ការបង្កើតវិញ្ញាបនបត្រព្រៃឈើ

នៅក្នុងរយៈពេលវែង ប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់នឹងជួយវិស័យព្រៃឈើឱ្យបង្កើតបាននូវវិញ្ញាបនបត្រព្រៃឈើ ដើម្បីបញ្ជាក់លើ ផលិតផលព្រៃឈើ ដែលបានមកពីការគ្រប់គ្រងប្រយដោយនិរន្តរភាព។ កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច នឹងជួយភ្ជាប់វិញ្ញាបនបត្រព្រៃឈើទៅនឹងផែនការកំពុងអនុវត្តរបស់រាជរដ្ឋាភិបាល។ វិញ្ញាបនបត្រជាវិធានការមួយជួយកាត់បន្ថយសកម្មភាពបទល្មើសព្រៃឈើ ហើយផ្តល់ការលើកទឹកចិត្តសម្រាប់អ្នកដែលគ្រប់គ្រងព្រៃឈើដោយនិរន្តភាព មានការទទួលខុសត្រូវ ចំពោះសង្គម និងបរិស្ថាន។

### ៣.១១.៦ ការធ្វើឱ្យប្រសើរនូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងអន្តរជាតិ

រាជរដ្ឋាភិបាលនឹងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងការធ្វើពាណិជ្ជកម្មឈើ និងសត្វព្រៃខុសច្បាប់ ហើយយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសឆ្លងដែនផ្សេងៗទៀតដែលមាន ទំនាក់ទំនងជាមួយបទល្មើសព្រៃឈើ (ករណីនេះមានលម្អិតក្នុងអនុកម្មវិធីទី២)។

### ៣.១១.៧ ការបង្កើតវិធានការធ្វើឱ្យមានតុល្យភាពរវាងតម្រូវការឧស្សាហកម្មនិងការផ្គត់ផ្គង់ឈើដោយនិរន្តរភាព

រដ្ឋបាលព្រៃឈើនឹងធ្វើការសិក្សាវិភាគសមត្ថភាពផលិតរបស់ឧស្សាហកម្មឈើនៅកម្ពុជា ដើម្បីឱ្យសមស្របទៅនឹងការផ្គត់ផ្គង់ និងតម្រូវការឈើពិតប្រាកដ។ ការសិក្សាអំពីឧស្សាហកម្មឈើនឹងជួយវាយតម្លៃសមត្ថភាពផលិតរបស់ឧស្សាហកម្មឈើ ដោយ ប្រៀបធៀបតម្រូវការឈើរបស់ឧស្សាហកម្មទៅនឹងសក្តានុពលនៃការផ្គត់ផ្គង់ឈើ។ ជាមួយគ្នានេះការសិក្សានឹងធ្វើការវិភាគផងដែរ នូវការលើកទឹកចិត្ត និងការទប់ស្កាត់បទល្មើសព្រៃឈើ ការសិក្សាទាំងនេះនឹងបង្ហាញការកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់បទល្មើស ព្រៃឈើ និងការសម្រេចចិត្តខាងគោលនយោបាយក្នុងការធ្វើនិយ័តកម្មទំហំឧស្សាហកម្មឈើនៅកម្ពុជា។

### ៣.១១.៨ លទ្ធផលរំពឹងទុក

- មូលហេតុសំខាន់នៃបទល្មើសព្រៃឈើត្រូវបានកំណត់ច្បាស់លាស់ និងចាត់វិធានការបន្តនៅក្នុងកំណែទម្រង់ច្បាប់ ស្ថាប័ន និង កម្មវិធីអនុវត្តផ្សេងៗ ដើម្បីជួយដល់ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងទប់ស្កាត់បទល្មើសព្រៃឈើគ្រប់ប្រភេទ។ យុទ្ធសាស្ត្រ ទប់ស្កាត់បទល្មើសព្រៃឈើកម្រិតជាតិមួយត្រូវបានបង្កើត និងអនុវត្តដោយរដ្ឋបាលព្រៃឈើ ហើយសហការយ៉ាងជិតស្និទ្ធជាមួយ អង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនៅក្នុងកម្មវិធីមួយចំនួនដែលមានគោលបំណងកាត់បន្ថយការពឹងអាស្រ័យលើព្រៃឈើ
- វិស័យព្រៃឈើបានក្លាយទៅជាវិស័យឈានមុខមួយផ្អែកលើតម្លាភាព និងគណនេយ្យភាព
- កំណែទម្រង់តុលាការ បានចូលរួមចំណែកក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ . កិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងត្រូវបានពង្រឹងនិងពង្រីកដើម្បីរកវិធីយ៉ាងណាធ្វើឱ្យមានកិច្ចអន្តរាគមន៍ក្នុងតំបន់ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើឆ្លងដែន
- តុល្យភាពរវាងតម្រូវការឈើនិងការផ្គត់ផ្គង់ឈើស្របច្បាប់ចេញពីព្រៃដាំនិងព្រៃធម្មជាតិត្រូវបានអនុវត្តដើម្បីលុបបំបាត់ការប្រើប្រាស់ឈើខុសច្បាប់នៅក្នុងឧស្សាហកម្មឈើ
- អភិបាលកិច្ចត្រូវបានធ្វើឱ្យមានលក្ខណៈប្រសើរ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពស្របច្បាប់នៃឈើនាំចេញ ហើយការនាំចេញផលិតផល

- ព្រៃឈើកែច្នៃទៅសហគមន៍អឺរ៉ុប និងអាមេរិកខាងជើងត្រូវបានបង្កើន . ប្រព័ន្ធវិញ្ញាបនបត្រត្រូវបង្កើតឡើង និងអភិវឌ្ឍដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។

### ៣.១២ អនុកម្មវិធីទី ១ ការកែទម្រង់ច្បាប់ និង រដ្ឋបាល

### ៣.១២.១ សេចក្តីអធិប្បាយ

ច្បាប់ស្តីពីព្រៃឈើត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០២ ហើយរដ្ឋបាលព្រៃឈើបាននឹងកំពុងរៀបចំលិខិតបទដ្ឋានក្រោម ច្បាប់ស្តីពីព្រៃឈើដែលពុំទាន់បានរៀបចំរួច។ បទបញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនរបស់អង្គភាពផ្សេងៗដែល បានចងភារកិច្ចជាន់គ្នាក្នុងការអនុវត្ត ក៏ត្រូវតែធ្វើការពិនិត្យពិចារណាផងដែរ។

អភិបាលកិច្ចល្អនៅក្នុងវិស័យព្រៃឈើពឹងផ្អែកទៅលើផ្នែកសំខាន់ៗផ្សេងទៀត ដែលពុំមែនទាក់ទងតែទៅនឹងបញ្ហាច្បាប់នោះ ទេ។ ផែនការសកម្មភាពមួយនឹងត្រូវបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ តម្រូវការថវិកា មធ្យោបាយ សម្ភារៈ និងមន្ត្រីរដ្ឋបាលព្រៃឈើ គឺជាតម្រូវការចាំបាច់ ក្នុងកិច្ចដំណើរការអនុវត្តផែនការសកម្មភាពនេះ។

### ៣.១២.២ មធ្យោបាយអនុវត្ត

### ៣.១២.២.១ ក្រុមការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រុមការងារមួយដែលមានមន្ត្រីបង្គោលពីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាននឹងត្រូវបង្កើតឡើង ដើម្បី រៀបចំលិខិតបទដ្ឋាន និងពិនិចកែសម្រួលបទបញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋានគតិយុត្ត និងលិខិតបទដ្ឋានផ្សេងៗ ទៀតដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ហើយក៏ជួយដល់ចក្ខុវិស័យកម្មវិធីព្រៃឈើជាតិផងដែរ។ ច្បាប់ស្តីពីព្រៃឈើត្រូវបាន ទទួលស្គាល់ថា ជាច្បាប់មានលក្ខណៈល្អត្រឹមត្រូវ និងសមស្របសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗ ហើយផ្តល់នូវបទបញ្ញត្តិច្បាស់លាស់សម្រាប់ឱ្យប្រជាជនមូលដ្ឋានទទួលផលប្រយោជន៍ពីព្រៃឈើ។ ក្រុមការងារនេះមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងអនុវត្តន៍ផែនការការងាររបស់ក្រុមការងារ ហើយធ្វើការតាមដានដំណើរវិវឌ្ឍន៍នៃលិខិតបទដ្ឋាននៅគ្រប់លំដាប់ ថ្នាក់រហូតដល់ការសម្រេចរួចរាល់
- ពិនិត្យលើបទបញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់នេះ និងបទបញ្ញត្តិនៃច្បាប់ផ្សេងៗទៀតដែលទាក់ទងនឹងវិស័យព្រៃឈើដែលអនុវត្តដោយក្រសួងពាក់ព័ន្ធ

- ធ្វើកិច្ចសហការជាមួយស្ថាប័នផ្សេងៗដើម្បីកំណត់អំពីបទល្មើសព្រៃឈើឱ្យបានច្បាស់លាស់ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ និងចាត់វិធានការបទល្មើសព្រៃឈើ
- រៀបចំលិខិតបទដ្ឋានក្រោមច្បាប់ស្ដីពីព្រៃឈើដោយសហការជាមួយនឹងនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋបាលព្រៃឈើ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គភាព និងអង្គការពាក់ព័ន្ធនានាដើម្បីជំរុញ និងធ្វើឱ្យប្រសើរដល់ដំណើរការពិនិត្យ និងសម្រេចលិខិតបទដ្ឋាន
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីរកថវិកាគាំទ្រដល់ក្រុមការងារនិងផ្នែកអភិបាលកិច្ចល្អ។

### ៣.១២.២.២ ក្រុមការងារស៊ើបអង្កេត និងអធិការកិច្ចបទល្មើសពឈើ

ដើម្បីពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ និងអភិបាលកិច្ច រដ្ឋបាលព្រៃឈើនឹងបង្កើតក្រុមការងារស៊ើបអង្កេត នឹង អធិការកិច្ចរបស់នាយកដ្ឋាននីតិកម្មនិងពង្រឹងការអនុវត្តច្បាប់ ដើម្បីធ្វើការស៊ើបអង្កេតសកម្មភាពបទល្មើសព្រៃឈើទូទាំង ប្រទេស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ។ សកម្មភាពសំខាន់ៗរបស់ក្រុមការងារនេះគឺ ៖

- ចុះពិនិត្យ និង ធ្វើសវនកម្មនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើមូលដ្ឋានពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ស្ដីពីព្រៃឈើ
- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធពង្រឹងការអនុវត្តច្បាប់ឱ្យមានលក្ខណៈសមស្រប និងមាន ប្រសិទ្ធភាព
- តាមដាន និងស៊ើបអង្កេតបទល្មើសព្រៃឈើទូទាំងប្រទេស រួមទាំងការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់
- ប្រមូល និងវិភាគព័ត៌មានបទល្មើសព្រៃឈើពីប្រភពផ្សេងៗ និងបញ្ចូលទៅក្នុងប្រព័ន្ធពង្រឹងការអនុវត្តច្បាប់ ស្ដីពីព្រៃឈើ
- រៀបចំរបាយការណ៍ស៊ើបអង្កេត និងអធិការកិច្ចដោយមានអនុសាសន៍ជូនរដ្ឋបាលព្រៃឈើ។

### ៣.១២.២.៣ គណៈកម្មការពិនិត្យវាយតម្លៃសកម្មភាពការងាររបស់មន្ត្រីរដ្ឋបាលពឈើ

រដ្ឋបាលព្រៃឈើនឹងបង្កើតគណៈកម្មការមួយដើម្បីពិនិត្យវាយតម្លៃសកម្មភាពការងារ ដើម្បីលើកសរសើរដល់មន្ត្រី ដែលមានស្នាដៃល្អ ឬដាក់ពិន័យដល់មន្ត្រីរដ្ឋបាលព្រៃឈើណាដែលបានប្រព្រឹត្តល្មើសនឹងវិជ្ជាជីវៈរបស់ខ្លួន។ សកម្មភាពសំខាន់ៗនគណៈកម្មការនេះគឺ ៖

- តាមដានសកម្មភាពប្រតិបត្តិទូទៅរបស់មន្ត្រីរដ្ឋបាលព្រៃឈើ

- រៀបចំកិច្ចប្រជុំដើម្បីវាយតម្លៃមន្ត្រីរដ្ឋបាលព្រៃឈើ ដើម្បីលើកទឹកចិត្តមន្ត្រីដែលបំពេញការងារល្អ មន្ត្រីដែលមានកំហុសធ្ងន់
- រៀបចំរបាយការណ៍វាយតម្លៃមន្ត្រីរដ្ឋបាលព្រៃឈើដោយមានអនុសាសន៍ជូនរដ្ឋបាលព្រៃឈើ។

### ៣.១២.២.៤ ការធ្វើឱ្យប្រសើរនូវរចនាសម្ព័ន្ធរដ្ឋបាលពឈើ

ពង្រឹងការងាររដ្ឋបាលដល់អ្នកគ្រប់គ្រងថ្នាក់ក្រោម ពិសេសរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីអភិវឌ្ឍអង្គភាព រដ្ឋបាល ព្រៃឈើជាអាជ្ញាធររាជរដ្ឋាភិបាលមួយប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព ធ្វើការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាល ព្រៃឈើនៅថ្នាក់មូលដ្ឋាន ( ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃ) ឱ្យមានដែនសមត្ថកិច្ចសមស្របក្នុងការគ្រប់គ្រងធនធាន ព្រៃឈើ លើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើជាស្ត្រីចូលរួមក្នុងការងារគ្រប់គ្រង។

### ៣.១២.២.៥ បង្កើនសមត្ថភាពរដ្ឋបាលព្រៃឈើដើម្បីគ្រប់គ្រង និងដោះស្រាយទំនាស់

- បង្កើនសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើអំពីការងារគ្រប់គ្រង និងនីតិវិធីដោះស្រាយទំនាស់ក្នុងវិស័យព្រៃឈើ តាមរយៈ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងសិក្ខាសាលាស្តីពីការដោះស្រាយទំនាស់
- បង្កើតបណ្តាញការងារក្នុងករណីចាំបាច់ ដើម្បីគ្រប់គ្រង និងដោះស្រាយទំនាស់
- ផ្តល់មធ្យោបាយ សម្ភារៈ និងថវិកាដល់រដ្ឋបាលព្រៃឈើដើម្បីដំណើរការគ្រប់គ្រង ទប់ស្កាត់ និងដោះស្រាយទំនាស់ក្នុងវិស័យព្រៃឈើ។

### ៣.១២.២.៦ ធ្វើឱ្យប្រសើរនូវទំនាក់ទំនងការងាររបស់រដ្ឋបាលព្រៃឈើ

- បង្កើនឱ្យមានបណ្តាញអ៊ីនធឺណែតនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដើម្បីងាយស្រួលដល់ទំនាក់ ទំនងការងារ
- បង្កើតគម្រោងការសាកល្បងចំពោះផ្នែករដ្ឋបាលព្រៃឈើមួយចំនួន ដោយធ្វើការផ្តល់កុំព្យូទ័រ ដើម្បីអភិវឌ្ឍនៅក្នុងផ្នែកទាំងនោះ
- បង្កើតផ្នែកបច្ចេកវិជ្ជាព័ត៌មាននៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ដើម្បីគ្រប់គ្រង ថែទាំ និងជួសជុលកុំព្យូទ័រនៅរដ្ឋបាល ព្រៃឈើ ឬក៏រៀបចំកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មឯកជន។

### ៣.១២.២.៧ អភិបាលកិច្ចព្រៃឈើ

អភិបាលកិច្ច គឺជាផ្នែកសំខាន់មួយនៃការពង្រឹងការអនុវត្តច្បាប់ ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលនឹងបន្តធ្វើអភិបាលកិច្ចព្រៃឈើលើការងារដូចខាងក្រោម ៖

- លើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា (ក្រសួងស្ថាប័នផ្សេងៗ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល) ក្នុងដំណើរ អនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ហើយបង្កើតនិងអភិវឌ្ឍវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើស ព្រៃឈើឱ្យមានប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង (បើចាំបាច់ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើ, TWG-F&E) និងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល
- ពង្រឹងគណៈកម្មាធិការជាតិ និងអនុគណៈកម្មាធិការខេត្តដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលេតយកដីធ្វើកម្មសិទ្ធិដើម្បីអភិវឌ្ឍប្រព័ន្ធប្រកបដោយប្រសិទ្ធភាពក្នុងការ ដោះស្រាយទំនាស់ដីព្រៃឈើ ព្រមទាំងធ្វើការទប់ស្កាត់ និងបង្ក្រាប ការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ
- សហប្រតិបត្តិការជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដើម្បីដោះស្រាយទំនាស់ដីធ្លីដោយមានការចូលរួមពីក្រសួង ពាក់ព័ន្ធ
- លើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាជនមូលដ្ឋានក្នុងការអភិរក្ស និងអភិវឌ្ឍព្រៃឈើនៅមូលដ្ឋាន ។
- ធ្វើឱ្យប្រសើរនូវវិធានការអនុវត្តច្បាប់ដូចជា ៖
  - បន្តកំណែទម្រង់ដើម្បីធ្វើឱ្យមនុស្សគ្រប់រូបក្នុងសង្គមគោរពច្បាប់
  - គាំទ្រផ្តល់ការលើកទឹកចិត្ត និងផ្តល់ហិរញ្ញវត្ថុសម្រាប់បង្ក្រាបបទល្មើសព្រៃឈើ
  - ធ្វើឱ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនងជាមួយស្ថាប័នតុលាការ ដើម្បីជំនុំជម្រះបទល្មើសព្រៃឈើឱ្យបានឆាប់រហ័ស។
- ធ្វើឱ្យប្រសើរនូវតម្លាភាព ៖
  - ទិន្នន័យ ព័ត៌មាន និង ស្ថិតិពាក់ព័ន្ធនឹងបទល្មើសព្រៃឈើនឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ
  - រដ្ឋបាលព្រៃឈើនឹងបន្តចេញផ្សាយទស្សនាវដ្តីព្រៃឈើជារៀងរាល់៦ខែម្តង សៀវភៅស្តីពីវិស័យព្រៃឈើរៀងរាល់ ២ ឆ្នាំម្តង និងធ្វើឱ្យប្រសើរគេហទំព័ររបស់ខ្លួន

- រដ្ឋបាលព្រៃឈើនឹងបន្តដំណើរការ និងអភិវឌ្ឍផ្នែកទំនាក់ទំនងសាធារណៈដើម្បីផ្តល់ព័ត៌មាន ឯកសារ និងលិខិត បទដ្ឋានច្បាប់ក្នុងវិស័យព្រៃឈើសម្រាប់អ្នកពាក់ព័ន្ធស្នើសុំ
- រដ្ឋបាលព្រៃឈើនឹងបន្តចូលរួម និងចែករំលែកព័ត៌មាន និងបទពិសោធន៍នៅក្នុងវេទិកាជាតិ តំបន់ និងអន្តរជាតិ ដូចជា វេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចតំបន់អាស៊ីខាងកើត (EA FLEG), វេទិកាពង្រឹង ការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម (EU FLEGT), វេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពី ព្រៃឈើ និងអភិបាលកិច្ចអាស៊ាន (ASEAN FLEG), សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN), វេទិកាបណ្តាញ ពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន (ASEAN WEN), អង្គការឈើតំបន់ត្រូពិចអន្តរជាតិ (ITTO) និងធនាគារ ពិភពលោក (WB)

- ធ្វើឱ្យប្រសើរនូវភាពទទួលខុសត្រូវ ៖
  - រដ្ឋបាលព្រៃឈើនឹងបង្កើតយន្តការឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងចាត់វិធានការសកម្មភាពបទល្មើសព្រៃឈើ សត្វព្រៃ និងដីព្រៃឈើដែលបានធ្វើការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន ដូចបានអធិប្បាយនៅក្នុងកម្មវិធីទី៣
  - រដ្ឋបាលព្រៃឈើនឹងបន្តការខិតខំប្រឹងប្រែងទំនាក់ទំនងនិងសហការឱ្យបានល្អជាមួយយន្តការឆ្លើយតបរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

### ៣.១២.២.៨ ការត្រួតពិនិត្យ និងវាយតម្លៃ (M&E)

ដើម្បីពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ រដ្ឋបាលព្រៃឈើនឹងបង្កើតការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត កម្មវិធី អនុកម្មវិធី និងគម្រោងអភិវឌ្ឍន៍វិស័យព្រៃឈើ ដែលការងារនេះស្ថិតនៅក្រោមសមត្ថកិច្ចរបស់នាយកដ្ឋាន នីតិកម្មនិងពង្រឹងការអនុវត្តច្បាប់។ សកម្មភាពសំខាន់ៗរបស់ការងារនេះមានដូចខាងក្រោម ៖

- រៀបចំ និងអនុវត្តគោលការណ៍បច្ចេកទេស ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធផលសម្រេចបានលើការអនុវត្តកម្មវិធី អនុកម្មវិធី គម្រោងអភិវឌ្ឍន៍វិស័យព្រៃឈើ និងការងារផ្សេងៗទៀត
- ធ្វើការសម្របសម្រួលក្នុងការកំណត់អាទិភាព និងរៀបចំរាល់កម្មវិធី អនុកម្មវិធី និងគម្រោងអភិវឌ្ឍន៍វិស័យព្រៃឈើ ដោយសហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធក្រោមឱវាទរដ្ឋបាលព្រៃឈើ

- ពិនិត្យកែសម្រួល និងកំណត់សូចនាករ តារាងតក្កភាព និងទម្រង់របាយការណ៍វឌ្ឍនភាព ព្រមទាំងជៀងគរជំនួយគាំទ បច្ចេកទេសក្នុងដំណើរការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការអនុវត្តកម្មវិធី គម្រោងអភិវឌ្ឍន៍ វិស័យព្រៃឈើ និងការងារផ្សេងទៀត
- បង្កើតប្រព័ន្ធទិន្នន័យនៃកម្មវិធី អនុកម្មវិធីជម្រោងអភិវឌ្ឍវិស័យព្រៃឈើ និងការងារផ្សេងទៀត ដែលកំពុងស្នើសុំ និង កំពុងអនុវត្តដោយរដ្ឋបាលព្រៃឈើ អង្គការជាតិ អង្គការអន្តរជាតិ និងវិស័យឯកជនដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ
- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី អនុកម្មវិធី គម្រោងអភិវឌ្ឍវិស័យព្រៃឈើ និងការងារផ្សេងៗទៀតតាមការចាំបាច់។

*លទ្ធផលរំពឹងទុក*

- លិខិតបទដ្ឋានក្រោមច្បាប់ស្តីពីព្រៃឈើដលនៅសេសសល់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើត្រូវបានរៀបចំ និងសម្រេច
- បទបញ្ញត្តិនៃបទល្មើសព្រៃឈើត្រូវបានកំណត់ច្បាស់លាស់ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាប
- ក្រុមការងារស៊ើបអង្កេត និងអធិការកិច្ចបទល្មើសព្រៃឈើត្រូវបានបង្កើតឡើងដោយរដ្ឋបាលព្រៃឈើ ដើម្បីធ្វើការស៊ើប អង្កេតសកម្មភាពបទល្មើសព្រៃឈើទូទាំងប្រទេស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ
- ប្រព័ន្ធលើកទឹកចិត្តក្នុងការអនុវត្តការងារត្រូវបានបង្កើត ហើយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវបានធ្វើការវាយតម្លៃជាបន្តបន្ទាប់ ដែលធ្វើឱ្យមន្ត្រីរដ្ឋបាលព្រៃឈើបំពេញការងារបានល្អទៅតាមតួនាទី និងភារកិច្ច
- ការងាររដ្ឋបាលត្រូវបានពង្រឹងដល់រដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីធ្វើឱ្យមានសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្ត ការងារ
- មន្ត្រីរដ្ឋបាលព្រៃឈើជាស្ត្រី ត្រូវបានលើកទឹកចិត្តក្នុងការងារគ្រប់គ្រងព្រៃឈើ
- ការទំនាក់ទំនងក្នុងរដ្ឋបាលព្រៃឈើត្រូវបានធ្វើឱ្យប្រសើរ ដើម្បីដំណើរការការពារឱ្យមានប្រសិទ្ធភាព
- ការចែករំលែកចំណេះដឹង និងព័ត៌មានអំពីវិស័យព្រៃឈើដល់អ្នកពាក់ព័ន្ធ ត្រូវបានធ្វើឱ្យប្រសើរតាមរយៈផ្នែកទំនាក់ ទំនងសាធារណៈរបស់រដ្ឋបាលព្រៃឈើ
- រាជរដ្ឋាភិបាលនឹងបន្ថែមថវិកាដល់រដ្ឋបាលព្រៃឈើ ដើម្បីអនុវត្តកម្មវិធីវិនិយោគសាធារណៈ (Public Investment Program-PIP និងកម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង

អភិបាលកិច្ចជាមួយគ្នានេះ ជំនួយថវិកាពីដៃគូ អភិវឌ្ឍន៍អាចរួមចំណែកជាមួយថវិកាមានកំណត់របស់រាជរដ្ឋាភិបាល។

## ៣.១៣.១ សេចក្ដីអធិប្បាយ

ដើម្បីដោះស្រាយបញ្ហានៃការបាត់បង់ និងរេចរឹលធនធានព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ ដើម្បីលុបបំបាត់សកម្មភាពបទល្មើសក្នុងវិស័យព្រៃឈើ និងដើម្បីអភិវឌ្ឍការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពស្របតាម បរវេណីអន្តរជាតិ និងសេចក្ដីត្រូវការរបស់ប្រជាជន។ រាជរដ្ឋាភិបាលបានចាត់វិធានការពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ ធ្វើការ ទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបសកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទ ដោយមានការសហការ និងគាំទ្រយ៉ាងសកម្មពីគ្រប់ស្ថាប័ន ជាតិ និងភ្នាក់ងារអន្តរជាតិ។ រាជរដ្ឋាភិបាលបានធ្វើការស្នើសុំថ្នាក់ដឹកនាំប្រទេសជិតខាងជួយសហប្រតិបត្តិការក្នុងការទប់ស្កាត់ ការនាំឈើចេញពីប្រទេសកម្ពុជាដោយខុសច្បាប់ ហើយក៏បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសជិតខាង ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ទប់ស្កាត់ និងលុបបំបាត់ការបាត់បង់ព្រៃឈើ រួមមានការកាប់ឈើខុសច្បាប់ និងការធ្វើពាណិជ្ជកម្មឈើ និងសត្វព្រៃឆ្លងដែន។

រាជរដ្ឋាភិបាលនឹងបន្តដោះស្រាយបញ្ហាដែលមិនទាន់សម្រេច ជាពិសេសបញ្ហាការកាប់រានដី និងហ៊ុមព័ទ្ធដីព្រៃឈើយកធ្វើ ជាកម្មសិទ្ធិខុសច្បាប់ និងការចេញលិខិតបញ្ជាក់ទិញលក់ដីដោយអាជ្ញាធរមូលដ្ឋានខ្លះ។ រាជរដ្ឋាភិបាលនឹងគាំទ្រដល់សកម្មភាព របស់អាជ្ញាធរខេត្តក្នុងការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យព្រៃឈើដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យពួកគាត់ចូលរួមសហការអនុវត្តច្បាប់ និងតាមដានបទល្មើសព្រៃឈើ។

រាជរដ្ឋាភិបាលទទួលស្គាល់ថា ការពង្រឹងការអនុវត្តច្បាប់ និងការតាមដានបទល្មើសព្រៃឈើមិនអាចធ្វើបានសម្រេចដោយ រដ្ឋបាលព្រៃឈើតែឯងនោះទេ ចាំបាច់ត្រូវមានកិច្ចសហការ និងការគាំទ្រពីអ្នកពាក់ព័ន្ធ។

## ៣.១៣.២ មធ្យោបាយអនុវត្ត

### ៣.១៣.២.១ ការផ្ដល់មធ្យោបាយ សម្ភារៈ និងបរិក្ខារ

ថវិកា មធ្យោបាយ សម្ភារៈ និងបរិក្ខារ គឺជាឧបករណ៍ដ៏មានសារៈសំខាន់បំផុតក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើស ព្រៃឈើគ្រប់ប្រភេទ។ បច្ចុប្បន្ន រដ្ឋបាលព្រៃឈើមានការលំបាកក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ដោយសារ ពុំមានថវិកា មធ្យោបាយ សម្ភារៈ និងបរិក្ខារសមស្រប។ ដូចនេះ

រដ្ឋបាលព្រៃឈើនឹងផ្តល់ថវិកា មធ្យោបាយ សម្ភារៈ និងបរិក្ខារ ដល់មន្ត្រីពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើ តាមរយៈការរៀបចំគម្រោងសំណើទៅរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

### ៣,១៣.២.២ អភិវឌ្ឍយន្តការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើឱ្យមានប្រសិទ្ធភាព

រដ្ឋបាលព្រៃឈើនឹងធ្វើឱ្យប្រសើរបន្ថែមទៀតនូវយន្តការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ ដែលបាន និងកំពុងអនុវត្តដោយជោគជ័យតាំងពីឆ្នាំ ១៩៩៩ ដោយមានអ្នកតាមដានដោយឯករាជ្យលើឧក្រិដ្ឋកម្មព្រៃឈើចូលរួម។សកម្មភាពដើម្បីធ្វើឱ្យប្រសើរនូវយន្តការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើមានដូចខាងក្រោមៈ

- អភិវឌ្ឍនីតិវិធីតាមដាន និងត្រួតពិនិត្យរបស់មន្ត្រីពង្រឹងការអនុវត្តច្បាប់នៃរដ្ឋបាលព្រៃឈើ
- អភិវឌ្ឍប្រព័ន្ធតាមដាន និងត្រួតពិនិត្យរួមគ្នារវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋានៈ ពិសេសនៅតំបន់ដែលមាន សក្តានុពលអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់
- រៀបចំកូនសៀវភៅណែនាំស្តីពីនីតិវិធីនៃការតាមដាន ត្រួតពិនិត្យការចងក្រងសំណុំរឿង នឹងធ្វើសេចក្តីរាយការណ៍បទល្មើសព្រៃឈើ សម្រាប់មន្ត្រីពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើ
- ធ្វើឱ្យប្រសើរនូវការប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធតាមដានព័ត៌មានបទល្មើសព្រៃឈើ ដែលមាននៅរដ្ឋបាលព្រៃឈើ
- ធ្វើការសិក្សារូបភាពផ្កាយរណបដើម្បីដឹងពីការប្រែប្រួលគម្របធនធានព្រៃឈើ
- លើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការតាមដានបទល្មើសព្រៃឈើ។

### ៣.១៣.២.៣ អភិវឌ្ឍប្រព័ន្ធទំនាក់ទំនងជាមួយស្ថាប័នតុលាការឱ្យមានប្រសិទ្ធភាព

- ភាពខ្វះខាតក្នុងការធ្វើទំនាក់ទំនងជាមួយស្ថាប័នតុលាការ នាំឱ្យការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើមិន មានប្រសិទ្ធភាព។ សកម្មភាពសំខាន់ៗដែលរដ្ឋបាលព្រៃឈើត្រូវអនុវត្តគឺ ៖
- ធ្វើឱ្យប្រសើរទំនាក់ទំនងជាមួយស្ថាប័នតុលាការ ដើម្បីដំណើរការរឿងក្តីបទល្មើសព្រៃឈើឱ្យមានប្រសិទ្ធភាព
- ផ្តល់ការបណ្តុះបណ្តាលនីតិវិធីដែលពាក់ព័ន្ធនឹងវិស័យច្បាប់ដល់មន្ត្រីពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើ និង បង្កើតសៀវភៅគោលការណ៍ណែនាំដល់មន្ត្រីទាំងនោះ
- បង្កើតយន្តការជំនួយផ្នែកច្បាប់ ដើម្បីគាំទ្ររដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីទប់ស្កាត់ និងបង្ក្រាប បទល្មើសព្រៃឈើទ្រង់ទ្រាយធំ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមផ្លូវតុលាការឱ្យមានប្រសិទ្ធភាព ចំពោះបទល្មើសព្រៃឈើទ្រង់ទ្រាយធំ។

### ៣.១៣.២.៤ ធ្វើឱ្យប្រសើរកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើឆ្លងដែន

កិច្ចសហប្រតិបត្តិការតាមព្រំដែនជាមួយប្រទេសជិតខាងនឹងត្រូវធ្វើឱ្យបានស៊ីជម្រៅ និងពង្រឹងថែមទៀត ដើម្បី ប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើឆ្លងដែនប្រកបដោយប្រសិទ្ធភាព។ សកម្មភាពសំខាន់ៗដែលត្រូវអនុវត្តគឺ ៖

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ ដើម្បីទប់ស្កាត់ការកាប់ឈើ និងការធ្វើពាណិជ្ជកម្មឈើ និងសត្វព្រៃខុសច្បាប់ឆ្លងដែន
- អភិវឌ្ឍប្រព័ន្ធផ្តល់ព័ត៌មាន និងទំនាក់ទំនងឆ្លងដែនឱ្យមានប្រសិទ្ធភាពស្តីពីការធ្វើពាណិជ្ជកម្មឈើ និងសត្វព្រៃខុសច្បាប់ដើម្បីធ្វើឱ្យប្រសើរការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងសត្វព
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចតំបន់អាស៊ីខាងកើត វេទិកា ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ចតំបន់អាស៊ាននិងវេទិកាបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃតំបន់អាស៊ាន ដើម្បីពង្រឹងការអនុវត្តច្បាប់ព្រៃឈើនិងសត្វព្រៃ។

### ៣.១៣.២.៥ សហការឱ្យមានប្រសិទ្ធភាពជាមួយអង្គភាពពង្រឹងការអនុវត្តច្បាប់ផ្សេងៗ

ដើម្បីទប់ស្កាត់ និងបង្ក្រាបការធ្វើពាណិជ្ជកម្ម ការធ្វើចរាចរឈើ និងសត្វព្រៃខុសច្បាប់ឱ្យមានប្រសិទ្ធភាព រដ្ឋបាល ព្រៃឈើបន្តធ្វើកិច្ចសហការជាមួយស្ថាប័ន ឬអង្គភាពពង្រឹងការអនុវត្តច្បាប់ផ្សេងៗទៀត។ សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តគឺ ៖

- បង្កើនកិច្ចសហការឱ្យមានប្រសិទ្ធភាពរវាងរដ្ឋបាលព្រៃឈើជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច (ក្រសួងមហាផ្ទៃ) និងអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រក្នុងការចាត់វិធានការបទល្មើសព្រៃឈើ
- រៀបចំវគ្គបណ្តុះបណ្តាលរួមគ្នារវាងមន្ត្រីពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើ និងមន្ត្រីពង្រឹងការអនុវត្តច្បាប់ផ្សេងៗ ទៀតស្តីពីការទំនាក់ទំនង និងការស៊ើបអង្កេតបទល្មើសព្រៃឈើនិងសត្វព្រៃ
- សហប្រតិបត្តិការរួមគ្នាដើម្បីទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើនិងសត្វព្រៃខុសច្បាប់ទ្រង់ទ្រាយធំ។

**៣.១៣.២.៦ អនុវត្តឱ្យមានប្រសិទ្ធភាពយន្តការប្រយុទ្ធប្រឆាំងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធយកដី ព្រៃឈើខុសច្បាប់**

បច្ចុប្បន្នសកម្មភាពកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធវាតយកដីព្រៃឈើដោយខុសច្បាប់ បានកើតមានឡើង នៅក្នុងដែនព្រៃរបស់រដ្ឋ ទាំងព្រៃដាំ និងព្រៃធម្មជាតិ។ ផ្អែកតាមច្បាប់ដែលមានជាធរមាន រាជរដ្ឋាភិបាលបានបង្កើតយន្តការនិងនីតិវិធីដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាពខុសច្បាប់ទាំងនេះ។ សកម្មភាពដែលត្រូវអនុវត្តគឺៈ

- បង្កើនសមត្ថភាព និងពង្រឹងអនុគណៈកម្មាធិការខេត្ត ដើម្បីស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ
- បង្កើតវេទិកាដោះស្រាយទំនាស់នៅមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃឈើ តាមនីតិវិធី
- ជំរុញការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបទល្មើសការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃខុសច្បាប់ ដល់អ្នកពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព
- ចាត់វិធានការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើ កម្មសិទ្ធិឱ្យមានប្រសិទ្ធភាព ដោយធ្វើការស្រាវជ្រាវរកមេក្លោង និងអ្នករួមសមគំនិតក្នុងចលនាបង្កឱ្យមានការកាប់រាន ហ៊ុមព័ទ្ធ និងបែងចែកដីព្រៃឈើដោយខុសច្បាប់បញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តតាមនីតិវិធី ព្រមទាំងធ្វើការ ស្រាវជ្រាវជីវប្រវត្តិជនចំណាកស្រុកដែលបានបោះទីតាំងសង់លំនៅឋានដោយអនាធិបតេយ្យក្នុងតំបន់ព្រៃឈើ ដើម្បី កំណត់ឱ្យចំមុខសញ្ញា នឹងចាត់វិធានការ ឱ្យបានសមស្រប។
- ស្វែងរក និងផ្តល់ថវិកាដល់គណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការ កាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើវាតយកដីធ្វើកម្មសិទ្ធិ និងរដ្ឋបាលព្រៃឈើ (នាយកដ្ឋាននីតិកម្ម និង ពង្រឹងការអនុវត្តច្បាប់) ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ កំណត់អត្តសញ្ញាណ ស្រង់ស្ថិតិ និងដកហូតដីព្រៃឈើ ដែលបានកាប់រាន និងហ៊ុមព័ទ្ធខុសច្បាប់មកទុកជាសម្បត្តិរដ្ឋ ការរៀបចំផែនទីទីតាំងដីដកហូត ស្លាកសញ្ញា បោះ បង្គោលព្រំ ការដាំដុះព្រៃឈើ ការស្រង់ស្ថិតិ និងដកហូតរណារយន្តកាត់ឈើគ្រប់ប្រភេទ ការផ្សព្វផ្សាយច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត និងការចាត់វិធានការទប់ស្កាត់ និងបង្ក្រាបតាមប្រព័ន្ធតុលាការ។ល។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការ កាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្ម

សិទ្ធិ និងបញ្ឈប់ ការទិញ លក់ និងផ្ទេរសិទ្ធិ កាន់កាប់ដីព្រៃឈើ ដែលស្ថិតនៅក្នុងផែនទីគម្របព្រៃឈើឆ្នាំ២០០២។

**៣.១៣.២.៧ ក្រុមការងារពង្រឹងការអនុវត្តច្បាប់ ដើម្បីកាត់បន្ថយ និងលុបបំបាត់សកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទ រដ្ឋបាលព្រៃឈើនឹងបង្កើតក្រុមការងារ**

ពង្រឹងការអនុវត្តច្បាប់របស់នាយកដ្ឋាននីតិកម្មនឹងពង្រឹងការអនុវត្តច្បាប់ដើម្បីចុះត្រួតពិនិត្យទប់ស្កាត់ និងបង្ក្រាបបទល្មើស ព្រៃឈើទូទាំងប្រទេស សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រង ការពារ និងអភិវឌ្ឍព្រៃឈើប្រកបដោយប្រសិទ្ធភាព។ សកម្មភាព សំខាន់ៗរបស់ក្រុមការងារនេះមានដូចខាងក្រោម ៖

- ត្រួតពិនិត្យ តាមដាន ស្រាវជ្រាវ ស៊ើបអង្កេត និងចុះអន្តរាគមន៍បង្ក្រាបរាល់សកម្មភាពបទល្មើសក្នុងវិស័យព្រៃឈើ ដើម្បីពង្រឹងការអនុវត្តច្បាប់
- ចុះស្រាវជ្រាវដល់មូលដ្ឋានដើម្បីតាមដាន និងវាយតម្លៃលើការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើមូលដ្ឋាន ហើយដាក់ វិធានការពង្រឹង និងណែនាំឱ្យអនុវត្តស្របតាមនីតិវិធីច្បាប់
- សហការជាមួយអាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ និងអង្គភាពពាក់ព័ន្ធនានា ដើម្បីពង្រឹងការអនុវត្តច្បាប់
- ធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យព្រៃឈើដល់មូលដ្ឋាន។

**៣.១៣.៣ លទ្ធផលរំពឹងទុក**

- មានមធ្យោបាយ សម្ភារៈ និង បរិក្ខារ ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- ការងារតាមដាន ការស៊ើបអង្កេត ការប្រមូលព័ត៌មាន ការបញ្ចូលទិន្នន័យ និងការធ្វើសេចក្តីរាយការណ៍ ព័ត៌មាន, និងទិន្នន័យបទល្មើសព្រៃឈើគ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព
- ដំណើរការជំនុំជម្រះក្តីលើសំណុំរឿងបទល្មើសព្រៃឈើដោយតុលាការ មានប្រសិទ្ធភាព ធ្វើឱ្យប្រជាជនគោរព និងអនុវត្តច្បាប់
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានធ្វើការផ្សព្វផ្សាយទូលំទូលាយដល់ប្រជាជន និងអ្នកពាក់ព័ន្ធ
- មានការយកចិត្តទុកដាក់ខ្ពស់ដល់ប្រជាជនមូលដ្ឋាន ដើម្បីឱ្យមានការចូលរួមគ្រប់គ្រងព្រៃឈើតាមបែបសហគមន៍
- មានកិច្ចសហការប្រកបដោយប្រសិទ្ធភាពជាមួយអង្គភាពពង្រឹងការអនុវត្តច្បាប់ផ្សេងៗដើម្បីកាត់បន្ថយបទល្មើសព្រៃឈើគ្រប់ប្រភេទ ធ្វើឱ្យការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ

- ការទប់ស្កាត់ និងបង្ក្រាបការកាប់រាន និងក្រុមព័ទ្ធដីព្រៃឈើខុសច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមថែរក្សាគម្របព្រៃឈើ ឱ្យបាន ៦០% នៅឆ្នាំ ២០១៥ ទៅតាមគោលដៅអភិវឌ្ឍសហសវត្ស
- បទល្មើសព្រៃឈើត្រូវបានកាត់បន្ថយ និងលុបបំបាត់
- មានកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងជាមួយប្រទេសជិតខាង តំបន់ និងអន្តរជាតិក្នុងការទប់ស្កាត់ និងបង្ក្រាបការធ្វើ ពាណិជ្ជកម្មឈើ និងសត្វព្រៃឆ្លងដែន។

## ៣.១៤ អនុកម្មវិធីទី ៣ ការឆ្លើយតបរហ័សចំពោះព័ត៌មានបទឧក្រិដ្ឋកម្មពឈើ

### ៣.១៤.១ សេចក្ដីអធិប្បាយ

រាជរដ្ឋាភិបាលបានបង្កើតយន្តការឆ្លើយតបរហ័សចំពោះព័ត៌មាន ដែលបានចុះផ្សាយតាមបណ្ដាញសារព័ត៌មាន ដើម្បីធ្វើឱ្យ ប្រសើរដល់ដំណើរការការងាររបស់ក្រសួង និងស្ថាប័ននានា។ យន្តការនេះស្ថិតក្រោមទីស្ដីការគណៈរដ្ឋមន្ត្រី ដែលមានភារកិច្ច ប្រមូល វិភាគ កត់ត្រាទិន្នន័យ និងធ្វើរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារជូនរាជរដ្ឋាភិបាល។

ផ្ដើមចេញពីនេះ រដ្ឋបាលព្រៃឈើនឹងបង្កើតក្រុមការងារឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើនៅថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន។ ក្រុមការងារនៅថ្នាក់កណ្ដាលមានភារកិច្ចប្រមូល វិភាគ និងកត់ត្រាព័ត៌មានបទល្មើសព្រៃឈើគ្រប់ប្រភេទដែលបាន ផ្សព្វផ្សាយក្នុងបណ្ដាញសារព័ត៌មាន ហើយធ្វើសេចក្ដីរាយការណ៍ជូនប្រធានរដ្ឋបាលព្រៃឈើ ដើម្បីចាត់វិធានការទៅតាមការចាំបាច់។ រីឯក្រុមការងារនៅថ្នាក់មូលដ្ឋាននឹងរៀបចំរបាយការណ៍ជូនរដ្ឋបាលព្រៃឈើ អំពីលទ្ធផលនៃចំណាត់ការក្រោយទទួលបានព័ត៌មានបទល្មើស ព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាន។ កិច្ចសហការជាមួយអ្នកសារព័ត៌មាន និងអ្នកផ្ដល់ព័ត៌មាន គឺមានសារៈសំខាន់ណាស់ក្នុង ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសព្រៃឈើ និងសត្វព្រៃ រួបមានការចាប់ឈើខុសច្បាប់ ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្ម ឈើ និងសត្វព្រៃល្មើសច្បាប់ និងការកាប់រាននឹងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់ផងដែរ។

### ៣.១៤.២ មធ្យោបាយអនុវត្ត

#### ៣.១៤.២.១ ក្រុមការងារឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្ដាល

ក្រុមការងារនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាននីតិកម្មនឹងពង្រឹងការអនុវត្តច្បាប់ ដោយមានភារកិច្ចពិនិត្យនិងឆ្លើយបំភ្លឺចំពោះព័ត៌មានបទល្មើសព្រៃឈើដែលបានចុះផ្សាយតាមបណ្ដាញសារព័ត៌មាន។ សកម្មភាពរបស់ក្រុមការងារ នេះគឺ៖

- តាមដាន និង ស្រង់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ សត្វព្រៃ និងដីព្រៃឈើក្នុងបណ្តាញផ្សព្វផ្សាយនានា
- ធ្វើការវិភាគ នឹងចាត់ថ្នាក់ពីព័ត៌មានពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ សត្វព្រៃ និងដីព្រៃឈើ ហើយបញ្ជូនទៅរដ្ឋបាលព្រៃឈើ មូលដ្ឋាន ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងចាត់វិធានការតាមនីតិវិធី និងធ្វើរបាយការណ៍បំភ្លឺតាមការចាំបាច់
- ពិនិត្យមើលរបាយការណ៍បំភ្លឺដែលបានទទួលពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងរៀបចំរបាយការណ៍ឆ្លើយបំភ្លឺព័ត៌មាន ពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ ជូនប្រធានរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ ស្ថាប័នផ្សេងៗទៀតក្នុងករណីចាំបាច់
- ទំនាក់ទំនងជាមួយស្ថាន និងអង្គភាព ដែលសារព័ត៌មានចុះផ្សាយបញ្ហាពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ ដើម្បីសហការ ចុះពិនិត្យស្រាវជ្រាវ ផ្ទៀងផ្ទាត់ព័ត៌មាន និងចាត់វិធានការតាមនីតិវិធី
- ចុះពិនិត្យស្រាវជ្រាវ ផ្ទៀងផ្ទាត់ព័ត៌មាន និងចាត់វិធានការតាមនីតិវិធីចំពោះបទល្មើសព្រៃឈើនៅទីវាលជាក់ស្តែងក្នុង ករណីចាំបាច់ ឬដើម្បីឱ្យប្រាកដថា ព័ត៌មានបទល្មើសព្រៃឈើក្នុងសារព័ត៌មាន ឬរបាយការណ៍ឆ្លើយបំភ្លឺព័ត៌មានបទល្មើសព្រៃឈើរបស់រដ្ឋបាលព្រៃឈើមូលដ្ឋានមានភាពពិត និងមានតម្លាភាព
- លើកសំណើជូនប្រធានរដ្ឋបាលព្រៃឈើពិនិត្យ និងសម្រេច ក្នុងករណីរកឃើញភស្តុតាងថាមានមន្ត្រីរដ្ឋបាលព្រៃឈើ ឬមន្ត្រីស្ថាប័ន ឬអង្គភាព ឬមន្ត្រីអាជ្ញាធរមូលដ្ឋាន មានជាប់ពាក់ព័ន្ធនឹងសកម្មភាពបទល្មើសព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាន
- បញ្ចូលព័ត៌មាន និង របាយការណ៍ចំភ្លឺបទល្មើសព្រៃឈើទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ចែករំលែកព័ត៌មានបទល្មើសព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាន និងរបាយការណ៍បំភ្លឺក្នុងគេហទំព័រ រដ្ឋបាល ព្រៃឈើក្នុងករណីចាំបាច់
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីពង្រឹងការងារស៊ើបអង្កេត និងប្រតិកម្មរហ័ស ឱ្យបានទូលំ ទូលាយក្នុងទូទាំងប្រទេស។

### ៣.១៤.២.២ ក្រុមការងារឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋាន

ក្រុមការងារឆ្លើយតបព័ត៌មានបទល្មើសព្រៃឈើនៅថ្នាក់មូលដ្ឋាន (នៅអធិការដ្ឋាន ឬខណ្ឌរដ្ឋបាលព្រៃឈើ) ត្រូវ បានបង្កើតឡើង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងឆ្លើយតបទៅនឹងព័ត៌មានបទល្មើសព្រៃឈើក្នុងសារព័ត៌មាន។ ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យមើលព័ត៌មានបទល្មើសព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាន ចុះពិនិត្យស្រាវជ្រាវផ្ទៀងផ្ទាត់ព័ត៌មាន និង ចាត់វិធានការតាមនីតិវិធីដោយសហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និង អង្គភាពពាក់ព័ន្ធនៅមូលដ្ឋាន
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងអង្គភាពនានានៅមូលដ្ឋាន ដែលសារព័ត៌មានបានចុះផ្សាយថា មានការពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ ដើម្បីសហការចុះពិនិត្យស្រាវជ្រាវ ផ្ទៀងផ្ទាត់ ព័ត៌មាន និងដោះស្រាយតាម នីតិវិធីក្នុងករណីចាំបាច់
- លើកសំណើជូនថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើពិនិត្យ និងសម្រេចក្នុងករណីរកឃើញភស្តុតាងថាមានមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ឬមន្ត្រីអាជ្ញាធរមូលដ្ឋាន ឬមន្ត្រីអង្គភាពនៅមូលដ្ឋាន ជាប់ពាក់ព័ន្ធនឹងសកម្មភាពបទល្មើសព្រៃឈើដែលបាន ចុះផ្សាយក្នុងសារព័ត៌មាន
- រៀបចំរបាយការណ៍ឆ្លើយតបព័ត៌មានបទល្មើសព្រៃឈើជូនរដ្ឋបាលព្រៃឈើ បញ្ចូលព័ត៌មាន និងរបាយការណ៍ចំភ្លឺបទល្មើសព្រៃឈើទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

### ៣.១៤.២.៣ កិច្ចសហការឱ្យមានប្រសិទ្ធភាពជាមួយអ្នកសារព័ត៌មាន និងអ្នកផ្តល់ព័ត៌មាន

រដ្ឋបាលព្រៃឈើនឹងសហការឱ្យបានជិតស្និទ្ធជាមួយអ្នកសារព័ត៌មាន និងអ្នកផ្តល់ព័ត៌មាន ដើម្បីអភិវឌ្ឍយន្តការឆ្លើយតប និងធ្វើរបាយការណ៍បំភ្លឺប្រកបដោយសមត្ថភាព និងប្រសិទ្ធភាពចំពោះបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃខុស ច្បាប់។ វិធានការមួយចំនួននឹងត្រូវយកមកអនុវត្ត ដើម្បីឱ្យព័ត៌មានបទល្មើសព្រៃឈើដែលបានចុះផ្សាយដោយសារព័ត៌មានឬផ្តល់ឱ្យដោយអ្នកផ្តល់ព័ត៌មានមានវិជ្ជាជីវៈត្រឹមត្រូវ និងពិតប្រាកដ។ សកម្មភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំកិច្ចប្រជុំរវាងរដ្ឋបាលព្រៃឈើ និងអ្នកផ្តល់ព័ត៌មាន ឬអ្នកសារព័ត៌មាន ដើម្បីរកវិធីសហការគ្នាឱ្យបានសមស្រប
- ធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់ដល់អ្នកសារព័ត៌មាន
- រៀបចម្ការបណ្តុះបណ្តាលអំពីប្រភេទ និងការស៊ើបអង្កេតបទល្មើសព្រៃឈើ រៀបចំទស្សនកិច្ចសិក្សាសម្រាប់អ្នកសារព័ត៌មាននៅទីតាំងកើតមានបទល្មើសព្រៃឈើ
- ផ្ទៀងផ្ទាត់រួមគ្នានូវព័ត៌មានបទល្មើសព្រៃឈើក្នុងករណីចាំបាច់
- ចែករំលែកព័ត៌មានបទល្មើសព្រៃឈើ
- ស្វែងរកថវិការដើម្បីផ្សព្វផ្សាយព័ត៌មានអំពីចំណាត់ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ
- បង្កើតប្រព័ន្ធទូរស័ព្ទមិនបង់ប្រាក់ (Free Telephane Hotline) និងប្រព័ន្ធផ្ញើសារ (SMS) រាយការណ៍ពីបទល្មើសព្រៃឈើសម្រាប់ទទួលព័ត៌មានបទល្មើសព្រៃឈើពីសាធារណជន និងបង្កើតមូលដ្ឋានប្រព័ន្ធទិន្នន័យសម្រាប់ផ្ទុកព័ត៌មានទាំងនេះ

- ថែទាំ នឹងពង្រីកការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវប្រព័ន្ធវិទ្យុទាក់ទង ដែលមាននៅតាមអង្គភាពរដ្ឋបាលព្រៃឈើ ដើម្បីបង្កើនការផ្តល់ព័ត៌មាន
- បង្កើតប្រអប់សំបុត្រទទួលពីត៌មាន នៅតាមស្នាក់ការរបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីទទួលព័ត៌មានបទល្មើសព្រៃឈើ និងមតិយោបល់កែលំអផ្សេងៗ។

### ៣.១៤.៣ លទ្ធផលរំពឹងទុក

- ក្រុមការងារឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាននឹងធ្វើការ
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានបទល្មើសព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាន និងចាត់វិធានការតាមនីតិវិធីច្បាប់
- មានកិច្ចសហការកាន់តែល្អប្រសើរឡើងថែមទៀតជាមួយអ្នកសារព័ត៌មាន និងអ្នកផ្តល់ព័ត៌មាន
- មានថវិកាគ្រប់គ្រាន់ដើម្បីគាំទ្រដល់ដំណើរការឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើ។

## ៣.១៥ ការជាប់ទាក់ទងនឹងកម្មវិធី (Cross-cutting implications)

### ៣.១៥.១ គោលនយោបាយ និង ច្បាប់

កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច មានជាប់ទាក់ទងទៅនឹងការរៀបចំ និងអនុវត្តគោលនយោបាយនឹងច្បាប់របស់រាជរដ្ឋាភិបាលដូចខាងក្រោម ៖

- រៀបចំលិខិតបទដ្ឋានក្រោមច្បាប់ស្តីពីព្រៃឈើ
- ពិនិត្យមើលលិខិតបទដ្ឋានគតិយុត្តដែលមាន និងបង្កើតថ្មីបន្ថែមតាមការចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ សហសវត្សកម្ពុជា ដែលប្តេជ្ញារក្សាតម្របព្រៃឈើចំនួន ៦០% នៅឆ្នាំ ២០១៥
- ចូលរួមក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងកាត់បន្ថយភាពក្រីក្រស្របតាមសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយវិស័យព្រៃឈើជាតិ
- ពង្រឹងការអនុវត្តច្បាប់ និងការផ្សព្វផ្សាយដើម្បីកាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ
- ធ្វើឱ្យប្រាកដថា ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុវត្តដោយស្ថាប័ននិងអង្គភាពនានាពាក់ព័ន្ធនឹងវិស័យព្រៃឈើ
- ធ្វើឱ្យប្រាកដថា ច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានក្រោមច្បាប់ស្តីពីព្រៃឈើ ត្រូវបានអនុវត្តដោយប្រជាជនគ្រប់ស្រទាប់ វណ្ណៈក្នុងសង្គម

- ជំរុញឱ្យមានការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើបសហគមន៍
- សហការជិតស្និទ្ធជាមួយស្ថាប័នពង្រឹងការអនុវត្តច្បាប់ដទៃទៀតក្នុងការកាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើដោយចីរភាព និងកាត់បន្ថយភាពក្រីក្រ។

### ៣.១៥.២ កំណែទម្រង់ និងទំនាក់ទំនងស្ថាប័ន

ដើម្បីធ្វើឱ្យការគ្រប់គ្រង ការពារ និងអភិវឌ្ឍព្រៃឈើកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ កម្មវិធីពង្រឹងការអនុវត្តច្បាប់ ស្តីពីព្រៃឈើ និងអភិបាលកិច្ច មានទំនាក់ទំនងជាមួយការកែទម្រង់ស្ថាប័នដូចខាងក្រោម ៖

- ពង្រឹងការងាររដ្ឋបាលដល់រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យមានសមត្ថភាព និង ប្រសិទ្ធភាពខ្ពស់
- មន្ត្រីរដ្ឋបាលព្រៃឈើនឹងអាចបំពេញការងារមានសមត្ថភាព និងប្រសិទ្ធភាពតាមរយៈការអភិវឌ្ឍសមត្ថភាព និងការធ្វើអធិការកិច្ច
- ធ្វើឱ្យមានប្រសិទ្ធភាពដល់ការងារតាមដានស្រាវជ្រាវ ប្រមូល បញ្ចូលទិន្នន័យ និងព័ត៌មានបទល្មើសព្រៃឈើ និងការធ្វើ សេចក្តីរាយការណ៍
- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ឱ្យមានសមត្ថភាពស្រាវជ្រាវ និងចងក្រងសំណុំរឿងបទល្មើសព្រៃឈើ បញ្ជូនទៅតុលាការ និងធ្វើបច្ចុប្បន្នភាពសំណុំរឿងដែលស្ថិតក្នុងសមត្ថកិច្ចតុលាការ។

### ៣.១៥.៣ តម្រូវការហិរញ្ញវត្ថុ

តារាងទី៣ ៖ គម្រោងថវិកា សម្រាប់កម្មវិធី ពង្រឹងច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ឆ្នាំ ២០១០-២០២០

| អនុកម្មវិធី | ថវិកាប៉ាន់ស្មានក្នុងឆ្នាំ ២០១០-២០១៤ (ដុល្លាអាមេរិក) | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ ២០១៥-២០២០ (ដុល្លាអាមេរិក) |
|---|---|---|
| ៣.១ ការកែទម្រង់ច្បាប់ និង រដ្ឋបាល | ៤៨៨.០០០ | ៤៨០.០០០ |
| ៣.២ ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាន និងរាយ ការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ | ៩៤៤.០០០ | ៩៤៤.០០០ |

| | | |
|---|---|---|
| ៣.៣ ការឆ្លើយតបរហ័សចំពោះព័ត៌មានបទឧក្រិដ្ឋកម្មព្រៃឈើ | ៥៦៨.០០០ | ៥៦៨.០០០ |
| សរុប | ២.០០០.០០០ | ២.០០០.០០០ |
| ថវិកាបរិច្ចាគមកពីដៃគូអភិវឌ្ឍន៍ | ១៥០០០០០ | |

សន្មតថា ចំណូលពីព្រៃឈើនឹងត្រូវធ្វើការវិនិយោគឡើងវិញទៅក្នុងផ្នែកនិងការងារខាងលើនេះ ដែលជាលទ្ធផល នឹងធ្វើឱ្យការអនុវត្ត ការងារនេះកាន់តែមានលក្ខណៈស្វ័យហិរញ្ញប្បទានសមស្រប និង មានសង្គតិភាពជាមួយនឹង កម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាព សម្រាប់វិស័យព្រៃឈើ។ ចំណែកឯថវិកាបរិច្ចាគពីដៃគូអភិវឌ្ឍន៍នឹងកាន់តែមានការថយចុះបន្តិចម្តងៗ នៅជំហានទី២ ដែលមាន រយៈពេល៥ឆ្នាំទៀត។

## ៨.៤ កម្មវិធីទី៤ សហគមន៍ឈើ

### ៤.១ ចំណុចអាទិភាពសំខាន់ៗ

- វិមជ្ឈការការគ្រប់គ្រងព្រៃឈើ៖ (សហគមន៍ព្រៃឈើ សហគមន៍ព្រៃផ្តល់ផល ព្រៃឈើដៃគូ នឹង សហគមន៍ព្រៃការពារ)
- កំណត់តំបន់សក្តានុពលព្រៃសហគមន៍ និងបង្កើតសហគមន៍ព្រៃឈើ
- ពង្រឹងសមត្ថភាព អភិវឌ្ឍសហគមន៍ និងបង្កើនជីវភាព
- ផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

### ៤.២ រយៈពេលកម្មវិធី

មានរយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ២០២៩

### ៤.៣ ការឆ្លើយតបទៅនឹងទស្សនវិស័យនៃកម្មវិធីព្រៃឈើជាតិ

កម្មវិធីសហគមន៍ព្រៃឈើ ដែលអនុលោមតាមគោលការណ៍យុទ្ធសាស្ត្រនៃកម្មវិធីព្រៃឈើជាតិ មានដូចខាងក្រោម ៖

- គោលបំណងនេះ គឺដូចមាននៅក្នុងកម្មវិធីសហគមន៍ព្រៃឈើដែលបានអភិវឌ្ឍនៅឆ្នាំ ២០០៦ ដែលនឹងត្រូវបន្តអនុវត្តឱ្យបានទូលំទូលាយតាមបែបវិមជ្ឈការនៃការគ្រប់គ្រងព្រៃឈើឱ្យបានពីរលានហិកតា

- ដោយផ្អែកលើគោលការណ៍ជំនួយឧបត្ថម្ភ សហគមន៍ ព្រៃឈើជាជម្រើសដ៏ប្រសើរបំផុតក្នុងការធ្វើសេចក្ដីសម្រេចចិត្តរួមគ្នា ស្ដីពីការប្រើប្រាស់ធនធានព្រៃឈើសម្រាប់ជាប្រយោជន៍សហគមន៍ហើយសហគមន៍ព្រៃឈើនឹងរួមចំណែកធ្វើ ឱ្យប្រសើរឡើងកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍ជនបទ កាត់បន្ថយភាពក្រីក្រ។ សហគមន៍ព្រៃឈើនឹង ទទួលបានផលប្រយោជន៍ដោយផ្ទាល់ និងធានាបាននូវសុវត្ថិភាពចំពោះធនធានព្រៃឈើដែលសហគមន៍បានប្រើប្រាស់ដោយប្រសិទ្ធភាពតាមតម្រូវការ និងជាទុនវិនិយោគក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទម្រង់ផ្សេងៗគ្នា ជាដៃគូ និង ការចូលរួមគ្រប់គ្រងព្រៃឈើ គឺជាបែបបទគន្លឹះរបស់សហគមន៍ព្រៃឈើ
- កម្មវិធីនេះនឹងអភិវឌ្ឍ និងពង្រឹងដល់រចនាសម្ព័ន្ធគ្រប់គ្រងនិងក្របខណ្ឌច្បាប់សម្រាប់អភិវឌ្ឍសហគមន៍ព្រៃឈើដើម្បីបង្កើនការ
- ចូលរួមនិងគាំទ្រពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ជាទំលាប់ សហគមន៍ព្រៃឈើមានតុល្យភាពពហុប្រយោជន៍ពីព្រៃឈើ រួមមានអភិរក្សជីវចម្រុះ និងបរិស្ថាន ក៏ដូចជាផលិតផល ឈើសំណង់ ឈើថាមពល អនុផលព្រៃឈើជាច្រើនប្រភេទទៀតដែលសម្រាប់ប្រើប្រាស់ផ្ទាល់ ឬ លក់។

## ៤.៤ ការឆ្លើយតបរបស់កម្មវិធីទៅនឹងគោលបំណងកម្មវិធីព្រៃឈើជាតិ

កម្មវិធីសហគមន៍ព្រៃឈើរួមចំណែកដោយផ្ទាល់ដល់គោលបំណងរបស់កម្មវិធីព្រៃឈើជាតិដែលមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម ៖

- គ្រប់ទម្រង់សហគមន៍ព្រៃឈើមានគោលបំណងគ្រប់គ្រងតំបន់ព្រៃសហគមន៍ប្រកបដោយនិរន្តរភាព ដែលជាផ្នែកមួយនៃតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍។ គ្រប់តំបន់ព្រៃសហគមន៍ នឹងមានការបោះព្រំប្រទល់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអតិន្ត្រៃយ៍ និងចុះបញ្ជីដីសាធារណៈរបស់រដ្ឋ
- ពហុបំណងនៃការគ្រប់គ្រងព្រៃឈើ គឺអាស្រ័យលើការសម្រេចលើផែនការគ្រប់គ្រង ដែលធានាឱ្យមាននិរន្តរភាព ដូចជាការ អភិរក្សជីវចម្រុះ និងបរិស្ថាន ដោយផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ចសង្គម សមធម៌ និងអភិបាលកិច្ច
- សហគមន៍ព្រៃឈើអនុញ្ញាតឱ្យសមាជិកសហគមន៍ទាំងអស់ចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងទទួលខុសត្រូវជាមួយ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដែលកើតឡើងពីការបោះឆ្នោតជ្រើសរើសដោយសមាជិកសហគមន៍។ មូលដ្ឋានន ការអភិវឌ្ឍរចនាសម្ព័ន្ធសហគម

ន៍ និងអភិបាលកិច្ចប្រជាធិតយ្យ គឺជាគោលបំណងតែមួយ ហើយទម្រង់ផ្សេងៗនៃសហគមន៍ព្រៃឈើនឹងគាំទ្រដល់គោលបំណងនេះ

- សហគមន៍មូលដ្ឋានអាចគៀងគរចលនាមហាជនដើម្បីការពារព្រៃឈើ បើសិនជាមហាជនយល់ថាគាត់ទទួលបានផលប្រយោជន៍ ពីការចូលរួមគ្រប់គ្រងព្រៃឈើនោះ។ ផល់ប្រយោជន៍នៃហេតុផលទាំងនេះអាចជួយដល់ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើផងដែរ
- ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អាចជួយជំរុញដោយទម្រង់ផ្សេងៗនៃសហគមន៍ព្រៃឈើ
- សហគមន៍ព្រៃឈើមានឥទ្ធិពលយ៉ាងខ្លាំងចំពោះផលប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដូចនេះកម្មវិធីនេះចាំបាច់ត្រូវពង្រីក តំបន់គោលដៅនិងក្របខ័ណ្ឌច្បាប់ឱ្យបានទូលំទូលាយ និងពង្រឹងសមត្ថភាព និងផ្តល់ផលប្រយោជន៍ទៅសហគមន៍ព្រៃឈើឱ្យ បានឆាប់រហ័ស
- កម្មវិធីនេះនឹងអភិវឌ្ឍនូវគំរូដ៏មានប្រសិទ្ធភាពថែមទៀតដើម្បីគាំទ្រដល់សហគមន៍ក្នុងការអភិវឌ្ឍការគ្រប់គ្រងព្រៃឈើនិងអភិបាលកិច្ចប្រកបដោយនិរន្តភាព ការប្រើប្រាស់ ការកែច្នៃ ទីផ្សារ និងទទួលបាននូវផលប្រយោជន៍ផ្សេងៗទៀត
- សហគមន៍ព្រៃឈើបែបអភិរក្សនឹងអាចជួយផ្តល់ដល់ការកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ លើសពីនេះ តាមរយៈ សហគមន៍បែបអភិរក្សមានសក្តានុពលសម្រាប់ការលក់ឥណទានកាបូន នឹងក៏ជាជម្រើសដ៏ប្រសើរមួយក្នុងការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាព។ ប្រាក់ចំណូលដលទទួលបានពីការលក់ឥណទានកាបូន នឹងរួមចំណែកជួយដល់សហគមន៍ឱ្យមានស្វ័យភាព ហិរញ្ញវត្ថុដោយនិរន្តរភាព។

## ៤.៥ សារៈសំខាន់នៃកម្មវិធី

សហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងតាំងពីពាក់កណ្តាលទសវត្សទី៩០ តាមរយៈគម្រោងសាកល្បងដោយមានការគាំទ ពីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។ សហគមន៍ព្រៃឈើមានសក្តានុពលក្នុងការការពារព្រៃឈើ និងធ្វើឱ្យប្រសើរ ឡើងនូវផលិតភាពព្រៃឈើ និងសមត្ថភាព ដើម្បីគាំទ្រដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ព្រមទាំងរក្សាបាននូវលំនឹងប្រព័ន្ធ អេកូឡូស៊ី និងការពារទីជម្រាល។

- ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២បានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលព្រៃឈើក្នុងការសិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ដើម្បីបង្កើត ជាព្រៃសហគមន៍ សម្រាប់សហគមន៍មូលដ្ឋានធ្វើការគ្រប់គ្រង និងទាញយកផលប្រយោជន៍ពីធនធានព្រៃឈើ
- នៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្របានតម្រូវឱ្យគ្រប់វិស័យទាំងអស់ចូលរួមចំណែកសម្រេចគោលដៅជាតិក្នុងការ កាត់បន្ថយភាពក្រីក្រ។ លើសពីនេះទៀត គោលដៅអភិវឌ្ឍន៍

សហសវត្សកម្ពុជាបានបញ្ជាក់ថា ត្រូវរក្សាគម្របព្រៃឈើឱ្យបាន ៦០% នៅឆ្នាំ២០១៥។ គោលនយោបាយនេះត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤ នៅក្នុងចតុកោណទី ១ មុំទី៤ ស្តីពីកំណែទម្រង់វិស័យព្រៃឈើ និងត្រូវបានដាក់បញ្ចូលបន្ថែមផងដែរក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី ២ ក៏បានចាត់ទុកសហគមន៍ព្រៃឈើជាការងារអាទិភាពក្នុងការគ្រប់គ្រងព្រៃឈើ។ រដ្ឋាភិបាលនឹងបន្តតាមដាន វាយតម្លៃប្រសិទ្ធភាពកម្មវិធីលើកកម្ពស់កម្រិតជីវភាពប្រជាជនជនបទ និងថែរក្សាចីរភាពព្រៃឈើ និងជំរុញការអនុវត្តព សហគមន៍ឱ្យកាន់តែទូលំទូលាយ។

- នៅពេលថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកទឹកចិត្តដល់សហគមន៍ព្រៃឈើ ថែរក្សាការពារព្រៃឈើនិងផ្តល់អាទិភាព ជាគោលការណ៍សម្រាប់ការលក់ឥណទានកាបូនព្រៃឈើក្នុងទីផ្សារកាបូន និងការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើកាលពីខែធ្នូ ឆ្នាំ២០០៣ គឺ ជារបត់ប្រវត្តិសាស្ត្រថ្មីនៃការគ្រប់គ្រង សហគមន៍ព្រៃឈើតាមបែបមិនផ្លូវការទៅជាផ្លូវការ ដោយទទួលស្គាល់ពីរាជរដ្ឋាភិបាល ហើយនេះគឺជាចំណុចចាប់ផ្តើមដែលសហគមន៍ព្រៃឈើត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិ ព្រមទាំងមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាផងដែរ
- តាមរយៈរបាយការណ៍ និងការផ្តល់អនុសាសន៍របស់ក្រុមវាយតម្លៃព្រៃឈើឯករាជ្យឆ្នាំ២០០៤ បន្ទាប់ពីបានធ្វើកាសិក្សា ស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យព្រៃឈើ ក្រុមវាយតម្លៃបានសំណូមពរឱ្យបន្តគាំទ្រការអនុវត្ត
- សហគមន៍ព្រៃឈើ ដោយផ្តោតលើការអភិវឌ្ឍសហគមន៍ ដើម្បីធ្វើឱ្យសហគមន៍ព្រៃឈើជានាបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុនិងអាចគ្រប់គ្រងបានដោយខ្លួនឯងប្រកបដោយនិរន្តរភាព។ របាយការណ៍ក៏បានផ្តល់អនុសាសន៍បន្ថែមឱ្យមានការសាកល្បង អនុវត្តគម្រោងព្រៃឈើដៃគូ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០០៦-២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានបញ្ជាក់បន្ថែមពីសារៈសំខាន់នៃការបង្កើតសហគមន៍ព្រៃឈើផងដែរ
- ដោយផ្អែកលើអនុសាសន៍ និងការវិភាគសេដ្ឋកិច្ចរបស់ក្រុមវាយតម្លៃព្រៃឈើឯករាជ្យ និងផ្អែកលើផលិតភាពព្រៃឈើដែលមាន ស្រាប់ និងតម្លៃឈ្នួលតាមផ្លូវការ និងមិនផ្លូវការនោះ ក្រុមវាយតម្លៃព្រៃឈើ ឯករាជ្យបានផ្តល់អនុសាសន៍ថា សម្រាប់ឃុំដែល មានផ្ទៃដីព្រៃប្រមាណជា ៥.០០០ ហ.ត ហើយជាប្រភេទ ព្រៃដែលមានតម្លៃសេដ្ឋកិច្ចនោះ គេអាចទទួលប្រាក់ចំណូលចំនួន ប្រហែល ១៥០០០០ ដុល្លារអាមេរិកក្នុង ១ឆ្នាំ (GFA II 2005)
- ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ត្រូវបានអនុម័ត និងចុះហត្ថលេខាជាផ្លូវការនៅឆ្នាំ២០០៦ ដើម្បីជា មូលដ្ឋានក្នុងការរៀបចំ អនុវត្ត និងគ្រប់គ្រងសហគមន៍ព្រៃឈើ

- កម្មវិធីសហគមន៍ព្រៃឈើជាតិ ត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍ សហគមន៍ព្រៃឈើក្រោម ការដឹកនាំរបស់រដ្ឋបាលព្រៃឈើ ហើយបានផ្សព្វផ្សាយជាសាធារណៈនៅខែឧសភា ឆ្នាំ២០០៦។ គោលបំណងសំខាន់ន កម្មវិធី គឺរៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការដល់សហគមន៍ព្រៃឈើដែលបានបង្កើត។ គោលបំណងផ្សេងទៀត គឺ ជួយដល់សហគមន៍ព្រៃឈើទាំងនោះឱ្យមានសមត្ថភាពប្រសើរឡើងនូវការគ្រប់គ្រងធនធានព្រៃឈើ និងធានាបាននូវផលប្រយោជន៍ ជាអតិបរមាដល់សមាជិកសហគមន៍ព្រៃឈើទាំងអស់
- របាយការណ៍ថ្មីៗជាច្រើន ដូចជា ៖ IFSR, 2004; ITTTO, 2005, Van Acket, 2005; CDRI, 2006 & CTSP;2004 បានផ្តល់ អនុសាសន៍ដោយចាត់អាទិភាពលើប្រព័ន្ធគ្រប់គ្រងព្រៃឈើផ្តល់ផលដោយមានការចូលរួមពីសហគមន៍ និងតាមបែបវិមជ្ឈការ ដោយធ្វើការសាកល្បងតាមស្ថានភាពជាក់ស្តែងរបស់ព្រៃសហគមន៍នីមួយៗ ដែលចាំបាច់ត្រូវមានការចូលរួមពីក្រុមប្រឹក្សាឃុំ
- រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តគោលនយោបាយវិមជ្ឈការផ្នែកហិរញ្ញវត្ថុ និងអំណាចរដ្ឋបាលឱ្យដល់ក្រុមប្រឹក្សាឃុំ ក្នុងការគាំទ្រសហគមន៍ព្រៃឈើតាមរយៈការចូលរួមគ្រប់គ្រងព្រៃឈើក្នុងភាពជាដៃគូ ដោយរួមបញ្ចូលទាំងការងារសហគមន៍ ព្រៃឈើ ការងារសហគមន៍ព្រៃការពារ ការងារសហគមន៍ព្រៃផ្តល់ផល និងការងារព្រៃឈើដៃគូ ទៅក្នុងផែនការប្រើប្រាស់ដីថ្នាក់ ឃុំ និងផែនការអភិវឌ្ឍឃុំ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍរបស់សហគមន៍ដោយអនុលោមតាមបញ្ញត្តិនៃថវិកាវិនិយោគរបស់ឃុំ
- យោងតាមទិន្នន័យសហគមន៍ព្រៃឈើខែវិច្ឆិកា ឆ្នាំ២០០៩ បានបង្ហាញថា មានសហគមន៍ព្រៃឈើចំនួន៤០១គ្របដណ្តប់ លើផ្ទៃដីព្រៃប្រមាណ ៣៨០.៥៨៧ ហ.ត ស្ថិតនៅក្នុងស្រុកចំនួន ៨០ ឃុំចំនួន ១៩៤ភូមិចំនួន ៧១៧ នឹងមានសមាជិក សហគមន៍ចំនួន ៧៩.៩២៤ គ្រួសារ។ ក្នុងនោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តចំនួន ១២៦ សហគមន៍ ព្រៃឈើ ដែលស្មើនឹងផ្ទៃដី ១៤៥.០៣៦ ហ.ត ស្ថិតនៅក្នុងខេត្ត សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ កំពង់ធំ កំពង់ឆ្នាំង និងកោះកុង។ ខណ្ឌរដ្ឋបាលព្រៃឈើសាមីបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព ឈើចំនួន ៩៤ កន្លែង ស្មើនឹង ១១៣៥៤៤ ហ.ត
- សហគមន៍ព្រៃឈើចំនួន ១២ កន្លែង ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ដែលមានផ្ទៃដីជាង ៦០៤៧៧ ហ.ត បានធ្វើការសាកល្បង អនុវត្តគម្រោងឥណទានកាបូនសហគមន៍ព្រៃឈើលើកទី ១ សម្រាប់ទីផ្សារឥណទាន កាបូននៅប្រទេសកម្ពុជា

- ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើតំណាងដោយរដ្ឋបាលព្រៃឈើនិងមានការចូលរួមពីបណ្តាក្រសួងពាក់ព័ន្ធ ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលបានដាក់បញ្ចូលនូវការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើទៅក្នុងផែនការរបស់ពួកគេ និងទៅក្នុងសូចនាករតាមដានរួមគ្នា។ គម្រោងនិងអង្គការមួយចំនួនបាននឹងកំពុងបន្តជួយអភិវឌ្ឍសហគមន៍ព្រៃឈើតាមរយៈក្រុម ការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើ
- ការិយាល័យសហគមន៍ព្រៃឈើបានបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិនៅឆ្នាំ២០០៧ ដែល ជានិច្ចកាលតែងតរៀបចំកិច្ចប្រជុំពិភាក្សា ចែករំលែកបទពិសោធន៍ សម្របសម្រួលសកម្មភាពការងារ និងផ្តល់អនុសាសន៍ ដើម្បី ដោះស្រាយបញ្ហាដែលកើតមានឡើង នាពេលបច្ចុប្បន្នក្នុងការងារសហគមន៍ព្រៃឈើ។

កម្មវិធីនេះនឹងមានអធិប្បាយអំពីទស្សនៈទូទៅនៃយុទ្ធសាស្ត្រ និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងសហគមន៍ ព្រៃឈើដែលផ្តោតលើការចូលរួមគ្រប់គ្រងព្រៃឈើតាមរយៈទ្រង់រាំង ៤ គឺបន្ថែមពីលើការអនុវត្តសហគមន៍ព្រៃឈើ ដែលមានការ បញ្ជាក់លម្អិតនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ នឹងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើនោះ នៅមានទម្រង់ ៣ ផ្សេងទៀត ដែលកំពុងអនុវត្តសាកល្បង ដើម្បីទទួលស្គាល់ស្របច្បាប់ ដូចជា នៅក្នុងតំបន់ព្រៃការពារតំបន់ព្រៃ ដែលក្រុមប្រឹក្សាឃុំមានការចាប់អារម្មណ៍ចូលរួមគ្រប់គ្រងព្រៃឈើត្រូវបង្កើតព្រៃឈើដៃគូ និងនៅតំបន់ដែលមានផ្ទៃដីព្រៃឈើធំទូលាយ និងមានសក្តានុពលក្នុងការធ្វើពាណិជ្ជកម្មត្រូវបង្កើតសហគមន៍ព្រៃផ្តល់ផល។ ក្នុងអំឡុងពេលអនុវត្តកម្មវិធីព្រៃឈើជាតិ លិខិតបទដ្ឋាន ច្បាប់ដែលគាំទ្រដល់ការអនុវត្តសហគមន៍ព្រៃឈើ នឹងត្រូវបានធ្វើការពិនិត្យឡើងវិញដោយផ្អែកលើបទពិសោធន៍ និងមេរៀនដែលទទួល បានពីកាអនុវត្តជាក់ស្តែងក្នុងការអនុវត្តសហគមន៍ព្រៃឈើនិងដើម្បីពង្រីកខ្លឹមសារនៃពាក្យសហគមន៍ព្រៃឈើដើម្បីគ្របដណ្តប់គ្រប់ទម្រង់ នៃការគ្រប់គ្រងព្រៃឈើតាមបែបរិមជ្ឈការ។

បើទោះបីជាចំណុចទាំងបួនខាងលើខុសប្លែកគ្នាបន្តិចបន្តួច តែវាមានការពាក់ព័ន្ធដល់ការគ្រប់គ្រងព្រៃឈើ ដោយមានការចូលរួម យ៉ាងសកម្មពីសហគមន៍មូលដ្ឋាន និងមានការគាំទ្រពីរដ្ឋបាលព្រៃឈើទាំងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងម្ចាស់ជំនួយផ្សេងៗទៀត។ សហគមន៍ព្រៃឈើបានរួមចំណែកយ៉ាងច្រើនដល់ការគ្រប់គ្រងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលជាគម្របព្រៃធម្មជាតិដ៏ធំទូលាយ។ ការអនុវត្ត និងការគាំទ្រដល់ទម្រង់ទាំងបួនខាងលើ មានលក្ខណៈស្រដៀងគ្នា ហេតុនេះហើយទើបកម្មវិធីនេះត្រូវបានបែងចែកជា៣ អនុកម្មវិធីដូចខាងក្រោម ៖

- *ការកំណត់តំបន់ សក្តានុពលពសហគមន៍ និងការបង្កើតសហគមន៍ព្រៃឈើ* គឺជាការកំណត់តំបន់ព្រៃឈើដែល មានសក្តានុពល និងការចូលរួមរបស់សហគមន៍មូលដ្ឋានដើម្បីបង្កើតជាព្រៃសហគមន៍ស្របទៅតាមទម្រង់នីតិវិធីនៃការបង្កើត សហគមន៍ព្រៃឈើ
- *ការអភិវឌ្ឍសហគមន៍ និងការបង្កើនជីវភាព* គឺជាការគាំទ្រដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើនៅថ្នាក់មូលដ្ឋានក្នុង គោលបំណងដើម្បីចូលរួមគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាព សំដៅរួមចំណែកដល់ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍ ព្រៃឈើប្រកបដោយនិរន្តរភាព និងផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច-សង្គមដល់សហគមន៍មូលដ្ឋាន
- *ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ* គឺជាការផ្តល់សេវាកម្មដល់សហគមន៍ព្រៃឈើ ដូចជា វគ្គបណ្តុះ បណ្តាលបច្ចេកទេសកែច្នៃផល-អនុផលព្រៃឈើ ការកសាងសមត្ថភាពផ្នែកច្បាប់ ការគ្រប់គ្រងសហគមន៏ ការគ្រប់គ្រងព័ត៌មាន នឹងបណ្តាញការងារ។ល។

អនុកម្មវិធីទាំងបីខាងលើ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយជោគជ័យដោយសហគមន៍មូលដ្ឋាន។

## ៤.៦ ការវិភាគបញ្ហា

ប្រជាពលរដ្ឋនៅតាមជនបទនៅមានភាពក្រីក្រនៅឡើយ។ ការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើមិនទាន់បានរួមចំណែកគ្រប់គ្រាន់ ក្នុងការកាត់បន្ថយភាពក្រីក្រនៅឡើយទេដោយហេតុថា ៖

### ៤.៦.១ កបខណ្ឌច្បាប់

- ការទាញយកផលប្រយោជន៍ពីព្រៃឈើរបស់សហគមន៍ និងអ្នកពាក់ព័ន្ធនៅមានកម្រិត។ សហគមន៍ព្រៃឈើមានការលំបាក ក្នុងការបង្កើតនៅក្នុងដីព្រៃសម្បទាន និងសម្បទានសេដ្ឋកិច្ច។ នេះគឺជាការខ្វះខាតនូវគោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ ក្នុងការកំណត់តំបន់សក្តានុពលព្រៃសហគមន៍។
- បន្ទាប់ពីការចូលរួមគ្រប់គ្រងព្រៃឈើរយៈពេល១៥ឆ្នាំ (រយៈពេលដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍) សិទ្ធិ នៃការដឹកនាំ និងគ្រប់គ្រងសហគមន៍ព្រៃឈើមិនត្រូវបានជានា និងបណ្តាលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតំលៃមានភាពមិន ប្រាកដ នាំអោយការវិនិយោគលើការងារសហគមន៍ព្រៃឈើត្រូវបានកាត់បន្ថយ
- អត្រាថ្លៃសួយសារ និងបុព្វលាភ មានភាពមិនប្រាកដប្រជា រាល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការវិនិយោគមិនអាចដំណើរការ ទៅបានក្នុងបរិយាកាសនៃភាពមិនប្រាកដប្រជាខាងផ្នែកសេដ្ឋកិច្ច

- ក្របខណ្ឌច្បាប់មានលក្ខណៈស្មុគ្រស្មាញ និងតឹងរឹង សិទ្ធិអំណាចរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនៅមានកម្រិតក្នុង ការបង្ក្រាបបទល្មើសព្រៃឈើដែលបង្កឡើងដោយអ្នកខាងក្រៅសហគមន៍ និងការគាំទ្រពីរដ្ឋបាលព្រៃឈើដល់ការអនុវត្ត ការងារសហគមន៍ព្រៃឈើមិនទាន់បានគ្រប់គ្រាន់នៅឡើយ
- កម្មវិធីសហគមន៍ព្រៃឈើនៅមិនទាន់មានគម្រោងគាំទ្រសកម្មភាពមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍ព្រៃឈើនៅឡើយ
- កម្មវិធីសហគមន៍ព្រៃឈើនៅមិនទាន់មានគម្រោងគាំទ្រសកម្មភាពមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍ព្រៃឈើនៅឡើយ ការរៀបចំសហគមន៍ព្រៃឈើបច្ចុប្បន្នកំពុងរៀបចំទៅតាមបែបបទផ្សេងៗគ្នា ប៉ុន្តែមានលក្ខណៈបត់បែនទៅតាមស្ថានភាព ជាក់ស្តែងនៅមូលដ្ឋាន
- ទោះបីក្រុមប្រឹក្សាឃុំមានតួនាទីក្នុងការការពារ និងអភិរក្សធនធានធម្មជាតិនិងបរិស្ថានក៏ដោយ ក៏ក្រុមប្រឹក្សាឃុំពុំបានបំពេញនូវ តួនាទីខាងលើនេះឱ្យបានសកម្មនៅឡើយ (ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ មាត្រា ៤៥)។ ហេតុនេះគួរពង្រឹង សមត្ថភាពក្រុមប្រឹក្សាឃុំឱ្យមានការចូលរួមកាន់តែសកម្មក្នុងការការពារ អភិរក្សធនធានធម្មជាតិ និងបរិស្ថាន ។

### ៤.៦.២ ក្របខណ្ឌស្ថាប័ន

- តំបន់សក្តានុពលព្រៃសហគមន៍ និងសហគមន៍ព្រៃឈើជាច្រើន នៅមិនទាន់មានការទទួលស្គាល់ជាផ្លូវច្បាប់នៅឡើយ។ ជា លទ្ធផល ភាពជាម្ចាស់ ឬសិទ្ធិនៃការប្រើប្រាស់ដីព្រៃសហគមន៍មិនត្រូវបានធានា ជាហេតុធ្វើឱ្យសហគមន៍មានការរារែកក្នុងការ ចំណាយពេលវេលា ការខិតខំប្រឹងប្រែង ការលះបង់ធនធានដើម្បីគាំទ្រនិងចូលរួមក្នុងការងារសហគមន៍ព្រៃឈើឱ្យបានពេល លេញ។ ការពន្យារពេលនេះ មិនបានលើកទឹកចិត្តដល់បណ្តាសហគមន៍ដែលមានភារៈយ៉ាងធ្ងន់ធ្ងរក្នុងការគ្រប់គ្រងព្រៃឈើ បើប្រៀបធៀបជាមួយអ្នកប្រើប្រាស់ដីដទៃទៀត
- កង្វះខាតការទទួលស្គាល់ផ្នែកច្បាប់ ក៏ជារនាំងមួយចំពោះសហគមន៍ព្រៃឈើក្នុងការធ្វើពាណិជ្ជកម្មព្រៃឈើឱ្យបានពេញលេញ។ ជម្លោះក្នុងការប្រើប្រាស់ដីធ្លី(ព្រៃសម្បទានដីសម្បទានសេដ្ឋកិច្ចចម្ការព្រៃដាំកសិដ្ឋានការរុករករ៉ែ។ល។)នៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរ ដែលត្រូវការដោះស្រាយជាបន្ទាន់
- ការគាំទ្រ និងកិច្ចសហការរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើជាតិនៅមានកម្រិតនៅឡើយ។ ហេតុនេះទាមទារឱ្យមានការពង្រឹងសមត្ថភាព និងស្វែងរកវិធីសាស្ត្រសហការល្អៗរវាងភាគីពាក់ព័ន្ធសំខាន់ៗក្នុងការគាំទ្រដល់កម្មវិធីសហគមន៍ព្រៃឈើជាតិ

- រដ្ឋបាលព្រៃឈើខ្វះមន្ត្រីទទួលបន្ទុកការងារបណ្ដុះបណ្ដាល និងការលើកទឹកចិត្ត ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ ក៏ដូចជាខ្វះធនធានដើម្បីអនុវត្តសកម្មភាពការងារនៅតាមបណ្ដាខេត្តឱ្យមានភាពរលូន
- សហគមន៍មូលដ្ឋានមិនទាន់បានយកចិត្តទុកដាក់ និងមិនមានចំណេះដឹងគ្រប់គ្រាន់ពីប្រយោជន៍នៃការធ្វើក្ខវប្បកម្ម ដើម្បីបង្កើននូវគុណភាពព្រៃឈើ ទាំងព្រៃធម្មជាតិ និងចម្ការព្រៃ
- ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងក្រុមអ្នកប្រើប្រាស់ធនធានព្រៃឈើ ក្នុងការអនុវត្តគម្រោងនៅមានកម្រិត ហើយបទពិសោធន៍ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើក៏មិនទាន់រឹងមាំនៅឡើយ
- តាមរបាយការណ៍របស់បណ្ឌិត សុខ វង និង អ៊ីដា ស៊ីហ្គេរី បានបង្ហាញថា សហគមន៍ព្រៃឈើត្រូវបានទទួលស្គាល់កាន់ តែខ្លាំងឡើង ក្នុងការបង្កើនកម្រិតជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងក្នុងការជួយទប់ស្កាត់នូវបញ្ហាបរិស្ថានផ្សេងៗតាម រយៈការលើកទឹកចិត្តឱ្យសហគមន៍មូលដ្ឋានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ប៉ុន្តែ ការអភិវឌ្ឍសហគមន៍ព្រៃឈើកន្លងមកមានភាពយឺតយ៉ាវ ដោយសារខ្វះខាតធនធានហិរញ្ញវត្ថុ សមត្ថភាព និងធនធានមនុស្ស ហើយផ្អែកស្ទើរតែទាំងស្រុងលើជំនួយបរទេស និងអង្គការសង្គមស៊ីវិល
- មានយន្តការមួយចំនួនត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ ដែលក្នុងនោះរួមមានការបង្កើត គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិ ដែលដឹកនាំដោយរដ្ឋបាលព្រៃឈើ (ការិយាល័យសហគមន៍ព្រៃឈើ) និងមានសមាជិកមកពីបណ្ដាអង្គការជាតិ និងអន្តរជាតិ ដែលបាននិងកំពុងអនុវត្តការងារសហគមន៍ព្រៃឈើ។ គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិនេះ បានបង្កើតឡើងក្នុងឆ្នាំ២០០៧ ដើម្បីសម្របសម្រួលសកម្មភាពសហគមន៍ ព្រៃឈើ រៀបចំផែនការសកម្មភាព និងពិភាក្សារកដំណោះស្រាយលើបញ្ហាក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើដែលកើតឡើង នៅមូលដ្ឋាន។ លើសពីនេះទៀត ក៏មានបណ្ដាញសហគមន៍ព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់ខេត្តផងដែរ ដែលបានបង្កើតឡើង តាំងឆ្នាំ ១៩៩៥ ដោយគម្រោងគ្រប់គ្រងបរិស្ថានកម្ពុជា ក្នុងគោលបំណងដើម្បីផ្ដល់វេទិកាជូនសហគមន៍មូលដ្ឋាន និងភាគី ពាក់ព័ន្ធបានជួបប្រជុំ និងចែករំលែកបទពិសោធន៍រវាងគ្នាទៅវិញទៅមក។ បើទោះជាមានយន្តការ ជាច្រើនយ៉ាងនេះក្ដី ក៏ការ គាំទ្រ និងកិច្ចសហការរវាងស្ថាប័ន និងភាគីពាក់ព័ន្ធនៅមានកម្រិតនៅឡើយ។ ហេតុនេះចាំបាច់ត្រូវមានការពង្រឹងសមត្ថភាព និងស្វែងរកវិធីសាស្ត្រសហការល្អៗបន្ថែមទៀតរវាងអ្នកពាក់ព័ន្ធសំខាន់ៗក្នុងការគាំទ្រដល់កម្មវិធីសហគមន៍ព្រៃឈើជាតិ

- បណ្តាញសហគមន៍ព្រៃឈើនឹងត្រូវបាត់បង់និរន្តរភាព ហើយកិច្ចខិតខំប្រឹងប្រែងពីមុនត្រូវបានតាំង ខណៈពេលដែលការគាំទ ថវិកាពីខាងក្រៅក៏ត្រូវបានផ្អាក។ របៀបវារៈនៃការជ្រើសរើសអ្នកចូលរួម និងកិច្ចដំណើរការទូទៅនៃសហគមន៍ព្រៃឈើត្រូវ បានដឹកនាំផ្តួចផ្តើមដោយរដ្ឋបាលព្រៃឈើ ឬអង្គការសង្គមស៊ីវិល។ ហេតុនេះគួរតែបង្កើតឱ្យមានជាបណ្តាញសហគមន៍ព្រៃឈើ
- បន្ទាប់ពីសហគមន៍ព្រៃឈើបានទទួលកិច្ចព្រមព្រៀងព្រៃសហគមន៍ ដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយសមាជិកសហគមន៍ខ្លួន ឯងផ្ទាល់ ហើយមានតែបណ្តាញសហគមន៍ព្រៃឈើបែបនេះទេ ទើបមាននិរន្តរភាព។

### ៤.៦.៣ សេដ្ឋកិច្ច-សង្គម

- តម្រូវការរបស់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច មិនតែងតែត្រូវបានគេទទួលស្គាល់ និងផ្តល់អាទិភាពជានិច្ចកាលនោះទេ ហេតុនេះហើយទើបការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពនៅមានកម្រិត
- សម្រាប់បន្ថែមទៅលើបញ្ហាដែលបានរៀបរាប់ខាងលើ សកម្មភាពចិញ្ចឹមជីវិតនៅក្នុងសហគមន៍ព្រៃឈើនៅមានកម្រិតនៅឡើយព្រោះបច្ចេកទេសនៅមានកម្រិតទាប ធនធានមនុស្សដែលមានជំនាញនៅមានកម្រិត និង ខ្វះថវិកា
- ជាទូទៅប្រព័ន្ធនៃការផ្តល់ថវិកាសម្រាប់អភិវឌ្ឍសហគមន៍ព្រៃឈើនាពេលបច្ចុប្បន្ន មិនមាននិរន្តរភាព (មានតែគម្រោងខ្លីៗរបស់ អង្គការជាតិ អន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាល)។ ដូច្នេះគួរស្វែងរកយន្តការផ្តល់ថវិកាគាំទ្រដល់សហគមន៍ព្រៃឈើ ដើម្បី
- ថែរក្សា ការពារ និងអភិវឌ្ឍព្រៃសហគមន៍ រួមទាំងប្រព័ន្ធហិរញ្ញវត្ថុឥណទានកាបូនផងដែរ •
- ជំរុញឱ្យមានភាពជាម្ចាស់លើសហគ្រាសផលិតផលព្រៃឈើនៅក្នុងសហគមន៍ព្រៃឈើ និងគួរធ្វើការវិភាគបន្ថែមលើខ្សែចង្វាក់ ផលិតកម្ម ដោយចាប់ពីចំណុចប្រមូលផល ការផលិត និងការស្វែងរកទីផ្សារ ក្នុងគោលបំណងដើម្បីយល់ឱ្យបានច្បាស់ពីការ បែងចែកផលប្រយោជន៍ និងជួយដល់សមាជិកសហគមន៍ព្រៃឈើកំណត់បាននូវឱកាសក្នុងការបន្ថែមតម្លៃលើផលិតផលព្រៃឈើរបស់ខ្លួន
- គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវកត់ត្រាពីការប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ ដែលអាចគណនាបរិមាណពិតប្រាកដនៃការដេកហូតពីព្រៃសហគមន៍។

### ៤.៦.៤ បរិស្ថាន

- នៅតែមានការគំរាមកំហែងជាប្រចាំ និងមានសម្ពាធទៅលើតំបន់ព្រៃធម្មជាតិទាំងនេះក៏អាស្រ័យដោយមានការខ្វះខាតក្នុងទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងការទប់ស្កាត់ការផ្ទេរដីព្រៃឈើជាលក្ខណៈទ្រង់ទ្រាយធំសម្រាប់ការធ្វើកសិដ្ឋាន និងចម្ការ ដំណាំពាណិជ្ជកម្មឧស្សាហកម្ម។
- កសិកម្មនៅតែជាប្រភពមុខរបរមួយដ៏សំខាន់សម្រាប់ប្រជាជនតាមជនបទ។ បើទោះជាយ៉ាងនេះក្តី ការវិភាគតម្លៃចំណេញមិន ត្រូវបានគេធ្វើឡើងមុនពេលសម្រេចចិត្តផ្ទេរពីដីព្រៃទៅជាដីកសិកម្មនោះឡើយ។ មានការសិក្សាតិចតួចប៉ុណ្ណោះ ដែលបាន អះអាងអំពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ថាជាជម្រើសមួយដ៏ល្អ និងមានលក្ខណៈយូរអង្វែង។ លើសពីនេះទៅទៀត ការបែងចែកផលប្រយោជន៍ក្នុងសហគមន៍ គួរតែធ្វើការពិចារណាថា តើសកម្មភាពដែលបានលើកឡើងនេះបានរួមចំណែក ដល់ការកាត់បន្ថយភាពក្រីក្រដោយរបៀបណា? តើព្រៃឈើបានរក្សាជីវចម្រុះនិងបរិស្ថានយ៉ាងណាខ្លះ? និងតើអ្នកណាជាអ្នក ទទួលផលប្រយោជន៍ទាំងនោះ
- ការជះឥទ្ធិពលជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុលើដំណុះព្រៃ ជីវចម្រុះ ព្រមទាំងជម្រើសក្នុងការប្រើប្រាស់ដីផ្សេងៗកំពុងត្រូវបានគេគិតតែពីកត្តាសេដ្ឋកិច្ចច្រើនជាង ដោយមិនបានគិតដល់ផលប្រយោជន៍របស់វាក្នុងការកាត់បន្ថយការផ្លាស់ប្តូរអាកាសធាតុ។

### ៤.៦.៥ តម្លៃ

ការបង្កើតសហគមន៍ព្រៃឈើ ត្រូវការចំណាយថវិកាច្រើន។

## ៤.៧ គោលបំណងនៃកម្មវិធី

- ដើម្បីធានាដល់ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយសមធម៌ និង ប្រជាធិបតេយ្យ
- ផ្តល់ឱកាសដល់សហគមន៍មូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃ បានចូលរួមរៀបចំបង្កើត គ្រប់គ្រង និងអភិវឌ្ឍព្រៃសហគមន៍ ស្របទៅតាមគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ដោយចូលរួមក្នុងការកំណត់តំបន់សក្តានុពលព្រៃសហគមន៍ និងការ ចូលរួមធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ
- ពិនិត្យ និងកែសម្រួលឡើងវិញក្នុងករណីចាំបាច់នូវរាល់លិខិតបទដ្ឋាននានាដែលគាំទ្រដល់ការអនុវត្តសហគមន៍ព្រៃឈើ ដោយ ផ្អែកទៅលើបទពិសោធន៍ដែលទទួលបានពីកាធនុវត្តកន្លងមក ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍មូលដ្ឋាន និងដោះស្រាយបញ្ហានានាដែលកើតមានឡើង
- ផ្តល់ការកសាងសមត្ថភាព និងគាំទ្រដល់មន្ត្រីរដ្ឋបាលព្រៃឈើ ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជួយគាំទ្រ និងផ្តល់សេវាកម្ម ដល់សហគមន៍ព្រៃឈើប្រកបដោយគុណភាព

- ពង្រឹងនិងជំរុញការគ្រប់គ្រងព្រៃសហគមន៍ប្រកបដោយនិរន្តរភាព ក្នុងគោលបំណងពាណិជ្ជកម្ម និងការបង្កើនជីវភាពតាមរយៈ ការបង្កើនផល-អនុផលព្រៃឈើ ការអភិរក្សជីវចម្រុះ និងការលក់ឥណទានកាបូនព្រៃឈើទៅទីផ្សារអន្តរជាតិដើម្បីធ្វើឱ្យសហគមន៍ ព្រៃឈើមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រងព្រៃសហគមន៍បានដោយខ្លួនឯង
- បង្កើនការចូលរួមរបស់សមាជិកសហគមន៍ព្រៃឈើ ជាពិសេសស្ត្រី ដើម្បីឱ្យមានតម្លាភាព អភិបាលកិច្ចល្អ និងការបែងចែកផលប្រយោជន៍យដោយសមធម៌
- ដើម្បីបង្ហាញនូវភាពផ្សេងៗគ្នានៃការអនុវត្តសហគមន៍ព្រៃឈើនិងបង្កើននូវភាពជឿជាក់ថាសហគមន៍មូលដ្ឋាន ពិតជាមានសារៈសំខាន់ក្នុងការចូលរួមគ្រប់គ្រងព្រៃឈើ។

## ៤.៨ សូចនាករ

- ចំនួនភូមិ និងចំនួនប្រជាជនដែលបានចូលរួមបង្កើតសហគមន៍ព្រៃឈើ
- ទំហំផ្ទៃដីព្រៃឈើ ដែលស្ថិតនៅក្រោមការរៀបចំបង្កើតសហគមន៍ព្រៃឈើ
- សេចក្តីណែនាំសម្រាប់ការកំណត់តំបន់សក្តានុពល ត្រូវបានអនុម័ត និងអនុវត្ត
- លិខិតបទដ្ឋានពាក់ព័ន្ធដល់ការគាំទ្រការអនុវត្តសហគមន៍ព្រៃឈើ
- ចំនួនមន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថភាពក្នុងការផ្តល់សេវាកម្មដល់សហគមន៍មូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាព
- ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពផ្តល់នូវបរិមាណផល-អនុផលព្រៃឈើ ជីវចម្រុះកើនឡើង និងមានឥណទានកាបូន
- បរិមាណផលិតផលព្រៃឈើស្របច្បាប់ ដែលបានផ្គត់ផ្គង់
- ចំនួនសហគមន៍ព្រៃឈើបានរួមចំណែកដល់ការបង្កើនជីវភាព និងការកាត់បន្ថយភាពក្រីក្រ
- ចំនួនសហគមន៍ព្រៃឈើដែលអាចដំណើរការដោយខ្លួនឯងបាន និងចំនួនសហគមន៍ដែលបានបង្កើតសហគ្រាសព្រៃឈើ ថវិកាដែលទទួលបានពីការលក់កាបូនព្រៃឈើរបស់សហគមន៍ព្រៃឈើ
- គោលការណ៍សម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តសមាគមន៍ព្រៃឈើ ត្រូវបានរៀបចំឡើង ដោយមានការចូលរួម ពីសមាជិកសហគមន៍ព្រៃឈើប្រកបដោយតម្លាភាព និងអភិបាលកិច្ចល្អ។

## ៤.៩ មធ្យោបាយផ្ទៀងផ្ទាត់

លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការងារសហគមន៍ព្រៃឈើ (ប្រកាស សេចក្តីណែនាំ កិច្ចព្រមព្រៀង ...)

- ផែនទីព្រៃសហគមន៍
- ទិន្នន័យការប៉ាន់ប្រមាណជនធាន និងការធ្វើសារពើភណ្ឌ
- ទិន្នន័យសហគមន៍ព្រៃឈើ កិច្ចព្រមព្រៀងព្រៃសហគមន៍
- របាយការណ៍សិក្សាស្រាវជ្រាវ
- របាយកាណ៍វាយតម្លៃ។

## ៤.១០ ហានិភ័យនៃកម្មវិធី

- ដីព្រៃឈើភាគច្រើននឹងត្រូវបានផ្ទេរទៅជាការប្រើប្រាស់ដីនិងការគ្រប់គ្រងព្រៃឈើតាមទម្រង់ផ្សេងៗទៀត ប្រសិនបើសហគមន៍ ព្រៃឈើមិនត្រូវបានគេចាត់ជាអាទិភាព
- ការប្រើប្រាស់ដីមានលក្ខណៈប្រកួតប្រជែង ព្រោះមានការគិតពីតម្លៃ
- សមត្ថភាពរបស់សហគមន៍នៅមានកម្រិតក្នុងការការពារ និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ការគ្រប់គ្រង ការលើកទឹកចិត្ត និងសមត្ថភាពរបស់មន្ត្រីរដ្ឋបាលព្រៃឈើនៅមានកម្រិត ដើម្បីជួយគាំទ្រដល់ការការពារ និងការ អភិវឌ្ឍសហគមន៍ព្រៃឈើ
- ខ្វះខាតថវិកាសម្រាប់ការរៀបចំសហគមន៍ព្រៃឈើ
- ខ្វះការសហការ និងការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងស្ថាប័នរដ្ឋាភិបាលផ្សេងៗទៀត
- គោលនយោបាយសម្រាប់ការផ្តល់សិទ្ធិគ្រប់គ្រងព្រៃឈើដល់សហគមន៍មូលដ្ឋាន និងការពិនិត្យកែសម្រួលលិខិតបទដ្ឋានគាំទ ដល់ការអនុវត្តសហគមន៍ព្រៃឈើ ដើម្បីដោះស្រាយបញ្ហាខាងលើពុំទាន់គ្រប់គ្រាន់
- ការប្រែប្រួលអាកាសធាតុៈ ប្រទេសកម្ពុជាត្រូវបានរំពឹងទុកថា ទទួលរងនូវវិបត្តិធ្ងន់ធ្ងរប្រសិនបើវិធានការនៃការកាត់បន្ថយការបញ្ចេញ ឧស្ម័ន មិនត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវ
- ទោះបីជាទីផ្សារឥណទានកាបូនព្រៃឈើមានការផ្លាស់ប្តូរ ឬមិនផ្លាស់ប្តូរក៏ដោយ ក៏ការបង់ចំណាយផ្សេងៗចំពោះការកាត់បន្ថយ ការបញ្ចេញឧស្ម័យពីការបាត់បង់ និងរេចរឹលព្រៃឈើ គួរតែធ្វើឱ្យប្រសើរបំផុតដល់ភាពគង់វង្សរបស់សហគមន៍ព្រៃឈើ។

## ៤.១១ យុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធី

គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិ នឹងធ្វើការសម្របសម្រួលសកម្មភាពរវាងរដ្ឋបាលព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាលជាតិ/អន្តរជាតិ និងស្ថាប័នរដ្ឋពាក់ព័ន្ធ ៖

- កំណត់សកម្មភាពសំខាន់និងចាំបាច់ដើម្បីអភិវឌ្ឍសហគមន៍ព្រៃឈើ
- វាយតម្លៃពីស្ថានភាពសហគមន៍ព្រៃឈើដែលមានស្រាប់
- ពិនិត្យសកម្មភាពដែលជាការប្តេជ្ញាចិត្តរបស់សហគមន៍ ដើម្បីបញ្ចប់សកម្មភាពទាំងនោះ
- ការវិភាគសកម្មភាពដែលជាតម្រូវការសម្រាប់គាំទ្រដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ
- កសាងផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តសកម្មភាពចាំបាច់ ដោយមានការសម្របសម្រួលតាមរយៈការធ្វើសំណើស្វែងរកថវិកាបន្ថែម
- របាយការណ៍សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍សហគមន៍ព្រៃឈើ។
- រដ្ឋបាលព្រៃឈើបញ្ជូនមន្ត្រីសហគមន៍ព្រៃឈើ ដើម្បីជួយផ្តល់សេវាកម្មដល់សហគមន៍ ដោយមានបញ្ជាក់លក្ខខណ្ឌការងារ (ToRs)
- គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើ រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការកំណត់តំបន់សក្តានុពល ព្រៃសហគមន៍ ដើម្បីដាក់ជូនរដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេច
- គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើ រៀបចំឯកសារដែលជាពិសោធន៍ល្អៗទទួលបានពីការអនុវត្តសហគមន៍ព្រៃឈើ និងដឹកនាំការពិនិត្យឡើងវិញនូវរាល់លិខិតបទដ្ឋានដែលគាំទ្រដល់ការអនុវត្តសហគមន៍ព្រៃឈើ ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍
- ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនជាពិសេសការអភិវឌ្ឍសហគ្រាស និងទីផ្សារ ដោយមានបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់
- រៀបចំវិធីសាស្ត្រសម្រាប់ការវាយតម្លៃបរិមាណកាបូនស្តុកក្នុងព្រៃសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ។ ចងក្រងសហគមន៍ព្រៃឈើក្នុងគោលបំណងទីផ្សារឥណទានកាបូន បង្កើតយន្តការបែងចែកផលចំណេញប្រកបដោយសមធម៌ពី ការលក់ឥណទានកាបូនព្រៃឈើ និងការចូលរួមរបស់សហគមន៍ក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ពន្ធ័ទៅនឹងការធ្វើឥណទានកាបូន
- ការិយាល័យសហគមន៍ព្រៃឈើទទួលខុសត្រូវលើការគ្រប់គ្រងព័ត៌មាន វិភាគ រៀបចំ និងផ្សព្វផ្សាយឯកសារសហគមន៍ព្រៃឈើ
- បង្កើតសហពន្ធ័សហគមន៍ព្រៃឈើ ពីកិច្ចប្រជុំបណ្តាញសហគមន៍ព្រៃឈើនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។

## ៤.១២ អនុកម្មវិធីទី ១ ការកំណត់តំបន់សក្ដានុពល និង ការបង្កើតសហគមន៍ព្រៃឈើ

### ៤.១២.១ សេចក្ដីអធិប្បាយ

ជំហានចាំបាច់ដើម្បីជំរុញដល់ការបង្កើតសហគមន៍ព្រៃឈើនៅទូទាំងប្រទេស គឺត្រូវបញ្ជាក់ឱ្យច្បាស់លាស់ពីស្ថានភាពភាពស្របច្បាប់ និងសិទ្ធិរបស់សហគមន៍ព្រៃឈើដែលមានស្រាប់ រួមទាំងសហគមន៍ព្រៃឈើដែលមាននៅក្នុងតំបន់ព្រៃសម្បទាន ហើយត្រូវធ្វើសេចក្ដីសម្រេចចិត្ត ថាតើការបង្កើតសហគមន៍ព្រៃឈើថ្មីគួរធ្វើនៅតំបន់ណា។ ដំណើរការរៀបចំ និងកំណត់តំបន់ព សហគមន៍ នឹងធានាថាសហគមន៍ព្រៃឈើទាំងអស់នឹងទទួលស្គាល់ដោយស្របច្បាប់ ហើយមិនអនុញ្ញាតឱ្យមានការផ្ទេរដីព្រៃ សហគមន៍ទៅជាការប្រើប្រាស់ដីផ្សេងបានឡើយ។

### ៤.១២.២ មធ្យោបាយអនុវត្ត

### ៤.១២.២.១ វិធីសាស្ត្រក្នុងការកំណត់តំបន់ និង បង្កើតសហគមន៍ព្រៃឈើ

ការកំណត់តំបន់ និងអនុម័តលើតំបន់សក្ដានុពលព្រៃសហគមន៍ គឺជាជំហានដំបូងក្នុងការបង្កើតសហគមន៍ព្រៃឈើ។ការងារនេះមានការពាក់ព័ន្ធជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍។ នេះគឺជាផ្នែកមួយនៃផែនការប្រើប្រាស់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលការគ្រប់គ្រងព្រៃសហគមន៍ គឺជា ទម្រង់មួយនៃការគ្រប់គ្រងដោយមានការចូលរួមពីសហគមន៍មូលដ្ឋានដែលមានការចាប់អារម្មណ៍ និងពឹងអាស្រ័យលើ ធនធានព្រៃឈើ។

ការកំណត់តំបន់សក្ដានុពលព្រៃសហគមន៍ តម្រូវឱ្យកម្មវិធីផ្សេងទៀតនៃកម្មវិធីព្រៃឈើជាតិ អនុវត្តនូវសកម្មភាព ដំណាលគ្នា ជាពិសេសការកំណត់ព្រំប្រទល់ និងការចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍។

### ៤.១២.២.២ ការធ្វើអត្តសញ្ញាណកម្ម

- ធ្វើការកំណត់នៅថ្នាក់ឃុំ ស្រុក និងខេត្ត ដែលអ្នកភូមិកំពុងរស់នៅក្នុង ឬ ក្បែរតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងមានការចាប់អារម្មណ៍ចូលរួមក្នុងការបង្កើតសហគមន៍ព្រៃឈើ
- ខណ្ឌរដ្ឋបាលព្រៃឈើនឹងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ និងសហគមន៍មូលដ្ឋាន ដើម្បីបញ្ជាក់អំពីការចាប់អារម្មណ៍ និងសមស្របអាចរៀបចំជាសហគមន៍ព្រៃឈើ ព្រមទាំងធ្វើការផ្សព្វផ្សាយពីតម្រូវការផលប្រយោជន៍ និងការបង្កើន សមត្ថភាព

- ការជានាពីក្រុមប្រឹក្សាឃុំ . និងការិយាល័យភូមិបាលមូលដ្ឋានថា ដីតំបន់នេះនឹងដាក់បញ្ចូលទៅក្នុងផែនការប្រើប្រាស់ ដីរបស់ឃុំ ផែនការអភិវឌ្ឍន៍ឃុំ និងការធ្វើផែនទីដីរបស់សហគមន៍ជនជាតិភាគតិច ព្រមទាំងពិចារណាក្នុងពេលធ្វើផែនទី ប្រើប្រាស់ដីរដ្ឋ
- កំណត់ព្រំប្រទល់តំបន់សក្តានុពលព្រៃសហគមន៍ជាមួយភាគីពាក់ព័ន្ធទាំងអស់ដោយប្រើប្រាស់ឧបករណ៍ ជីភីអេស និងបង្កើតជាផែនទី ព្រមទាំងកត់ត្រានូវរាល់ការព្រមព្រៀងជាមួយភាគីពាក់ព័ន្ធទាំងនោះ។ ផែនទីព្រៃសហគមន៍ និង ឯកសារពាក់ព័ន្ធត្រូវរក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគមន៍ព្រៃឈើនៅថ្នាក់ខណ្ឌរដ្ឋបាលព្រៃឈើ បញ្ជូនផែនទីនិងឯកសារពាក់ព័ន្ធទៅអាជ្ញាធរស្រុក នឹងខេត្ត ដើម្បីដាក់បញ្ចូលទៅក្នុងផែនការប្រើប្រាស់ដី ដែលបង្កើតឡើងដោយគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត/ក្រុង, ព្រមទាំងបញ្ជូនមករដ្ឋបាលព្រៃឈើ (ការិយាល័យសហគមន៍ព្រៃឈើ) ពិនិត្យនិងរៀបចំបែបបទបញ្ជូនបន្តទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេច។ ផែនទីនិងឯកសារពាក់ព័ន្ធ ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកទៅធ្វើការផ្ទៀងផ្ទាត់ ដើម្បីធានាថាការផ្តល់ដីព្រៃសហគមន៍នេះមិនត្រួតស៊ីគ្នាលើដីសម្បទានសេដ្ឋកិច្ច និងចម្ការព្រៃដាំដទៃទៀត
ឡើយ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្រួមដំណើរការពិនិត្យ និងទទួលស្គាល់តំបន់សក្តានុពលព សហគមន៍ ដោយត្រូវកំណត់ពីពេលវេលាឱ្យបានច្បាស់លាស់ ហើយធានាថាបញ្ហាដែលកើតឡើងក្នុងតំបន់មួយនៃខេត្ត មួយនឹងមិនពន្យាភពលដល់ខេត្តដទៃដែលគ្មានបញ្ហា។ ដំណើរការនេះនឹងបន្តរហូតដល់តំបន់សក្តានុពលព្រៃសហគមន៍ ទាំងអស់ទទួលបានការអនុម័ត។ការផ្តួចផ្តើមបង្កើតសហគមន៍ព្រៃឈើ អាចធ្វើឡើងដោយសហគមន៍មូលដ្ឋាន តាមរយៈការទំនាក់ទំនងជាមួយ រដ្ឋបាលព្រៃឈើមូលដ្ឋាន បន្ទាប់មកសហគមន៍មូលដ្ឋានត្រូវអនុវត្តទៅនីតិវិធីដូចបានរៀបរាប់ខាងលើ។ ប្រសិនបើមានការផ្ទេរដីព្រៃ ដើម្បីប្រើប្រាស់ដីក្នុងរូបភាពផ្សេងនោះ សហគមន៍មូលដ្ឋានគួរត្រូវបានចូលរួមពិគ្រោះ យោបល់ជាមុនសិន ដើម្បីឱ្យដឹងច្បាស់ថាពួកគាត់មានការចាប់អារម្មណ៍ក្នុងការរៀបចំសហគមន៍ព្រៃឈើ ឬយ៉ាងណាមុន នឹងសម្រេចឱ្យមានការប្រើប្រាស់ដីក្នុងរូបភាពណាមួយទៀតនោះ ហេតុនេះជម្រើសនៃការប្រើប្រាស់ដីផ្សេងៗ គួរត្រូវបាន ព្យួរទុកសិនរហូតដល់សំណើតំបន់សក្តានុពលព្រៃសហគមន៍បានដំណើរការពិនិត្យជាមុន។

### ៤.១២.២.៣ ការបង្កើតសហគមន៍ព្រៃឈើ

ជំហាននីមួយៗនៃការបង្កើតសហគមន៍ព្រៃឈើប្រភេទគំរូណាមួយ (សហគមន៍ព្រៃឈើ ព្រៃឈើដៃគូ សហគមន៍ព្រៃផ្តល់ផល និងសហគមន៍ព្រៃការពារឱ្យស្របទៅតាមច្បាប់ ត្រូវកំណត់យ៉ាង

ច្បាស់លាស់នៅក្នុងអនុក្រឹត្យស្តីពីការ គ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។ ការរៀបចំបង្កើតនីតិវិធីន ដំណើរការសហគមន៍តំរូវនីមួយៗ គួរតែរៀបចំដោយផ្អែកតែទៅលើអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាស ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។ ជំហាននីមួយៗនៃការបង្កើតសហគមន៍គំរូខាងលើ មានលក្ខណៈខុសប្លែកគ្នាតិចតួចដោយផ្អែកទៅតាមស្ថានភាពដែលបាននិងកំពុងអនុវត្ត ហើយចាំបាច់ត្រូវតែបញ្ជាក់នូវចំណុចដែលមាន លក្ខណៈខុសប្លែកគ្នាណាមួយ។ ជំហាននៃការបង្កើតសហគមន៍ព្រៃឈើរួមមាន ៖

- *ជំហាន ០៖ ការកំណត់តំបន់សក្តានុពលព្រៃសហគមន៍* (សូមអានអត្ថបទដែលបានពន្យល់ខាងលើ)
- *ជំហាន ១ ៖ ការបង្កើតសហគមន៍ព្រៃឈើ*
  សហគមន៍មូលដ្ឋានដែលមានការចាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំបង្កើតសហគមន៍ព្រៃឈើជូនអភិបាលខេត្តសាមីដោយមានការឯកភាពពីប្រធានភូមិ មេឃុំ និងអភិបាលស្រុក ដើម្បីទទួលបានការឯកភាព។ ក្រោយពីទទួលបានការ ឯកភាពពីអភិបាលខេត្ត សហគមន៍មូលដ្ឋានត្រូវធ្វើការស្នើសុំបង្កើតព្រៃសហគមន៍មកខណ្ឌរដ្ឋបាលព្រៃឈើសាមី ដោយ មានបង្ហាញពីចូលរួមរបស់សមាជិកយ៉ាងតិច ៦០% នៃចំនួនគ្រួសារសរុបនៅក្នុងភូមិ។
- *ជំហាន ២៖ ការប្រមូលព័ត៌មាន*

បង្កើតក្រុមការងារមួយដែលរួមមាន រដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ និងតំណាងអង្គការដៃគូ ដើម្បី ប្រមូលព័ត៌មានអំពីសហគមន៍ និងការប្រើប្រាស់ធនធានព្រៃឈើ ហើយរបាយការណ៍ទាំងនេះនឹងប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ធ្វើផែនការគ្រប់គ្រងព្រៃសហគមន៍ក្នុងពេលអនាគត។

- *ជំហាន ៣ ៖ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើ* ក្នុងដំណាក់កាលនេះ រចនាសម្ពន្ធ័គ្រប់គ្រងសហគមន៍ព្រៃឈើ គឺជាគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ឬ ក្រុម ប្រឹក្សាភិបាលនឹងត្រូវបានបង្កើត។ គណៈកម្មការបោះឆ្នោតបណ្តោះអាសន្នត្រូវបានបង្កើតឡើង និងបក្ខជនឈរឈ្មោះបោះឆ្នោតត្រូវបានជ្រើសរើសដោយសហគមន៍ ឬចាត់តាំងដោយក្រុមប្រឹក្សាឃុំសម្រាប់ព្រៃឈើដៃគូ។ បន្ទាប់មក គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនេះត្រូវដាក់ពាក្យស្នើសុំបង្កើតព្រៃសហគមន៍ជូននាយខណ្ឌរដ្ឋបាលព្រៃឈើសាមី ដើម្បីទទួលបានការឯកភាព។
- *ជំហាន ៤ ៖ ការរៀបចំបទបញ្ញាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ/ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ*

បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ/ក្រុមប្រឹក្សាភិបាលត្រូវបាន រៀបចំដោយគណៈកម្មការ គ្រប់គ្រងសហគមន៍ព្រៃឈើ/ក្រុមប្រឹក្សាភិបាលឬក្រុមប្រឹក្សាឃុំ ដោយមានការសម្របសម្រួលពីរដ្ឋបាលព្រៃឈើ ឬ អង្គការដៃគូ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ/ក្រុម ប្រឹក្សាភិបាលឬក្រុមប្រឹក្សាឃុំ និងមានការបញ្ជាក់និងឯកភាពពីរមេឃុំបន្ទាប់មកត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ព្រៃឈើដើម្បីចូលរួមអនុវត្ត។

- *ជំហាន ៥ ៖ ការកំណត់ព្រំប្រទល់ព្រៃសហគមន៍ និង ការធ្វើផែនទីព្រៃសហគមន៍*

  យមានជំនួយបច្ចេកទេសពីរដ្ឋបាលព្រៃឈើ និងអង្គការនៃការរៀបចំព្រំប្រទល់ព្រៃសហគមន៍ត្រូវបានកំណត់ដោយ ប្រើប្រាស់ឧបករណ៍ជីភីអេស (GPS) និងមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ អ្នកភូមិជិតខាង និងអ្នកពាក់ព័ន្ធ ផ្សេងទៀត ដើម្បីចៀសវាងមានទំនាស់ព្រំប្រទល់ត្រួតគ្នា។

- *ជំហាន ៦ ៖ ការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ*

  លក្ខន្តិកៈសហគមន៍ព្រៃឈើ នឹងត្រូវរៀបចំដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ ដោយមានការជួយសម្របសម្រួលពីរដ្ឋបាលព្រៃឈើនិងអង្គការដៃគូ។ លក្ខន្តិកៈនេះ ត្រូវបានចុះហត្ថលេខាដោយប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ និងមានការបញ្ជាក់និងឯកភាពពីមេឃុំ បន្ទាប់មកត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ព្រៃឈើដើម្បីចូលរួមអនុវត្ត។

- *ជំហាន ៧ ៖ ការរៀបចំកិច្ចព្រមព្រៀងពសហគមន៍*

  សេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ នឹងរៀបចំដោយខណ្ឌរដ្ឋបាលព្រៃឈើសាមី និងធ្វើការពិគ្រោះយោបល់ ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ។ កិច្ចព្រមព្រៀងនេះនឹងត្រូវចុះ ហត្ថលេខាដោយប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ និងរដ្ឋបាលព្រៃឈើ ឬអ្នកមានសិទ្ធិចុះហត្ថលេខា។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ មានការសង្ខេបអំពីតួនាទី និងការទទួលខុសត្រូវរបស់ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ រដ្ឋបាលព្រៃឈើ និងអជ្ញាធរពាក់ព័ន្ធ ។

ដោយបំពេញបាននូវជំហានទាំងនេះរួចហើយ សហគមន៍ព្រៃឈើនឹងអាចប្រើប្រាស់ធនធានព្រៃឈើរបស់ខ្លួន ក្នុង រយៈពេលដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ ប៉ុន្តែប្រឈមនឹងការដកហូតដីព្រៃសហគមន៍មកវិញ ប្រសិនបើ សហគមន៍ព្រៃឈើនោះមិនបានបំពេញទៅតាមតួនាទីរបស់ខ្លួនមានចែងក្នុងកិច្ចព្រមព្រៀង។ ទោះជាយ៉ាងនេះក្តី ជំហាន ខាងក្រោមនៅតែជាតម្រូវការចាំបាច់ដើម្បី

ឱ្យសហគមន៍ព្រៃឈើអាចគ្រប់គ្រងព្រៃឈើលក្ខណៈពាណិជ្ជកម្ម ព្រមទាំងធានា បាននូវភាពជាម្ចាស់លើការប្រើប្រាស់ដីព្រៃសហគមន៍របស់ខ្លួន។

- *ជំហាន ៨ ៖ ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍*
ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវរៀបចំឡើងដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ ដោយមានការសម្របសម្រួលពីរដ្ឋបាលព្រៃឈើ អង្គការដៃគូ ឬ វិស័យឯកជន។ ដំណើរការរៀបចំនេះ មានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ ការបណ្តុះបណ្តាល ការប្រមូលព័ត៌មាន ការវិភាគ និងធ្វើផែនទី។ ផែនការ គ្រប់គ្រងព្រៃសហគមន៍ត្រូវពិនិត្យនិងអនុម័តដោយនាយឧណ្ឌរដ្ឋបាលព្រៃឈើសាមី។
- *ជំហាន ៩ ៖ ការអភិវឌ្ឍសហគ្រាសសហគមន៍ព្រៃឈើ* សម្រាប់សហគមន៍ព្រៃផ្តល់ផល ឬអាចសហគមន៍ព្រៃឈើ និងព្រៃឈើដៃគូ ការអភិវឌ្ឍសហគ្រាសនឹងត្រូវបានបង្កើតឡើង។ ដំណើរការបង្កើតសហគ្រាសគឺអាស្រ័យទៅតាមប្រភេទនៃសហគ្រាស និងលិខិតបទដ្ឋានដែលមានស្រាប់នាពេលបច្ចុប្បន្ន។
- *ជំហាន ១០ ៖ ការអនុវត្តផែនការគ្រប់គ្រង* ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវបានអនុវត្ត និងអាចប្រតិបត្តិការជាមួយសហគ្រាសដទៃទៀតបាន។ កិច្ចប្រជុំប្រចាំ ឆ្នាំរបស់សហគមន៍នឹងត្រូវរៀបចំ នឹងធ្វើការឡើងវិញលើផែនការប្រតិបត្តិប្រចាំឆ្នាំ។
- *ជំហាន ១១ ៖ ការត្រួតពិនិត្យ និង វាយតម្លៃ* ការត្រួតពិនិត្យនិងវាយតម្លៃនឹងត្រូវធ្វើឡើងដោយសហការយ៉ាងជិតស្និទ្ធជាមួយការតាមដាន និងរាយការណ៍របស់កម្មវិធី ព្រៃឈើជាតិ។

គួរកត់សំគាល់ផងដែរថា ថ្វីបើការអធិប្បាយខាងលើមានលក្ខណៈជាជំហាន ប៉ុន្តែមិនចាំបាច់អនុវត្តតាមលំដាប់ លំដោយទាំងស្រុងនោះទេ ជំហាននីមួយៗអាចធ្វើឡើងក្នុងពេលដំណាលគ្នាក្នុងការរៀបចំសហគមន៍ព្រៃឈើ។ សក្តានុពល នៃទីផ្សារផលិតផលព្រៃឈើ អាចត្រូវបានគិតពិចារណាក្នុងដំណើរការរៀបចំសហគមន៍ព្រៃឈើ ហើយត្រូវរៀបចំជា គោលបំណង និងសកម្មភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើមួយចំនួន។

### ៤.១២.៣ លទ្ធផលរំពឹងទុក

#### ៤.១២.៣.១ លទ្ធផលរំពឹងទុកសម្រាប់រយៈពេលវែង ( ២០ ឆ្នាំ ) ៖

- គ្រប់សហគមន៍មូលដ្ឋានទាំងអស់ដែលរស់នៅក្នុងឬក្បែរតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ មានឱកាសក្នុងការចូលរួម គ្រប់គ្រងព្រៃឈើ កំណត់តំបន់សម្រាប់រៀបចំជាព្រៃសហគមន៍ និងដំណើរការរៀបចំបង្កើតសហគមន៍ព្រៃឈើ

- កិច្ចសហការរវាងរដ្ឋបាលព្រៃឈើ និងក្រុមប្រឹក្សាឃុំ (ព្រៃឈើដៃគូ) ក្នុងការបង្កើតផែនការប្រើប្រាស់ដីព្រៃសហគមន៍និងការដោះស្រាយបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងព្រៃឈើ
- កាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធាននៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយផ្តល់នូវសិទ្ធិចូលរួម គ្រប់គ្រងព្រៃឈើដល់សហគមន៍មូលដ្ឋាន
- បទពិសោធន៍ដែលទទួលបានពីការអនុវត្តការងារសហគមន៍ព្រៃឈើ សហគមន៍ព្រៃផ្តល់ផល ព្រៃឈើដៃគូ នឹងសហគមន៍ ព្រៃការពារ ត្រូវបានចងក្រងជាឯកសារ និងផ្តល់ដល់ការរៀបចំនិងកែលំអគោលនយោបាយសំដៅធ្វើឱ្យប្រសើរឡើង នូវការគ្រប់គ្រងព្រៃឈើនៅថ្ងៃអនាគត។

### ៤.១២.៣.២ លទ្ធផលរំពឹងទុកក្នុងរយៈពេលខ្លី (៥ ឆ្នាំ) ៖

- សហគមន៍ព្រៃឈើចំនួន ៣០០ កន្លែង នឹងត្រូវបានរៀបចំដោយមានកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងព្រៃសហគមន៍ ហើយយ៉ាងហោចណាស់តំបន់សក្តានុពលព្រៃសហគមន៍ថ្មីចំនួន ២០០ កន្លែងត្រូវបានកំណត់សម្រាប់រៀបចំសហគមន៍ព្រៃឈើ ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់សហគមន៍មូលដ្ឋាន និងក្រុមប្រឹក្សាឃុំ
- ព្រៃឈើដៃគូចំនួន ៥ កន្លែង នឹងត្រូវរៀបចំនៅក្នុង ៥ឃុំ នៃ ៥ ខេត្ត ដែលជាគម្រោងសាកល្បង ដើម្បីជួយក្នុងការរៀបចំ លិខិតបទដ្ឋានច្បាប់សម្រាប់ដំណើរការរៀបចំ និងអនុវត្តព្រៃឈើដៃគូ
- សហគមន៍ព្រៃផ្តល់ផលនឹងរៀបចំនៅក្នុង ១០ ឃុំនៃខេត្តគោលដៅចំនួន០៥ ដែលជាគម្រោងសាកល្បង ដើម្បីជួយ ក្នុងការរៀបចំលិខិតបទដ្ឋានច្បាប់សម្រាប់ដំណើរការរៀបចំ និងអនុវត្តសហគមន៍ព្រៃផ្តល់ផល
- សហគមន៍ព្រៃការពារចំនួន ១០ កន្លែងនឹងត្រូវរៀបចំ ដែលជាគំរោងសាកល្បងដើម្បី ជួយក្នុងការរៀបចំលិខិតបទដ្ឋាន ច្បាប់សម្រាប់ដំណើរការរៀបចំ និងអនុវត្តសហគមន៍ព្រៃការពារ។

## ៤.១៣ អនុកម្មវិធីទី ២ ការអភិវឌ្ឍសហគមន៍ និង ការបង្កើនជីវភាព

### ៤.១៣.១ សេចក្តីអធិប្បាយ

អនុកម្មវិធីទី ២ គឺ ជួយដល់ការអភិវឌ្ឍវចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការបង្កើនជីវភាពដល់សមាជិកសហគមន៍ព្រៃឈើក្នុងគោលបំណងដើម្បីទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមា (ផលិតផល និងសេវាកម្មព្រៃឈើ ពីការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព រួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន។ ការអភិវឌ្ឍសហគមន៍ និងការពង្រឹងស្ថាន គឺផ្តោតសំខាន់ទៅលើការគ្រប់គ្រង និងការអភិវឌ្ឍអង្គការចាត់តាំងសហគមន៍ ព្រៃឈើ ដើម្បីគាំទ្រដល់ការបង្កើនជីវភាពរបស់សហគមន៍ប្រកបដោយសមធម៌។ ការ

បង្កើនជីវភាពដល់សហគមន៍នឹងផ្តល់អាទិភាព ដល់ការប្រើប្រាស់ផលិតផលក្នុងស្រុកប្រកបដោយនិរន្តរភាព (ការចិញ្ចឹមសត្វម្ហូបអាហារ ផលិតផលឈើ ឈើថាមពល ឱសថ បុរាណ និងអនុផលព្រៃឈើ ដែលអាចជួយគាំទ្រដល់ជីវភាពរបស់សហគមន៍មូលដ្ឋាន)។ ការបង្កើនប្រាក់ចំណូលតាមរយៈការធ្វើពាណិជ្ជកម្មផល-អនុផលព្រៃឈើ នឹងត្រូវបានលើកទឹកចិត្តផងដែរ ដូចជាទីផ្សារផលអនុផលព្រៃឈើ, ធ្យូង អេកូទេសចរណ៍និងឥណទានកាបូន។

- កសាងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងដល់សមាជិកសហគមន៍ព្រៃឈើ ដើម្បីលើកទឹកចិត្តដល់ អភិបាលកិច្ចស្ថាប័ន រួមមាន ៖
    - បង្កើនការចូលរួម និង ការឯកភាពគ្នាក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ
    - ការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ចំពោះសមាជិកសហគមន៍
    - ការកសាងផែនការសកម្មភាព និង ថវិកាដោយមានការចូលរួម
    - ការគ្រប់គ្រងប្រព័ន្ធគណនេយ្យ និង ហិរញ្ញវត្ថុ * ការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌
    - ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
    - ការធ្វើរបាយការណ៍
    - ការសរសេរគម្រោងសំណើ
    - ការការពារព្រៃ និង ការពង្រឹងការអនុវត្តច្បាប់
    - ការគ្រប់គ្រងទំនាស់។
- ការពង្រឹងសមត្ថភាពរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសមាជិកសហគមន៍ព្រៃឈើ ដើម្បីឈានទៅរកនិរន្តភាព ផលិតភាព និងគុណភាពនៃផលិតផលព្រៃឈើ សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងធ្វើពាណិជ្ជកម្ម
- ធ្វើឱ្យប្រសើរឡើងនូវជំនាញគ្រប់គ្រង និងអភិវឌ្ឍផល-អនុផលព្រៃឈើ ព្រមទាំងការស្វែងរកទីផ្សារផលិតផល
- បង្កើនការយល់ដឹងអំពីការងារសហគមន៍ព្រៃឈើដល់មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដើម្បីលើកទឹកចិត្តចំពោះការគាំទ្ររបស់ ពួកគេ និងលើកទឹកចិត្តក្នុងការរៀបចំផែនការអភិវឌ្ឍន៍និងការប្រើប្រាស់ដី ព្រមទាំងគាំទ្រថវិកាសម្រាប់អភិវឌ្ឍសហគមព្រៃឈើ ឱ្យកាន់តែប្រសើរថែមទៀត
- ការអភិវឌ្ឍសហគ្រាសនៅកន្លែងដែលសហគមន៍ព្រៃឈើត្រូវការក្នុងទិសដៅធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើ ឬ សេវាកម្មដទៃ ទៀតដែលពាក់ព័ន្ធទៅនឹងព្រៃឈើ ដូចជា ទេសចរណ៍ធម្មជាតិដែលអាចជំរុញឱ្យមាននៅតាមបណ្តាគ្រួសារ ជាសមាជិកសហគមន៍និងភាគីអ្នកពាក់ព័ន្ធឬ

នៅក្នុងសហគមន៍ព្រៃឈើតាមភូមិ ឬអន្តរសហគមន៍ព្រៃឈើ។ បណ្តាសហគ្រាសអាចអនុវត្តនូវគំរូពាណិជ្ជកម្មរួមគ្នា ឬ សហការជាសមាគម។ ការគាំទ្រចំពោះការអភិវឌ្ឍសហគ្រាសទាមទារនូវការកសាងសមត្ថភាពទៅលើជំនាញជាច្រើនដូចដែល បានកំណត់ខាងលើ ក៏ដូចជាការធ្វើជំនួញ ការស្វែងរកទីផ្សារ ការផ្តល់បច្ចេកទេស ការវេចខ្ចប់និងគ្រប់គ្រងគុណភាព ត្រូវបាន លើកទឹកចិត្តក្នុងភាពជាដៃគូជាមួយវិស័យឯកជន ដោយមានជំនួយពីអ្នកសម្របសម្រួលការងារសហគមន៍ព្រៃឈើ។

### ៤.១៣.២ មធ្យោបាយអនុវត្តន៍

- ការបង្កើតសហគមន៍ព្រៃឈើទាមទារឱ្យមានការសិក្សាវាយតម្លៃចំពោះការអភិវឌ្ឍស្ថាប័ននិងការបង្កើនជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋក្នុងគោលបំណងដើម្បីឱ្យការគាំទ្រចំទិសដៅ និងតម្រូវការជាក់ស្តែង។ ការកំណត់ សក្តានុពលសម្រាប់អភិវឌ្ឍ សហគ្រាសអាចធ្វើឡើងកំឡុងពេលរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ដើម្បីជានាឱ្យមានការគាំទ្រ យ៉ាងពេញលេញពីសមាជិកសហគមន៍ព្រៃឈើ
- ការបណ្តុះបណ្តាលបណ្តាញសហគមន៍ព្រៃឈើ ការធ្វើទស្សនកិច្ចសិក្សា និងការចែករំលែកបទពិសោធន៍ជាក់ស្តែងនឹងត្រូវ បានអនុវត្តដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងពីការងារសហគមន៍ព្រៃឈើ និង សមត្ថភាពផ្សេងៗ
- ថវិកាដើមទុនត្រូវបានរៀបចំសម្រាប់បង្កើតសហគ្រាសសហគមន៍ព្រៃឈើរួមទាំងថ្លៃប្រតិបត្តិ និងថ្លៃដើមដែលអាចរកបានមកពី ថវិកាជំនួយប្រាក់កម្ចី ឬ គម្រោងឥណទានខ្នាតតូចផ្សេងៗ និងការគាំទ្រពីថវិការបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន។
- ការរៀបចំ បច្ចេកទេស វិធីសាស្ត្រ សកម្មភាព ឧបករណ៍ ក្បួន ចិត្តប។ល។ សម្រាប់ប្រើប្រាស់ដើម្បីផ្តល់នូវគោលការណ៍ ណែនាំក្នុងទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងសហគមន៍ព្រៃឈើផ្អែកទៅតាមបែបបទផ្សេងៗដែលឆ្លុះបញ្ចាំងនូវវប្បធម៌តាម តំបន់នីមួយៗ។

### ៤.១៣.៣ លទ្ធផលរំពឹងទុក

- និរន្តរភាព ភាពរឹងមាំ ប្រសិទ្ធភាពនរៀបចំគ្រប់គ្រងសហគមន៍ព្រៃឈើ និងផលប្រយោជន៍ដែលទទួលបានពីព្រៃសហគមន៍ ដែលត្រូវបានបែងចែកដោយសមធម៌ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្កើនជីវភាព និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ
- បណ្តោមធ្យោបាយ វិធីសាស្ត្រ និងបច្ចេកទេសដែលបានរៀបចំដ៏សមស្របត្រូវបានយល់ព្រមនិងប្រើប្រាស់ដោយបណ្តាដៃគូ អភិវឌ្ឍន៍សហគមន៍ព្រៃឈើ

- សមត្ថភាពសមស្របគ្រប់គ្រាន់របស់បណ្ដាដៃគូអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍការបង្កើនជីវភាពនិងការងារសហគមន៍
- ការផ្គត់ផ្គង់នៃផលិតផលព្រៃឈើដែលស្របច្បាប់និងមានលិខិតបញ្ជាក់សេវាកម្មផ្សេងៗ សម្រាប់ការនាំចេញ និងការប្រើប្រាស់ក្នុងស្រុកត្រូវបានធ្វើឱ្យប្រសើរឡើង
- រចនាសម្ព័ន្ធគ្រប់គ្រង សហគមន៍ព្រៃឈើត្រូវបានពង្រឹងក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពផល-អនុផល ព្រៃឈើ និងទីផ្សារ ដើម្បីបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍តាមរយៈការចូលរួមគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងការកាត់បន្ថយភាពក្រីក្រ
- សហគមន៍ព្រៃឈើត្រូវបានទទួលនូវជំនាញកែច្នៃ ផល-អនុផលព្រៃឈើ និងមានលទ្ធភាពស្វែងរកទីផ្សារសម្រាប់ផលិតផលព្រៃឈើរបស់ខ្លួន
- សមាជិកសហគមន៍ព្រៃឈើមានលទ្ធភាពក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ ទំនាស់ដែលអាចកើតមានឡើងនៅក្នុងសហគមន៍បាន។

## ៤.១៤ អនុកម្មវិធី ៣ ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

### ៤.១៤.១ សេចក្តីអធិប្បាយ

ដើម្បីឱ្យសហគមន៍ព្រៃឈើបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងជំរុញឱ្យមានការគ្រប់គ្រងព្រៃឈើប្រកបដោយ និរន្តរភាព ការគាំទ្រនិងការទទួលស្គាល់ផ្លូវច្បាប់ គឺទាមទារអនុវត្តនូវគ្រប់កម្រិតទាំងអស់រួមទាំង ការពិនិត្យ ការកែសម្រួលលើ លិខិតបទដ្ឋានច្បាប់ ការពង្រឹងសមត្ថភាព និងការដោះស្រាយទំនាស់ ដូចមានរៀបរាប់ខាងក្រោម ៖

### រាជរដ្ឋាភិបាលកម្ពុជា

- ដើម្បីជួយដល់អ្នកធ្វើសេចក្តីសម្រេចចិត្តឱ្យបានយល់ដឹងពីវិធីសាស្ត្រដ៏ល្អនិងគាំទ្រដល់ដំណើរការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍ សហគមន៍ព្រៃឈើ ចាំបាច់ត្រូវរៀបចំ និងពង្រឹងគោលនយោបាយ លិខិតបទដ្ឋាន ច្បាប់ដែលពាក់ព័ន្ធក្នុងវិស័យព្រៃឈើដោយ ផ្អែកលើព័ត៌មាននិងឯកសារដេលទទួលបានពីបណ្តាស្ថាប័ន ដែលកំពុងអនុវត្តការងារហគមន៍ព្រៃឈើ និងទទួលបានពីការ ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។
- បន្ទាប់ពីអនុវត្តកម្មវិធីសហគមន៍ព្រៃឈើបានរយៈពេល៥ឆ្នាំរដ្ឋបាលព្រៃឈើក្នុងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធចាំបាច់ត្រូវ ធ្វើការពិនិត្យ និងកែសម្រួលនូវទម្រង់នៃការបង្កើតសហគមន៍ព្រៃឈើដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ។

### រដ្ឋបាលព្រៃឈើ

- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មាន រួមមានទិន្នន័យ លទ្ធផល និងព័ត៌មានភូមិសាស្ត្រដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ។ ទិន្នន័យទាំងនេះ នឹងដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមរយៈគេហទំព័ររបស់រដ្ឋបាលព្រៃឈើ និងចែកចាយដល់ដៃគូពាក់ព័ន្ធ
- លើកទឹកចិត្តដល់សហគមន៍តាមរយៈការកាត់បន្ថយថ្លៃសួយសារ និងបុព្វលាភដល់សហគមន៍ព្រៃឈើដើម្បីរួមចំណែកដល់ការ កាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល
- គាំទ្រដល់សហគមន៍ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើក្នុងព្រៃសហគមន៍។

### អាជ្ញាធរមូលដ្ឋាន

- គាំទ្រដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើតាមរយៈការធ្វើសមាហរណកម្មផែនការសហគមន៍ព្រៃឈើទៅក្នុងផែនការអភិវឌ្ឍ និង ប្រើប្រាស់ដី និងកម្មវិធីវិនិយោគឃុំ ព្រមទាំងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគមន៍ព្រៃឈើ។

### សហគមន៍ព្រៃឈើ

- ត្រូវចងក្រងឯកសារ និងទិន្នន័យសហគមន៍ព្រៃឈើទាំងអស់ រួមទាំងបទពិសោធន៍ដែលទទួលបានពីកាអនុវត្តការងារសហគមន៍ ព្រៃឈើ
- ចងក្រងសមាជិកសហគមន៍ព្រៃឈើជាបណ្តាញ ក្នុងគោលបំណងបង្កើតជាសម្ព័ន្ធភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងចែករំលែកនូវបទពិសោធន៍ដែលទទួលបានពីការអនុវត្តរវាងសមាជិកសហគមន៍ព្រៃឈើ ភ្នាក់ងាររាជរដ្ឋាភិបាល និងភាគី ដៃគូពាក់ព័ន្ធផ្សេងៗទៀត។

### ៤.១៤.២ វិធីសាស្ត្រអនុវត្ត

អនុកម្មវិធីនេះនឹងត្រូវអនុវត្តន៍ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបាននឹងកំពុងធ្វើការងារសហគមន៍ព្រៃឈើ ក៏ដូចជា អង្គការដៃគូ និងសហគមន៍មូលដ្ឋាន។ ដើម្បីអនុវត្តអនុកម្មវិធីនេះបានទទួលជោគជ័យ សកម្មភាពមួយចំនួននឹងត្រូវធ្វើដូចតទៅ ៖

- *ផ្តល់ចំណេះដឹងពង្រឹងសមត្ថភាពផ្សព្វផ្សាយ និងសិក្សាស្រាវជ្រាវ៖* ដូចមានចែងនៅក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព និងស្រាវជ្រាវ
- *គ្រប់គ្រងព័ត៌មាន៖* ប្រមូល វិភាគ គ្រប់គ្រង និងចែកចាយព័ត៌មានអំពីព្រៃឈើទៅឱ្យភាគីពាក់ព័ន្ធ
- យន្តការដោះស្រាយទំនាស់៖ មន្ត្រីរដ្ឋបាលព្រៃឈើនឹងធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ដើម្បីកាត់បន្ថយផលប៉ះពាល់ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ

- *រៀបចំបណ្តាញសហគមន៍ព្រៃឈើ៖* រៀបចំបណ្តាញសហគមន៍ព្រៃឈើថ្នាក់ជាតិ និងនៅមូលដ្ឋាន ដើម្បីពង្រឹងការគ្រប់គ្រង បណ្តាញដោយខ្លួនឯង
- *សម្របសម្រួល និងកិច្ចសហការ៖* បង្កើនទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធ តាមរយៈគណៈកម្មការសម្របសម្រួលកម្មវិធី សហគមន៍ព្រៃឈើ
- *កែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋាននានា៖* ធ្វើការពិនិត្យឡើងវិញពីប្រសិទ្ធភាពនៃកាធនុវត្តលិខិតបទដ្ឋាន នានាពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ដើម្បីឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែង
- *ថ្លៃសួយសារ និងបុព្វលាភ៖* រៀបចំប្រព័ន្ធឱ្យមានតម្លាភាពក្នុងការកំណត់ថ្លៃសួយសារនិងបុព្វលាភសម្រាប់សហគមន៍ព ឈើ ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងដល់សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធសំខាន់ៗ អំពីបច្ចេកទេសគ្រប់គ្រងព្រៃឈើជា មូលដ្ឋានទាំងព្រៃធម្មជាតិ និងចម្ការព្រៃដាំរបស់សហគមន៍។

### ៤.១៤,៣ លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកសម្រាប់រយៈពេល ២០ ឆ្នាំ មានដូចខាងក្រោម ៖

- ចំណេះដឹងផ្នែកសហគមន៍ព្រៃឈើ ត្រូវបានបង្កើន
- សមត្ថភាពរបស់ភាគីពាក់ព័ន្ធ នឹងការងារសហគមន៍ព្រៃឈើ ត្រូវបានបង្កើន
- ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តសហគមន៍ព្រៃឈើ ត្រូវបានការប្រមូល គ្រប់គ្រង និងធ្វើការចែកចាយដល់អ្នកពាក់ព័ន្ធតាមរយៈ គេហទំព័ររបស់រដ្ឋបាលព្រៃឈើ
- ទំនាស់ក្នុងការគ្រប់គ្រងព្រៃសហគមន៍ ត្រូវបានកាត់បន្ថយ
- បណ្តាញសហគមន៍ព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវបានបង្កើតឡើង
- គម្រោងឥណទានកាបូនសហគមន៍ព្រៃឈើ ត្រូវបានបង្កើត
- ការគ្រប់គ្រងព្រៃសហគមន៍ ការបែងចែកផលប្រយោជន៍ អភិបាលកិច្ច ទីផ្សារ និងការបង្កើនជីវភាពត្រូវបានធ្វើឱ្យប្រសើរឡើង
- កិច្ចសហការរវាងភាគីពាក់ព័ន្ធ ត្រូវបានធ្វើឱ្យប្រសើរឡើង
- លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធសហគមន៍ព្រៃឈើ ត្រូវបានកែលំអ ដោយយោងទៅលើបទពិសោធន៍ដែលទទួលបានពីការអនុវត្ត និងយុទ្ធសាស្រ្តថ្មីៗ
- ប្រកាសស្តីពីការកំណត់ថ្លៃសួយសារ និងបុព្វលាភសម្រាប់សហគមន៍ព្រៃឈើ ត្រូវបានអនុម័ត និងអនុវត្ត។

### ៤.១៥ ផ្នែកពាក់ព័ន្ធសំខាន់ៗ ( គោលនយោបាយ ច្បាប់ កំណែទម្រង់ស្ថាប័ន ទំនាក់ទំនង សមត្ថភាព ហិរញ្ញប្បទាន តម្រូវការ និងការបែងចែកផលប្រយោជន៍ )

- ផ្តល់សិទ្ធិអំណាចដល់សហគមន៍ព្រៃឈើ ក្នុងការប្រើប្រាស់ដី និងការរៀបចំ គ្រប់គ្រងព្រៃឈើក្នុងរយៈពេលវែង
- ការកសម្រួលលិខិតបទដ្ឋានច្បាប់ ដើម្បីបង្កើតជាទម្រង់បែបបទសម្រាប់សហគមន៍ព្រៃឈើអនុវត្តទៅដោយរលូន និងឯកភាពគ្នា
- ក្នុងចំណោមសហគមន៍ព្រៃឈើទាំងអស់ដែលចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ពីការទទួលខុសត្រូវផ្នែកសេវាកម្មឱ្យដល់ ភាគីពាក់ព័ន្ធផ្សេងៗ
- ពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ដើម្បីជៀសវាងរាល់បញ្ហាទំនាស់ផលប្រយោជន៍ និងគោលបំណងដើម្បីស្វែងរកផលប្រយោជន៍
- ជំរុញឱ្យមានការដាំដុះព្រៃឈើឡើងវិញ ក្នុងគោលបំណងច្រើនយ៉ាង
- ប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវបានធ្វើឱ្យងាយស្រួលឡើង (សារពើភណ្ឌព្រៃឈើ រុក្ខវប្បកម្ម អត្រាដំណុះ តារាងមានឈើ អនុផលព្រៃឈើ ការគ្រប់គ្រង និងត្រួតពិនិត្យជីវចម្រុះ)។ល។
- អភិបាលកិច្ចផ្ទៃក្នុងស្ថាប័នល្អ
- ផ្តល់សម្ភារៈផ្សព្វផ្សាយ សម្រាប់សហគមន៍ព្រៃឈើ ដូចជាផ្ទាំងរូបភាព បដា ខិត្តបណ្ណ វិទ្យុ ខ្សែភាពយន្ត។ល។
- អាជ្ញាធរមូលដ្ឋានទទួលបានថវិកាពីក្រសួងមហាផ្ទៃ សម្រាប់ការអភិវឌ្ឍសហគមន៍ព្រៃឈើ
- បន្តនូវមូលនិធិ នៅកម្រិតសហគមន៍ព្រៃឈើ សម្រាប់និរន្តរភាពផ្នែកហិរញ្ញវត្ថុនៃការងារសហគមន៍ព្រៃឈើ
- ការវិនិយោគឡើងវិញដោយផ្ទាល់ នូវរាល់ចំណូលដែលបានមកពីពន្ធអាករ និងឥណទានកាបូន (ឧទាហរណ៍ពីកម្រិតជាតិ ទៅ ក្នុងការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើជាតិ)។

### ៤.១៦ តម្រូវការហិរញ្ញវត្ថុ

តារាងទី៤ ៖ គម្រោងថវិកា សម្រាប់កម្មវិធីសហគមន៍ព្រៃឈើជាតិ ឆ្នាំ ២០១០-២០២០ (គិតជាដុល្លារអាមេរិច)

| | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ |
|---|---|---|

| អនុកម្មវិធី | ២០១០-២០១ (ដុល្លារអាមេរិក) | ២០១០-២០១៤ (ដុល្លារអាមេរិក) |
|---|---|---|
| ៤.១ ការកំណត់តំបន់សក្តានុពល និងការបង្កើតសហគមន៍ព្រៃឈើ | ៦.៣៥០.០០០ | ៦៣៥.០០០ |
| ៤.២ ការអភិវឌ្ឍសហគមន៍ និង ការបង្កើនជីវភាព | ១.៤៥០.០០០ | ១.៤៥០.០០០ |
| ៤.៣ ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍ សហគមន៍ព្រៃឈើ | ១.២០០.០០០ | ១.២០០.០០០ |
| សរុប | ៩.០០០.០០០ | ៩.០០០.០០០ |
| ថវិកាបរិច្ចាគមកពីដៃគូអភិវឌ្ឍន៍ | ៦.១០០.០០០ | |

សន្មតថា ចំណូលពីព្រៃឈើនឹងត្រូវធ្វើការវិនិយោគឡើងវិញទៅក្នុងផ្នែកនិងការងារខាងលើនេះ ដែលជាលទ្ធផល នឹងធ្វើឱ្យការអនុវត្ត ការងារនេះកាន់តែមានលក្ខណៈស្វ័យហិរញ្ញប្បទានសមស្រប និងមានសង្គតិភាពជាមួយនឹងកម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាព សម្រាប់វិស័យព្រៃឈើ។ ចំណែកដ ថវិកាបរិច្ចាគពីដៃគូអភិវឌ្ឍន៍នឹងកាន់តែមានការថយចុះបន្តិចម្តងៗ នៅជំហានទី២ ដែលមាន រយៈពេល៥ឆ្នាំទៀត។

## ៨.៥ កម្មវិធីទី ៥ អភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ

### ៥.១ ចំណុចអាទិភាពសំខាន់ៗ

- អភិវឌ្ឍន៍ធនធានមនុស្ស
- អភិវឌ្ឍការអប់រំ និង ស្ថាប័ន
- ផ្សព្វផ្សាយស្តីពីវិស័យព្រៃឈើ នឹង បង្កើនការយល់ដឹងជាសាធារណៈ
- វិភាគ និង បកស្រាយទិន្នន័យ អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ
- សម្របសម្រួលក្នុងចំណោមអ្នកអនុវត្ត

### ៥.២ រយៈពេលកម្មវិធី

មានយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២៩។

## ៥.៣ ការឆ្លើយតបរបស់កម្មវិធីនេះទៅនឹងទស្សនវិស័យកម្មវិធីពលឈើជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសស្ដីពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ នៅឆ្នាំ ២០០៨ ដែលក្នុងនោះ មានគោលបំណងមួយគឺ ជានានូវនិរន្តរភាពបរិស្ថាន តាមរយៈការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ កម្មវិធី ព្រៃឈើជាតិផ្តល់នូវគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រដែលមានគោលបំណងគាំទ្រដល់គោលនយោបាយវិស័យព្រៃឈើជាតិ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការអភិរក្សជីវចម្រុះ និងបរិស្ថាន។

ប្រសិនបើពុំមានឆន្ទៈក្នុងការកសាងសមត្ថភាព និងដោះស្រាយបញ្ហាប្រឈមនោះទេ នោះនឹងពុំអាចអនុវត្តកម្មវិធី ព្រៃឈើជាតិបានជោគជ័យតាមការតម្រូវការជាក់ស្តែងឡើយ។ ដូចនេះ ការពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធមានសារៈសំខាន់ ណាស់ ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលបំណងក្នុងកម្មវិធីព្រៃឈើជាតិ។កម្មវិធីអភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវ ជាមូលដ្ឋានគ្រឹះគាំទ្រដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ ដោយធ្វើការពង្រឹងសមត្ថភាពនៅគ្រប់កម្រិត និងធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពនឹងសកម្មភាពការងារស្រាវជ្រាវ ដើម្បីធ្វើឱ្យសម្រេចដល់ការអនុវត្តកម្មវិធី ផែនការ និងគោលនយោបាយវិស័យ ព្រៃឈើជាតិ។

កត្តាសំខាន់ ដើម្បីនិរន្តរភាពសកម្មភាពការងារទាំងអស់នេះ គឺជានាធនធានហិរញ្ញវត្ថុដើម្បីបង្កើនគុណភាពកម្មវិធីសិក្សាអប់រំ វិស័យព្រៃឈើ និងធានាឱ្យមានអ្នកមានសមត្ថភាពសមស្រប ដែលត្រូវជ្រើសរើសមកបម្រើការងារក្នុងវិស័យព្រៃឈើ។ សាលាជាតិកសិកម្ម ព្រែកលៀប និងសកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលជាគ្រឹះស្ថានអប់រំអំពីវិស័យព្រៃឈើដ៏សំខាន់ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរនូវទម្លាប់ចាស់ (វប្បធម៌) នៃការអនុវត្ត និងចាំបាច់ត្រូវមានទស្សនវិស័យវែងឆ្ងាយ គួបផ្សំជាមួយការលើកកម្ពស់វិធីសាស្ត្របង្រៀន និងបច្ចុប្បន្នភាព កម្មវិធី និងមុខវិជ្ជាសិក្សាព្រមទាំងសមត្ថភាពគ្រូបង្រៀន។

## ៥.៤ ការឆ្លើយតបរបស់កម្មវិធីនេះទៅនឹងគោលបំណងកម្មវិធីព្រៃឈើជាតិ

កម្មវិធីនេះនឹងកំណត់បាននូវតម្រូវការសមត្ថភាពជាយុទ្ធសាស្ត្រ និងរៀបចំកម្មវិធីពង្រឹងសមត្ថភាពដើម្បីជួយដល់អ្នកពាក់ព័ន្ធ នៅក្នុងវិស័យព្រៃឈើ និងបរិស្ថានទទួលបានប្រយោជន៍ពីការចូលរួមក្នុងការងារទាំងនេះ នឹងធ្វើឱ្យសម្រេចបានតាមគោលបំណងកម្មវិធី ព្រៃឈើជាតិ។ កម្មវិធីនេះនឹងពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធដើម្បីជំនះឧបសគ្គនាពេលអនាគត តាមរយៈការអភិវឌ្ឍជាប្រចាំនូវជំនាញដោះស្រាយបញ្ហាចំពោះមុខប្រព័ន្ធគ្រប់គ្រង និងការបង្កើតបច្ចេកទេសថ្មីៗទៀតក្នុងវិស័យព្រៃឈើ។ ធ្វើដូច្នេះនឹងបង្កើននូវក្តីសង្ឃឹមន ការអភិវឌ្ឍ និងការគ្រប់គ្រងព្រៃឈើបែបថ្មីដោយនិរន្តរភាព ក៏ដូចជាការផ្តួចផ្តើមគម្រោងមូលនិធិបែបថ្មីផងដែរ។

## ៥.៥សាវតារកម្ម

ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យព្រៃឈើ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជ្រុង ២ នៃមុំទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី ២ (ដែលបានវិវត្តពី យុទ្ធសាស្ត្រត្រីកោណ)គឺជាការធ្វើឱ្យប្រសើរឡើងនូវវិស័យកសិកម្ម និងកសាងសមត្ថភាពនិងអភិវឌ្ឍធនធាន មនុស្ស រាជរដ្ឋាភិបាលកម្ពុជា ២០០៨)។ ដូចនេះកម្មវិធីនេះ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអាទិភាពជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការសិក្សាមួយចំនួននាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញនូវសារៈសំខាន់និងតម្រូវការជាចាំបាច់ក្នុងការ អភិវឌ្ឍសមត្ថភាព ដូចជា អ្នកបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបច្ចេកទេស និងពីសកលវិទ្យាល័យមានចំណេះដឹងមិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហា។នេះគឺជាបញ្ហាចម្បងមួយក្នុងដំណើរការកំណែទម្រង់ការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងបែបវិមជ្ឈការ(អង្គការ JICA ២០០៤ ធនាគារពិភពលោក ២០០៤ គម្រោង CTSP ២០០៥ និង GFA ២០០៥)។ម្យ៉ាងវិញទៀត នៅក្នុងដំណើរការធ្វើវិមជ្ឈការ ជាឧទាហរណ៍ ត្រូវបានធ្វើការប៉ាន់ស្មានថា ដើម្បីកសាងបាននូវសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលក្រុមប្រឹក្សាឃុំនិងសហគមន៍មូលដ្ឋាន ទាមទាររយៈពេលជាច្រើនឆ្នាំ។

វិស័យព្រៃឈើបានទទួលនូវជំនួយអភិវឌ្ឍសមត្ថភាពកាលពីឆ្នាំមុនៗ ប៉ុន្តែនៅតែមានភាពខ្វះចន្លោះ ដែលចាំបាច់ត្រូវធ្វើការ ដោះស្រាយដើម្បីធ្វើឱ្យរដ្ឋបាលព្រៃឈើក្លាយទៅជាអាជ្ញាធរព្រៃឈើដែលមានសមត្ថភាពពេញលេញ។ កម្មវិធីពង្រឹងសមត្ថភាពសម្រាប់ វិស័យព្រៃឈើនាពេលបច្ចុប្បន្នដែលគាំទ្រដោយអង្គការ JICA បានរកឃើញថា មន្ត្រីរដ្ឋបាលព្រៃឈើត្រូវការវគ្គបណ្តុះបណ្តាលស្តីពីការ ធ្វើផែនការគ្រប់គ្រងព្រៃឈើ ការអនុវត្តការងារនៅលើទីតាំងជាក់ស្តែងបច្ចេកទេសរុក្ខវប្បកម្ម និងសហគមន៍ព្រៃឈើ ។

មានការផ្តល់ជាអនុសាសន៍ផងដែរថា ការពង្រឹងសមត្ថភាពត្រូវផ្តោតការយកចិត្តទុកដាក់លើជំនាញអនុវត្តជាក់ស្តែងក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់ សមត្ថភាពវិភាគ សមត្ថភាពគ្រប់គ្រង និងសមត្ថភាពគរុកោសល្យ។

ដើម្បីឱ្យអនុកម្មវិធីនីមួយៗរបស់កម្មវិធីព្រៃឈើជាតិអនុវត្តបានជោគជ័យ ការសំខាន់គឺអ្នកអនុវត្តត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរួមចំណែកពេញលេញធ្វើឱ្យសម្រេចនូវគោលបំណងនៃកម្មវិធីនីមួយៗ។ ដោយបច្ចុប្បន្ន មានគម្លាតខ្លាំងរវាងសមត្ថភាព ជាក់ស្តែង និងតម្រូវការនោះ ជាការចាំបាច់ត្រូវអភិវឌ្ឍកម្មវិធីកសាងសមត្ថភាព ដើម្បីពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធចូលរួមអនុវត្តកម្មវិធី ព្រៃឈើជាតិឱ្យបានរឹងមាំ។

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពនិងការស្រាវជ្រាវត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងចំណុចខ្វះខាតនៃធនធានមនុស្សនៅក្នុង វិស័យព្រៃឈើ។ កម្មវិធីនេះត្រូវឆ្លើយតបទាំងផ្នែកទ្រឹស្តីនិងការអនុវត្តជាក់ស្តែង ជាពិសេសត្រូវផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្ត។ ប្រការនេះនឹងរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សដែលជាអ្នកពាក់ព័ន្ធនៅក្នុងវិស័យព្រៃឈើ នឹងជួយគាំទ្រដល់រាជរដ្ឋាភិបាល កម្ពុជាក្នុងការសម្រេចនូវពហុបំណងទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## ៥.៦ ការវិភាគបញ្ហា

នាពេលបច្ចុប្បន្ននេះ តំបន់ព្រៃឈើជាច្រើនដែលពុំទាន់ត្រូវបានរៀបចម្ការគ្រប់គ្រងឱ្យល្អ មានហានិភ័យខ្ពស់ ចំពោះការរេចរឹល ព្រៃឈើ និងការផ្លាស់ប្តូរទៅជាដីប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ។ ចំពោះមុខ រាជរដ្ឋាភិបាលកម្ពុជា កំពុងដំណើរការកំណែទម្រង់ វិស័យព្រៃឈើ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់វិស័យព្រៃឈើដល់ការអភិវឌ្ឍ និងការអភិរក្ស។

នៅក្នុងកំណែទម្រង់វិស័យព្រៃឈើ កំពុងជួបប្រទះនូវការលំបាកក្នុងការស្វែងរកនូវប្រព័ន្ធដែលសមស្រដើម្បីគាំទ្រដល់ការ អនុវត្តចក្ខុវិស័យព្រៃឈើជាតិ និងចាំបាច់ត្រូវបន្តការសិក្សាស្រាវជ្រាវនិងធ្វើការសាកល្បងនូវគំរូថ្មីៗនៃការគ្រប់គ្រងព្រៃឈើប្រកបដោយ និរន្តរភាពនឹងពង្រីកបន្ថែមការអនុវត្ត។ នាពេលថ្មីៗនេះ រដ្ឋបាលព្រៃឈើកំពុងស្ថិតនៅក្នុងដំណើរការពង្រីកប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដោយមានការចូលរួម ដូចជាសហគមន៍ព្រៃឈើ នឹងធ្វើការសិក្សានូវគំរូគ្រប់គ្រងព្រៃឈើតាមបែបសហគមន៍ពាណិជ្ជកម្មព្រៃឈើនៅ ក្នុងតំបន់ព្រៃសម្បទាន។ បេក្ខជននិស្សិតចេញមកពីសកលវិទ្យាល័យ និងសាលាមធ្យមបច្ចេកទេសនានា មិនទាន់មានសមត្ថភាព គ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាប្រឈមដែលអាចនឹងកើតមានឡើងនៅពេលអនាគតទេ ជាការសំខាន់ណាស់ដែលអ្នកកំពុង គ្រប់គ្រងព្រៃឈើបច្ចុប្បន្ន និងអ្នកពាក់ព័ន្ធនៅក្នុងវិស័យព្រៃឈើ ត្រូវអភិវឌ្ឍន៍ជំនាញដើម្បីបំពេញទៅនឹងតម្រូវការ ថ្មីៗនេះ ក្នុងគោលបំណង គាំទ្រដល់សហគមន៍ ក្រុមប្រឹក្សាឃុំ ដៃគូឯកជននិងអង្គការសង្គមស៊ីវិល ដែលដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍ និងអនុវត្តន៍គំរូ គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ ជំនាញទាំងនេះមិនត្រឹមតែទាក់ទងដល់ការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងប៉ុណ្ណោះទេ ថែមទាំង រួមចំណែកក្នុងការផ្លាស់ប្តូរឥរិយាបថទំនាក់ទំនងប្រកបដោយសមធម៌ជាមួយអ្នកពាក់ព័ន្ធថែមទៀតផង។ នេះគឺជាដំណើរការរយៈពេល យូរមួយ ដោយតម្រូវឱ្យមានការឆ្លុះបញ្ចាំងជាប្រចាំដើម្បីកែលំអការគ្រប់គ្រងព្រៃឈើឱ្យទទួលបានលទ្ធផលល្អ។

នាពេលបច្ចុប្បន្ននេះ ការស្រាវជ្រាវអំពីវិស័យព្រៃឈើនៅក្នុងប្រទេសកម្ពុជានៅមានកម្រិត និងពុំសូវមានការសម្របសម្រួល ហើយជាធម្មតា ការសិក្សាស្រាវជ្រាវទាំងនេះពុំបានគាំទ្រពេញលេញដល់កិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងព្រៃឈើដោយ និរន្តរភាពឡើយ។ រដ្ឋបាលព្រៃឈើ

បច្ចុប្បន្ននេះពុំទាន់មានសមត្ថភាពពេញលេញដើម្បីអនុវត្តការងារស្រាវជ្រាវជាមូលដ្ឋានអំពីព្រៃឈើ ទេ ហើយសកលវិទ្យាល័យនានាក៏ខ្វះនូវធនធានមនុស្ស និងថវិកាដើម្បីអនុវត្តគម្រោងស្រាវជ្រាវព្រៃឈើដែរ។ ការស្រាវជ្រាវទាក់ទង នឹងព្រៃឈើកន្លងមក ច្រើនតែធ្វើឡើងដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិនានា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និង អ្នកស្រាវជ្រាវអន្តរជាតិ ។

លទ្ធផលស្រាវជ្រាវទាំងនេះមិនត្រូវបានផ្តល់មករដ្ឋបាលព្រៃឈើដើម្បីពិនិត្យ និងប្រើប្រាស់ក្នុងពេលរៀបចំនូវគោលនយោបាយ ព្រៃឈើឡើយ។ តម្រូវការចាំបាច់ដែលថ្នាក់ជាតិត្រូវធ្វើឱ្យប្រសើរឡើងនោះ គឺកិច្ចសហប្រតិបត្តិការសម្របសម្រួលរវាងអង្គការស្រាវជ្រាវ និងអង្គភាពរដ្ឋាភិបាលដើម្បីប្រើប្រាស់លទ្ធផលស្រាវជ្រាវសម្រាប់រៀបចំយុទ្ធសាស្ត្រថ្មីៗ បម្រើដល់ការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព កាត់បន្ថយភាពក្រីក្រ ធានាកិច្ចការពារ អភិរក្សជីវចម្រុះ បរិស្ថាន និងអភិវឌ្ឍសេដ្ឋកិច្ច។

នៅក្នុងដំណើរការត្រួតពិនិត្យ និងធ្វើផែនការគ្រប់គ្រងវិស័យព្រៃឈើ ចាំបាច់ត្រូវប្រមូលទិន្នន័យដោយប្រើប្រាស់នូវវិធីសាស្ត្រ វិទ្យាសាស្ត្រសមស្រប។ សំខាន់ជាងនេះទៅទៀតគឺថា ទិន្នន័យទាំងនោះដួរត្រូវបានយកមកប្រើប្រាស់តាមរយៈការវិភាគ នឹងបកស្រាយ ទិន្នន័យច្បាស់លាស់។ លទ្ធផលនឹងត្រូវយកទៅបង្ហាញដល់អ្នកគ្រប់គ្រង និងអ្នកធ្វើសេចក្តីសម្រេចចិត្តទាំងក្នុងរដ្ឋបាលព្រៃឈើ និង ស្ថាប័ន អង្គភាពពាក់ព័ន្ធគឺដើម្បីធ្វើឱ្យប្រសើរឡើងលើការងារត្រួតពិនិត្យ ការធ្វើផែនការគ្រប់គ្រងព្រៃឈើសម្រាប់ការអភិវឌ្ឍធនធាន ព្រៃឈើជាបន្តបន្ទាប់។ ជាងនេះទៅទៀត ជាការចាំបាច់ ត្រូវមានតម្លាភាពក្នុងការចែករំលែកព័ត៌មាន និងត្រូវរៀបចំផងដែរនូវយុទ្ធសាស្ត ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដើម្បីជូនជាព័ត៌មានដល់អ្នករៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អ្នកគ្រប់គ្រងព្រៃឈើ តាមមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ព្រមទាំងផ្សព្វផ្សាយព័ត៌មានស្រាវជ្រាវ និងផ្តល់ឯកសារផ្សព្វផ្សាយជាសាធារណៈ។

## ៥.៧ គោលបំណង

គោលបំណងរបស់កម្មវិធីនេះ គឺមានសមត្ថភាព ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ។ ការអភិវឌ្ឍសមត្ថភាព គឺត្រូវធ្វើ ដោយយកចិត្តទុកដាក់បំផុតដោយមិនត្រឹមតែធ្វើការបណ្តុះបណ្តាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់បុគ្គល ម្នាក់ៗ ឬក្រុមដែលមានភារកិច្ចបំពេញតួនាទីរបស់ខ្លួន។ ម្យ៉ាងទៀត ការអភិវឌ្ឍសមត្ថភាពមិនត្រឹមតែកសាងធនធានមនុស្សប៉ុណ្ណោះទេ គឺត្រូវគិតគូរអំពីធនធានដែលជាតម្រូវការក្នុងការអនុវត្តរបស់ពួកគេ។

*គោលបំណងជាក់លាក់របស់កម្មវិធីនេះរួមមាន ៖*

- លើកកម្ពស់ការអប់រំជាមូលដ្ឋានទៅលើការគ្រប់គ្រងធនធានធម្មជាតិ

- បង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធ ដើម្បីឱ្យមានសមត្ថភាពនិងជឿជាក់ក្នុងការដោះស្រាយបញ្ហាប្រឈមដែល
- កើតមាននៅក្នុងពេលដំណើរការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពតាមបែបគំរូថ្មី
- បង្កើនសមត្ថភាពនិងប្រសិទ្ធភាពក្នុងការរៀបចំជាយុទ្ធសាស្រ្តផ្សព្វផ្សាយនិងផ្តល់នូវសេវាផ្សព្វផ្សាយដែលផ្តល់ការគាំទ្រយ៉ាងសកម្មជាប្រចាំដល់ការងារស្តារព្រៃឈើឡើងវិញ និង គ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន
- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវមន្ត្រីរដ្ឋបាលព្រៃឈើ សាលាបច្ចេកទេស សកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលដែលធ្វើការងារ ស្រាវជ្រាវ ដើម្បីផ្តល់នូវព័ត៌មានឯករាជ្យ និងជឿជាក់បានសម្រាប់គាំទ្រដល់ការរៀបចំ និងអនុវត្តគោលនយោបាយព្រៃឈើ និង គោលបំណងស្តីពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការការពារ បរិស្ថាន និងការកាត់បន្ថយភាពក្រីក្រ
- បញ្ជ្រាបការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន។

## ៥.៨ សូចនាករ

### ៥.៨.១ ការកសាងសមត្ថភាព និង ការកែទម្រង់អង្គភាព

- ការប៉ាន់ស្មានតម្រូវការសមត្ថភាព និងយុទ្ធសាស្រ្តបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សាអប់រំពាក់ព័ន្ធអង្គការសង្គមស៊ីវិល អ្នកពាក់ព័ន្ធចាំបាច់ត្រូវរៀបចំនិងអនុវត្ត។
- ការកែទម្រង់រដ្ឋបាលព្រៃឈើត្រូវតែធ្វើ ដោយមានការកំណត់អំពីតួនាទី និងការទទួលខុសត្រូវយ៉ាង
- ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន និងការកំណត់អំពីតម្រូវការវគ្គបណ្តុះបណ្តាល
- កម្មវិធីលើកទឹកចិត្ត ដើម្បីបង្កើនផលិតភាពដោយមន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវរៀបចំ និងអនុវត្ត
- មន្ត្រីរដ្ឋបាលព្រៃឈើ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន គ្រឹះស្ថានសិក្សាអប់រំចូលរួមក្នុងវគ្គបណ្តុះបណ្តាល
- ផែនការវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ត្រូវបានរៀបចំ និងអនុវត្ត
- បង្កើនការយល់ដឹង និងការអនុវត្តដោយធ្វើផែនការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពីការងារគ្រប់គ្រងព្រៃឈើដោយ និរន្តភាពតាមបែបគំរូថ្មី ដូចជាយន្តការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ (REDD) សេវាកម្មអភិរក្សជីវចម្រុះ និងបរិស្ថាន ត្រូវបានរៀបចំនិងអនុវត្ត។

### ៥.៧.២ ការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង

- គោលការណ៍ណែនាំអំពីការបញ្ជ្រាបគោលនយោបាយព្រៃឈើជាតិ និងឯកសារពាក់ព័ន្ធទៅនឹងវិស័យព្រៃឈើត្រូវបានអភិវឌ្ឍ
- ក្រុមប្រឹក្សាឃុំ សហគមន៍ ប្រជាជនមូលដ្ឋាន គាំទ្រការអនុវត្តឱ្យបានជោគជ័យចំពោះការងារគ្រប់គ្រងព្រៃឈើតាមបែបវិមជ្ឈការ និងការដាំដុះព្រៃឈើឡើងវិញជាលក្ខណៈឯកជន
- មន្ត្រីផ្សព្វផ្សាយត្រូវបានទទួលការបណ្តុះបណ្តាលស្តីពីការងារសម្របសម្រួល និងដោះស្រាយទំនាស់
- យុទ្ធនាការផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីការអនុវត្តកម្មវិធីព្រៃឈើជាតិ ត្រូវបានរៀបចំ និងអនុវត្ត
- ការពិគ្រោះយោបល់ជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន សហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធក្នុងការងារគ្រប់គ្រងព្រៃឈើ ត្រូវបានរៀបចំ
- ឯកសារផ្សព្វផ្សាយត្រូវបានរៀបចំអភិវឌ្ឍ និងផ្សព្វផ្សាយដោយផ្តល់ឯកសារតាមគេហទំព័រនិងតាមមធ្យោបាយសមស្របផ្សេងៗទៀត
- មជ្ឈមណ្ឌលផ្សព្វផ្សាយព្រៃឈើ ត្រូវបានរៀបចំឡើង និងដាក់ឱ្យដំណើរការ
- គេហទំព័រត្រូវបានរៀបចំអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទៀងទាត់ ឬតាមការចាំបាច់សម្រាប់អ្នកប្រើប្រាស់ដោយមូលំទូលាយ
- ការងារគ្រប់គ្រងព្រៃឈើដោយនិរន្តភាពត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំសិក្សាគ្រប់កម្រិត។

### ៥.៨.៣ ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវព្រៃឈើ

- កម្មវិធីស្រាវជ្រាវដើម្បីគាំទ្រដល់កម្មវិធីព្រៃឈើជាតិ ដែលត្រូវអនុវត្តដោយរដ្ឋបាលព្រៃឈើសកលវិទ្យាល័យពាក់ព័ន្ធ និង វិទ្យាស្ថានស្រាវជ្រាវផ្សេងៗទៀត នឹងត្រូវរៀបចំ និងបន្តអនុវត្ត
- យុទ្ធសាស្ត្រទំនាក់ទំនងក្នុងការងារស្រាវជ្រាវត្រូវបានរៀបចំ និងអនុវត្ត
- ឯកសារស្រាវជ្រាវ គោលនយោបាយ ស្ថិតិ និងក្បួនអនុវត្តជាក់ស្តែង ត្រូវបានរៀបចំ និងបោះពុម្ព
- កម្មវិធី ឬគម្រោងស្រាវជ្រាវព្រៃឈើ ជីវចម្រុះរួមគ្នាជាមួយអង្គការជាតិ និងអន្តរជាតិត្រូវបានរៀបចំ និង អនុវត្ត
- ផ្តល់បទបង្ហាញស្តីពីលទ្ធផលស្រាវជ្រាវថ្មីៗក្នុងសិក្ខាសាលាថ្នាក់ជាតិ និង អន្តរជាតិ
- មន្ត្រីរដ្ឋបាលព្រៃឈើ និងអង្គការស្រាវជ្រាវពាក់ព័ន្ធចូលរួមបង្រៀនដល់និស្សិតផ្នែកព្រៃឈើ និងបរិស្ថាន សម្រាប់កម្រិតឧត្តម និងក្រោយឧត្តម។

## ៥.៩ មធ្យោបាយផ្ទៀងផ្ទាត់

### ៥.៩,១ ការកសាងសមត្ថភាព និងការកែទម្រង់អង្គភាព

- ឯកសារប៉ាន់ស្មានតម្រូវការសមត្ថភាព
- ឯកសារភារកិច្ចការងាររបស់មន្ត្រីរដ្ឋបាលព្រៃឈើ (ថ្នាក់កណ្តាលនិងមូលដ្ឋាន) និង ឯកសារ
- ឯកសារមន្ត្រីរដ្ឋបាលព្រៃឈើទទួលអនុវត្តកម្មវិធីលើកទឹកចិត្ត
- ឯកសារវគ្គបណ្តុះបណ្តាល (មន្ត្រីរដ្ឋបាលព្រៃឈើ អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា) • ឯកសារ ផែនការបណ្តុះបណ្តាល
- ឯកសារផ្សព្វផ្សាយ ឬ ផែនការបណ្តុះបណ្តាល ។

### ៥.៩.២ ការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង

- ឯកសារគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបគោលនយោបាយព្រៃឈើជាតិ និងឯកសារពាក់ព័ន្ធទៅនឹងវិស័យព្រៃឈើ
- ឯកសារ និង របាយការណ៍ស្តីពីការចូលរួមគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន
- ឯកសារបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយ

  ៥.៩.៣ ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវព្រៃឈើឯកសារនិងរបាយការណ៍ស្តីពីការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន
- ឯកសារ របាយការណ៍ពិគ្រោះយោបល់
- គេហទំព័រដំណើរការជាអចិន្ត្រៃយ៍
- របាយការណ៍បដ្ឋមណ្ឌលផ្លាស់ប្តូរព័ត៌មាន
- ឯកសារកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំសិក្សា ។

- ឯកសារកម្មវិធី និងលទ្ធផលស្រាវជ្រាវ
- ឯកសារយុទ្ធសាស្រ្តទំនាក់ទំនងការងារស្រាវជ្រាវ
- ឯកសារបោះពុម្ពស្តីពីលទ្ធផលស្រាវជ្រាវ និងឯកសារពាក់ព័ន្ធ
- ឯកសាកម្មវិធីស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវ រួមគ្នាជាមួយអង្គការជាតិ អន្តរជាតិ
- របាយការណ៍បទបង្ហាញលទ្ធផលស្រាវជ្រាវ កម្រិតជាតិ អន្តរជាតិ
- ឯកសារ និងរបាយការណ៍មន្ត្រីរដ្ឋបាលព្រៃឈើ និងអង្គការស្រាវជ្រាវពាក់ព័ន្ធចូលរួមបង្រៀនដល់និស្សិត។

## ៥.១០ ការរំពឹងទុក និងហានិភ័យនៃកម្មវិធី

### ៥.១០.១ ការរំពឹងទុក

- គ្រប់គ្រឹះស្ថានសិក្សាអប់រំដែលពាក់ព័ន្ធមានការយកចិត្តទុកដាក់
- មន្ត្រីត្រូវបានលើកទឹកចិត្ត ឱ្យចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាល
- ថវិកាគឺជាអាទិភាពចម្បងសម្រាប់ការងារបង្កើនសមត្ថភាព និងការងារស្រាវជ្រាវ
- មន្ត្រីស្រាវជ្រាវមានជំនាញច្បាស់លាស់ ឬមន្ត្រីមានសក្តានុពលអភិវឌ្ឍជំនាញត្រូវបានជ្រើសរើស។

### ៥.១០.២ ហានិភ័យ

- ខ្វះភាពជឿជាក់រវាងរដ្ឋបាលព្រៃឈើ និងស្ថាប័ន អង្គភាពផ្សេងៗ
- ខ្វះគ្រូឯកទេស គ្រូបណ្តុះបណ្តាល អ្នកសម្របសម្រួល ដែលមានសមត្ថភាពសមស្រប
- ខ្វះកិច្ចសហការចាំបាច់ជាមួយអ្នកពាក់ព័ន្ធ
- ខ្វះកិច្ចសហការពីអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាល ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រី នគរបាល តុលាការ
- ខ្វះធនធានហិរញ្ញវត្ថុ និងមធ្យោបាយសម្ភារៈក្នុងដំណើរការកំណែទម្រង់។

## ៥.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី

ការអនុវត្តអនុកម្មវិធីនៃកម្មវិធីព្រៃឈើជាតិ ទាមទារនូវចំណេះដឹងជាក់លាក់នៅគ្រប់កម្រិត និងជំនាញថ្មីៗពីរដ្ឋបាលព្រៃឈើ និង អ្នកពាក់ព័ន្ធដែលចូលរួមនៅក្នុងការគ្រប់គ្រងព្រៃឈើ ជាពិសេសលទ្ធភាពនៃការផ្ទេរនិងផ្តល់នូវចំណេះដឹងផ្នែកទ្រឹស្តីពិបាកៗតាមវិធី ងាយស្រួលគឺមានសារៈសំខាន់ណាស់ដល់អ្នកអនុវត្តជាក់ស្តែង។ការបញ្ជ្រាបចំណេះដឹងទាំងនោះដល់បណ្តាអ្នកពាក់ព័ន្ធក៏មានសារៈសំខាន់ ក្នុងការធ្វើឱ្យសម្រេចជោគជ័យនៃកម្មវិធីព្រៃឈើជាតិដែរ។ ការកសាងសមត្ថភាពអាចត្រូវបានសម្របសម្រួលដោយរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលដែលនឹងត្រូវបានបណ្តុះបណ្តាលដើម្បីអាចឱ្យមានលទ្ធភាពអាចផ្តល់សេវាកម្មបានល្អ។

ទាំងការបណ្តុះបណ្តាលជាផ្លូវការ និងការហ្វឹកហ្វឺនក្រៅផ្លូវការ រួមទាំងជំនួយផ្នែកស្មារតីនឹងត្រូវធ្វើឡើងដើម្បីលើកកម្ពស់ការយល់ដឹង និងបង្កើនសមត្ថភាព។ ការផ្លាស់ប្តូរទស្សនកិច្ច ក៏ដូចជាការផ្លាស់ប្តូរព័ត៌មាននឹងត្រូវធ្វើដូចគ្នា ដើម្បីឱ្យសិក្ខាតាមចែករំលែក បទពិសោធន៍ និងសិក្សាពីគ្នាទៅវិញទៅមក។

មានអនុកម្មវិធីចំនួនបីនឹងត្រូវអនុវត្ត ដើម្បីកសាងសមត្ថភាពដែលពាក់ព័ន្ធសំខាន់ទៅនឹងកង្វះខាតក្នុងវិស័យព្រៃឈើ - ដើម្បី បំពេញអោយចក្ខុវិស័យកម្មវិធីព្រៃឈើជាតិមានជាអាទិ៍ ៖

- ការអភិវឌ្ឍការអប់រំ
- ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន
- ការបង្កើនចំណេះដឹង និងផ្សព្វផ្សាយ
- ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ

កម្មវិធីនឹងដោះស្រាយបញ្ហាជាច្រើនក្នុងវិស័យព្រៃឈើ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវផ្នែកទាំង ៤ ទាក់ទងទៅនឹងការកសាង សមត្ថភាព ៖

- បរិបទ (គោលនយោបាយ បទបញ្ញត្តិ ការគាំទ្រគោលនយោបាយ តួនាទីនិងការទទួលខុសត្រូវ)
- រចនាសម្ព័ន្ធ ( ជួរនៃការបង្គាប់បញ្ជាតាមខ្សែទទឹង/ខ្សែបណ្ដោយ រចនាសម្ពន្ធ័គ្រប់គ្រងតាមឋានានុក្រម តួនាទី ការបង្កើត ស្ថាប័ន ទីស្នាក់ការកណ្ដាល និងខេត្ត)
- ប្រព័ណីទំនាក់ទំនង (ធ្វើសេចក្ដីសម្រេចចិត្តក្រៅផ្លូវការ ពិធីការ នីតិវិធីជ្រើសរើស ការសរសើរ)
- សមត្ថភាពបច្ចេកទេស កំណែទម្រង់ស្ថាប័នបន្តបន្ទាប់ទាក់ទងទៅនឹងផ្នែកខាងលើក្នុងរយៈពេល ២០ ឆ្នាំ ខាងមុខនឹងធ្វើឱ្យរដ្ឋបាលព្រៃឈើក្លាយជា ស្ថាប័នមួយមានប្រសិទ្ធភាព សុក្រឹតភាព និងមាននិរន្តរភាពក្នុងការបន្តសម្រេចនូវគោលបំណងពាក់ព័ន្ធនឹងកម្មវិធីព្រៃឈើជាតិ។

## ៥.១២ អនុកម្មវិធីទី ១ ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

### ៥.១២.១ សេចក្ដីអធិប្បាយ

រដ្ឋបាលព្រៃឈើមានមន្ត្រីរាជការសរុបចំនួន ១.៦៦៧ នាក់ ក្នុងនោះមានតែមន្ត្រីប្រមាណ ៦០០ នាក់ប៉ុណ្ណោះ ដែលមានជំនាញ ខាងព្រៃឈើចាប់ពីកម្រិតថ្នាក់បរិញ្ញាបត្រឡើងទៅ។ មន្ត្រីបន្ថែមនឹងត្រូវបានជ្រើសរើសឱ្យបំពេញការងារនៅតាមបណ្ដាអង្គភាពក្រោម ឱវាទរដ្ឋបាលព្រៃឈើ - មន្ត្រីថ្មីនិងមន្ត្រីដែលកំពុងបំពេញការងារនាពេលបច្ចុប្បន្នត្រូវការនូវការបណ្ដុះបណ្ដាល និងការជំរុញលើក ទឹកចិត្តដើម្បីឱ្យអាចបំពេញនូវតួនាទីថ្មី និងប្រតិបត្តិនូវការទទួលខុសត្រូវពេញសមត្ថភាព។ ដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិឱ្យបាន ជោគជ័យ ទាមទារឱ្យមានការពង្រឹងសមត្ថភាពដល់ដៃគូពាក់ព័ន្ធដែលត្រូវចូលរួមអនុវត្តអនុកម្មវិធីនេះ ។

### ៥.១២.២ មធ្យោបាយសម្រាប់អនុវត្ត

#### ៥.១២.២.១ ការធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើ

អនុកម្មវិធីនេះនឹងគាំទ្ររដ្ឋបាលព្រៃឈើនៅក្នុងការកែទម្រង់ដែលកំពុងតែដំណើរការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវ សមត្ថភាពអង្គភាពដោយ ៖

- បំពាក់មធ្យោបាយប្រើប្រាស់សម្រាប់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានដែលបានបង្កើតថ្មី ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើម ការគ្រប់គ្រងព្រៃឈើមូលដ្ឋាន
- អនុវត្តការគ្រប់គ្រងសកម្មភាពប្រតិបត្តិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលការងាររបស់មន្ត្រី
- កំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់សម្រាប់មន្ត្រីគោលដៅ
- ធ្វើឱ្យប្រសើរឡើងប្រព័ន្ធរដ្ឋបាលតាមរយៈការបង្កើតឡើងប្រព័ន្ធទំនាក់ទំនង និងចែករំលែកព័ត៌មានឱ្យមានប្រសិទ្ធភាពចែករំលែកគោលការណ៍ណែនាំបច្ចេកទេស ឯកសារយួនណែនាំរបាយការណ៍។ល។ ក្នុងចំណោមមន្ត្រីរដ្ឋបាល ព្រៃឈើ និងអ្នកពាក់ព័ន្ធ។

### ៥.១២.២.២ អភិវឌ្ឍការអប់រំដើម្បីជានាមស្ត្រីមានគុណភាពត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារ

កត្តាសំខាន់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ គឺការលើកកម្ពស់ការអប់រំខាងផ្នែកព្រៃឈើ និងគ្រប់គ្រងធនធាន ធម្មជាតិ ដើម្បីធានាឱ្យមានអ្នកមានសមត្ថភាពសមស្របក្នុងការអនុវត្តការងារ។ គ្រឹះស្ថានសិក្សាអប់រំចាំបាច់ត្រូវធ្វើកាណែនាំ ឡើងវិញ ឆ្ពោះទៅរកការបំពាក់បំប៉នជំនាញ និងសម្ភារៈឱ្យស្របតាមសមត្ថភាពចាំបាច់ដល់អ្នកគ្រប់គ្រងព្រៃឈើនាពេល អនាគត និងដើម្បីដោះស្រាយការប្រឈមចំពោះមុខក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ការអនុវត្ត នេះអាចធ្វើទៅបាន ទាមទារឱ្យមានទស្សនវិស័យក្នុងរយៈពេលវែងមួយ និងសុឆន្ទៈពីដៃគូអភិវឌ្ឍន៍ក្នុងការផ្លាស់ប្តូរវប្បធម៌ នៅក្នុងគ្រឹះស្ថានសិក្សាទាំងពីរ គឺសាលាកសិកម្មព្រែកលាប និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដោយការលើកកម្ពស់ ឬ ធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា និងសមត្ថភាពគ្រូបង្រៀន។

ដើម្បីធានាថាមន្ត្រីដែលបានជ្រើសរើសឱ្យចូលបម្រើការងារ មានសមត្ថភាពបំពេញការងារតាមតួនាទីគ្រប់គ្រង ធនធានធម្មជាតិតាមកម្មវិធីព្រៃឈើជាតិ កម្មវិធីនេះនឹងជួយរួមចំណែកលើកកម្ពស់ការអប់រំវិស័យព្រៃឈើនៅកម្រិតឧត្តម សិក្សាតាមរយៈការ ៖

- អភិវឌ្ឍសមត្ថភាពរបស់គ្រឹះស្ថានអប់រំពហុបច្ចេកទេសទាំងពីរ គឺសាលាកសិកម្មជាតិព្រែកលៀប (វិញ្ញាបត្រ និងមធ្យម សិក្សាបច្ចេកទេស) និងសកលវិទ្យាល័យភូមិន្ទកសិកម្ម (អនុបណ្ឌិត និងបរិញ្ញាបត្រ) តាមរយៈកិច្ចសហការបញ្ជូនមន្ត្រីជំនាញជួយបង្រៀនតាមមុខវិជ្ជាចាំបាច់

- រួមចំណែកចំពោះការរៀបចំសៀវភៅអប់រំពាក់ព័ន្ធនានា ដើម្បីធានាថាការគ្រប់គ្រងធនធានធម្មជាតិបានបញ្ចូលពេញលេញនៅក្នុងកម្មវិធីអប់រំថ្នាក់ជាតិ
- កំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់សម្រាប់បុគ្គលិកគោលដៅ
- ធ្វើឱ្យប្រសើរឡើងប្រព័ន្ធអប់រំតាមរយៈការបង្កើតឡើងប្រព័ន្ធទំនាក់ទំនង និងចែករំលែកព័ត៌មានឱ្យមានប្រសិទ្ធភាពដើម្បីចែករំលែកគោលការណ៍ណែនាំបច្ចេកទេស ឯកសារក្បួនណែនាំ របាយការណ៍។ល។ ក្នុងចំណោមមន្ត្រីរដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធ
- រួមចំណែករៀបចំវគ្គអប់រំពាក់ព័ន្ធនានា ដើម្បីធានាថាការគ្រប់គ្រងធនធានធម្មជាតិបានបញ្ចូលពេញលេញទៅក្នុងកម្មវិធី អប់រំថ្នាក់ជាតិ ។

### ៥.១២.២.៣ ការជ្រើសរើសមន្ត្រីថ្មី និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលព្រៃឈើ

រដ្ឋបាលព្រៃឈើ នឹងធ្វើការជ្រើសរើសមន្ត្រីបច្ចេកទេសមកបន្តវេនដោយផ្អែកទៅលើគុណភាពនៃការអប់រំ ហើយ បន្ទាប់មកនឹងមានការពង្រឹងសមត្ថភាពបន្ថែមជាប់ជាប្រចាំ ដោយផ្តល់នូវឱកាសសិក្សាតាមរយៈវគ្គបណ្តុះបណ្តាលសម្រាប់ រយៈពេលវែង ឬ ខ្លី តាមការចាំបាច់។

### ៥.១២.២.៤ បង្កើនសមត្ថភាពដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិ

- វគ្គបណ្តុះបណ្តាលទូទៅនឹងរៀបចំនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ជូនដល់ភាគីពាក់ព័ន្ធទាក់ទងទៅនឹងកម្មវិធី ទាំងឡាយ ដែលរួមមានទាំងជំនាញធ្វើឱ្យប្រសើរឡើងសម្រាប់ ៖
- ធ្វើការសម្របសម្រួលជាមួយនឹងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិ
- រៀបចំ គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគម្រោង
- ការបង្ហាញពីរបៀបដែលរដ្ឋបាលព្រៃឈើកល អាចមានលទ្ធភាពគាំទ្រដល់រដ្ឋបាលព្រៃឈើមូលដ្ឋាន អភិវឌ្ឍជំនាញ គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃ និងវិភាគបញ្ហា ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការសមត្ថភាពសម្រាប់អនុវត្តន៍កម្មវិធីព្រៃឈើជាតិ កម្មវិធីនេះនឹងរៀបចំវគ្គបណ្តុះបណ្តាល សម្រាប់មន្ត្រីរាជការមានសមត្ថកិច្ច មន្ត្រីមកពីគ្រឹះស្ថានសិក្សាអប់រំពាក់ព័ន្ធ ដៃគូសង្គមស៊ីវិល និងគណៈកម្មការគ្រប់គ្រង ព្រៃឈើមូលដ្ឋានព្រមទាំងសមាជិកសហគមន៍។ ផ្នែកសំខាន់ៗនៃគម្រោងពង្រឹងសមត្ថភាពមានដូចខាងក្រោម ៖

### ៥.១២,២.៥ ការកំណត់ព្រំប្រទល់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាព្រៃឈើជាតិ

- កិច្ចសហការប្រកបដោយប្រសិទ្ធភាពការដោះស្រាយទំនាស់និងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការកំណត់ព្រំប្រទល់ព្រៃឈើ អនុលោមទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិដោយភាពរលូនសម្រាប់កំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

- មន្ត្រីរដ្ឋបាលព្រៃឈើកណ្តាលមានបទពិសោធដែលត្រូវបានប្រគល់ភារកិច្ចឱ្យចូលរួមក្នុងការកំណត់ព្រំប្រទល់ព្រៃឈើ នឹងត្រូវបានបណ្តុះបណ្តាល ដើម្បីផ្តល់ការគាំទ្រដល់អង្គភាពរដ្ឋបាលមូលដ្ឋាន រួមមាន ការធ្វើផែនការ និងការបណ្តុះ បណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន អំពីគោលការណ៍ថ្នាក់ជាតិ និងផ្តល់នូវការគាំទ្រផ្សេងៗទៀត នៅពេលចាំបាច់។

**៥.១២.២.៦ ការគ្រប់គ្រងធនធានព្រៃឈើនិងអភិរក្ស ( សម្រាប់គ្រឹះស្ថានសិក្សាអប់រំនិងរដ្ឋបាលព្រៃឈើ)**

- អភិបាលកិច្ចល្អក្នុងប្រព័ន្ធគ្រប់គ្រងព្រៃឈើ
- វិធីសាស្ត្រសមស្របតាមធម្មជាតិសម្រាប់ធ្វើផែនការគ្រប់គ្រងព្រៃឈើ ដើម្បីធ្វើសមាហរណកម្មវិស័យផ្សេងៗទៀត និង ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- ការធ្វើផែនការគ្រប់គ្រងព្រៃឈើនៅកម្រិតថ្នាក់ជាតិនិងមូលដ្ឋាន ដើម្បីសម្របសម្រួលការអនុវត្តការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
- ជម្រើសផ្សេងទៀតនៃប្រព័ន្ធគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព (ពហុគោលបំណងនៃវិស័យព្រៃឈើ ដោយមិនផ្តោត ជាសំខាន់ទៅលើព្រៃឈើពាណិជ្ជកម្ម) ផ្អែកទៅលើគោលការណ៍អភិបាលកិច្ចល្អនៃព្រៃឈើ
- វិធីសាស្ត្រថ្មីៗ ចំពោះការគ្រប់គ្រងព្រៃ វាយនិរន្តរភាពនៅក្នុងតំបន់ព្រៃផ្តល់ផល
- ការអភិរក្សសេនេទិចព្រៃឈើ និងការប្រើប្រាស់
- បច្ចេកទេសវរប្បកម្ម
- បច្ចេកទេសដាំដុះព្រៃឈើឡើងវិញ និងការថែទាំ
- អេកូ-ទេសចរណ៍ដលមាននៅក្នុងតំបន់ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ការធ្វើសមាហរណកម្មរវាងការអភិរក្សព្រៃឈើ និងទេសចរណ៍ធម្មជាតិ និងការចែករំលែកផលប្រយោជន៍ជាមួយនឹងសហគមន៍មូលដ្ឋាន
- ជម្រើសប្រភពថាមពលផ្សេងៗ (ក្រៅពីអុស)
- ការអភិរក្សជីវចម្រុះ
- ការកាត់បន្ថយ និងទប់ស្កាត់ ការប្រែប្រួលអាកាសធាតុ
- ចម្ការព្រៃឈើដាំដោយនិរន្តរភាព ដោយគិតអំពីទិដ្ឋភាពអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម
- វិញ្ញាបនបត្រ និងខ្សែចង្វាក់ផ្គៀងផ្ទាត់សម្រាប់ផលិតផលព្រៃឈើ
- ការកែច្នៃផលអនុផលព្រៃឈើ និងការអភិវឌ្ឍបច្ចេកវិទ្យាឈើ

- ការផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋានស្តីពីផែនការគ្រប់គ្រងព្រៃឈើ និងប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍សម្រាប់ ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព (MAR-SEM)។

### ៥.១២.២.៧ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច

- ធ្វើសមាហរណកម្មនៃការពង្រឹងការអនុវត្តច្បាប់ស្តីអំពីព្រៃឈើ និងអភិបាលកិច្ចទៅក្នុង គ្រឹះស្ថានសិក្សាអប់រំជាមូលដ្ឋាន(វិញ្ញាបនបត្រ-បរិញ្ញាបត្ររង-បរិញ្ញាបត្រ)
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដែលចេញពីគ្រឹះស្ថានសិក្សាអប់រំ ដើម្បីបង្កើតជាក្រុមមន្ត្រី ពង្រឹងការអនុវត្តច្បាប់ ស្តី ពីព្រៃឈើ និងអភិបាលកិច្ច ដើម្បីមានសមត្ថភាពអាចរៀបចំវគ្គប ណ្តុះបណ្តាល និងណែនាំបន្តដល់អ្នកផ្សេងៗទៀត
- បណ្តុះបណ្តាលគ្រូបង្រៀន មន្ត្រីរដ្ឋបាលព្រៃឈើ អង្គការសង្គមស៊ីវិលជាដៃគូ អាជ្ញាធរមូលដ្ឋាន គណៈកម្មការគ្រប់គ្រង សហគមន៍ព្រៃឈើ និងសមាជិកសហគមន៍ នូវវាល់បច្ចេកទេស សម្រាប់ទប់ស្កាត់បទល្មើសព្រៃឈើ
- បណ្តុះបណ្តាលអ្នកគ្រប់គ្រង ដើម្បីកំណត់បញ្ហាដែលងាយកើតឡើង ដែលអាចបណ្តាលឱ្យ មានបទល្មើសព្រៃឈើ
- បណ្តុះបណ្តាលមន្ត្រីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ដើម្បីការពារ និងទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ
- រៀបចំវគ្គបណ្តុះបណ្តាលអន្តរក្រសួងដើម្បីឆ្លើយតបទៅនឹងកង្វះខាតសមត្ថភាពផ្នែកច្បាប់ នីតិបញ្ញត្តិ និងអំណាចនីតិ ប្រតិបត្តិ ដែលការនេះនឹងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការអន្តរក្រសួង ក្នុងការប្រយុទ្ធប្រឆាំង នឹងទប់ស្កាត់សកម្មភាព ព្រៃឈើខុសច្បាប់ ។

### ៥.១២.២.៨ សហគមន៍ព្រៃឈើ

មន្ត្រីរដ្ឋបាលព្រៃឈើទទួលបន្ទុក អង្គការសង្គមស៊ីវិលជាដៃគូអាជ្ញាធរមូលដ្ឋាន គណៈកម្មការគ្រប់គ្រង សហគមន៍ ព្រៃឈើ និងសមាជិក ដែលចូលរួមប្រតិបត្តិក្នុងសកម្មភាពគ្រប់គ្រងព្រៃឈើ នឹងត្រូវបានប ណ្តុះបណ្តាល ស្តីពីការគ្រប់គ្រង ព្រៃឈើតាមបែបវិមជ្ឈការតាមគំរូផ្សេងៗ ( សហគមន៍ព្រៃឈើ ព្រៃឈើដៃគូសហគមន៍ពាណិជ្ជកម្មព្រៃឈើ )។ល។

ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងព្រៃឈើតាមបែបវិមជ្ឈការនឹងធ្វើដល់ក្រុមគោលដៅផ្សេងៗ ដូចជា ៖

- នៅតាមគ្រឹះស្ថានសិក្សាអប់រំកម្រិតមធ្យមសិក្សាបច្ចេកទេស និងបរិញ្ញាបត
- គ្រូជំនាញបណ្តុះបណ្តាល (បណ្តុះបណ្តាលគ្រូបង្គោល)

- មន្ត្រីរដ្ឋបាលព្រៃឈើដែលមានតួនាទីទទួលខុសត្រូវការងារអភិវឌ្ឍន៍សហគមន៍ព្រៃឈើ
- បុគ្គលិកអង្គការសង្គមស៊ីវិលដែលធ្វើកាសម្របសម្រួលការងារសហគមន៍ព្រៃឈើ
- គណៈកម្មការនិងសមាជិកសហគមន៍ព្រៃឈើ អាជ្ញាធរមូលដ្ឋាន ដែលមានតួនាទីចូលរួមក្នុងការងារគ្រប់គ្រងព្រៃឈើ
- វិស័យឯកជន ដែលមានមុខងារក្នុងការងារគ្រប់គ្រងព្រៃឈើ

### ៥.១២.២.៩ ហិរញ្ញប្បទានព្រៃឈើដោយនិរន្តរភាព

ការកសាងសមត្ថភាពស្តីពីរញ្ញប្បទានព្រៃឈើ នឹងផ្តោតជាបឋមទៅលើ ៖

- សិក្សាកម្រិតបរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិត នៅតាមគ្រឹះស្ថានសិក្សាអប់រំ ថ្នាក់ជាតិ និងអន្តរជាតិ
- គ្រូជំនាញបណ្តុះបណ្តាល (បណ្តុះបណ្តាលគ្រូបង្គោល) មន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការងារពាក់ព័ន្ធ
- អាជ្ញាធរមូលដ្ឋានដែលមានការពាក់ព័ន្ធ
- វិស័យឯកជនដែលមានការងារពាក់ព័ន្ធ
- បណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ (REDD)។

### ៥.១២.៣ លទ្ធផលរំពឹងទុក

### ៥.១២.៣.១ ការធ្វើឱ្យប្រសើរឡើងលើការងារកសាងសមត្ថភាពនៅតាមគ្រឹះស្ថានសិក្សាអប់រំនិងរដ្ឋបាលព្រៃឈើ

- មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវបានកំណត់តួនាទី និងការងារទទួលខុសត្រូវច្បាស់លាស់នៅឆ្នាំ ២០១០
- ការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សាផ្នែកគ្រប់គ្រងធនធានធម្មជាតិត្រូវបានកំណត់ និងធ្វើផែនការដើម្បីអនុវត្ត
- ការវិភាគលើលទ្ធផលបង្រៀនរបស់គ្រូបង្រៀនត្រូវបានអនុវត្តន៍
- កម្មវិធីគ្រប់គ្រងលើលទ្ធផលអនុវត្តការងារត្រូវបានធ្វើនៅឆ្នាំ ២០១៥. ដើម្បីឱ្យមន្ត្រីរដ្ឋបាលព្រៃឈើមានឆន្ទៈបំពេញការងារ និងសកម្មម្ចាស់ការអនុវត្តកម្មវិធីព្រៃឈើជាតិ នៅថ្នាក់ជាតិ នឹងមូលដ្ឋាន។

- ប្រព័ន្ធចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធទំនាក់ទំនង ត្រូវបានបង្កើតឡើងត្រឹមឆ្នាំ ២០១៣។

**៥.១២.៣.២ សមត្ថភាពនៃរដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធផ្សេងទៀតទៅនឹងវិស័យព្រៃឈើ ត្រូវបានធ្វើឱ្យប្រសើរឡើង**

- មន្ត្រីមានសមត្ថភាពដែលសមស្របនឹងតម្រូវការថ្មីនៃរចនាសម្ព័ន្ធការងាររបស់រដ្ឋបាលព្រៃឈើ ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលបន្ថែមទៅតាមតួនាទីដែលនឹងទទួលខុសត្រូវ។ ការងារនេះត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០១៥
- ផែនការអភិវឌ្ឍធនធានមនុស្សទាំងអស់ គឺជាផ្នែករួមបញ្ចូលគ្នាមួយនៃការពង្រឹងសមត្ថភាពនៅរដ្ឋបាលព្រៃឈើ ហើយ សមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើនឹងត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការងារអនុវត្តជាក់ស្តែង និងការបណ្តុះបណ្តាល រយៈពេលវែង និងខ្លី លើមុខវិជ្ជាជាក់លាក់ដែលទាក់ទងទៅនឹងការអនុវត្តកម្មវិធីព្រៃឈើជាតិ
- អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងគណៈកម្មាធិការគ្រប់គ្រងព្រៃឈើមូលដ្ឋាន សមាជិកគ្រប់គ្រងព្រៃឈើ មូលដ្ឋាន និងភាគីឯកជនទាំងអស់ ត្រូវបានបណ្តុះបណ្តាល និងមានសមត្ថភាពអាចបំពេញតួនាទីដែលរំពឹងទុក
- កម្មវិធីសិក្សាលើជំនាញគ្រប់គ្រងព្រៃឈើ និងការបណ្តុះបណ្តាលមុខវិជ្ជាព្រៃឈើជាមូលដ្ឋានគ្រឹះ ត្រូវបានកែលំអដើម្បីធានាដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ។

## ៥.១៣ អនុកម្មវិធីទី២ ការអប់រំ និងផ្សព្វផ្សាយសាធារណៈ

### ៥.១៣.១ សេចក្តីផ្តើម

មូលដ្ឋានគ្រឹះនៃសកម្មភាពផ្សព្វផ្សាយព្រៃឈើដែលមានលក្ខណៈអប់រំល្អ គឺជាការតម្រង់ទិសអភិវឌ្ឍ និងពង្រីកបន្ថែមនូវ កម្រិតនៃការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន។

ដើម្បីឱ្យមានការជឿជាក់ និងចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពពីសំណាក់សហគមន៍មូលដ្ឋាន និងភាគី ពាក់ព័ន្ធ ការបង្ហាញនូវគំរូនិងភាពជោគជ័យលើការងារគ្រប់គ្រងព្រៃឈើ និងការដាំដុះព្រៃឈើរបស់វិស័យឯកជន គឺមានសារៈ សំខាន់ណាស់ ព្រោះជាការបង្ហាញនូវឧទាហរណ៍ល្អនៃការអនុវត្តច្បាប់ បច្ចេកទេស និងការងារគ្រប់គ្រងធនធានធម្មជាតិប្រកប ដោយប្រសិទ្ធភាពពីអ្នកជំនាញ។

ការបញ្ជ្រាបចំណេះដឹងទូទៅស្តីពីព្រៃឈើទៅដល់សិស្ស និស្សិតនៅតាមគ្រឹះស្ថានសិក្សានានាមានប្រយោជន៍យ៉ាងខ្លាំងក្នុងការពង្រីកចំណេះដឹងពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរ

ភាព និងបណ្តុះគំនិតចូលរួមក្នុងការការពារ និងថែរក្សាព្រៃឈើនាពេលអនាគត។ រដ្ឋបាលព្រៃឈើក៏ត្រូវទទួលបន្ទុកចំពោះការបញ្ជ្រាបនូវចំណេះដឹងទាំងនេះទៅដល់សាធារណជន ផងដែរ។

ដើម្បីអនុវត្តសកម្មភាពផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងទូទៅស្តីពីព្រៃឈើឱ្យបានជោគជ័យ រដ្ឋបាលព្រៃឈើត្រូវពង្រឹង សមត្ថភាពក្នុងការផ្តល់សេវាកម្មផ្សព្វផ្សាយព្រៃឈើឱ្យបានទូលំទូលាយ ។

### ៥.១៣.២ មធ្យោបាយនៃការអនុវត្ត

#### ៥.១៣.២.១ ជំរុញការកែប្រែឥរិយាបថមនុស្សជំនាន់ក្រោយ

ដើម្បីជំរុញការកែប្រែឥរិយាបថក្នុងរយៈពេលវែង អនុកម្មវិធីនេះនឹងផ្តល់ចំណេះដឹងដែលមានប្រសិទ្ធភាពដល់ សិស្សសាលាគោលដៅទាំងឡាយ ឱ្យមានការយល់ដឹងខ្ពស់ពីការប្រើប្រាស់ និងគ្រប់គ្រងព្រៃឈើនាពេលអនាគត។ ម្យ៉ាង ទៀត ការបង្កើតបរិយាកាសក្នុងការប្រាស្រ័យទាក់ទង ការចែករំលែកព័ត៌មាន និងការផ្លាស់ប្តូរចំណេះដឹង គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសកម្មភាពផ្សព្វផ្សាយ។ កម្មវិធីនេះនឹង៖

- កំណត់យន្តការផ្សព្វផ្សាយអំពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព នៅតាមគ្រឹះស្ថានសិក្សា ឬ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈនានា។
- រៀបចំបង្កើតឯកសារ និងសម្ភារៈផ្សព្វផ្សាយព្រៃឈើសមស្រប
- ជំរុញសកម្មភាពផ្សព្វផ្សាយដល់គ្រូបង្រៀន សិស្ស និងនិស្សិត ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

#### ៥.១៣.២.២ ជំរុញយុទ្ធនាការផ្សព្វផ្សាយដើម្បីជួយដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ

ជំរុញយុទ្ធនាការផ្សព្វផ្សាយដល់ ក្រុមប្រឹក្សាឃុំ និង សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធស្តីពី ៖

- គោលបំណង និងកម្មវិធីព្រៃឈើជាតិ
- ឱកាសសម្រាប់គ្រប់គ្រងធនធានព្រៃឈើនៅមូលដ្ឋាន
- គោលបំណង និងនីតិវិធីនៃការកំណត់ព្រំប្រទល់ដែនព្រៃឈើ ផែនការសកម្មភាពអភិវឌ្ឍព្រៃឈើ និង របាយការណ៍វាយតម្លៃនៃប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ច្បាប់ បទបញ្ញា និងកាតព្វកិច្ចរបស់អ្នកពាក់ព័ន្ធ
- ការអនុវត្តច្បាប់ រួមទាំងការធ្វើពាណិជ្ជកម្មព្រៃឈើ និងសត្វព្រៃ
- បញ្ហាផ្សេងៗទៀតដែលជាតម្រូវការ ដើម្បីលើកកម្ពស់ការយល់ដឹង។

#### ៥.១៣.២.៣ ការរៀបចំ និងដំណើរការមជ្ឈមណ្ឌលផ្សព្វផ្សាយព្រៃឈើ

នៅពេលអនាគតរដ្ឋបាលព្រៃឈើនឹងរៀបចំដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្សព្វផ្សាយព្រៃឈើ ដើម្បីបើកលើក ចំណេះដឹងទូទៅ និងព័ត៌មានស្តីពីព្រៃឈើទៅកាន់សាធារណជន។ មជ្ឈមណ្ឌលនេះ នឹងផលិតឯកសារ និងសម្ភារៈផ្សព្វផ្សាយ ព្រៃឈើសម្រាប់ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី កាសែត និងគេហទំព័រផងដែរ ដើម្បីជួយបំពេញបន្ថែមនូវចំណេះដឹង ដល់សាធារណជននិងភាគីពាក់ព័ន្ធ។ លើសពីនេះ ឯកសារនិងសម្ភារៈផ្សព្វផ្សាយព្រៃឈើទាំងអស់ត្រូវបានរក្សាទុកក្នុង ប្រព័ន្ធទិន្នន័យ ដើម្បីងាយស្រួលប្រើប្រាស់។ មជ្ឈមណ្ឌលនេះនឹងដើរតួនាទីសំខាន់ក្នុងការចូលរួមអប់រំនៅតាមសាលារៀន ដើម្បីបង្កើនការយល់ដឹងពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

### ៥.១៣.២.៤ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង

រដ្ឋបាលព្រៃឈើនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា គ្រឹះស្ថានអប់រំសាធារណៈ និងសាលាបណ្តុះ បណ្តាលវិជ្ជាជីវៈ ក្នុងការអភិវឌ្ឍមូលដ្ឋានចំណេះដឹងស្តីពីព្រៃឈើ ដោយកសាងបន្ថែមនូវយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីជំរុញការចូលរួមពីសាធារណជននិងភាគីពាក់ព័ន្ធនានាក្នុងកម្មវិធីផ្សព្វផ្សាយព្រៃឈើកាន់តែទូលំទូលាយ។ យុទ្ធសាស្ត ប្រាស្រ័យទាក់ទងនឹងជួយដល់ការកំណត់ក្រុមគោលដៅសំខាន់ៗ សម្រាប់ទទួលសេវាកម្មផ្សព្វផ្សាយ និងរៀបចំយុទ្ធសាស្ត សមស្របទៅនឹងតម្រូវការរបស់ក្រុមគោលដៅនីមួយៗ។

### ៥.១៣.២.៥ ការគាំទពិសេសចំពោះសកម្មភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន

ដើម្បីគាំទ្រដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រដ្ឋបាលព្រៃឈើត្រូវរៀបចំសេវាកម្មផ្សព្វផ្សាយសមស្រប ងាយនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានានៅមូលដ្ឋាន ជួយដល់ការគ្រប់គ្រងព្រៃឈើតាមបែបវិមជ្ឈការ រួមទាំងការដាំដុះព្រៃឈើវិស័យឯកជនផងដែរ។ ដើម្បីសម្រេចបាននូវសកម្មភាពខាងលើ ចាំបាច់ត្រូវធ្វើការបណ្តុះបណ្តាល បន្ថែមនូវបច្ចេកទេស និងជំនាញដល់មន្ត្រីផ្សព្វផ្សាយព្រៃឈើ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារផ្សព្វផ្សាយ គាំទ្រដល់សកម្មភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន។

### ៥.១៣.២.៦ ការវាយតម្រូវការពង្រឹងសមត្ថភាព

រដ្ឋបាលព្រៃឈើ នឹងធ្វើការត្រួតពិនិត្យនិងវាយតម្លៃតម្រូវការពង្រឹងសមត្ថភាពដើម្បីកំណត់តំបន់គោលដៅ និង មុខជំនាញដែលត្រូវផ្តល់ការបណ្តុះបណ្តាលដែលចំបាច់បន្ទាន់ដល់ការអភិវឌ្ឍសេវាកម្មផ្សព្វផ្សាយសំដៅគាំទ្រដល់ការធ្វើកំណែ ទម្រង់ក្នុងវិស័យព្រៃឈើ និងដល់ការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន។

### ៥.១៣.២.៧ ការចែករំលែកបទពិសោធក្នុងការគ្រប់គ្រងព្រៃឈើ

វិស័យអប់រំអាចជួយរដ្ឋបាលព្រៃឈើក្នុងការបង្កើនកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សាស្រាវជ្រាវនិងដៃគូអភិវឌ្ឍន៍ ដើម្បីបន្តត្រួតពិនិត្យ វាយតម្លៃ និងកំណត់នូវវិធីសាស្ត្រគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានប្រកបដោយនិរន្តរភាព ព្រមទាំងចងក្រងនូវកសារផ្សព្វផ្សាយផ្អែកលើបទពិសោធន៍ទាំងនេះ។ តាមរយៈនេះបណ្ដាញផ្សព្វផ្សាយព្រៃឈើថ្នាក់ជាតិនឹងត្រូវបានពង្រឹងផងដែរ។

ចំណេះដឹងជាមូលដ្ឋានមួយចំនួន ដូចជា ការគ្រប់គ្រងបណ្ណាល័យ ការបង្កើត ការថែរក្សាប្រព័ន្ធទិន្នន័យ និងការបញ្ចូលទិន្នន័យនឹងត្រូវបានផ្តល់ឱ្យដល់មជ្ឈមណ្ឌលបែងចែកព័ត៌មាន។

### ៥.១៣.៣ លទ្ធផលរំពឹងទុក

- មានកិច្ចសហប្រតិបត្តិការសម្របសម្រួល និងផ្តល់សេវាកម្មផ្សព្វផ្សាយព្រៃឈើពេញលេញ ដើម្បីជួយសហគមន៍មូលដ្ឋាន និង ភាគីពាក់ព័ន្ធផ្សេងក្នុងការងារគ្រប់គ្រងធនធានព្រៃឈើ
- ការយល់ដឹងស្តីពីការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាពបានធ្វើឱ្យប្រសើរឡើង តាមរយៈការបញ្ជ្រាបការផ្សព្វផ្សាយព្រៃឈើតាមបណ្តាគ្រឹះស្ថានសិក្សាអប់រំ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ
- ព័ត៌មានព្រៃឈើត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការបោះពុម្ពផ្សាយជាប្រចាំនូវឯកសារពាក់ព័ន្ធទៅនឹងវិស័យព្រៃឈើ (ទស្សនាវដ្តី ព្រឹត្តបត្រ ខិត្តបណ្ណ រូបភាពផ្សព្វផ្សាយ អត្ថបទផ្សព្វផ្សាយព្រៃឈើតាមគេហទំព័រ និងប្រព័ន្ធឃោសនានានា។
- សេវាកម្មផ្សព្វផ្សាយត្រូវបានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំដើម្បីបញ្ជាក់ថា ការផ្តល់សេវាកម្មសម្រាប់ប្រព័ន្ធគ្រប់គ្រងព្រៃឈើ នៅមូលដ្ឋាន បានធ្វើបច្ចុប្បន្នភាពជាមួយកម្មវិធីអភិវឌ្ឍន៍ថ្មីៗ
- ចំណេះដឹងទូទៅស្តីពីការងារគ្រប់គ្រងធនធានព្រៃឈើត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការផ្សព្វផ្សាយជាប្រចាំ ដើម្បីជំរុញ និងលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃៗទៀតក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## ៥.១៤ អនុកម្មវិធីទី ៣ ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ

### ៥.១៤.១ សេចក្តីអធិប្បាយ

ដោយសារតែចំនួនមន្ត្រីស្រាវជ្រាវនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃនៃរដ្ឋបាលព្រៃឈើ មានចំនួនតិចតួច ហើយសមត្ថភាពនៅមានកម្រិតក្នុងការបំពេញការងារជាអ្នកស្រាវជ្រាវ គួបផ្សំនឹងការខ្វះថវិកា និងមធ្យោបាយសម្រាប់ធ្វើកាស្រាវជ្រាវ ផងនោះ ជាហេតុធ្វើឱ្យការស្រាវជ្រាវទទួលបានលទ្ធផលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ហើយព័ត៌មានជាមូលដ្ឋាន ស្តីពីព្រៃឈើនៅកម្ពុជាមិនទាន់មានគ្រប់គ្រាន់នៅឡើយ។ បញ្ហាស្រដៀងគ្នានេះ ក៏កើតមានឡើងនៅតាមមហា

វិទ្យាល័យ សាកល វិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនានានៅទូទាំងប្រទេសកម្ពុជាផងដែរ។ ហេតុដូច្នេះ ជាការចាំបាច់ណាស់ ត្រូវពង្រឹងការងារស្រាវ ជ្រាវពាក់ព័ន្ធនឹងវិស័យព្រៃឈើនៅកម្ពុជាឱ្យបានសកម្ម ដើម្បីចូលរួមក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ។

### ៥.១៤.២ មធ្យោបាយអនុវត្ត

#### ៥.១៤.២.១ ក្រុមការងារសម្របសម្រួលការងារស្រាវជ្រាវព្រៃឈើ

ក្រុមការងារសម្របសម្រួលការងារស្រាវជ្រាវព្រៃឈើមួយនឹងត្រូវបានបង្កើតឡើងដែលមាន សមាជិកមកពីនាយកដ្ឋានអង្គភាពក្រោមឱវាទរដ្ឋបាលព្រៃឈើ សាកលវិទ្យាល័យ អង្គភាពស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍នានា។ ក្រុមការងារនេះមាន ភារកិច្ចៈ

- រៀបចំតម្រង់ទិសយុទ្ធសាស្ត្រស្រាវជ្រាវ ឱ្យស្របតាមកម្មវិធីព្រៃឈើជាតិ
- សម្របសម្រួល និងផ្តល់មតិណែនាំ លើកគម្រោងសំណើសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ ធ្វើយ៉ាងណាឱ្យគម្រោងសំណើទាំងនោះស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និង កម្មវិធីព្រៃឈើជាតិ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលព្រៃឈើនិងជំនាញផ្សេងទៀត ដែលចូលមក សិក្សាស្រាវជ្រាវនៅ ក្នុងតំបន់ព្រៃឈើ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិ លើការសិក្សា ស្រាវជ្រាវវិស័យព្រៃឈើ
- រៀបចំយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីចែករំលែកព័ត៌មានសិក្សាស្រាវជ្រាវឱ្យមានប្រសិទ្ធភាព
- ពិនិត្យ ផ្តល់មតិយោបល់ កែលំអទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវព្រៃឈើ ដើម្បីធានាថា លទ្ធផលទាំងនោះ អាចជឿជាក់បាន។

#### ៥.១៤.២.២ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃនៃរដ្ឋបាលព្រៃឈើត្រូវ បន្តកិច្ចខិតខំប្រឹងប្រែង របស់ខ្លួនថែមទៀត ដើម្បីសម្របសម្រួល និងអនុវត្តន៍ការងារសិក្សាស្រាវជ្រាវវិស័យព្រៃឈើ ធ្វើយ៉ាង ណាឱ្យការងារនេះមានភាពរីកចម្រើន។ ដើម្បីឱ្យការងារនេះអាចសម្រេចទៅបាន ចាំបាច់ត្រូវមានមន្ត្រី គ្រប់គ្រាន់ដែលមានសមត្ថភាពស្រាវជ្រាវច្បាស់លាស់រួមនឹង មន្ត្រីដែលទើបបញ្ចប់ការសិក្សាថ្មីៗជា ជំនួយការស្រាវជ្រាវវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃចាំបាច់ត្រូវមានកញ្ចប់ថវិកាគ្រប់

គ្រាន់ពីប្រភពផ្សេងៗ (ជាតិ និង អន្តរជាតិ) ដើម្បីលើកទឹកចិត្តដល់អ្នកជំនាញក្នុងការលើកគម្រោង និងអនុវត្តការងារសិក្សាស្រាវជ្រាវ។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃនឹងអាចមានសមត្ថភាព ៖

- រៀបចំអនុវត្តការងារស្រាវជ្រាវ ដើម្បីស្វែងរកគំរូ និងជម្រើសនៃបែបផែនគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព
- រៀបចំបង្កើត និងថែរក្សាឡូត៍គំរូ និងតំបន់ស្រាវជ្រាវនៅក្នុងដែនសម្បត្តិព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍
- សាកល្បងគំរូគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដោយសហការជាមួយភាគីពាក់ព័ន្ធ
- អនុវត្តការផ្សព្វផ្សាយកម្មវិធីស្រាវជ្រាវដោយសហការជាមួយដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ ដើម្បីរៀបចំវិធីដ៏មានប្រសិទ្ធភាព
- ក្នុងការផ្តល់ជំនួយក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃឈើ និងសកម្មភាពដាំដុះព្រៃឈើជាមួយប្រជាពលរដ្ឋមូលដ្ឋាន
- សម្របសម្រួលនិងសហការជាមួយដៃគូអភិវឌ្ឍ និងស្ថាប័នស្រាវជ្រាវព្រៃឈើជាតិ និងអន្តរជាតិ ដើម្បីស្វែងរកថវិកា សម្រាប់ស្រាវជ្រាវ និង បណ្តុះបណ្តាល
- រៀបចំផែនការបណ្តុះបណ្តាល និងបំពាក់បំប៉នកទេសដល់អ្នកគ្រប់គ្រងការស្រាវជ្រាវ អ្នកស្រាវជ្រាវ និងអ្នកជំនួយ ការស្រាវជ្រាវ។

### ៥.១៤.២.៣. ការផ្សារភ្ជាប់ការងារស្រាវជ្រាវព្រៃឈើជាមួយសាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវ

ដើម្បីធានាឱ្យមានអ្នកជំនាញក្មេងៗអាចបំពេញការងារស្រាវជ្រាវព្រៃឈើ កម្មវិធីស្រាវជ្រាវនឹងសហការជួយលើក កម្ពស់គុណភាពសិក្សាពាក់ព័ន្ធនឹងការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន។ រដ្ឋបាលព្រៃឈើ នឹងសហការជាមួយស្ថាប័នស្រាវជ្រាវសាកលវិទ្យាល័យនៅកម្ពុជានិងបរទេស ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើមុខជំនាញ ព្រៃឈើ។ ផ្នែកនៃផែនការនេះគឺត្រូវពង្រឹងសមត្ថភាពស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងការអនុវត្តការគ្រប់គ្រងព្រៃឈើជាតិ ប្រកបដោយនិរន្តរភាព។

ការស្រាវជ្រាវព្រៃឈើដែលធ្វើឡើងដោយស្ថានស្រាវជ្រាវនឹងភាគីពាក់ព័ន្ធ ចាំបាច់ត្រូវធ្វើកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងគ្នានឹងគ្នា នឹងលទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនោះអាចទទួលយកបាន និងមានប្រយោជន៍ដល់អ្នកប្រើប្រាស់លទ្ធផល ជាពិសេសសម្រាប់ អ្នករៀបចំផែនការ និងគោលនយោបាយ។

### ៥.១៤.២.៤ ការធ្វើឱ្យប្រសើរដល់បណ្តាញស្រាវជ្រាវ

កម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍសមត្ថភាពនឹងពង្រឹងកិច្ចសហការជាមួយស្ថាប័នស្រាវជ្រាវជាតិ និងអន្តរជាតិ ដើម្បី អភិវឌ្ឍជំនាញបច្ចេកទេស រៀនសូត្របទពិសោធន៍ល្អៗ និងទាញយកប្រយោជន៍ពីការបណ្តុះបណ្តាល និងស្វែងរកជំនួយ ថវិកាសម្រាប់ការងារស្រាវជ្រាវ។

### ៥.១៤.២.៥ ការស្រាវជ្រាវដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ

ការងារស្រាវជ្រាវជាជំហានដំបូងមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម។ ទោះបីយ៉ាងណាក៏ដោយ ចាំបាច់ត្រូវ មានការកំណត់អាទិភាព និងតម្រូវការការងារស្រាវជ្រាវនៅពេលអនាគតផងដែរ។

*ការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ*

- រៀបចំអភិវឌ្ឍ និងអនុវត្តផែនការស្រាវជ្រាវគ្រប់កម្រិត និងតាមដានវាយតម្លៃការអនុវត្តសិក្សាស្រាវជ្រាវមូលដ្ឋានព្រៃឈើ សិក្សាអំពីប្រភេទ ភាពសម្បូរ និងចលនាប្រែប្រួលនៃរុក្ខជាតិព្រៃសម្រាប់ជម្រកសត្វព្រៃ សិក្សាជីវសាស្ត្រ និងជីវមណ្ឌលដ្ឋាន សត្វព្រៃ-ជីវចម្រុះ អង្កេត និងធ្វើសារពើភណ្ឌសត្វព្រៃគ្រប់ប្រភេទ និងវាយតម្លៃជីវចម្រុះ តាមតំបន់ក្នុងភូមិភាគព្រៃឈើ សំខាន់ៗ
- ស្រាវជ្រាវកត្តា វិទ្យាសាស្ត្រ ជម្រើស និងបង្កាត់ពូជរុក្ខជាតិ-សត្វព្រៃ ពិសោធស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកទេសបង្កើន គុណភាពព្រៃឈើឡើងវិញ និងរៀបចំសួនភូតគាមសាស្ត្រ និងបង្កាត់ពូជរុក្ខជាតិលំអ និងមានសោភ័ណភាព
- សិក្សាស្រាវជ្រាវ និងបង្កើតស្ថានីយស្រាវជ្រាវព្រៃឈើ និងជីវចម្រុះនៅតាមភូមិភាគនិងប្រភេទព្រៃឈើសំខាន់ៗក្នុង ទូទាំងប្រទេស
- សិក្សាស្រាវជ្រាវពីលក្ខណៈរូប និងលក្ខណៈគីមីរបស់ដីព្រៃឈើ
- សិក្សាអំពីឱកាសនៃការបង្កើតទេសចរធម្មជាតិនៅក្នុងតំបន់ព្រៃឈើកម្ពុជា និងសមាហរណកម្មវាទៅក្នុងការអភិរក្សព្រៃឈើ និងប្រព័ន្ធនិរន្តរភាពមួយសម្រាប់ការបែងចែកផលប្រយោជន៍រវាងរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន
- ការស្រាវជ្រាវ និងអភិវឌ្ឍការកែច្នៃផល-អនុផលព្រៃឈើ។

*ការអនុវត្តច្បាប់ និងអភិបាលកិច្ចព្រៃឈើ*

- រៀបចំ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល លើផែនការពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់ និងអភិបាលកិច្ចព្រៃឈើ និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់រដ្ឋបាលព្រៃឈើ និងការអភិវឌ្ឍវិស័យព្រៃឈើ។

*សហគមន៍ព្រៃឈើជាតិ*

- សិក្សាស្រាវជ្រាវអត្តសញ្ញាណ និងការប្រើប្រាស់ផល-អនុផលព្រៃឈើ បច្ចេកវិទ្យាកែច្នៃ និងបង្កើនគុណភាពតម្លៃ និង ឋមាណីផលិតផលព្រៃឈើ វិភាគពីសង្គម-សេដ្ឋកិច្ចក្នុងការផ្លាស់ប្តូរមុខរបរ ដើម្បីកាត់បន្ថយសម្ពាធប៉ះពាល់ព្រៃឈើ
- សិក្សាពីរចនាសម្ព័ន្ធលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍផលិតផលព្រៃឈើ និងការស្វែងរកទីផ្សារ . ធ្វើឱ្យមានភាពងាយស្រួលនូវប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព (សារពើភណ្ឌ វប្បកម្ម ការតាមដានអត កំណើនមាឌឈើ វិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់ក្នុងពេលអាជីវកម្មព្រៃឈើ ការតាមដាន និងគ្រប់គ្រងជីវចម្រុះ...)
- ធ្វើគារវិភាគអំពីការប្រើប្រាស់ និងចរាចរផលិតផល-អនុផលព្រៃឈើ ផ្សង ដោយធ្វើផែនទីបញ្ជាក់ និងចង្អុលបង្ហាញ លក្ខណៈតំបន់ ភាពប្រឈម និងឱកាស (ព្រៃឈើ ចម្ការព្រៃឈើដាំផលិតផលធៀបជាមួយនឹងការប្រមូលផល)
- ការស្វែងរកទីផ្សារសម្រាប់ផលិតផលក្នុងស្រុក។

*ការប្រែប្រួលអាកាសធាតុ*

- សិក្សាអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើព្រៃឈើ និងតួនាទីរបស់ព្រៃឈើនៅក្នុងការកាត់បន្ថយការប្រែប្រួល អាកាសធាតុ
- សិក្សាស្រាវជ្រាវតំបន់សក្តានុពលសម្រាប់អនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ(REDD)

*ហិរញ្ញប្បទាន*

- ធ្វើការត្រួតពិនិត្យវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថានធម្មជាតិចំពោះរាល់គម្រោងសំណើវិនិយោគ និងអភិវឌ្ឍក្នុងវិស័យព្រៃឈើ
- ការវិភាគប្រៀបធៀបផល-តម្លៃ ធៀបនឹងការប្រើប្រាស់ដី ឬ ការគ្រប់គ្រងព្រៃឈើតាមជម្រើសផ្សេងៗ
- សិក្សាស្វែងរកប្រភពចំណូលពីការបង់ថ្លៃសេវាកម្មបរិស្ថាន និងការលក់ឥណទានកាបូនតាមរយៈការកាត់ បន្ថយការ បញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ។

### ៥.១៤.៣ លទ្ធផលរំពឹងទុក

- យុទ្ធសាស្ត្រស្រាវជ្រាវព្រៃឈើកម្រិតជាតិ ត្រូវបានរៀបចំឡើងដើម្បីកំណត់ទិសដៅស្រាវជ្រាវ និងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ ដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ

- ក្រុមការងារសម្របសម្រួលការងារស្រាវជ្រាវព្រៃឈើមួយនឹងត្រូវបានបង្កើតឡើង ដើម្បីរៀបចំតម្រង់ទិសយុទ្ធសាស្ត្រស្រាវជ្រាវ ឱ្យស្របតាមកម្មវិធីព្រៃឈើជាតិ
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើនឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្របសម្រួល និងអនុវត្តការងារសិក្សាស្រាវជ្រាវវិស័យព្រៃឈើ ឆ្លើយតបទៅនឹងកម្មវិធីទាំងប្រាំដែលបានចែងក្នុងកម្មវិធីព្រៃឈើជាតិ
- ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃជាមួយសាកលវិទ្យាល័យព្រមទាំង អង្គភាពស្រាវជ្រាវនានាត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការសិក្សាស្រាវជ្រាវរួមគ្នា ហើយលទ្ធផលដែលបានមកពីការសិក្សា ស្រាវជ្រាវទាំងនោះនឹងត្រូវបានប្រើប្រាស់ជាប្រយោជន៍ដល់អ្នកប្រើប្រាស់ និងអ្នករៀបចំផែនការនិងគោលនយោបាយ។
- ការចូលរួមរបស់អង្គភាពស្រាវជ្រាវនៅកម្ពុជានៅក្នុងបណ្តាញស្រាវជ្រាវព្រៃឈើជាតិ តំបន់ និងអន្តរជាតិ ត្រូវបានពង្រឹង ហើយ អង្គភាពស្រាវជ្រាវទាំងនេះនឹងអាចទាញយកផលប្រយោជន៍ពីការបណ្តុះបណ្តាល និងមានលទ្ធភាពអាចស្វែងរកជំនួយបរទេស សម្រាប់ធ្វើការសិក្សាស្រាវជ្រាវវិស័យព្រៃឈើ។

## ៥.១៥ តម្រូវការហិរញ្ញវត្ថុ

តារាង៥ ៖ គម្រោងថវិកា សម្រាប់អនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវ ពីឆ្នាំ ២០១០-២០២០

| អនុកម្មវិធី | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ ២០១០-២០១៤ (ដុល្លាអាមេរិក) | ថវិកាប៉ាន់ស្មាន ក្នុងឆ្នាំ ២០១៥-២០២០ (ដុល្លាអាមេរិក) |
|---|---|---|
| ៥.១ ការអភិវឌ្ឍស្ថាប័ននិងធនធាន មនុស្ស | ៨.០៥០.០០០ | ៥.០០០.០០០ |
| ៥.២ ការអប់រំ និង ផ្សព្វផ្សាយសាធារណៈ | ២.៣៥០.០០០ | ២.៣៥០.០០០ |
| ៥.៣ ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ | ២.៦០០.០០០ | ២.០០០.០០០ |
| សរុប | ១៣.០០០.០០០ | ប្រហែល ៩.៣៥០.០០០ |

| | | |
|---|---|---|
| ថវិកាបរិច្ចាគមកពីដៃគូអភិវឌ្ឍន៍ | ៩.២០០.០០០ | |

សន្មតថា ចំណូលពីព្រៃឈើនឹងត្រូវធ្វើការវិនិយោគឡើងវិញនៅក្នុងផ្នែកនិងការងារខាងលើនេះ ដែលជាលទ្ធផល និងធ្វើឱ្យការអនុវត្ត ការងារនេះកាន់តែមានលក្ខណៈស្វ័យហិរញ្ញប្បទានសមស្រប និងមានសង្គតភាពជាមួយនឹងកម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់ វិស័យព្រៃឈើ។ ចំណែកឯថវិកាបរិច្ចាគពីដៃគូរភិវឌ្ឍន៍នឹងកាន់តែមានការថយចុះបន្តិចម្តងៗនៅជំហានទី២ ដែលមានរយៈពេល ៥ ឆ្នាំទៀត។

## ៨.៦ កម្មវិធីទី ៦ ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ

### ៦.១ ចំណុចអាទិភាពសំខាន់ៗ ៖

- មាននិរន្តរភាពធុរកិច្ចសម្រាប់ការងារសហគមន៍មូលដ្ឋាន ការងារគ្រប់គ្រង និង ការងារអភិរក្សព្រៃឈើ
- មានការចូលរួមពីស្ថាប័ន អង្គភាព និងដៃគូពាក់ព័ន្ធ (រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ។ល។
- ធ្វើឱ្យប្រសើរឡើងនូវធុរកិច្ច និងបរិយាកាសវិនិយោគ (តម្លាភាព និងសុវត្ថិភាពនៃការផ្តល់សិទ្ធិ និងសិទ្ធិប្រើប្រាស់)។
- ផ្តល់ឱកាសឱ្យស្មើភាពគ្នានិងយុត្តិធម៌គ្រប់ភាគីពាក់ព័ន្ធ

### ៦.២ រយៈពេលកម្មវិធី

មានរយៈពេល ២០ឆ្នាំ ចាប់ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២៩

### ៦.៣ ការឆ្លើយតបទៅនឹងទស្សនវិស័យកម្មវិធីព្រៃឈើជាតិ

កម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើមានទិសដៅគាំទ្រ និងចូលរួមផ្តល់ដល់ការអនុវត្តកម្មវិធី ព្រៃឈើជាតិតាមបណ្តាអនុកម្មវិធី ដោយភ្ជាប់ទំនាក់ទំនងទៅនឹងការអនុវត្តកម្មវិធីទាំង ៥ របស់កម្មវិធីព្រៃឈើជាតិ។

អនុកម្មវិធីនីមួយៗនៃកម្មវិធីព្រៃឈើជាតិអាចប្រព្រឹត្តទៅបានតាមការផ្តល់ហិរញ្ញប្បទាន ទោះជាតាម ការបង្កើតប្រាក់ ចំណូល មូលនិធិរាជរដ្ឋាភិបាល ឬជំនួយអភិវឌ្ឍក្តី សុទ្ធតែមានអានុភាពទៅលើគ្រប់សកម្មភាព និងផ្តល់ឱ្យដឹងនូវវិសាលភាព និងកម្រិតសកម្មភាពការងារផ្សេងៗគ្នា។ កម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ មានទិសដៅផ្តល់ឱ្យ មានគម្រោងសេដ្ឋកិច្ចដោយនិរន្តរភាពសម្រាប់កម្មវិធីព្រៃឈើជាតិ។

## ៦.៤ ការឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

គោលបំណងនៃកម្មវិធីព្រៃឈើជាតិ នឹងទទួលបានជោគជ័យអាស្រ័យលើការអនុវត្តបណ្តាកម្មវិធីនីមួយៗ។ កម្មវិធីហិរញ្ញប្បទាន ដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ មានអនុកម្មវិធីចំនួន ៥ ដូចខាងក្រោមៈ

1. ការផ្តល់ហិរញ្ញប្បទាន និងការចំណាយ
2. ចំណូលពីវិស័យព្រៃឈើ
3. ចំណូលពីវិស័យឯកជន និងសហគមន៍ព្រៃឈើ
4. ការផ្តល់ហិរញ្ញប្បទាន តាមរយៈដៃគូអភិវឌ្ឍន៍
5. ប្រភពហិរញ្ញប្បទានថ្មីៗនៃសេវាកម្មបរិស្ថានព្រៃឈើ និងឥណទានកាបូន ។

## ៦.៥. ប្រវត្តិកម្មវិធី

ប្រទេសកម្ពុជា មានបទពិសោធន៍អំពីផលវិបាកនៃការបំផ្លិចបំផ្លាញព្រៃឈើដោយសារការធ្វើអាជីវកម្មព្រៃឈើគ្មានការត្រួតពិនិត្យ ជាពិសេសនៅក្នុងកំឡុងពេលមានសង្គ្រាមផ្ទៃក្នុង និងការផ្តើមអនុវត្តកិច្ចព្រមព្រៀងព្រៃសម្បទាន។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែល កើតឡើងពីការធ្វើអាជីវកម្មឈើខុសច្បាប់ រាជរដ្ឋាភិបាលបានផ្អាកការងារអាជីវកម្មព្រៃសម្បទានទាំងអស់ចាប់ពីខែមករាឆ្នាំ ២០០២ រហូតមកដល់បច្ចុប្បន្ន។

ឆ្នាំ ២០០៦ គម្របព្រៃឈើកម្ពុជាបានថយចុះពី ៧៣% (ក្នុងឆ្នាំ ១៩៦៥) មកត្រឹមប្រមាណ ៥៩% (ប្រហែល ១០៧ លានហិកតា)។ ការថយចុះគម្របព្រៃឈើនេះបណ្តាលមកពីការកាប់រាន និងហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើដោយខុសច្បាប់ និងការប ក្លាយដីព្រៃឈើទៅជាដីកសិកម្ម។

កំឡុងទស្សវត្សឆ្នាំ ១៩៩០ និងដើមស្សវត្សឆ្នាំ ២០០០ ផ្ទៃដីព្រៃឈើប្រមាណ ៦៨ លានហិកតាត្រូវបានផ្តល់ជាព្រៃសម្បទាន ចំណូលផលព្រៃឈើដែលទទួលបានពីរបបគ្រប់គ្រងព្រៃសម្បទាននេះមានចំនួនតិចតួចជាងចំនួនដែលបានរំពឹងទុក (ត្រឹមតែ៤-១២% ប៉ុណ្ណោះ) នៃផលទុនក្នុងស្រុកសរុបរបស់ជាតិ។ ការនាំឈើចេញប្រមាណជា ៥៩០.០០០ ម៉ែត្រគូប ដែលជាកម្រិតកំពូលនៅឆ្នាំ ១៩៩៥ ត្រូវបានធ្លាក់មកត្រឹមប្រមាណ ៧៤ .០០០ ម៉ែត្រគូប នៅឆ្នាំ ២០០០ ហើយ ស្ទើរតែសូន្យនៅឆ្នាំ ២០០៧។

បច្ចុប្បន្ននេះ ផ្ទៃដីព្រៃឈើសរុបជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍មាន ៥៩% នៃផ្ទៃដីប្រទេស ក្នុងនោះ ២៨% ត្រូវបានចាត់ថ្នាក់ជាតំបន់ការពារ (ប្រមាណជា៣លានហិកតា) ១៤% ជាព្រៃការពារ

(ប្រមាណជា ១.៥ លានហិកតា) ៣០%ជាព្រៃសម្បទាន(ប្រមាណជា ៣.២ លានហិកតា) និងនៅសល់ ២៨%(ប្រមាណជា៣លានហិកតា) គឺជាព្រៃផ្ដល់ផលផ្សេងទៀត។

ប្រទេសកម្ពុជាមានប្រជាជន ៨៤% រស់នៅក្នុងតំបន់ជនបទ ហើយភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិ។ ដូចនេះ ការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាពមានភាពសំខាន់ណាស់សម្រាប់ជីវភាពរស់នៅ ក៏ដូចជាក្នុងការកាត់បន្ថយភាពក្រីក្រ Schweithelm,2009)។បញ្ហានេះបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណស្ដីពី កំណើនផលទុនជាតិ បង្កើតការងារ សមភាព និងប្រសិទ្ធភាព រួម ទាំងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (២០០២) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-១០)បានកំណត់ការងារគ្រប់គ្រង វិស័យព្រៃឈើជាចំណុចអាទិភាពក្នុងកម្មវិធីអភិវឌ្ឍជាតិ ហើយទីបំផុតការរក្សាគម្របព្រៃឈើនៅក្នុងកម្រិត ៦០% នៃផ្ទៃដីទូទាំងប្រទេស គឺជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។

ករណីប្រៀបធៀបជាមួយប្រទេសជិតខាង ស្ថានភាពព្រៃឈើកម្ពុជា គឺនៅមានលក្ខណៈល្អប្រសើរជាង។ ដូចនេះ ប្រសិនបើជា មានការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព នោះព្រៃឈើជាប្រភពចំណូលដ៏សំខាន់សម្រាប់ជាតិ និងមូលដ្ឋាន។

## ៦.២ ការវិភាគបញ្ហា

វិស័យព្រៃឈើត្រូវការផ្ដល់នូវហេតុផលសមស្របនៃការបង្កើតប្រាក់ចំណូល។ តំបន់ព្រៃសម្បទាន តំបន់ព្រៃឈើសហគមន៍ និង តំបន់ព្រៃផ្ដល់ផលផ្សេងទៀត រួមបញ្ចូលមានទំហំប្រមាណជាង ៥,៧ លានហិកតា ដូចនេះ បើសិនជាគិតពីសន្និធិប្រាក់ចំណូលជា មធ្យមពីឈើហ៊ុបដែលផ្ដល់តម្លៃប្រចាំឆ្នាំក្នុងមួយហិកតាប្រមាណ ៨ - ១០ ដុល្លារ ឬ សន្និធិប្រាក់ចំណូលសរុបអាចទទួលបានប្រចាំឆ្នាំជាមធ្យមប្រមាណ) ៤៦-៥៧ លានដុល្លារ។ បច្ចុប្បន្ន សន្និធិប្រាក់ចំណូលនេះមិនទាន់បានគិតគូរកចំណូលឱ្យបានជាក់ស្ដែងនៅឡើយ។ ជាងនេះទៅទៀត ការបង់សេវាព្រៃឈើ ដូចជា សេវាបរិស្ថាន អេកូ-ទេសចរណ៍ ចំណូលពីពាណិជ្ជកម្មកាបូន ឬ ពីគំរូគ្រប់គ្រងព្រៃឈើ ផ្សេងៗទៀតនឹងអាចចាប់ផ្ដើមដំណើរការ និងទទួលបានចំណូលចំនួនមិនតិចជាង ឬអាចច្រើនជាងចំណូលពីអាជីវកម្មឈើហ៊ុបហើយ ក៏ជាប្រភេទចំណូលដោយមាននិរន្តរភាព។ ប្រសិនបើដីព្រៃឈើមិនអាចផ្ដល់ចំណូលពីឈើហ៊ុបប្រចាំឆ្នាំបាន ៨-១០ ដុល្លាក្នុងមួយ ហិកតានោះទេ ក៏មានជម្រើសប្រភេទចំណូលពីការបង់សេវាព្រៃឈើ ឬពីគំរូគ្រប់គ្រងព្រៃឈើផ្សេងៗទៀតមកអនុវត្តផងដែរ។ ដូច្នេះ ហេតុផលនឹងត្រូវបានចោទសួរ និងធ្វើការប្រៀបធៀបស្ដីពីប្រភេទចំណូលពីការដកហូតផលព្រៃឈើ (ឈើហ៊ុប) ជាមួយនឹងប្រភេទចំណូលពីសេវាព្រៃឈើ ហើយនឹងជាមួយប្រភេទចំណូលពីការប្រើប្រាស់ដី ផ្សេងៗទៀត។

រូបវន្តបុគ្គល សហគមន៍ និងវិស័យឯកជនអាចចូលរួមធ្វើការវិនិយោគក្នុងវិស័យព្រៃឈើនៅពេលដែលពួកគេមានធនធានគ្រប់គ្រាន់ និងទទួលបានការលើកទឹកចិត្ត។ ការវិនិយោគរយៈពេលវែងក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព គឺអាស្រ័យទៅលើជាតុសំខាន់ៗដូចខាងក្រោម ៖

- សុវត្ថិភាពសិទ្ធិនៃការប្រើប្រាស់ដី
- សុវត្ថិភាពផ្តល់មូលនិធិ/ហិរញ្ញវត្ថុ
- ភាពច្បាស់លាស់ តម្លាភាព លទ្ធភាពគ្រប់គ្រង និងភាពត្រឹមត្រូវនៃការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗទៀត ការងាររដ្ឋបាលសមស្រប និងមានទំនុកចិត្តរបស់ប្រជាជនទៅលើអាជ្ញាធរសាធារណៈ
- បង្កើតការផ្តួចផ្តើមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ។

ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ និងយុទ្ធសាស្រ្តចតុកោណផ្តល់នូវក្របខណ្ឌយុទ្ធសាស្រ្ត និងច្បាប់សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ប៉ុន្តែកាអនុវត្តនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពត្រូវទទួលគ្រោះថ្នាក់ដោយសារការយល់ដឹងរបស់ប្រជាជន អំពីថា តើគេត្រូវធ្វើដូចម្តេច ការមិនគិតគូរវែងឆ្ងាយ ការបាត់ជំនឿលើអាជ្ញាធរ និងការអភិរក្សនិយមលើវប្បធម៌។

*មានសំណួរពាក់ព័ន្ធមួយចំនួន ៖*

- តើមានផ្ទៃដីប៉ុន្មានហិកតាទៀតដែលត្រូវកំណត់ប្រគល់ឱ្យសហគមន៍ព្រៃឈើ?
- តើតំបន់សម្បទានបច្ចុប្បន្ននឹងស្ថិតនៅកម្រិតណា?
- តើរដ្ឋបាលព្រៃឈើនឹងគ្រប់គ្រងដោយផ្ទាល់ចំពោះព្រៃឈើផ្តល់ផលឬទេ?
- តើក្នុងតំបន់ព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋមានគម្រោងផ្តល់ដីសម្បទានសេដ្ឋកិច្ចប៉ុន្មានហិកតាទៀត?

ការផ្តល់មូលនិធិ គឺត្រូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ និងកម្មវិធី អនុវត្តកម្មវិធីព្រៃឈើជាតិ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលនិងរដ្ឋបាលព្រៃឈើមានសមត្ថភាព ប៉ុន្តែពុំមានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីអនុវត្តន៍ កម្មវិធីព្រៃឈើជាតិ ហេតុនេះហើយទើបទាមទារឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ជំហានអនុវត្តដំបូងជាចាំបាច់ មុនពេលដែលវិស័យព្រៃឈើជាតិអាចម្ចាស់ការខ្លួនឯងក្នុងការរួមចំណែករយៈពេលវែងក្នុងកំណើន និងសុខមាលភាពសាធារណៈ។

## ៦.៧ គោលបំណងនៃកម្មវិធី

អនុកម្មវិធីទាំងអស់ ត្រូវចូលរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ហើយសម្រេចឱ្យបាននូវសុខមាលភាព សាធារណៈតាមមធ្យោបាយ

- សុវត្ថិភាពនៃកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់
- ធានាថាតម្លៃពេញលេញរបស់ធនធានព្រៃឈើត្រូវក្តោបក្តាប់បាន
- បង្កើតយន្តការហិរញ្ញវត្ថុឱ្យមាននិរន្តរភាព និងកម្មវិធីវិនិយោគ
- ជំរុញការរួមចំណែកការស្រូបឧស្ម័នកាបូន សម្រាប់ព្រៃឈើ
- ជំរុញចរន្តនៃការប្រើប្រាស់ចំណូលព្រៃឈើមកធ្វើការវិយោគឡើងវិញក្នុងវិស័យនេះ ដើម្បីទទួលបាននូវនិរន្តរភាពហិរញ្ញវត្ថុ
- ជំរុញការផ្តើមគំនិតអភិវឌ្ឍន៍ពីការពឹងអាស្រ័យលើជំនួយមកពឹងលើខ្លួនឯង

## ៦.៨ សូចនាករ

- ការប្តេជ្ញាចិត្តផ្នែកនយោបាយ
- បុគ្គលិកមានការយល់ដឹង មានការប្តេជ្ញាចិត្តដើម្បីសម្រេចគោលដៅ
- វិធីកៀងគរហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់ និងសកម្មភាពជាក់លាក់សម្រាប់អនុកម្មវិធី
- បណ្តាសហគមន៍ព្រៃឈើ និងអ្នកដាំឈើឯកជនទាំងឡាយមានការជឿជាក់ក្នុងការធ្វើវិបុលកម្ម
- តម្លាភាពថវិកាសាធារណៈ និងគណនេយ្យភាពចំពោះការវិភាជន៍មូលនិធិសម្រាប់ដំណើរការសកម្មភាព អនុកម្មវិធីរបស់ព្រៃឈើជាតិតាមគោលបំណងដែលបានកំណត់
- ប្រើប្រាស់ចំណូលព្រៃឈើដើម្បីវិនិយោគឡើងវិញទៅក្នុងវិស័យនេះ
- ធ្វើការគ្រប់គ្រងផលិតផលដែលមានតម្លៃខ្ពស់ដើម្បីធ្វើការកែច្នៃនាំចេញ
- ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តច្បាប់
- គុណប្រយោជន៍ និងប្រាក់ចំណូលពីសកម្មភាពសហគមន៍ព្រៃឈើ រួមទាំងចំណូលបានមកពីការលក់ផលិតផលព្រៃឈើ
- ការវិភាជន៍ធនធានរបស់រដ្ឋបាលព្រៃឈើដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិមានហិរញ្ញប្បទាន ក៏ដូចជាធនធានមនុស្សនិងមូលនិធិផ្សេងទៀត។

## ៦.៩ ការផ្ទៀងផ្ទាត់

- ប្រព័ន្ធតាមដានកម្មវិធីព្រៃឈើជាតិ
- អនុក្រឹត្យ
- គោលការណ៍ណែនាំអនុវត្តលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

- ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ស្ថិតិនាំចូលប្រៀបធៀប និងស្ថិតិនាំចេញរបស់កម្ពុជា
- គណនេយ្យសហគមន៍ព្រៃឈើ
- គណនេយ្យប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ
- ស្ថិតិព្រៃឈើ
- បទដ្ឋានវិញ្ញាណ្ណបត
- ការថែរក្សាឯកសារស្តីពី ចំនួនមនុស្សដែលចាប់ខ្លួន រឿងក្តីតុលាការ និង ការកាត់ទោស

## ៦.១០ ហានិភ័យ

- ពុំមានសុធន្ទៈគ្រប់គ្រាន់ក្នុងការិះរកវិធីដោះស្រាយថ្មីៗ ហើយនិងដើម្បីទទួលហានិភ័យ
- ភាពមិនប្រាកដប្រជា និងការអនុវត្តពុំបានគ្រប់ជ្រុងជ្រោយនូវនយោបាយបច្ចុប្បន្ន រួមទាំងការអនុវត្តកម្មវិធីព្រៃឈើជាតិ ដោយសារខ្វះសមត្ថភាពស្ថាប័ន
- សមត្ថភាពកត់ត្រាក្នុងវិស័យព្រៃឈើនៅមានការខ្វះចន្លោះ ជាពិសេស គឺការកត់ត្រាតួរលេខផលិតកម្ម ចខ្វះការវាយតម្លៃលើតម្រូវការអប់រំដែលអាចទុកចិត្តបាន និងខ្វះសមត្ថភាពធ្វើ
- ខ្វះការប្តេជ្ញា និងសមត្ថភាពដើម្បីចូលរួមក្នុងភាពជាដៃគូជាមួយផ្នែកពាក់ព័ន្ធ
- ការកាប់ឈើខុសច្បាប់ដែលកើតឡើងដោយសារការអនុវត្តច្បាប់នៅខ្សោយ ០ខ្វះការអនុម័តគោលការណ៍ណែនាំចំពោះការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
- ការរីករាលដាលនូវទំហំ និងអនាគតដីសម្បទានសេដ្ឋកិច្ច
- ខ្វះការចូលរួមឱ្យបានពេញលេញ ដោយសារមានភាគីខ្លះពុំចង់ឱ្យមានការរៀបចំបានល្អនូវវិស័យព្រៃឈើ
- កង្វះម្ចាស់ជំនួយដែលចង់ផ្តត់ផ្គង់ថវិកាជំនួយ។

## ៦.១១ យុទ្ធសាស្ត្រអនុវត្តកម្មវិធី

យុទ្ធសាស្ត្រនៃកម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ គឺឈរលើមូលដ្ឋាននៃការសន្មតដូចតទៅ ៖

- គម្របព្រៃឈើកម្ពុជានឹងស្ថិតនៅកម្រិតកំណត់ ៦០% នៃផ្ទៃក្រឡាប្រទេស (១០៩ លានហិកតា)
- តំបន់ព្រៃសម្បទាននឹងរៀបចំ អភិវឌ្ឍ តាមមុខងារ និងសក្តានុពលពិតប្រាកដរបស់ព្រៃឈើ

- សកម្មភាពសេដ្ឋកិច្ច ដូចជាអេកូទេសចរណ៍ និងកម្មវិធី REDD ត្រូវបានកំណត់ផ្ទៃដីព្រៃឈើប្រមាណយ៉ាងតិច ៣ លានហិកតា សម្រាប់គ្រប់ប្រភេទព្រៃទាំងអស់ (ក្នុងតារាង ទី៤)
- តំបន់ព្រៃឈើប្រមាណ ២ លានហិកតា ត្រូវបានរៀបចំជាសហគមន៍ព្រៃឈើ (តារាង ទី៤)
- ការធ្វើចំណាត់ថ្នាក់ឡើងវិញ សម្រាប់ប្រភេទព្រៃផ្តល់ផល ចំនួន ២៤ លានហិកតា និងត្រូវបានគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ និងឯកជន ធ្វើការអនុវត្តតាមសៀវភៅបច្ចេកទេសស្តីពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព (តារាង ទី៤)
- ការផ្តល់ឱកាសសម្រាប់ការជួលឱ្យភាគីទីបី និងការដាក់ដេញថ្លៃប្រកួតប្រជែងនឹងត្រូវបានជំរុញ និងបង្កើននូវតម្លៃប្រសិទ្ធភាព ក្នុងការអនុវត្ត
- ការផ្តល់ជម្រើសនឹងត្រូវបានជំរុញសម្រាប់ការប្រមូលពន្ធបរិស្ថានពីឧស្សាហកម្មព្រៃឈើ ដែលបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថាន។ ការទទួលជោគជ័យលើផ្នែកសេដ្ឋកិច្ចរយៈពេលវែង គឺជាគ្រឹះសម្រាប់កម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ។ ទស្សនៈក្នុងការសំរេចឱ្យបាននិរន្តរភាព និងជោគជ័យសេដ្ឋកិច្ច គឺអាស្រ័យលើការសន្មតថា អ្នកផ្តល់ជំនួយអន្តរជាតិនឹងវិនិយោគក្នុងការរៀបចំដំបូងដែលចំណាយថវិកាច្រើន ប៉ុន្តែនេះជាហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់។ នៅពេលហេដ្ឋារចនាសម្ព័ន្ធនេះដំណើរការហើយ ពេលនោះវានឹងត្រូវការថវិកាតិចជាងក្នុងការអនុវត្ត។ នេះជាចំណុចសំខាន់បំផុតសម្រាប់កម្ពុជាអភិវឌ្ឍបន្តដោយប្រើប្រាស់ធនធានធម្មជាតិ របស់ខ្លួន។ ដើម្បីអភិវឌ្ឍន៍ពីការពឹងផ្អែកលើជំនួយមកជាការពឹងលើខ្លួនឯង យុទ្ធសាស្ត្រហិរញ្ញវត្ថុជារួមត្រូវបានអភិវឌ្ឍ។

តារាង៦ ៖ សេចក្តីសង្ខេបកម្មវិធី

| | រយៈពេលខ្លីដំណាក់កាលសាកល្បង(៥ឆ្នាំ) | រយៈពេលមធ្យមដំណាក់កាល ពង្រីក (៨ឆ្នាំក្រោយ) | រយៈពេលវែងដំណាក់កាល ពង្រឹង(៧ឆ្នាំ) |
|---|---|---|---|
| សកម្មភាព | ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការប្រមូលទិន្នន័យដំបូង បង្កើនការអប់រំការកសាង សមត្ថភាព រៀបចំប្រព័ន្ធគណនីកាបូនជាតិ | ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការកំណត់គោលដៅ (បរិមាណីបង្កើនការអប់រំ ការកសាងសមត្ថភាពការតាមដាននិងវាយតំលៃ | ការរក្សាដំណើរការហេដ្ឋារចនាសម្ព័ន្ធ ការតាមដាននិងវាយតំលៃការផ្តល់សេវាកម្មបណ្តុះបណ្តាល ការផ្លាស់ប្តូរ |

| | | | |
|---|---|---|---|
| | | | ចំណេះដឹងការតាមដាន និងវាយតំលៃ |
| ការផ្ទង់ផ្ទេរហិរញ្ញវត្ថុ | ជំនួយសម្រាប់ការអភិវឌ្ឍ (ODA)ជំនួយគ្មានសំណង (grants)ការវិភាជន៍ថវិកាជាតិ | ODA = ៦០% វិស័យឯកជន = ២៥ ថវិកាជាតិ = ១៥% | ODA = ៤០% វិស័យឯកជន = ៣៥% ថវិកាជាតិ = ២៥% |
| លក្ខខណ្ឌ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា នីតិកម្ម-ទីផ្សារ ការកំណត់ធនធាន ការរៀបចំស្ថាប័ន | ការកែទម្រង់ដីធ្លី ការផ្ដល់កម្មសិទ្ធិដី និងសិទ្ធិប្រើប្រាស់ដី។ល។មានទីផ្សារល្អ-វប្បធម៌ស្អាតស្អំ(មិនពុករលួយ) និងតម្លាភាព | |

មុខសញ្ញានៃកម្មវត្ថុប្រទាក់ក្រឡា (នយោបាយ ច្បាប់ ការកែទម្រង់អង្គភាព ប្រទាក់ក្រឡា ជាមួយអ្នកពាក់ព័ន្ធ សមត្ថភាពហិរញ្ញវត្ថុ និងការបែងចែកផលប្រយោជន៍ )។

ក្របខណ្ឌគោលនយោបាយព្រៃឈើជារួមត្រូវបានបង្កើត និងកំពុងអនុវត្ត (ច្បាប់ស្ដីពីព្រៃឈើឆ្នាំ ២០០២) ប៉ុន្តែដើម្បីអនុវត្តកម្ម វិធីព្រៃឈើជាតិឱ្យបានជោគជ័យចាំបាច់ត្រូវធ្វើការពិនិត្យនិងកែសំរួលឡើងវិញ ឬរៀបចំបន្ថែមនូវអនុក្រឹត្យនិងលិខិតបទដ្ឋានពាក់ព័ន្ធមួយ ចំនួន ឧទាហរណ៍ដូចជា អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងបទដ្ឋានស្ដីពីការកំណត់ព្រំប្រទល់ព្រៃឈើចាំបាច់ត្រូវកំណត់គោលបំណងឱ្យបានច្បាស់លាស់ និងផ្ដល់សារៈសំខាន់ ហើយត្រូវមានការគាំទ្រផ្នែកនយោបាយចំពោះសំណើសកម្មភាពសេដ្ឋកិច្ច។ដូចជាសកម្មភាពផ្សេងៗ អាចទទួលយកមកអនុវត្តក្នុងតំបន់ការពារ និងព្រៃការពារ ។

តំបន់ការពារក៏ជាតំបន់ព្រៃឈើដែរ (មិនមែនសុទ្ធតែព្រៃទាំងអស់នោះទេ កន្លែងខ្លះជាវាលស្មៅ កន្លែងខ្លះជាព្រៃគុម្ពោត) ប៉ុន្តែគ្រប់គ្រងដោយក្រសួងបរិស្ថាន។

ដីសម្បទានសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារដែលជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍មានភាពច្បាស់លាស់អំពីស្ថានភាពគ្រប់គ្រង នឹងត្រូវដំណើរការយ៉ាងដូចម្ដេចនាពេលអនាគត។

ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យព្រៃឈើមានភាពជឿនលឿនទៅមុខល្អ ប៉ុន្តែការអនុវត្តនៅមានការខ្វះខាត។ ការអនុវត្តកម្មវិធីព្រៃឈើជាតិជាការសំខាន់ណាស់ដែលត្រូវកំណត់ព្រំប្រទល់ព្រៃឈើ ការផ្តល់សិទ្ធិ និងសិទ្ធិប្រើប្រាស់ដី ដើម្បីប្រគល់ការទទួលខុសត្រូវសម្រាប់សហគមន៍ព្រៃឈើក៏ដូចជាជួយដល់ភាគីពាក់ព័ន្ធអោយទទួលស្គាល់ភាពជាម្ចាស់និងអនុវត្តឱ្យសមស្របតាមវិធានប្រតិបត្តិ។

ភាពផ្លាស់ប្តូរនការចាត់ចែងរៀបចំ និងការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើជាការសំខាន់បំផុត។សហគមន៍ព្រៃឈើចំនួន ៣២៥ ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៣៥០. ២៣៩ ហិកតានឹងត្រូវផ្តល់សេវាផ្សព្វផ្សាយដល់ក្រុមគ្រប់គ្រងព្រៃសហគមន៍ ដើម្បីគ្រប់គ្រងព្រៃឈើសហគមន៍ដោយនិរន្តរភាព។

ភាពស្មោះត្រង់ និងតម្លាភាពនៃការងារសម្បទានផ្សេងៗ និងការដេញថ្លៃព្រៃគុបប្រចាំឆ្នាំ ត្រូវរៀបចំនិងអនុវត្តឱ្យបានគោល ការណ៍ណែនាំ និងលិខិតបទដ្ឋានដែលកំពុងអនុវត្តយន្តការត្រួតពិនិត្យពីក្រៅអង្គភាព ជាលទ្ធភាពនៃជម្រើសចាំបាច់ផ្តល់ការងាយស្រួល ក្នុងការអនុវត្ត និងជាសក្តានុពលដើម្បីប្រសិទ្ធភាពតម្លៃ។

ការកសាងសមត្ថភាព និងការអភិវឌ្ឍអង្គភាពនៃកិច្ចសហការការងារគ្រប់គ្រង និងវប្បធម៌រួបរួមគ្នាជាកិច្ចការដ៏ចំបងបំផុត។ជាមួយនឹងការប្តេជ្ញាចិត្តចំពោះការងារកំណត់ព្រំប្រទល់ដីព្រៃឈើ និងធ្វើចំណាត់ព្រៃឈើ ការចេញប័ណ្ណកាន់កាប់ដី និងការបរិយាយអំពីសិទ្ធិកាន់កាប់ នឹងសិទ្ធិប្រើប្រាស់ ជាការចាំបាច់ឱ្យមានធាតុចូលដ៏ចំបងនូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេស។ ក្នុងពេលអភិវឌ្ឍន៍សមត្ថភាពអង្គភាព កម្រូវឱ្យមានការប្រឹងប្រែងព្យាយាមជានិរន្តដើម្បីទទួលបានសុទិដ្ឋិនិយមចំពោះការរៀបចំអនុវត្តការងារគ្រប់ពេលវេលា។

កម្មវិធី( REDD )ដែលមានរដ្ឋបាលព្រៃឈើជាអាជ្ញាធរប្រតិបត្តិ គឺជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីការគ្រប់គ្រងព្រៃឈើដោយ និរន្តរភាព។ កម្មវិធីនេះអាចមានទិសដៅច្បាស់លាស់អាស្រ័យទៅតាមលទ្ធផលនៃកិច្ចប្រជុំលើកទី១៥ នៃសន្និសិទ្ធប្រទេសបណ្តាភាគី COP 15 (Conference of the Patty) របស់កិច្ចព្រមព្រៀងក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

## ៦.១២ សាចតារនៃការគណនាថវិកា

ការបង្កើតចំណូល នឹងត្រូវបានពន្យារ ព្រោះសកម្មភាពសំខាន់ៗមួយចំនួន មិនអាចចាប់ផ្តើមបានមុនពេលបំពាក់ហេដ្ឋារចនា សម្ព័ន្ធចាំបាច់សម្រាប់កិច្ចដំណើរការបានទេ។

ចំពោះប្រភេទចំណូលសុទ្ធដូចក្នុងករណី REDD ត្រូវបានគណនាដោយបញ្ចុះតម្លៃកាបូនដោយសារការចំណាយមានកម្រិត ខ្ពស់លើការរៀបចំប្រព័ន្ធ ការងារ។ដើម្បីដោះស្រាយបញ្ហានេះ គឺប្រមូលផ្តុំពីគម្រោងតូចៗ បង្កើតជាគម្រោងធំៗ

បើទោះបីជាវិស័យព្រៃឈើអាចជួយបង្កើតនូវប្រាក់ចំណូលបានច្រើននិងជួយដល់និរន្តរភាពនៃផែនការអភិវឌ្ឍន៍ជាតិក៏ដោយក៏តម្រូវឱ្យមានការវិនិយោគដំបូងពីខាងក្រៅឧទាហរណ៍មូលនិធិអភិវឌ្ឍអន្តរជាត

តារាង៧ ៖ តួលេខសំខាន់ៗមួយចំនួន

| បរិយាយ | ចំនួន |
|---|---|
| សក្តានុពលនៃការធ្វើអាជីវកម្មឈើហ៊ុបមូលប្រកបដោយនិរន្តរភាពមាន | ០,៥-១លាន ម៉ែត្រគូប |
| សក្តានុពលនៃការអាជីវកម្ម ជ្បូង អុសបង្គោលរបង។ល។ ប្រកបដោយនិរន្តរភាពមាន | ១,៥-២ លាន ម៉ែត្រគូប |
| ការប៉ាន់ប្រមាណនៃការប្រមូលផលឈើហ៊ុបមូលជានិរន្តរ៍ ឆ្នាំ<br>(ការគណនាតាមកំរឹតលូតលាស់ឈើ) | ០,៣-០,៥ ម៉ែត្រគូប/ហិកតា/ |
| តម្លៃឈើហ៊ុបមូលនៅរោងចក្រអារឈើប្រមាណ | ១៥០-២០០ ដុល្លារ ម៉ែត្រគូប |
| ផ្ទៃដីសម្បទានសេដ្ឋកិច្ចមានទំហំប្រមាណ | ០,៨-១ លាន ហិកតា |
| ការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ និងគម្រោងគ្រប់គ្រងការអភិវឌ្ឍគ្រោងចំណាយ | ២០ ដុល្លារូហិកតា |
| សហគមន៍ព្រៃឈើនៅឆ្នាំ ២០០៩ មានចំនួន | ៣២៥ សហគមន៍ព្រៃឈើ |
| សហគមន៍ព្រៃឈើសង្ឃឹមថានឹងរៀបចំបានចំនួន | ១.០៧០ សហគមន៍ព្រៃឈើ |
| ផ្ទៃដីព្រៃឈើសហគមន៍នៅឆ្នាំ ២០០៩ មានទំហំ | ៣៥០.២៣៩ ហិកតា |
| ផ្ទៃដីព្រៃឈើសហគមន៍សម្រាប់ផែនការ ៥ ឆ្នាំបន្ទាប់ | ៣៥០.០០០ហិក្ត |

| | |
|---|---|
| ក្តាគ្រោងសម្រេចបានបន្ថែមទៀតមានទំហំ | |
| ផ្ទៃដីព្រៃឈើសហគមន៍ដែលសង្ឃឹមថានឹងធ្វើការគ្រប់គ្រង ជាព្រៃឈើសហគមន៍សរុបមានទំហំ | ២លានហិកតា |
| មន្ត្រីរដ្ឋបាលព្រៃឈើនៅឆ្នាំ ២០០៨ មាន | ១៥៨០នាក់ |
| រដ្ឋបាលព្រៃឈើទទួលបានការបង់ថ្លៃសួយសារឈើក្នុងឆ្នាំ ដុល្លា ២០០៨ (៣៦ .៧៨៥ម³)មានទឹកប្រាក់ចំនួន | ២.៥៦៥.៨៦១ |
| មានទឹកប្រាក់ចំនួន តម្លៃសួយសារឈើលេខ ២ មួយម៉ែត្រគូប ៥៤ ដុល្លារ និង បុព្វលាភ ២៥ ដុល្លារ (ពីឆ្នាំ ១៩៩៩ ដល់បច្ចុប្បន្ន ២០០៩) | ៥៦,៥ដុល្លា |
| ចំណូលទទួលបានពីផាកពិន័យនៅឆ្នាំ ២០០៨ មានទឹកប្រាក់ចំនួន ដុល្លា | ២.៥៩៦.៨៦១ |
| ការប្រើប្រាស់ធ្យូងប្រចាំឆ្នាំប្រមាណ (០,៣ លានម៉ែត្រគូបនៃឈើ) | ៤៣០.០០តោន |
| ការប្រើប្រាស់អុសប្រចាំឆ្នាំប្រមាណ | ២,៣លានម៉ែត្រ |
| តម្រូវការប្រើប្រាស់ឈើសំណង់មានប្រមាណ ម៉ែត្រគូប | ៣០០.០០០-៣៦០.០០០ |
| ការប៉ាន់ស្មានសន្និធិកាបូនព្រៃឈើមាន (តួរលេខរដ្ឋបាលព្រៃឈើ) កតា | ១០០តោន/ហិ |
| ចំណូលគ្រោងទទួលបានពីឥណទានកាបូន (ចំណូលសុទ្ធ) តោន (តួរលេខរដ្ឋបាលព្រៃឈើ) | ៥ដុល្លា/ |

តារាង ៨ ៖ចំណាត់ថ្នាក់មុខងារព្រៃឈើបច្ចុប្បន្នដោយយោងតាមការសម្រេចរក្សាគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃដីទូទាំងប្រទេស។

| ចំណាត់ថ្នាក់ A | ចំណាត់ថ្នាក់ B | ចំណាត់ថ្នាក់ C | ចំណាត់ថ្នាក់ D | ចំណាត់ថ្នាក់ E |
|---|---|---|---|---|
| គ្រប់គ្រងដោយក្រសួងបរិស្ថានគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរដ្ឋបាលព្រៃឈើ | | | | |
| តំបន់ការពារ ប្រមាណ៣ | ព្រៃការពារ ប្រមាណ១,៥ | ព្រៃឈើសហគមន៍ ប្រមាណ២ | ព្រៃសម្បទាន ប្រមាណ៣,២ | ព្រៃផ្តល់ផល ប្រមាណ១,២ |

| | | | | |
|---|---|---|---|---|
| លានហិកតា | លានហិកតា | លានហិកតា | លានហិកតា | លានហិកតា |
| ដីព្រៃផ្សេងៗ ២០០.០០០ ហិកតា | ដីព្រៃផ្សេងៗ ១០០.០០០ ហិកតា | ដីព្រៃផ្សេងៗ ២០០.០០០ ហិកតា | ដីព្រៃផ្សេងៗ ៣០០.០០០ ហិកតា | ដីព្រៃផ្សេងៗ ២០០.០០០ ហិកតា |
| តំបន់ប្រតិបត្តិ ២.៥លានហិកតា | តំបន់ប្រតិបត្តិ ១.៤លានហិកតា | តំបន់ប្រតិបត្តិ ២.៨លានហិកតា | តំបន់ប្រតិបត្តិ ២.៩លានហិកតា | តំបន់ប្រតិបត្តិ ១លានហិកតា |

តារាង ៩ ៖ ការរំពឹងទុកនការធ្វើចំណាត់ថ្នាក់ព្រៃឈើឡើងវិញ តាមមុខងារព្រៃឈើ ដោយយោងតាមការសម្រេច រក្សាគម្របព្រៃឈើអោយបាន ៦០% នៃផ្ទៃដីទូទាំងប្រទេស

| ចំណាត់ថ្នាក់ A | ចំណាត់ថ្នាក់ B | ចំណាត់ថ្នាក់ C | ចំណាត់ថ្នាក់ D | ចំណាត់ថ្នាក់ E |
|---|---|---|---|---|
| គ្រប់គ្រងដោយក្រសួងបរិស្ថានគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរដ្ឋបាលព្រៃឈើ | | | | |
| តំបន់ការពារ ប្រមាណ៣ លានហិកតា | ព្រៃការពារ ប្រមាណ៣ លានហិកតា | ព្រៃឈើសហគមន៍ ប្រមាណ២ លានហិកតា | ព្រៃសម្បទាន ប្រមាណ០,២ លានហិកតា | ព្រៃផ្តល់ផល ប្រមាណ ២,៦ លានហិកតា |
| ការប្រើប្រាស់ ផ្សេងៗ ២០០.០០០ ហិកតា | ការប្រើប្រាស់ ផ្សេងៗ ០ហិកតា | ការប្រើប្រាស់ ផ្សេងៗ ០ហិកតា | ការប្រើប្រាស់ ផ្សេងៗ ០ ហិកតា | ការប្រើប្រាស់ ផ្សេងៗ ០ហិកតា |
| តំបន់ប្រតិបត្តិ ២.៨លានហិកតា | តំបន់ប្រតិបត្តិ ៣លានហិកតា | តំបន់ប្រតិបត្តិ ២លានហិកតា | តំបន់ប្រតិបត្តិ ០.៣លានហិកតា | តំបន់ប្រតិបត្តិ ២.៥លានហិកតា |

### ៦.១២.១ តួលេខថវិកា

តួលេខសម្រាប់ធ្វើការគណនាគឺបានមកពីការធ្វើសម្ភាសន៍ជាមួយមន្ត្រីរដ្ឋបាលព្រៃឈើ។ លទ្ធផលនៃសម្ភាសន៍នេះគឺទទួល បានពីការរៀបចំ និងការបំពេញបញ្ជីសំណួរដោយរដ្ឋបាលព្រៃឈើ និងក្រុមពិនិត្យវាយតម្លៃព្រៃឈើឯករាជ្យ( ឆ្នាំ ២០០៤)។

*ប្រាក់ចំណូលពីសេវាកម្មសំខាន់ៗ និងប្រាក់ចំណូលផ្សេងៗទៀត ដែលមិនទាន់បានប៉ាន់ស្មាន*

- តម្លៃអនុផលព្រៃឈើ (រួមមាន អុស និងធ្យូង រុក្ខជាតិជាឱសថ សត្វព្រៃ)
- តម្លៃប្រសិទ្ធភាពនៃការបង្កើតការងារ ពីការធ្វើអាជីវកម្មឈើហ៊ុប នឹងការកែច្នៃ
- បង្កើនតម្លៃបន្ថែមតាមរយៈបង្កើនការកែច្នៃឈើបន្ថែមទៀត
- តម្លៃប្រសិទ្ធភាពព្រៃឈើដែលធ្វើឱ្យមានស្ថិរភាពជាវិជ្ជមាន ដូចជា ការការពារភាពរាំងស្ងួត និងទឹកជំនន់សម្រាប់វិស័យកសិកម្ម និងវិស័យផ្សេងៗទៀត
- ការបង់ថ្លៃសេវាកម្មព្រៃឈើសម្រាប់កិច្ចការពារបរិស្ថាន (Payment for Ecosystem Service)
- តម្លៃអេកូ-ទេសចរណ៍

ហេតុដូច្នេះហើយ សម្រាប់ការគិតគូរចំពោះតែ ឈើអារ នឹងឥណទានកាបូនទាំងនេះ គ្រាន់តែជាតម្លៃមួយផ្នែកដែលមានតម្លៃប្រមាណតិចជាងពាក់កណ្ដាលនៃតម្លៃព្រៃឈើសរុប។

## ៦.១៣ សង្ខេបនិងតម្រូវការហិរញ្ញវត្ថុ

តារាង ១០ ៖ សង្ខេបនិងតម្រូវការហិរញ្ញវត្ថុ

| ប្រភពចំណូល | ដុល្លារ | ការចំណាយតាមកម្មវិធី | ដុល្លារ |
|---|---|---|---|
| ហិរញ្ញប្បទានពរាជរដ្ឋាភិបាល | ១៥លាន | ១.កម្មវិធីកំណត់ព្រំប្រទល់ (ការងារចុះបញ្ជី និងចាត់ថ្នាក់) | ៩លាន |
| ការគ្រោងវិភាជន៍ចំណូលពីព្រៃឈើជាតិ | ១,៧លាន | ២.កម្មវិធីអភិរក្ស និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងជីវចម្រុះ (៥ឆ្នាំ) | ១០ លាន |
| វិស័យឯកជន | ១លាន | ៣.កម្មវិធីពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ចល្អ(៥ឆ្នាំ) | ២លាន |

| | | | |
|---|---|---|---|
| អ្នកផ្តល់ជំនួយសម្រាប់អនុវត្តកម្មវិធី ព្រៃឈើជាតិសម្រាប់រយៈពេល ៤ឆ្នាំ | ២៧,១ លាន | ៤. កម្មវិធីសហគមន៍ព្រៃឈើ (៥-៨ឆ្នាំ) | ៩លាន |
| មូលនិធិផ្សេងៗទៀត | ២លាន | ៥.កម្មវិធីកសាងសមត្ថភាពនិងការស្រាវជ្រាវ (៥ឆ្នាំ) | ១៣លាន |
| | | ៦.កម្មវិធីហិរញ្ញប្បទាននិងបញ្ជីគណនេយ្យ (៥ឆ្នាំ) | ០,១លាន |
| | | ៧.ការងារគ្រប់គ្រងទំនាស់ (៥ឆ្នាំ) | ១លាន |
| | | ៨. កម្មវិធីប្រព័ន្ធត្រួតពិនិត្យនិងរាយការណ៍(ឆ្នាំ) | ១លាន |
| សរុបចំណាយដំបូង | ៤៦.៨ លាន | សរុបចំណាយដំបូង | ៤៦.១ លាន |

សម្គាល់៖តួលេខទាំងនេះត្រូវបានពិនិត្យពិចារណាស្តីពីតម្រូវការធនធានហិរញ្ញវត្ថុដើម្បីផ្តើមធ្វើការវិនិយោក្នុងកម្មវិធីព្រៃឈើជាតិនិងតម្រូវឱ្យមានលក្ខខណ្ឌដំបូងចំពោះសក្តានុពលចំណូល(ដែលបានធ្វើការគណនា) តាមបណ្តាអនុកម្មវិធី និងតាមការបញ្ជាក់ក្នុងសេណារីយ៉ូនៃកម្មវិធីនិរន្តរភាពហិរញ្ញប្បទានសម្រាប់វិស័យព្រៃឈើ។

ជាងនេះទៅទៀត ការអនុវត្តកម្មវិធីនីមួយៗ មានភ្ជាប់នូវតារាងចំណាយថវិកាលម្អិតនៃកម្មវិធី។

### កំណត់សម្គាល់លើការចំណាយ

*កម្មវិធីកំណត់ព្រំប្រទល់ព្រៃឈើជាតិ ការចាត់ថ្នាក់ និងការចុះបញ្ជី*

- *ការកំណត់ព្រំប្រទល់ ៖* ២.០០០ គ.ម/ឆ្នាំ ផ្អែកលើកម្រៃតម្រោងសាកល្បងដំបូងមានថ្លៃ ៥០០ ដុល្លារ/គ.ម ។ នៅពេលទទួលបានបទពិសោធន៍ និងប្រសិទ្ធិផលការងារ នោះការចំណាយនឹងថយចុះប្រមាណ ៣០% ឬ ៣៥០ ដុល្លារ/គ.ម។
- *សម្គាល់៖* ការចូលរួមការដេញថ្លៃប្រកួតប្រជែងពីភាគីខាងក្រៅដើម្បីអនុវត្តការងារកំណត់ព្រំប្រទល់ និងការចាត់ថ្នាក់ វាជាជម្រើសនៃការកាត់បន្ថយចំណាយ។
- *ការធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីព្រៃឈើ ៖* ផ្ទៃដីព្រៃឈើជាង ៨ លានហិកតាមិនទាន់ធ្វើចំណាត់ថ្នាក់។ តម្លៃ ប៉ាន់ស្មានគឺ ១ដុល្លាហិកតា។ ការងារចំណាត់ថ្នាក់ព្រៃឈើ ភូគ៌តធ្វើតាមសភាពព្រៃឈើជាក់ស្តែងតាមតម្រូវការចាំបាច់ និងឱ្យស្របតាមដំណើរការប្រតិបត្តិផ្សេងទៀត។

សមត្ថភាព និងប្រព័ន្ធដោះស្រាយជម្លោះមិនទាន់បានអភិវឌ្ឍ ដូច្នេះមិនទាន់គណនា។ ប៉ុន្តែទឹកប្រាក់ចំនួន ១ លានដុល្លារ បានប៉ាន់ស្មានថា ជាតម្រូវការចាំបាច់ និងគ្រប់គ្រាន់សម្រាប់ការកសាងចំណេះដឹងគ្រប់គ្រងជម្លោះ និងសមត្ថភាពចូលរួមជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗ។

## កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច

នេះជាការចាំបាច់នៃការងារអភិវឌ្ឍសមត្ថភាពង្គភាពបង្កើតប្រព័ន្ធត្រួតពិនិត្យ និងអភិវឌ្ឍន៍កម្មវិធីពង្រឹងការអនុវត្តច្បាប់នឹង អភិបាលកិច្ច។ បង្កើតក្រុមការងារចម្រុះនៃកម្មវិធីហិរញ្ញប្រទានព្រៃឈើដែលជួយជំរុញឱ្យមានការវិនិយោគសម្រាប់រយៈពេល ៥. ឆ្នាំដំបូង ដែលនឹងចំណាយប្រមាណ ១ លានដុល្លារ។ ដំណាក់កាលបន្ទាប់ ដែលជាដំណាក់កាលពង្រីកសកម្មភាពការងារនឹង ត្រូវត្រៀមវិនិយោគប្រមាណ ១ លានដុល្លារបន្ថែមទៀត។

## កម្មវិធីសហគមន៍ព្រៃឈើ

រហូតដល់ពេលបច្ចុប្បន្ន មានផ្ទៃដីព្រៃប្រមាណជាង ៣៥០.០០០ ហិកតា ត្រូវបានផ្តល់សិទ្ធិគ្រប់គ្រងជូនសហគមន៍ ចំនួន ៣២៥. ដោយបានចំណាយប្រមាណជាង ៩៧៥០០០ ដុល្លារ ឬ ២,៨ ដុល្លារ។ ប៉ុន្តែតាមការបញ្ជាក់ដោយមន្ត្រីកម្មវិធី សហគមន៍ព្រៃឈើជាតិ ចំណាយពេញលេញ និងជាក់ស្តែងប្រមាណ ២០ដុល្លារហិកតា។ ការត្រៀមដីព្រៃឈើប្រមាណ ១៦៥០០០០ ហិកតា ទៀតជូនសហគមន៍ប្រមាណ ៦៧៥ រំពឹងថានឹងត្រូវអនុវត្តបានក្នុងរយៈពេល ៨ ឆ្នាំ ខាងមុខ។ ការផ្តល់ អនុសាសន៍សម្រាប់វិនិយោគក្នុងការងារនេះ ប្រមាណពី ៤,៨ ទៅ ៥ លានដុល្លារ គឺជាកម្មវត្ថុនៃការទទួលបានពីអ្នកផ្តល់ជំនួយ។

នៅពេលដែលសហគមន៍ព្រៃឈើបានប្រតិបត្តិការងារ មានន័យថាបានប្រគល់សិទ្ធិគ្រប់គ្រងពេញលេញ និងបានសម្រេចលើផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ សហគមន៍ព្រៃឈើអាច

អភិវឌ្ឍធនធានព្រៃឈើលើសពីសេចក្ដីត្រូវការប្រចាំថ្ងៃហើយនោះជាជាកម្មវត្ថុបង់សួយសារ ឬពន្ធជូនរដ្ឋដូចសហគ្រាសឯកជនដទៃទៀតដែរ។ ទោះជាយ៉ាងក៏ដោយ សមិទ្ធផលសហគមន៍ព្រៃឈើជានិច្ចជាកាល ត្រូវធ្វើការប្រៀបធៀបទៅនឹងជម្រើសថ្មីៗទៀតនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ ទោះបីទទួលបានសួយសារពីការធ្វើអាជីវកម្មព្រៃឈើយ៉ាងណាក៏ដោយ ក៏ត្រូវគិតថា សហគមន៍ព្រៃឈើបានផ្ដល់វិភាគទានបើការចំណាយក្នុងការងារ ប្រតិបត្តិចំពោះកម្មវិធីព្រៃឈើជាតិ ។

ជាការចាំបាច់ដែលត្រូវអភិវឌ្ឍប្រព័ន្ធផែនការគ្រប់គ្រងសហគមន៍ព្រៃឈើដោយសាមញ្ញ។ ទោះបីធ្វើបានដូច្នេះក្ដី និងដែន ការគ្រប់គ្រងព្រៃសហគមន៍អាចរៀបចំបានប្រកបប្រសិទ្ធភាពក៏ដោយ ក៏ត្រូវរំពឹងថា សហគមន៍នឹងមានធន្ទះចំណាយសម្រាប់ការ អភិវឌ្ឍផែនការគ្រប់គ្រងព្រៃឈើ។ ការប៉ាន់ស្មានចំណាយចំពោះការងារនេះ មានប្រមាណ ៥ លានដុល្លារ ក្នុងរយៈពេល ៥-៨ឆ្នាំ។

**កម្មវិធីការកសាងសមត្ថភាព និង អភិវឌ្ឍន៍ការងារស្រាវជ្រាវ**

យោងតាមការវិភាគក្របខណ្ឌយុទ្ធសាស្ត្រ និងតម្រូវការអនុវត្តកម្មវិធីព្រៃឈើជាតិ ត្រូវមានការអភិវឌ្ឍសមត្ថភាពជាចាំបាច់ (កសាងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពអង្គភាព)សម្រាប់វិស័យព្រៃឈើ។ កសាងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព អង្គភាពត្រូវគិតពីដំណើរការឱ្យមាននិរន្តរភាព ប៉ុន្តែទោះជាដូច្នេះក្ដីក៏តម្រូវ ឱ្យមានការចិត្តទុកដាក់បន្ថែមទៀតចំពោះគ្រឹះស្ថានសិក្សា អប់រំ និងចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃសមត្ថភាព និងផ្លាស់ប្ដូរឱ្យឆ្លើយតបនឹងតម្រូវការនៃដំណោះស្រាយបញ្ហា ប្រឈមនាពេលអនាគតក្នុងវិស័យព្រៃឈើ និងបរិស្ថាន។

## ៦.១៤ អនុកម្មវិធីទី១ ហិរញ្ញប្បទានផ្ដល់ដោយរដ្ឋ

### ៦.១៤.១ សេចក្ដីអធិប្បាយ

អនុកម្មវិធីនេនឹងយកចិត្តទុកដាក់លើលទ្ធភាពហិរញ្ញប្បទានរបស់រដ្ឋាភិបាលសម្រាប់កម្មវិធីព្រៃឈើជាតិ ឧទាហរណ៍៖ ការ ធ្វើវិភាគមូលនិធិឡើងវិញពីថវិកាជាតិ ចំណូលពីប្រាក់ពិន័យនិងពន្ធនាំចេញផលិតផលព្រៃឈើ។

ឆ្នាំ ២០០៨ រដ្ឋបាលព្រៃឈើមានមន្ត្រីសរុបចំនួន ១,៥៨០ នាក់ និងមានថវិកាសម្រាប់ប្រតិបត្តិការងារចំនួន : ១,៣៥លាន ដុល្លារ (ក្នុងនោះមានថវិកាគម្រោង P3 និង P4) ហើយប្រាក់ពិន័យដែលប្រមូលបានមានចំនួន ០,៥ លាន ដុល្លារ (ប្រភពចំណូលពីប្រាក់ពិន័យនឹងធ្លាក់ចុះទាបបំផុត នៅពេលអនុវត្តកម្មវិធីព្រៃឈើជាតិទទួលបានជោគជ័យ)។

### ៦.១៤.២ មធ្យោបាយសម្រាប់អនុវត្ត

- ការងារហិរញ្ញវត្ថុនេះនឹងផ្តល់នូវព័ត៌មានសម្រាប់ការងារតាមដានប្រភពចំណូល
- គណនេយ្យប្រចាំឆ្នាំត្រូវមានការកត់ត្រាលម្អិត និងផ្សព្វផ្សាយជាសាធារណៈ
- ស្ថាប័នមានសមត្ថកិច្ចនឹងសម្រេចទទួលយកលើការវិភាគមូលនិធិឡើងវិញទៅតាមកម្រិតថវិកាដែលបានកំណត់ ដើម្បីគាំទ្រ ដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិទាំងមូល។
- ជាមួយនឹងការចាំបាច់នៃការផ្តល់មូលនិធិ ធនធានមនុស្សក៏ត្រូវធ្វើការបែងចែកតាមគោលដៅសមស្រប
- ការវិភាជន៍ហិរញ្ញវត្ថុសម្រាប់កម្មវិធីព្រៃឈើជាតិត្រូវឱ្យស្របតាមទម្រង់ផែនការ P3 និង P4 នៃប្រព័ន្ធនៃថវិកាជាតិ

### ៦.១៤.៣ លទ្ធផលរំពឹងទុក

ការវិភាគថវិកាត្រូវធ្វើតាមសំណើដូចខាងក្រោម ៖

- សហហិរញ្ញប្បទានសម្រាប់ការគ្រប់គ្រងព្រៃឈើតាមគោលការណ៍និរន្តរភាពមាន ៩៣០.០០០ ដុល្លាអាមេរិក/ឆ្នាំ។ រយៈពេល ៥ ឆ្នាំ មានថវិកាសរុបចំនួន ៤,៦៥ លានដុល្លារអាមេរិក។
- ប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផល ៖ ១០០០០០ ដុល្លារអាមេរិក។ រយៈពេល ៨ ឆ្នាំ មានថវិកាចំនួន ៨០០០០០ ដុល្លារ អាមេរិក។

## ៦.១៥ អនុកម្មវិធីទី ២ ចំណូលពីវិស័យព្រៃឈើ

### ៦.១៥.១ សេចក្តីអធិប្បាយ

នៅក្នុងបណ្តាប្រទេសជាច្រើន ការគ្រប់គ្រងព្រៃឈើរដ្ឋ (សូមពិនិត្យខ្ទង់ ៥នៃតារាងទី៤) ធ្វើឡើងដោយអង្គភាពរដ្ឋ ប៉ុន្តែ មានការបែងចែកដាច់ពីគ្នារវាងអង្គភាពដែលទទួលខុសត្រូវលើការងារគ្រប់គ្រង និងអង្គភាពពង្រឹងការអនុវត្តច្បាប់។

### ៦.១៥.២ មធ្យោបាយសម្រាប់អនុវត្ត

- ថ្លៃសួយសារ និង ពន្ធផ្សេងទៀតពីការធ្វើអាជីវកម្មឈើ
- ការលក់ផលិតផលព្រៃឈើ
- ការលក់ឥណទានកាបូន
- ចំណូលពីប្រព័ន្ធគ្រប់គ្រងព្រៃឈើផ្សេងៗទៀត

### ៦.១៥.៣ លទ្ធផលរំពឹងទុក

ត្រូវបានរំពឹងទុកថាព្រៃពាក់កណ្ដាលស្រោង និងព្រៃស្រោង ៥០% មិនទាន់ធ្វើអាជីវកម្ម និងព្រៃឈ្មោះ មានប្រមាណ ៥០%។ ការប្រមូលផលឈើដោយនិរន្តរភាពប្រចាំឆ្នាំជាមធ្យមគឺ ០,៨,ម/៣ហត ក្នុងនោះផលវិបាកពីការថយចុះវិមាណឈើក៏ត្រូវគិតគូរ ផងដែរ។ ឈើក្រៅពីឈើអាចរំពឹងថានឹងប្រើប្រាស់សម្រាប់ផលិតកម្មផ្សេងទៀត ដូចជា ធ្លុង អុស ឬ បង្គោល។ល។ ការប្រមូល ផលឈើសរុប ត្រូវគេរំពឹងថាមានចំនួនទាបជាងកំណើនរបស់ព្រៃក្នុងរយៈពេល១០-២០ ឆ្នាំខាងមុខនេះ ដោយសារតែភាព រេចរឹលនៃព្រៃឈើ។

តារាង ១១ ៖ ថ្លៃសួយសារឈើទទួលបានពីតំបន់ព្រៃមិនទាន់ធ្វើអាជីវកម្ម (ចំណាត់ថ្នាក់ E នៃតារាងទី៤ )

| ការពណ៌នា | ឯកតា | តំលៃ/ឯកតា | សរុប ដុល្លា |
|---|---|---|---|
| ថ្លៃដីប្រមាណជាង ១,២៥ លានហ.ត (៥០%នៃព្រៃផ្តផល) | ០៨ មក/ឆ្នាំ/ហ.ត | ៥៦លាន | ប្រហែល ៥៦ លានឆ្នាំ |
| ចាប់ផ្តើមពីឆ្នាំទី៤ ប៉ុន្តែប្រសិទ្ធិភាពធ្វើអាជីវកម្ម | ១៣លាន | ៥៦លាន | ៧២៨ លាន |

សន្និធិកាបូនត្រូវបង្កើតឡើងនៅក្នុងតំបន់ព្រៃរេចរឹលដោយសារការធ្វើអាជីវកម្មមានកម្រិតតិចជាងបរិមាណកំណើនរបស់ព្រៃ។

តារាង ១២ ៖ ចំណូលពីឥណទានកាបូន (១ម៣ ប្រហែល ១តោនកាបូនឌីអុកស៊ីត)

| ការពណ៌នា | ឯកតា | តំលៃ/ឯកតា | សរុប ដុល្លា |
|---|---|---|---|
| ផ្ទៃដីប្រមាណជាង០.៥ លានហិកតា | ១០០តោន | ៥ដុល្លា/តោន | ២០៥លាន |
| ការពណ៌នា | | | ដុល្លា |
| ១-ថ្លៃសួយសារឈើទទួបានពីតំបន់ព្រៃមិនទាន់ធ្វើអាជីវកម្ម (ចំណាត់ថ្នាក់ E នៃតារាងទី៤) | | | ៧២៨លាន |
| ២-ចំណូលពីស្តុកកាបូន(១ម៣ ប្រហែល ១តោន កាបូនឌីអុកស៊ីត) | | | ២៥០ លាន |
| សរុបរួមរយៈ ២០ ឆ្នាំ | | | ៩៧៨លាន |

(សម្គាល់៖ តួលេខនៃការប្រមូលផល គឺមានការប្រែប្រួល)

## ៦.១៦ អនុកម្មវិធីទី ៣ ចំណូលពីវិស័យឯកជន និង សហគមន៍ពលឈើ

### ៦.១៦.១ សេចក្តីអធិប្បាយ

សហគមន៍ព្រៃឈើ (សូមពិនិត្យចំណាត់ថ្នាក់ C នៃតារាងទី៤) ត្រូវបានពិចារណាចំពោះការផ្លាស់ប្តូរជា ចម្ការព្រៃដាំ ឬការ ធ្វើសម្បទានតាមរយៈគម្រោងផ្សេងៗទៀត (ឥណទានកាបូនទេសចរណ៍ធម្មជាតិ។ល។)។ ជាទូទៅ ដីព្រៃឈើត្រូវបានប្រើប្រាស់ សម្រាប់ផលិតកម្មនៃកំណើនផល-អនុផលព្រៃឈើប្រចាំឆ្នាំ។ ប្រសិនបើកំណើនផល-អនុផលព្រៃឈើនេះមិនធ្វើអាជីវកម្មដកហូត ទេ នោះផល-អនុផលព្រៃឈើទាំងនេះនឹងត្រូវបាត់បង់ទៅវិញតាមការពុកផុយ (នេះជាចំណុចស្តុកកាបូនកើនខ្ពស់បំផុត ដូច្នេះប្រភព ប្រាក់ចំណូលក៏ត្រូវបាត់បង់។ដូចនេះត្រូវចេះពិចារណាអំពីផលប្រយោជន៍សេដ្ឋកិច្ចចំពោះការប្រើប្រាស់សក្តានុពលធនធានព្រៃឈើ នៅពេលដែលគេមិនទាន់ដាក់អភិរក្សតឹងតែងលើធនធានទាំងនេះ។

*រាជរដ្ឋាភិបាលអាចបង្កើតប្រាក់ចំណូលដែលបានមកពី*

- ព្រៃផ្តល់ផលទំហំប្រមាណជាង ១២ លាន ហ.ត និងចម្ការព្រៃដាំទំហំប្រមាណជាង ៥០០.០០០ ហ.ត (៥០% ចំណាត់ ថ្នាក់ ៤ នៃតារាងទី៤)
- សហគមន៍ព្រៃឈើ ២ លានហត (ចំណាត់ថ្នាក់ នៃតារាងទី៤)
- ព្រៃការពារ ឬព្រៃផ្តល់ផល (ឥណទានកាបូន។ល។)

មធ្យោបាយសំខាន់ៗ ដើម្បីធានាឱ្យការធ្វើអាជីវកម្មព្រៃឈើ និងថែរក្សាការពារព្រៃការពារដោយនិរន្តរភាពនិងព្រៃសហគមន៍ គឺត្រូវមានផែនការគ្រប់គ្រង វិញ្ញាបនបត្រ REDD និងសារៈសំខាន់បំផុតនោះ គឺផ្តល់សុវត្ថិភាពហិរញ្ញវត្ថុ និងការបណ្តាក់ទុនរយៈពេល វែង រួមទាំងការផ្តល់សិទ្ធិ និងសិទ្ធិអ្នកប្រើប្រាស់ផងដែរ។

## ៦.១៦.២ មធ្យោបាយសម្រាប់អនុវត្ត

- ពន្ធលើផលរបរចំពោះការដាំឈើដោយឯកជន
- ថ្លៃសួយសារ និង ពន្ធអាករ លើអាជីវកម្មឈើក្នុងសហគមន៍ព្រៃឈើ
- ថ្លៃសួយសារ និង ពន្ធអាករ លើអាជីវកម្ម
- កំរៃផ្តល់សេវាកម្មក្នុងវិស័យព្រៃឈើ

## ៦.១៦.៣ លទ្ធផលរំពឹងទុក

ត្រូវបានរំពឹងទុកថាមានតំបន់ព្រៃផ្តល់ផល(ដែលត្រូវបានបែងចែកនៅក្នុងកម្មវិធីនេះ)ដែលមានផ្ទៃដីព្រៃឈើប្រមាណ១២៥ លានហិកតា (សូមពិនិត្យ ៥០% ចំណាត់ថ្នាក់ E នៃតារាងទី៤) ក្នុងនោះរួមមានផ្ទៃដីព្រៃឈើប្រមាណ ១/៣ ជាព្រៃឈ្មោះ រេចរឹល ១/៣ ជាព្រៃពាក់កណ្តាលស្រោង និង ១/៣ ជាព្រៃស្រោង និងជាមធ្យមចម្ការឈើដាំមានប្រមាណ ១០០,០០០ ហិកតា។

- ការប្រមូលផលឈើជាមធ្យម រួមទាំងផលចម្ការព្រៃឈើដាំ អាចផ្តល់បានឈើហ៊ុបមូល ០,៥ម" ក្នុង ១ ហិកតា ក្នុង ១ ឆ្នាំ
- ក្រៅពីការធ្វើអាជីវកម្មដកហូតឈើមូល គឺត្រូវបានរំពឹងទុកថានឹងមានការកែច្នៃកាកសំណល់ឈើ ដើម្បីប្រើប្រាស់សម្រាប់ផលិតផលដូចជា ធ្យូង អុស ឬ បង្គោល។ល។

ការប្រមូលផលឈើសរុបត្រូវសន្មតថា ឱ្យទាបជាងបរិមាណកំណើនមាឌឈើសរុបក្នុងរយៈពេល១០-២០ឆ្នាំខាងមុខ។

តារាង ១៣ ៖ ចំណូលថ្លៃសួយសារពីសហគមន៍ព្រៃឈើ (សូមពិនិត្យមើលចំណាត់ថ្នាក់ C នៃតារាងទី៤)

| ការពិពណ៌នា | ឯកតា | តម្លៃ/ឯកតា | សរុប ដុល្លារ |
|---|---|---|---|
| ផ្ទៃដីប្រមាណជាង២លាន ហ.ត | ១/៤ម³/ឆ្នាំ/ហ.ត | ៥៦ | ប្រហែល២៨លាន |
| ចាប់ផ្តើមបន្តិចម្តងៗរហូតដល់ប្រសិទ្ធភាពពេញលេញ ក្នុងកំឡុងពេល ១៧ ឆ្នាំ នៃកម្មវិធីរយៈពេល ២០ឆ្នាំ | ១៧ឆ្នាំ | ២៨លាន | ៤៧៦លាន |

(សម្គាល់:ការប្រមូលផលឈើគឺតិចជាងកំណើននៃការលូតលាស់មាឌឈើពិសេសនៅសហគមន៍មានតំបន់ ព្រៃរិចរឹល)

(សម្គាល់: ថ្លៃសួយសារផលឈើពីសហគមន៍នឹងអាចចុះថ្លៃ)

តារាង ១៤ ៖ ចំណូលលក់ឥណទានកាបូនពីតំបន់ព្រៃសហគមន៍

| ការពិពណ៌នា | ឯកតា | តម្លៃ/ឯកតា | សរុប ដុល្លារ |
|---|---|---|---|
| ថ្ងៃដីប្រមាណជាង ០៥ លានហិចតា(សហគមន៍តំបន់ព្រៃរេចរឹល) | ១០០តោន/ឆ្នាំ/ ហ.ត | ៥ ដុល្លា តោន | ២៥០លាន |
| | | | |

| ការពិពណ៌នា | ដុល្លារ/ឆ្នាំ |
|---|---|
| ១-ចំណូលថ្លៃសួយសារ ពីព្រៃផ្តល់ផល<br>(សូមពិនិត្យចំណាត់ថ្នាក់ E នៃតារាងទី៤) | ៤៥៥លាន |
| ២-ចំណូលថ្លៃសួយសារ ពីសហគមន៍ព្រៃឈើ<br>លាន<br>( សូមពិនិត្យចំណាត់ថ្នាក់ C នៃតារាងទី៤ ) | ៤៧៦ |
| ៣-ចំណូលពីការលក់ឥណទានកាបូនពីព្រៃសហគមន៍ | ២៥០លាន |
| សរុបរួមរយៈពេល ២០ឆ្នាំ | ១.១៨១លាន |

(សម្គាល់: តួរលេខនៃការប្រមូលផល អាចមានការប្រែប្រួល)

## ៦.១៧ អនុកម្មវិធីទី ៤ ការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

### ៦.១៧.១ សេចក្តីអធិប្បាយ

ប្រទេសកំពុងអភិវឌ្ឍ ជាបេក្ខភាពប្រទេសអាចទទួលបានជំនួយអភិវឌ្ឍន៍ពីបរទេស។ ប្រភពធនធានធម្មជាតិគឺជាទ្រព្យសម្បត្តិ របស់ប្រទេស។ ព្រៃឈើមានតួនាទីចូលរួមចំណែកជាសកល ក្នុងការប្រយុទ្ធប្រឆាំងនឹងការបម្រែបម្រួលអាកាសធាតុ ដោយសារការស្រូបយកកាបូនពីបរិយាកាស។ ព្រៃឈើក៏បានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើនជីវភាពសហគមន៍ជនបទ ប្រសិន បើមានការគ្រប់គ្រងដោយនិរន្តរភាព។

អ្នកផ្តល់ជំនួយអាចមានតួនាទីជាដៃគូទ្វេភាគី ពហុភាគី និងអង្គការសង្គមស៊ីវិល។ ចំពោះមូលនិធិពីសប្បុរសជន និងកិច្ច សហការពីវិស័យឯកជន ក្នុងការផ្តល់ជំនួយ ក៏ត្រូវចាត់ចូលក្នុងក្រុមខាងលើនេះដែរ។

### ៦.១៧.២ មធ្យោបាយសម្រាប់អនុវត្ត

វិស័យព្រៃឈើត្រូវការចាំបាច់ការគាំពារផ្នែកហិរញ្ញវត្ថុទៅតាមតួនាទី និងកាលានុវត្តភាពនៃព្រៃឈើ ដូចនេះ ត្រូវយកចិត្ត ទុក ដាក់តម្រូវឱ្យមានគំរូបែបបទតែមួយ ឬច្រកចេញចូលតែមួយ ឧទាហរណ៍ផ្តល់គម្រោងជំនួយតាមរយៈយន្តការរាជរដ្ឋាភិបាល (IWG-F&E ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើ)ហើយជំនួយទាំងនេះក៏មិនគ្រាន់តែជាការផ្តល់អនុសាសន៍ ទទេៗនោះទេ។

### ៦.១៧.៣ លទ្ធផលរំពឹងទុក

តារាង ១៥ ៖ ការគណនាហិរញ្ញប្បទានជំនួយលើបណ្តាគម្រោងសម្រាប់រយៈពេល៥ឆ្នាំដំបូង និងរយៈពេលបន្តបន្ទាប់ទៀត

| គម្រោងដែលត្រូវផ្តល់ជំនួយ | ចំនួនឆ្នាំដែលគាំទ្រ | សរុបជាលានដុល្លា |
|---|---|---|
| ប្រព័ន្ធដោះស្រាយជម្លោះនិង សមត្ថភាព | ១-៥ | ១,០ |
| គោលការណ៍ណែនាំ SEM | ១-៥ | ១,០ |
| ធនធានព្រៃឈើ និងការអភិរក្ស | ១-៥ | ១,៥ |
| វាយតំលៃ និងវិញ្ញាបនបត្រ | ១-៥ | ៥,៥ |
| ពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ចរួមទាំងការតាម ដាន<br>និងរាយការណ៍ | ១-៥ | ០,២ |
| ការបង្កើតប្រព័ន្ធគណនីកាបូ នជាតិ | ១-៨ | ១,៥ |
| សារពើភណ្ឌព្រៃឈើជាតិ | ១-៥ | ៥ |
| ការបង្កើត និងធ្វើផែនការ គ្រប់គ្រងសហគមន៍ព្រៃឈើ | ១-៨ | ៨ |
| ការអភិវឌ្ឍផែនការគ្រប់គ្រង សហគមន៍ព្រៃឈើ | ១-៥ (៨) | ១,៥ |
| ការអភិវឌ្ឍសមត្ថភាព រួមទាំង គ្រឹះស្ថានសិក្សាអប់រំ | ១-៥ (៨) | ៤,៦ |
| ការតាមដានត្រួតពិនិត្យ និង រាយការណ៍ | ១-៥ | ៩,២ |
| ប្រពន្ធ័គណនេយ្យ និងចុះបញ្ជី គណនី | ១-៥ | ១,០ |
| ប្រពន្ធ័គណនេយ្យ និងចុះបញ្ជី គណនី | ១-៥ | ០,១ |
| | | ៤០,១ |

## ៦.១៨ អនុកម្មវិធីទី ៥: ប្រភពហិរញ្ញប្បទានថ្មីៗនៃសេវាកម្មបរិស្ថាន ព្រៃឈើ និងផលលាភការបូន

### ៦.១៨.១ សេចក្ដីអធិប្បាយ

ធនធានព្រៃឈើផ្ដល់សក្ដានុពលប្រាក់ចំណូលតាមបែបប្រពៃណីតិចតួច។ ព្រៃឈើជាមូលដ្ឋាននៃការបង្កើតទេសចរណ៍ ធម្មជាតិ ដែលជាឧស្សាហកម្មមួយកំពុងរីកលូតលាស់លើពិភពលោក។ ក្រៅពីនេះ ព្រៃឈើក៏ផ្ដល់នូវកិច្ចការពារបរិស្ថានដូចជា ការពារ ការហូរច្រោះ ផ្ដល់ទឹកស្អាត។ល។ ដែលជាការងារចាំបាច់និងចំបងសម្រាប់សុខមាលភាព និងការរីកចំរើនរបស់ប្រជាជន។ ជាង នេះទៅទៀត កិច្ចការពារខ្លះក្នុងចំណោមកិច្ចការពារខាងលើអាចនឹងមានទីផ្សារនៅពេលអនាគត។

មានទីផ្សារដំណើរការល្អសម្រាប់អនុផលព្រៃឈើ។ ពិសេសក្នុងសហគមន៍ព្រៃឈើ ការកែច្នៃអនុផលព្រៃឈើ និងរុក្ខជាតិឱសថ អាចបន្ថែមតំលៃសម្រាប់ផលិតផលព្រៃឈើ។ ដំណើរការលក់នឹងអាចជាកម្មវត្ថុសម្រាប់កំណត់ពន្ធអាករនៅដំណាក់កាលបន្ទាប់។

### ៦.១៨.២ មធ្យោបាយសម្រាប់អនុវត្ត

- ការបង់កំរៃសម្រាប់សេវាបរិស្ថាន
- ការផ្ដល់សម្បទានតាមការងារអភិរក្ស
- ការបង់ថ្លៃពីការចូលកំសាន្តតំបន់ព្រៃការពារ
- ការចេញអាជ្ញាប័ណ្ណផ្ដល់សិទ្ធិប្រមូលផល-អនុផលព្រៃឈើ
- ការលក់កាបូនតាមរយៈការបញ្ចៀសការបាត់បង់ និងចរឹលព្រៃឈើ (REDD)
- ការលក់សន្និធិកាបូនដោយផ្អែកលើការកាត់បន្ថយផលប៉ះពាល់ពីការធ្វើអាជីវកម្មព្រៃឈើ
- ការលក់សន្និធិស្រូបយកកាបូននៅតំបន់ព្រៃល្បែរេចរឹល
- ការលក់សិទ្ធិប្រមាញ់។

### ៦.១៨.៣ លទ្ធផលរំពឹងទុក

- ***ការបង់កម្រៃសម្រាប់សេវាបរិស្ថាន៖*** ទោះជាការងារកំណត់យកកំរៃសេវាមិនទាន់បានអនុវត្ត ប៉ុន្តែការព្យាយាមខិតខំរៀបចំ បទដ្ឋានកំរសម្រាប់សេវាបរិស្ថានបាន និងកំពុងដំណើរការទៅមុ

ខ។ ក្រៅពីសន្និធិកាបូន ទីជម្រកសត្វព្រៃដ៏វិសេស និងប្រភព ទឹកស្អាត អាចជាប្រភពសេវាចំណូលនៅក្នុងគម្រោងនេះ (មិនទាន់បានគណនា)

- ***ការបង់ថ្លៃពីការចូលកំសាន្ត៖***ជាតំបន់ងាយស្រួលក្នុងការបង្កើត និងប្រមូលចំណូលពីការចូលកំសាន្ត ប៉ុន្តែតម្រូវឱ្យមាន ហេដ្ឋារចនាសម្ព័ន្ធអប្បបរមាមួយ ដូចជា អាហារ កន្លែងស្នាក់ ផ្លូវលំផែនទី និងសំភារៈព័ត៌មាន (មិនទាន់បានគណនា)
- ***ការប្រមូលអនុផលព្រៃឈើ៖*** ការផ្តល់សិទ្ធិក្នុងការប្រមូលអនុផលព្រៃឈើ អាចដាក់លក់ដោយដេញថ្លៃបាន (ប៉ុន្តែមិនទាន់ បានគណនា)។ កិច្ចការនេះមិនទាមទារឱ្យមានទុនវិយោគ ហើយក៏ងាយស្រួលក្នុងការអនុវត្ត
- ***កម្មវិធី REDD៖*** ការគណនាកាបូនពីកម្មវិធីនេះទាក់ទងនឹងជីវម៉ាស់នៅខាងលើនិងក្រោមដី (ឈើងាប់ សម្រាម ស្លឹកឈើ និង សរីរាង្គក្នុងដី)។ បរិមាណមាឌឈើឈរនៅក្នុងព្រៃស្រោង, ដែលមិនទាន់ធ្វើអាជីវកម្ម ត្រូវបានគណនាថា មានផលឈើ ប្រមាណ ២៤៣ ម៣/ហ.ត (តួលេខនេះគណនាតែពីមាឌឈើពាណិជ្ជកម្មប៉ុណ្ណោះ) ម្យ៉ាងវិញទៀត ព្រៃស្រោងនោះបានទទួល អរការខូចខាតជាបន្តបន្ទាប់។ ត្រូវបានរំពឹងទុកថាថ្ងៃព្រៃការពារ ( គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ) នឹងកើនដល់ ៣ លានហិកតា (សូមពិនិត្យចំណាត់ថ្នាក់ B តារាងទី ៤) ដែលភាគច្រើនជាព្រៃស្រោងពាក់កណ្តាលស្រោងមិនទាន់រងការធ្វើអាជីវកម្ម។ ក្នុងករណី ព្រៃការពារទាំងអស់មិនទទួលការធ្វើអាជីវកម្មរយៈពេល ២០ ឆ្នាំ ខាងមុខនោះ ព្រៃទាំងនោះនឹងវិវត្តន៍ទៅជាព្រៃពេញសក្តានុពល នៃព្រៃបៃតងជានិច្ច ដែលមានមានឧឈើឈរប្រមាណ ២៤០ ម៣/ហត។ គម្រោងការវាយតម្លៃព្រៃឈើចំពោះការងារវេណទាន កាបូនត្រូវការរយៈពេលពី២ទៅ៣ឆ្នាំ ដើម្បីឱ្យដឹងថាពុំមានការបំផ្លិចបំផ្លាញព្រៃឈើ ហើយត្រូវទទួលស្គាល់ជាលក្ខណៈ អន្តរជាតិ និងសម្រាប់ទីផ្សារកាបូន។ តម្លៃលក់កាបូនគឺគិតតាមកាបូនស្តុក/តោន ដែលតម្លៃលក់កាបូនក្នុងមួយតោន, រួមមាន ទាំងតម្លៃចំណាយសម្រាប់រៀបចំ និងអភិវឌ្ឍផ្សេងៗទៀត
- ***កីឡាប្រមាញ់៖*** ការងារនេះបានអនុវត្តនៅប្រទេសជាច្រើនក្នុងពិភពលោក ជាពិសេស ការប្រមាញ់នៅក្រោមការត្រួតពិនិត្យ យ៉ាងតឹងរ៉ឹង ហើយអាចប្រមូលចំណូលបានច្រើន ហើយមានផលប៉ះពាល់តិចតួច ប្រសិនបើយើងអនុវត្តការផ្តល់សិទ្ធិប្រមាញ់ នេះបានត្រឹមត្រូវ។ ប៉ុន្តែ កីឡាប្រមាញ់នេះប៉ះពាល់ដល់បញ្ហាបុណ្យបាបរបស់សាសនា (ចំណូលពីការងារនេះមិនទាន់បានគណនា)។ កីឡាប្រមាញ់នេះ ត្រូវការទុនវិនិយោគទាប។

## សេណារីយ៉ូសម្មតិកម្មចំនួនពីរ

ជម្រើសសេណារីយ៉ូ ត្រូវបានបង្ហាញនូវចំណុចពិសេសពីរ។ សេណារីយ៉ូទាំងនេះគឺជាការប៉ាន់ស្មានលើកដំបូងដោយផ្អែកទៅ លើរបៀបគ្រប់គ្រងវិស័យព្រៃឈើ ដែលមានវិធីសាស្រ្តក្នុងការប្រមូលផលឈើដោយនិរន្តរភាព និងតាមគោលការណ៍អភិបាលកិច្ច ដូចមានចែងនៅក្នុងកម្មវិធីព្រៃឈើជាតិ។ តួលេខចំណូលពីកម្មវិធី REDD គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។

**១. ការលក់កាបូនសុទ្ធ ដោយមិនមានធ្វើអាជីវកម្មឈើបែបប្រពៃណី (REDD)**

តំបន់ព្រៃឈើស្ថិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ រួមទាំងព្រៃឈើសហគមន៍ គឺមានផ្ទៃដីព្រៃឈើប្រមាណ ៧៩ លានហិកតា (តារាងទី៤)។ ទោះបីពុំមានគម្រោងស្តារព្រៃឈើឡើងវិញក្តី ក៏ព្រៃឈើទាំងនេះ អាចមានលទ្ធភាពប្រមាណ ៥ លានហិកតា សម្រាប់អនុវត្តឥណទានកាបូនដែលអាចផ្តល់ចំណូលបានចំនួន ២.៥០០ លានដុល្លារ សម្រាប់ រយៈពេល៦០ឆ្នាំ ឬ ៤២ លានដុល្លារ /ឆ្នាំ (៥ លានហិកតា X ១០០ តោន X ៥ ដុល្លារ = ២.៥០០ សម្រាប់រយៈពេល ៦០ ឆ្នាំ)។ ការងារនេះតម្រូវអោយមានការវិនិយោគមួយចំនួនលើការងារដាំឈើ និងដំណុះឈើធម្មជាតិ។

**២. ការគ្រប់គ្រងពផ្តល់ផលឈើដោយនិរន្តរភាព (SFM)**

ព្រៃផ្តល់ផលនិងព្រៃឈើសហគមន៍មានទំហំប្រមាណ ៤,៥លានហិចតា។ តាមការប៉ាន់ស្មានប្រមាណ ២,២៥ លានហិចតា (៥០%) ត្រូវបានចាត់ជាព្រៃឈើរេចរឹល ដែលមានផលិតភាពតិចតួចសម្រាប់រយៈពេល ២០ ឆ្នាំដំបូង ដោយ មានលទ្ធភាពដកហូតឈើប្រចាំឆ្នាំប្រមាណ ០៥ម៣ហិចតា និងមានតំលៃសួយសារមធ្យម ៥៤ ដុល្លារ /ម៣ (រដ្ឋធ្វើ អាជីវកម្មព្រៃគុបតាមលក្ខណប្រពៃណី) ដូច្នេះចំណូលសរុបគឺចំនួន ៦០,៧៥ លានដុល្លារ/ឆ្នាំ។ ចំពោះផ្ទៃដីព្រៃប្រមាណ ២២៥ លានហិចតាទៀតដែលជាព្រៃមិន

ទាន់ធ្វើអាជីវកម្មអាចមានលទ្ធភាពដកហូតឈើប្រចាំឆ្នាំបានប្រមាណ ១,១ មក,ហិចតា និងមានតំលៃសួយសារជាមធ្យម ៥៤ ដុល្លារ/ម៣ ដូច្នេះចំណូលសរុបគឺ ១៣៣,៦៥ លានដុល្លារ/ឆ្នាំ ។ ការងារ នេះតម្រូវអោយមានការវិនិយោគមួយចំនួនលើការងារដាំឈើ និងដំណុះឈើធម្មជាតិ។

# ជំពូក៤

# ប្រវត្តិនៃការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តព្រៃឈើផ្សេងៗ

# មេរៀនទី៩ ប្រវត្តិនៃការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តព្រៃឈើផ្សេងៗ

ប្រទេសកម្ពុជាមានច្បាប់ផ្សេងៗទាក់ទងនឹងការគ្រប់គ្រងព្រៃឈើនិងធនធានធម្មជាតិដូចមានរៀបរាប់ខាងក្រោម៖

- **ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិក្នុងឆ្នាំ ១៩៩៣** (ODC, ១៩៩៣)ព្រះរាជក្រឹត្យនេះត្រូវបានឡាយព្រះហស្តលេខាជាផ្លូវការនៅថ្ងៃទី ១ ខែវិច្ឆិកាឆ្នាំ ១៩៩៣ ដោយអតីតព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តមសីហនុ។ យោងតាមក្រឹត្យនេះតំបន់ការពារធម្មជាតិចំនួន ២៣ ត្រូវបានបង្កើតឡើងនិងចែកចេញជា ៤ តំបន់៖ ឧទ្យានជាតិ ជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង។
- **ច្បាប់ស្តីពីការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិក្នុងឆ្នាំ ១៩៩៦ ( RGC ; ១៩៩៦)៖** ច្បាប់នេះត្រូវបានចេញផ្សាយនៅថ្ងៃទី ១៨ ខែវិច្ឆិកាឆ្នាំ ១៩៩៦ ដែលមានគោលបំណងដូចតទៅ៖ (១) ដើម្បីការពារនិងលើកកំពស់គុណភាពបរិស្ថាននិងសុខភាពសាធារណៈដោយមធ្យោបាយការពារ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថាន (២) ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានមុនពេលចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើគម្រោងដែលបានស្នើទាំងអស់ (៣) ដើម្បីធានានូវការគ្រប់គ្រងដោយនិរន្តរភាពទាំងការបម្រុងទុក ការអភិវឌ្ឍ ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា (៤) ដើម្បីលើកទឹកចិត្តនិងផ្តល់លទ្ធភាពដល់សាធារណៈជនឱ្យចូលរួមក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (៥) ដើម្បីបង្ក្រាបសកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់បរិស្ថាន។ យោងតាមច្បាប់នេះធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាពិសេសព្រៃឈើ អនុផលព្រៃឈើ និងសត្វព្រៃត្រូវបានអភិរក្សអភិវឌ្ឍ និងគ្រប់គ្រងដើម្បីប្រើប្រាស់ប្រកបដោយហេតុផលនិងប្រកបដោយនិរន្តរភាព។
- **ច្បាប់ព្រៃឈើឆ្នាំ ២០០២** (RGC,២០០២)៖ ច្បាប់នេះកំណត់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងការប្រមូលផលការប្រើប្រាស់ ការអភិវឌ្ឍន៍ និងអភិរក្សព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺដើម្បីធានាការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីផលប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថានរួមទាំងការអភិរក្សភាព ចម្រុះជីវសាស្ត្រនិងបេតិកភណ្ឌវប្បធម៌។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះព្រៃឈើទាំងអស់មិនថាធម្មជាតិឬកាដាំដុះ។ ការគ្រប់គ្រងព្រៃឈើស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។

ច្បាប់នេះត្រូវបានអនុវត្តដើម្បីធានាការចូលរួមជាសាធារណៈនៅក្នុងសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលដែលមានសក្តានុពលសម្រាប់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋទូទៅដែលមានការព្រួយបារម្ភជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាននិងធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា។ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវធ្វើតាមរបៀបដែលស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ។

- **ច្បាប់ជលផលក្នុងឆ្នាំ ២០០៦៖** ច្បាប់នេះមានគោលបំណងដើម្បីធានាការគ្រប់គ្រងជលផល និងធនធានជលផលលើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្មការគ្រប់គ្រងផលិតកម្មនិងការកែច្នៃ និងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍មូលដ្ឋានសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងបរិស្ថានរួមទាំងនិរន្តរភាពនៃការអភិរក្សជីវចម្រុះ និងបេតិកភណ្ឌវប្បធម៌ធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តំបន់នោះត្រូវបានគេកត់សម្គាល់ថាតំបន់ការពារដែលលិចទឹកគឺជាដីដែលលិចទឹកនៅក្នុងឡូត៍នេសាទ និងតំបន់ព្រៃលិចទឹកនិងព្រៃកោងកាងដែលត្រូវការពារសម្រាប់ការដាំឬអភិរក្សសម្រាប់ការដាំដើមឈើឡើងវិញដើម្បីធ្វើឱ្យមានតុល្យភាពប្រព័ន្ធអេកូនេសាទ។ សកម្មភាពខាងក្រោមត្រូវបានហាមឃាត់ (i) ការពង្រីកដីកសិកម្មឬប្រើប្រាស់ដីដែលត្រូវបានការពារដោយការផ្តល់ច្បាប់នេះសម្រាប់គោលបំណងផ្សេងទៀតក្រៅពីការអភិវឌ្ឍជលផលនៅក្នុងតំបន់លិចទឹក (ii) ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងតំបន់លិចទឹកដែលបានការពារ។ (iii) កាប់រានយកដីជីកដីឈូសឆាយដុតឬកាន់កាប់ព្រៃលិចទឹកនិងដើមកោងកាង (iv) ការបំផ្លាញការកាប់បំផ្លាញព្រៃលិចទឹកនិងព្រៃកោងកាងឬចាក់ឬសដើម្បីប្រមូលដើមព្រៃលិចទឹកនិងកោងកាង (v) ការប្រមូលពាណិជ្ជកម្ម ការដឹកជញ្ជូននិងការស្តុកទុកអុសអុសឬធ្យូងនៃប្រភេទព្រៃលិចទឹកនិងព្រៃកោងកាង (vi) សាងសង់ឡ កន្លែងសិប្បកម្ម កន្លែងកែច្នៃ និងរុក្ខជាតិគ្រប់ប្រភេទដោយប្រើប្រាស់វត្ថុធាតុដើមឈើនៃព្រៃលិចទឹកនិងព្រៃកោងកាង។
- **ច្បាប់ស្តីពីការការពារធម្មជាតិឆ្នាំ ២០០៨ (RGC, ២០០៨)៖** ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រងការអភិរក្សនិងការអភិវឌ្ឍតំបន់ការពារ។ គោលបំណងនៃច្បាប់នេះគឺដើម្បីធានាការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ការពារ។ ការគ្រប់គ្រងតំបន់ការពារធម្មជាតិដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានមាន" រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ" (NPCA) ជាលេខាធិការដ្ឋានរបស់ខ្លួនដើម្បីគ្រប់គ្រងតំបន់ការពារស្របតាម

គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការរៀបចំនិងការប្រព្រឹត្តទៅនៃរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់អភិរក្សនីមួយៗត្រូវកំណត់ដោយ (ប្រកាស) របស់ក្រសួងបរិស្ថាន។ ការគ្រប់គ្រងតំបន់ការពារត្រូវជានាសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិដើមភាគតិចនិងសាធារណៈជនឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងអភិរក្សជីវចម្រុះប្រកបដោយនិរន្តរភាព។

- **អនុក្រឹត្យលេខ ៨៣ ស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឆ្នាំ ២០០៩ (FAO, ២០០៩)៖** គោលបំណងនៃអនុក្រឹត្យនេះគឺកំណត់គោលការណ៍នីតិវិធីនិងយន្តការសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាប័ណ្ណសម្ជហភាព។ អនុក្រឹត្យនេះមានគោលបំណងផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិចនូវសិទ្ធិស្របច្បាប់លើសិទ្ធិកាន់កាប់ដីធ្លីជានាសន្តិសុខដល់សិទ្ធិកាន់កាប់ដីធ្លីនិងការពារកម្មសិទ្ធិសម្ជហភាពតាមរយៈការថែរក្សាអត្តសញ្ញាណវប្បធម៌ទំនៀមទម្លាប់និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច៖ អនុក្រឹត្យនេះ មានវិសាលភាពនៃការដាក់ពាក្យស្នើសុំសម្រាប់សហគមន៍ជនជាតិដើមដែលត្រូវបានបង្កើតឡើងជានីតិបុគ្គលនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍ទូទៅដែលត្រូវអនុវត្តចំពោះការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមានដូចខាងក្រោម៖ ការចុះឈ្មោះដីសហគមន៍ជនជាតិដើមភាគតិចគឺជាការចុះបញ្ជីដីទាំងអស់របស់សហគមន៍ដែលជាប័ណ្ណសម្ជហភាពនៅលើផែនទីសុរិយោដីតែមួយ។ វិញ្ញាបនបត្រប័ណ្ណសម្ជហភាពដែលនឹងត្រូវចេញឱ្យសហគមន៍គួរតែបញ្ជាក់ឈ្មោះនិងទីតាំងរបស់សហគមន៍លេខយោងចំពោះផែនទីសុរិយោដីតែមួយដែលចង្អុលបង្ហាញអំពីទីតាំងទំហំព្រំប្រទល់ការសម្របសម្រួលនៃដីឡូត៍ដែលជាកម្មសិទ្ធិរួម និងវិញ្ញាបនប័ត្រនៃប្រភេទ ការប្រើប្រាស់ដីនិងកំណត់ចំណាំផ្សេងៗ។ សហគមន៍ដែលបង្កើតឡើងជានីតិបុគ្គលដែលមានលក្ខន្តិកៈនិងការទទួលស្គាល់ជាផ្លូវការអាចដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាប័ណ្ណសម្ជហភាព។ សហគមន៍ត្រូវបានបង្កើតឡើងជានីតិបុគ្គលដែលមានវិធានផ្ទៃក្នុងចែងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ដីឡូត៍ក៏ដូចជាកំណត់លក្ខខណ្ឌមួយចំនួនដូចជាការគ្រប់គ្រងដីធ្លីសម្ជហភាពនិងការប្រើប្រាស់ដីធ្លីយោងតាមប្រភេទដីនិងការផ្សះផ្សានៅកម្រិតសហគមន៍ក្នុងករណីមានជម្លោះទាក់ទងនឹងការប្រើប្រាស់ដីធ្លីតាមបែបប្រពៃណី។
- **យុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**(RGD ,២០១៤b )៖ យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារសមធម៌និងប្រសិទ្ធភាពដែលជារឿយៗត្រូវ

បានគេពិពណ៌នាថាជាយុទ្ធសាស្ត្រចតុកោណដែលបង្ហាញពីការប្តេជ្ញាចិត្តខាងនយោបាយចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាពរបស់ប្រទេស និងការគ្រប់គ្រងប្រកបដោយចីរភាព។ នៃធនធានធម្មជាតិត្រូវបានចុះបញ្ជីជាផ្នែកមួយនៃចតុកោណបួន។ យុទ្ធសាស្ត្របច្ចុប្បន្នគឺដំណាក់កាលទី ៣ គ្របដណ្តប់ឆ្នាំ ២០១៣- ២០១៨ ចតុកោណកែងគឺ" ការលើកកម្ពស់វិស័យកសិកម្ម" និងផ្នែកមួយនៃបួនជ្រុងនៃចតុកោណគឺ" ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព" ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៤-២០១៨ គឺជាផែនការអភិវឌ្ឍជាតិរបស់កម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅដំណាក់កាលទី ៣ គ្របដណ្តប់រយៈពេល ៤ ឆ្នាំចន្លោះឆ្នាំ ២០១៤ និង ២០១៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដំណាក់កាលទី ៣ អនុវត្តរបៀបវារៈដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌និងប្រសិទ្ធភាពដំណាក់កាលទី ៣ ។

- **ផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពបរិស្ថាននិងក្រមបរិស្ថាន** (RGC ឆ្នាំ ២០១៥)៖ យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីបរិស្ថាន (NESAP) មានរយៈពេលចន្លោះពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២៣ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនិងការការពារបរិស្ថាន។ យុទ្ធសាស្ត្រនេះនិងណែនាំក្រសួងរដ្ឋាភិបាលវិស័យឯកជនសង្គមស៊ីវិលនិងអង្គការអភិវឌ្ឍន៍ដើម្បីបញ្ជ្រាបការពិចារណាបរិស្ថានទៅក្នុងគោលនយោបាយផែនការនិងការវិនិយោគ។ យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីបរិស្ថាន បានអនុម័តនាពេលថ្មីៗនេះ និងនៅក្នុងដំណើរការនៃការអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ក្រមបរិស្ថានផ្តោតសំខាន់លើការបង្កើតក្របខ័ណ្ឌច្បាប់កាន់តែរឹងមាំសម្រាប់គោលនយោបាយបរិស្ថាននិងយុទ្ធសាស្ត្រ។ សេចក្តីព្រាងក្រមត្រូវបានបង្កើតរួចហើយហើយឥឡូវនេះកំពុងស្ថិតក្នុងដំណើរការពិនិត្យឡើងវិញ។ ក្របខ័ណ្ឌគ្រប់គ្រងប្រព័ន្ធយុទ្ធសាស្ត្រតំបន់ការពារធម្មជាតិក្របខ័ណ្ឌគ្រប់គ្រងប្រព័ន្ធយុទ្ធសាស្ត្រតំបន់អភិរក្សជាតិ (NPASMF) ត្រូវប្រកាសចេញនូវការណែនាំរយៈពេលវែងជាមធ្យោបាយដើម្បីដោះស្រាយឧបសគ្គនានាក្នុងការបង្កើតតំបន់ការពារនិងតំបន់អភិរក្សថ្មីៗ សម្ពាធនៅបច្ចុប្បន្ន និងនាពេលអនាគតដែលអាចកើតមានពីការគំរាមកំហែងផ្សេងៗលើតំបន់ការពារនិងតំបន់អភិរក្សដែលមានស្រាប់និងឧបសគ្គរាំងការគ្រប់គ្រងតំបន់ទាំងអស់នេះ។
- **ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (RGC,២០១៤ a)៖** ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCSP) ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងខែតុលាឆ្នាំ ២០១៣ ស្របតាមវដ្តនៃផែនការរបស់NSDP។ ផែនការយុទ្ធ

សាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីធានាបាននូវការរួមផ្សំជាយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការដោះស្រាយបញ្ហាជាច្រើនដែលទាក់ទងនឹងការបំរែបំរួលអាកាសធាតុ ទាក់ទងនឹងការបន្សុាំ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍកាបូនទាប។ ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា គោលបំណងរដ្ឋចំនួន ៨ គោលដៅយុទ្ធសាស្ត្រនិងគោលដៅយុទ្ធសាស្ត្រទី ៣ គឺ “ ជានាភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាបមេគង្គប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រតំបន់ខ្ពង់រាប ជីវចម្រុះតំបន់ការពារធម្មជាតិនិងបេតិកភណ្ឌវប្បធម៌” យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំង ៤ ដើម្បីសំរេចគោលបំណងនេះគឺ៉ ជំរុញការបង់ប្រាក់សម្រាប់សេវាកម្មអេកូឡូស៊ីរួមមានREDD+ ត្រូវបានគេទទួលស្គាល់ថាជាឧបករណ៍មួយដែលសមស្របសម្រាប់ដោះស្រាយបញ្ហាអាកាសធាតុ។

- **កម្មវិធីព្រៃឈើជាតិឆ្នាំ ២០១០-២០២៩៖** កម្មវិធីស្បៀងអាហារជាតិគឺជាផែនការមួយសម្រាប់វិស័យព្រៃឈើដែលគ្របដណ្តប់ចន្លោះឆ្នាំ ២០១០ និង ២០២៩ និងត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីក្នុងខែតុលាឆ្នាំ ២០១០។ ការអភិរក្សនិងការអភិវឌ្ឍធនធានព្រៃឈើនិងជីវចម្រុះ ការអនុវត្តច្បាប់និងអភិបាលកិច្ចព្រៃឈើ សហគមន៍ព្រៃឈើ ការអភិវឌ្ឍសមត្ថភាពនិងការស្រាវជ្រាវ និងហិរញ្ញប្បទានព្រៃឈើប្រកបដោយនិរន្តរភាព។ ការប្តេជ្ញាចិត្តនៃគោលនយោបាយជាតិបច្ចុប្បន្នក្រោមកម្មវិធីព្រៃឈើជាតិ រួមមានការបង្កើនគម្របព្រៃឈើរបស់ប្រទេសរហូតដល់ ៦០% ។ គោលបំណងសំខាន់មួយរបស់កម្មវិធីស្បៀងអាហារជាតិគឺដើម្បីគាំទ្រដល់ការបង្កើតព្រៃសហគមន៍តាមរយៈការបែងចែកដីព្រៃដែលបានកើនឡើងដល់សហគមន៍ជនបទ។ នៅក្រោមច្បាប់ព្រៃឈើសិទ្ធិរបស់សហគមន៍មូលដ្ឋាន និងសារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិត្រូវបានទទួលស្គាល់។ ចក្ខុវិស័យប្រព័ន្ធអេកូឡូស៊ីសេដ្ឋកិច្ចសង្គមវប្បធម៌និងបរិស្ថានការគ្រប់គ្រងនិងការអភិវឌ្ឍព្រៃឈើសម្រាប់សុខុមាលភាពសាធារណៈ។ មានគោលបំណងជាយុទ្ធសាស្ត្រចំនួន ៩៖ (i) បង្កើនការចូលរួមចំណែកព្រៃឈើប្រកបដោយចីរភាព ដល់ការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ (ii) សម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុនិងកាត់បន្ថយផលប៉ះពាល់របស់វាលើជីវភាពរស់នៅរបស់ព្រៃឈើ (iii) ផែនការប្រើប្រាស់ដីធ្លីម៉ាក្រូ សម្រាប់ការធ្វើផែនការរួមនៅគ្រប់វិស័យយុត្តាធិការនិងព្រំដែនរដ្ឋាភិបាលតែមួយ (iv) អភិបាលកិច្ចព្រៃឈើច្បាប់និងការអនុវត្តច្បាប់នៅគ្រប់កម្រិតទាំងអស់ (v) បង្កើតប្រព័ន្ធគ្រប់គ្រងជម្លោះ (vi) បង្កើនការយល់ដឹងសមត្ថភាពនៃស្ថាប័ននិងគុណភាពនៃការអប់រំដើម្បីធ្វើឱ្យមាននិរន្តរភាព អនុវត្តកម្មវិធីព្រៃឈើ

ជាតិ (vii) ធានាការការពារបរិស្ថាននិងការអភិរក្សធនធានព្រៃឈើ (viii) អនុវត្តគំរូគ្រប់គ្រងប្រកបដោយនិរន្តរភាពទំនើបសម្របខ្លួនទៅនឹងបរិបទផ្លាស់ប្តូរ (ix) អភិវឌ្ឍប្រព័ន្ធហិរញ្ញប្បទានប្រកបដោយនិរន្តរភាព។

- **អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ** អនុក្រឹត្យនេះមានគោលបំណងកំណត់វិធានកាសម្រាប់ការបង្កើត ការគ្រប់គ្រងនិងការប្រើប្រាស់ព្រៃសហគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃអនុក្រឹត្យនេះរួមមានៈ (i) អនុវត្តច្បាប់ស្តីពីព្រៃឈើនិងច្បាប់ដទៃទៀតទាក់ទងនឹងការគ្រប់គ្រងសហគមន៍មូលដ្ឋាននៃធនធានព្រៃឈើ (ii) ដើម្បីកំណត់សិទ្ធិតួនាទីនិងភារកិច្ចរបស់អាជ្ញាធរទទួលខុសត្រូវព្រៃឈើរដ្ឋបាលសហគមន៍សហគមន៍និងអ្នកពាក់ព័ន្ធដទៃទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍ព្រៃឈើ (iii) បង្កើតនីតិវិធីដើម្បីឱ្យសហគមន៍អាចគ្រប់គ្រងប្រើប្រាស់និងទទួលបានអត្ថប្រយោជន៍ពីធនធានព្រៃឈើថែរក្សាវប្បធម៌ប្រពៃណីនិងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ (iv) ដើម្បីធានាសិទ្ធិអ្នកប្រើសម្រាប់សហគមន៍ សហគមន៍ព្រៃឈើ ក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ជួយគាំទ្រដល់គោលនយោបាយកាត់បន្ថយភាពក្រីក្រនិងវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា (vi) ដើម្បីផ្តល់នូវមធ្យោបាយដ៏មានប្រសិទ្ធិភាពសម្រាប់សហគមន៍ សហគមន៍ព្រៃឈើ ចូលរួមក្នុងការដាំដើមឈើស្តារ និងអភិរក្សធនធានធម្មជាតិព្រៃឈើនិងសត្វព្រៃ (vii) ដើម្បីឱ្យប្រជាពលរដ្ឋអាចយល់បានច្បាស់ និងយល់ដឹងពីពីអត្ថប្រយោជន៍និងសារៈសំខាន់នៃធនធានព្រៃឈើតាមរយៈការចូលរួមដោយផ្ទាល់ក្នុងការគ្រប់គ្រងនិងការពារធនធានព្រៃឈើ (viii) ដើម្បីផ្តល់ក្របខ័ណ្ឌច្បាប់ដើម្បីជួយដល់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅតំបន់ជនបទក្នុងការបង្កើតសហគមន៍ព្រៃឈើ។ នៅក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះបានលើកឡើងថាព្រៃសហគមន៍គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ (RGC, ២០០៣) ។ រដ្ឋបាលព្រៃឈើមានសិទ្ធិផ្តល់ការទទួលស្គាល់ជាផ្លូវការអំពីការបោះបង្គោលព្រំប្រទល់សហគមន៍ព្រៃឈើនីមួយៗ។ អំណាចក្នុងការដឹកនាំនិងគ្រប់គ្រងសហគមន៍ព្រៃឈើ ទទួលបានតាមរយៈការបោះឆ្នោតជ្រើសរើសសមាជិកសហគមន៍។ សហគមន៍សហគមន៍ ព្រៃឈើ អាចត្រូវបានផ្តួចផ្តើមនិងបង្កើតឡើងដោយសហគមន៍មូលដ្ឋានឬរដ្ឋបាលព្រៃឈើ។ ដើម្បីបង្កើតសហគមន៍ សហគមន៍ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលព្រៃឈើ។ រដ្ឋបាលព្រៃឈើមូលដ្ឋានត្រូវវាយតម្លៃនិងវិភាគលើតម្រូវការនិងបញ្ហាដែលសហគមន៍មូលដ្ឋានបានស្នើសុំដែលបានស្នើសុំបង្កើតសហគមន៍ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានឬក្រុមប្រឹក្សាឃុំសង្កាត់។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ

រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីទាំងអស់ និងរដ្ឋលេខាធិការក្រសួង និង ស្ថាប័នពាក់ពន្ធ និងអភិបាលនៃរដ្ឋបាលខេត្តត្រូវទទួលខុសត្រូវក្នុងការអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួន។

# បណ្ណាល័យសាស្ត្រ


Bampton, J., & Cammaert, B. (2006). *How can timber rents better contribute to poverty reduction through community forestry in the Terai region of Nepal.* Paper presented at the International Conference on: Managing Forests for Poverty Reduction: Capturing opportunities in forest harvesting and wood processing. 3rd-6th October.

Bhandari, P. K., Bhusal, P., Paudel, G., Upadhyaya, C. P., & Khanal Chhetri, B. B. (2019). Importance of community forestry funds for rural development in Nepal. *Resources, 8*(2), 85.

Bock, M. J. (2012). Formalization and community forestry in Jambi, Indonesia: indigenous rights, rural migrants, and the informal divide.

Dhakal, M., & Masuda, M. (2009). Local pricing system of forest products and its relations to equitable benefit sharing and livelihood improvement in the lowland community forestry program in Nepal. *Forest Policy and Economics, 11*(4), 221-229.

FA. (2006). NATIONAL COMMUNITY FORESTRY PROGRAMME. *Forest Administration, Cambodia*.

FA. (2008). Country Paper on Forest Outlook 2020. *Forest Administration, Cambodia*.

FA. (2013). Community Forestry Statistic in 2013. *Forest Administration, Cambodia*.

FAO. (2006). Forty years of community-based forestry: A review of its extent and effectiveness. *Food and Agriculture Organzation*.

FAO. (2009). Sub-decree No.83 on Registration of Land of Indigenous Communities 2009. *Food and Agriculture Organzation*.

FAO. (2015). How agroforestry can provide multiple solutions to environmental problems. *Food and Agriculture Organzation*.

FAOSTAT. (2020). Estimation of Forestry Area in Cambodia. Retrieved from http://www.fao.org/faostat/en/#data/GF

Ghimire, P., & Lamichhane, U. (2020). Community Based Forest Management in Nepal: Current Status, Successes and Challenges. *Grassroots Journal of Natural Resources, 3*(2), 16-29.

IPCC. (2019). Special Report on Climate Change, Desertification, Land Degradation, Sustainable Land Management, Food Security, and Greenhouse gas fluxes in Terrestrial Ecosystems. *Intergovernmental Panel on Climate Chang.*

McKenney, B., Chea, Y., Tola, P., & Evans, T. (2004). *Focusing on Cambodia's high value forests: livelihoods and management*: Cambodia Development Resource Institute.

Miyawaki. (2020). The Miyawaki Method: Data & Concept.

Nhem, S., Jin Lee, Y., & Phin, S. (2018). The impact of forest resource decline: Analyzing forest-related income supplements to reduce income inequality and poverty of the Kouy indigenous people living in Kampong Thom province, Cambodia. *Journal of Sustainable Forestry, 37*(2), 97-119.

ODC. (1993). Royal decree on Establishment of Natural Protected Areas in 1993.

Paudel, G. (2014). Analysis of equity, poverty and sustainability aspects of community forests of Nepal. *VIKAS (A Journal of Development), 36*(1), 89-96.

RGC. (1996). Law on Environmental Protection and Management of Natural Resources. *Royal Government of Cambodia*.

RGC. (2002a). *Forestry Law in Cambodia*. Retrieved from Royal Government of Cambodia: https://forestlegality.org/risk-tool/country/cambodia

RGC. (2002b). Law on Forestry. *Kingdom of Cambodia*.

RGC. (2003). Sub-Decree on Community Forestry Management *Royal Government of Cambodia*.

RGC. (2006). *Law on Fisheries*. Retrieved from Royal Government of Cambodia: https://data.opendevelopmentmekong.net/laws_record/law-on-fishery

RGC. (2008a). Law on Nature Protection. *Royal Government of Cambodia*.

RGC. (2008b). *Protected Area Law*. Retrieved from Royal Government of Cambodia: http://www.cambodiainvestment.gov.kh/law-on-nature-protection-area-protected-areas-law_080104_080104.html

RGC. (2014a). Cambodia Climate Change Strategic Plan 2014-2023 *Royal Government of Cambodia*.

RGC. (2014b). Rectangular Strategy and National Strategic Development Plan 2014-2018. *Royal Government of Cambodia*.

RGC. (2015). National Environment Strategy and Action Plan and Environmental Code. *Royal Government of Cambodia*.

RGC. (2021). Second Forest Reference Level for Cambodia under the UNFCCC Framework. *Royal Government of Cambodia*.

Safa, M. S., Ibrahim, Z., & Abdu, A. (2004). Potentialities of new line planting technique of Enrichment planting in Peninsular Malaysia: A review of resource sustainability and economic feasibility.

Sunderlin, W. D. (2006). Poverty alleviation through community forestry in Cambodia, Laos, and Vietnam: An assessment of the potential. *Forest Policy and Economics, 8*(4), 386-396.

Un, K., & So, S. (2009). Politics of natural resource use in Cambodia. *Asian Affairs: An American Review, 36*(3), 123-138.

UNDP. (2011). Climate Change and Forestry. *Human Development Report*.
WOCAN. (2019). Mainstreaming Gender into Cambodia's REDD+ Action and Investment Plan.